ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣០ លេខ ១ ខែមករា

ព.ស. ២៥០០ គ.ស. ១៩៥៨

– ភ្នំពេញ –

P K. 1
958 . 1

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំនឿងខាងសាសនា និងអក្សរសាស្ត្រ
ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា ទំព័រ

- សត្តិសមាសកថា របសព្រះឧបាលិវង្ស សុរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក . . . . ១
- ជាវេរកកថា លោកគុយ-សុគ្រ រៀបរៀង . . . . . . . . . ៩
- គបបញ្ចកកម្មដ្ឋាន ពាក្យកាព្យ លោកស៊ុខ-ហ៊ាន រៀបរៀង . . . . . . . ១៥
 សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់ (តមក) លោកភ៉ាយ-ប៊ុក រៀបរៀង . ១៧
- និទានសុភាសិត ព្រះមហាម៉ៅ-ខាន់ រៀបរៀង . . . . . . . . . . . ២៥

ផ្នែកអក្សរសាស្ត្រ

- រឿងព្រេង រឿងក្ងានទឹងកំពីស លោក លាង-ហាប់-អាន រៀបរៀង . . . . ៣៣
- រឿងអ្នកគង្វាលចៀមសួតត្រង់នឹងព្រះរាជធីតា (តមក) លោកផេង-ជ្រីវ រៀបរៀង . ៤៤
- រឿងទេវន្តរបស់អម្រឹតក្សត្រីម៉ុក (តមក) លោកញ៉ក-ថែម ពិនិត្យ . . . . . ៤៩
- រឿងសាមកុក (តមក) . . . . . . ឧកញ៉ាឌូ-កន ប្រែ . . . . . . ៥៧
- រឿងចៅជាយក្ដាំង (តមក) លោកទៀង-តៃ-ឈុន ប្រែរៀបរៀង . . . . . ៦៥
- រឿងព្រេងនឹងរឿងបូរាណនៃប្រទេសជប៉ុន លោក ភ៉ាយ-ប៊ុក ប្រែរៀបរៀង . . . ៧៣

ផ្នែកកំណត់ទីនប្រវត្តិការណ៍

- មហាសន្និបាតលើកទី ៦ នៃពុទ្ធិកសមាគមកម្ពុជរដ្ឋ លោកសម-ញាណ រៀបរៀង . ៨១
- ដំណើរទស្សនាការសហរដ្ឋអាមេរិកនៃព្រះពោធិវង្ស (តមក) លោកជា-ទន់ រៀបរៀង ៨៣
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហាបាង-ខាត់ រៀបរៀង . . . . . ៨៦

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជាវ ២៣០៛០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## TABLE DES MATIERES

*PARTIE RELIGIEUSE :*

-Sabbhisamasakatha par Vén. *SO HAY* . . . . . . . . 1
-Paverakakatha par *M. KUY-SAUT* . . . . . . . . . . . 9
-Tacapancakakammatthan en vers par *M. SIN-HEAN* . 15
-Réflexion d'un bouddhiste (suite) par *M. RAY-BUC* . . . 17
-Nidanasubhasita (suite) par Vén. *MAU-KHANN* . . . . 25

*PARTIE LITTERAIRE :*

-Légende d'un jars et des écrevisses
par *M. LEANG-HAP-AN* . . . . . . . . . . . . . 33
-Le Berger fidèle de la princesse (suite)
par *M. PHENG-CHRIV* . . . . . . . . . . . . . 44
-Histoire de Devanda de *M. MOK* (suite) revue
et corrigée par *M. NHOK-THEM* . . . . . . . 49
-Histoire de Samkok (suite) traduit par *M. NOU-KAN* . . 57
-Légende de « Sieur Croûte de riz » (suite) traduit
par *M. TIANG-TAY-CHHUN* . . . . . . . . . . 65
-Conte et légende du Japon traduit par *M. RAY-BUC* . 73

*NOTES ET CHRONIQUES :*

-Procés-verbal de la 6ème Assemblée Générale
de l'Association Mondiale des bouddhistes
Cambodge par *M. SAM-NHEAN* . . . . . . . . 81
-Voyage du Vén. Huot-Tat aux U.S.A (suite)
par *M. CHEA-TON* . . . . . . . . . . . . . . 93
-Dictionnaire Sanskrit-Khmèr (suite)
par Vén. *PANG-KHAT* . . . . . . . . . . . 96

Prix d'abonnement annuel (comprenant 12 numéros) : 230 r.00

## ផ្នែកសាសនា

### សព្ភិសមាសគាថា

របស់ព្រះឧបាលិវង្ស ស៊ូរ - ប៉ាយ៍ វត្តឧណ្ណាលោម ក្រុមជំនុំព្រះត្រៃបិដក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ ។

វេលានេះ អាត្មាភាព សូមសំដែងធម៌ចំពោះការរួមដោយពួកសប្បុរស តាមអត្ថន័យពុទ្ធភាសិត ដែលបាននាំទុកខាងដើមនេះ រួចសេចក្តីប្រែ ព្រមទាំងអធិប្បាយតាមលំអាននៃពុទ្ធដីកានិងអដ្ឋកថា សមគួរដល់ពេលវេលានៃក្រសួងឃោសនាការជាតិ ដែលលោកអគ្គលេខាធិការនៃពុទ្ធសា-សនបណ្ឌិត្យ តម្រូវនិមន្តឲ្យសំដែងក្នុងថ្ងៃឧបោសថសីលនេះ ដើម្បីផ្សាយឧត្តមប្រយោជន៍នៃព្រះពុទ្ធសាសនា ដែលមានក្នុងព្រះត្រៃបិដក តាមវិទ្យុឃោសនសព្ទប្រទេសកម្ពុជា ដូចតទៅនេះ ៖

## សេចក្ដីប្រែនៃពុទ្ធភាសិតខាងដើមនេះថា

បុគ្គលគប្បីប្រប្រួម ដោយពួកសប្បុរស

បុគ្គលគប្បីធ្វើនូវសេចក្ដីស្និទ្ធស្នាល ដោយពួកសប្បុរស

បុគ្គលដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែនរួចចាកទុក្ខទាំងពួង ។

## ពុទ្ធភាសិតនេះបែកជាអត្ថបទ ៣ យ៉ាង៖

១- សព្ភិរេវ សមាសេថ បុគ្គលគប្បីប្រប្រួមដោយពួកសប្បុរស

២- សព្ភិ កុព្វេថ សន្ថវំ បុគ្គលគប្បីធ្វើនូវសេចក្ដីស្និទ្ធស្នាលដោយពួកសប្បុរស

៣- សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ បុគ្គលដឹងច្បាស់នូវព្រះសទ្ធម្ម របស់ពួកសប្បុរស រមែនរួចចាកទុក្ខទាំងពួង ។

## អធិប្បាយពង្រីកសេចក្ដី

១- សព្ភិរេវ សមាសេថ គប្បីប្រប្រួមដោយពួកសប្បុរស ។

ពាក្យថា "គប្បីប្រប្រួម" បានដល់ការសេពគប់រាប់រកគ្នា ដែលបុគ្គលគួរធ្វើដោយកុសលោបាយ ដើម្បីមិត្តភាពរវាងគ្នានឹងគ្នា ជាបគ្គសម្ពន្ធតទៅ ។

ពាក្យថា " សប្បុរស ក្នុងអត្ថបទនេះ " សំដៅយកមនុស្សល្អ ដោយការប្រព្រឹត្តកាយវាចាចិត្តជាសុចរិត ដែលមិនមានចលនាក្នុងផ្លូវទុច្ចរិត, មួយទៀត បព្វជិតឬគ្រហស្ថ អ្នកមានកាយវាចាចិត្តស្ងប់ប្រាសចាកអំពើអាក្រក់មានការសម្លាប់សត្វជាដើម ហៅថា " អ្នកសប្បុរស " ។ លោកពួកសប្បុរសនេះ បើសំដៅយកបុគ្គលដែលមានឋានៈខ្ពស់ ដូចយ៉ាងព្រះអរិយៈទាំងឡាយមានព្រះសម្ពុទ្ធជាដើម ។ មួយវិញទៀត បុគ្គលណាទោះជាបព្វជិតក្តី គ្រហស្ថក្តី មិនរើសពួកគណៈទេ កាលបើប្រកបដោយសប្បុរសធម៌ ៧ ប្រការ បុគ្គលនោះ ព្រះសម្មាសម្ពុទ្ធត្រាស់ហៅថា " សប្បុរសដោយបរិបូណ៌ " ។ សប្បុរិសធម៌ ៧ ប្រការ មានសទ្ធាជាដើម ទុកជាជាសញ្ញាបត្រ ដើម្បីបញ្ជាក់ឲ្យឃើញថា ធម៌សម្រាប់ញ៉ាំងមនុស្សគ្រប់ជាន់ ឲ្យឡើងឋានៈជា ជាមនុស្សសប្បុរស ។

## សប្បុរិសធម៌ ៧ ប្រការគឺ

១) សទ្ធា ជំនឿមានហេតុផល ,

២) ហិរិ សេចក្តីអៀនខ្មាសអំពើទុច្ចរិត,

៣) ឱត្តប្ប សេចក្តីខ្លាចចំពោះអំពើទុច្ចរិត ,

៤) ពាហុសច្ចៈ ការសិក្សារៀនសូត្រច្រើន,

៥) វីរិយៈ សេចក្តីប្រឹងប្រែង,

៦) សតិ សេចក្តីនឹករលឹក ដឹងខ្លួន,

៧) បញ្ញា ការចេះដឹងយល់ច្បាស់លាស់ ។

សប្បុរិសធម៌ទាំង ៧ យ៉ាងនេះកាលបើមានទៅក្នុងបុគ្គលណា រមែងញ៉ាំងបុគ្គលនោះ ឲ្យដល់ឋានៈជាសប្បុរស គឺឲ្យមានគុណសម្បត្តិ មានសីលធម៌រៀបរយល្អជាដើម ។ សប្បុរិសធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថាជាឧត្តម-គតិរបស់សប្បុរស ឬ ថាជាធម៌សម្រាប់បណ្តុះបណ្តាល មនុស្សធម្មតាឲ្យបានទទួលនាម ថាជាមនុស្សសប្បុរស, បើមិនមានសប្បុរិសធម៌ ៧ យ៉ាងនេះទេ ក៏ត្រូវទទួលនាមផ្ទុយពីនេះវិញដែរ ។ ឯមនុស្សជាសប្បុ-រស ទោះនឹងទៅកាន់ទីណា ពិគ្រោះកិច្ចការនឹងអ្នកណាមួយ ក៏មិនបៀតបៀន មិនញុះញង់អ្នកនោះឲ្យឈ្លោះទាស់ទែងបែកសាមគ្គីគ្នាទីនោះឡើយ ទោះបើនឹងគិតការអ្វី និយាយការអ្វី ធ្វើការអ្វី ក៏ពុំមែនគិត ពុំមែននិយាយ ពុំមែនធ្វើ ដើម្បីបៀតបៀនដល់បុគ្គលណាមួយទេ ។ បុគ្គលអ្នកមានសន្តានចិត្តប្រព្រឹត្តល្អប្រាកដដូច្នេះ ទើបព្រះសម្ពុទ្ធត្រាស់ហៅថា " មនុស្សសប្បុរស" ព្រោះថា បុគ្គលនោះ ជាសម្មាទិដ្ឋិ តែងឃើញច្បាស់ថា " អំពើល្អក្តី អំពើអាក្រក់ក្តី ដែលគេធ្វើហើយ អំពើនោះនឹងឲ្យផលល្អ ឬ ផលអាក្រក់ដល់បុគ្គលអ្នកធ្វើនោះវិញជាប្រាកដ " ។

លោក គឺក្រុមមនុស្សសត្វទាំងអស់ ដែលកើតមក ហើយរស់នៅជា

ពួក ៗ គឺតាំងអំពីគ្រួសារមួយ ត្រកូលមួយ ស្រុកមួយ ប្រទេសមួយ ត្រូវតែមានការទាក់ទងគ្នាទៅវិញទៅមកតាមសមគួរ ទើបប្រព្រឹត្តទៅដោយសុខស្រួលយូរអង្វែងបាន ។ ការប្រាស្រ័យទាក់ទងសេពគប់រាប់រកគ្នានេះ ទុកជាបញ្ហាមួយរបស់មនុស្ស គឺការសេពគប់ជាមួយគ្នា ប៉ុន្តែមនុស្សទាំងអស់ សុទ្ធតែមានអាកប្បកិរិយាផ្សេងៗគ្នា មានអធ្យាស្រ័យ គំនិតគំនិតផ្សេងៗគ្នា មានកិរិយាប្រព្រឹត្តក៏ផ្ទុយគ្នាខ្លះ ស្របគ្នាខ្លះ ដែលគួរចំណាំបាន ព្រោះហេតុនោះ បុគ្គលត្រូវជ្រើសរើសមនុស្ស ដែលខ្លួនគួរសេពគប់ជាមុន ដោយការពិនិត្យមើល ឲ្យឃើញថា មនុស្សនេះជាកល្យាណជន គួរសេពគប់យកជាមិត្តសំឡាញ់. មនុស្សនុ៎ះជាបាបជន កុំគួរសេពគប់ មិនមែនចេះតែសេពគប់ ចំពោះមនុស្សទាំងអស់ ដោយមិនបានពិនិត្យជ្រើសរើសនោះឡើយ ពីព្រោះ មនុស្សទាំងអស់ សុទ្ធតែមានលក្ខណៈ ដែលអាចសំគាល់ អាចទាយបានថាជាមនុស្សសប្បុរស ជាមនុស្សអសប្បុរស ឬជាបណ្ឌិត ក៏មាន ជាពាលក៏មាន ។ ករណីនេះ ការសេពគប់រាប់អានចំពោះមនុស្ស ឈ្មោះថាជាការចាំបាច់មួយ របស់វិញ្ញូជន ដែលត្រូវតែគិតមុនជាដំបូង ដោយហេតុថា ការសេពគប់នេះ ជាមូលដ្ឋានមួយដែលនាំឲ្យមានសេចក្ដីចំរើនក៏បាន នាំឲ្យមានសេចក្ដីវិនាសក៏បាន គឺថា បើសេពគប់ត្រូវ នាំឲ្យមានសេចក្ដីសុខ-ចំរើន. សេពគប់ខុស នាំឲ្យមានសេចក្ដីវិនាស ឬសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ជាប្រាកដ ។

ពិតណាស់ ការសេពគប់បណ្ឌិត នាំមកនូវសេចក្ដីសុខ ការសេពគប់ជនពាល នាំមកនូវសេចក្ដីទុក្ខ ។ ការសេពគប់សប្បុរស រមែងញ៉ាំងប្រយោជន៍ ឲ្យសម្រេច, ការសេពគប់អសប្បុរស រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស ទាំងឥធលោកនិងបរលោក ដោយពិត ដ្បិតថា ការសេពគប់សប្បុរស អាចគ្រប់គ្រងរក្សានូវអ្នកសេពគប់នោះបាន, ការសេពគប់អសប្បុរស មិនអាចគ្រប់គ្រងរក្សានូវអ្នកសេពគប់នោះបានឡើយ សមដូចភាសិតរបស់នន្ទព្រាហ្មណ៍ សំដែងចំពោះស្ដេចព្រះនាម សុតសោម ដែលមានក្នុងសុតសោមជាតក ថា

សកិទេវ សុតសោម សព្ភិ ហោតិ សមាគមោ
សា នំ សង្គតិ បាលេតិ នាសព្ភិ ពហុសង្គមោ ។

ប្រែថា " បពិត្រព្រះអង្គ ព្រះនាមសុតសោម សមាគម គឺការប្រជុំរួមគ្នាដោយពួកសប្បុរស មានតែមួយកាលប៉ុណ្ណោះ ការប្រជុំរួមគ្នានោះរមែងរក្សានូវបុគ្គលនោះបាន សង្គម គឺការទាក់ទងគ្នា ជាច្រើនដង ដោយពួកអសប្បុរស មិនអាចរក្សានូវបុគ្គលបានឡើយ " ។ គាថាភាសិតនន្ទព្រាហ្មណ៍នេះ បញ្ជាក់សេចក្ដីឲ្យឃើញថា "ការប្រជុំរួម ឬ ទាក់ទងគ្នាដោយពួកសប្បុរស ជាបច្ច័យនាំឲ្យកើតមធ្យោបាយ សម្រាប់គាំពារខ្លួនឲ្យបានចំរើន, ប្រជុំរួមទាក់ទងដោយពួកអសប្បុរស ជាបច្ច័យ នាំឲ្យវិនាស"។

សេវនធម៌ (ការសេពគប់រាប់រកគ្នា) នេះ ឈ្មោះថាជាមូលដ្ឋានមួយ នៃសុភមង្គលក៏មាន នៃអពមង្គលក៏មាន ។ អាស្រ័យដំណើរការណ៍ ដូចអធិប្បាយមកនេះហើយ បានជាព្រះសម្មាសម្ពុទ្ធ សំដែងត្រង់អត្ថបទទីមួយថា "បុគ្គលគប្បីរួបរួមសេពគប់ ដោយពួកមនុស្សសប្បុរស" ។

តាំងពីកាលណាមក បុគ្គលជាសប្បុរសតែងញ៉ាំងជនដែលមកសេពគប់ ឲ្យបានសម្រេចផលល្អ គឺឲ្យមានស្មារតីដឹងខ្លួនយល់ត្រូវទាំងផ្លូវលោក ផ្លូវធម៌ ជាដរាប ព្រោះហេតុនៃការសេពគប់សប្បុរសនោះ ជាបច្ច័យនាំឲ្យបានស្ដាប់ពាក្យប្រៀនប្រដៅ នាំឲ្យបានចម្លងតម្រាប់ ប្ដូរយោបល់របស់មនុស្សសប្បុរស ។ ដំណើរនេះបុគ្គលគប្បីពិចារណារឿយ ៗ ឲ្យឃើញថា "ការសេពគប់នេះ ជាគុណក៏មាន ជាទោសក៏មាន ឬថា ជាបុណ្យក៏មាន ជាបាបក៏មាន, បើសេពគប់កល្យាណមិត្ត រមែងទៅជាគុណ ជាបុណ្យ, បើសេពគប់ខុស គឺសេពគប់បាបមិត្ត រមែងទៅជាទោស ជាបាប ឃើញជាក់ច្បាស់ក្នុងលោកនេះ និងលោកខាងមុខ" ។ ក្នុងករណីនេះ ទើបបណ្ឌិតអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម តែងសំដែងដាស់តឿនរឿយ ៗ អំពីការសេពគប់ ត្រូវតែពិនិត្យពិច័យ បុគ្គលជាមុន សឹមធ្វើនូវការរួបរួមស្និទ្ធស្នាលជាលំដាប់ទៅ ដូចសេចក្ដីក្នុងអត្ថបទ នៃពុទ្ធភាសិតទី ២ តទៅនេះ

២ សត្ថា គារវតា សង្ឃ បុគ្គលគប្បីធ្វើសេចក្ដីស្និទ្ធស្នាល ដោយពួកសប្បុរស ។

ពាក្យថា "គប្បីធ្វើសេចក្ដីស្និទ្ធស្នាល" សំដៅយកការសិក្សារៀនហាត់ផ្ចិតផ្ចង់, ការចម្លងយកតម្រាប់, ការប្រឹងប្រែងប្រព្រឹត្តតាម ចំពោះធម៌ ឬ ចំពោះច្បាប់, ការប្រណិបត្តន៍គោរពកោតក្រែង, ការទទួលទុកចិត្ត ការធ្វើសក្ការបូជា ចំពោះបុគ្គលដែលគួរគោរពបូជា ទាំងនេះហៅថា "ធ្វើនូវសេចក្ដីស្និទ្ធស្នាល" ។

ពាក្យថា "ស្និទ្ធស្នាល" នេះ មកអំពីបាលីថា "សន្ថវៈ" ប្រែថាសេចក្ដីស្និទ្ធស្នាល, សេចក្ដីសរសើរ, សេចក្ដីស្រឡាញ់, ការចាប់ចិត្ត ។

## សន្ថវៈនេះមានពីរយ៉ាង:

១) ធម្មសន្ថវៈ សេចក្ដីស្និទ្ធស្នាលចំពោះធម៌,

២) បុគ្គលសន្ថវៈ សេចក្ដីស្និទ្ធស្នាលចំពោះបុគ្គល ។

## មួយទៀត សន្ថវៈមានពាយ៉ាង

១) លោកសន្ថវៈ សេចក្ដីស្និទ្ធស្នាលចំពោះលោក,

២) មិត្តសន្ថវៈ សេចក្ដីស្និទ្ធស្នាលចំពោះមិត្រ,

(មានត)

ធាវេរភាកថា

លោក គុយ-ស៊ុត្រ រៀបរៀង

*ប្រគួតជាប់លេខ ២*

# ក្នុងពិធីបុណ្យ ព.ស. ២៥០០

## នមត្ថុ រតនត្តយស្ស

*សូមជំរាបអស់លោក-អ្នកជាពុទ្ធបរិស័ទថា*

*ចាប់ផ្ដើមតាំងពីកាល ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូ របស់យើង ត្រាស់ដឹងឡើងជាដំបូង ក្នុងលោកដរាបដល់បរិនិព្វាន ទ្រង់បានប្រទាន ពុទ្ធឱវាទ មានច្រើនជាអនេកប្បការ តម្រូវតាមមនុស្ស ឬទេវតា អាចបេះ ចាំចប់សព្វគ្រប់បាន ។ ព្រោះហេតុនោះ ក្នុងឱកាសនេះ ខ្ញុំបាទ សូមដកស្រង់ពុទ្ធឱវាទជាសារវន្ត តែត្រឹមគន្លឹះគាថាយ៉ាងសង្ខេប ដែលមានសេចក្ដីពិស្ដារ នៅក្នុងផ្ទៃនៃគម្ពីរធម្មបទដ្ឋកថា ខុទ្ទកនិកាយ យកមកថ្លែងជូនជាទីសណ្ដាប់ ចំពោះអស់លោក អ្នកពុទ្ធបរិស័ទទាំងឡាយ ឲ្យសមតាមកាលវេលា ក្នុងមហាសន្និបាតនេះថា:*

ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។

*អ្នកទាំងឡាយ ចូរដកខ្លួនចេញឲ្យផុតពីភក់ល្បាប់ចុះ.*

ដូចជាដីរដាប់កក់ ហើយវេទ្ធនរូបដូច្នោះឯង ។

សូមអធិប្បាយពង្រីកសេចក្តី នៃពុទ្ធភាសិតក្នុងបាទទី១នេះជាមុនៗ ពាក្យថា "ខ្លួន" ក្នុងទីនេះ បានដល់ចិត្ត ឬ នាមរូបសំដៅយកអត្តភាពទាំងមូល របស់សត្វលោក ។ ពាក្យថា ភក់លល្បាប់ បានដល់ពួកធម៌ជាគ្រឿងនាំចិត្តឲ្យសៅហ្មង ឲ្យកករល្អក់ ឲ្យអាក្រក់ ឲ្យដាប់ស្អិត ឲ្យមិនស្អាត គឺពួកកិលេសមានរាគៈជាដើម ឬ ឧបក្កិលេសណាមួយៗ កិលេសធម៌ទាំងអម្បាលនេះ លោកចាត់ទុកថាជាអន្លង់ភក់ អន្លង់ជ្រាំ ប្រចាំនៅនិត្យ ក្នុងវាលវដ្តសង្សារ ជាសភាវៈដែលសត្វលោកឆ្លងកាត់ទៅកាន់ទីគោក គឺព្រះនិព្វានបានដោយកម្រពន់ពេក, ព្រោះជាទីញាំងពួកសត្វឲ្យដាប់ ឲ្យលង់លិចចុះក្នុងអំណាចខ្លួន ព្រមទាំងឲ្យរងទុក្ខ សោកខ្សឹកខ្សួល ក្តៅក្រហាយ រៀងរាល់ជាតិ មិនមានទីបំផុត ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ឃើញថា សត្វលោកទាំងអស់ ដែលទទួលរងសេចក្តីទុក្ខ-លំបាកគ្រប់បែបគ្រប់យ៉ាង ក៏ព្រោះតែផុងខ្លួនជាប់នៅក្នុងភក់ គឺកិលេសនេះឯង ជាមូលហេតុ ទើបទ្រង់ត្រាស់ដាស់តឿនក្រើនរំលឹកពុទ្ធបរិស័ទ ឲ្យខំប្រឹងប្រែងរើខ្លួនចេញ ឲ្យផុតអំពីគ្រឿងសៅហ្មងទាំងអម្បាលនេះ ដោយព្រះទ័យប្រកបដោយមេត្តា ករុណាដ៏ធំទូលាយ ប្រៀបដូចមាតាបិតា កាលៈឃើញបុត្ររបស់ខ្លួនដួលដេកនៅក្នុងរណ្តៅភក់ជ្រាំ តែងស្រែកប្រាប់កូនឲ្យប្រឹង ស្ទុះក្រោកឡើងដូច្នោះដែរ ។

ក្នុងបាទទី ២ ពាក្យថា "ដូចជាដំរីជាប់ភក់ ហើយរើខ្លួនរួចដូច្នោះ" សេចក្ដីថា ដំរីជាសត្វចតុប្បាទ មានទំហំខ្លួនធំជាងពួកសត្វចតុប្បាទ ទាំងអស់ ៗ សត្វនេះ កាលបើផុងខ្លួនជាប់ភក់ ក្នុងទីណាមួយហើយ ពុំព្រមនៅស្ងៀមទេ ក៏តែងខំប្រឹងបម្រះនទៀត រើខ្លួនរបស់វាយ៉ាងពេញទំហឹង ដោយកំឡាំងដៃផង ជើងមុខនិងជើងក្រោយផង លុះត្រាតែដកខ្លួនចេញផុត អំពីភក់នោះបាន ៗ ដើម្បីបញ្ជាក់គោលពុទ្ធ-ភាសិតនេះ ខ្ញុំបាទសូមនាំយកវត្ថុនិទានមួយ អំពីសត្វដំរីជាប់ភក់ មកជាឧទាហរណ៍ ៗ

សេចក្ដីដំណាលថា: កាលជំនាន់ពុទ្ធសម័យ ក្នុងក្រុងសាវត្ថី មានដំរីមង្គលមួយឈ្មោះបាវេរកៈ ជាព្រះរាជទ្រព្យដ៏ប្រសើររបស់ព្រះចៅបសេនទិកោសល ៗ កាលដំរីនេះ កំពុងពេញកំឡាំងនៅឡើយ ជាសត្វក្លៀវក្លាអង់អាច ធ្លាប់ចុះស្នាមក្នុងសឹកសង្គ្រាមយ៉ាងថ្លុក. លុះដល់ចាស់ជរាថមថយកំឡាំងប្រើការពុំកើត គេក៏ពុំសូវអើពើនឹងថែទាំប៉ុន្មានឡើយ ៗ

ថ្ងៃមួយ. បាវេរកហត្ថីបានចុះទៅក្នុងស្រះបោក្ខរណី ដើម្បីស្វែងរកចំណីអាហារគឺស្មៅនិងទឹក ក៏លង់ខ្លួនផុងក្នុងភក់ជាប់នៅក្នុងកណ្ដាលស្រះនោះ ៗ ព្រោះរឿងចំឡែកក្លែកយ៉ាងនេះ ពួកមហាជនក៏ឆោឡោនាំគ្នាមកមើលដេរដាស ឈរមើលដោយមានចិត្តអាណិតអាសូរសត្វនោះ

ពន់ពេក ៗ ដំណឹងនេះ ឮជ្រួតជ្រាបដល់ព្រះពជាក្រុងសាវត្ថី ទ្រង់ក៏ត្រាស់បញ្ជាមហាត្ថាមាត្យ (ហ្មដ័រ) ដែលមុនប្រុសបឲ្យចាត់ចែងការស្រេងដ័រនោះ ៗ

ឯមហាត្ថាមាត្យក៏ចាត់ចែងពិធីស្រេងដូចនេះគឺ

១.- តម្រូវមនុស្សម្នាក់ឲ្យកាន់ទង់ជ័យបំបាំង មានផ្ចាំងធំ ១ ដើរនាំមុខទ័ព ដើម្បីបង្ហាញឲ្យដ័រនោះឃើញច្បាស់,

២.- រៀបចំពលថ្មើរជើងជាជួរ ជាសង្កាត់ សុទ្ធសឹងប្រដាប់ដោយគ្រឿងអាវុធគ្រប់ដៃ តាមរបៀបក្បួនទ័ព.

៣.- វាយស្គរធំ គឺស្គរជ័យ ឬ ស្គរទ័ព ដើម្បីកំឡាចិត្តយោធពលឲ្យអាចហ៊ាន ក្នុងពេលចូលប្រយុទ្ធ ៗ

លុះរៀបចំចែងការស្រេចហើយ, ក៏យាត្រាទ័ពសំដៅទៅកាន់ទៀវស្រះបោក្ខរណីនោះ ដោយការសំដែងយុទ្ធវិធីយ៉ាងស្វាហាប់ ហាក់ដូចចូលទៅប្រយុទ្ធ នឹងកងទ័ពនៃពួកខ្មាំងណាមួយ ៗ

ក្នុណនោះ បាវេរកហត្ថីក្រឡេកឃើញទង់ជ័យបំបាំងផង ឃើញកងទ័ពកំពុងសន្ធឹញចូលមកផង ទាំងឮសន្ធឹកស្គរផ្ទួនៗ ដែលគួរស្ញែងផងកើតព្រឺកេមព្រឺស្បែក កំរើកសព្វសព្វាង្គកាយ ៗ

ដោយចិត្តមានះដែលធ្លាប់ចុះស្នាម ក្នុងសង្គ្រាម, ក៏ខំប្រឹងរង្កៀក

ខ្លួនដើរយ៉ាងទឹងទើងមុខជើងក្រោយព្រមៗគ្នា ត្រាតែរបូតចេញអំពីភក់នោះ ហើយទៅឈរនៅលើទីគោក ។ រឿងហេតុនេះ ត្រូវពួកភិក្ខុនាំមកក្រាបបង្គំទូលព្រះមានព្រះភាគៗ កាលបើបានវត្ថុជានិទស្សន៍គួរដល់ការសំដែងធម៌យ៉ាងនេះ ទ្រង់ក៏ព្រោសប្រទានពុទ្ធដីកា ដោយអនុលោមទៅតាមដំណើររឿងនោះថា "អ្នកទាំងឡាយ ប្តូរដកខ្លួនចេញឲ្យផុតពីភក់ល្បាប់ចុះ ដូចជាដំរីជាប់ភក់ ហើយរើខ្លួនរួចផុតទោះឯង" ។ ពុទ្ធភាសិតដ៏សំខាន់នេះ ចាត់ចូលក្នុងបញ្ញាខន្ធ ។

## គតិរឿង

១ - ដំរីជាប់ភក់ ប្រៀបដូចសាធុជន ជាប់ក្នុងភក់គឺកិលេស;

២ .- ដំរីក្រឡេកឃើញទង់ជ័យចំបាំង ប្រៀបដូចសាធុជនកំពុងសំឡឹងឃើញទង់ជ័យ នៃព្រះពុទ្ធសាសនា ដែលបក់រវិចក្នុងពិធីពុ ឃុនេះ;

៣ - ដំរីឮសូរពាំពង់ស្គរជ័យ ប្រៀបដូចសាធុជនដែលបានឮ បានស្តាប់សំឡេងស្គរគឺព្រះសទ្ធម្មទេសនា (សទ្ធម្មភេរី) ដែលមានពាល់ពត្រ ក្នុងពិធីបុណ្យនេះដែរ .

៤.- ដំរីខំប្រឹងរើខ្លួនឲ្យរួច ប្រៀបដូចសាធុជន ដែលប្រឹងប្រែងរើខ្លួន ដោយធ្វើបុញ្ញកិរិយាវត្ថុមានទានសីលជាដើម ក្នុងពិធីបុណ្យ ព.ស. ២៥០០ នេះ ។

## យោបល់

ឃើញថា ដំរីជាជាតិតិរច្ឆានសោះ តែអាចរើខ្លួនចេញពីភក់បាន ដោយការខំប្រឹងប្រែងទាំងដៃទាំងជើងយ៉ាងនេះ ៗ ឯយើងជាតិមនុស្ស កាលបើដឹងថា ខ្លួនជាប់នៅក្នុងភក់ជ្រាំ គឺកិលេសហើយ គួរតែខំតស៊ូព្យាយាម កំចាត់ពួកកិលេសមារ ឲ្យឃ្លាតចេញពាកខន្ធសន្តាន ដើម្បីដោះខ្លួនឲ្យផុតពីសេចក្តីទុក្ខ សោក ក្តៅក្រហាយគ្រប់ប្រការ ៗ

### អវសានគាថា

ដំរីជាជាតិសត្វតិរច្ឆាន អាចរើខ្លួនបានផុតភក់ជ្រាំ
ដោយក្តីព្យាយាមយ៉ាងមុតមាំ ទំពំរូបខ្លួនស្ទើរតែស្លាប់ ៗ
យើងជាតិជាមនុស្សទោះប្រុសស្រី កើតក្នុងលោកិយច្រើនគាំងគាប់
គួរប្រឹងព្យាយាមតាមលំដាប់ កុំឲ្យអន់អាប់ជាងដំរី ៗ

ជយោ ព្រះពុទ្ធសាសនា ២៥០០!

ជយោ. សន្តិភាព!

តចបញ្ចកកម្មដ្ឋាន

ពាក្យកាព្យ

# លោក ស៊ុន-ហ៊ាន រៀបរៀង

អនុលោម : កេសា លោមា នខា ទន្តា តចោ

បដិលោម : តចោ ទន្តា នខា លោមា កេសា ។

កេសា សក់, លោមា រោម, នខា ក្រចក, ទន្តា ធ្មេញ,

តចោ ស្បែក ។

បទព្រហ្មគីត កេសាសក់ទាំងឡាយ នៅលើកាយល្អគន់
សក់ប្អូនប៉ុកបន់ក្រន់ ស្អាតម៉ដ្ឋហ្នឹងគួរស្នេហា ។ សក់ជ្រុះឬកើតស្កូវ ទឹងក្រ
ញូវស្រដីថា សក់ក្បាលធ្លាក់ពីណា លើទឹកថ្លាបាយចំណី ។ ខ្ពើមស្អប់ឆ្អើម
កេសា ចាប់ប្រវះចោលទៅដី ជឿថាសក់អប្រិយ៍ ខូចចំណីរបស់អញ ។
សក់គ្រឿងអសុភហើយ អ្នកថ្លៃអើយគួរគិតគាញ់ រកធម៌ព្រះសាមញ្ញ
ជាសំឡាញ់ដល់និព្វាន ។ លោមារោមទាំងឡាយ ឲ្យនឿយណាយ-
ហើយរះជ្យាន ចំរើនបឋមជ្ឈាន ញាំងវិញ្ញាណឲ្យបរិសុទ្ធ ។ នខាក្រចក
តែងក្តិចបកសកហិតហុត ក្រចកបាក់ដាច់ផុត យកទៅដុតគ្មានមេត្រី ។
ទន្តាឯធ្មេញ សម្រាប់ញោញញ៉ាំចំណី កាលបាក់ធ្លាក់ដល់ដី -ចាប់គ្រញី
ចោលប្រញាប់ ។ តចោរីឯស្បែក បើរហែកស្អុយអួរគាប់ ខ្ទើមណាស់-

មិនចង់ចាប់ ផន្លៀបផ្ដាប់ពោលចេញឆ្ងាយ ។ ហេតុនេះសង្ឃត្រូវហស្ត កុំសោមនស្សនឹងរូបកាយ ជាគ្រឿងតែងអន្តរាយ គួរនឿយណាយរាល់-រូបា ។ គថបញ្ចក: កម្មដ្ឋាន:នេះឯងណា អ្នកប្រាជ្ញបានពោលថា ធ្វើកណ្ដាឲ្យឃ្លាតចេញ ។

បទពាក្យប្រាំពីរ

ហេតុនោះទើបព្រះឧបជ្ឈាយ៍ និងបញ្ជាដល់កុលបុត្រ
ឲ្យកម្មដ្ឋាននេះជាអាវុធ ខាងដើមបំផុតនៃការបួស ។
ដើម្បីទុកឲ្យអ្នកបួសថ្មី ឃ្លាតខ្ញុំការពាររក្សាផ្នួស
កុំឲ្យកាមច្ឆន្ទលុកលុយហួស ជ្រុលជ្រួសធ្វើឲ្យខូចភេទសង្ឃ ។
សត្រូវធំគឺកាមច្ឆន្ទ: ធ្វើសមណ:ឲ្យលះបង់
នូវភេទប្រណីតថ្លៃថ្កូង ឲ្យមកវិលវល់ក្នុងសង្សារ ។

ចតុរង្គ : ហៃអស់ប្រុសស្រីគួបធំ ចូរខំអភិរម្យ រៀនឲ្យបេះចាំ ៗ ព្រះកម្មដ្ឋានតាំងប្រាំ ប្រុងប្រឹងបរិកម្ម ចំរើនកុំដាច់ ។ នឹងបានផល-បុណ្យសម្រេច ដឹងអរិយសច្ច ទាំង៤ប្រការ ។ ឃើញយល់ក្នុង-កងសង្ខារ ផ្ដាលផ្ដាញ់ប្រហារ កិលេសសាំញ៉ាំ បុកបែនបញ្ជាន់ចំព្រាំ អស់បាបវៀរកម្ម ចូលនិព្វានហោង ។

ចប់-

សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់

លោក រ៉ាយ-ប៊ុក រៀបរៀង

(តមកពីលេខ ១២ ឆ្នាំ ១៩៥៧)

---

## ទុក្ខអរិយសច្ច,

## សមុទយអរិយសច្ច,

## និរោធអរិយសច្ច,

## មគ្គអរិយសច្ច,

ទុក្ខអរិយសច្ចគឺ ទុក្ខទាំង១៣កង, មានជាតិទុក្ខជាដើម, សមុទយអរិយ-សច្ច ហេតុដែលនាំឲ្យកើតទុក្ខគឺ កាមតណ្ហា, ភវតណ្ហា និង វិភវតណ្ហា, និរោធអរិយសច្ច គឺការរលត់បង់លះបង់ ប្ដូរបផុតអំពីតណ្ហា១០៨ដោយព្រះអរិយមគ្គ, មគ្គអរិយសច្ច គឺអដ្ឋង្គិកមគ្គ ផ្លូវប្រកបដោយអង្គប្រាំបីដែលនាំសត្វឲ្យទៅកាន់ស្ថានរលត់ទុក្ខ គឺព្រះនិព្វាន ។

ទុក្ខដែលមកពីតណ្ហាគឺ សេចក្ដីប្រាថ្នាតែងនាំសត្វឲ្យកើត ក្នុងភពតូច-ភពធំ, វិលទៅវិលមក, តណ្ហាគឺបំណង, ស្រើបស្រាល, ត្រេកត្រអាល ក្នុងវដ្ដសង្សារ ក្នុងអារម្មណ៍ទាំងប្រាំមានរូបារម្មណ៍ជាដើម, ក្នុងកាម

គុណប្រាំមានរូបជាដើម; តាមគុណទាំងប្រាំតែងរួត ក្រៀតខ្ទប់មាំមួននូវសន្តានចិត្ត បង្គ្រៃបង្ខុកឲ្យគ្រាប់ផ្តាត់ ក្នុងវដ្តសង្សារវិលស្លាប់វិលកើត វិលយកកំណើត ក្នុងភពតូចភពធំ, រងទុក្ខវេទនាជាអនេកប្បការ ពីព្រោះកងទុក្ខគឺជរាព្យាធិមរណៈ តាមបៀតបៀនញាំញីឈ្មួចឈ្មីសត្វនោះឲ្យរងទុក្ខលំបាកគ្រប់យ៉ាង, ស្លាប់ពីនេះទៅកើតឯណោះ, ស្លាប់ពីឯណោះទៅកើតឯនេះ, ត្រឡប់វិលស្លាប់ កើតៗស្លាប់ មិនចេះផុត, មិនចេះចប់ ត្រឡប់ត្រឡិន ដោយខ្សែតណ្ហានេះឯង ។

ដោយសេចក្តីទុក្ខលំបាក, យំទ្រហូលអាក់ខ្សឹកខ្សួល, ទើបមនុស្សទាំងឡាយបង់បំបាត់នូវទុក្ខនោះ ឲ្យជ្រុះស្រឡះពីសន្តាន បានជាស្វែងរកឱសថដែលជំនាញ ដើម្បីនឹងរំលត់ទុក្ខនោះ ។ អ្នកប្រាជ្ញ ដែលចេះដឹងគម្ពីរសាស្ត្រា ដើម្បីនឹងទូន្មានខ្លួនឲ្យរួចចាកទុក្ខ ។ បង្ហាញផ្លូវដែលទៅកាន់ស្ថានសុខ ស្ថានសុភមង្គល ។ បើមនុស្សយើងដឹងច្បាស់ដោយខ្លួនឯងថា ទុក្ខទាំង១៣កងមកពីតណ្ហា ហើយចង់រួចពីទុក្ខនោះ,ក៏ខំព្យាយាមត្រាប់ទៅកាន់ផ្លូវអដ្ឋង្គិកមគ្គ ដែលមានអង្គ ៨ ដើម្បីនឹងធ្វើតណ្ហាឲ្យថយអានុភាពបន្តិចៗទៅរហូតដល់រលត់សូន្យឈឹង បាននិរោធអរិយសច្ច ។ លុះព្រោះយោគាវចរធ្វើវិបស្សនាកម្មដ្ឋាន ពិចារណាបញ្ចក្ខន្ធជាអនិច្ចំ ទុក្ខំ អនត្តា ចិត្តក៏កាន់អរិយមគ្គបាន អរិយផលក៏កើតឡើងតាមលំដាប់ ក៏បានសម្រេច

សោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល ព្រះយោគាវចរនោះ បានសម្រេចសុគមគ្គផល តាំងពីជាន់ទាបរហូតដល់ជាន់ខ្ពស់ ៗ

៣ មនុស្សភាគច្រើន តែងប្រកបដោយអវិជ្ជា តណ្ហា ពកាទិក្កិលេស គ្រាស់ខាងអកុសលគឺលោភៈ ទោសៈ មោហៈ មនុស្សតែងគ្រាស់ដោយអកុសលមូល គឺលោភៈ ទោសៈ មោហៈ ដែលជាដើមចមនៃបាបអកុសលទាំងឡាយ; លោភៈ ទោសៈ មោហៈ នេះ តែងនាំសត្វឲ្យទៅកាន់ទុគ្គតិភព ៗ ដល់ទទួលផលជាទុក្ខយូរៗ ទៅ ទើបទៅកេផ្សុំសុខឃើញ ៗ

បាបអកុសលមិនទាន់ឲ្យផល មនុស្សដែលប្រព្រឹត្តបាបអកុសលនោះ ក្រុបខ្លួនរវល់តែសោយផលបុណ្យ លុះដល់បាបឲ្យផលវេលាណាដល់ពេលនោះ រងទុក្ខធំវេលានោះ សមដូចពុទ្ធភាសិត ក្នុងធម្មបទខុទ្ទកនិកាយ បាបវគ្គវណ្ណនា អនាថបិណ្ឌិកសេដ្ឋីវត្ថុថា:

បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ
បស្សតិ ៗ

មនុស្សបាបរមែងឃើញអំពើល្អ ដរាបទាល់តែបាបមិនទាន់ឲ្យផល លុះកាលណាបាបឲ្យផល កាលនោះ (មនុស្សបាប) រមែងឃើញច្បាស់នូវបាបទាំងឡាយ ៗ

ដល់ខ្លួនយល់ថា បាបអកុសលដែលប្រព្រឹត្តកន្លងទៅហើយមុខជាឲ្យផលថ្ងៃណាមួយមិនខាន, ហើយនឹងទុក្ខបារម្ភផុសផុល ក្នុងសន្តានចិត្ត នាំសត្វមិនឲ្យប្រព្រឹត្តបាបអកុសលតទៅទៀតបាន ។

បាបអកុសលនេះឯង ដែលធ្វើសត្វឲ្យរងទុក្ខលំបាកគ្រប់យ៉ាង ហើយជាសត្រូវសម្បជញ្ញៈសត្វ ឲ្យស្ទើរកើតជាទីពឹង ជាទីរលឹក គឺព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃ ។

៤- មនុស្សភាគច្រើនមិនដឹង ផ្លូវខុសផ្លូវត្រូវ, ផ្លូវល្អ, ផ្លូវអាក្រក់ មនុស្សទាំងឡាយមិនដឹងផ្លូវខុសព្រោះខ្លួនសេពគប់នឹងមនុស្សពាល, ទុច្ចរិត, និងមិត្តអាក្រក់ ដែលទូន្មានទៅខាងអបាយមុខ, ឲ្យប្រព្រឹត្តបាបអកុសលគ្រប់យ៉ាង; ដល់ប្រព្រឹត្តបាបទុច្ចរិតយូរៗទៅ ក៏ទទួលផលអាក្រក់តាមលំដាប់ ហើយមានថ្ងៃមួយ ក៏ភ្ញាក់រលឹកដឹងខ្លួនថា: ''ខ្លួនអញរងទុក្ខលំបាកជាច្រើនលើកច្រើនគ្រា មកពីអាត្មាអញប្រព្រឹត្តខុសពាក្យគន្លងធម៌, ផ្លូវដែលអញដើរគឺផ្លូវខុស'' ក៏ប្រឹងនាំខ្លួនឲ្យបានទៅកាន់ផ្លូវត្រូវ ផ្លូវល្អវិញ ។ ការដែលទៅកាន់ផ្លូវត្រូវ ផ្លូវល្អបាន ដោយសារការបួល ទៅសមាគមគប់នឹងបណ្ឌិត ដែលមានវិជ្ជាអាចបង្ហាញផ្លូវខុស, ផ្លូវត្រូវ, ផ្លូវល្អ, ផ្លូវអាក្រក់, ធ្វើតាមព្រះឱវាទគឺសាសនា ទើបបុគ្គលនោះ ទៅកាន់ផ្លូវត្រូវ ផ្លូវល្អបាន ។

ហេតុដូច្នេះ ការមិនដឹងផ្លូវខុស ផ្លូវត្រូវនេះហើយ នាំមនុស្សឲ្យប្រព្រឹត្ត

បាបអកុសល, ទទួលផលអាក្រក់, រងទុក្ខលំបាកគ្រប់យ៉ាង សាសនាជាមិត្តខុសគេ សម្រាប់ណែនាំអ្នកវង្វេង, ដើរផ្លូវខុសឲ្យទៅកាន់ផ្លូវត្រូវបាន ។ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា ផ្លូវមានបី: ផ្លូវត្រូវតាមជ្ឈិមាបដិបទា បាន ដល់អដ្ឋង្គិកមគ្គ , ផ្លូវអមទាំងពីរខាងគឺផ្លូវខុស បានដល់កាមសុខល្លិកា-នុយោគ ១, អត្តកិលមថានុយោគ១ ។

អដ្ឋង្គិកមគ្គគឺផ្លូវមានអង្គ ៨ ដ៏ប្រសើរនេះឯង (ហៅថាសេចក្តីប្រតិ-បត្តិជាកណ្តាល) សេយ្យដីធំ អដ្ឋង្គិកមគ្គនោះដូចម្តេចខ្លះ?

| | |
|---|---|
| សម្មាទិដ្ឋិ | សេចក្តីយល់ឃើញត្រូវ , |
| សម្មាសង្កប្បោ | សេចក្តីត្រិះរិះត្រូវ . |
| សម្មាវាចា | សំដីត្រូវ , |
| សម្មាកម្មន្តោ | ការងារត្រូវ , |
| សម្មាអាជីវោ | ការចិញ្ចឹមជីវិតត្រូវ , |
| សម្មាវាយាមោ | ព្យាយាមត្រូវ , |
| សម្មាសតិ | សេចក្តីរឭកត្រូវ , |
| សម្មាសមាធិ | ការដំកល់ចិត្តឲ្យនឹងត្រូវ ។ |

ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គនោះឯងដែលហៅថា សេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិ-

បត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរលត់ទុក្ខ ។

កាមសុខល្លិកានុយោគ,ធម៌ប្រកបខ្លួនឲ្យជាប់ជំពាក់ ដោយកាម,ក្នុងកាមទាំងឡាយៈ

ហីនោ ជាធម៌ថោកទាប ,

គម្មោ ជាធម៌របស់អ្នកស្រុក ,

បោថុជ្ជនិកោ ជាធម៌របស់បុថុជ្ជន ,

អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ ,

អនត្ថសញ្ហិតោ មិនប្រកបដោយប្រយោជន៍ឡើយ ។

អត្តកិលមថានុយោគោ គឺធម៌ដែលប្រកបដោយសេចក្តីលំបាកដល់ខ្លួន ,

ទុក្ខោ ជាហេតុនាំឲ្យលំបាកកាយទទេ,

អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ ,

អនត្ថសញ្ហិតោ មិនប្រកបដោយប្រយោជន៍ឡើយ ។

ព្រោះហេតុដូច្នេះ, មជ្ឈិមាបដិបទា ជាផ្លូវប្រតិបត្តិកណ្តាលគឺអដ្ឋង្គិកមគ្គនេះឯង ជាផ្លូវប្រតិបត្តិដ៏ល្អ សម្រាប់ទៅកាន់ស្តុកមណ្ឌលគឺព្រះនិព្វាន ។

៤) មនុស្សភាគច្រើន តែងមានឧបាទាន, ប្រកាន់ស្អិតនូវសាសនា,

លទ្ធិ, ក្រុមបក្សពួក, គណៈ,និកាយជាដើម ។

មនុស្សទាំងឡាយច្រើនមានឧបាទាន ខ្ជាប់ខ្ជួនសន្តានចិត្តរបស់ខ្លួនគឺការប្រកាន់ហួសហេតុ, មិនព្រមសម្រុះសម្រួល, រាប់អានគ្នាជាបងប្អូន ច្រើនតែប្រទូសរ៉ាយគ្នានឹងគ្នា, នាំឲ្យកើតសេចក្តីក្តៅក្រហាយ, រងទុក្ខលំបាកគ្រប់យ៉ាង មកពីឧបាទាននេះឯង ឧបាទាននេះជាបំណាំនៃតណ្ហា ជាដើមចមនៃទុក្ខទាំង១២ ប្រការ មានជាតិទុក្ខជាដើម ។ ឧបាទាន គួរនាដូចជាដែនដីជាទីកើតនៃរុក្ខជាតិទាំងពួង ។ មួយទៀត,កងទុក្ខទាំងពួងតែងបៀតបៀន ខន្ធទាំង៥ នេះជានិច្ចជានិរន្តរ៍ មិនមានដាច់ ។ ខន្ធទាំង ៥ នឹងបដិសន្ធិ ក្នុងភពណាៗក្តី កងទុក្ខទាំង ១២ ប្រការ មានជាតិទុក្ខ, ជរាទុក្ខ, ព្យាធិទុក្ខ, មរណទុក្ខជាដើម ក៏ដិតដោយជាប់តាមបៀតបៀនក្នុងភពនោះ បីដូចស្រមោលអន្ទោលតាមប្រាណ ដូច្នោះ ។

ព្រោះហេតុដូច្នេះ, បានជាព្រះយោគាវចរកុលបុត្រ ជាពុទ្ធជនោរស ដឹងច្បាស់ថា ខន្ធទាំងប្រាំនេះ ជាដើមចមនៃទុក្ខទាំងឡាយ, លោកពិចារណាឲ្យឃើញទោសនៃខន្ធប្រាំ គឺនាមធម៌នឹងរូបធម៌នេះ ជាអនិច្ចំ,ទុក្ខំ, អនត្តា, ចិត្តលោកក៏តោងយកមគ្គ, ផល, លះអាសវក្កិលេស, ជាសមុច្ឆេទប្បហានទៅបាន, ផុតទុក្ខទាំងពួង បានសេចក្តីសុខ គឺព្រះនិព្វាន ។

ដោយហេតុនេះហើយបានជាថា សាសនា គឺឧបាយ ដែលព្រះសម្មាសម្ពុទ្ធទេសនាប្រដៅ ឲ្យសត្វលះបង់នូវទុក្ខទាំងពួង ដើម្បីយកសុខគឺព្រះ

និព្វាន ។ សាសនាណា ដែលនាំមនុស្សទៅកាន់សេចក្ដីគ្រេកគ្រអាល ក្នុងកាមគុណប្រាំ, ធ្វើកាយឲ្យលំបាកទទេ, ឲ្យបានសេចក្ដីទុក្ខទោស ភ័យគ្រប់យ៉ាង, មិនឲ្យបានសុខស្រួល ឲ្យក្ដៅក្រហាយ, សាសនា-នោះ មិនមែនជាពុទ្ធសាសនាទេ, សាសនាណាដែលណែនាំមនុស្ស ឲ្យវៀរចាកកាមគុណប្រាំ, ធ្វើកាយ វាចា ឲ្យមានរបៀបរៀបរយ, ណែនាំចិត្តឲ្យបានផូរផង់, ប្រាសចាកសេចក្ដីទុក្ខ ទោស ភ័យ, បានសេចក្ដីស្ងប់, សុខកាយសប្បាយចិត្ត លះបង់នូវការប្រព្រឹត្តអាក្រក់ រំលត់នូវសេចក្ដីក្ដៅក្រហាយ ទៅកាន់សេចក្ដីសុភមង្គល គឺព្រះនិព្វាន, សាសនានេះ ពិតជាពុទ្ធសាសនា ដែលប្រជារាស្ត្រក្នុងពិភពលោកត្រូវតែអប់រំ, សន្សំ, សិក្សារៀនសូត្រយកមកអនុវត្តក្នុងជីវភាពរាល់ថ្ងៃ ដើម្បីសេចក្ដីសុខចំពោះខ្លួន, សេចក្ដីស្រួលចំពោះអ្នកដទៃ, សន្តិភាពលោកជាបរិយោសាន ។ ពិតមែនតែមានសាសនា ជាច្រើនបែបច្រើនយ៉ាង, ត្រូវពិចារណាត្រិះរិះរកយកសាសនាណា ដែលណែនាំមនុស្សឲ្យមានសីលធម៌, វឌ្ឍនធម៌រួបរួមមនុស្សក្នុងពិភពលោក ដោយភាតរភាព, សាមគ្គីភាព, មេត្រីភាព និងសម្បូណ៌ភាព, ប្រែកមនុស្សពាល, ទុច្ចរិត អសប្បុរស ឲ្យទៅជាមនុស្សបណ្ឌិត, សុចរិត, សប្បុរស ធ្វើមនុស្សទាំងឡាយឲ្យទៅជាមនុស្សធម៌ពេញលក្ខណៈ, ណែនាំពិភពលោកឲ្យទៅជាស្ថានបរម-សុខគឺស្ថានព្រះនិព្វាននៅក្នុងលោក ។ ☛ (មានត)

## និទានសុភាសិត

### ពិសោធរកមនុស្សល្អ

# ព្រះមហា ម៉ៅ ខាន់ (ឆន្ទវីរិយោ)

ក្រុមជំនុំព្រះត្រៃបិដកៈ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

(តមកពីលេខ ១២ ឆ្នាំ ១៩៥៣)

---

ក្នុងគំនរងងឹតនៃរាត្រីស្ងាត់ ប្រកបដោយបរិយាកាសដ៏ត្រជាក់ល្ហឹមនោះ មាណពភ្ញាក់ស្មារតី ក្រោកអង្គុយឡើង ៗ គំនិតថ្មីរបស់គេ បានផុះឡើង ខុសពីពេលមុនទ្រា ដូចចំហាយដែលហុយឡើងពីធរណី ក្នុងពេលព្រលឹម ខុសគ្នាពីពេលល្ងាច ៗ គេគិតឃើញថា ៖

ឱ! ញាតិទាំងនេះ គេស្រឡាញ់អាត្មាអញ ទុកចិត្តអាត្មាអញ សំគាល់អាត្មាអញថា ជាបង ជាប្អូនបង្កើតរបស់គេ, គេមានឧបការៈដល់អាត្មាអញ គេញាប់រំទុកបំរុងអាត្មាអញ តាំងពីជួយសំលៀកបំពាក់ ឲ្យប្រាក់កាសចាយវាយ រហូតដល់អាត្មាអញរៀនសូត្របានជាអ្នកចេះដឹងនេះ ៗ មិនតែប៉ុណ្ណោះ ក្នុងពេលនេះ គេដឹងថា អាត្មាអញប្រឡងជាប់ចេញពីសំណាក់គ្រូមក គេមកចោមរោម សំដែងសេចក្ដីអបអរសាទរថែមទៀត ៗ

មិនសមបើ អាត្មាអញមកមានគំនិតក្បត់មករមិលគុណពួកញាតិទាំងនេះ សោះទេ! មិនសមបើ អាត្មាអញ បង់បំពេញបំណងរបស់ខ្លួនឯង ហើយ មកលួចទ្រព្យសម្បត្តិ របស់ញាតិទាំងនេះ ដូច្នេះសោះ" ។

"កុំថាឡើយ តែញាតិសន្តានរបស់អាត្មាអញ, ទោះបីអ្នកណាក៏ដោយ ទ្រព្យសម្បត្តិរបស់គេ គេខំរកមក ដោយកំលាំងហត់នឿយ បែកញើស ភាំងទឹក សូម្បីហាលភ្លៀងផ្គរ ហាលខ្យល់ និងកំដៅថ្ងៃ មិនគិត គឺគេ រកទ្រព្យមក ដើម្បីផ្គត់ផ្គង់សេចក្ដីសុខផ្ទាល់ខ្លួនគេ និងក្រុមគ្រួសាររបស់គេ អ្នកលួចប្លន់ទ្រព្យគេ ឈ្មោះថាហុតឈាមគេ ផ្ដាច់ផ្ដិលសេចក្ដីសុខរបស់គេ, ធ្វើគេឲ្យលំបាកវេទនា ឲ្យកើតទុក្ខក្ដៅក្រហាយ ដោយសារខ្លួន ។ ការលួច នោះដោយរបៀបណាក៏ដោយ ចាត់ជាអំពើអាក្រក់ថោកទាបទាំងអស់" ។

"ព្រោះតែស្អប់ខ្ពើមអំពើអាក្រក់, ព្រោះតែចង់វៀរវាងអំពើអាក្រក់ ព្រោះតែចង់ចិញ្ចឹមជីវិតដោយផ្លូវល្អ, ព្រោះតែចង់ដឹកនាំអ្នកដទៃឲ្យបានល្អ ទើបអាត្មាអញខំទៅសិក្សា" ។

"អាត្មាអញខំទៅសិក្សា ក៏ព្រោះតែប្រាថ្នាចង់យកការចេះដឹងនោះមក ប្រើ ដើម្បីឲ្យសម្រេចប្រយោជន៍ និងសេចក្ដីសុខចំរើន ដល់ខ្លួន ដល់ គ្រួសារ និងដល់ជនរួមជាតិរបស់ខ្លួន" ។

"ចុះបើមកប្រព្រឹត្តអាក្រក់ដដែល, ចិញ្ចឹមជីវិតដោយផ្លូវទុច្ចរិតដដែល,

បង្កទុក្ខសោកដល់អ្នកដទៃដដែល អាត្មាអញចាំបាច់ទៅខំប្រឹងសិក្សាធ្វើអ្វី , សេចក្ដីចេះដឹងរបស់អាត្មាអញ មានប្រយោជន៍ដល់ខ្លួន ដល់ញាតិសន្ដាន និងជាតិយ៉ាងណា " ។

គិតមកដល់ត្រង់នេះ ខ្លួនគេកើតសង្វេគសតចិត្តយ៉ាងជូរ នាំឲ្យគេនឹកស្រាវជ្រាវដល់ដំបូន្មានមាតាបិតា កាលបញ្ជូនខ្លួនឲ្យទៅរៀនសូត្រថា " បាឯង ទៅនៅក្នុងសំណាក់អាចារ្យ ត្រូវខំរៀន ខំយកចិត្តទុកដាក់ប្រតិបត្តិអាចារ្យ ប្រយ័ត្នកុំឲ្យមានហ្មងគ្មង ត្រូវការកេរ្ដិ៍វង្សត្រកូល ត្រូវរាំងខ្លួនឲ្យបានល្អជានិច្ច ទោះបីមានហេតុអ្វី នាំឲ្យលំបាក នាំឲ្យឈឺចិត្ត...ក៏ត្រូវតាំងថា យើងជាអ្នកមករៀនសូត្រ មករកបំណោះវិជ្ជា មករកសេចក្ដីសុខចំរើន", នេះមិន គឺលោកព្រួយបារម្ភ ក្រែងអាត្មាអញ មិនបានសុខ មិនបានចេះដឹង មិនបានល្អ ឬ ? "

គេនឹកឆ្ងល់នឹងការបង្គាប់របស់អាចារ្យថា

" ហេតុម្ដេចហ្ន៎ លោកគ្រូអញ ! តាំងពីដើមរៀងមក លោកតែងតែអប់រំ ប្រៀនប្រដៅអាត្មាអញថា អ្នកត្រូវចៀសវាងសេចក្ដីអាក្រក់ កុំប្រព្រឹត្តសេចក្ដីអាក្រក់ សូម្បីបន្តិចបន្តួចឲ្យសោះ ; ត្រូវស្រឡាញ់សេចក្ដីល្អ ត្រូវធ្វើតែសេចក្ដីល្អ ត្រូវបណ្ដុះមេត្តាករុណា ដល់អ្នកដទៃ ត្រូវឲ្យអភ័យដល់សត្វទាំងពួង ត្រូវដឹងថា ខ្លួនយើងស្រឡាញ់សុខ ខ្ពើមទុក្ខយ៉ាងណា

គេក៏ស្រឡាញ់សុខ ខ្ពើមទុក្ខយ៉ាងនេះដែរ ហើយលោកបានតាំងពន្យល់ទោសនៃសេចក្ដីអាក្រក់ និងគុណនៃសេចក្ដីល្អ ឲ្យអាត្មាអញយល់ចូលចិត្តយ៉ាងច្បាស់លាស់ ។ ផ្ទុយពីនេះស្រឡះ ពេលដែលចប់វិជ្ជា សន្មត់ថាជាអ្នកចេះដឹងហើយ លោកបែរជាមកបង្គាប់ឲ្យយកទ្រព្យគេ ដែលគ្មានគេដឹងឃើញ យកទៅជូនលោក លោកនឹងឲ្យបុត្រី...ទៅវិញ" ។

"ណ្ហើយចុះ! មិនបានបុត្រីលោកអាចារ្យក៏ហើយចុះ! អាត្មាអញ មិនព្រមលះសេចក្ដីល្អ ទៅប្រព្រឹត្តសេចក្ដីអាក្រក់ឡើយ" ។

កាលគេ ពិចារណាពាក្យអាចារ្យច្រើនលើកច្រើនសារ, មួយសន្ទុះ ទឹកមុខគេក៏ឡើងរឹងប៉ឹង គេលាន់មាត់ថា "ល្អណាស់ប្រសាសន៍លោកគ្រូត្រង់ថា ដែលគ្មានគេដឹងឃើញ" ។

ព្រលឹមឡើង, ក្រោយដែលបានសំដែងអាការកិរិយារែកពាយលើសពីពេលល្ងាចរួចហើយ បណ្ឌិតមាណពក៏បានប្រណិប័តន៍លាមាតាបិតានិងក្រុមញាតិ វិលទៅកាន់សំណាក់អាចារ្យវិញ ។

សិស្សឯទៀតៗ សុទ្ធតែបានរបស់មកប្រគល់ជូនអាចារ្យអស់ហើយ បាត់តែសិស្សម្នាក់ មិនទាន់ឃើញមក, ព្រឹកនោះ អាចារ្យទិសាបា-មោក្ខ ក៏អង្គុយរង់ចាំ ។

មួយរំពេចនោះ, ស្រាប់តែឃើញមាណព ចូលមកសំពះសួរដែ

ទទេ ៗ អាចារ្យឃើញដូច្នោះ ក៏សួរក្រាមថា "អើបា! ម៉េចក៏បាត់យូរដាំង គេម្ល៉េះ? មិនបានរបស់អ្វីខ្លះមកទេឬ?" ៗ

"សូមអភ័យទោស លោកគ្រូ! បានជាខ្ញុំបាទ ក្របានមក ព្រោះពួកញាតិដែលបានឮថា ខ្ញុំបាទបានសម្រេចសិល្បវិជ្ជា គេទៅជួយអបអរសាទរខ្ញុំបាទកាត់តែទៅគួរសមនឹងគេ, ខ្ញុំបាទឥតបានរបស់អ្វីមកជូនទេ" ៗ

"យី! ម៉េចក៏ដូច្នោះ?" ៗ

"បាទ! លោកគ្រូ មានប្រសាសន៍ថា នឹងទទួលយកចំពោះតែរបស់ដែលបានមក ដោយគ្មានគេដឹងឃើញម្យ៉ាង មិនទទួលរបស់ក្រៅពីនេះទេ, មែនឬ?" ៗ

"មែនហើយ, តែហេតុម្តេច ក៏អ្នកគ្មានបានរបស់មកខ្លះនឹងគេសោះ?" ៗ

"សូមជម្រាបប្រសាសន៍លោកគ្រូ! រឿងនេះខ្ញុំបាទពិចារណាទៅៗ ទល់គំនិត ទល់ប្រាជ្ញ, ព្រោះសំឡឹងមិនឃើញទីណាមួយ ដែលស្ងាត់កំបាំង ល្មមហុចឱកាសឲ្យខ្ញុំ ធ្វើសេចក្តីអាក្រក់បានសោះ ៗ ទុកណាជាកំបាំងភ្នែកអ្នកដទៃ គេមើលមិនឃើញ ខ្លួនខ្ញុំបាទក៏គង់ឃើញថាខ្លួនឯង កំពុងធ្វើដែរ ហើយបើបេះតែធ្មេចភ្នែកធ្វើទៅ ដល់បានរបស់នោះមកជូនលោកគ្រូ លោកគ្រូក៏នឹងឃើញការប្រព្រឹត្តអាក្រក់របស់ខ្ញុំបាទនោះ

ថែមទៀត ។ ខ្ញុំបាទមានសេចក្ដីអៀនខ្មាសពេក ព្រោះត្រកូលខ្ញុំបាទ រហូតដល់រូបខ្ញុំបាទ មិនដែលធ្វើសេចក្ដីអាក្រក់ដូច្នោះទេ ហេតុនេះ ទើបខ្ញុំបាទ ឥតបានរបស់យកមកជូនលោកគ្រូសោះយ៉ាងនេះ" ។

អាចារ្យបានស្ដាប់ហើយ ក៏ញញឹមហើយនឹករពឹងតែក្នុងចិត្តថា សិស្សរបស់អញ និយាយពាក្យថ្លៃថ្នូរណាស់ មានហេតុផលល្អណាស់ ។ ហើយគាត់នឹកសារទៅខាងដើម ក៏ចាំបានថា "មាណពនេះ ជាសិស្សល្អ យកចិត្តទុកដាក់ ក្នុងការសិក្សា មានសតិបញ្ញាច្រើន ជាអ្នកខ្វល់ខ្វាយ ក្នុងកិច្ចតូចធំមានបរិយាយរហ័សរហួននឹងរបៀបរយ មានអធ្យាស្រ័យទន់ភ្លន់ ជាអ្នកចេះគម្រូអធ្យាស្រ័យអាចារ្យ ដឹងស្គាល់សុខទុក្ខនឹងបំណងរបស់ឪពុកម្ដាយមិនហ៊ានចាយវាយ ឥតសណ្ដាប់ធ្នាប់ មិនដែលដើរលេងប្រឡែប្រឡោឡើយ តាំងការងាររបស់គេ, ប្រដាប់ប្រដាសម្រាប់រៀនសូត្រ រហូតដល់សំលៀកបំពាក់របស់គេ ស្អាតស្អំជានិច្ច ....." ។

អាចារ្យក៏ពុំតែងញ៉ើងគិត, មាណពពោធិសត្វ ក៏បន្ដពាក្យស្លោកទៅទៀតថា ៖

" ទីស្ងាត់ឥតមានក្នុងលោកពិត ឲ្យសត្វប្រព្រឹត្តធ្វើអកុសល
ពួកភូតក្នុងព្រៃតែយល់ តែដល់ពេលវិញថាសម្ងាត់ ។
ខ្ញុំគន់មិនឃើញទីតាំងនោះ ពិតជាគ្មានសោះទីស្ងប់ស្ងាត់

ធ្លាប់ឃើញទីណាកំបាំងបាត់ ទីនោះពុំស្វាត់ក្នែកខ្ញុំឡើយ ។

គ្រាន់តែមាណពពោធិសត្វ បញ្ចប់សំណោកនេះចុះភ្លាម , អាចារ្យទិសាបាមោក្ខ ក៏ឲ្យស័ព្ទសាធុការ សរសើរលើកតំកើងមាណពពោធិសត្វជាច្រើន នៅចំពោះមុខពួកសិស្ស ហើយស្រដីទៅកាន់មាណពពោធិសត្វតទៅទៀតថា " បាអើយ ! មិនមែនថាយើងហើយក្រទ័លដល់ទៅខ្វះសម្បត្តិទ្រព្យ សម្រាប់ចែកឲ្យជីតារបស់យើងហើយឲ្យបាទៅលួចទ្រព្យគេមកឲ្យនោះទេ តែដែលយើងធ្វើដូច្នេះ គឺដើម្បីពិសោធមើលការប្រព្រឹត្តិ របស់ពួកសិស្សថា តើអ្នកណាជាមនុស្សសុចរិតទៀងត្រង់តាំងនៅក្នុងសីលធម៌ល្អពិតប្រាកដ តាំងចំពោះមុខតាំងកំបាំងមុខ ហើយយើងប្រាថ្នា នឹងលើកជីតារបស់យើង ឲ្យដល់អ្នកនោះតទៅ ។ ឥឡូវយើងឃើញច្បាស់ហើយ សេចក្ដីប្រព្រឹត្តិរបស់បាឯងជាទីពេញចិត្តយើងច្រើន... " ។

ពោលមកដល់ត្រង់នេះ អាចារ្យទិសាបាមោក្ខ បែរមុខទៅរកសិស្សឯទៀត សួរបញ្ជាក់ថា " តើអ្នកទាំងអស់គ្នាឃើញដូចយើង ឬមាននរណាយល់ឃើញថាដូចម្ដេចដែរ? ក្នុងរឿងនេះ " ។

សិស្សទាំងអស់ គ្មាននរណាម្នាក់អាចជំទាស់បាន ព្រោះពិចារណាហេតុផលទៅ ឃើញស្របថា មាណពពោធិសត្វ ប្រព្រឹត្តប្រពៃមែន ហើយ

ទទួលសារភាពថា ខ្លួនឯងទាំងអស់គ្នាបានប្រព្រឹត្តមកពុំសមគួរឡើយ ។

ក្រោយការអនុម័តជាឯកច្ឆន្ទ នៃពួកសិស្ស, អាចារ្យទិសាបាមោក្ខ ក៏ប្រដាប់តាក់តែងបុត្ររបស់ខ្លួន ហើយលើកឲ្យជាគូគ្រងដល់មាណពពោធិសត្វ ព្រមទាំងទ្រព្យសម្បត្តិមតិកជាច្រើន ។

លុះសម្រេចកិច្ចវិវាហមង្គលហើយ ទើបគាត់ការបញ្ជូនពួកមាណពជាសិស្សទាំងនោះ ឲ្យនាំយករបស់ទ្រព្យ ដែលបានលួចគេមកទាំងអស់ ឲ្យត្រឡប់យកទៅប្រគល់ដល់ម្ចាស់ដើមវិញទីទៃ ។

បញ្ជាក់រឿងនេះ

( ភាសិតរបស់ព្រះបរមគ្រូ )

មាណព សិស្សច្រើនគ្នា ចិត្តប្រាថ្នា ស្រីកល្យាណ
លាភផល អន្តរធាន ព្រោះបំពាន សីលសត្យា ។
ឯព្រាហ្មណ៍ សិស្សត្រៅនេះ គបគម្រិះ សុបញ្ញា
តាំងនៅ ក្នុងសីលា បង់ពីណា លាភាផល ។
សរសើរ ទីងសុខយស បានខ្ពស់ ប្រសើរសល់
ភរិយា ល្អនិម្មល គឺគ្រូផ្ដល់ ផលស្ពាន់ ។

# ផ្នែកអក្សរសាស្ត្រ

## រឿងព្រេងរឿងក្ងាននិងកំពឹស

លោកលាន-ហាប់-អាន សាស្ត្រាចារ្យ

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

រៀបរៀង

តើមិត្តដែលពិនិត្យឃើញសត្វក្ងានអាស្រ័យកំពឹស ឬទេ ? ។ មិត្តពិសោធ ដោយយកស្រូវមួយក្តាំ ហើយគប់ក្នុងកំពឹសមួយនៅក្នុងនោះ ហើយយកទៅឲ្យក្ងានស៊ីមើល តើវាដូចម្តេចទៅ ? នោះមិត្តនឹងឃើញសត្វបក្សីស៊ីស្រូវ ដោយឥតឲ្យដោយនូវកំពឹសសោះ ។ តើមកពីអ្វី? វាខ្លាចពុល ឬ? មិនដូច្នោះទេ គឺក្ងានគោរពដឹងគុណកំពឹស ដូចមាននិទានតទៅនេះ ៖

ក្នុងកាលសម័យពីព្រេងនាយយូរលង់ហើយ មានសេដ្ឋីម្នាក់ជាអ្នកបរបាញ់ តែងត្រាច់ចរដោយសេះទៅក្នុងព្រៃជ្រៅមួយ ដើម្បីបាញ់ម្រឹគម្រឹគា

នឹងអស់បក្សាបក្សី ៗ នៅជំបូកមួយជាប់ស្រយាល នៅក្រោមដើមពំង ព្រានសេដ្ឋីបានគយគន់ជាញឹកញាប់ ឃើញពស់មួយគូញីឈ្មោលស្រឡាញ់គ្នារួមជីវិតមួយ ៗ ពេលដែលពស់ជាតិយាសកហើយ ខ្លួននៅខ្ចីទន់ ទន់ទុកទៅរកស៊ីពុំរួច, ពស់ឈ្មោលជាប្ដីតែងលូនទៅរកអាហារ ពាំយកនូវអំពារផ្សេង មកផ្ដល់បញ្ចុកឲ្យពស់ប្រពន្ធ រហូតដល់រឹងប៉ឹង មានកម្លាំងកំហែងមាំទាំ ទើបទៅរកស៊ីទាំងគូ ៗ

ពេលមួយ វេលាដែលសេដ្ឋីព្រាន ដើរសំដៅមកដល់ជំបូក ពស់ឈ្មោលដែលមានខ្លួនខ្សោយ ទើបនឹងសកសំណកថ្មីៗ ធ្វើក្បាលងើងក្ងើកកឹសៗ ដូចជាទន្ទឹងនរណាមួយ ដែលជាត្រួយជីវិតប្រាកដ ៗ ព្រានអ្នកមានដឹងជាក់ក្នុងចិត្តថា សត្វអាសិរពិសឈ្មោលនេះ ចាំមើលផ្លូវប្រពន្ធវា ដែលប្រហែលជាផ្លាស់វេនគ្នា ទៅរកចំណីមកបញ្ចុកប្ដីសម្លាញ់វា ហើយមើលទៅ ៗ គិតដូច្នោះ ព្រានសេដ្ឋីក៏បង្ហួសដំណើរទៅមុខទៀត ៗ មិនឆ្ងាយប៉ុន្មាន ស្រាប់តែព្រានឃើញពស់មួយគូលូនទន្ទឹមគ្នាឆ្ងើរកៗ មកពីនាយ ៗ ព្រានយល់ជាក់ជាពស់មួយញី ពស់មួយឈ្មោល ឯពស់ញីគឺពស់ប្រពន្ធ ពស់ឈ្មោលដែលសកនៅនាជំបូក ៗ ព្រានគាត់យល់ក្នុងចិត្តភ្លាមថា មេពស់ញីនេះគ្មានពាំយកអ្វីក្នុងមាត់ទៅផ្ដល់ឲ្យប្ដីសោះ បែរជាធ្វើម្ចុកម្ចក់នាំឈ្មោល សហាយទៅលេងស្មោរ គួរឲ្យសង្ស័យថា មុខជាវានាំគ្នានេះទៅប្រហារប្ដីព្យា-

បាវបុត្រកសត់ទន់ខ្សោយ នៅឯរូងជាប្រាកដ ៗ គិតយល់ដូច្នោះ ព្រាននឹកថា ឱហ្ន៎! សត្វតិរច្ឆានអើយ អ៊ីក៏សាមាណ ដូចមនុស្សលោកម្ល៉េះហ្ន៎! វេលាឯងមានទុក្ខ គ្នាប្ដីឈ្មោលខំត្រាច់រកអាហារ មិនខ្លាចនឿយហត់ មិនខ្លាចស្លាប់យកមកឲ្យស៊ី ដើម្បីរស់ ដល់ពេលគ្នាមានអាសន្នវិញ បែរជាផិតចិត្តប្រុស្តទៅនាំឯសហាយស្មន់ មកយាយីគ្នាទៅវិញ ឱហ្ន៎! ចិត្តញី! ចិត្តអ៊ីកង្កេះម្ល៉េះ! នេះបានចំជាចិត្តកាំបិត ចិត្តកាំភ្លើង ចិត្តអាវុធ គិតមកដល់នេះ ព្រានសេដ្ឋីនឹកសង្វេគអាណិត ដល់ដំរីសត្វឥតទោស ទៅឯនាយកំសាំងគំនិតថា នឹងបាញ់អាចោរសាមាណពស់ឈ្មោល ជាសហាយ មីញីនេះឲ្យបាន កុំឲ្យវាទៅព្យាបាទយាយីគេខ្សោយ ៗ ព្រានក៏យឹតធ្នូដំឡើងព្រួញ ភ្ញាញ់ដំរង់ទៅពស់ឈ្មោល តែ..តែ អកុសលអ្វី ខណៈនោះ ដំរីតវាល់ កងព្រួញនឹងពស់ញីចិត្តយក្សនោះខ្ទេចវាទេ បែមកទទួលផ្លែព្រួញដល់សេចក្ដីស្លាប់ ដោយកម្លាំងថ្មីដៃមច្ចុកដក្លាម ៗ ពស់សហាយស្មាំងកាំងមិនដឹងទិសទៅឯណា. ក៏គេចលួនក្លាមមួយរំពេច, ប្រាស់យកតែអាយុទៅក្នុងគុម្ពោតព្រៃ ៗ ព្រាននឹកស្ដាយក្រោយ ក៏បរសេះទៅមុខទៀត ដើម្បីទៅរកព្រឹក្សាធ្វើទ្រនំស្នាក់បរបាញ់បានយូរថ្ងៃ ៗ

ថ្ងៃឯងពស់ឈ្មោលជាប្ដីនាងពស់ញីចិត្តចោរ មើលផ្លូវប្រពន្ធយូរទៅៗ ហួតដល់យប់ ក៏មិនឃើញមកវិញ ទើបនឹកថា ប្រហែលប្រពន្ធវង់គ្រោះ

ឬមានភ័យយ៉ាងណា គិតតែពីសោកសង្រេង អាឡោះអាល័យម្នាក់ឯង ៗ លុះគន់ពេលបន្តិចទៅ, មានកម្លាំងល្ហម, ពស់នេះក៏លូនតិចៗ ចេញទៅរកប្រពន្ធ ហើយក៏ប្រទះឃើញដេកស្លាប់នៅលើធរណី ដោយមានព្រួញយ៉ាងមុតមួយជាប់នៅក្បាល ប្រឡាក់ឈាមស្រមក ៗ ពស់កំសត់ខ្សឹកខ្សួល អួលអាក់យំស្រោកឯកោ ៗ ក្រោយមកពស់នេះក៏ស្រង់កូនព្រួញ ដឹងជាក់ជាព្រានសេដ្ឋី ជិះសេះជិតរន្ធខ្លួនបាញ់ប្រពន្ធស្លូតត្រង់ ឥតទោសស្លាប់ទទេៗ ក៏នឹកឈួលឆេះក្នុងបេះដូង តាំងគំនុំថានឹងទៅដល់ផ្ទះព្រាននេះចឹកពាំឲ្យស្លាប់ដូចបំណង ៗ សត្វឥតវិចារណញ្ញាណនេះ លូនតាមស្នាមនឹងក្នុងជើងសេះ ថយក្រោយរហូតទាល់តែដល់ផ្ទះសេដ្ឋីចិត្តបុណ្យ ៗ ក៏លូនឡើងទៅលើផ្ទះស្ងាត់ ៗ ទៅពួននៅជិតទ្វារត្រង់សំយាប ចាំឲ្យសេដ្ឋីត្រឡប់មកពីបរបាញ់ នឹងលោតមកចឹកបញ្ចូលពិសឲ្យស្លាប់ តែហោងដូចបំណង ៗ

ឯនាយសេដ្ឋីព្រាន លុះគំរប់ថ្ងៃត្រឡប់ពីព្រៃមកផ្ទះ, គាប់ជួនថ្ងៃពស់ផ្ទំចាំលើទ្វារ នាសំយាបនោះ គាត់មិនឡើងចូលក្នុងផ្ទះ តាមហោ-ណាំងមុខ ដូចសព្វមួយដងទេ, គាត់ឡើងតាមដំណើរក្រោយ ចូលទៅក្នុងផ្ទះ ៗ ដោះអាវជូតញើសស្រួលបួល សេដ្ឋីមកប្រជុំញាតិផៅគាត់នៅកណ្តាលផ្ទះ . ហើយនិយាយរាប់រៀបនូវអស់រឿងចៅពស់កំសត់ប្តីប្រពន្ធ រហូតដល់គាត់សម្លាប់មេញីសាហាវ ដោយឥតបំណងសោះនោះ ៗ

ពស់ឈ្មោលដែលចិត្តកន្ទះរា ហើយពេញទៅដោយទោសៈ លុះបាន ត្រងត្រាប់ស្តាប់នូវសេចក្តីពិតនៃមរណភាព យ៉ាងអាសអាកាសរបស់ ប្រពន្ធខ្លួនដូច្នេះ, វាក៏ទន់ចិត្តនឹកអរគុណសេដ្ឋីព្រាន ដោយយល់ថា "អើហ្ន៎" គំនិតអញពេញជាបាប អញគិតនឹងបង្ខុសការពិតស្រឡះ លោកសេដ្ឋី នេះ ចិត្តបុណ្យបង់ជួយយកអាសាជីវិតអញសោះ បើគាត់កុំបាញ់មេពោរ អន្ទក់ឃ្លេះនេះស្លាប់ទេ, កុំអីវាខឹងនាំសហាយមកទាំសម្លាប់អញ កំឡាំង ខ្សោយទន់ខ្លួនទេ ប្អូ! ឱ! លោកនេះ មានគុណធំបំផុតដល់អញណាស់ អញត្រូវតែសងគុណលោកឥឡូវឲ្យសមបំណង ៗ ថាហើយពស់ក៏សត់ ក៏ហាមាត់ក្អួតនូវដុំគជ់មួយគ្រាប់ ទម្លាក់មកឲ្យសេដ្ឋី ហើយក៏លូនចុះទៅ លំទៅជាសុខសាន្ត ៗ សេដ្ឋីអរណាស់ ដោយបានរើសយកនូវដុំគជ់នេះ ហើយយកមកក្រេកុកនឹងខ្លួនហាក់បំពេរ ៗ តាំងពីថ្ងៃសេដ្ឋីបានដុំគជ់ នេះមក សោតបសាទ ក៏ប្រែជាចេះស្តាប់ នូវភាសាសត្វទាំងឡាយ ដែល ប្រាស្រ័យទើយធ្លង់គ្នា ឥតបន្ទោះឡើយ ៗ សេដ្ឋីរីករាយណាស់ ៗ

ថ្ងៃមួយសេដ្ឋី ត្រូវធ្វើដំណើរចូលទៅភូមិមួយដាច់ស្រយាល ដែល ខ្លួនធ្លាប់ទៅ ៗ ដល់ទៅភូមិ គាប់ជួនជាពេលល្ងាច សេដ្ឋីមិនចូលទៅ ស្នាក់ផ្ទះមិត្តអ្នកមាន ៗ ទេ, គាត់ចូលទៅផ្ទះបុរសភរិយាស្វាមីមិត្តគាត់ ម្នាក់ដែលក្រហោមហោមនៅខ្ទម ដំបូលប្រក់មេឃ មានត្រឹមតែក្ងាន.

មួយគូ ញីឈ្មោលជាទ្រព្យៈក្រោមផ្ទះប៉ុណ្ណោះ ។ បុរសប្តីប្រពន្ធអរគេខំបកខុប រៀបបាយទឹកអម្រេសអម្រ មកជូនមិត្តសេដ្ឋីពិសា ។ នាយសេដ្ឋីនៅស្នាក់ផ្ទះនេះក្នុងយប់នោះ ។ នាកណ្តាលអធ្រាត្រស្ងាត់ បុរសជាប្តី និយាយទៅកាន់ករិយាថា "ឯងអើយ ឥឡូវ មិត្រយើង គេអ្នកមានធំមកលេងដល់យើង ១ គ្មានបានម្ហូបអ្វីឆ្ងាញ់ពិសា ជូនគេពិសាសោះ ពីល្ងាចមិញ ។ ឥឡូវស្អែកនេះ ពេលព្រឹក យើងនឹងឃាត់មិត្តយើងឲ្យគេនៅពិសាបាយមួយពេល ទិនរើងទៀត ។ ករិយាឆ្លើយថា "អើហ្ន៎ អ្នកអើយ បើលុយគ្មាន ខ្ទុនក្រយ៉ាំនេះ តើស្អែកយើងបានអ្វីជូនលោកសេដ្ឋីពិសា មិនអំបិលប្រហុក ដូចពីម្សិលទៀតឬ!" ។ ប្តីឆ្លើយគាត់ជូនថា "ឯងអើយ គិតអ៊ីកំរែងម្ទេះ ស្លឹកគ្រៃ, ម្ទេស, ខ្ទឹម, ខ្ទះ, ឆ្នាំង, បង្ក្រាន, ទឹក, ភ្លើង យើងមានស្រេចហើយ ឯក្រោមផ្ទះ ក្នុងទ្រុងក្រោមកន្ទ្រង់យើងនេះ អាក្ងានយើងមួយគូទុកជាធ្វើអ្វី ចាប់វាមួយសម្លាប់ស្ងោរស្លកទៅ ខ្វះអ្វីម្ហូបឆ្ងាញ់នៅមុខសោះ!" ។ ប្រពន្ធឮដូច្នោះ ក៏អស់សំណើចហើយសាទរនាំគ្នាដេកទាំព្រឹកនឹង បម្រុងរឿងនេះ ។ ថ្ងៃឯក្ងានប្តីប្រពន្ធទាំងគូ នៅក្នុងទ្រុងក្រោមដំណេកម្ចាស់វា លុះឮការពិគ្រោះប្តី ប្រពន្ធ ដំរូវសម្លាញ់មួយដូច្នោះ ក៏ដេកលែងលក់ ក៏ស្រណោះស្រណោក យំស្រែកប្រាស្រ័យគ្នា ជាភាសាសត្វដូច្នេះ "ឱបូនសម្លាញ់ផ្លូវជីវិតបងអើយ នេះគឺសំពីគ្មានប្តី, ឥឡូវ

ម្ចាស់ថា សម្លាប់មួយមិនដឹងជាប៉ះលើរូបឯណាទេអូន!"ៗ"ឱបងបណ្ដូល ជីវិតប្អូន បើប៉ះលើរូបប្អូនចុះ នោះប្អូនបន់ណាស់ សូមឲ្យទេវតាលោក ទុកជីវិតបងចុះ!" ៗ "ទេ ទេ! ប្អូនព្រលឹងមាសតន់ ឲ្យគេចាប់បងចុះសោះ បើគិត ឲ្យតែជីវិតនៅនៅ!" ៗ "ឱមាសស្នេហ៍បងអើយ បើយ៉ាងនេះសូមឲ្យ លោកម្ចាស់ចាប់យើងទាំងពីរ សម្លាប់មួលគ្នាទៅ សោះនឹងបាត់មួយទៅ-មួយយើងនឹងទៅជួបគ្នាខាងមុខទៀត!" ៗ ការយំសោកនេះ មិនតិចតួចក៏ លាន់ឮដល់ត្រចៀកសេដ្ឋី ដែលកំពុងផ្ទៀងស្ដាប់តាំងពីសម្ដេងមួយម៉ាត់ ដំបូង ៗ សេដ្ឋីនឹកអាណោចអាធម្មដល់ជីវិត នៃគូសង្សាររួមជីវិតនៃសត្វក្ងាន ទាំងពីរ ៗ គាត់គិតថា ឱហ្ន៎! ជីវិតគេជីវិតឯង សត្វក៏ដូចមនុស្ស, មានការ ស្នេហា, មានសេចក្ដីតក់ស្លុតខ្លាចនឹងការស្លាប់ដាច់ស្ងួតទាំងអស់, មាន ចិត្តស្រឡាញ់ជីវិតលើសលុបក្នុងលោក, ចុះខ្លួនអញអីក៏អាក្រក់ខ្លាំងម្ល៉េះ ចូលមកជាគេនេះ ធ្វើឲ្យអំពល់ដល់សេចក្ដីសុខ នឹងសុភមង្គលរបស់ក្ងាន កំសត់នេះម្ល៉េះ!... សេដ្ឋីត្រិះរិះយ៉ាងនេះ រហូតដល់លង់លក់ទៅ ៗ លុះភ្លឺ ស្រាង ៗ ឡើង គាត់ក៏ក្រោកពីដំណេកចូលទៅផ្ទះបាយ ស្រាប់តែឃើញ ប្ដីប្រពន្ធ កំពុងដាំទឹកក្ដៅលើជើងក្រានមួយថ្ងាងធំ គាត់លាន់មាត់ថា "នែ ក្មាក់ភាំថ្មើណា ចុះដាំទឹកធ្វើអ្វី?"ៗ"បាទ អញ្ជើញទៅចំរេតវិញទៅ នៅងងឹត ណាស់ ទុកតាមតែខ្ញុំចុះ កុំបារម្ភមិត្ត"ៗ"ទេៗ! ខ្ញុំដឹងហើយ មិត្តធ្វើអីនឹង ៗ

“ បាទ ខ្ញុំប្តីប្រពន្ធបំរុងធ្វើការទុកធ្វើម្ហូបជូនពិសាព្រឹកនេះណា ” ។ “ឱ ទេៗ! កុំៗ ! កុំម៉ិត្ត ! កុំ ! ខ្ញុំមិនទទួលទានទេ! ជីវិតគេក៏ដូចជាជីវិតយើង កុំអំពល់នឹងខ្ញុំ បើគ្មានអ្វីចាំក៏មានអ្នកទទួលគេទូលអម្រស់អម្រអ៊ីមក តែបន្តិចខ្ញុំបានហើយ ! ” ។ ប្តីប្រពន្ធក៏ត្រេកអរតាមសំដីឃាត់របស់សេដ្ឋី ហើយក៏នាំគ្នាមកអង្គុយនៅមុខផ្ទះ ចាំមើលទទួលពេលព្រឹក ។ គាប់ជួនមួយរំពេចនោះ មានស្រីម្នាក់ទូលកំពឹសបឹងមួយកញ្ជើមក សេដ្ឋីក៏បញ្ជាប់ឱ្យទិញមួយកញ្ចប់ យកមកធ្វើម្ហូបសាស្រ័យជាមួយគ្នា យ៉ាងអភិរម្យ។ ក្ងានទាំងពីររួចពីសេចក្តីស្លាប់ ដោយសារគុណកំពឹសនេះឯងទើបវាស្បថថា “តាំងពីថ្ងៃនោះមក វាដឹងគុណកំពឹសផាន់និច វាមិនត្រូវស៊ីកំពឹសជាអ្នកមានគុណទេ ! ” ។ លុះបំណាច់ក្រោយមកសេដ្ឋីក៏ទទួលអនិច្ចកម្ម ដំណឹងយ៉ាងរន្ធត់នេះ បានឮដឹងដល់ក្ងានទាំងគូ ដែលសេដ្ឋីជួយឱ្យរួចជីវិត ដោយបេះស្តាប់កាសាវ៉ា វាទាំងពីរក៏នាំគ្នាកាន់មរណសញ្ញា សងគុណសេដ្ឋី ដោយមានឆ្នូតខ្មៅមួយនៅកោម ។ យ៉ាងនេះហើយទើបបានជា, ក្ងានខ្លះរហូតមកដល់ឥឡូវនេះ មានពណ៌កោមខ្មៅជុំៗ ក៏វាកាន់ទុក្ខ ។

# អ្នកគង្វាលចៀមចិត្តស្លូតត្រង់នឹងព្រះរាជធីតា

លោក ផែង-ជ្រីវ នៅក្រសួងឃោសនាការជាតិ

ប្រែចាកសៀវភៅ កុងត៍អេឡេសង់ដ៍ ដឺ រោមានី

(តមកពីលេខ ១២ ឆ្នាំ ១៩៥៧)

( Contes et Légendes de Roumanie, )

នៃមេសេះកំណាចសំគម ចូរកុំបណ្ដាយទុកឲ្យ តែមាណពនេះដឹកនាំមក ផ្ទះវិញ ប្រយ័ត្នស្រែកមេហាន៍ឯងចុះ ។

- មិនអីទេ មិនអីទេ សូមយាយកុំព្រួយ ខ្ញុំនឹងលួនចូលពួនក្នុងព្រៃ ញាតស្បាត គ្មានអ្នកណានឹងអាចចូលដល់ខ្ញុំឡើយ ។

អ្នកគង្វាលយើង ដឹកមេសេះទៅឲ្យស៊ីនៅលើកួនភ្នំមួយ មុនដំបូង គេបានប្រទះឆ្កែចចកមួយ ហើយគេគិតថា:

- អញនឹងវាយចចកនេះសម្លាប់ចោល , ការណ៍នេះមិនជាខុសត្រូវអ្វី ហើយធ្វើដូច្នេះឈ្មោះថា អញបានជួយសង្គ្រោះដល់ពួកចៀមទាំងឡាយ ។

ចចកឆ្លើយថា: —

- បពិត្រអ្នកហាវហាន ចូរកុំសម្លាប់ខ្ញុំ , ខ្ញុំនឹងជួយសង្គ្រោះដល់អ្នក វិញ ។ ងឿងឆ្ងល់ពេក គេក៏បណ្ដាយឲ្យចចកត្រាច់ហួសទៅ - - - ។

ឆ្ងាយពីទីនោះបន្តិចទៀត អកមួយបាក់ស្លាបម្ខាង ដេកនៅដីហើយនិយាយអង្វរថា: សូមកុំសម្លាប់ខ្ញុំលោក! សូមយកថ្នាំមកបិទ ហើយរុំឲ្យខ្ញុំវិញ ល្អ! ខ្ញុំនឹងដឹងគុណអ្នក ទៅថ្ងៃក្រោយ ៗ អ្នកគង្វាលយើងយកថ្នាំរុំបិទឲ្យសត្វអក ។ ឆ្ងាយពីនោះទៅទៀត នៅជិតកន្ទែងស្មៅ ក្បែរមាត់ត្រពាំង មានត្រីមួយធំ កំពុងតែបំរះនេនៀលនៅលើដី ។ អ្នកគង្វាលគិតថា: អើ អញ-នឹងសម្លាប់ត្រីនេះ ព្រោះអញឃ្លានបាយ ។ ត្រីអង្វរថា: បពិត្រលោកហាវហាន សូមកុំសម្លាប់ខ្ញុំ ។ សូមយកឈើមក ហើយឆ្កិះខ្ញុំទៅក្នុងទឹកល្អផាង នោះលោកនឹងមិនមានក្តៅក្រហាយស្តាយក្រោយទេ ។ ទោះបីសេចក្តីស្រេកឃ្លានគ្រប់សង្កត់យ៉ាងណាក៏ដោយ អ្នកគង្វាលចាប់ត្រីបោះ-ទៅក្នុងទឹកវិញ ។

បំណែកមេសេះគិតតែស៊ីស្មៅ ហើយអ្នកគង្វាលយើងជិះលើខ្នង ទំប្រឹងមិនឲ្យងងុយដេក ប៉ុន្តែទោះបីទំប្រឹងដូចម្តេចក៏ដោយ គេលោលក់ទៅមិនដឹងខ្លួន ។ លុះព្រឹកគេភ្ញាក់ឡើង ស្រាប់តែខ្លួនគេទៅនៅទ្រោបលើទ្រនំតាអ្នូត ។ មេសេះទៅណាបាត់! ។

អុញ! អញស្លាប់តើ! ហើយគិតតែពីយំ គិតតែនិយាយត្អូញត្អែរតែម្នាក់ឯង - - ។ ចុះអ្នកណាស្តាប់ពុ? មានតែជួនដៃព្រៃព្រឹក្សា ។ គេដើរដល់ចបកក្តាម ដែលគេទុកជីវិតឲ្យនោះ ហើយចបកក៏មកដល់ទាន់ចិត្ត

ទៅពីមុខហើយសួរថាៈ បពិត្រលោកទាហាន តើលោកមានការណ៍អ្វី?ៗ

- អញបាត់មេសេះរបស់យាយយក្ខិនីហើយ ៗ អញមុខជានឹងស្លាប់ជាមិនខាន ៗ

- រឿងតែប៉ុណ្ណឹងទេលោក? សូមកុំព្រួយ ចាំទៅពួននៅក្នុងគុម្ពោតព្រៃ បន្ទាប់ឯណោះ ហើយខ្ញុំនឹងដេញវាឲ្យចេញ ឥតពីបាកអ្វីទេ ដោយហៅពួកម៉ាកខ្ញុំឲ្យមកស្រែកលូក្បាវា ៗ

ពិតមែន មិនយូរប៉ុន្មាន អ្នកគង្វាលចិត្តស្លុតគ្រប់ ឃើញមេសេះផាយចេញមកពីទីនោះ ៗ ក្នុងវេលាយប់នោះ មេសេះបង្កើតបានកូនបី ៗ គេស្រែកហៅមេសេះ តាមពាក្យបង្គាប់របស់ចចកថាៈ

- ចូរមកអាយ! ចូរមកអាយ! ចូរមកអាយ! មេសេះកូនបីនៃយាយយក្ខិនី!ៗ

មេសេះដើរចូលមកក្រោម ៗ គេឡើងជិះហើយបរនាំយកទៅដាក់ក្នុងក្រោល ៗ យាយយក្សលាក់កំហឹងនៃអាត្មាទុក ហើយឲ្យបាយដល់អ្នកគង្វាលបរិភោគ រួចបញ្ជូនឲ្យទៅដេក ៗ ហើយគាត់ទៅឯក្រោល សំពងមេសេះ ស្ទើរស្លាប់ហើយប្រាប់ថាៈ យប់នេះ ត្រូវពួនឲ្យបាត់ពុប្ហុះទេមេកញ្ចាស់សំគម បើមិនដូច្នោះទេអញសម្លាប់មេហែងឯងចោល ៗ

ព្រឹកឡើងយាយយក្សឲ្យនាំមេសេះទៅទៀត ៗ ចំណែកអ្នកគង្វាល កំពុងតែប្រុងស្មារតី ដើម្បីកុំឲ្យងងុយដេក ស្រាប់តែសេចក្តីងោកងុយបុល

មកគ្របក្តិប ទន់គ្របកន្ត្រក . . . . . លុះភ្ញាក់ឡើង នៅវេលាព្រឹកមិនឃើញមេសេះ ហើយខ្លួនឯង នៅពោបលើគូនឈើមួយដើម ។

មួងនេះរកអ្នកណាជាមិនកើតឡើយ អំពីសេចក្តីទុក្ខព្រួយនៃអ្នកគង្វាល ។ គេនឹកឃើញដល់បង្គោល ដែលនៅចាំដោតក្បាល ហើយជាការឥតអំពើសោះ ដែលព្រះរាជធីតានៃព្រះចៅ ប្រទានស្មៀតសក់ឲ្យគេ ។ ប្រហែលព្រះនាងចេះតែរង់ចាំមើលផ្លូវជានិច្ច ទព្រះនាងកំសត់អើយ គេនឹកយ៉ាងខ្លាំងដល់ព្រះរាជធីតា ព្រោះតែព្រះនាងបានជាគេស៊ូលះបង់ហ្វូងចៀម បងប្រុស និងអាពុកម្តាយ .... ។ តើហេតុអ្វីបានជាគេមិនមានចិត្តក្លាហានដើម្បីធ្វើជាអ្នកគង្វាល ? ។

គ្រានោះ គំពុងតែយំរៀបរាប់ អ្នកគង្វាលឃើញលោមានគំនិតមួយនឹកដល់សត្វអកពីថ្ងៃមុន ។ មួយស្របក់គេឮសំឡេងស្រែកពីលើក្បាលថា:

- បពិត្រលោកហាវហាន តើលោកមានការណ៍អ្វី ? ។ អ្នកកំឡោះក៏អធិប្បាយប្រាប់រឿងសព្វគ្រប់ ។

- សូមលោកបាត់ភ័យទៅ ។ លោកឃើញឬទេ ពពកនឹងអត្តូទាំងនោះនៅឯលើមេឃ ? ។

- ចាំមិនឃើញ ។

- បពិត្រលោក គឺហ្វូងហើយមេសេះព្រមទាំងកូនរបស់វាផង ។

យើងជាសត្វអក យើងនឹងទៅដេញវាឲ្យចេញ ហើយបញ្ជូនវាមកឲ្យលោក. គឺដេញចឹកវាទាំងបំពុះ ៗ

គ្រាន់តែសត្វអកស្ទុះហើរឡើងទៅ ហើយកំពុងបំបែកពពកដោយសំរែក ស្រាប់តែអ្នកគង្វាលយើងស្រែកហៅថា: " មកអាយ! មកអាយ! មកអាយ ! មេសេះកូនប្រាំមួយរបស់យាយយក្ស ហើយឃើញមេសេះនឹងហ្វូងកូនសេះមកដល់ភ្លាម ៗ

គេឡើងជិះត្រឡប់នាំមកផ្ទះវិញ យកទៅទុកក្នុងក្រោលទៅរកបាយស៊ី ហើយទៅដេកទៅ ៗ ចំណែកយាយយក្សក្ដៅចិត្តខ្លាំងពេកបោចតែសក់ខ្លួនឯង រួចស្ទុះទៅឯក្រោលសេះ គាត់វាយឥតប្រណីហើយស្រែក-ទាំងក្រោធថា បើយប់នេះទៀត មេហាងឯងត្រឡប់មកជាមួយនឹងវាទៀត គឺខ្លួនមេហាងឯងហើយ ដែលត្រូវអញសម្លាប់ជំនួសវា ៗ

យប់ក្រោយមកមានរឿងដូចគ្នាទៀត ៗ អ្នកគង្វាលយើងដេកលក់ព្រងើយ ៗ

លុះព្រឹកឡើងគេភ្ញាក់ឡើង មេសេះសំគមទៅណាបាត់ ហើយគេអង្គុយនៅលើសំបុកស្រមោច ៗ

ម្តងនេះ ឈប់ព្រួយ គេនឹកដល់ត្រី ហើយត្រីក៏មកដល់មួយរំពេចនៅពីមុខ ហើយនិយាយថា: បពិត្រលោកហាវហាន សូមលោកស្តាប់ខ្ញុំ :

មេសេះនេះទៅត្រសុលពួននៅក្រោមសាពយ ឯបាតសមុទ្រ ។

សូមលោកកុំភ័យ ខ្ញុំនឹងទៅនាំមកជូន ហើយក៏ស្រាប់តែមានរលក-ហោកបក់ បែកផ្កាត្រែងក្ដួចទឹកពុះពោរ អ្នកគង្វាលយើងគាំងស្រែកហៅទៀតថា "មកអាយ ... មកអាយ ... មកអាយ ... មេសេះកូនប្រាំបួនរបស់យាយយក្ស ! ដ្បិតវាបង្កើតកូនបានកូនបីទៀត ។

មេសេះចូលមកហើយ គេចាប់ដំរមក ។ ប៉ុន្តែកំពុងតែបរទៅ អ្នកគង្វាលយើងបានឮមេសេះនិយាយប្រាប់ ព្រោះវាដឹងថា ជីវិតវាទៀងតែអស់ត្រឹមពេលហ្នឹងជាប្រាកដ ។

- បពិត្រលោកហាវហាន លោកនឹងឯងជាហេតុនៃសេចក្ដីអន្តរាយជីវិតខ្ញុំ ប៉ុន្តែទោះបើដូច្នោះក៏ដោយ ខ្ញុំប៉ង់ធ្វើសេចក្ដីល្អដល់លោក ។ សូមលោកចាំពាក្យរបស់ខ្ញុំ ដែលនឹងជាប្រយោជន៍ដល់លោក ។

- ពាក្យយ៉ាងដូចម្ដេច ? ។

- ពាក្យនោះដូច្នេះ ៖ យាយយក្សនឹងខ្វះយកដួងចិត្តពីកូនខ្ញុំទាំងប្រាំបី ដើម្បីយកទៅដាក់តែក្នុងខ្លួនកូនទីប្រាំបួន ដែលគាត់នឹងយកទៅបោះបោលឯគំនរសម្រាម ។ កូនសេះទាំងប្រាំបីដែលគ្មានចិត្ត មានរូបល្អ ហើយសមណាស់ ចំណែកកូនទីប្រាំបួន តូចហើយស្គមក្រពើង មិនជាមើបទេ សូមលោកយកតែអាមួយហ្នឹងចុះល្អហើយ ។

អ្នកគង្វាលអរគុណជាក្រៃលែង ចំពោះមេសេះជាបច្ចាមិត្រ ហើយអ្នកទាំងពីរក៏ត្រឡប់ចូលទៅដល់ផ្ទះ ៗ

លុះឃើញមេសេះនឹងអ្នកគង្វាលទៅដល់ យាយយក្សខឹងពេកស្រែកតែម្នាក់ឯងបោចសក់ ហោកក្បាលនឹងជញ្ជាំង ៗ រួចអន់ខឹងគាត់ទៅកាន់ក្រោលសេះ សម្លាប់មេសេះ ខ្វេះបេះដូង យកពីកូនសេះទាំង៨ ហើយបិទជិតល្អទៅវិញ គាត់ធ្វើដូចជាមេសេះនិយាយប្រាប់ ៗ លុះទីបំផុតគាត់ក៏ត្រឡប់ចូលមកកាន់ផ្ទះវិញ ហើយប្រាប់អ្នកគង្វាលថា: នែអ្នកកំឡោះទៅ អញឲ្យកូនសេះដល់ឯងមួយ តាមតែឯងរើសយកចុះ ដ្បិតឯងបានបំរើអញត្រឹមត្រូវតាមច្បាប់ហើយ ៗ

លុះនាំអ្នកគង្វាលដល់ក្រោល គាត់បង្អួលបង្ហាញកូនសេះទាំងប្រាំបី៖

-ចូររើសយកតាមួយណាដែលត្រូវចិត្តឯងចុះ ៗ

អ្នកគង្វាលឆ្លើយថា : ទេ ខ្ញុំដឹងថាមេសេះមានកូនដល់ប្រាំបួន ចុះអាទី៩ នៅឯណា ? ៗ

-នែ អ្នក អានៅឯគំនរសម្រាមឯណោះ អានោះឯងយកទៅប្រើការមិនកើតទេ ៗ

-ទោះម្តេចក្តា ខ្ញុំចង់មើលឲ្យឃើញ ៗ

-ចុះចង់មើលបានប្រយោជន៍អ្វី ? ចូរយកតាល្អៗ ដែលប្រើការកើតឯ

ណោះវិញ ។ អ្នកគង្វាលធ្វើទឹកមុខខឹងហើយឆ្លើយថា៖ បើចង់ខ្ញុំទៅវិញ មិនខ្វល់យកអ្វីទាំងអស់ ។ ប៉ុន្តែប្រយាយចាំទុកចុះ មុខជាខ្ញុំទៅនិយាយបរិហារប្រាប់គេពាល់គ្នាថា យាយឯងកាច ចិត្តអាក្រក់ជាពន់ពេក ។ រួចធ្វើទំនងដូចជានឹងចេញដើរទៅ ។ យាយយកត្រ រត់តាមហៅមកវិញហើយប្រាប់ថា៖ នែអ្នកកំឡោះ ឯងយកអាណាក៏យកចុះ ប្រយ័ត្ន-តែស្ដាយក្រោយយាយមិនដឹងទេ ...... ។

គាត់ធ្វើទឹកមុខល្អ ប៉ុន្តែខាងក្នុង ក្ដៅស្ទើរឆេះ បើអស់លោកអ្នកក៏គួរខឹងដែរ !

អ្នកគង្វាលមានសេចក្ដីត្រេកអរជាពន់ពេក ។ គេទៅឯគំនរសម្រាមកកាយយកកូនសេះដូតចេញយ៉ាងស្អាត បោសអង្អែល ដាក់ប្រឡោឲ្យរួចដឹកយកទៅ ។ មិនយូរប៉ុន្មានកូនសេះងាកមើលម្ចាស់ហើយនិយាយថា៖

បពិត្រចៅហ្វាយ ចុះហេតុអ្វីក៏លោកដឹកខ្ញុំឲ្យដើរខាងក្រោយ ដូចជាគេអូសសម្រះដូច្នោះ? ឬខ្ញុំជាឆ្កែ បានជាលោកនាំបណ្ដើរខ្ញុំដូច្នោះ? លោកធ្វើនេះនាំឲ្យខ្ញុំខ្មាសគេណាស់ ។

សូមជិះខ្ញុំទៅស្រួលជាង ហើយសូមលោកអង្គុយឲ្យស្រួលបួល ។

- ក្រែងឯងតូចពេក !

- តូច? ខ្ញុំតូចពិត តែដូចនោះជ្រពណ្ណរាយ លោកនឹងឃើញឥឡូវនូវវត្ថុដែលខ្ញុំអាចធ្វើបាន ។

(មានត)

# រឿងទេវង្គ

## ពាក្យកាព្យ

## លោក អម្មតក្សត្រីម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

## លោក ញ៉ុក-ថែម ពិនិត្យ

(តមកពីលេខ ១២ ឆ្នាំ ១៩៥៧)

---

នន្ទិយក្ខយំយល់ ក្រេវក្រោធកំហល់ គំហកទៅថា កុំកោតកុំគិត

កុំគិតគយា ចាំមើលរន្ធា អង្គអញនេះម្តង ៗ រស់មនុស្សញ៉ែសព្វ ពិតពុំ

ស្តែងស្លាប់ រងភ័យកន្ទង រងយំរងយែក រងស្រែកអឺងកង ភ្លេចប្អូនភ្លេចបង

យក តអាយុះ ៗ យក្ខចាំងពីរពង្រ ពះអង្គខ្ទេចអង្គ ស៊ឹងរឹងស៊ឹងរូស កែកាយ

ការគេច ប្រទេចប្រទូស្ត ប្រទះហ៊ានហួស ទៅមកកាន់គ្នា ៗ ប្រជ័រប្រឹង

ប្រកោះប្រកឹង ប្រកាប់ប្រការ ប្រកាន់ប្រកោះ ស៊ឹងក្តោះស៊ឹងក្តា

ស៊ឹងក្តោះស៊ឹងមារ ស៊ឹងមួនស៊ឹងមាំ ៗ សម្កុកសម្កឹង ក្រញើយក្រញឹង

ក្រញៅក្រញាំ ត្រូវនឹងក្រចក របកសាច់ដាំ អាចអត់ទ្រទ្រាំ ជម្ពាត់ជម្ពី ៗ

ពុំបានថយថុប ពុំមានកកុច ពុំមានព្រួចព្រឺ ស្រែកសព្ទដូចផ្គរ កំទរកំទីរ

សព្ទស្ទុះនោះឮ ដល់ព្រះស្រោតថ្ងៃ ៗ

ស្ដេចត្រាស់ទៅកាន់ ទាំងបក្កុម្មណ្ឌ ចូរអ្នកវៃ ៗ បញ្ចោតយក្ខខ្មៅ មកក្រៅ
ក្រុងក្រៃ កុំឲ្យជាញជ័យ នៅក្នុងនគរ ៗ ក្រែងអស់មនុស្សម្នា ក្សណក្សយ
ជន្មា យក្ខបីថ្វាយករ ផ្គាំមផ្កាកដំកល់ សិរសាបវរ លាព្រះភូធរ ហើបហោះ
ទៅដល់ ៗ ចាំងពាថយក្រោយ បណ្ដែតបណ្ដោយ ដោយនូវកិច្ចកល
បញ្ចោតឲ្យទៅ ដល់ក្រោមមណ្ឌល នឹងគតៈពល ហោមចាប់ពិឃាដ ៗ
យក្ខយល់យក្ខបួន ឆាត់ជំមាំមួន នីរទេសគគាត ក្រអួតក្រអឺត ញញើតអង្គ
អាត្ម មោះខំពះពាត ផ្សាដោយក្រោធក្រៃ ៗ បញ្ចោតល្មុះទៅ ទាល់ទី
ឋានក្រៅ ទៀបពន្លាជ័យ ប្រែប្រាណទប់ទល់ តាំងតតេតដៃ រឹងរឹទ្ធិក្រៃ
ទាំងប្រាំប្រុតប្រុះ ៗ សព្ទគ្រេបសព្ទគ្រំ ពារភ្លុំល្អិតភ្លុំ ដោយកែដតបះ
សន្ធិញសង្ស្រក សព្ទត្សកសព្ទទះ សព្ទដំប្រហះ ប្រហារគានគ្នា ៗ
ជាញដេញជ័យដែន ហោះហាខះខែង កៀកកៀនលីលា ពារពះពលពាល
កណ្ដាលវេហាស៍ ដោយតេជរិទ្ធា ប្រាំប្រតិពល ។ ល្អិតល្អុចព្រៃព្រឹក្ស
សន្ធាប់សន្ធឹក នូវរិទ្ធិហាក់ខ្យល់ ប្រទះដំបង វារនិ៍ទប់ទល់ លោលោត
ជាញដល់ ញាប់ញ័ររញ្ជួយ ៗ ដកដើមព្រឹក្សា ដកដុំសិលា ដកភ្នំស្អុប
ស្អួយ បំបោកបំបែក សព្ទស្រែកស្បូរព្ទួយ ឈើឈរផតគ្រួយ ទ្រោម
ទ្រុឌផែនដី ៗ ដោយតេជយក្ខប្រាំ សឹងមានខមួនមាំ ស្រឹហ៍នូវសិហ៍
ប្រទះប្រទូស្ត រឹងរូសពេកក្រៃ ខន្ទយក្ខតិរ្យ ថប់ថយកម្លាំង ៗ ពីរនាក់

ចូលចាប់ ដៃទាំងពីរខ្ទប់ ពីរនាក់ធាក់ទាញ ចាប់ជើងកន្ត្រាក់ នន្ទិយក្ស
ក្រវាត់ក្រវាំង ដួលដេកបង្គ្រាំង លើមហាពសុធា ។

ឯសេះសោតសល់ ស្វាញស្អុះទៅដល់ ទីងទាំសិរសា ជើងមុខ
អស្សពង្ស ជាន់ត្រង់ទ្រូង ជើងក្រោយអស្សពាហ៍ ជាន់ក្តៅទាំងពីរ ។
ផាច់សាច់ចេញឈាម ហៀរហូរហាម របកសាច់សិរ នន្ទិយក្ស មហិ-
មាទិនទេវ បម្រះរួចពី ពាជីនោះបាន ។ ក្សណស្វាក្សណខ្វា ចោម
ទាំមិសា យក្សយង់សាមាន្យ ឥតមានបន្ទោះ សាច់ស្អុះសត្វប្រាណ មៀង
មើលមិនមាន យល់សាច់យក្ស ។ ផាច់ផាចអង្គកាយ ឈាមហូរខ្ចរខ្ចាយ
ផាច់ទាំងកាំមាំ នាសិកសិងស្អុច កំបុតសោះសា យក្សយង់វិញ រលាស់
ពានរ ។ នូវខ្ញាតិវេញ្ចន រួចពីអង្គប្រាណ ហៀរហោះទៅឈរ លើភ្នំមួយ
ធំ កាយយកដុំថ្ម ប្រមូលបានបរិ-បូណ៌ ប្លាចចុះទៅ ។ អនេកពេកពន់
បំផ្លិចពុំណា លើស្វាខ្វាក្សរ យក្សទាំងបួនសោត ក្រៅក្រោធក្តាត់ក្តៅ
ស្វាញស្អុះតាមទៅ តាំងតទល់គ្នា ។ យក្សម្នាក់រាយក ម្នាក់រាយទ្រូង
យក្សម្នាក់ម្ដងម្ហា សំពងទរទៅ ត្រូវៈក្តៅយក្ស ម្នាក់រាយជង្គ្រ ដួលដេក
ក្សណក្ស័យ ។ វិលវិងមកប-ង្គំគាល់តួជពង្ស ពោធិសត្វថៃ ថ្វាថៃងមហាទ្វី
វង្សវិជ្ជាញ្ញ័-យាយល់ចើងក្រែ លែងលោកស្ងៀងស្ងប់ ។

ស្រេចព្រះទ្រង់ស័ក្តិ ប្រោសប្រើយក្សម្នាក់ ប្រែជាមាណព ចុរ

ចូលទៅកាន់ ខេត្តខណ្ឌភិកព ថ្លែងសារសព្វគ្រប់ ដល់មន្ត្រីថា ៗ តៀត ព្រះនរេន្ទ្រ នរេស្សរធិបតេន្ទ្រ នរៈរាជា បានសម្លាប់យក្ខ អបលក្ខណ៍ មោហា ដល់ដួលមរណា ដោយតេជបារមី ៗ ឥឡូវព្រះផ្តាំ ឲ្យខ្ញុំនាំ សារសព្វសេចក្តី មកថ្វាថ្លែងថា បើមហាមន្ត្រី សេនាសេនី និកាយយោធាៗ ចិត្តចង់ចេញច្បាំង គេទៀតប្តូរតាំង ទ័ពទៅច្បាំងគ្នា ឬទៅខ្ទប់ខ្ទាប អំណាច ចេស្តា ទទួលយកជា អម្ចាស់សិរសី ៗ ប្តូរកេសាចស្រស់ នូវផល កោដនក័ស្តុ សុខសិងថ្មីៗ រៀបរៀងពីក្នុង កំឡុងបុរី លុះទៀបទីស្រី សុវណ្ណពន្ធា ៗ

មន្ត្រីចរចូល ក្រួញក្រាបទៀងទូល សម្តេចវិមលា ជួបដោយសាសាំ បណ្តាំវចា សម្តេចព្រះមហា-បុរសឧត្តមមោ ៗ នាងឮព្រះសូរ ព្រះ សារមធុរ ទ្រង់ត្រេកអរសោ មនស្សាសល់ បង់យល់អត្ថទុ សោត្ថសេ-ផ្តា បើកបន្ទូលថា ៗ

ចូរទៅប្រដាប់ រួសរៀបឆាប់ៗ នឹងឲ្យបុត្រា ចូលមកឆាប់ខ្ចី មន្ត្រី ម៉ឺមា រៀបរូបដូចជា បន្ទូលក្សត្រី ៗ រៀបរៀងមគ្គា ដល់ទីពន្ធា ព្រះ បាទនរបតី អស់អាមាត្យា អគ្គមហាសេនី សេនាធិបតី នូវរាស្ត្រប្រជា ៗ កាន់ទង់ឆត្រឆាយ ឈរឈមរៀងរាយ សង់ខាងមគ្គា តូរ្យដន្ត្រីត្រែ រងំ ហែរាជា ត្រើសព្រមប្រុងប្រា-កដកបករកាន់ ៗ

កាលណោះមហាក្សត្រ វិសេសវិវឌ្ឍន៍ វិសាលសោកណា លុះបាន ឫក្សពារ ពេលាជោគជាន់ ឆាយាយល់ស្បាន់ ប្រកបជោគជ័យ ៗ ព្រះអនុជបុត្រា គង់លើស្តេចស្វា មាននិរភ័យ បេញជាស្រួលស្រាប់ សម្តេចក្សត្រថ្ងៃ លះលៃងមនោមយ៍ គង់កក្កុណ្ឌ ៗ ឲ្យនាងបន្ទា ជិះស្តេចខ្លាជា ជំនិះជំនាន់ លើកតាមអភ័យ ទាំងបីកក្កុណ្ឌ ហត្ថាករគាន់ ក្រទាដែកដើរ ៗ នូវពានរបរ ដង្ហែក្បួរ តាមក្សត្រប្រសើរ ពានរយោធី សឹងស៊ីផ្លែឈើ តាមតែអំពើ ប្រោសប្រុងប្រាថ្នា ៗ ខ្លាឃ្មុំត្រេកត្រាប់ សោតសឹងស៊ីសាច់ ផ្អែតស្កល់ពល់គ្នា ក្សេមក្សាន្តសប្បាយ ឈោះលាយមហិមា សត្វនិមនុស្សជា មិត្រមេត្រីមូល ៗ ហេតុក្សត្រក្បួរ ប្រឡំគ្នារ ស្រុះស្រែកស្រើបស្រួល សម្តេចព្រះមហា ក្សត្រាវង្ករ លើលាលុះចូល ដល់មុខព្រះលាន ៗ ព្រះបាទក្សត្រថ្ងៃ ស្តេចឲ្យអភ័យ វេក្សាភាហាន ស្តេចយាងយាត្រា តែមហាក្សត្រក្សាន្ត នូវនាងចូលឋាន ប្រាសាទរ័ត្ន ៗ

នាងនាថយង់ឃល់ រត្នាពជបុត្រជល់ ញ៉ារថ្មើមប្រមាត់ រត់មកអាទេប ក្រះសាបបុត្ររត្ន ទាំងបីអង្គក្សត្រ សោយសន្ទប់លុង ៗ អស់ស្ទំស្រីង្គារ បរិវារបរិពារ សេនាចតុរង្គ សឹងភ័យរន្ធត់ ស្ទន់ស្ទុតឡើងឡង់ សោយសោកគ្រប់អង្គ សឹងស្ទូនស្រន្ទប់ ៗ ចាស់ជរាក្តី ទាំងប្រុសទាំងស្រី

គួចតាបតុំទប់ សោកសឹងសោយសោក វិយោគសូន្យសត្វ សូន្យឈឹង សន្ធប់ ទូទាំងមណ្ឌល ។

អកយ៍កុមារ យកនូវបរិពារ កាំងកិតក័យសល់ ឲ្យយកទូពីរផ្ទុះ ហិបហោះទៅដល់ ស្រះស្រីយង់យល់ ជង់យករូសរាន់ ។ មកស្រោចបី ក្សត្រ រូបរស់ឡើងថ្លាត់ ស្រោចអស់គ្រប់ម-ណ្ឌលទីនគរ បវរបានប-ន្ទោ ទុក្ខរូបជន្ម-ជាតិជីវិតវិញ ។

ទើបនាងវិមលា សួរពោធិ៍ថា ហៃមាសព្រលឹង កាលបារត់ទៅ ម្តាយក្តៅទ្រូងតឹង សោយសោកណាស់ទឹង កូនកែវស្ងួតស្ងៀយ ។ ឲ្យ មនុស្សដើររក សព្វជ្រោះសព្វច្រក គិរព្រឹក្សព្រៃ ប្រាំខែត្រឡប់ មក ប្រាប់ថាថ្ងៃ បាត់បង់សូន្យព្ធ ព្រៃពនាករ ។ ម្តាយសោកសន្ធប់ ស្មារតី សូន្យសត្វ យកូលោមអង្ករ ថាទៅរកទៅ ពាលពៅសន្ធរ ប្រាំពីរថ្ងៃបរ វិលមកប្រាប់ថា ។ អ្នកមាសព្រលឹង ទាំងពីរទៅពឹង ឥសីសីលា ស្មាធ៍ ស្ទឹងធ្វើព្រះ តបះគុណការ រួបរៀនសិល្បា-សាស្ត្រស៊ុះសព្វសាយ ។ ម្តាយគ្រាន់ស្រាកស្រាល ស្រាកស្រន់ស្រយាល ទុក្ខព័អង្គកាយ តែងតែ ទន្ទឹង ព្រលឹងពណ្ណរាយ បូរអ្នកប្រាប់ប្រាយ ពិតឬមុសា ។

ពង់ព្រុទ្ធង្គរ ក្រុញក្រាបទៀងទូល កាលខ្ញុំយាត្រា ពុំដឹងដោយ ផ្លែន តាមតែវាសនា សេះនាំយាត្រា ដោយព្រៃពនេចរ ប្រាំខែគត់

ស្ពាន់ យក្ខតាមទៅទាន់ សម្លាប់អស្សតរ ក្សិណក្ស័យជីវិត កាត់ក្បាល សេះស ហើយខ្ញុំពុំមរ-ណា នោះព្រោះបុណ្យ ៗ ចូលពួនអាស្រ័យ នៅក្នុងរន្ធជ្រៃ ទេព្តាមានគុណ បំបាំងបំបិទ ជិតពិតពេកពន់ បានរួចរស់ ជន្ម ព្រោះយក្ខពុំយល់ ៗ ខ្ញុំយល់សេះក្ស័យ សែនសោយសោកក្រៃ សន្ទប់សូន្យសល់ ក្ដៅដល់អាសនា ឥន្ទ្រាថ្កើងថ្កល់ ហាបហោះមកដល់ ប្រុសរស់ជន្មា ៗ ស្ដេចប្រើខ្ញុំបរ នឹងប្អូនរិះរក ក្បាលសេះព្រាហ៍ បាន ក្បាលកជសីហ៍ ទើបក្ស័យជន្មា ថ្វាត់ថ្វាយឥន្ទ្រា ប្រោសប្រុសអស្សយាន ៗ ទើបក្សត្រកុជរ ប្រទានឱ្យពរ ទាំង៤ថ្កើងថ្កាន តាំងពីកាលនោះសេះហោះ ទៅបាន ទៅនៅនាឋាន ហេមន្តនគរ ៗ ស្រុកនោះស្ងប់ស្ងាត់ ព្រោះដ្បិត មានសត្វ ឥន្ទ្រិយ៍មោហា ទាំងឈ្មោលទាំងញី មកស៊ីមនុស្សម្នា ជ្រូកក្ដាន់ មាន់ទា ឆ្កែឆ្មាក្សិណក្ស័យ ៗ ឯក្សត្រវង្ស ទូលពីបំណង អនុជថ្លាថ្លៃ ប្រើ ព្រះកុជរ ចេរចរទៅព្រៃ មានយក្ខិនីភ័យ នូវស្វានីងខ្វា ៗ ស្ដេចពុំ ទូលពី កំបុកចរទៅ សម្លាប់ក្សត្រា ទើបពុទ្ធង្កូរ ទៀងទូលទៀតថា សូមទ្រង់មេត្តា ខ្ញុំយល់ឆ្គងក្រៃ ៗ ដ្បិតមានរាជបុត្រ ក្សត្រាវិសុទ្ធ រូប រាងល្មមល្អ សន្មតនាមហៅ នោះហៅអភ័យ កុមារចិត្តល្អ កើតសុវណ្ណ ៗ ខ្ញុំយល់ឧត្តម រូបរាងសក្តិសម នឹងព្រះប្អូនស្រី ផ្សែផ្សំផ្សប់ផ្សះ ជាប្រ ពន្ធប្ដី ពុំចេះប្រណី ប្រោសប្រាណមេត្តា ៗ ឥឡូវខ្ញុំផ្ដាំ ឲ្យនៅថា

ទាហានសេនា បើទ្រង់ប្រាណប្រោស អត់ទោសករុណា នឹងឲ្យយាត្រា ចូលមកបង្គំ ។

នាងស្តាប់ពន្យពោល ផិតសត្វអង្គុឌ-រសេវត្នសានសម ដែងផោយអាថ៌ អស់ សោមនស្សមនោរម្យ ត្រាស់ថាកូនកុំ-គិតគោតមាតា ។ ចូរកូន ពាលពៅ អ្នកឲ្យទៅហៅ ប្តីនាងចន្ទា ឥឡូវឆាប់ៗ ប្រញាប់មម្ចា អាល ឲ្យមាតា យន់យល់កក្រុផង ។ ពោធិសត្វថៃ ឲ្យហៅអភ័យ ចូល ទៅពុំផ្សង ថ្វាត់ថ្វាយបង្គំ ប្រណម្យាំបរង មាតាច្បាស់ច្បង នូវព្រះ ដេផ្កា ។

នាងនាងយន់យល់ រូបរាងនិមល សួនសក្តិសមគ្នា សរសើរពោ-ធិ សត្វវិសេសសារ-ពេជ្ឈពន្យព្ធា ទកូនទត្តម ។ បេះផ្សំប្អូនស្រី ឲ្យ មានស្វាមី អភិរូបអភិរម្យ ល្អាក់ល្អមនិងខ្លួន សក្តិសួនស្មស័សម ទអង្គ អញអំ ណរនឹងអ្នកណាស់ ។ ឯអង្គមាយយល់ ដួរជាតិទុពិល ប្រាកដ កេរ្តិ៍ច្បាស់ ដូចស្រីអបលក្ខ ដួរជាតិជៀងផាស មកមានទោសទាស់ ពុំពេញស្រិលស្រី ។ គិតគួរតែស្លាប់ ទៅវិញពេញគាប់ នៅនាលោកីយ៍ បំណាច់បង់បោ កើតកេរ្តិ៍អប្រិយ៍ ពុំដូចស្រិលស្រី ទាំងឡាយនោះសោតៗ

កាលណោះព្រះភូ-ធរាជពិស្ណុ ត្រកូលជាតិជោគ ទៀងទើបសម្តេច

(មានត)

# រឿងសាមកុក

## ភាគទី ២៩

ឧកញ៉ាវិបុលរាជសេនា ញ៉ុក-ថែម ប្រែរៀបរៀង

(តមកពីលេខ ១២ ឆ្នាំ ១៩៥៧)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ចំណែក អួនថាំក៏លើកកងទ័ព ត្រឡប់ទៅស្រុកពេងង្វនគួនវិញ ។ គួ ទៅនិយាយនឹងអួនថាំថា ដែលចូននឹងលើកបុត្រីឲ្យជាភរិយានៃលោកនោះ ខ្ញុំបាទយល់ថា មិនមែនដូចពាក្យថាទេ ឥឡូវចូនតាំងលើកផង លើសៀង ជានាយទាហាន ហើយយកទុកប្រើការផងនោះ ឃើញថា ចូន ក្លែងឧបាយ លើកដំកើង ដើម្បីឲ្យចូលចិត្តគិតធ្វើការឲ្យស្មោះត្រង់ ដែលចូនប្រើឧបាយដូច្នេះ ឧបមាដូចគៀងត្រីបញ្ចូលលប បើលោកជឿចិត្តចូនហើយ ខ្ញុំបាទយល់ឃើញថា ខ្លួនលោក នឹងរកណាខែត្រខាងទិសឧត្តរនោះ នឹងមាន

អន្តរាយផ្សេង ៗ ដោយអំណាចកលឧបាយប្អូនជាប្រាកដ សូមឲ្យលោកធ្វើគ្រាសម្រាប់នាយទាហាន ២ ដួង ឲ្យអ្នកបំរើយកទៅឲ្យលីកង លីសៀង ហើយផ្ដាំជាសេចក្ដីស្ងាត់ថា ឲ្យលីកង លីសៀងគិតនឹកដល់លោកកុំភ្លេច កុំឲ្យប្រែចិត្តទៅចូលខាងប្អូន បើប្អូនលើកកងទ័ពទៅវាយអួនស៊ុងហើយ ឲ្យលីកង លីសៀង ធ្វើជាកលសឹក បើបានការវេលាណា ឲ្យ ៗ ដំណឹងមកយើង ៗ នឹងលើកចូលទៅធ្វើប្រទូស្តរ៉ាយ ប្អូន វេលានោះ ។

អួនថាំយល់ឃើញត្រូវ ក៏ឲ្យធ្វើគ្រា ២ ដួង ហើយ ប្រគល់ឲ្យអ្នកបំ-រើនាំទៅឲ្យជាការស្ងាត់ ដល់លីកង លីសៀង តាមពាក្យអួនថាំបង្គាប់ៗ លីកង លីសៀងខ្លាចមិនរួចខុស ទើបធ្វើជាយកគ្រានោះទៅឲ្យប្អូនមើលថា អួនថាំផ្ញើមកឲ្យ តែខសេចក្ដីឯទៀតនោះ មិនបាននិយាយប្រាប់ឲ្យប្អូស់ ៗ ប្អូនឃើញគ្រាដួងនោះក៏ថា អួនថាំធ្វើគ្រាមកឲ្យជាសម្រាប់ការនាយទាហានដល់អ្នកទាំង ២ នេះ ព្រោះអួនថាំគិតនឹងប្រទូស្តរ៉ាយយើង ប្រាថ្នានឹងឲ្យអ្នកទាំង ២ ធ្វើជាកលសឹកខាងក្នុង អ្នកប្ដូរទទួលយកគ្រាទាំង ២ នេះទុកបុះ សេចក្ដីដែលអួនថាំផ្ដាំមកល្អ អាក្រក់ប្រការម្ដេច អ្នកត្រូវតែផ្ដាំទៅវិញថា បានទទួលធ្វើតាមទាំងអស់ បើយើងលើកកងទ័ព ទៅកំចាត់អួនស៊ុងចេញ ហើយយើងនឹងលើកទៅសម្លាប់អួនថាំទៀតៗលីកង លីសៀងឃើញសេចក្ដី

គិតរបស់ចូឆូក្នុងជីជង្ហោះ ក៏ឲ្យទឹកខ្ទាបក្រែងចូឆូជីងដល់ មិនបានទំ-
យាយប្រាប់អ្នកបំរើអួនថាប្រការម្តេចសោះ ។

ឯអួនសុងជីងថា ចូឆូឲ្យជីកព្រែកដូង្ហោះ ក៏ប្រឹក្សានឹងសឹមផោយថា ដែលចូឆូ
គិតធ្វើការដូច្នេះ ប្រាថ្នានឹងបញ្ជូនស្បៀងអាហារទៅមកដោយស្រួល អ្នក
នឹងគិតការពារដូចម្តេច ? ។ សឹមផោយឆ្លើយថា ឲ្យលោកមានសំបុត្រទៅ
ដល់អ៊ិនកៃទៅហ្វាយស្រុកប៊ូអ៊ន ដែលបំណុះស្រុកយើង ឲ្យលើកកងទ័ព
មកតាំងនៅដែនស្រុក ម៉ះសៀ ហើយឲ្យចងគី ដែលទៅនាំស្បៀងពីស្រុក
សៀងតុងនោះ ឲ្យលើកទាហានមកតាំងនៅដែនស្រុកហ៊ានតន់ ទើប
ចូឆូនឹងមិនអាចលើកចូលមកវាយ យកស្រុកគីជីវបាន ព្រោះខ្លាចទ័ពទាំង
២ អន្លើនេះទង្គ្រលុកមកពីក្រោយ ឯលោកត្រូវលើកកងទ័ព ទៅវាយ
ស្រុកពេងជួនគួន បើបានហើយទើបលើកកងទ័ពមកបញ្ចូលគ្នា នឹងកងទ័ព
ទាំង ២ ស្រុកនោះ លើកទៅបោមព័ទ្ធវាយកងទ័ពចូឆូ ក៏នឹងបែកបានដោយ
ងាយ អួនសុងបានស្តាប់ហើយយល់ឃើញថាត្រូវ ក៏ធ្វើសំបុត្រទៅដល់
ខែត្រទាំង ២ ឲ្យលើកកងទ័ពទៅតាំង តាមពាក្យសឹមផោយនិយាយ
ហើយឲ្យគិនលឹមនឹងសឹមផោយនៅរក្សាស្រុក អួនសុងប្រមូលទាហាន
បានព្រមស្រេចហើយ ក៏ប្រើម៉ាអៀននឹងទៀវគី ជានាយទ័ពមុខ លើក
ទៅវាយយកស្រុកពេងជួនគួន ។

អួនថាំដឹងដំណឹងថា អួនសុងលើកទ័ពមក ក៏ធ្វើសំបុត្រចាត់បំរើឲ្យនាំទៅឲ្យប្អូនលើកទ័ពទៅជួយ ។ ប្អូនឃើញសំបុត្រដូច្នោះ ក៏ថា ស្រុកគីដាវគ្រានេះ នឹងបានដល់យើងជាប្រាកដ ។

ខណៈនោះ ទទួលខៅហ៊ីវមកពីក្រុងហ៊ូតោ បានដឹងដំណឹងថា អួនសុងលើកទ័ពទៅច្បាំងនឹងអួនថាំ ឯស្រុកពេងង្ហួនគួន ខៅហ៊ីវក៏និយាយនឹងប្អូនថា ហេតុម្តេចបានជាលោកមកសម្ងំនៅស្ងៀមដូច្នេះ នឹងចាំឲ្យរន្ទះបាញ់អួនថាំនឹងអួនសុងស្លាប់ឯងៗ ទើបទៅយកស្រុកគីដាវ ឬអ្វី ប្អូនឮហើយ ក៏អស់សំណើច ហើយនិយាយថា អ្នកកុំគិតក្តីឡើយ យើងគិតការទុកជាស្រេចអស់ហើយ ទើបប្រើចាហាងលើកទាហានទៅវាយស្រុកគីដាវ ឯប្អូននោះ ក៏លើកកងទ័ពទៅវាយអ៊ិនកៃ ដែលតាំងទ័ពនៅដែនស្រុកម៉ីសៀ ។

ឯអ៊ិនកៃឃើញប្អូនលើកទ័ពមក ក៏ឡើងសេះលើកទាហានចេញទៅឈរនៅមុខបន្ទាយ ។ ប្អូនក៏ប្រើខៅឆ្លួលច្បាំងនឹងអ៊ិនកៃបាន ៤ ក្បុង ខៅជួយកងួនចាក់អ៊ិនកៃធ្លាក់ពីលើសេះស្លាប់ ។ ទាហានអ៊ិនកៃក៏របួសពិការស្លាប់ជាច្រើន ណាដែលនៅរស់ ក៏រត់ចូលទៅខាងទ័ពប្អូនខ្លះៗ ប្អូនឃើញចំណាប់ ក៏លើកទ័ពទៅវាយបងគី ដែលតាំងបន្ទាយនៅដែនស្រុកហ័នគ័នទៀត ។ បងគីឃើញប្អូនលើកទ័ពមក ក៏ឡើងសេះនាំទាហាន

ចេញទៅឈរនៅមុខបន្ទាយ ទៀវលៀវសូមអាសាបរសេះពាំនួនចេញទៅ ប្រាំងនឹងបង្គីបាន ៣ ភ្លេង បង្គីទ្រាំនឹងកំឡាំងទៀវលៀវមិនបាន ក៏បរសេះថយរត់ ទៀវលៀវបួលការប់ទំលាយបន្ទាយ សម្លាប់ទាហានបង្គីស្លាប់អស់ជាច្រើន ហើយបរសេះដេញតាមទៅ យកដំបាញ់ត្រូវបង្គីធ្លាក់ពីលើសេះស្លាប់ ខណៈនោះ ទាហានបុឆ្កក៏ចាប់ទាហានបង្គីបានទុកជាច្រើន ហើយបុឆ្កក៏លើកទ័ពស្រួតទៅបញ្ចូលគ្នា នឹងទ័ពបោហង ឲ្យតាំងបន្ទាយព័ទ្ធទ្រាមស្រុកទុកជុំវិញ ហើយក៏ឲ្យទាហានជញ្ជូនយកអាចម៍ដី មកគរជាពំនូកខ្ពស់ឡើង ស្មើនឹងកំពែងស្រុក ហើយឲ្យដកខ្មុញបិតនឹងឲ្យផ្ទុះចូលទៅក្នុងស្រុក ឯសឹមដោយទឹងតនលិម ឃើញបុឆ្កលើកកងទ័ពមកឡោមព័ទ្ធជុំវិញស្រុក ប្រឹងទំជាមាំមួនដូច្នោះ ក៏ត្រួតត្រាមន្ទីរសើនបន្ទាយឲ្យការពាររក្សាជាមាំមួន ។

ខណៈនោះ ប៉ាំងឡេជានាយទាហានរក្សាគយទិសខាងកើត ផឹកស្រាស្រវឹងដេកលក់ទៅ មិនបានបង្គាប់បញ្ជាត្រួតទាហាន ឲ្យយាមល្បាតរក្សាសើនជាមាំមួនរសោះ សឹមដោយទៅត្រួតមើលឃើញដូច្នោះ ក៏ខឹងណាស់ឲ្យចាប់យកខ្លួនប៉ាំងឡេទៅវាយជាច្រើន ប៉ាំងឡេបានសេចក្ដីក្ដៅក្រហាយចិត្តខាំងណាស់ លុះពេលយប់ក៏លបរត់ចេញ ទៅចូលខាងកងទ័ពបុឆ្ក ហើយយកសេចក្ដីដែលមានចិត្តឈឺក្ដៅនោះ ទៅប្រាប់ឲ្យបុឆ្កស្ដាប់គ្រប់ប្រការ ។

ចូចដឹងដូច្នោះក៏ទទួលអំណរសាទរ ទើបនិយាយថា ខ្ញុំអ្នកឯងនៅក្នុងស្រុកនោះ បានឃើញការផ្លូវស្រោលម្តេចៗទាំងអស់ នឹងឲ្យយើងធ្វើប្រការម្តេច ទើបនឹងបានស្រុកនេះដោយឆាប់ៗ ប៉ាំងទៀវឆ្លើយថា ខាងកំពែងបន្ទាយទិសខាងកើតនោះ ខ្ញុំបាទឃើញដីនោះ រឹងមាំមួនណាស់ សូមលោកដឹកទម្ពចូលទៅ ហើយទំលុះឡើងចំកណ្តាលស្រុក រួចឲ្យទាហានទាំងពួងស្ទុះឡើងធ្វើការ ក៏នឹងបានស្រុកដោយងាយៗ ចូចយល់ឃើញត្រូវ ក៏កេណ្ឌទាហាន ៥ រយ ឲ្យប៉ាំងទៀវនាំទៅដឹកទម្ពទិសខាងកើត តែក្នុងពេលយប់ឲ្យផ្ទុះហូតទៅបាន លុះពេលយប់ ប៉ាំងទៀវក៏លើកទាហានឆ្ពងទ្វារស្រុក ចូលទៅដឹកទម្ពជាប្រួលប្រូបល់ ៗ

សឹមដោយដឹងថា ប៉ាំងទៀវកៀកទៅចូលខាងចូច ក៏ឡើងត្រួតត្រាការបង្គាប់បញ្ជាទាហានឲ្យរក្សាទីសើនបន្ទាយ ដាក់វេនយាមល្បាតកុំឲ្យធ្វេសប្រហែស ៗ ក្នុងពេលយប់នោះ សឹមដោយ ក៏ទៅលើសើនទិសខាងកើតនោះ ពួកទាហាន ដែលយាមល្បាតបានដឹងការ ក៏ទៅជំរាបសឹមដោយថា បន្ទាយត្រង់ទ្វារ ដែលចេញទៅនោះឃើញងងិតប៉ុកណាស់ ប្រហែលជាសត្រូវនឹងគិតធ្វើការអ្វីក៏មិនដឹងៗ សឹមដោយបានឮក៏ក្រឡេកមើលទៅ ឃើញដូចពាក្យទាហាននិយាយ ហើយថា ដែលបន្ទាយនៅទីនោះងងិតដូច្នេះ ប្រហែលជាគាប៉ាំងទៀវលើកទាហានគាសាចូចដឹកទម្ព នឹងឲ្យផ្ទុះហូតមក

ក្នុងស្រុកទេដឹង ៗ ស៊ីមដោយក៏ចាត់ប្រើទាហាន ដែលមានកំឡាំង ឲ្យជញ្ជូនយកដុំថ្មមកគរទុក ត្រង់មាត់ទ្វារជាច្រើន ហើយឲ្យបើកទ្វារចំហរ បង្ខំឲ្យទាហានជញ្ជូនដុំថ្មទៅទម្លាក់បិទ នៅមាត់រណ្ដៅទម្ពង់ ឲ្យពេញណែនកុំឲ្យខ្យល់ចូលបាន លុះជញ្ជូនរួចក៏ឲ្យទាហានវិលចូលមក ក្នុងស្រុកវិញ ៗ ទាហានប៉ុន្មានដែលបាំងទៀននាំទៅជីកទម្ពង់ដីនោះ ទៀងមកវិញមិនរួច ខ្យល់ក៏ចេញចូលមិនបាន ក៏ថប់ដង្ហើមដាច់ខ្យល់ស្លាប់ទាំងអស់ នៅក្នុងដីនោះ ៗ លុះព្រឹកឡើង ទាហានទៅជំរាបប៉ូឆថា មាត់រណ្ដៅទម្ពង់នោះ មានថ្មបិទជិតទាំងអស់ ៗ ប៉ូឆព្រួយព្រោះគិតគិតថា ការដែលជីកទម្ពង់នោះ មានគេដឹងដល់ បានជាឲ្យមនុស្សជញ្ជូនដុំថ្ម ទៅបិទសន្ធប់មាត់រណ្ដៅ ទាហានយើងក៏ស្លាប់ទាំងអស់ តាំងពីនោះមក ប៉ូឆមិនបានគិតជីកទម្ពង់ទៀតឡើយ ហើយលើកបន្ទាយដែលព័ទ្ធស្រុកនោះចេញទៅទាំងអស់ ថយទៅតាំងទ័ពនៅតំបន់អូនស៊ុយ ប្រាថ្នានឹងចាំទទួលច្បាំងនឹងកងទ័ពអូនស៊ុង ៗ

ឯអូនស៊ុងកាលដែលលើកទ័ព ទៅឡោមព័ទ្ធស្រុកពេងង៉ួនគួននោះ មានបំរើសេះម្នាក់ទៅប្រាប់ដំណឹងថា ប៉ូឆនឹងលើកកងទ័ពមកសម្លាប់អ៊ិនកែនឹងបងគីស្លាប់អស់ហើយ ត្រូវលើកទៅឡោមព័ទ្ធស្រុកគីជីវទៀត អូនស៊ុងដឹងដូច្នោះ ក៏ឲ្យលើកទ័ពត្រឡប់ទៅវិញ ។ ម៉ាអៀនតបថា ដែលលោកនឹងលើកកងទ័ពត្រឡប់ទៅតាមផ្លូវហ្នឹងនោះ ខ្ញុំបាទយល់ឃើញថា ប៉ូឆ

នឹងឲ្យទាហានមកចាំស្កាត់កណ្ដាលផ្លូវ សូមឲ្យលោកលើកកងទ័ពគាត់ទៅផ្លូវក្នុងខាងលិចវិញ បើទៅដល់ទន្លេបេកតុក ហើយនឹងបានវាយយកស្បៀងដែលដញ្ជូនទៅឲ្យប្អូននោះផង កងទ័ពប្អូនក៏នឹងដាច់ស្បៀងអាហារ សោះទាហានទាំងនោះក៏នឹងអត់ឃ្លាន មុខជាប្អូននឹងលើកទ័ពត្រឡប់ទៅវិញ ទោះបើនឹងតាំងនៅ ទាហានទាំងអម្បាលនោះ ក៏អស់ស្បៀងអាហារ ហើយយើងក៏នឹងបានធ្វើការបម្បាំង ដោយងាយ ៗ អ្នកសុងយល់ឃើញត្រូវផង ក៏ប្រើឲ្យម៉ាអៀននឹងទៀវគី លើកទាហានការពារទៅជាក្រោយ ហើយអ្នកសុងក៏លើកកងទ័ពគាត់ដម្រង់ ទៅផ្លូវក្នុងទិសខាងលិច ៗ

បំរើសេះប្អូនជីងផ្ទោះ ក៏ស្រូតនាំសេចក្ដីនោះ ទៅប្រាប់ប្អូនគ្រប់ប្រការ ប្អូនឮហើយក៏និយាយនឹងទីប្រឹក្សាទាំងពួងថា " យើងខ្លាចក្រែងតែអ្នកសុងនឹងលើកទ័ពមកតាមផ្លូវហាង ព្រោះកងទ័ពយើងស្ពឹងស្គូចបែកខ្ចកអស់ទៅហើយ ត្រឡប់អ្នកសុងលើកមកតាមផ្លូវទិសឯលិចវិញ យើងនឹងរិះគិត ចាប់យកខ្លួនអ្នកសុងឲ្យបាន ព្រោះហេតុថា អ្នកសុងលើកទ័ពមកដល់ទីងងុតភ្លើងឲ្យឆេះឡើង ឲ្យទាហានដែលនៅក្នុងស្រុកនោះ ឃើញជាសំគាល់ ហើយនឹងបានលើកទ័ពវាយខ្ទប់ទ័ព យើងបេញមក យើងចាំកេណ្ឌទាហានជា ៤ កង ឲ្យលើកទៅចាំបង្កាំង គឺនឹងអ្នកសុង ១ កង ,

☛ (អានត)

# ចៅពាយក្តាំង

## លោក ទៀង-តៃ-ឈុន

ក្រុមការដើមខ្សែលេខ ១

ប្រែរៀបរៀង

(តមកពីលេខ ១២ ឆ្នាំ១៩៤៧)

---

ឯយើងខ្ញុំ ត្រូវបុះគ្រាំទឹកចំនួនបីថ្ងៃ មុននឹងចូលទៅក្នុងព្រះរាជអាណាចក្រនៃព្រះបរមរាជបិតា ដែលជាទីគោរពរបស់យើងខ្ញុំ ។

ចៅបាយក្តាំងចូលទៅតួន ក្នុងរូងដើមឈើ តាមទំនងនៃនាគទាំងពីរ ។ ក៏បុះគ្រាំទឹកបីងចំនួន ៣ ថ្ងៃ ។ កាលណោះ, ព្រះបាទភូជង្គ ដែលជាព្រះបរមរាជបិតា ក្តៅក្រហល់ក្រហាយនឹងគង់នៅ ក្នុងព្រះបរមរាជវាំងពុំបាន ។ ព្រះអង្គទ្រង់ប្រមូលមហេសី និងរាជ្ជមន្ត្រីទាំងអស់មកប្រាប់ថា ព្រះអង្គនឹងយាងទៅបេះផ្កា និងផ្លែឈើក្នុងព្រៃ ឲ្យសប្បាយព្រមទាំងរត់ប្រឡែងលេងក្នុងបឹង ។

ដូច្នេះ, ព្រះបាទភូជង្គ, ព្រះជាយាទាំងឡាយនិងក្រុមព្រះរាជវាំង បានយាងចេញពីព្រះបរមរាជវាំង ទៅក្នុងព្រៃទទ្បាន ដោយបំណងនឹងបេះផ្កា និងផ្លែឈើ ឲ្យបានសប្បាយដោយសុខសាន្ត ។ បន្ទាប់មក, ព្រះអង្គទឹង

បរិវារយានទៅដល់បឹង ។ ពួកមហេសីនិងបរិចារព្រមទាំងព្រះរាជបំរើ បានចុះទៅងូតទឹក ។ ព្រះបាទកូដង្គទ្រង់គង់នៅលើមាត់បឹង ទតមើលអ្នកទាំងអស់ រត់លេងប្រទេរងគ្នាក្នុងទឹក ។

កូននាគទាំងពីរគិតគ្នាថា: យើងយកស្លឹកឈូកមកគ្របលើក្បាល ដើម្បីកុំឲ្យព្រះបរមរាជបិតាទតឃើញយើង។ យើងនឹងបង្ហាញមុខ ក្នុងកាលដែលយើងឮព្រះបរមរាជបិតា មានព្រះទ័យចង់ជ្រាបរឿងយ៉ាងៗ ។

បន្ទាប់មក, នាគបងបានឃើញព្រះអគ្គមហេសីទីមួយ នៃព្រះបាទកូដង្គ ក៏យកកន្ទុយកាវជើងទាញមក ។

ព្រះអគ្គមហេសីទ្រង់ភ្ញាក់ហើយស្រែកថា: អ្នកណាមានចិត្តក្លាហាន ហ៊ានចាប់ជើងអញទាញដូច្នេះ? ។

នៅពេលនោះ កូននាគទាំងពីរបែកស្លឹកឈូកចេញ ហើយបង្ហាញមុខៗ ព្រះបាទកូដង្គកាលទតឃើញហើយ សួរទៅកូននាគថា: នែអ្នកពីរនាក់អ្នកឯងជាអ្វី ដែលមានទ្រង់ទ្រាយ ដូចជានាគនិងនាគី, មកពីណាទៅណា? ឪពុកម្តាយឯងឈ្មោះអ្វី? សេចក្តីក្លៀវក្លារបស់ឯងយ៉ាងណា បានតែហ៊ានចុះក្រាំទឹកក្នុងបឹងយើង? . ហេតុដូចម្តេច បានជាហ៊ានចាប់ជើងអគ្គ-មហេសីអញ ទាញលេងជាល្បែងនៅក្នុងទឹក? ពិតមែនហើយ , សេចក្តីព្រះហ៊ានរបស់ឯង អស្ចារ្យណាស់! ។

កូននាគទាំងពីរ ដែលជាព្រះរាជបុត្រឆ្លើយថា: យើងជាព្រះរាជបុត្រនៃព្រះបាទភូជង្គ ដែលសោយរាជសម្បត្តិ នៅក្នុងព្រះរាជអាណាចក្របាតាល (Pàtàla) ។

ព្រះមហាក្សត្រឮហើយ ទ្រង់ព្រះចិន្តាថា "អញគ្មានកូនទេ, ហើយគ្មានអ្នកណាមួយ ធ្លាប់និយាយបោកប្រាសយ៉ាងនេះសោះ, ចំឡែកតែកូននាគទាំងពីរនេះ ដែលបានពោលអះអាងអម្បាញ់មិញថា ខ្លួនជាកូនអញ គួរឲ្យឆ្ងល់ណាស់ ? ។

បន្ទាប់មក ព្រះបាទភូជង្គទ្រង់មានព្រះបន្ទូលហៅព្រះរាជបុត្រថា : ឯងមកច្បាំងនឹងអញ ។ កុំពេញចិត្តតែនិយាយកុហក ក្រៅពីតយុទ្ធគ្នា ហើយកៀសខ្លួនក្នុងបឹង ។

នាគបងកាលបើឮព្រះបរមរាជបិតា ទ្រង់ហៅខ្លួនទៅវាយគ្នា ក៏ឆ្លើយទៅវិញថា: បើព្រះអង្គសព្វព្រះរាជហឫទ័យដូច្នោះ យើងក៏ព្រមវាយគ្នាដែរ ។

តពីចម្លើយនេះ នាគបងងាកមកផ្ដាំនាគប្អូនថា: នែនាគប្អូន! នាងប្អូនចាំបងនៅត្រង់កន្លែងនេះ នៅពេលដែលបងឡើងទៅច្បាំង ។

នាគបងឡើងពីបឹង ដោយព្រមតយុទ្ធនឹងព្រះបរមរាជបិតា ។ លុះប្រយុទ្ធគ្នាបន្តិចមក មិនចាញ់មិនឈ្នះ,ព្រះបាទភូជង្គទ្រង់ឈប់សួរទៅគូសត្រូវថា:នែនាគកុមារ! ឯងនិយាយថា កូនអ្នកណា? ។ នាគកុមារឆ្លើយ

ថា៖ ទូលព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រនៃព្រះបាទភូជង្គ ។

ព្រះបាទភូជង្គទ្រង់មានព្រះបន្ទូលថា៖ នែនាគកុមារ, ប្រយុទ្ធលើដី, កម្លាំងយើងស្មើគ្នា, បើដូច្នោះ យើងឡើងទៅប្រយុទ្ធលើអាកាស ។

នាគកុមារឆ្លើយថា៖ យើងទៅ ។

តពីម្លើយនេះមក, នាគបងផ្តាំនាគប្អូនថា៖ ប្អូនឯងកុំបារម្ភឲ្យសោះ, ចាំបងនៅទីនេះឲ្យសុខសាន្ត ។

នាគកុមារហោះទៅអាកាស ។ ព្រះបាទភូជង្គទ្រង់សួរថា៖ ឯងមានធ្នូព្រួញ ឬទេ? ។ បើទូលព្រះបង្គំជាខ្ញុំបងបាន១ក្លាម ។

គូសត្រូវទាំងពីរចាប់ផ្តើមច្បាំងគ្នាទៅទៀត ។

ព្រះមហាក្សត្របាញ់ព្រួញមួយទៅ ព្រួញនោះប្រែក្លាយទៅជាដែក ដែលបរកោគបាន ។ នាគកុមារបាញ់ព្រួញមួយទៅវិញ, ប៉ុន្តែព្រួញនោះប្រែក្លាយទៅជាផ្កា ។ គូសត្រូវទាំងពីរប្រយុទ្ធដូច្នេះ លុះត្រាតែហត់ដង្ហក់ អស់កម្លាំងរៀងខ្លួន ។

កាលបើផ្តើមច្បាំងទៅអស់កម្លាំងខ្លាំងពេក ព្រមទាំងមិនចាញ់មិនឈ្នះ ព្រះបាទភូជង្គទ្រង់ហៅនាគកុមារឲ្យចុះទៅដី ។ ព្រះអង្គទ្រង់ធុញណាស់, ព្រោះព្រះអង្គទ្រង់ធ្លាប់ច្បាំង ច្រើនលើកច្រើនគ្រាមកហើយ មិនដែលដូច្នេះសោះ ។

ព្រះអង្គទ្រង់សួរទៅនាគកុមារម្ដងទៀតថា៖ នែកូននាគ ! ឯងប្រាប់អញឲ្យពិតប្រាកដមើល តើឪពុកឯងជាអ្វី ? ។

នាគកុមារឆ្លើយថា៖ ព្រះបរមរាជបិតារបស់ទូលព្រះបង្គំជាខ្ញុំ គឺព្រះបាទកូដង្គ, ដែលគង់នៅ ក្នុងព្រះរាជអាណាចក្របាតាល ។ កាលណោះ ព្រះមាតាទូលព្រះបង្គំជាខ្ញុំ យាងទៅក្រសាលក្នុងព្រៃ ទ្រង់ប្រសូតទូលព្រះបង្គំជាខ្ញុំ នៅលើផែនដីមនុស្សលោក ហើយព្រះមាតាបោលទូលព្រះបង្គំជាខ្ញុំនឹងនាគីប្អូននៅទីនោះ ។ ឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំទាំងពីរនាក់បងប្អូនបានធំមាំមួនហើយ ក៏ដើរស្វែងរកព្រះបរមរាជបិតា ។

លុះហើយ, ព្រះបាទកូដង្គទ្រង់ឆ្ងល់យ៉ាងក្រៃលែង ឥតឧបមា ។ ព្រះអង្គទ្រង់ហៅមហេសីទាំងអស់ ហើយទ្រង់សាកសួរ ៗ ព្រះជាយាទាំងអស់ឆ្លើយថា គ្មានបានប្រសូតឡើយ, នៅសល់តែព្រះនាងពៅ ដែលជាមហេសីទីពីរ ។ ព្រះអង្គទ្រង់សួរព្រះនាងពៅ ៗ ឆ្លើយថា៖ ឱវេលានេះ ជាពេលចុងបំផុតរបស់ខ្ញុំម្ចាស់, ដូច្នេះ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសអនុគ្រោះដល់ខ្ញុំម្ចាស់ផង, ព្រោះខ្ញុំម្ចាស់ប្រសូតបុត្រមែន, ដ្បិតកាលដែលខ្ញុំម្ចាស់ទៅលេងក្នុងព្រៃ នៅឋានមនុស្សលោក, ស្រាប់តែខ្ញុំម្ចាស់ឈឺពោះយ៉ាងខ្លាំង ហើយសម្រាលស៊ុតពីរ ទុកបោលក្នុងព្រៃនោះ ដោយខ្ញុំម្ចាស់ខ្លាចព្រះអង្គយកទោស ខ្ញុំម្ចាស់ក៏មិនហ៊ានក្រាបទូលព្រះអង្គ អំពីរឿងនេះ ។

កាលបើ ព្រះបាទកុសន្តទ្រង់ព្រះសណ្ដាប់រឿងរ៉ាវ ដូចខាងលើនេះ ហើយព្រះអង្គទ្រង់ព្រះកន្សែង ហើយមានព្រះបន្ទូលថា: ឱ កូនជាទីស្នេហា ! ឪពុកមិនបានស្គាល់កូនសោះ ។

ព្រះអង្គទ្រង់មានព្រះបន្ទូលទៅកាន់កូននាគប្បងថែមទៀតថា: ឱកូន! បើបិតាមានតែសង្ស័យបន្តិចបន្តួច, បិតាមិនបង្ខំកូនឲ្យធ្វើចម្បាំង ដ៏លំបាកដែលនាំឲ្យកូនអស់កម្លាំង យ៉ាងក្រៃលែងនេះទេ ។

ព្រះបាទកុសន្តទ្រង់ឈប់សំដែងសេចក្ដីសោក ហើយទ្រង់នាំព្រះរាជបុត្រទាំងពីរព្រះអង្គ ទៅដល់ព្រះបរមរាជវាំង ហើយទ្រង់មានព្រះឱង្ការបង្គាប់ឲ្យរៀបអាហារថ្វាយសោយ ដើម្បីឲ្យព្រះរាជបុត្រមានកម្លាំងឡើងវិញ ។

ព្រះរាជបុត្រទាំងពីរទតឃើញថា: ព្រះបរមរាជបិតាមានព្រះចិន្តាស្រួលហើយ, ទ្រង់អង្វរព្រះបរមរាជបិតាថា: ទូលព្រះបង្គំជាខ្ញុំសូមអនុគ្រោះពព្រះអង្គមួយ ហើយសូមព្រះអង្គទ្រង់មេត្តាប្រោសអនុញ្ញាត ឲ្យទូលព្រះបង្គំជាខ្ញុំ សំដែងនូវអនុគ្រោះនេះ ។

- និយាយចុះកូន ជាទីស្នេហា! កាលដែលកូននៅក្នុងឋានមនុស្សលោក, កូនគ្មានឪពុកទេ ។ ឥឡូវនេះ កូនមកដល់ក្នុងព្រះរាជអាណាចក្ររបស់ឪពុកហើយ , បើកូនចង់បានរបស់អ្វី , កូននឹងបានទាំងអស់ តាមបំណងឲ្យតែកូនប្រាប់ឪពុកឲ្យដឹងពីចំណង់របស់កូន ។

បន្ទាប់មក, កូននាគទាំងពីរ និយាយទៅកាន់ព្រះបរមរាជបិតាថា: កាលដែលទូលព្រះបង្គំជាខ្ញុំ នៅក្នុងឋានមនុស្ស, មានបុរសម្នាក់, ពិតមែនតែក្រលំបាកគោកយាកខ្លាំង តែបានជួយទំនុកបម្រុងទូលព្រះបង្គំជាខ្ញុំអស់ទំហឹង ។ ទូលព្រះបង្គំជាខ្ញុំ ត្រូវសងគុណបុរសនេះ អស់មួយជីវិត. ព្រោះគាត់ចិញ្ចឹមថែរក្សាគ្រប់គ្រង ទូលព្រះបង្គំជាខ្ញុំទាំងពីរនាក់ តាំងពីចេញចាកព្រះទ្វារមក លុះត្រាតែបានធំមាំមួនឡើង ។ បើគ្មានបុរសនេះ,ទូលព្រះបង្គំជាខ្ញុំមិនបានរស់ជីវិតទេ ហើយមិនបានឃើញព្រះភក្ត្រព្រះបរមរាជបិតានិងមាតាទេ ។ ទូលព្រះបង្គំជាខ្ញុំ បាននាំបុរសនេះមកជាមួយដែរ,តែឥឡូវនេះ គាត់ទៅពួនក្នុងរន្ធឈើ, ព្រោះគាត់ខ្លាចនាគណាស់ ។

ព្រះបាទកូដន្តស្តាប់ព្រះរាជបុត្រអធិប្បាយរួចហើយ, ទ្រង់មានព្រះបន្ទូលថា: ឱកូនសំឡាញ់,! បើដូច្នេះមែន, កូនទៅនាំបុរសនោះមក ។ បុរសនោះទុកដូចជាឪពុកកូនឯងដែរ ។ ឪពុកម្តាយកូនឯងគ្រាន់តែបង្កើតទេ, ប៉ុន្តែ បុរសនោះបានចិញ្ចឹមទំនុកថែរក្សាជីវិតឯង ។ បើគ្មានបុរសនោះទេ;កូនឯងទាំងពីរ មិនបានរស់ជីវិត និងមិនបានឃើញមុខឪពុកឡើយ ។ ការដឹងគុណ ចំពោះបុរសនោះខ្លាំងណាស់ ហើយរស់រវើក, ឪពុកមិនដឹងជាបានរបស់អ្វីឱ្យទៅបុរសនោះវិញ ។

នាគកុមារនិយាយទៅកាន់ព្រះបរមរាជបិតាតទៅទៀតថា: កាលដែល

ទូលព្រះបង្គំជាខ្ញុំនិយាយនឹងអ្នកសប្បុរសនោះ ឲ្យជូនទូលព្រះបង្គំជាខ្ញុំមក, គាត់ឆ្លើយថា ព្រមជូនដំណើរទូលព្រះបង្គំជាខ្ញុំ តែគាត់បង់បានសំពត់មួយ ដែលស្តេចទាំងឡាយតែងតែទ្រង់ ហើយនឹងព្រះសារិកាមួយ (វ.ត្រៃស្នេង) ល្អដូចកៅអីស្តេច ។ ទូលព្រះបង្គំជាខ្ញុំគិតឃើញថា អ្នកមានគុណនេះ ធ្លាប់ធ្វើល្អនឹងទូលព្រះបង្គំជាខ្ញុំៗក៏បានសន្យាជានាអះអាងថា នឹងរករបស់ខាងលើនេះ ឲ្យខាងតែបានតាមបំណង ។

លុះបានស្តាប់ព្រះរាជបុត្រថ្លែងចប់ហើយ ព្រះបាទក្បូដក្តទ្រង់មានព្រះរាជឧត្តរបញ្ជាឲ្យស្រីស្នំទាំងឡាយ យកសំលៀកបំពាក់យ៉ាងល្អអស្ចារ្យ, យកទឹកអប់ យកខ្ទឹមចន្ទន៍ និងយកក្រស្នា ព្រមទាំងបញ្ជាឲ្យព្រះរាជបរិវៀបចំព្រះសារិកាមួយថែមទៀតផង ដើម្បីទៅទទួលចៅបាយក្តាំង ដែលនៅពួនក្នុងរន្ធដើមឈើ ។

បន្ទាប់មក ព្រះរាជបុត្រទាំងពីរព្រះអង្គ ប្រមូលវត្ថុទាំងនេះហើយទ្រង់យាងចេញទៅជាមួយនឹងរដ្ឋមន្ត្រីនិងនាយទាហានទាំងឡាយ ដើម្បីនាំចៅបាយក្តាំងមកក្នុងព្រះបរមរាជវាំង ។

លុះយាងទៅដល់កន្លែងដែលចៅបាយក្តាំងពួនហើយ ទ្រង់ស្រែកថា នែបង! ចេញមក! ចៅបាយក្តាំងឮហើយស្គាល់សំឡេងនាគប្អូនទាំងពីរ

(មានត)

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តមកពីលេខ ១២ ឆ្នាំ ១៩៥៣)

## លោក ប៉ាយ-ប៊ុក ប្រែរៀបរៀង

## ២. ការចុះទៅស្ថាននរក

បុរសអ៊ិជសាណាគីនិងនារីអ៊ិជសាណាមី បានបង្កើតជីវសត្វទាំងបួនពាន់នាក់ គឺកោះជប៉ុនៈនោះឯង ។ អ្នកទាំងពីរនាក់ក៏បានស្ថាបនានូវទេវបុត្រទេវតាឯទៀតជាច្រើន ។

តែព្រះរាជបុត្រប្អូនបង្អស់គឺព្រះអគ្គី ។ ព្រះអគ្គីនេះធ្វើឲ្យមាតានេះក្ដៅក្រហាយជាខ្លាំង ទាល់តែមាតានោះទទួលអនិច្ចកម្ម, ក្រោយដែលមានរោគគ្រុនយ៉ាំងខ្លាំងសម្បើមអស្ចារ្យ ។

ពួកទេវតាជប៉ុនមានសភាពខុសគ្នាពីពួកទេវតា នៃប្រជារាស្ត្រទាំងឡាយ ហើយមានលក្ខណៈ ដូចមនុស្សសាមញ្ញដោយទេវតានេះត្រូវទទួលមរណៈភាព ។

អ៊ិជសាណាគី ព្រួយចិត្តជាអនេកប្បការ ដោយមិនបានឃើញនាងអ៊ិជសាណាមី ដែលជាភរិយាគូស្នេហាមួយជីវិត ឋិតនៅជិតខ្លួន ។ ជីវភាពអ្នកទាំងពីរ មានសភាពជិតស្និទ្ធពន់ពេក, ទាល់តែបុរសនោះ

ព្រួយលំបាកស្ទើរស្លាប់ខ្លួន ដោយចិត្តនឹកទៅឃើញព្រះនាងអ៊ិដសាណាមី ឋិតនៅក្នុងស្មារតី និងហទយវត្ថុជានិរន្តរ៍ ។ បុរសនោះនឹកមិនភ្លេច ចំពោះអនុស្សាវរីយ៍ដែលខ្លួនបានរស់នៅ ជាមួយព្រះនាង ដោយសេចក្ដីស្នេហាជាយ៉ាងក្រៃពេក, នឹកឡើងស្ទើរប្រេះទ្រា ផ្សាក្រហល់ក្រហាយ, របេះរបោច ៗ ឱ, នឹកកាលនៅតែជាមួយនៅលើផែនដីជំបូងនឹងប្អូនតែពីរនាក់ សប្បាយ, សែនសប្បាយ ! ឱ! ពេលនោះគឺសប្បាយដូចព្រះសូរិយារះឡើងបញ្ចេញរស្មីត្រជាក់ត្រជុំសុខស្រួល . . . ឥឡូវនេះគឺព្រះសុរិយាអស្ដង្គត, លេចសូន្យឈឹង . . . ៗ

ការដែលបាត់បង់ព្រះនាងអ៊ិដសាណាមីនេះ នាំឲ្យអ៊ិដសាណាគីបាត់បង់នូវសេចក្ដីសប្បាយគ្រប់យ៉ាង, លែងចង់រស់នៅទៀតនោះ, កើតទុក្ខជាអនេកប្បការ . . ព្រួយសែនព្រួយ . . . ហើយក៏ថ្ងូរនិ . . បញ្ចេញមនោសញ្ចេតនា ដែលមានក្នុងហទយវត្ថុ . . ឲ្យស្រាលនូវទុក្ខទាំងនោះ ៗ ទឹកព្រះនេត្រហូរស្រក់, គួរឲ្យអាណោចអាធ័មពន់ពេក . . . ៗ

ទេវតាទៅជាមានចិត្តដូចមនុស្សធម្មតា កើតទុក្ខដូចមនុស្សសាមញ្ញ ៗ តែទេវតានេះស្គាល់នូវសច្ចធម៌ ច្រើនជាងមនុស្សសាមញ្ញ ។ លោកជ្រាបថា មនុស្សស្លាប់មិនមែនសូន្យទាំងអស់ទេ; ពិតមែនតែមនុស្សស្លាប់ចាកចេញពិភពលោក ដើម្បីទៅកាន់ភពថ្មីហើយរស់នៅទីនោះ, បាន

នរក ដែលមិនមែនបានសម្រាប់ដាក់ទណ្ឌកម្ម ចំពោះអ្នកប្រព្រឹត្តបាបអកុសលព្រោះថា អ្នកប្រព្រឹត្តបុណ្យកុសលក៏ទៅកាន់ទីនោះដែរ ដូចជាអ្នកប្រព្រឹត្តបាបអកុសល ។

អ៊ិជសាណាគីបានជ្រាបច្បាស់ថា នាងអ៊ិជសាណាមី នាងបានចុះទៅឋាននរក ជឿជាក់ថា ថ្ងៃណាមួយ, លោកនឹងបានជួបនឹងនាងមិនខាន ។ តែថ្ងៃនោះអាចនឹងមកដល់យូរ, ក៏មិនដឹង... ហេតុម្ដេចក៏មិនទៅក្នុងថ្ងៃនេះ? ហេតុម្ដេចក៏មិនគិតលៃលកយកនាងឲ្យបានមក, ហើយនាំនាងមកនៅលើផែនដីសុខស្រួលសប្បាយ? ។

នៅជិតនេះ, ខាងខែត្រអ៊ីស៊ូម៉ូ, មានទីកន្លែងមួយឆ្ងាយដាច់ស្រយាល, មានដើមស្រល់ពណ៌ស្រអាប់ ដុះខ្មៅងងឹតឈ្មប់ ទាល់តែក្រឡេកទៅគួរឲ្យតក់ស្លុត, ភ័យដាយ៉ានក្រៃពេក ។ មានដុំថ្មរាក់រាយពាសពេញទីកន្លែងនោះ ។ នៅក្រោមថ្មជាមួយមានទ្រង់ទ្រាយប្លែកពីធម្មតា មានប្រហោងមួយមានសភាពអាថ៌កំបាំង, ជាគុហាមួយជ្រៅក្រៃលែងជ្រៅ ទាល់តែមើលបាត់មិនយល់ ។

អ៊ិជសាណាគី ដឹងច្បាស់ថា កន្លែងនេះឯងជាទ្វារចូលទៅកាន់ប្រទេសអន្ធការ ។ ដល់អ៊ិជសាណាគីអញ្ជើញដល់មុខគុហាងងឹតឈ្មប់, ក៏ឈប់មួយស្របក់; លោកបានរៀបចំកម្រងបុប្ផាដែលពទ្ធជុំវិញព្រះសិរសា,

តម្រង់ស្មៀតដែលសៀតនឹងសក់វែងខ្មៅព្រោក, ព្រះហស្តកាន់ដងព្រះច័ន្ទ, ក៏ចូលដោយចិត្តក្លាហាន ទៅកាន់ឋាននរកនោះ ។

ដរាបណា អិដសាណាគីធ្វើដំណើរកាន់តែឆ្ងាយ ៗ ទៅ, ដរាបនោះ រស្មីព្រះសូរិយាក៏កាន់តែអន់ថយបន្តិចម្តងៗ រហូតដល់ងងឹតឈឹប ៗ ទេវតាក៏គ្រាច់ដោយដំហានរហ័ស, ទៅក្នុងពេលយប់ខ្មៅងងឹត ។

លុះដើរបន្តិចទៅ, ស្រាប់តែបានជួបនាយយមបាលម្នាក់, ទេវតានោះក៏សូមឲ្យនាយយមបាលនេះ នាំទៅកាន់ប្រាសាទក្រោមដី ដែលព្រះនាងអិដសាណាមីគង់នៅ ។ អិដសាណាគី អញ្ជើញទៅដល់មុខគោធ្វារប្រាសាទ, ចិត្តរំពៃគិតដល់ព្រះនាង, ចង់ឃើញព្រះនាងនោះពន់ពេកណាស់ ។ ក្នុងមួយរំពេច, ស្រាប់តែឮសូរសំឡេងពិរោះអស្ចារ្យ ប្រគំដោយសុខដុមរមនាថា:

"បពិត្រស្វាមី ប្រសើរឥតបី បងអញ្ជើញមក ជាកិត្តិយស ខ្ញុំបាត់សោយសោក អ្នកចាកឋានលោក មករកភរិយា ។ ឲ្យប្រុសពិសី ប្អូនគប់បេតិយ គ្រាច់តាមមគ្គា មករកប្អូនស្រី ខ្ញុំអរមហិមា គាត់អរញាញ់ យប់ថ្ងៃមិនគិត ។ នេះបំគូព្រេង ស្នេហ៍ស្និទ្ធស្វះស្វែង ស្វែងរកប្អូនពិត លំបាកយ៉ាងណា គាត់ព្រៃក៏ជិត មកៈភរិមិត្រ ពេញជាប្រុសគន់ ៗ

អិដសាណាគី ប្រៀនតបទៅព្រះនាងអិដសាណាមីថា:

"ឱកែវកែវផ្កា ត្រសួររាំហា ព្រឹព្រាយពេកពន់ សព្វសព៌ាង្គកាយ មហាគុណធ្ងន់ ប្រសើរលើសលន់ ឲ្យខ្ញុំជួបនាង ៗ ដូចកើតម្ដងទៀត មុខខ្ញុំបានបៀត ជិតកែវស្រស់ស្រាង គ្រប់ពេលរាត្រី ហេតុក្ដីបានសាង ច្រើនជាតិបានស្អាង កម្មផលជាមួយ ៗ បងបំណងនឹក មកស្រស់ពន្លឹក អាទិទេពជួយ បងបានជួបនាង ពាំងការជាត្រួយ ចិត្តថ្មើមល្ហួយ ដឹកនាងញឹកញាប់ ៗ បងរកមាសស្នេហ៍ ឃ្លាតមកយូរខែ យកនាងប្រញាប់ ទៅឯផែនដី ស្នេហ៍ក្ដីជាប់ សប្បាយគួរគាប់ នាងឆាប់វិលវិញ ៗ ការងារដែលធ្វើ បារប្រសើរ ដែលយើងខំប្រឹង មិនទាន់បានចប់ បូរកែវនួនខ្ញឹង សូមព្រះទីពឹង នាងត្រឡប់ឆាប់ ៗ

នាងនាថតបទៅវិញថា:

ឱព្រះស្វាមី? ខ្ញុំមិនចង់ស្ដី គួរខ្ញុំថ្លែងប្រាប់ ស្ដាយណាស់សែនស្ដាយ អ្នកមកមិនគាប់ ខ្ញុំសូមសារសព្វ ដំរាបប្រុសបង ៗ ខ្ញុំបរិភោគ អាហារគេបោក នៅស្ថានក្រោមប្រែង មិនអាចវិលបានខុសច្បាប់គន្លង ទៅឋានមនុស្សហោង មិនបានដាច់ខាត ៗ

ស្វាមីឆ្លើយទៅវិញថា: ឱនាងឆោមឆាយ ឆោមឆើតគួរស្ដាយប្រសើរស្អាងស្អាត តើអូនចង់វិល ត្រឡប់ប្រាសាទ រស់នៅជាខ្នាត ពីរនាក់នឹងបង ៗ បងមានចេតនា ចិត្តគិតប្រាថ្នា ទៅអូនទន់វង ចង់បានរួម

សុខ ទៅមុខស្ងួនគ្រង តើអូនបំណាង ចង់ទៅឬទេ? ។

នាងជាភរិយា សរសេរទៅស្វាមីថា:

“ចិត្តប្អូននឹកបង ខែឆ្នាំកន្លង គ្មានពេលទំនេរ ប្អូនចង់វិលទៅ ចិត្តរិះគ្មាន់គ្នេរ ព្យាយាមរិះរេ មិនដឹងធ្វើម្ដេច? ។ រាល់ទិនទិវា រាត្រីវេលា មិនអាចសម្រេច អូនទាល់គំនិត មិនមែនគិតគេច ចិត្តអូនមិនភ្លេច ម្ចាស់បងប្រុសស្នេហ៍ ។

ស្វាមីឆ្លើយតបទៅនាងថា:

“ឱអូនដោមស្និទ្ធ បូនាងតាំងចិត្ត កុំនាងប្រាសប្រែ ទៅសួរទេវតា យមរាជអ្នកថែ ដោះគុនគេចកែ ចំអន្ទ្រលោក ។ ថាសូមមេត្តា ជួយយកអាសា មេត្តាអធ្យាក លោកទ្រង់សណ្ដាប់ លោកជួយប្រញាប់ ថ្លែងតាមប្រាជ្ញព្រោក បំពោះមុខលោក អនុញ្ញាតឲ្យនាង ។

ព្រះនាងអិដសាណាមី ទ្រង់តបទៅស្វាមីវិញថា:

“ខ្ញុំម្ចាស់ទៅ, តែសូមទ្រង់សន្យា ខ្ញុំម្ចាស់ថាទ្រង់រង់ចាំនៅទីនេះ ដោយខន្តីស្ដាប់សេចក្ដីសម្រេចរបស់យមរាជ ។ តែសូមទ្រង់សន្យានឹងខ្ញុំម្ចាស់ថាបើលោកយមរាជមិនព្រមឲ្យខ្ញុំម្ចាស់ទៅទេ, ទ្រង់កុំរកខ្ញុំម្ចាស់កុំចង់ឃើញខ្ញុំម្ចាស់ ។ វិមានការនៅស្ថាននេះ គឺហាមដាច់ខាត សូមទ្រង់សន្យាថាទ្រង់នឹងធ្វើតាមខ្ញុំម្ចាស់” ។

ព្រះស្វាមីក៏តបព្រះនាងវិញថា: ''ខ្ញុំសូមសន្យានឹងព្រះនាងថា ខ្ញុំនឹងប្រតិបត្តិតាមនាងមិនឲ្យឃ្លង; ចូរនាងទៅហើយត្រឡប់វិលឆាប់!,, ។

ទេវតាអ៊ិជសាណាគី បានឃើញនាងអ៊ិជសាណាមី, ក្នុងព្រះទ័យលោកសោមនស្សពន់ប្រមាណហើយពោលថា: "ព្រះនាងបិតទៅអម្បាញ់មិញឯទីនេះ, ព្រះនាងជាភរិយាសំឡាញ់របស់ខ្ញុំ, ព្រះនាងដែលជាបណ្ដូលថ្លើមរបស់ខ្ញុំ! ចុះគួរឲ្យសប្បាយណាស់, ចុះគួររីករាយពន់ពេក!" ។

នៅខាងមុខដំណាក់ព្រះនាងអ៊ិជសាណាមី, ទេវតាអ៊ិជសាណាគីទ្រង់រង់ចាំ, ទឹកសង្ឃឹមពេញលក្ខណៈថា លោកយមរាជមិនជាសង់ទឹងបំណងនៃទេវតាទាំងពីរឡើយ ។

ទេវតា អ៊ិជសាណាគី រង់ចាំ....ទេវតាអ៊ិជសាណាគីរង់ចាំ....តែពេលវេលាមានសភាពយឺតអ្វីម្ល៉េះ! តើទេវតានោះរង់ចាំក្នុងនាទី, ម៉ោង ឬថ្ងៃ? ប្រហែលជាក្នុងនាទីដែលយូរ ដូចជាក្នុងម៉ោង, ឬក្នុងម៉ោងដែលយូរដូចជាថ្ងៃដូច្នោះ ។

តែក្នុងពេលនោះ, អនុស្សាវរីយ៍នៃអតីតកាល លាត់ត្រដាងបង្ហាញរូបពន្លឺច្បាស់លាស់ ចំពោះព្រះភក្ត្រ ទេវតាអ៊ិជសាណាគី ធ្វើចិត្តទេវតាឲ្យអាណោចអាធ័មពន់ពេក ហើយពោលថា: ''ឱនាងអ៊ិជសាណាមីជាទីស្នេហារបស់ខ្ញុំ, គឺមកពីនាងឯងបានជាខ្ញុំចុះពីឋានសួគ៌ មកឋានពិភពលោក

ដើម្បីស្ដាប់នាពិគពលោកទាំងមូល! ឱនាងដែលមានសម្រស់ល្អប្រិមប្រិយ, កាលយើងទាំងពីរនាក់រស់នៅជាមួយគ្នានៅលើកោះនោះ កោះដែលលំពែងអាទិទេពបានជម្រុះធ្លាក់ចុះពីមហាមេឃ ។ ឱព្រះនាងមានរូបឆោមលោមពណ៌ គួរឲ្យបេតនាពន់ពេក! តើព្រះនាងនៅតែមានរូបល្អដូច្នេះឬ! ខ្ញុំចង់ឃើញនាង,ចង់ឃើញតែមួយភ្លែត, ចង់ឃើញឥឡូវនេះ ។

ផល់ទៅកាអិដសាណាគី ទឹកក្រែកគ្រែអាលដោយសេចក្ដីស្នេហាចំពោះព្រះនាងដូច្នេះ, ទេវតានោះក៏មិនអាចទប់ទល់នឹងតណ្ហាបាន ។ ពិតមែនតែទេវតាបានធ្វើកិច្ចសន្យាចំពោះព្រះនាង, លោកក៏ចូលទៅក្នុងដំណាក់ព្រះនាងអិដសាណាមី, បានដកស្នៀតសក់ចេញពីក្នុងសក់ព្រះនាង, កាច់បំបាក់ធ្មេញមួយហើយយកកើងមកដុត ។

បាននរកក្នុងពេលនោះ, ក៏មានពន្លឺរស្មីសន្ធោសន្ធៅឡើង ..... ។

ក្នុងពេលដែលធ្មេញស្នៀតសក់ព្រះនាងកំពុងឆេះ, ព្រះនាងដួលទៅលើប្រថពីហើយក្នុងមួយភ្លែត រូបព្រះនាងក៏រលួយរលេះទៅ, ព្រះភក្ត្រព្រះនាងទៅជាមាតិណាខៀវដូចស្លឹកឈើ, សក់ព្រះនាងជ្រុះអស់, ព្រះនេត្របើកតែគ្មានរស្មី, ដងខ្លួនក៏ចុះក្នុងរូបដែលពីដើមមានលំអឥតឧបមា ។

ព្រះនាងអិដសាណាមីក៏ស្រែកទៅកាន់អិដសាណាគីថា:

☞ (មានត)

## កំណាត់ដំណើរប្រវត្តិការណ៍

## កត់ហេតុមហាសន្និបាតលើកទី ៦

## នៃពុទ្ធិកសមាគមកម្ពុជរដ្ឋ

### លោក សម-ញាណ

ប្រធាននៃពុទ្ធិកសមាគមកម្ពុជរដ្ឋ រៀបរៀង

ពុទ្ធសករាជពីរពាន់ប្រាំរយ ឆ្នាំរកានព្វស័ក ខែបុស្ស ពីរកើត ថ្ងៃអង្គារ ត្រូវនឹងថ្ងៃទី៧ ខែមករា ១៩៥៨ វេលាម៉ោង ៧ និង ៣០នាទី ។

នៅមន្ទីរសំណាក់ការនៃពុទ្ធិកសមាគម កម្ពុជរដ្ឋ សមាជិកសមាជិកា ទាំងឡាយ ទាំងពីរប្រភេទនឹងបព្វជិត បាននិមន្ត-អញ្ជើញមកកាន់មហាសន្និបាត តាមលិខិតនិមន្ត អញ្ជើញនៃលោកសម-ញាណ ប្រធាន ។

លុះដល់ម៉ោង១៨ និង២០នាទី មានការពិនិត្យចំនួនសមាជិកសមាជិកា តាមប្រការ ៣៦ នៃលក្ខន្តិកៈទៅឃើញថា:

- សមាជិកផ្នែកខាងព្រះសង្ឃ មានចំនួន៧៩អង្គ ដែលបានមករួមប្រជុំ
- » គ្រហស្ថ » ១០១រូប ដែលបានមករួមប្រជុំ ។

ដោយបានឃើញថា គ្រប់អង្គប្រជុំហើយ សម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃនាយកគណៈមហានិកាយ បាននិមន្តឡើងលើវេទិកាថ្លែងនូវអំណរ ចំពោះមហាសន្និបាត ដែលនៅពេលនោះ សម្តេចបានមានព្រះថេរដីកាជាអាទិ៍ថា "ខ្ញុំព្រះករុណា អាត្មាមានអំណរយ៉ាងក្រៃលែងដោយបានឃើញអស់លោក អ្នកនិមន្ត អញ្ជើញមកជួបជុំ ដើម្បីធ្វើមហាសន្និបាតច្រើនរូបនេះណាស់ ព្រោះថា ការមកជួបជុំនេះ ឈ្មោះថាបានធ្វើឲ្យពុទ្ធិកសមាគមកម្ពុជរដ្ឋ បានចំរើនជឿនលឿនទៅមុខ ឈ្មោះថាបានជួយបំពេញកិច្ចជ្រោមជ្រែង ទំនុកបំរុងព្រះពុទ្ធសាសនា ឲ្យមានពន្លឺផ្សាយចេញទៅកាន់ពិភពលោកដោយពិត សូមឲ្យអស់លោក-អ្នកបានប្រកបដោយអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ តទៅ ។

បន្ទាប់មក លោកសម ញាណ ប្រធានបានឡើងលើវេទិកាថ្លែងបើកពេលប្រជុំមហាសន្និបាតហើយ រៀបរាប់អំពីសកម្មភាពនៃគណៈកម្មាធិការនាយក ដែលបានធ្វើចំពោះសមាគមក្នុងឆ្នាំ ដែលកន្លងទៅហើយ ក្នុងសេចក្តីថ្លែងការណ៍នោះមានសុំមហាសន្និបាតឲ្យកែប្រែលក្ខន្តិកៈដូចតទៅ ៖

ក- ត្រង់ចំពូក១ ប្រការ២ ជាដើម ដែលមានសេចក្តីថា ពុទ្ធិកសមាគម កម្ពុជរដ្ឋ ជាប់ការលើខ្ទង់អំពីរឿងប្រាក់បរិលាភខានចំនួនមួយពាន់រៀលនិងប្រាក់ចំនួន២៥% នៃប្រាក់លាភកាលឆ្នាំ ដែលបានមកអំពីសមាជិក

របស់ខ្លួនក្តី អំពីសាខា ឬ អង្គការដែលឡើងមកខ្លួនក្តី ។

សូមមហាសន្និបាតពិចារណា បើមិនមានយល់ទាស់ទេ សូមលុបចោលចេញនូវគ្រប់តែប្រការណា ដែលមានការៈ ជាប់ទាក់ទងនឹងពុទ្ធិក-សមាគមពិភពលោក ។

នៅខណៈនោះ លោកអ៊ូច-ឯក បានស្នើសួរថា បើយើងលែងមានការជាប់ទាក់ទង តើខូចប្រយោជន៍ ឬទេ? បើយើងនៅទាក់ទងវិញ តើបានលទ្ធផលយ៉ាងណា? ។

ចំពោះសំនួរខាងលើនេះ លោកសម-ញាណ បានឆ្លើយរែកញែកប្រាប់ហេតុផល ដែលបណ្តាលឲ្យសុំមហាសន្និបាត កែប្រែដោយសព្វគ្រប់ បន្ទាប់មក ព្រះពោធិវង្ស ហ-តាត បាននិមន្តឡើងលើវេទិកាពន្យល់ថែមទៀត ហើយដែលមានសេចក្តីជាអាទិ៍ថា ប្រាក់ដែលសមាគមយើងបានផ្ញើទៅ ចំនួនមួយពាន់រូពី ទៅពុទ្ធិកសមាគមពិភពលោក នៅទីក្រុងកោលម្ប៉ូ ឥតបានផលអ្វីបន្តិចបន្តួចទាល់តែសោះ ដោយហោចទៅ សូម្បីតែផ្ញើដំណឹងមកវិញថា បានទទួលប្រាក់នោះហើយ ក៏មិនឃើញផង ទោះបីយើងរំឭកហើយរំឭកទៀតក៏ដោយ ។

ក្រោយនៃការពិភាក្សាដេញដោលមក មហាសន្និបាតបានយល់ព្រមជាឯ-កច្ឆន្ទ ទទួលយកនូវសេចក្តីសម្រេចចិត្ត ដែលមានអត្ថបទដូចខាងក្រោមនេះ

## សេចក្ដីសម្រេចចិត្ត

ដោយយល់ឃើញថា តាំងពីខ្លួនបានបង្កើតឡើង "គ.ស. ១៩៥២" ដោយការអនុវត្តន៍បទបញ្ញត្តិលក្ខន្តិកៈ របស់ខ្លួនផង ដោយការអនុវត្តន៍លក្ខន្តិកៈរបស់ពុទ្ធិកសមាគមពិភពលោក នៅទីក្រុងកោលម្បូ មជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ បានបញ្ជូនមកក្នុង គ.ស. ១៩៥៣ នូវប្រាក់ចំនួនមួយពាន់រូពី (១.០០០រូពី) ទៅពុទ្ធិកសមាគមពិភពលោក នៅទីក្រុងកោលម្បូ ហើយសមាគមនេះ ពុំដែលតបមកវិញសោះ មកទល់នឹងថ្ងៃទី ៧ មករា ១៩៥៨នេះ ថ្វីបើមានលិខិតរំឭកហើយរំឭកទៀតជាច្រើនលើកច្រើនគ្រាៗ

ដោយយល់ឃើញថា ថ្វីបើផ្នែកខាងយើងៗ ខំប្រឹងប្រែងធ្វើការល្បង ជាញឹកញយ ដើម្បីការទាក់ទងជិតស្និទ្ធ រវាងមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ នឹងពុទ្ធិកសមាគមពិភពលោក នៅទីក្រុងកោលម្បូ សូម្បីធ្វើយ៉ាងម្ដេចក៏ដោយ ក៏នៅតែឥតបានលទ្ធផលអ្វីសោះ ៗ

ដោយយល់ឃើញថា អគ្គបទជាសារវត្ថុទាំងឡាយ ដែលសន្និសីទពុទ្ធិកសមាគមពិភពលោក នាក្រុងកោលម្បូ ចុះថ្ងៃទី៦មិថុនា១៩៥០ បានកំណត់ហើយ សមាគមនេះ ឥតបានអនុវត្តន៍សោះតាំងស្រុង សមាគមនេះបានបង្ហាញគុណវិបត្តិ របស់ខ្លួនយ៉ាងពេញលេញ ៗ

ដោយមានហេតុការណ៍ខាងលើនេះ

គប្បីតែមជ្ឈមណ្ឌលកម្មការកម្ពុជរដ្ឋ ត្រូវនៅក្នុងកតព្វកិច្ចសំដែងថា ខ្លួនប្រកបដោយស្វ័យភាពពេញបរិបូណ៌ ហើយទទួលយល់ព្រមនូវអត្ថបទ ដែលខ្ចាស់ជាប់មកជាមួយនេះ ដែលស្ដីពីការរើពិនិត្យឡើងវិញនិងការកែប្រែលក្ខន្តិកៈរបស់ខ្លួន ។

សូមរាជរដ្ឋាភិបាល មេត្តាជូនដំណឹងតាមផ្លូវការ ទៅរដ្ឋាភិបាលលង្កាទ្វីបថា ប្រទេសកម្ពុជា រំលាយនូវកិច្ចដែលប្រតិភូរបស់ខ្លួន បានចុះហត្ថលេខា នៅថ្ងៃទី៦មិថុនា១៩៥០ នៅក្នុងកាលសន្និសីទនៃពុទ្ធិកសមាគមពិភពលោក នៅទីក្រុងកូឡុំបូ ហើយព្រមទាំងថា ក៏ប៉ុន្តែ ពុទ្ធិកសមាគមមជ្ឈមណ្ឌលនៃកម្ពុជរដ្ឋថ្មី នៅតែស្ម័គ្រចិត្តធ្វើសហការជាមួយនឹងអង្គការទាំងឡាយ ដែលមានគោលបំណងដូចគ្នា ដោយរក្សាទុកនូវស្វ័យភាពពេញទីរបស់ខ្លួនតទៅ ។

ធ្វើនៅក្រុងភ្នំពេញ ចុះថ្ងៃទី ១ ធ្នូ ១៩៥៧

ហត្ថលេខា: សមាជិកទាំងឡាយនៃគណៈកម្មាធិការនាយក

អត្ថបទដែលមហាសន្និបាត ចុះថ្ងៃទី៧ មករា១៩៥៨ នៃ ពុ.ពិ.ម.ភូ.ក. បានយល់ព្រមទទួលយក ហើយដែលស្ដីពីការរើពិនិត្យឡើងវិញ

នឹងការកែប្រែលក្ខន្តិកៈរបស់ខ្លួន "គឺពីសេចក្តីសម្រេចចិត្តមួយ ដែល-បានប្រគល់ដោយអនុលោមទៅតាមបទបញ្ញត្តិនៃប្រការ ៤៩ របស់-លក្ខន្តិកៈនៃខ្លួន " ។

១- នាមថ្មីរបស់សមាគម

- ត្រូវអានថា: ពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ ។

២ - នៅខាងចុងសេចក្តីប្រារព្ធ ត្រូវបន្ថែមវគ្គខណ្ឌដូចតទៅនេះ :

ប៉ុន្តែមកដល់ថ្ងៃទី ៧ មករា ១៩៥៨ មហាសន្និបាតនៃសមាគមបានបញ្ចេញឆន្ទៈ ទទួលយកនូវសេចក្តីសម្រេចចិត្តមួយជាបានការថា ខ្លួនត្រូវមានស្វ័យភាពពេញបរិបូណ៌ ដោយហេតុថា កាលពីសមាគមនេះកើតឡើង " គ.ស. ១៩៥២ " នោះឥតមានការទាក់ទងគ្នា អ្វីណាមួយសោះរវាងបជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ និងពុទ្ធិកសមាគមពិភពលោក នៅទីក្រុងកោលម្បូ " លង្កាទ្វីប " ហើយមហាសន្និបាតបានប្រគល់ការឲ្យគណៈកម្មាធិការនាយកថ្មី ដូនដំណើរតាមផ្លូវច្បាប់ ដោយប្រតិបត្តិតាមនីតិក្រមត្រឹមត្រូវ អំពីកិច្ចវិលាបនេះ ទៅអង្គការនោះៗ ដែលគេថាជា " មាតា " ប្រសិនបើអង្គការនោះមាន " ។

៣ - បំណាច់ដើម - ត្រូវអានថា :

ពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ ។

ប្រការ១ – ត្រូវអានថា ៖

ប្រការ១ " ថ្មី " ជនទាំងឡាយកេងក្រហស្ត ឬ បព្វជិត ដែលគាប់ចិត្តនឹងលក្ខន្តិកៈនេះ បានរួបរួមគ្នាធ្វើសមាគមមួយ មាននាមថា " ពុទ្ធិក·សមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ " ហៅខ្លីត្រឹមតែ " ពុទ្ធិកសមាគមកម្ពុជរដ្ឋ " ប្រើអក្សរសង្ខេបថា " ពុ·ម·ក· " ។

ប្រការ ២ – លុបចោល ។

ប្រការ ៣ " ទៅជាប្រការ ២ ថ្មី " ដែលមានសេចក្តីដូចតទៅ៖

ប្រការ ២ " ថ្មី " " ពុ·ម·ក· " ខំប្រឹងប្រែងសម្រេចនូវគោលបំណងនិងកម្មវត្ថុទាំងឡាយ ដូចតទៅនេះ ៖

( ទៅសល់តទៅទៀត ឥតផ្លាស់ប្តូរអ្វីទេ ) ។

ប្រការ ៣-៤-៦-១១ ២៨ ៣០ ៤២និង៤៣ " ថ្មី " ត្រង់ពាក្យថា " ពុ·ពិ·ម·កួ·ក· " ត្រូវជាកថា " ពុ·ម·ក· " ជាជំនួសវិញ ។

ប្រការ៤៩ " ថ្មី " ត្រូវអានដូចខាងក្រោមនេះ

ការចាត់តាំងអ្នកតំណាងទាំងពួង ឲ្យទៅធ្វើបេសកកម្មនៃបុគ្គលិយេសក៍ជាមុខការរបស់គណៈកម្មាធិការនាយក ដែលសម្រេចយកតាមពីរភាគបី "២%៣" នៃចំនួនសមាជិកគណៈកម្មាធិការនាយក ដោយរាជរដ្ឋាភិបាលយល់ព្រមផង ។

ប្រការ ៤៧ " ចាស់ " ត្រូវលុបចោល ។

ប្រការ ៤៨ " ចាស់ " ត្រូវទៅជាប្រការ ៤៦ " ថ្មី " ដែលមានសេចក្ដីដូចតទៅ :

ប្រការ ៤៦ " ថ្មី " ទង់របស់ ពុ.ម.ក. ជាទង់មានពណ៌ ៦ . គម្រូវនឹងពណ្ណរង្សី របស់ព្រះសមុទ្ទ ទុកជាមូលដ្ឋាន ។

ប្រការ ៤៩ " ចាស់ " ទៅជាប្រការ ៤៧ " ថ្មី " ដែលមានសេចក្ដីដូចតទៅនេះ :

ប្រការ ៤៧ " ថ្មី " ត្រាសារីសរបស់ ពុ.ម.ក. ជារូបធម្មចក្កមានកាំ ៨ គាង់អរិយមគ្គមានអង្គ ៨ ។

បន្ទាប់មកទៀត លោកស៊ សែម ក៏បាននាំជាអគ្គហេរញ្ញិក ក៏បានថ្លែងរៀបរាប់អំពីស្ថានភាព ហិរញ្ញវត្ថុនៃសមាគម ក្នុងឆ្នាំដែលកន្លងទៅ " ប្រាក់ចំណូលចំណាយ " សឹងមានសព្វគ្រប់ ក្នុងសេចក្ដីថ្លែងការណ៍នោះហើយដែលបានឲ្យដំកល់ទុកជាឯកសារស្រាប់ ។

ក្រោយការប្រកាសលាលែងពាក់តំណែង ពីគណៈកម្មាធិការនាយកនៃលោក សម ញាណមក មហាសន្និបាតបានជ្រើសតាំងក្រុមអភិបាលបណ្ដោះអាសន្នមួយ តាមប្រការ ៣៣ នៃលក្ខន្តិកៈ ដែលមានលោកនាគកញ្ញាពិជគេជះ គន់-មៅ ជាព្រឹទ្ធប្រធាន ហើយមានលោក ម៉ែ-ប៊ុន

នឹងលោក ខោល-វៃ ជាលេខាធិការ ដើម្បីឲ្យពាក់ការបោះឆ្នោត តាមប្រការ ៣១ នៃលក្ខន្តិកៈតទៅ ។

មុននឹងចាត់ការឲ្យបោះឆ្នោត ជ្រើសតាំងគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៥៨ លោក ម៉ៃ ប៉ាន់ បានប្រកាសសុំនាមអស់លោកដែលស្ម័គ្រចិត្តឈរឈ្មោះ ។

នាមត្រកូលអស់លោក ដែលស្ម័គ្រចិត្តឈរឈ្មោះដូចខាងក្រោម :

១ លោក សម-ញាណ
២- " កាយ-ល្អត
៣ " ទេស-យ៉ង់
៤- " ម៉ុ នរស៊ីហ៍
៥- " ម៉ែន-ទន់
៦- " នូ-ឯម
៧- " រស់-ហៃម
៨- " បេ-យាន
៩- " អ៊ុង-គីមង៉ន
១០- " ជា-ផុង
១១- " តា-ជាវលី

១២- លោក យុន-យ៉ា

១៣. " ឡឹក-ឡាញ់

១៤- " មុី-នាន

១៥- " ស្រី កឹយ-លុត

១៦. " " អុឹន-គឹមនន

១៧- " " គង់-សរ

១៨ ឃុនព្រះម្ចាស់ យិន-គាត

១៩– លោក អេន-មាស

២០- " ជុយ-កេ

២១- " ឆឹន-ខេម

២២ " ស្រី សម-ញាណ

២៣- " ស៊ុន-ក៉ន់

២៤- " ប៊ុន-ថាន់

២៥- " ឈឹម-ស៊ុម

២៦- " តា-ប៊ុនឡេង

២៧- " ឡេង-ទូប

២៨- " ក្ដុប-កៀន

២៩- " លី-គិមសា ។

ក្រោយការសួរបញ្ជាក់ទៅឃើញថា គ្មានអ្នកបោះឆ្នោតទៀតទេ ក្រុមអធិបាល ក៏ចាប់រាប់សន្លឹកឆ្នោត ឃើញមានចំនួន ១៤១សន្លឹក ។

លោក ម៉ៃ-ប៉ុន លេខាធិការនៃព្រឹទ្ធប្រធាន បានប្រកាសលទ្ធផលនៃការបោះឆ្នោត ជ្រើសតាំងគណៈកម្មាធិការនាយកជាស្ថាពរ មានសមាសភាព ដូចតទៅនេះ :

១ - លោក សម ញាណ បានឆ្នោត ១៤១ សន្លឹក
២ - " ពៅយ-ឈុត " ១៣៩ "
៣ " អ៊ឹង-គឹមឆន " ១២៧ "
៤ - " បេ-យោន " ១២៣ "
៥ - " ទា-ផាវណី " ១៤១ "
៦ - " ទូ ឯម " ១១៧ "
៧ - " រស់-ហៃម " ១១៦ "
៨ " ម៉ែន-ទន់ " ១០២ "
៩ - " យុង·យ៉ាំ " ៩៤ "
១០ · " ស្រីពៅយ-ឈុត " ៩០ "
១១ - " " អ៊ឹង-គឹមឆន " ៨៩ "
១២ ·· " ម៉ី នរសីហ៍ " ៨៩ "

១៣ - លោក ស្រី គង់ សរ បានឆ្នោត ៨៦ សន្លឹក

១៤ - " អេង-មាស " ៨៦ "

១៥ - " ជា-ផុន " ៧២ " ។

តាមគោលការណ៍ ដែលមានចែងត្រង់ប្រការ ៨ នៃបទបញ្ជា អ្នកជាប់ឆ្នោតទាំងឡាយ ត្រូវប្រជុំគ្នាភ្លាម ដើម្បីសម្រេះសម្រួលគ្នា ចែកមុខងារ ប៉ុន្តែដោយពេលនោះ កាលៈទេសៈបណ្តាលមិនឲ្យធ្វើបាន ទើបលោក សម-ញាណប្រកាសថា នឹងសម្រេចទៅថ្ងៃក្រោយវិញ ហើយថ្លែងទទួលអំណរគុណចំពោះសមាជិកសមាជិកា ដែលបានបោះឆ្នោតជ្រើសតាំងខ្លួនលោក ឲ្យធ្វើជាគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៥៨ តទៅទៀត ។

មុននឹងបិទពេលប្រជុំ សម្តេចព្រះមហាសុមេធាធិបតីនីងព្រះមហាថេរានុត្ថេរៈ បានសូត្រឲ្យយធម៌ប្រសិទ្ធពរជ័យសិរីមង្គលជូនអស់លោក ដែលបានជាប់ឆ្នោត ច្រើនជាងគេ ហើយត្រូវបានជ្រើសតាំងជាគណៈកម្មាធិការ-នាយក ជាកិច្ចបញ្ចប់នៃពិធីមហាសន្និបាតលើកទី ៦ នេះ ។

គ្មានហេតុអ្វីទៀត ពេលប្រជុំ បានលើកនៅម៉ោង ២១ គត់ ។

គត់ហេតុធ្វើនៅមន្ទីរស្នាក់ការថ្ងៃ ១១ ឆ្នាំដដែល មានខាងលើស្រាប់ ។

ហត្ថលេខា:-

ក្រុមអភិបាលបោះឆ្នោត ។

ដំណើរធនស្ថាគារសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតក្រុងភ្នំពេញ

# រៀបរៀង ដោយជា ទន់

សា៖ សាស្ត្រាចារ្យទទួលភារៈខាងការបង្រៀនអង់គ្លេសនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

( កម្ពុជ លេខ ១២ ឆ្នាំ ១៩៥៧ )

---

ហេតុនេះ ដើម្បីឲ្យមានទីកន្លែងទុកប្រាក់កាសប្រាសចាកភយន្តរាយ គេពីងមានឃ្លាំងប្រាក់ហៅថា Bank សំរាប់ទុក ៗ មានឃ្លាំងប្រាក់ច្រើនសន្ធឹកណាស់ សំរាប់ប្រមូលដាក់ទុកប្រាក់កាសឲ្យគង់វង្ស ៗ ដល់មានប្រាក់ច្រើនល្មមវិញឲ្យានបាន គេវិញឲ្យានជះ ព្រោះយ៉ាងនេះចាប់ទី១ ហើយ គេផ្តើមកេរបរឯទៀតៗ តាមដើមទុនដែលមាន ៗ សណ្ឋាគារក្តី, អាគារធំៗ ខ្ពស់ៗ ដែលជាទីហាងលក់ដូរក្តី សុទ្ធតែជារបស់ឯកជន, របស់ក្រុមហ៊ុន, របស់សមាគមស្ទើរតែទាំងអស់ ព្រោះហេតុហ្នឹងហើយ បានជាទីក្រុងនីមួយ ៗ លាតសន្ធឹងរីកធំឡើងៗ អាគារកើនកំពស់ទៅលើកាន់តែខ្ពស់ឡើង ៗ ដោយពួកក្រុមជនអ្នកមានប្រាក់ រកបរជំនួញនេះជាហេតុដើម ។ គេសាងទីក្រុងធំ ៗ រាតតម្រឹកយ៉ាងទូលាយជាប់ទាក់ទង

រកគ្នា ស្ទើរតែថាទីក្រុងទាំងអស់ ពេញសហរដ្ឋទៅហើយ បើរាប់តែឈ្មោះ ទីក្រុងដែលធំ ៗ ហើយដែលមានអាគារខ្ពស់ ៗ ទល់នឹងមេឃ ហើយដែលយើងបានឃើញច្បាស់នឹងភ្នែកផងនោះ ដូចជាទីក្រុងនូយ៉ក មានចំណុះប្រជាជនជាង ៨ លាន មានអាគារខ្ពស់ ៗ ពី ៥០ ទៅ៧០ ជាន់ជាច្រើន ៗ រីឯអាគារដែលខ្ពស់ជាងគេមាន១០២ជាន់ ក្រុងនេះជាទីក្រុងធំជាងគេ ក្នុងសហរដ្ឋ ហើយទីក្រុងឯទៀតជាធំទី ២ ៣-៦ ៥ នោះគឺ Chicago, Philladelphia, Los Angeles, Boston, San Francisco, New-Orleans ដែលសុទ្ធតែជាទីក្រុងសំខាន់ ៗ របស់សហរដ្ឋ ៗ ក្នុងទីនីមួយ ៗ សុទ្ធសឹងតែមានទស្សនីយដ្ឋាន, អនុស្សរណីយដ្ឋាន ជាច្រើនប្លែក ៗ ដែលគេកសាងឡើង ទុកជាប្រវត្តិនៃទីក្រុង ហើយមានបណ្ណាល័យ, សារមន្ទីរ, វិហារដែលគេហៅថា Chu ch ជាច្រើនណាស់ទៅទៀត ៗ ដូច្នេះ ក្នុងក្រុងនីមួយ ៗ មានសេចក្តីរៀបរយ និងរបៀបរៀបចំត្រឹមត្រូវ ល្អឥតខ្ចោះត្រង់ណាទេ ៗ មានទីក្រុងខ្លះ ប្រតិស្ឋាននៅលើភ្នំធំ ៗ , គេសង់ផ្ទះសំបែង តាំងពីកំពូលភ្នំរហូតដល់ជើងភ្នំ ៗ វេលាយប់មើលៈឃើញពន្លឺភ្លើងឆ្លាស់ពណ៌ ល្អអនេកអនន្តពន់ពេក ៗ

ចំណែកប៉ែកខាងសង្គមកិច្ច ប្រជាជនអាមេរិកាំង មានការស់ស្រោះគ្នាទៅវិញទៅមកណាស់ មានមន្ទីរព្យាបាលរោគ និងឱសថស្ថាន ដែល

គេហៅថា Drugstore ឬ Phamacy ជាច្រើនកន្លែងមានសមាគមធានាជីវិតប្រជាជន, ធានាគេហដ្ឋាន, ធានាទ្រព្យសម្បត្តិឯទៀតៗ មានរថយន្តជាដើម ។ ប្រជាជនម្នាក់ៗ សុទ្ធតែមានគ្រូពេទ្យរបស់ខ្លួន សំរាប់អភិបាលរក្សា ការពាររោគពាធគ្រប់ប្រការ ។ ជនជាតិអាមេរិកាំង មានជំនឿជឿស៊ប់ក្នុងពេទ្យ ក្នុងក្បួនពេទ្យជាខ្លាំង មិនមានជំនឿលើអ្នកដទៃក្រៅពីពេទ្យទេហើយ គ្រាន់តែផ្តាសាយតឹងច្រមុះ កណ្តាស់បន្តិចបន្តួច ឈឺបំពង់ក (យើងថាបន្តិចបន្តួច) គេថា ទៅពេទ្យ, ឲ្យពេទ្យពិនិត្យមើល ក្រែងមានបើយ៉ាងណា។ តាមការមិនធ្លាប់នៃជនជាតិយើង ព្រោះជនជាតិយើងជាអ្នកអត់ធន់ យើងថាគេវិវន់ ឈឺបន្តិចបន្តួចចាំបាច់ទៅរកពេទ្យធ្វើអ្វី? ចំណែកខាងជនជាតិគេ ដោយគ្រូពេទ្យសំបូរណាស់ផង ឲ្យតែមិនស្រួលខ្លួន គេទៅពេទ្យភ្លាម ៗ ព្រោះហេតុហ្នឹងហើយ បានជាគេមានមន្ទីរពេទ្យធំៗ ច្រើនណាស់ សំរាប់ជួយសង្គ្រោះអាយុជីវិតប្រជាជន ។

ប្រជាជនអាមេរិកាំង ទាំងប្រុស ទាំងស្រី មានសិទ្ធិ និងសេរីភាពស្មើគ្នាទាំងអស់ ៗ បុរសមានសិទ្ធិធ្វើអ្វីបាន ស្ត្រីក៏មានសិទ្ធិធ្វើនោះបានដូចគ្នា ហើយមានការបោះឆ្នោត ក៏ដូចគ្នាដែរ ។ ស្ត្រីអាមេរិកាំង មានធ្វើការរាជការគ្រប់ក្រសួង, ធ្វើជានាយកក្រសួង, លេខាធិការិណី, សាស្ត្រាចារ្យ,

### វចនានុក្រមសំស្រ្កឹត-ខ្មែរ

( តមកពីលេខ ១២ ឆ្នាំ ១៩៥៧ )

# ព្រះមហាប៉ាង-ខាត់ រៀបរៀង

- ធារណា ស្រ្តី. កិរិយាទ្រទ្រង់នូវអង្គ ។ -ប៉រិវត៌ន នបុំ. កិរិយា បង្វិលនូវអង្គ កិរិយាមិគពត់អង្គ ។ ធាត- បុំ. អង្គធាតុ,គណនីបញ្ជី ។ ធាលី ឬ ធាលិកា ស្រ្តី. " កិរិយារក្សានូវអង្គ '' ការទប ឬ ការឆប់, ស្រីមេដោះ ។ - ធាលី ស្រ្តី. អ្នករក្សានូវអង្គ, ការឆប់ ស្រីក្យាបាលមនុស្សឈឺ, គិលានុបដ្ឋាយិកា ។ - ភាជ គុ. (ក្នុង) ដែលពន្លឺចង្កេះ (ផ្លែឈើ) ដែលទុំមុន ដែលស្រគាល ។ - វិទ្យា ស្រ្តី. អង្គវិទ្យា, ធណភិតសាស្រ្ត ។ - លោឡ បុំ. ធីបុី ។ - គរុយិន - ស្ត,- អាលក្ការិន គុ.ដែលពន្លឺចង្កេះ ; ។ អនេក្ក - ភយ គុ. ( សត្វ ) ដែលទំលើ . . . . ។ អង្គី - គត ឬ គុ. ដែលទប, ដែលឆប់ , ។

អង្គន នបុំ. គ្រឿងសំគាល់ ក្រា ។

អង្គស នបុំ. ចង្កេះសេះ ឬ គ្រឿងអានសេះ ។

អង្គី ស្រ្តី. ស្តូរគូប ។

អង្គដ បុំ. កូនសោ

( មានត )

ម៉ោង ១៧ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះឧបយុវ-រាជ ស្តេចយាងដល់ ។

- លោក ពិយ លុត រដ្ឋមន្ត្រី ក្រសួងធម្មការថ្វាយសុន្ទរកថា ។

- ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ប្រទានភ្លើង ។

## ថ្ងៃទី ៤ ថ្ងៃសៅរ៍ ២២-២-៥៨

ម៉ោង ៧ ព្រឹក ព្រះសង្ឃបំពេញសត្តប្បករណ៍ ប្រែព្រះរូបរើសព្រះអដ្ឋិ ហើយដង្ហែព្រះអង្គារទៅបណ្តែតក្នុងទន្លេចតុមុខ ។

ម៉ោង១០ :-និមន្តព្រះអដ្ឋិទៅដំកល់លើបញ្ចាវិញ ។

## ថ្ងៃទី ៥ ថ្ងៃអាទិត្យ ២៣-២-៥៨

ម៉ោង៧ ព្រឹក: ជួបជុំព្រះសង្ឃ ឧបាសក ឧបាសិកា ហែព្រះអដ្ឋិទៅដំកល់នៅមុខវិហារព្រះចេតិយធំក្នុងវត្តបទុមវតី ។

ម៉ោង ៨- ជួបជុំរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ នាម៉ឺនសព្វមុខមន្ត្រី នៅពន្លានាមុខព្រះចេតិយធំ ។

ម៉ោង៨-១៥-ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ ស្តេចយាងជាព្រះរាជាធិបតី ព្រះរាជាធិប-តានីដោយមានក្រុមឧត្តមប្រឹក្សាព្រះរាជា និងព្រះរាជបរិពារផ្គាល់តាមហែ ។

- បន្ទាប់មកឯកឧត្តមឧកញ៉ាមហាមន្ត្រី ញឹក នូវ លើកព្រះអដ្ឋិថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង១ ទ្រង់ព្រះរាជទានទៅអ្នកអគ្គម្ចាស់ ស៊ីសុវត្ថិសិរិមត្តៈ១ ទទួលយកទៅបញ្ចុះដំកល់ក្នុងព្រះចេតិយធំ , ហើយព្រះសង្ឃសូត្រជយន្តោ ; រួចប្រគំភ្លេងពិណពាទ្យ ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣០ លេខ ២ ខែកុម្ភៈ

ព.ស. ២៥០០ គ.ស. ១៩៥៨

– ភ្នំពេញ –

1958 - 2

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


*ផ្នែកសាសនា* — ទំព័រ

- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . . . ៩៧
- សត្តិសមាសកថា របស់ព្រះឧបាលិវង្ស សួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក . . . . ១០១
- សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់ (តមក) លោកភ៉ាយ-ប៊ុក រៀបរៀង . . ១១៣

*ផ្នែកអក្សរសាស្ត្រ*

- រឿងទេវន្ទរបស់អម្រឹតក្សត្រីម៉ុក (តមក) លោកញ៉ុក-ថែម ពិនិត្យ . . . . . . ១១៧
- រឿងសាមកុក (តមក) . . . . . . ឧកញ៉ានូ-កន ប្រែ . . . . . . . ១២៩
- រឿងអ្នកគង្វាលចៀមចិត្តស្មោះត្រង់នឹងព្រះរាជធីតា (តមក) លោកផេង-ជ្រីវ រៀបរៀង ១៤១
- រឿងចៅបាយក្ដាំង (តមក) លោកទៀង-តៃ-ឈន ប្រែរៀបរៀង . . . . . . ១៤៧
- រឿងនាងនាយចង្ក្រាន លោក លាង-ហាប-អាន រៀបរៀង . . . . . . . . ១៥១
- រឿងព្រេងនឹងរឿងបុរាណនៃប្រទេសជប៉ុន លោក ភ៉ាយ-ប៊ុក ប្រែរៀបរៀង . . . ១៦៣

*ផ្នែកកំណត់ហេតុប្រវត្តិការណ៍*

- ពិធីអនុស្សាវរីយៈ មហាសន្និបាតលើកទី ១៤ នៃមន្ត្រីសង្ឃ លោក ឯន-ប៉ង់ រៀបរៀង ១៦៧
- ដំណើរទស្សនាការសហរដ្ឋអាមេរិកនៃព្រះពោធិវង្ស (តមក) លោកជា-ទន់ រៀបរៀង ១៧១
- ពិធីទទួលព្រះត្រៃបិដកអក្សរទីបេត៌លោក ភ៉ាយ-ប៊ុក រៀបរៀង . . . . . . . . ១៧៧
- ពិធីទទួលព្រះត្រៃបិដកអក្សរចិន ស្រី អ៊ូ រៀបរៀង . . . . . . . . . . ១៨៣
- វចនានុក្រមសំស្ក្រឹត ខ្មែរ (តមក) ព្រះមហាបាង-ខាត់ រៀបរៀង . . . . . ១៩២


មួយឆ្នាំមាន ១២ សៀវភៅ ដំរៃប្រជាវ ២៣០៛០០

**KAMBUJASURIYA**

Revue religieuse et littéraire
éditée par l'Institut Bouddhique

## TABLE DES MATIERES

*PARTIE RELIGIEUSE* :

-Histoire du Bouddhisme au Cambodge par Vén. *PANG-KHAT* . . . . . . . . . . . . . . . . . . 97
-Sabbhisamasakatha (suite) par Vén. *SO-HAY* . . . . . . 101
-Réflexion d'un Bouddhiste (suite) par *M. RAY-BUC* . . 113

*PARTIE LITTERAIRE* :

-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* . . . . . . . 117
-Histoire de Samkok (suite) traduit par *M. NOU-KAN* . . 129
-Le Berger fidèle de la princesse (suite) par *M. PHENG-CHRIV* . . . . . . . . . . . . . 141
-Légende de «Sieur Croûte de riz» (suite) traduit par *M. TIANG-TAY-CHHUN* . . . . . . . . . . 147
-Histoire du Cendrillon traduit par *M. LEANG-HAP-AN* . 151
-Conte et légende du Japon traduit par *M. RAY-BUC* . 163

*NOTES ET CHRONIQUES* :

-Quatorzième réunion annuelle des dignitaires religieux pour l'année 1958 par *M. EN-PANG* . . . . . . 167
-Voyage du Vén. Huot-Tat aux U.S.A (suite) par *M. CHEA-TON* . . . . . . . . . . . . . . . 171
-Cérémonie de réception des Tripitaka en langue tibétaine par *M. RAY-BUC* . . . . . . . . . . 177
-Cérémonie de réception des Tripitaka en langue chinoise par *M. SREY-OU* . . . . . . . . . . . 183
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT* . . . . . . . . . . . 192

---

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

# ផ្នែកសាសនា

## ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

ប្រទេសខ្មែរបានទទួលអរិយធម៌ឥណ្ឌាទុកជាមត៌ក តាំងពីបុរាណ-កាល, សាសនាព្រាហ្មណ៍ក្ដី ពុទ្ធសាសនាក្ដី ដែលបានមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ក៏ក្លាយទៅជាអរិយធម៌សម្រាប់ប្រទេស ប្រជាជនខ្មែរបានរក្សាអរិយធម៌នោះទុកជាប្រពៃណីដោយប្រពៃ តពូជពង្សរៀងរាបរហូតមកដល់បច្ចុប្បន្នកាល ។ ដើមឡើយ, បុព្វជនខ្មែរ ក៏ដូចជាបុព្វជននៃមនុស្សទាំងឡាយ លើភិភពលោកសម័យមុនប្រវត្តិសាស្ត្រដែរ តែងតែគោរពលោកធាតុគឺ ទឹក ដី ភ្លើង ខ្យល់ អារក្ស ទេពារក្ស ព្រះធរណី ព្រះពាយ យកឈើព្រៃក្តីក្រំថ្មដាទីពឹងទីរឭក សម្រាប់បង្ក្រាបភ័យតក់ស្លុតដូចយើងបានឃើញការលៀងអារក្ស ជាទំនៀមយើង ក្នុងកាលសព្វថ្ងៃនេះ សមនឹងពុទ្ធភាសិតថា (១):

១- ធម្មបទ ។

"មនុស្សទាំងឡាយច្រើន ដែលត្រូវភ័យគម្រាមហើយ
តែងយកភ្នំព្រៃ អារាម ឈើ ចេតិយ ជាទីពឹងទីរឭក នុះ
មិនមែនជាសរណៈក្សេមទេ នុះមិនមែនជាសរណៈឧត្តមទេ ។

សម័យតមក ប្រជាជនខ្មែរស្រាល់ជ្រើសយកសាសនាតែមួយ ដែលខ្លួនយល់ឃើញថាជាសរណៈឧត្តម អាចបង្ក្រាបភ័យតក់ស្លុតបាន អាចសម្រេចសេចក្តីប្រាថ្នា នឹងសេចក្តីសង្ឃឹមបាន ព្រមទាំងអាចបញ្ចាក់នូវសេចក្តីទុកចិត្តរបស់ខ្លួន ទៅអនាគតបានផង សមដូចពុទ្ធភាសិតថាៈ(១)

"អ្នកណាបានដល់នូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃ
ទុកជាទីពឹងទីរឭក បានឃើញច្បាស់នូវអរិយសច្ច
ទាំង ៤ ដោយប្រាជ្ញាប្រពៃ គឺទុក្ខសច្ច ១
សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ចមាន
អង្គ ៨ ជាដំណើរទៅកាន់ក្តីរម្ងាប់ទុក្ខ ១
នុះឯងជាសរណៈក្សេម នុះឯងជាសរណៈឧត្តម
អ្នកនោះ ទើបរួចចាកទុក្ខទាំងពួងបាន ព្រោះ
អាស្រ័យនូវសរណៈឧត្តមនេះ,, ។

ក្នុងសាសនាបានទូន្មានអប់រំប្រជាជនខ្មែរ ហើយបង្រៀនឲ្យចេះប្រើជីវិតគស្ម យកឈ្មោះនូវដំណើរក្តីនិយមនៃបុព្វជន គ្រាតែរសព្រះធម៌ជ្រួត

---

១ ធម្មបទ ។

ជ្រាប ក្នុងសាច់ឈាមនិងជីវិតចិត្តថ្លើមរៀងរាល់ថ្ងៃ ។ តាំងពីបានចូលមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ព្រះពុទ្ធសាសនាក៏បានតាំងនៅស៊ប់ឥតសាបសូន្យទៅក្នុងវេលាណាមួយឡើយ គ្រាន់តែមិនបានបញ្ចេញឈ្មោះជាផ្លូវការ ឬមិនបានទទួលក្តីប្រោសប្រាណពីរាជសំណាក់ ក្នុងកាលខ្លះប៉ុណ្ណោះ ហើយផ្សាយឥទ្ធិពលទៅលើសិល្បៈ និងអក្សរសាស្ត្រខ្មែរទៀតផង ។ ក្នុងសម័យភាប់ទុន ព្រះពុទ្ធសាសនាអាចជ្រកជ្រៀតនៅជាមួយសាសនាព្រាហ្មណ៍បាន ហើយឋិតថេរចិរកាល នៅរហូតមក ដូចប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរបង្ហាញឱ្យឃើញស្រាប់ ។

ប្រភពផ្សាយពុទ្ធសាសនាចូលមកប្រទេសខ្មែរ. ក្រោយពុទ្ធបរិនិព្វានទៅ ប្រមាណជា ២១៨ ឆ្នាំ មានព្រះរាជាមួយអង្គព្រះនាមព្រះបាទធម្មាសោកមហារាជ បានឡើងសោយរាជ្យក្នុងព្រះរាជធានីបាត-លិបុត្តនៃមគធរដ្ឋ ។ ព្រះរាជាអង្គនេះ ប្រកបដោយឫទ្ធានុភាពច្រើន ផ្សាយតេជានុភាពទូទៅពេញប្រទេសឥណ្ឌា ។ ទ្រង់បានចូលកាន់ពុទ្ធសាសនាហើយ បានជាព្រះរាជូបត្ថម្ភក្នុងការធ្វើតតិយសង្គាយនា ព.ស. ២៣៤ ។ លុះធ្វើតតិយសង្គាយនាហើយ ទ្រង់បានបញ្ជូនសមណទូតទៅកាន់បច្ច-ន្តប្បទេសនានា ផុតពីដែនដីមជ្ឈិមប្រទេសមុនដំបូងអង្គស់ ក្នុងប្រវត្តិពុទ្ធសាសនា ។ ការបញ្ជូនសមណទូតទៅប្រកាសពុទ្ធសាសនា នៅ

ប្រទេសនានាគ្រានេះ ឈ្មោះថា ទ្រង់បានបើកនាំងសកលលោក ហើយ បំភ្លឺឲ្យប្រជានិករបានស្គាល់ពុទ្ធសាសនា តាំងពីកាលនោះមក ។ ក្នុងបច្ចុប្បន្នកាលនេះ ពិភពលោកទាំងមូល បានទទួលស្គាល់ពុទ្ធសាសនា ហើយ នៅទ្វីបអឺរ៉ុបក្តី ទ្វីបអាមេរិកក្តី ទ្វីបអាហ្វ្រិកក្តី ស្ទើរតែមិនមានទីបន្ទោះ មានជនានុជនចូលកាន់សាសនាពុទ្ធតែង កាន់តែកើនច្រើនឡើង ហើយ ឥឡូវនេះ មានទីឋានណាមួយ ដែលមិនស្គាល់ពុទ្ធសាសនា? ឃើញថា បានលទ្ធផលសមតាមព្រះពរបំណងព្រះអង្គមែន ។

យើងបានដឹងតាមប្រវត្តកោះសិរីលង្កាថា ក្រោយកាលធ្វើតតិយសង្គាយនា ព្រះមោគ្គលិបុត្តតិស្សត្ថេរ បានបញ្ជូនព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរមកកាន់សុវណ្ណភូមិ ក្រោមព្រះរាជូបត្ថម្ភនៃព្រះបាទធម្មាសោកមហារាជ (១) ដូចសេចក្តីក្នុងគម្ពីរបឋមសមន្តបាសាទិកា ចែងទុកថា:

"ធ្វើតតិយសង្គាយនារួចហើយ ព្រះមោគ្គលិបុត្តតិស្សត្ថេរត្រិះរិះថា ព្រះពុទ្ធសាសនានឹងតាំងនៅដោយប្រពៃ ក្នុងទីឋានណាហ្ន៎? ព្រះមហាថេរត្រិះរិះហើយឃើញថា ព្រះពុទ្ធសាសនានឹងតាំងនៅដោយប្រពៃ ក្នុងបច្ចន្តប្បទេសទាំងឡាយ ស្រេចហើយព្រះមហាថេរក៏បានបញ្ជូនភិក្ខុទាំងឡាយជាសមណទូតកាន់ទីនោះ ។"

---

១ - គ្រងពាហិរនិទានវណ្ណនា, មហាវង្ស ។

( មានត)

# សត្តិសមាសកថា

របស់ព្រះឧបាលិវង្ស ស៊ុវ - ហ៊ាយ វត្តឧណ្ណាលោម ក្រុមជំនុំព្រះត្រៃបិដក

( តមក )

## ៣) តណ្ហាសន្ថវៈ សេចក្តីស្និទ្ធស្នាលចំពោះតណ្ហា ។

## អធិប្បាយ

១) ពាក្យថា "សេចក្តីស្និទ្ធស្នាលចំពោះធម៌" បានដល់ការយកចិត្តទុកដាក់ ក្នុងធម៌ទាំងឡាយ ដែលព្រះអរិយៈមានព្រះពុទ្ធជាដើមសំដែងទុកមកហើយ ។ ពាក្យថា "ធម៌ទាំងឡាយ" នេះលេបសេចក្តីបានច្រើនណាស់ ក្នុងទីនេះមិនបានប្រែសព្ទរបស់ពាក្យថា "ធម៌" ឲ្យជាប់មកបានឡើយ ប៉ុន្តែពាក្យថា "ធម៌" ក្នុងទីនេះ លោកសំដៅយកពុទ្ធវចនៈទាំងអស់គឺព្រះត្រៃបិដក ដែលព្រះអង្គបញ្ញត្តសំដែង បង្អុលបង្ហាញហេតុផល ជាគោល ជាគំនូស ឲ្យសត្តនិករយល់ឃើញដោយខ្លួនឯង ហើយស្ម័គ្រចិត្តប្រព្រឹត្តតាមសមគួរដល់ភេទរបស់ខ្លួន ។ ឯពាក្យថា "ព្រះត្រៃបិដក" នេះ ជាឈ្មោះទាំងធម៌ទាំងវិន័យ ជួនកាលលោកហៅថា " បាវចនៈ " ប្រែថា " ពាក្យជាប្រធាននៃព្រះសម្មាសម្ពុទ្ធ" ឬប្រែថា "ព្រះពុទ្ធសាសនា" ដូច្នេះក៏បាន ដោយហេតុថា លោកកាប់យកគោលធម៌មួយ វិន័យមួយ ទាំងពីរមាត់នេះ រួមមកហៅថា "សាសនា" ។ ពាក្យថា "ធម៌" បាត់ជាបិដកមាន ២ គឺសុត្ត-

ន្តបិដក ១ អភិធម្មបិដក ១ ។ សុត្តន្តបិដកនោះ ប្រដាប់ដោយធម្មក្ខន្ធ ២១០០០, អភិធម្មបិដក ប្រដាប់ដោយធម្មក្ខន្ធ ៤.២០០០ ។

សុត្តន្តបិដក មាននិកាយ ៥ គឺ ទីឃនិកាយ សំដែងដោយសូត្រ មានសេចក្តីវែងៗ, មជ្ឈិមនិកាយ សំដែងដោយសូត្រ យ៉ាងកណ្តាលៗ, សំយុត្តនិកាយ សំដែងដោយសូត្រ ដែលប្រកបផ្សំនឹងហេតុ ឬ បុគ្គលៗ អង្គុត្តរនិកាយ សំដែងធម៌ជាពួកជាកងៗ, ខុទ្ទកនិកាយ សំដែងដោយសូត្រតូចៗ ។

អភិធម្មបិដក មាន ៧ គម្ពីរ គឺធម្មសង្គណីៗ វិភង្គៗ ធាតុកថាៗ បុគ្គលបញ្ញត្តិៗ កថាវត្ថុៗ យមកៈៗ មហាបដ្ឋានៗ ។

វិន័យបិដកនោះ ចាត់ជាខន្ធមាន ២១០០០ ខន្ធ ។ បើចែកតាមពួកយ៉ាងខ្លី មាន ២ យ៉ាងគឺ អនាគារិយវិន័យ វិន័យសម្រាប់បព្វជិតៗ អាគារិយវិន័យ វិន័យសម្រាប់គ្រហស្ថៗ ។

វិន័យបិដកមាន ៥ គម្ពីរគឺ មហាវិភង្គៗ បាចិត្តិយៗ មហាវគ្គៗ ចុល្លវគ្គៗ បរិវារៈៗ ។ ពាក្យថា "វិន័យ" នេះ បានដល់ច្បាប់ ដែលចាប់ទាក់ទងដោយព្រះបញ្ញត្តិ និងព្រះអនុញ្ញាត ដែលតែងតាំងទុកដោយព្រះ-អាជ្ញាចាត់ជាសិក្ខាបទ ឬ ជាមាត្រាមួយៗ និងអភិសមាចារៈ ដើម្បីទូន្មានកាយៈវាចារបស់ព្រះបរិស័ទ ឲ្យមានសណ្តាប់ធ្នាប់រៀបរយល្អឡើង ។

ពាក្យថា "បិដក" មានសព្ទដែលត្រូវប្រែដូចតទៅនេះ ៖

ប្រែថា

១- គ្រឿងបញ្ចេញនូវអត្ថ,

២ គ្រឿងបញ្ចេញនូវធម៌,

៣- ភាជនៈ នៃបរិយត្តិ គឺការសិក្សា ឬមេរៀន ,

៤- ផ្លោះសំឡេង គឺធម្មជាតសម្រាប់បោះបញ្ចេញនូវសំឡេង ,

៥- គម្រោ គឺក្បួន ឬច្បាប់ដែលកត់ត្រាទុក ,

៦. ល្អី ឬកញ្ជើ ,

៧- ការរួបរួមប្រមូលទុក ( នូវឯកសារ ) ។

ព្រះត្រៃបិដកនេះ ជាឈ្មោះគម្ពីរនៃព្រះពុទ្ធសាសនា កាលបើបុគ្គលណាមួយ ទោះបព្វជិត ឬគ្រហស្ថ បានសិក្សាអប់រំល្អហើយ អាចនាំឲ្យជ្រះ បំភ្លឺ ឃើញសារប្រយោជន៍ទាំងផ្លូវលោកផ្លូវធម៌ ។ ព្រះត្រៃបិដកនេះមានទ្រឹស្តី (ពាក្យពន្យល់ឲ្យឃើញហេតុផល) ជាច្រើនយ៉ាង, មានអត្ថបទល្អៗ ជាច្រើនណាស់, មានវប្បធម៌ ក្នុងផ្នែកអក្សរសាស្ត្រ ក៏បរិបូណ៌ណាស់, ធម៌ជាន់ខ្ពស់ គឺសមាបត្តិ, ឈាន, មគ្គផលនិព្វាន ដែលជាទីដៅរបស់ព្រះពុទ្ធសាសនា ក៏មាននៅក្នុងព្រះត្រៃបិដក ដោយបរិបូណ៌ ។ ព្រះត្រៃបិដកទុកជាឯកសារ ដ៏ប្រសើរបំផុត ឈ្មោះថា ជាឃ្លាំងរបស់វប្បធម៌ក្នុងផ្នែកអក្សរសាស្ត្រ ទាំងជាប់ទាក់ទងដោយផ្លូវវិទ្យាសាស្ត្រផង ។

ការសិក្សារបស់មនុស្សនៅក្នុងលោក ដើម្បីចេះដឹងតែខាងវិជ្ជាផ្លូវ

លោក ឈ្មោះថា មានភ្នែកផ្លូវលោក, ការសិក្សាគម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនា ដើម្បីចេះដឹងកុងផ្លូវធម៌ ឈ្មោះថា មានភ្នែកខាងផ្លូវធម៌ ។ ការសិក្សាទាំងវិជ្ជាលោកទាំងវិជ្ជាធម៌ ឲ្យមានបញ្ញាចក្ខុគឺមើលឃើញច្បាស់ទាំងផ្លូវលោកផ្លូវធម៌ ទើបឈ្មោះថា មានភ្នែកទាំងពីរ ។ បពុជិតឬគ្រហស្ថ អ្នកមានការចេះដឹងច្រើន ដោយសារការសិក្សាមើលច្បាប់ទម្លាប់ច្រើន ទើបហៅថា ជាបុគ្គលពហុស្សូត ជាអ្នកមានភ្នែកក្តីទាំងពីរ គឺភ្នែកលោក ភ្នែកធម៌ ។

ព្រះសារីបុត្រជាអគ្គសាវ័កខាងស្តាំរបស់ព្រះសម្មាសម្ពុទ្ធ ជាឯតទគ្គៈ (មានកិត្តិសព្ទពីរោះល្បីល្បាញ នោះ) ព្រោះហេតុតែលោកសិក្សារៀនសូត្រច្រើនចំពោះខ្លួនផង កសាងគម្ពីរដីកាជាធម្មទាន ដើម្បីឲ្យគេរៀនសូត្រតទៅផង ទើបព្រះសារីបុត្រ មានប្រាជ្ញាឈ្លាសវៃស្រួចស្រាលល្បីល្បាញបន្ទាប់បន្សំនឹងព្រះសម្មាសម្ពុទ្ធ ដោយអានិសង្ស ធម្មទាន ដែលលោកបានសាងកសាងមក ព្រោះថា ធម្មទាន ជាទានប្រសើរណាស់ជាងអាមិសទានទាំងអស់ សមដូចពុទ្ធភាសិតថា

សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ សព្វទុក្ខំ តណ្ហក្ខយោ ជិនាតិ ។

ធម្មទាន រមែងឈ្នះអាមិសទានទាំងអស់ ធម្មរស រមែងឈ្នះរសទាំងអស់ សេចក្តីត្រេកអរក្នុងធម៌ រមែងឈ្នះតម្រេកទាំងអស់ ការអស់

តណ្ហា រមែងឈ្នះសេចក្ដីទុក្ខទាំងអស់ ។ ពុទ្ធភាសិតនេះ បំភ្លឺសេចក្ដីថា " បណ្ដាទានទាំងអស់ មានតែធម្មទាន ទើបជាទានប្រសើរខ្ពង់ខ្ពស់អាចឲ្យសម្រេចផលានិសង្ស ក្នុងលោកនេះផង ក្នុងលោកខាងមុខផង" ។ ពាក្យថា "ធម្មទាន" សំដៅយកទាំងការរៀនសូត្រដោយខ្លួនឯងទាំងការសំដែងឲ្យអ្នកដទៃស្ដាប់ ទាំងការបង្រៀន ទាំងការកសាងគម្ពីរដីកាដោយការជាវទុកសម្រាប់សាធារណជន ដើម្បីសិក្សារៀនសូត្រតទៅ ។

សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ បានប្រែព្រះត្រៃបិដកពីបាលីមកជាភាសាខ្មែរ ចប់ស្រេចហើយ, បានបោះពុម្ពដល់ភាគទី៩២ហើយ ។ លោកអ្នកផលត្រូវការក្នុងវិប្បធម៌ក្ដី ក្នុងផ្លូវសីលធម៌រិយធម៌ក្ដី ក្នុងផ្លូវប្រតិបត្តិធម៌ក្ដី គួរអានមើល គួរពិនិត្យ គួរជាវទុកជាសម្បត្តិប្រចាំជីវិត ដើម្បីនឹងសិក្សាតអាយុព្រះពុទ្ធសាសនាទៅអនាគត ។ ព្រះត្រៃបិដកជាគម្ពីរនៃព្រះពុទ្ធសាសនានេះ សម្បូណ៌ដោយរឿងនិទាន, ដោយអត្ថបទដ៏ល្អច្រើនណាស់, ដោយវប្បធម៌ផ្នែកខាងអក្សរសាស្ត្រដោយគល្យាណវត្តជាច្រើនណាស់។ ព្រះត្រៃបិដក ទុកជាមូលដ្ឋាននៃព្រះពុទ្ធសាសនាដោយពិត ។

សេចក្ដីស្ងួតស្ទាល, សេចក្ដីជ្រះថ្លាពេញចិត្ត ចំពោះធម៌នេះ ទុកជាករណីយកិច្ចដ៏ឧត្ដម របស់មនុស្សសប្បុរស គឺមនុស្សល្អដែលអាចធ្វើបានជាមួយនឹងពួកសប្បុរស ហើយជាបុញ្ញកម្មមួយដ៏ប្រសើរបំផុត របស់យើង

អ្នករស់នៅក្នុងលោក ដែលអ្នកមានគុណមគតិទាំងឡាយ គួរបំពេញឲ្យកើតមាន សម្រាប់ជីវភាព ដែលបំណាច់កើតមកជាមនុស្ស តាមព្រះពុទ្ធសាសនា ។

២) ពាក្យថា "សេចក្តីស្និទ្ធស្នាលចំពោះបុគ្គល" សំដៅយកមនុស្សជាបុរសក្តី ជាស្ត្រីក្តី ជាគ្រហស្ថក្តី ជាបព្វជិតក្តី ដែលមានសីលធម៌ ឬពុំទាន់មានសីលធម៌នៅឡើយ ប៉ុន្តែជាមនុស្សគួរសេពគប់ ក៏ត្រូវតែធ្វើនូវសេចក្តីស្និទ្ធស្នាលរាប់អាន ទទួលស្គាល់ ដោយគោរព ដើម្បីចងសាមគ្គីភាពក្នុងរវាងគ្នានឹងគ្នា ឲ្យកើតផ្កាយចូលៈយតទៅ ។

## លក្ខណៈ ៣ យ៉ាងទៀត

១) ពាក្យថា "សេចក្តីស្និទ្ធស្នាលចំពោះលោក" បានដល់សេចក្តីស្រឡាញ់ពេញចិត្ត ប្រកបដោយសេចក្តីសន្តោស ចំពោះលោកដែលកើតឡើងហើយប្រកបដោយធម៌ មិនត្រូវរំលោភហួសប្រមាណ ហួសហេតុក្នុងការស្នេហ៍រកលោកនោះឡើយ ព្រោះការស្នេហ៍រក ការចង់បានដែលប្រាសចាកធម៌សន្តោស ច្រើនតែនាំឲ្យមានការប្រព្រឹត្តទុច្ចរិត មានការរំលោភដ៏ះដាន់ជាដើម ។

២) ពាក្យថា "សេចក្តីស្និទ្ធស្នាលចំពោះមិត្ត" បានដល់ការស្គាល់ស្និទ្ធយល់ចិត្តថ្លើមគ្នា, ការសង្គ្រោះមិត្រសំឡាញ់ ដោយប្រយោជន៍ណាមួយ ក្នុងកាលដែលមិត្រសំឡាញ់ត្រូវការ ឬមានគ្រោះថ្នាក់ ដើម្បីទំនុក

បំរុងមិត្រផ្សាភ្ជាប់មិត្តភាពរវាងខ្លួននឹងមិត្រសំឡាញ់ មិនឲ្យប្រេះឆារបែក
សាមគ្គីរវាងមិត្ត ។

៣) ពាក្យថា "ស្និទ្ធស្នាលចំពោះតណ្ហា" បានដល់ការប្រព្រឹត្តិរបស់មនុស្សបុថុជ្ជន ដែលច្រើនតែលុះក្នុងអំណាចនៃតណ្ហា ដោយពិត ប៉ុន្តែធម្មតា មនុស្សជាសប្បុរស ទោះបីធ្វើការណាមួយដោយកាយវាចា តែងស្គាល់ប្រមាណក្នុងករណីយកិច្ចជាដរាប ពុំបានលុះលង់គំនិត ពុលស្រវឹងទៅក្នុងកិច្ចការនោះ ៗ ឲ្យហួសប្រមាណទេ តែងភ្ញាក់ដឹងខ្លួនរឿយៗ ដោយអំណាចការចេះដឹង ។ ការស្និទ្ធស្នាលចំពោះអារម្មណ៍ទាំងអស់ ដែលប្រកបដោយរាគតណ្ហា លោកចាត់ថា ជាបហាតព្វកិច្ច គឺកិច្ចដែលត្រូវលះបង់ មិនត្រូវបណ្ដោយឲ្យរាគតណ្ហាគ្របសង្កត់ ញាំញីចិត្តរបស់ខ្លួនបានឡើយ ។

បុគ្គលដែលបានធ្វើសេចក្ដីស្និទ្ធស្នាល ដោយការពេញចិត្តជ្រះថ្លាចំពោះធម៌ ចំពោះបុគ្គលដូចរៀបរាប់មកនេះ ឈ្មោះថាជាឧត្តមបុរសក្នុងលោក ។ បុគ្គលជាអ្នកប្រាជ្ញ ដែលត្រូវអ្នកឯទៀតចូលទៅសេពគប់ តែងតែព្រមានដាស់តឿនចង្អុលប្រាប់ប្រយោជន៍ ក្នុងផ្លូវនាំឲ្យបានជួបប្រទះនូវសុភមង្គលដល់អ្នកឯទៀតជាដរាប មិនដែលបង្ហាញផ្លូវដើម្បីឲ្យវិនាសចាកប្រយោជន៍ឡើយ សមដូចពុទ្ធភាសិត ក្នុងធម្មបទខុទ្ទកនិកាយ ថា

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ ។

បុគ្គលដែលឃើញបណ្ឌិតណា ជាអ្នកមានប្រាជ្ញា ចង្អុលបង្ហាញទោស ពោលពាក្យសង្កត់សង្កិន (ដោយទុច្ចាយល្អ) ដូចមនុស្សប្រាប់កំណប់ទ្រព្យ គួរសេពគប់បណ្ឌិតនោះចុះ ។ ពុទ្ធភាសិតនេះ បញ្ជាក់ពីការគប់ឲ្យឃើញថា "បណ្ឌិតតែងដឹកនាំគេ ចង្អុលប្រាប់ផ្លូវទៅរកគុណ មិនដែលដឹកនាំគេទៅរកទោសទេ ទោះបីមានមាត់ពាក្យគម្រាមកំហែង តាមវិធីប្រៀនប្រដៅខ្លះក៏ដោយ ត្រូវតែចូលទៅជិតសេពគប់ ដើម្បីចម្លងរបៀបផ្សេង ៗ ផង ដើម្បីញ៉ាំងសម្ពន្ធភាពមិនឲ្យប្រេះឆាផង " ។

មនុស្សទាំងអស់ក្នុងលោក តែងជាប់ទាក់ទងដោយការសេពគប់គប់រកគ្នាដោយពិត ប៉ុន្តែការសេពគប់នោះ នាំមកនូវសេចក្តីចំរើនក៏មាន នូវសេចក្តីវិនាសក៏មាន ព្រោះហេតុនោះ បានជាព្រះអរហន្ត សម្មាសម្ពុទ្ធត្រាស់ថា " បុគ្គលត្រូវពិចារណាស្ដាប់ស្ទង់ឲ្យឃើញជាមុន សឹមសេពគប់ជាខាងក្រោយ ព្រោះការសេពគប់នេះ ទុកជាបញ្ហាមួយក្នុងជីវភាពរបស់មនុស្ស" ។ បើបុគ្គលសេពគប់ ចំពោះមនុស្សសប្បុរសជាអ្នកចេះដឹង រមែងបានស្តាប់នូវធម៌គាថាណាមួយ ក្នុងសំណាក់លោកអ្នកចេះដឹងពុំខាន បើសេពគប់ចំពោះមនុស្សអសប្បុរស ជាអ្នកមិនចេះដឹង ជាមនុស្សប្រព្រឹត្តទុច្ចរិត ក៏រមែងបានស្តាប់នូវពាក្យ តិរច្ឆានកថាដែលមិនមែនជាធម៌វិន័យ ។ សេចក្តីសង្ស័យកើតឡើងចំពោះ ក្នុងធម៌ទាំងឡាយណាមួយ កាលបើបុគ្គលមានបំណងដើម្បីដោះស្រាយ ត្រូវចូលទៅ

តែមនុស្សសប្បុរសអ្នកចេះដឹង ទើបអាចដោះស្រាយសេចក្តីសង្ស័យបាន មិនមែនដោះស្រាយ ក្នុងសំណាក់នៃមនុស្សអសប្បុរសបានឡើយ ។ លោកអ្នកសប្បុរស គឺអ្នកចេះដឹង ជាអ្នកទទួលភារៈក្នុងការដោះស្រាយបញ្ហាដែលបុគ្គលត្រូវការជាអ្នកដឹកនាំ នូវសេចក្តីយល់ភាន់ច្រឡំ របស់មនុស្សឲ្យយល់ឃើញត្រូវ ឲ្យមានសតិសម្បជញ្ញៈគ្រប់គ្រាន់ តាមសមគួរដល់សមត្ថភាព របស់ខ្លួន ឲ្យស្គាល់ចំណែកនៃសេចក្តីប្រតិបត្តិខាងដើម កណ្តាលនិងខាងចុង តាមជំនាន់វ័យរបស់មនុស្ស ។ ធម្មតាលោកអ្នកសប្បុរស អ្នកមានកាយវាចាចិត្តស្ងប់រម្ងាប់ តែងដឹកនាំជនទាំងឡាយ ឲ្យបែរមុខឈមទៅរកសេចក្តីស្ងប់រម្ងាប់ចាកបាបអកុសលទាំងពួង ឲ្យមានកាយវាចាចិត្តបរិសុទ្ធផូរផង់ ដើម្បីដោះខ្លួនឲ្យរួចចាកទុក្ខភ័យទាំងលោកនេះនិងលោកខាងមុខ ដូចអត្ថបទទី ៣ តទៅនេះ

៣ សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ បុគ្គលដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរួចចាកទុក្ខទាំងពួង ។

អត្ថបទនៃពុទ្ធភាសិតទីបំផុតនេះ សំដែងចំពោះអានិសង្ស គឺលទ្ធផលដែលកើតមកអំពីការចេះដឹង, ការយល់ត្រូវ, ការប្រតិបត្តិត្រូវ, ឯការចេះដឹងយល់ត្រូវក៏កើតមកអំពីការសេពគប់លោកអ្នកសប្បុរសដោយពិត ។ បុគ្គលអ្នករួចចាកទុក្ខគ្រប់យ៉ាង មានជាតិទុក្ខជាដើម ដែលជាពិសេសបំផុតនោះ ក៏ព្រោះហេតុនៃការចេះដឹងនូវព្រះសទ្ធម្ម ដែលជាពាក្យ

ប្រៀនប្រដៅរបស់លោកអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្ពុទ្ធជាដើម ។

ព្រះសទ្ធម្ម បើនិយាយដោយខ្លីមាន ៣ យ៉ាង

១) បរិយត្តិសទ្ធម្ម ព្រះសទ្ធម្ម គឺជាមេរៀនសូត្រ

២) បដិបត្តិសទ្ធម្ម ព្រះសទ្ធម្ម គឺជាផ្លូវប្រតិបត្តិ

៣) បដិវេធសទ្ធម្ម ព្រះសទ្ធម្មគឺជាគន្លងដើម្បីត្រាស់ដឹង ។

ពុទ្ធវចនៈ គឺព្រះត្រៃបិដក ដែលលោកអ្នកប្រាជ្ញ បានសង្គាយនា រៀបចំទុកមក មានអង្គ ៩ មានសុត្តៈ គេយ្យ ជាដើម ដែលជាមេរៀន ក្នុងថ្នាក់ជាដំបូង ហៅថា "បរិយត្តិសទ្ធម្ម" ។

សេចក្តីជ្រះថ្លាពេញចិត្ត, សេចក្តីយល់ច្បាស់ ក្នុងកុសលធម៌ទាំងឡាយដែលគួរចំរើនផង ក្នុងអកុសលធម៌ទាំងឡាយដែលគួរលះផង របស់បព្វជិត ឬ គ្រហស្ថ ដែលអាចចូលចិត្ត យល់សេក្តីច្បាស់លាស់ដោយខ្លួនឯង ហើយបានទទួលគុណវិសេស តាំងអំពីឈានសមាបត្តិ រហូតដល់មគ្គផលនិព្វាន ដែលជាទីដៅដ៏ខ្ពស់បំផុត នៃព្រះពុទ្ធសាសនា ទាំងនេះ ហៅថា "បដិវេធសទ្ធម្ម" មនុស្សក្នុងសកលលោក បើស្រស់ជានាំគ្នា អនុវត្តឲ្យម៉ត់ចត់នូវព្រះសទ្ធម្មទាំងនេះ ប្រាកដជាបានទទួលផលនៃសន្តិសុខ ឃើញជាក់ច្បាស់ពុំខាន ព្រោះព្រះសទ្ធម្ម គង់ប្រព្រឹត្តទៅដើម្បីស្ងប់កិលេស, កាលបើកិលេសស្ងប់ សេចក្តីទុក្ខភ័យទាំងពួង ក៏វិនាសសាបសូន្យទៅជាលំដាប់ ។

ព្រះសទ្ធម្ម ៣ យ៉ាងនេះជាគតិបណ្ឌិតដែលអាចនឹងរៀនបិតនៅតែក្នុងវង្ស នៃលោកអ្នកសប្បុរស មិនដែលបិតនៅ មាននៅក្នុងវង្សពួកអសប្បុរសទេ កាលបើបុគ្គលត្រូវការចម្លងផ្ដិតយកព្រះសទ្ធម្មទាំងនេះ ត្រូវចូលទៅសេព-គប់លោកអ្នកសប្បុរស ដូចអធិប្បាយមកហើយតាមន័យខាងដើម ។ មួយទៀត ការសិក្សា ការហាត់រៀនទន្ទេញ ការពិនិត្យមើល ឲ្យចេះចាំយល់សេចក្ដី ក្នុងផ្លូវធម៌ទាំងឡាយ លោកហៅថា ជាបរិយត្តិ ។ ការវៀរចាកទុច្ចរិត ៣ ប្រការ ការប្រព្រឹត្តកាន់តាមសុចរិត ៣ប្រការ, ការរម្ងាប់នូវកិលេសទាំងឡាយដ៏គ្រោតគ្រាត លោកហៅថា បដិបត្តិ ។ ការយល់ធ្លុះធ្លាយ ការបាននូវគុណវិសេសមានឈានជាដើម, ការរួចចាកកិលេសថ្នាក់កណ្ដាល ឬល្អិត លោកហៅថា បដិវេធ ។

ការសិក្សាធម៌ ប្រតិបត្តិធម៌ និងការយល់ច្បាស់ក្នុងធម៌ កាលបើបុគ្គលបានចំរើន បានពិចារណារឿយ ៗ គឺរមែងឃើញជាក់ដោយប្រាជ្ញាខ្លួនឯងនូវសេចក្ដីសង្ស័យ គឺរមែងអស់ទៅចាកខន្ធសន្តាន សមដូចពុទ្ធ-ភាសិតក្នុងពុទ្ធវចន ក្នុងកាលដែលព្រះអង្គទើបនឹងបានត្រាស់ថ្មី ៗ ថា

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ ។

ប្រែថា ធម៌ទាំងឡាយ រមែងកើតប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមជាគ្រឿងដុតនូវកិលេស អ្នកពិនិត្យរំពឹងក្នុងកាលណា សេចក្តីសង្ស័យទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងសាបសូន្យទៅ ព្រោះស្គាល់ច្បាស់នូវធម៌ព្រមទាំងបច្ច័យ ក្នុងកាលណោះ ។ ពាក្យថា "ធម៌ទាំងឡាយ" ក្នុងគាថានេះ បានដល់មគ្គផល ។ ពាក្យថា "ព្រាហ្មណ៍" លោកសំដៅយក អ្នកប្រព្រឹត្តធម៌យ៉ាងតឹងរឹង ដើម្បីបន្សាត់ចោលនូវបាបមិនមែនសំដៅយកព្រាហ្មណ៍ដោយជាតិនោះទេ ។ ពាក្យថា "ធម៌ព្រមទាំងហេតុបច្ច័យ" នោះ លោកពោលចំពោះខន្ធ ៥ ព្រមទាំងហេតុគឺកិលេសដែលជាបច្ច័យគាត់តែងឲ្យកើតបញ្ចក្ខន្ធមានអវិជ្ជា តណ្ហាជាដើម ។

ធម្មទេសនា ចំពោះការប្រជុំ សេពគប់ ដោយពួកសប្បុរសក្នុងវេលានេះក៏ល្មមសមគួរ តាមកាលបរិច្ឆេទ ។ ជាទីបំផុតនេះ សូមថ្វាយព្រះរាជកុសលនៃធម្មទេសនា ចំពោះព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ, សូមថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះឧបយុវរាជ សូមឲ្យព្រះអង្គប្រកបដោយព្រះជន្មសុខគ្រប់ប្រការ! សូមជូនកុសលចំពោះលោកអ្នកពុទ្ធបរិស័ទទាំងអស់ សូមឲ្យប្រកបដោយពរទាំង ៤ ប្រការគ្រប់ៗគ្នា កុំបីឃ្លៀងឃ្លាតឡើយ !

## សេចក្តីពិចារណានៃពុទ្ធសាសនិកជនម្នាក់

## លោក រ៉ាយ-ប៊ុក រៀបរៀង

(តមក)

សួរ. ហេតុដូចម្តេច ក៏គេមិនឲ្យស្ត្រីបួសក្នុងព្រះពុទ្ធសាសនា? ។

ឆ្លើយ. បានជាគេមិនឲ្យស្ត្រីបួស ក្នុងព្រះពុទ្ធសាសនា ព្រោះថា ធម្មតាភិក្ខុនី ដែលបួសត្រូវមានឧបជ្ឈាយ៍, កម្មវាចាចារ្យ ត្រូវសូត្រជាភិក្ខុនីមានវស្សាចាស់; ក្នុងសម័យឥឡូវនេះ មិនមានភិក្ខុនីសោះឡើយ ។ បើតាមសំដែងក្នុងមិលិន្ទបញ្ហា ថា ព្រះពុទ្ធសាសនាគ្រប់ ១០០០ ឆ្នាំ គិតតាំងពីព្រះសម្មាសម្ពុទ្ធ ទ្រង់ចូលព្រះនិព្វាន, នឹងបាត់ភិក្ខុនី នៅតែពួកសីលវតី គឺឧបាសិកា អ្នកកាន់អដ្ឋង្គសីល, ពួកសិក្ខមានា គឺស្ត្រីដែលមុននឹងបួស ត្រូវកាន់សិក្ខាបទប្រាំមួយ តាំងពីបាណាតិបាត ដល់វិកាល អស់រយៈវេលាពីរឆ្នាំ ។

សួរ. ខ្ញុំមិនទាន់បានដឹងពីសីលវតី ឬ សិក្ខមានានោះទេ ការដែលខ្ញុំបានដឹងថា ហេតុដូចម្តេច បានជាបាត់ភិក្ខុនី? ។

ឆ្លើយ. មុននឹងពណ៌នាអំពីរឿងមានភិក្ខុនី ខ្ញុំសូមជំរាបថា កាលព្រះបរមគ្រូទ្រង់គង់ធរមាននៅឡើយ, ព្រះនាងមហាបជាបតី-

គោតមី ជាម្ដាយមីង ជាម្ដាយចិញ្ចឹមព្រះអង្គ បានចូលទៅក្រាបបង្គំទូលសូមឧបសម្បទា ជាភិក្ខុនី ព្រះអង្គទ្រង់មិនយល់ព្រមសោះឡើយ ។ លើកទីពីរព្រះអានន្ទត្ថេរបានទៅក្រាបបង្គំទូល សូមព្រះអង្គឲ្យទ្រង់ពុទ្ធានុញ្ញាតឲ្យព្រះនាងមហាបជាបតីគោតមីបួសជា ភិក្ខុនី, ព្រះអង្គទ្រង់មិនព្រមជាដាច់ខាត ។ ដល់លើកទីបី ព្រះអានន្ទត្ថេរ ក៏ដើរឧបាយដើម្បីញ៉ាំងព្រះហឫទ័យព្រះអង្គឲ្យអនុញ្ញាត ឲ្យព្រះនាងមហាបជាបតីគោតមី បួសជាភិក្ខុនីបាន ។ ព្រះអានន្ទត្ថេរដ៏មានអាយុ បានក្រាបបង្គំទូលសួរព្រះអង្គថា ចំពោះស្ត្រី ដែលបានលះបង់ឃរាវាសហើយ ទៅប្រព្រឹត្តបតិបត្តិតាមធម៌ ធ្វើសមាធិកម្មដ្ឋាន តាមបរមពុទ្ធោវាទ តើការប្រព្រឹត្តនោះនឹងបានមគ្គផល ឬ ទេព្រះអង្គ? ។

ព្រះសម្ពុទ្ធទ្រង់តបទៅវិញថា ម្នាលអានន្ទ ផលនោះប្រាកដជានឹងបាន ។

ព្រះអានន្ទត្ថេរ ក៏ក្រាបបង្គំទូល តទៅទៀតថា បើដូច្នេះ បើព្រះនាងមហាបជាបតីគោតមី មានចិត្តស្មោះស្ម័គ្រនឹងព្រះអង្គ ដោយព្រះនាង, កាលនៅជាម្ដាយមីង ក្រោយដែលព្រះនាងស្រីមហាមាយាទេវី សោយព្រះទិវាល័យ បានបីបាច់ថែរក្សាព្រះអង្គ ដូចជាកូនចេញពីសាច់, គួរណាស់តែព្រះអង្គទ្រង់អនុញ្ញាត ឲ្យព្រះនាងបួសជាភិក្ខុនីបាន, គួរណាស់

តែព្រះអង្គទ្រង់អនុញ្ញាតឲ្យស្ត្រីលះបង់គ្រួសារ ទៅប្រព្រឹត្តប្រតិបត្តិ តាមព្រះបរមពុទ្ធោវាទ ដែលព្រះអង្គទ្រង់បានសំដែងហើយ ដោយប្រពៃ រឿងនេះ មានសំដែងក្នុងខន្ធកទី ១០ ចុល្លវគ្គនៃវិន័យបិដក ។

ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងតបទៅព្រះអានន្ទត្ថេរវិញថា " តថាគតមិនយល់ទាស់ទេ អានន្ទ បើព្រះនាងមហាបជាបតីគោតមី បង់បួសជាភិក្ខុនី ក្នុងសាសនាតថាគត ត្រូវព្រះនាងប្រព្រឹត្តប្រតិបត្តិនូវគរុកម្ម ៨ យ៉ាងសិន គឺ

១- ភិក្ខុនី, បើទុកជា ឧបសម្បទាដល់ទៅ ១០០ វស្សា ក៏ត្រូវគោរពភិក្ខុ ដែលទើបនឹងបានឧបសម្បទា ១ថ្ងៃ,

២- ភិក្ខុនី, ត្រូវនៅចាំវស្សានៅវត្តដែលមានភិក្ខុ,

៣- ភិក្ខុនី, ត្រូវតែប្រព្រឹត្តប្រតិបត្តិនូវវត្តពីរយ៉ាងគឺ, ត្រូវសួរឧបោសថ ត្រូវទទួលឱវាទពីភិក្ខុសង្ឃ ក្នុងកន្លះខែម្តង,

៤- ភិក្ខុនី, បើចេញវស្សាហើយ ត្រូវបវារណាព្រះសង្ឃទាំងពីរផ្នែក,

៥ ភិក្ខុនី, បើប្រព្រឹត្តល្មើសនឹងគរុធម៌ហើយ ត្រូវប្រព្រឹត្តខមាទោសនឹងព្រះសង្ឃទាំងពីរផ្នែក គឺព្រះសម្មតិសង្ឃ នឹងព្រះអរិយសង្ឃ,

៦- ភិក្ខុនី, ត្រូវឲ្យឧបសម្បទានាងសិក្ខមានា ដែលរក្សាសីល ៦ គឺតាំងពីបាណាតិបាតរហូតដល់វិកាល,

៧- ភិក្ខុនី មិនត្រូវសម្រេចរឿងពីរបស់ភិក្ខុ,

៨ ភិក្ខុនី មិនត្រូវបង្អាក់បង្រៀនភិក្ខុៗអាចបង្អាក់បង្រៀនភិក្ខុនីបានៗ

ម្នាលអានន្ទ, បើព្រះនាងបជាបតីគោតមី បានប្រព្រឹត្តប្រតិបត្តិតាមគរុធម៌ទាំង៨យ៉ាងសព្វគ្រប់ហើយ, តថាគត នឹងអនុញ្ញាតឲ្យបួសជាភិក្ខុនីបាន.ៗ

រឿងនេះគឺខ្ញុំដកស្រង់យកពីអដ្ឋកថាបាត អង្គុត្តរនិកាយ ៗ

ក្រៅអំពីនេះ ភិក្ខុនីត្រូវប្រព្រឹត្តប្រតិបត្តិតាមសិក្ខាបទ ៣០៩ (សិក្ខាបទរបស់ភិក្ខុមានតែ ២២៧, សិក្ខាបទរបស់ភិក្ខុនីលើស ៨២) ៗ

សួរ. ហេតុដូចម្ដេច ក៏សិក្ខាបទភិក្ខុនីមានដល់ទៅ ៣០៩ សិក្ខាបទ. លើសសិក្ខាបទភិក្ខុដល់ទៅ ៨២? ៗ

ឆ្លើយ. ព្រះបរមគ្រូទ្រង់បញ្ញត្តសិក្ខាបទភិក្ខុនី លើសសិក្ខាបទភិក្ខុដល់ទៅ៨២ សិក្ខាបទ ដោយហេតុថា បរិយា ភិក្ខុនីនោះលំបាកនឹងថែរក្សាពន់ពេក ប្រៀបដូចជា លើកទំនប់ទប់ទឹក កុំឲ្យហៀរហូរ ទៅកាន់ទីដទៃដូច្នោះ ៗ ម្យ៉ាងវិញទៀត, ស្ត្រីលំបាកនឹងសំគាល់បរិយាឲ្យច្បាស់លាស់, មានកលមាយាជាច្រើនប្រការ, មានឧបាយគ្រប់បែបគ្រប់យ៉ាង ៗ សិក្ខាបទចំពោះភិក្ខុនី ក៏តឹង ឧបសម្បទាភិក្ខុនីក៏តឹង ការដែលបំបួសភិក្ខុនី គឺត្រូវបួសចំពោះមុខព្រះភិក្ខុនីសង្ឃម្ដង រួចទើបព្រះភិក្ខុសង្ឃ សម្រេចជាអវសាន ៗ

(មានត)

# ផ្នែកអក្សរសាស្ត្រ

## រឿងទេវន្ត

ពាក្យកាព្យ

## លោក អម្ចាស់ក្សត្រីម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

## លោក ញ៉ុក ថែម ពិនិត្យ

( តមក )

សារពេជ្រពន្សពោធិ៍ មានញាណរុងរោត្យ ទៀនទូលទៅថា ៗ បពិត្រ
ព្រះគុណ ប្រសើរមហាធ្ងន់ ឥតឯទបមា ខ្ញុំនឹងថ្លាថ្លៃ សំដែងធម្មា
ប្រសើរថ្លៃថ្លា សណ្តាប់ព្រះមេ ៗ ធម្មតាជាសត្វ អន្ទោលក្នុងវដ្ត ភព
សង្សារ អនិច្ចាអនិច្ចំ ទុក្ខទុក្ខ ពៀរពិតតែងតែ ជិតជាយអង្គ ៗ
នេះហៅកម្មភាព កម្មកាយឯងភាព ឲ្យអង្គមាតា អសារអសោ អា
ស្រូវអាត្មា សូមព្រះបិត្តា រំពឹងញាន ៗ

នាងស្តាប់ពាក្យបុត្រ ថ្លាថ្លៃវិសុទ្ធ ទូលទៀនសព្វហាន ចិត្តចាប់ជួបចូល

ទទួលទូន្មាន ព្រះទ័យក្រៀមក្រាន្ត ឥតអន់ចិន្តា ៗ ទាំងប្អូនព្រះអង្គ សោមនស្សត្រេកត្រេង បដិសណ្ឋាក ទៅមកទៅវិញ ពេកពេញចិន្តា ទៀងទើបព្រះមហា- បុរសថ្កើងថ្កល់ ៗ ឲ្យរៀបប្រាសាទ មាសមួយស្អាងស្អាត ព្រះប្រោសប្រទាន ឲ្យអង្គអភ័យ ព្រះថ្វីក្សត្រក្សាន្ត គង់ក្រៀមរួមបាន នឹងនាងចន្ទា ៗ ប្រទានព្រះស្នំ ពលលៀងចាស់ទុំ អាមាត្យសេនា ទើបព្រះបមចក្រ ហៅយក្សស្វាខ្វា ចូលមកវន្ទា ព្រះបាទបមទៅ ៗ

ត្រាស់ទ្រង់ផ្តាំថា ចូរអ្នកពល់គ្នា ត្រឡប់វិលទៅ គាន់ទីគាន់បាន ពិមានលំនៅ សឹងសុខឥតសៅ ទីរនេសទុក្ខា ៗ ស្វាខ្វាអញមក ប្រាំមួយខែគត់ ឲ្យផ្លាស់ប្តូរគ្នា នានាំយកឃ្មុំ នូវអំពៅផង សួយសារសព្វគ្រា កុំឲ្យខកខាន ៗ កុម្ភណ្ឌមត់តែ មួយខែ ១ ឲ្យនាំផលសាន ផ្លែផ្កាឈូក នូវ ក្រនុឈូកមាន ក្របាប់មកថ្កាន អង្គអញពុំធុស ៗ នាអ្នកនឹងខាន នៅអាយពុំបាន ដ្បិតជាស្រុកទេស មិនសមអាស្រ័យ សព្វថ្ងៃរនេស សព្វសត្វលេបលេស លាយឡំផងគ្នា ៗ មួយសោតគ្មានអ្នក ណានឹងរួមរ័ក្ស ស្រះឃ្មុំនៅច្បារ នឹងខ្ទួចនឹងខាយ អន្តរាយទៅជា ព្រះព្រៃព្រឹក្សា សោះសូន្យស្ងប់ស្ងាត់ ៗ

កុម្ភណ្ឌស្វាខ្វា ក្រញុំក្រាបលុកលា ទៅបានវិញថ្កាត់ កែងនាំ

ដង្វាយ មកថ្វាយមហាក្សត្រ តាមព្រះបញ្ញត្ត បង្គាប់ផ្តាំផ្ញើ ។ (យើង
នឹងឈប់សេះ និទានត្រឹមនេះ តែងទុកជារឿង បីបន្ទាប់បួន ពាក្យបួន
បទ្ទំ ក្អកក្រោធប្រាប់ប្រែ ទុកគសាសនា)(១) ។

(ចប់រឿងបីតែប៉ុណ្ណោះ) ។

នឹងនិទានត តំណើតំណរ ទំនងរៀងកប ហៅជារឿងបួន
ជាប់ដួនដកប ដោយនូវសុភាព កាព្យកិច្ចលោកិយ ។ កាលព្រះ
ពង្សពោធិសត្វមោ លើសលើលោកិយ លាព្រះមាតា ក្សត្រាធិបតី
ទៅរកមហេសី ប្រសើរស្មោលស្នេហ៍ ។ សម្តេចពង្សព្រុទ្ធ ធិកជអង្គ-
ទ-ត្តមោតែងតែ គេស្រមក្សត្តសោយសុខ នឹវទុក្ខឡើយឡើ រក្សាពជ-
រដ្ឋ ប្រមាណខែបី ។ ទើបអស់ព្រាហ្មណ៍ព្រឹទ្ធ ព្រាហ្មណ៍បុរោហិត
មាត្យមុខមន្ត្រី ជួបជុំទុំគ្នា ឲ្យសារសេចក្តី ទៅយកបុត្រី ក្សត្រិយឯក
អង្គ ។ ព្រាហ្មណ៍សេលក្ខណា បានមួយគូជា មហេសីវរវង្ស ទូល
ព្រុទ្ធង្គរ ថាបួលព្រះអង្គ ទទួលរាជ្យទ្រង់ ស្នាប់ស្នងបិតា ។ យើងរើស
ក្សត្រី បានមួយជាស្រី ប្រកបលក្ខណា លើសនាងទាំងឡាយ នឹងថ្វាយ
ជាតិជា ឯកអគ្គជាយា ព្រះបាទនរបតី ។

ពោធិបមទៅ យានយាត្រាទៅ ទតរូបក្សត្រី ទាំងអស់អង្គប្រាណ

១ ដល់ចប់រឿងបី មិនទាប់ចុងជួនតទៅក្នុងរឿងបួនទេ ។

ពុំមានរបតី ត្រាស់កាន់មន្ត្រី ជាអស់ពីគា ៗ សឹងល្អស័ក្តិសម មែន-តែពិតពុំ បុព្វផងគ្នា ខ្ញុំពុំគន់គិត ចាប់ចិត្តស្នេហា ខ្ញុំនឹងសុំលា ទៅរកគូខ្ញុំ ៗ ឯអស់ក្សត្រី ចូរអស់សេនី សេនាជាធំ ឲ្យវិលវិងទៅលំនៅជួបជុំ ញាតិសាច់នឹងផ្សំឲ្យមានប្តីសី ៗ

មន្ត្រីបានស្តាប់ ទទួលបង្គាប់ បង្គំនរបតី ចាត់តាមបណ្តាំ ឲ្យនាំក្សត្រី វិលទៅបុរី ទីទៃពល់គ្នា ៗ ស្តេចក្សត្រឧត្តម ចរចូលបង្គំព្រះវរមាតា ទូលថាអញខ្ញុំ សូមសុំក្រាបលា ទៅរកពនិតា នគរដទៃ ៗ ក្រែងមានស្ត្រីណា ប្រកបលក្ខណ៍ជា ស្ត្រីរត្នថាថ្លៃ កើតនៅនាក្នុង កំឡុងភពត្រៃ ជាតិជានិស្ស័យ គួរគូផងគ្នា ៗ ខ្ញុំនឹងនាំយក នូវនាងនោះមក អភិសេកឡើងជា ឯកអគ្គទេពី មួយនេះផ្តា ដ្បិតខ្ញុំលាកលា ខ្ញុំសូមផ្ញើនៅ ៗ

នាងស្តាប់បុត្ររត្ន បន្ទូលខាំងឃាត់ កូនអើយកុំទៅ ចាកចេញចោលម្តាយ ទៅឆ្ងាយឡើយពៅ អាសូរម្តាយទៅ ដ្បិតម្តាយចាស់ហើយ ៗ មួយសោតស្រុកយើង នគរថ្កុំថ្កើង ព្រលឹងមាសអើយ បើច្នោះចូរពៅ រកនៅអាយហើយ កុំអ្នកទៅឡើយ អាសូរម្តាយពា ៗ

បពិត្រស្រុកអាយ ទោះជិតទោះឆ្ងាយ មានមែនតែថា ពុំត្រូវចិត្តខ្ញុំ ខ្ញុំសូមក្រាបលា ទៅរកស្រីជា គួរគូប្រដិពទ្ធ ៗ សូមទ្រង់បើកខ្ញុំ

ឲ្យបានទៅកុំ បីបន្ទូលឃាត់ នាងនាថស្តេងស្តាប់ សារសព្វបុត្រក្ត
ពុំអាចទាំងឃាត់ ព្រមតាមចិន្តា ។

ពន្ធកសារពេជ្ញ លាកលាស្រាប់ស្រេច ស្តេងស្តេចលីលា វិលវិង
រាជឋាន ពិមានថ្លៃថ្លា ឲ្យអស់សេនា រៀបរាជអស្សពង្ស ។ ស្រេច
ព្រះទេវិន្ទ្រ ព្រះករកាន់ខាន់ ពិសេសទ្រើសទ្រង់ គ្រប់គ្រឿងប្រដាប់
បម្រាប់អស់អង្គ គ្រចះគ្រចង់ យាត្រាចេញចរ ។ ហើយក្សត្រផ្តល់
ថ្កីង់ ស្តេចស្ទុះផែលឡើង លើអង្គអស្សតរ រូបដូចមហាព្រហ្ម
ស័ក្តិសមសន្ធរ ផ្ទះផ្ទាក់លែងអមរ មណ្ឌលសួគ៌ា ។ ហោះឯអាកាស
ក្តីផ្តេកផ្ទះផ្ទាស មើលម្តងដូចជា ព្រះឥន្ទ្រព្រះអង្គ ស្តេចគង់អស្សពាហ៍
មើលម្តងគណនា សុវណ្ណហង្សហើរ ។

រាស្ត្រទាសស្តេចស្តេង យង់យល់ស្ងប់ស្ងែង ក្សត្រក្សាន្តប្រសើរ
ហេតុព្រះពង្សពុទ្ធ ជាម្ចាស់លើសលើ ក្សត្រផងឥតបើ នឹងប្រៀបឧបមា ។
អស់ព្រាហ្មណ៍គរី ព្រាហ្មណ៍ព្រឹទ្ធមន្ត្រី ទាំងពីរអនុជា នូវអស់ព្រះស្ន
ចាស់ទុំស្រីផ្កា ទាំងនាងវិមលា បំរើនពារបុត្រ ។ សូមព្រះអង្គឥន្ទ្រ
សហស្សចក្ខុន្ទ្រ ព្រហ្មព្រឹទ្ធវិសុទ្ធ វិសេសថ្លៃថ្លា ទេវតាទេវបុត្រ យក្ខ
យង់គ្រុងគ្រុឌ នាគានាគី ។ មួយម៉ឺនចក្រវាឡ ទាំងទេពបាដាល
ផលសាគរណី សូមជួយបំបាត់ ជម្ពាត់ព្យាធិ បំរើនវុឌ្ឍិ-សេសសម-

ពណ្ណរាយ ៗ ឲ្យប្រកបរិទ្ធិ ប្រសើរប្រសិទ្ធិ លែងលោកសម្ងាយ ប្រាស
លែងទុក្ខា ភយាទាំងឡាយ សត្រូវពាយអាយ វិនាសដោយបុណ្យ ៗ

កោធិពន្ធក ហៀរហោះរេរក ក្សត្រីវត្ថគន់ ប្រកបលក្ខណ៍គ្រប់
សុះសព្វតំបន់ ពុំមានដូរដន បទបាតក្នុងក្រៅ ៗ លំហើយលំហែ
ហោះហួសខ្វេរ នៃពដឋានទៅ ហុកសិបយោជន៍គត់ មហាក្សត្រដោម
ទៅ ដល់ទីលំនៅ ឥសីសិល្បសាស្ត្រ ៗ ព្រះនាមថាថៃ ឈ្មោះអស-
ន្ធេយ្យ ឥសីស្ទឹងស្នាធិ បំរើនបតុពេទ សាស្ត្រពុទ្ធបាទ សម្តេចមុនិនាថ
វិសេសប្រសើរ ៗ ទ្រើសទ្រង់ដជា ពាសពាក់ស្បែកខ្លា ទន់ល្មិតគដ្ឋី
ចរិយាលែះផ្ដាំ ស្ទៀកសំបកឈើ អំពលអំពើ ពិធីគុណការ ៗ
អស់អញលំគេញ ការនាបំពេញ ព្រឹទ្ធព្រតក្តពិស្តារ បំរើនវេទា ព្រះធម៌
សម្មា មានពុកបក្ក ដុះដាសពាសវែង ៗ ព្រះកាណរិយុរយារ គន្ធ
ឥតទន្ទា មើលទៅគួរស្ញែង ក្សត្រក្សាន្តទសពល យង់យល់ដាក់ស្តែង
ព្រះឡឹបថាថែង ទឹងពាដីថា ៗ បងអើយដ្បិតបាន អាស្រមវិហាន
ឥសិសីលា ចូរបងចុះទៅ យើងនៅនមស្ការ ប្រតិស្ឋានជា កុសល
ផលបុណ្យ ៗ យើងនៅសួរសាន រកស្រីកល្យា-ណីនៅតំបន់ ដ្បិត
លោកមែនមាន ព្រះញាណទិព្វគន់ ឯងអាចគួរគន់ សុះសព្វសួរព្រាហ្ម
សេះទន្ទាបទៅ ស្តេចទុកសេះនៅ នាក្រៅអាស្រម ស្រេចទើបកោធិ-

សត្វវិសេសសម បរចូលបង្គំ ឥសីសិល្បសេយ្យ ។

ឥសិយង់យល់ ពោធិថ្កើងថ្កល់ លើសលោកកពត្រៃ ស្គាល់ជាក់ ជាតិជា ក្សត្រមហាថ្ងៃ នៃក្សត្រទ្រង់ស័ក្តិ ប្រុសប្រាជ្ញញាណៈញាយ្យ ពង្ស ពោធិសត្វ ។ គយគ្រប់នរលក្ខណ៍ ត្រិះត្រែកអរក្តាត់ ដូចអ្នកមួយប្រាណ មែនមានតម្កាត់ ហើយហៀបនៅបាត់ ជីវិតមរណា ។ យល់ព្រះដូច យល់ ចិត្តពេទ្យមកដល់ យកទុសថា មកៈប្រាសមកប្រស់ រួចរស់ ជន្មា ឥសីគិតថា បាបអញប៉ុន្មាន ។ ពីដើមអញធ្វើ នូវកម្មកំពើ ពិត ពុំកល្យាណ ពន្ទុកព្រៃគ្រាស់ គេជះអញបាន ប្រសព្វក្សត្រក្សាន្ត ពុទ្ធ· ន្ធូវថ្ងៃ ។ អស់បាបទាំងនោះ ទើបបានល្ហោះ រង្គោះក្សណក្ស័យ អង្គអញ សោតទើប បានពីងដេស្តជ័យ នាំជាក់ដល់ញ បរមនិព្វាន ។ ទើបសួរ ទៅថា មហាពជយាត្រា តែទើងអស្សយាន លះលែងស្នេហ៍ស្នេះ លំ នៅពជឋាន មកតើមោះមាន ប្រាថ្នាកស្តុអ្វី ។

ពោធិស្តេចស្តែង តំណើរថ្វាថ្វៃង អស់អាថិសេបក្តី ដើមក្សត្រ ពន្ទក ទៅគេមហោសី ចង់ជួបក្សត្រី ត្តូគាប់បូរាណ ។ បរចូលបង្គំ ប្រយោជន៍នៅសូម ពីងព្រះពុទ្ធញាណ វិះរកបូរី ស្រុកស្រីកល្យា· ណីៈនោះទើបបាន បរបូណ៌បំណង ។

ឥសីស្តេចស្តាប់ ព្រះសូរសោរស័ព្ទ ឆ្លាសឆ្លើយវិងស្នង កុំព្រួយអាត្មា

ឆានាពាំបរង ណែះណែនេះម្តង ឲ្យបរិបូណ៌បាន ៗ តែចូរអ្នកផ្ទុំ អាស្រ័យអាស្រម សម្រាកសម្រាន្ត សម្រេចសម្រស់ គោជន៍កស្តុ ព្រឹក្សាន ប្រសើរសើងមាន រសជាតិពិសា ៗ ចូរអ្នកទៅស្រង់ ជម្រះ អស់អង្គ ទឹកនៃអាត្មា មានទៅក្នុងត្រួត (១) នានាំយាត្រា គីរីគម្ពីរ (២) ពីជ្រោះប្រកក្នុ ៗ

ពោធិច្បងច្បាស់ ឆ្លើយថាអរណាស់ អរនឹងអង្គអ-ម្ចាស់ប្រោស ស្ម័គ្រស្មោះ គឺមោះអញខ្ញុំ ប្រគេនវិញសុំ នូវមគ្គផលា ៗ ក្បែរគ្រនូវឥសី សំណេះមេត្រី សំណាលសន្ទនា សួរសព្ទទុក្ខសោក នូវរោគភយា សួរសព្ទនាមា ទីទេសក្រុងត្រៃ ៗ ព្រះមុនីនាថនោះ បានជានាមឈ្មោះ ហៅអសន្ធ័យ ព្រោះព្រះជន្មា ទីឃាវែងត្រៃ តែមកនៅព្រៃ សាងសីលភាវនា ៗ អសន្ធ័យគិត នៅទៀតនោះឥត បើកបទុបមា ពោធិទុត្តម ស្តេចផ្ទុំនៅនា ឥសីសីលា ប្រមាណបីថ្ងៃ ៗ

ឥសីសិល្បសាស្ត្រ ភាវនាស្ងិងស្ងាត់ រះកក្បែរ វិសេសស្តួស្តីសល់ កបកល្យាណ ទើបព្រះឥសី ប្រាប់ពោធិថា ៗ អាត្មាយង់យល់ បូរាណ មណ្ឌល បូរីនាមា កោសេយ្យនគរ នាមកក្សត្រា បវរសេដ្ឋា យសវតី ៗ រព្រះពនិតា ទ្រង់នាមបទុមា ពីរពង្សអង្គឥ សួរស្ងួស្តិ៍ស័ក្តិសម បរមជាតិ

---

១ សៀមប្រែថា (ពាង) ។ ២ ជ្រោះភ្នំមានជម្រៅនៅភ្នំ ។

ឥតមានអរិ(១) ណាទទឹងតតា ៗ សេពសោយរាជ្យបិត ដោយធម៌ទសពិធ
មនោសេដ្ឋា ឯងអាចបន្ទោរ ទោះសោមោហា ខន្តីសច្ចា ដូចព្រះ
អរហន្ត ៗ ពីរពង់ស្រាកសុទ្ធ កបកើតរាជបុត្រ ឯកអង្គសោភ័ណ ទ្រ
ទ្រង់រូបា ឆាយានីរមន្ទិល ទិព្វប្រេន្ទ្រ ឧទ័យជ្រះថ្លា ៗ ទ្រង់នាមករ សុវណ្ណ-
កេសរ ប្រកបលក្ខណា អង្គឥតថ្លៃថ្លឹង ទ្រង់ឲ្យការ នាងនាថថ្លៃថ្លា ជា
ធ្មើមបូរី ៗ នាងមានប្រាជ្ញា ដោះសាប្រស្នា អាចអត្ថអ៊ីៗ ទៀវឈ្លាស
ឆ្លាសឆ្ងះ ប្រាជ្ញប្រុះប្រូតី ពលពាន់ពេកពី សេសសុះសព្វសារ ៗ នាង
នោះថ្លាថ្លៃង លែងស្រីគតក្រៃ ទំងយកស្រីណា ស្មោះស្មើត្រៀបត្រឹម
មកផ្ទឹមទេបមា ឲ្យល្អដូចជា ក្សត្រីពុំបាន ៗ នាងនាថប្រុះប្រា-កដកន្យ-
សារ-ពេជ្រញោធញ្ញាណ វិសេសពុញ្ញា ជាគូបូរណ បរមជាតិបាន សាងទីង
ព្រះអង្គ ៗ រីពជសីមា ឥស្សូរសុខា ក្សត្រថ្លៃវរវង្ស អធិកពិស្តារ ធិការ
ភិម ផ្គុំបេគាប់ទេតង្គ ទេក្តមទេក្តណា ៗ នៅខាងខេត្តខែម ខែត្រខណ្ឌព្រះ
ហេម-ពាន្តខាងទេក្ត បន្ទាយជុំវិល ប្រាំពីរជាន់មហា-ទីឃោរដោយត្បារ
សឹងមានមណ្ឌប ៗ គូគោកថ្នាក់ថ្នល់ ឥតដលមានដល ពិចិត្រគ្រៅ
គ្រប់ ផ្កាព័ន្ធញូពេង ខាត់ខ្វែងប្រសព្វ ប្រសើរសឹងអ-ក្ខរម្យគួរខ្វាប ៗ
រសូត្តបរិ ក័ណ្ឌសីធន្ត ព័ន្ធសុមេរុពេជ ប្រាសាទរតនា ប្រាំប្រការស្ងាប

---

១ បាលី: ប្រែថា សឹកសត្រូវមកពីពាក្យថា អរិ

ចាញ៉ងចិញ្ចាប រត្តះខ័ណ្ឌ ៗ មាសមៃលៀនលែម កាត់កៃកាល់
កែម កញ្ចក់កញ្ចាន់ កញ្ចុំក្រោងព្រាយ ត្រកួយគាប់គាន់ គន់ទិព្វសុវណ្ណ
វិពេចន៍វង្វៀងខ្ទមពគវត្ត ហៅមហាមារកេដ ទាទិព្វស្រស់ស្រី ពិទាយពិទូរ្យ
បុស្សរាជ្យាគ្រី ពេជ្រពិតពីសី ពិសេសឆ្អះឆ្អាស់ ៗ សូរកានមហានិល
ឥន្ទនូទំកវិល ពពាលព្រាលព្រាស នូវកដនពវត្ត លោហិតគ្គជាស មំសំ
អកិកាស ដំរៀបរេខា ៗ គ្រីសូរស្រោងស្រឹង គ្រៃដេតត្រដឹង ឆើត
ឆាយឆាយា គាងឃ្មាយដកគាំ បទ្ទុមមាលា ទែនកែវរចនា ពិមានមាស
ផូង់ ៗ ក្រវិលពេនពន្ធ័ ខ្ពាត់ខ្ទង់ឆ្ងាយឆ្ងាត់ មាសមៃបទំបង់ នេត្រនៃ
រូបស់ ទង់ស្រស់រហង់ លួតលេចពីក្នុង ក្បែបក្បាយក្អិកក្អក់ ៗ ពញ្ញូមឡេ
ឡៀ រុងរឿងឆ្អះឆ្អៅ រលង់ស្មើរស្រក់ មាសមៃកែវកល់ កមល់ទែនទុក
ប្រាង្គប្រាសាទសុខ មន្ទីរឆ្អៅឆ្អាក់ ៗ គ្រែគ្រប់ទ្រទ្រង់ ទ្រនាប់ទ្រនង់
នូវរូបពងយក្ស បន្ទូមបក្ខា ហើយហារជៀងជាក់ ខាស់ទេងរឹទ្ធិស័ក្តិ រូបស់
វិញ្ញាណ ៗ ក្លិតសៃរ៉ើយប៉ាក់ សង់ខាងកំដរក់ ក្រោមព្រះពិមាន ពួក
ខ្មល់ព្រៃព្រំ បៀមចំមាសមាន ស័ក្តិសម្បូរហាន ទិព្វទេសសេយ្យនាឲ ទ្រៃត្រ
សន្ធិសម តន្ត្រីត្រូវជំ បំរើកដាំ សម្រាប់ប្រៀនប្រូច គ្រលួចសព្វសា សូរ
សោតសមគ្នា ក្តលេចល្វែងល្វើយ ៗ អនេកមន្ត័ក្ស ត្រសៀតត្រសាក់
ព្រះពាយរំភើយ រួសរះត្រែកត្រេប កាព្យកិច្ចឆ្ងាស់ឆ្ងើយ ស្តេចកៃងលំ

ហើយ លំហែហឫទ័យ ៗ ស្តែងស្តេចប្រដាប់ខ្សានសម្រាប់ ព្រះរាជ-បុត្រថ្ងៃ បើនាងកល្យាណ ពុំក្សាន្តព្រះទ័យ តែងនាំសារជ័យ ទៅលេង· សព្វគ្រា ៗ មានស្រះកេ្បមក្សាន្ត ដូចនឹងខ្សាន សម្តេចឥន្ទ្រា មាន តាសព្រឹននាក់ ពីក្តិកេ្យ ធ្លុះសម្បែនអា-ស្រយ័គ្គនខ្សាន ៗ បើព្រះ អង្គទៅ ចូលសំណាក់នៅ នឹងតាសព្រហ្មណ៍ ពិតពុំលន់លង់ ព្រះ អង្គនឹងបាន នៃនាងកល្យាណ ដូចក្តីប្រាថ្នា ៗ

ព្រះពោធិសត្វ ព្ទនាមប្អូនភ្លេ ដល់ព្រះកាំម៉ា ត្រីព្រួចដួចយន់ យល់ អង្គពីតា ក្លុចកើតស្នេហា ហេតុគុបុរណ ៗ ទើបមហាក្សត្រា ក្រាប ទូលមហា ឥសីវញ្ញាណ សូមព្រះករុណា មេត្តាប្រោសប្រោណ ជន្សា នាងបាន ប៉ុន្មានវស្សា ៗ

ឥសីផ្ទាសឆ្លើយ ថាមហារាជអើយ នាងនោះជន្មា ចួបចូលសោឡស ស្រៀបស្រស់អស់ការ អាពាហ៍ពិពាហ៍ មន្តលថ្កើងថ្កាន ៗ

ពោធិសួរថា បពិត្រអ្នកតា មគ្គាដែនដាន ទៅដល់កោះសយ្យ វិជ័យរាជដ្ឋាន ចម្ងាយប៉ុន្មាន យោជន៍យាត្រាដល់ ៗ

ឥសីឆ្លើយថា បពិត្រព្រះមហា រាជរមណ្ឌល ពីនេះទៅធ្ល កោះសយ្យ ក្រុងសល់ សាមសិបយោជន៍ដល់ ដាដិតល្អមទេ ៗ

ពោធិ៍ឆ្លើយថា បពិត្រអ្នកតា ខ្ញុំនឹងទៅតែ រំពេចឲ្យដល់ មណ្ឌល រដ្ឋ អាត្មាឥតឯ រកអ្នីផឹមគ្នា ៗ

ឥសីឆ្លើយថាន អ្នកកុំអាលទាន់ ពេលាពុំបាន ដ្បិតមានយក្ខស្រី អប្រិយ៍សាមាន្យ នៅកណ្ដាលឋាន មគ្គាដែលទៅ ៗ ហួសពីនោះ ទីង បានដល់ដងស្ទឹង មួយមានទឹកជ្រៅ ក្រពើត្រីផង យង់យួងយោរយៅ សឹងសំណាក់នៅ នាស្ទឹងនោះណា ៗ ត្រីមួយជាប្បង លើសលើត្រីផង ប៉ោមមហាលោមា មនុស្សម្នាណាចុះ ស្ទឹងនោះគាលណា ក្បែណក្បែ ជន្មា ពុំដែលរួចរស់ ៗ បានជាអាហារ។ ត្រីនោះកាត្លា ក្នុងស្ទឹងទាំងអស់ បើដល់គុំបី ក្បត្រៃថ្ងៃទ្រង់យស ចុះស្រង់សម្រស់ សម្រាកកាយា ៗ ថាបើព្រះអង្គ ចង់បរចុះស្រង់ ចូររៀនចិន្តា-មណីព្រះមន្ត ទិព្វគន់អាត្មា ថ្វាយមហាក្សត្រា ស្មើពលទាហាន ៗ នរអ្នកណា មោះមកពាំងា បៀតបៀនក្សត្រក្សាន្ត សូត្រស្រែកព្រះមន្ត ទិព្វគន់ថ្កើងថ្កាន ប្រែប្រួបប្រោសប្រាណ ជាមិត្រស្នេហា ៗ ហួសពីស្ទឹងទៅ នោះឥតអ្វីនៅ ខាន់ខាំងមគ្គា កេ្សមក្សាន្តសប្បាយ លោះលាយព្រឹក្សា លង់លុះឫក្សា បុព្វណាកោសេយ្យ ៗ

ពោធិសោភ័ណ ស្ដេចសូមរៀនមន្ត ហេតុប្រាជ្ញញាណញ៉េយ្យ ព្រះញាណគ័ត្វណ ដវែនរាំងវៃ ព្រះឥសីសេយ្យ ប្រាប់តែមួយបាន ៗ ស្ដេចផ្ទំត្រអាល ឯករាត្រីកាល លុះព្រឹកក្សត្រក្សាន្ត ចរចូលកក្ដី ឥសីវរញ្ញាណ ប្រយោជន៍លាថ្កាន គោសេយ្យនគរ ៗ (មានត)

# រឿងសាមកុក

## កណ្ឌទី ២៩

លោកញ៉ាវិបុលរាជសេនា ង៉ូ-កាន ប្រែរៀបរៀង

( តមក )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជការផ្លាស់ បើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

មួយកងទៀតនោះ ឲ្យលើកទៅតាំពន្ធាយអាហារ ដែលលើកចេញមកពីក្នុងស្រុក ហើយប្លន់ប្រមូលពលអាហារបំរុងទុក តាមពាក្យដែលនិយាយ ។

អ៊ូនស៊ុនលើកទាហានដាក់កងទ័ព ទៅដល់ទន្លេប៉ែកតុក មើលទៅមិនឃើញទូកសៀវបួនសោះ អ៊ូនស៊ុនក៏លើកទ័ពទៅតាំង នៅជំរំយុនប៉ែនវិញ ផ្លូវជិតស្រុកគីជីវប្រហែល ២០០ សិន ( ៨ គ ) ហើយបង្គាប់ទាហានឲ្យទៅដញ្ជួះយកចម្បើង នឹងស្មៅមកគរទុកជាច្រើន ប្រាថ្នានឹងដុតភ្លើងឲ្យឆេះឡើង ដើម្បីឲ្យសឹមដោយឃើញជាសំគាល់ នឹងបានលើក

ទាហានជួយខ្ចប់កងទ័ពបួបចេញមក ទើបឲ្យលីហ៊ូ តែងខ្លួនបន្លំជាទាហាន
បួបហើយបង្គាប់ថា ឲ្យចូលទៅប្រាប់សឹមផ្ដាយថា យើងលើកកងទ័ព
មកដល់ទីនេះហើយ បើឃើញពន្លឺភ្លើងដែលយើងដុតឡើងកាលណា ឲ្យ
លើកទាហានវាយខ្ចប់ចេញមកទទួលយើង ចូលទៅក្នុងស្រុក ។ លីហ៊ូក៏
បន្លំធ្វើជាទាហានបួបចូលទៅ ក្នុងស្រុកបាន ហើយប្រាប់សឹមផ្ដាយតាម
ពាក្យដែលអ្នកសុងបង្គាប់នោះ សឹមផ្ដាយបានស្ដាប់ដូច្នោះ ក៏ចាត់ចែង
ទាហានត្រៀមទុកព្រម ។ លីហ៊ូដឹងថា ស្រូវអង្ករស្បៀងអាហារក្នុងស្រុក
នោះស្ទួចស្ដើងហើយ ក៏និយាយនឹងសឹមផ្ដាយថា ដែលអ្នកសុងនឹងលើក
ទ័ពចូលមកតាំងនៅក្នុងស្រុកគីដវនេះ ខ្ញុំបានយល់ឃើញថា នឹងខ្វះខាត
ដោយស្បៀងអាហារ ខ្ញុំបាននឹងសុំរិះគិតឲ្យអ្នកស្រុកចេញទៅ ចុះចូល
នៅនឹងបួប មុខជាបួបគាត់ស្មាតើជួសប្រវៃវាសទៅ លោកត្រូវលើកទា
ហានតាមចេញទៅចោមវាយកងទ័ពបួបក៏គង់នឹងបែកទៅដោយងាយមិន
ខាន សឹមផ្ដាយយល់ឃើញត្រូវផង ក៏ឲ្យទាហានយកទង់សមកសរសេរជា
អក្សរថា “ ស្បៀវអ្នកសុងមិនបាននៅក្នុងស្រុកទេ អ្នកស្រុកទាំងអស់ព្រម
ចិត្តគ្នានឹងសុំទៅចំណុះចុះចូលនឹងមហាទ័ពវិញ ” ហើយយកទង់នោះ
ទៅដោតលើសើនបន្ទាយ ។ បួបឃើញអក្សរក្នុងទង់ដូច្នោះ ក៏និយាយ
ក្នុងទីប្រឹក្សាទាំងពួងថា “ ទង់សរសេរអក្សរដោតលើសើននោះ ព្រោះ

សឹមផៅយឃើញថា ស្បៀងអាហារក្នុងស្រុកស្តួចស្តើងណាស់ហើយ ទើបរិះគិតធ្វើឧបាយដូច្នេះ ឲ្យអ្នកស្រុកចេញមកបំណុះបុះបួលយើង ឲ្យយើងទុកចិត្ត ឯខ្លួនសឹមផៅយនោះនឹងលើកទាហានចេញមកព័ទ្ធវាយកងទ័ពយើង" ប្អូនក៏ឲ្យទៀវលៀវនឹងស៊ុហ្វុងលើកទាហានម្នាក់ ៣ ពាន់ ទៅពួនបង្កប់នៅជើងភ្នំក្បែរកំពែងស្រុក បើឃើញសឹមផៅយលើកចេញមកក៏ឲ្យនាំគ្នាព្រួតវាយខ្ទប់ចាប់យកខ្លួនសឹមផៅយឲ្យបាន ហើយប្អូនក៏ពាក់គ្រោះដោះសេះចាំងស្បូវធំ នាំទាហានទៅជិតជើងកំពែងស្រុក ប្រាថ្នាថាច្បាំងនឹងសឹមផៅយ ឯទ្វារស្រុកនោះក៏បិទជិត ទទួលក្រះឡុកមើលទៅឃើញអ្នកស្រុកដែលចាស់ជរាកាន់ឈើច្រត់ នឹងធូបទៀនផ្កាភ្ញីចេញមកជាច្រើនហើយឃើញសឹមផៅយលើកទាហារតាមមកទៀត ប្អូនក៏ឲ្យបោកទង់ក្រហម ៣ ដង ៗ

ឯទៀវលៀវនឹងស៊ុហ្វុងឃើញដូច្នោះ ក៏លើកទាហានដែលបង្កប់នោះចេញមកវាយខ្ទប់ចាំងសងខាង កាប់សម្លាប់ទាហានសឹមផៅយនឹងពួកអ្នកស្រុកស្លាប់ជាច្រើនមិនដែរជាស សឹមផៅយយល់ឃើញថានឹងតស៊ូពុំបានក៏នាំទាហានថយចូលស្រុកវិញ ៗ ប្អូនឃើញទ្វារស្រុកបើកបាក់បរសេះចូលទៅជិតជើងកំពែងស្រុក ប្រាថ្នានឹងដេញទាហានទាំងនោះឲ្យបាំងទំលាយចូលទៅក្នុងស្រុកឲ្យបាន នោះទាហានដែលនៅលើសេនក៏តដៃគ្នាជាពន្ទឹកហើយបាញ់ធ្នូសំដៅ ព្រួញធ្លាក់ទៅត្រូវមួកបងផ្ទុះហួតទៅ ៗ

# កណ្ឌទី ៣០

**កាំងពីទាហានចូចភាយបន្ទាយអ្នូនសុងបែកគេទៅ**

**ចូចយកបានស្រុកជីជីវ សម្លាប់ស៊ីទតោយ**

**នឹងគោហ៊ីវ ហើយលើកតាមអ្នូនចាំទៅស្រុកឡាំភី**

**វហួគងល់ចូចប្រឹក្សានឹងលើកទៅវាយឡោយៀវ ។**

---

បណ្ដាទាហានទាំងពួងក៏ភ័យស្លុតចិត្តគិតថា ចូចត្រូវព្រួញ ក៏នាំគ្នាចូលទៅចោមរោមហើយនាំចូចចូលទៅក្នុងបន្ទាយ ចូចក៏ចាត់ចែងទាហានលើកទៅវាយបន្ទាយអ្នូនសុង ៗ ជិនហើយក៏លើកទាហានចេញមកច្បាំងនឹងកងទ័ពចូចជាពន្លឹក ។ អ្នូនសុងខូចខាតទាហានច្រើនណាស់ឃើញថានឹងទ្រាំតទៅមិនបាន ក៏នាំទាហានដែលសល់នៅទាំងប៉ុន្មាននោះ លើករត់ទៅកាំងបន្ទាយនៅក្នុងទិសខាងលិច ហើយឲ្យបំរើសេះស្រួតទៅហៅម៉ា-អៀនទីងទៀវយ៉ីមក ។

**ខណៈ**នោះ មានបំរើសេះម្នាក់មកប្រាប់ចូចថា អ្នូនសុងលើកកងទ័ពចេញពីស្រុកពេងង៉ួនគួនទៅហើយ ។ ចូចប្រើលីកង លីសៀង ពោបញ្ចុះបញ្ចូលម៉ាអៀនទីងទៀវយ៉ីបានមក ហើយឲ្យធ្វើជានាយទាហាន ។ កាលថ្ងៃដែលស៊ុមផោយចេញមកនោះ លុះដល់ពេលយប់ស្ងាត់ ចូចក៏ឲ្យ

លីកង, លីសៀង, ម៉ាអៀន, ទៀវយើ, លើកទាហានទៅប៉ះបន្ទាយអួនស៊ុនៗមិនទាន់ដឹងខ្លួន ក៏ខូចខាតទាហានជាច្រើន ទើបថយទៅតាំងនៅក្នុទិសខាងលិច ចម្ងាយពីស្រុកប្រហែល ៤០០ ស៊ិន(១៦គ)អួនស៊ុនឃើញទាហានរបស់ខ្លួនស្លាប់ស្ទើរ បែកខ្ញែកគ្នាដូច្នោះ ក៏ឲ្យសឹមអេងទៅជំរាបប៊ូធូថាយើងនឹងសូមមកចំណុះចុះចូល ធ្វើការរាជការ ជាមួយនឹងមហា·ខបពងផង ៗ សឹមអេងក៏ចូលទៅគេប៊ូធូ ហើយអធិប្បាយសេចក្ដី តាមពាក្យដែលអួនស៊ុនបង្គាប់ ៗ

ប៊ូធូបានស្ដាប់ដូច្នោះហើយក៏គិតថា " អួនស៊ុនដែលនឹងមកចំណុះចុះចូលយើងនេះ ព្រោះអស់ជំរេះប្រាជ្ញា បើយើងនឹងគេប្រកែកមិនបាន តែត្រូវទទួលតាមពាក្យចុះ គេទៅមុខសឹមគិតសម្លាប់ចេញឲ្យបាន " ប៊ូធូគិតហើយក៏ឆ្លើយទៅសឹមអេងថា ដែលអួនស៊ុនចូលមកចំណុះយើង ព្រមធ្វើរាជការផង ក៏តាមចិត្តចុះ ៗ សឹមអេងក៏លាប៊ូធូត្រឡប់ទៅប្រាប់អួនស៊ុនវិញថា ប៊ូធូព្រមទទួលហើយ ៗ

លុះពេលព្រលប់ ប៊ូធូក៏ប្រើទៀវលៀវនឹងស៊ុហាំងឲ្យលើកទាហានទៅវាយបន្ទាយអួនស៊ុន ទៀវលៀវនឹងស៊ុហាំងលើកទាហានទៅជិតបន្ទាយប្រហែលជាយាម ៣ ប៉ាយ ក៏លើកចូលទៅវាយទំលាយបន្ទាយអួនស៊ុន ខណៈនោះ អួនស៊ុនមិនដឹងខ្លួន ក៏ខូចខាតទាហានជាច្រើន ហោលគ្រា

សម្រាប់ការពិធីរបស់ទ្រព្យទាំងអស់ នាំទាហានដែលសល់នៅទាំងប៉ុន្មាន
នោះ រត់ចូលក្នុងទៅ ទៀវលៀវនឹងស៊ុហ្វុង កំរើសយកគ្រាន់និងរបស់ទ្រព្យ
ទៅឲ្យប្អូនហើយពណ៌នារឿងរ៉ាវ ឲ្យប្អូនស្តាប់គ្រប់ប្រការ ។

ប្អូនលុះដឹងច្បាស់ដូច្នោះ ក៏មានសេចក្តីក្រោធណាស់ ទើបលើកកងទ័ព
ទៅព័ទ្ធស្រុកគីជីវ ។ ទៅហ៊ុវនិយាយនឹងប្អូនថា ហេតុម្តេចបានជាលោក
មកធ្វើសង្គ្រាម បង្អែបង្អង់នៅដូច្នេះ មិនគួរសោះ សូមឲ្យលោកលើកទា-
ហានជីកព្រែកបង្ហូរទឹក ឲ្យចូលមកក្នុងគូកំពែងស្រុក ទឹកកំពុងហូរមក
តាមព្រែកចូលទៅលិចស្រុក មនុស្សទាំងឡាយក៏នឹងលង់លិចស្លាប់ពុំ
ខាន លោកក៏នឹងបានស្រុកគីជីវ ដោយងាយ ។ ប្អូនយល់ឃើញថាត្រូវ
ក៏កេណ្ឌទាហានឲ្យធ្វើទំនប់ទប់ទន្លេជៀងហោទុក ហើយឲ្យជីកព្រែកមួយ
ពីមាត់ទន្លេជៀងហោ កាត់តម្រង់ទៅស្រុកគីជីវ ចម្ងាយផ្លូវប្រហែលជា
៤០០ ស៊ិន (១៦គ.) ។

ឯស៊ីមាជាយនៅលើសេនបន្ទាយ ឃើញប្អូនត្រឡប់មកធ្វើការជីកព្រែក
ដូច្នោះ ក៏សើចហើយនិយាយនឹងទាហានទាំងពួងថា គិះគប្អូនគិតធ្វើការ
ដូច្នេះ យើងមិនខ្លាចសោះឡើយ យើងខ្លាចតែជីកព្រែកនោះឲ្យជ្រៅ
ទើបបង្ហូរទឹកចូលមកឲ្យលិចស្រុកយើងបាន ។ ស៊ីមាជាយឃើញថាប្អូននឹង
ធ្វើការនោះមិនកើតហេតុ ទើបមិនបានជាគិតការពារប្រការដូចម្តេចសោះ ។

ឯចុងធុមមិនបានឃើញពួកអ្នកស្រុកគីដីរធ្វើការពារអ្វីសោះ ក៏ឃើញបាន បំណាប់ផ្ដួចគំនិតគិត លុះវេលាយប់ក៏ប្រមូលពលទាហានឲ្យទៅចូលគ្នា ដីកព្រែកទំហំ ៤ ព្យាម ជំរៅ ៤ ព្យាម (៨ ម.) ឲ្យហើយស្រេចតែក្នុង ពេលយប់នោះ ទាហានទាំងអស់ក៏ជួយគ្នាប្រមុះធ្វើការដីកព្រែក ទំហំទឹង ជំរៅ ៤ ព្យាម (៨ ម.) ហើយស្រេច រួចក៏បើកទំនប់ក្នុងពេលយប់នោះ ទឹកក៏បាក់ហូរចុះទៅក្នុងគូពេញព្រៀប ហើយហូរចូលទៅតាមព្រែកដីក ក្នុងស្រុកនោះ ជាច្រើនអន្លង់គ្រប់ដំបន់ ទើបលិចពេញស្រុកជម្រៅទឹកប្រហែល ៧-៨ ហត្ថ បណ្ដាជននឹងពួកទាហានទាំងពួង ក៏ទញ្ញខ្លះខាត ដោយស្បៀងអាហារ ស្លាប់ដោយលង់ទឹកខ្លះៗ ក៏គេឡើងទៅលើសើន បន្ទាយ ។

ឯស៊ីនគីក៏រើសយកបានត្រាសម្រាប់នាំរដែនមួក នឹងគ្រឿងប្រដាប់ តែងខ្លួនរបស់អ៊ុនស៊ុង ដែលបានទុកចោលក្នុងបន្ទាយនោះ ស៊ីនគីក៏រើស យកពាក់ទៅលើចុងឈើ លើកឡើងគ្រវីស្រែកប្រាប់បណ្ដាជនទាំងពួងថា ឥឡូវនេះ មហាទ័ពរាជសម្លាប់អ៊ុនស៊ុងចេញហើយ អ្នកកាល់គ្នានឹងនៅ ស្ងៀមធ្វើអ្វី ឲ្យដល់ខ្លួនសេចក្ដីស្លាប់ ចូរនាំគ្នាត្រឡប់មកបំណុះចុះចូលនៅ នឹងមហាទ័ពរាជចុះ ទើបនឹងរស់រួចជីវិតតទៅ ។ សម័យដោយបានឮស៊ីន គីស្រែក ប្រកាសដូច្នោះ ក៏ខំនាំណាស់បង្គាប់ឲ្យចាប់យកករយោបុត្រនឹង

បក្ខពួកបងប្អូនស៊ុនគីប្រហែល ៨០ នាក់ ទៅសម្លាប់ចោលទាំងអស់ ហើយយកខ្មោចនោះបោះចេញទៅ ឲ្យស៊ុនគីឃើញ ស៊ុនគីឃើញដូច្នោះ ក៏រន្ធត់ស្លុតចិត្ត ស្រែកទ្រហោយំទួញ កាលយកកិរិយាបុត្រនឹងបងប្អូន ញាតិសន្តានតពន់ប្រមាណ ។

ខណៈនោះ សឹមអេងត្រូវជាក្មួយសឹមផៅយនោះ ជាកៀនសំឡាញ់នឹងស៊ុនគី កាលបើសឹមអេងឃើញសឹមផៅយឲ្យសម្លាប់កិរិយាបុត្រញាតិសាច់សាលោហិតស៊ុនគីអស់ហើយ ក៏នឹកខឹងក្តៅក្រហាយខ្លាំងណាស់ ព្រោះសឹមអេងស្រឡាញ់ស៊ុនគីជាច្រើន ទើបសរសេរសំបុត្រជាសេចក្តីថា ខ្ញុំបាទសឹមអេងជាក្មួយសឹមផៅយ ជាកៀនសំឡាញ់នឹងស៊ុនគី មានសេចក្តីក្តៅក្រហាយ នឹងសឹមផៅយខ្លាំងណាស់ ព្រោះសឹមផៅយជាមាខ្ញុំបាទ សម្លាប់កិរិយាបុត្រនឹងញាតិសាច់សាលោហិតស៊ុនគីអស់ ពេលយប់នេះសូមឲ្យមហាទបពជ លើកទ័ពចូលមកចុះ ខ្ញុំបាទនឹងបើកទ្វារស្រុកចាំទទួល ហើយយកសំបុត្រនោះចងនឹងព្រួញបាញ់ចេញទៅ ។

ឯស៊ុនគីកាលបើរើសបានសំបុត្រ ក៏យកមកមើលឃើញសេចក្តីច្បាស់ហើយ ក៏មានអំណរណាស់ ទើបនាំយកសំបុត្រនោះទៅឲ្យប្អូនៗដឹងសេចក្តីច្បាស់ហើយក៏ឲ្យយកទៅប្រកាសប្រាប់ដល់ទាហានទាំងពួងថា យើងនឹងលើកទ័ពចូលស្រុកក្នុងពេលយាម ៣ ក្នុងយប់នេះ កុំឲ្យនរណាធ្វើទុក

បុកម្ចេញពួកសែអួន នឹងពួកដែលសូមចំណុះចុះចូលជាដាច់ខាត បើនរ-ណាមួយ ល្មើសមិនស្តាប់នឹងឲ្យសម្លាប់ជីវិតបង់ ។

លុះពេលដិតក្តី សឹមអេងក៏បើកទ្វារស្រុកទុកតាមសញ្ញា ស៊ុនគីឃើញហើយក៏លើកទាហានចូលទៅក្នុងស្រុកគីជីវ សឹមជោយនៅក្យាគយល្បាតសើនបន្ទាយ ខាងទិសឯកើត ឃើញទាហានកងទ័ពចួនចូលមកក្នុងស្រុកពីទិសខាងត្បូង ក៏លើកទាហានប្រហែល ៣០ នាក់មកប្រឹងនឹងតដៃនឹងទាហានចួន ទទួលប្រទះនឹងស៊ុហួន សឹមជោយក៏បរសេះចូលច្បាំងនឹងស៊ុហួនប្រដាប់គ្នា ស៊ុហួនព្រួតចាប់ខ្លួនសឹមជោយបាន ក៏បងនាំទៅឲ្យចួន ស៊ុនគីជឹងដូច្នោះហើយ ក៏បរសេះស្រួតតាមទៅ ដោយអំណាចចិត្តដែលខឹងក្តៅពន់ប្រមាណ គិយកសែសេះវ៉ាយសឹមជោយ ហើយខាំធ្មេញជេរថាអាសត្រូវ អាឯងស្លាប់ក្នុងថ្ងៃនេះហើយ ។

សឹមជោយឮដូច្នោះ ក៏ខឹងណាស់ទើបឆ្លើយតបថា អាឯងប្រែចិត្តទៅចូលនឹងអាចួនជាសត្រូវ អញមានចិត្តខឹងចង់ស៊ីសាច់អាឯងទៀត ស៊ុហួនចំស្រួតនាំខ្លួនសឹមជោយ ទៅឲ្យចួនក្នុងបន្ទាយ ទើបចួនសួរសឹមជោយថា ឯណាបើកទ្វារស្រុកទទួលទាហានយើង សឹមជោយឮហើយក៏ខឹងណាស់ទើបនិយាយថា កុំតែអាសត្រូវពីក្នុងឲ្យដៃទៅ សត្រូវក្រៅ កុំអីមិនខូចស្រុកសោះ ។

ប្អូនក៏សួរសឹមផោយថា កាលពីថ្ងៃខ្លួនបានធ្វើកល១បាយឱ្យអ្នកស្រុក ចេញមកចុះបួលយើងនោះ យើងជិះសេះបួលទៅជិតជើងកំពែង ទាហាន នៅលើសើនយកធ្នូបាញ់បម្រះបុះមកពីណាក៏ច្រើនម៉េះ សឹមផោយឆ្លើយ ថា ខ្លួនជាសត្រូវនាយចៅហ្វាយយើង មានសេចក្ដីខឹងគុំគួន នេះត្រូវលើ ពេលដែលជិតពេក បើប្រសិនជាមានច្រើនទៀតនឹងឱ្យទាហានបាញ់ បន្ថែមឱ្យខ្លួនដល់នូវសេចក្ដីស្លាប់តែម្ដង ។ ប្អូនតបទៅវិញថា ដែលខ្លួន មានសេចក្ដីសត្យកតញ្ញូ នឹងនាយចៅហ្វាយរបស់ខ្លួននោះ យើងពេញចិត្ត ណាស់ តែវេលានេះ អ្នកសៀវចៅហ្វាយរបស់ខ្លួនស្លាប់បាត់ទៅហើយ ខ្លួនព្រមមកនៅធ្វើការរាជការជាមួយនឹងយើងឬ យើងនឹងបញ្ចាំមទំនុកបំរុង គេទៅ? ។ ស៊ុនក៏បានឮប្អូនថាដូច្នេះ ក៏ឆ្លើយដកបទៅវិញថា បុត្រករយោ ទឹងបក្ខពួករបស់ខ្ញុំបាទជាង ៨០ នាក់ សឹមផោយវាសម្លាប់អស់រលីង ហើយ សូមឱ្យលោកសម្លាប់វាឱ្យស្លាប់តាមគ្នាទៅ ទើបខ្ញុំបាទនឹងបាត់ ទុំន ។ សឹមផោយឆ្លើយតបថា ឯងកុំមកញុះញង់បែមថ្មីទៀត អញមិន មែនសោកស្ដាយជីវិតទេ ព្រោះខ្លួនអញកើតមកជាមនុស្សកតញ្ញូ គិត តាំងចិត្តថា ធ្វើជាបាវអ្នកណាហើយ ក៏ត្រូវតែទៀងត្រង់នឹងអ្នកនោះ យ៉ាង ដូចអញបានមកនៅជាបាវសែអ៊ួន ក៏ត្រូវតែស្រឡាញ់ស្មោះត្រង់ដោយ សុចរិត ទោះបីខ្លួនអញស្លាប់ទៅទៀត ក៏សូមឱ្យទៅជួបជាបាវសែអ៊ួនទៀត

មិនបានគិតទុច្ចរិតដូចខ្លួនឯងក៏ទេ ឯងប្រញាប់ញាប់ប្អូនឲ្យសម្លាប់អញចេញចុះ ៗ ប្អូនឮដូច្នោះក៏ខឹងណាស់ ទើបបង្គាប់ទាហានឲ្យយកខ្លួនសឹមដោយទៅសម្លាប់ ទាហានទាំងពួងក៏នាំខ្លួនសឹមដោយចេញទៅ ខណៈកាលមិនលើកដាវឡើងកាប់នោះ សឹមដោយក៏និយាយអង្វរពេជ្ឈឃាតថាចៅហ្វាយយើងនៅទិសឯជើង សូមឲ្យបង្អង់ក៏អាលសម្លាប់សិន យើងសូមបែរមុខទៅកាន់ទិសត្រង់ចៅហ្វាយយើងនៅរួចសឹមកាប់ចុះ សឹមដោយក៏បែរខ្លួនបែរមុខទៅទិសឧត្តរ ផ្ចង់ចិត្តគិតដល់ចៅហ្វាយនាយ ហើយពេជ្ឈឃាតក៏លើកដាវឡើងកាប់ស្លាប់នៅទីនោះ ៗ

ចូឆូយល់ឃើញដូច្នោះ ក៏តែងលើកសរសើរសឹមដោយ ប្រាថ្នានឹងឲ្យសេនាទាហានរបស់ខ្លួន មានចិត្តស្នេហគក្ដីមេត្រី ស្រឡាញ់ដល់ខ្លួនជាចៅហ្វាយនាយ ហើយថាសឹមដោយនេះជាមនុស្សមានសេចក្ដីសត្យកតញ្ញូដឹងនាយចៅហ្វាយណាស់ នរណានឹងធ្វើរាជការគេទៅត្រូវឲ្យយកជាគំរូយ៉ាងសឹមដោយទុកខ្លួនចុះ ហើយក៏ឲ្យតែងការសពនាំយកទៅកប់តាមទំនៀមទទួលទាហានចាប់បានខ្លួនតនលមនាំមកទៀត ចូឆុកសួរតនលមថា ដែលអ្នកសៀវឲ្យខ្លួនតែងសេចក្ដីសំបុត្រចំជាប្រកាសគ្រប់អាណាខេត្តទាំងអស់ថា យើងធ្វើការទុច្ចរិតអាក្រក់ក្នុងផែនដីនោះក៏ត្រូវមែនហើយ ព្រោះអ្នកសៀវនឹងយើងជាសត្រូវនឹងគ្នា ហេតុក៏បានជាខ្លួនចេះដឹងឈានិយាយ

កកាយទៅដល់ដីតាបិតាយើងថា គិតប្រទុស្តក៏យកស្រែផែនដីដោយហេតុអ្វី? តនលឹមតបថា ដែលខ្ញុំបានតែងសំបុត្រនោះ ឧបមាដូចអ្នកយកធ្នូផ្គងព្រួញនឹងបាញ់ ត្រូវទាញខ្សែប្រឡះឲ្យតឹងតម្រង់ព្រួញឲ្យត្រង់ ហើយលែងទៅឲ្យត្រូវមនុស្សនឹងសត្វដល់នូវសេចក្ដីស្លាប់តែម្ដង ។ ទីប្រឹក្សានឹងសេនាទាហានទាំងពួងឮដូច្នោះក៏ខឹងណាស់ ទើបនិយាយនឹងចូធថា ដែលតនលឹមនិយាយក៏យករឿងដូច្នេះជាទីប្រមាថមើលងាយខ្លាំងណាស់ សូមឲ្យលោកយកខ្លួនទៅសម្លាប់ចេញ ។ ចូធតបថា ដែលតនលឹមនិយាយនោះ ជាសេចក្ដីពិត អ្នកពលគ្មានឹងប្រកាន់ខឹងឲ្យយើងសម្លាប់ចេញនោះមិនគួរទេ. យើងត្រូវចិញ្ចឹមទុកសម្រាប់នឹងឲ្យតែងសំបុត្រនឹងចុតហ្វាយតទៅ ។

ឯចោរក៏ជាបុត្រចូធនោះ អាយុបាន ១៨ ឆ្នាំ មានសតិបញ្ញាឆ្លៀវឆ្លាតណាស់ ។ ចូធស្រឡាញ់ពេញចិត្តជាច្រើន ទោះបីនឹងលើកគងទ័ពទៅច្បាំងដល់ដែនណា ចោរក៏តែងទៅតាមបិតាជាដរាប ។ កងកាលដែលចូធវាយយកបានស្រុកតីជីវនោះ ចោរក៏ជាបុត្ររបស់ចូធក៏កាន់ត្រូវបបួលទៅជាមួយនឹងទាហានដល់ទ្វារផ្ទះអ្នកសៀវ ទាហានហាមឃាត់ចោរថា មហា-ឧបរាជបានហាមប្រាមទុកថា កុំឲ្យនរណាធ្វើអន្តរាយដល់បុត្រភរិយាញាតិ

(មានត)

# អ្នកគង្វាលចៀមចិត្តស្លូតត្រង់និងព្រះរាជធីតា

លោក ជើង-ជឿរ នៅក្រសួងឃោសនាការជាតិ

ប្រែចាកសៀវភៅ កុងត៍អេឡេសង់ដ៍ ដឺ រេមានី

( តមក )

( Contes et Légendes de Roumanie, )

អ្នកគង្វាលឡើងជិះ ហើយកូនសេះស្ទុះក្លែតលឿនដូចខ្យល់ ដូចគំនិតដែលនឹក រួចក៏បានដល់ប្រាសាទស្តេចយក្សក្លាម ។ យក្សចេញទៅលេងព្រៃ ដើម្បីបរបាញ់ទៀត ។

អ្នកគង្វាលចិត្តស្លូតត្រង់ យកនាងកូនយាយព្រះសៅរ៍ឲ្យជិះពីខាងក្រោយ ហើយបរចេញទៅយ៉ាងរហ័ស ។

គ្រានោះ សេះរបស់យក្ស គាំងស្រែកកញ្ជ្រៀវពេញរំពងមាត់ ។

- ឃើ ! ឃើ ! សេះយក្ស សេះសិង្ហ ! ឯងមិនទាន់បានផឹក មិនទាន់បានស៊ីទេឬ ? ។

– ខ្ញុំបានផឹក បានស៊ីហើយ ទៅហ្វាយ ។ ប៉ុន្តែទៅហ្វាយស្រីល្អបាត់ទៅ ជាមួយនឹងអ្នកគង្វាលទៅទៀតហើយ ។

បើដូច្នោះ តើអញឈប់ស៊ី ឈប់ផឹកសិនផង បានឬទេ ? ។

- មិនបានទេ សូម្បីតែឡើងជិះលើខ្នងខ្ញុំយឺតយូរ ក៏មិនបានផង ។

កាលណោះ ស្តេចយក្សលោតហក់លើខ្នងសេះយ៉ាងរួសរាន់ឥតបង្អង់ ហើយបរចេញលឿនដូចខ្យល់ព្យុះដេញតាមអ្នកតាក់ ដែលត្រាប់លឿនដូចផ្គរបន្ទោរ ។ ជនទាំងពីរទៅដាច់បានឆ្ងាយហើយ ។ មិនយូរប៉ុន្មានខ្យល់ដង្ហើមរបស់សេះយក្សក្តៅ ដូចអណ្តាតភ្លើងផ្សាយមកប៉ះខ្នងអ្នកគង្វាល ។ ម្ល៉ោះហើយគេក៏វាយកូនសេះ ដើម្បីឲ្យខំផាយឡើង ។ ប៉ុន្តែកូនសេះប្រាប់ថា

- ចៅហ្វាយ កុំវាយខ្ញុំ ។ ខ្ញុំនឹងនិយាយប្រាប់បងរបស់ខ្ញុំឲ្យគាត់ទុកឱកាស ដើម្បីឲ្យយើងរត់រួច ។

រួចកូនសេះស្រែកប្រាប់ទៅសេះយក្សថា:

- បពិត្រអ្នកបងសំឡាញ់ សូមអ្នកបងត្រៀងខ្លួនមុនទៅ ។

ខណៈនោះ សេះយក្សកាលបើបានឮប្អូនស្រែកប្រាប់ដូច្នោះ ក៏ត្រៀងខ្លួនហោស យក្សធ្លាក់មកយ៉ាងខ្លាំងដល់ដី ទាំងខ្លួនល្អិតដូចជាធូលី ។

អ្នកមកទាំងពីរនាំគ្នាឈប់ ។ ឥឡូវនេះ គេបានសេះពីរជាជំនិះផង គេបានផុតពីសេចក្តីវិនាសផង ។

ប៉ុន្តែ ចំណែកអ្នកគង្វាលបោះតែនឹកទៅរកព្រះរាជធីតាជានិច្ច ។ ចុះឥឡូវ តើធ្វើដូចម្តេចនឹងទៅថ្វាយបង្គំព្រះចៅកើត បើគ្មានផ្លែទៀបមាសទាំងបី ហើយថែមទាំងមាននាងក្រមុំនេះទៅជាមួយផង? ។

សេះយកប្រ្រាកដជាដឹងចិត្តអ្នកគង្វាល បានដាក់ស្រែកកញ្ជ្រៀវហើយ និយាយថា:

- បពិត្រលោកនាយ សូមលោកកុំព្រួយឲ្យសោះ ខ្ញុំនឹងនាំលោកទៅកាន់សំណាក់យាយព្រះសៅរ៍ ៗ កន្លែងនោះ ខ្ញុំដែលទៅម្ដងហើយ ! ប៉ុន្តែ សូមលោកជិះឲ្យប្រយ័ត្នក្រែងរលំមុខ ៗ

ប្រហែលមួយព្រិចភ្នែក សេះពាំងពីរនាំជនទាំងពីរហោះតាមអាកាសឡើងទៅដល់ខ្ទមរបស់យាយព្រះសៅរ៍ក្លាម ៗ អ្នកគង្វាលប្រាប់ថា

- បពិត្រលោកយាយ ខ្ញុំបាននាំនាងក្រមុំមកជូនលោកយាយវិញហើយ ៗ ឥឡូវ សូមលោកយាយអត់ទោសដល់ខ្ញុំ ហើយគាណិតនាំខ្ញុំទៅចុងទៀបផង តើបានឬទេ ? ៗ

•យាយព្រះសៅរ៍គ្រេកអរពេក ក៏ប្រាប់ថា:

- ចូរទៅតាមមែកនេះពៅ ៗ ចូរបេះតែឡើងទៅលើដានិច្ច ហើយពៅនឹងសម្រេចបានដល់លំនៅរបស់តាព្រះគង់ ដែលជាបងរបស់យាយ គាត់ចាស់ជាងយាយតែមួយថ្ងៃទេ ៗ ប្រហែលគាត់នឹងអាចឲ្យដំណឹងដល់ពៅបាន ៗ នែពៅគង្វាលចិត្តស្លូតត្រង់ បើកាលណាពៅត្រឡប់ទៅដីវិញ គាណិតមកយកកូនយាយទៅផង ពីព្រោះដើមទៀបនេះ នឹងមិនគាប់រក្សានាងនេះ តយូរទៅទៀតបានឡើយ ៗ

ហើយអ្នកគង្វាលយើងក៏ចាប់សួរទៅទៀត ៗ លុះទីបំផុត ដោយបានឃើញតាម្នាក់ ពុកមាត់សសំពោងគេស្រែកសួរថា:

- បពិត្រលោកតាព្រះកេតុ សូមលោកតាប្រាប់ខ្ញុំបន្តិច តើត្រង់ណាចុងទៀប ព្រោះខ្ញុំខំប្រវារឡើងមកជាយូរណាស់ហើយ ៗ

តាព្រះកេតុពោលដោយសុន្ទរពចថា:

នែហៅ ចូរទៅតាមនេះ បេះតែទៀនៗទៅក្នុងបីថ្ងៃទៀត ហៅនឹងបានដល់ចុងទៀបដែលជាលំនៅរបស់តាព្រះទេវានមិត្រ ៗ ដល់ទីនោះហើយ ត្រូវឲ្យផ្កាតផង ហើយប្រញាប់ប្រញាល់ផង ដូចពាក្យចំនៀមថា: " ក្តានផង ចៅផង ថ្លោលផង " ដើម្បីបេះផ្លែទៀបកុំឲ្យគេឃើញ ព្រោះអ្វី ហៅមិនដឹងទេឬ ដែលគេហៅព្រះទេវានមិត្រ ? ហៅដឹងឬទេ គឺលោកតាហ្នឹងហើយ ដែលតែងត្រាច់ទៅកាន់ផែនដី ដើម្បីគល់បញ្ជីជីវិតទាំងឡាយនៃមនុស្សនានា ៗ ហើយសព្វថ្ងៃនេះក៏ដោយ លោកឥតនៅទេ លោកគាល់យមទៅទីឯណោះឆ្ងាយណាស់ ឆ្លងផែនដីប្រាំបួន និងសមុទ្រប្រាំបួន ដើម្បីដកជីវិតយកពីព្រះចៅកជាធិរាជមួយព្រះអង្គ ដែលកំពុងតែគង់ក្រសាលនៅឯគុ ហើយមិនទ្រង់ជ្រាបថា ព្រះជន្មាយុអស់ហើយ ៗ ចូរទៅឲ្យឆាប់ ទាន់លោកមិននៅ ហើយគោរពប្រយ័ត្នគាត់ផង ៗ

☛ ( មានត )

# ចៅបាយក្តាំង

## លោក ទៀង តៃ-ឈុន

ក្រមការដើមខ្សែលេខ ១

ប្រែរៀបរៀង

( តមក )

---

ប្រាកដ ក៏ចេញបង្ហាញខ្លួន ៗ នាគប្អូនទាំងពីរមានព្រះបន្ទូលទៅចៅបាយក្តាំងថា ព្រះបរមរាជបិតាយើងទ្រង់បញ្ជា ឲ្យនាំយកព្រះសារិកា និងសំលៀកបំពាក់នេះ ព្រមទាំងទឹកអប់, ទឹមបន្ទន់នឹងក្រស្នា មកឲ្យបងឯង ៗ បងសំអាតខ្លួនឲ្យស្អាត ទឹងទឹកក្រអូបទាំងនេះ, ស្លៀកពាក់ហើយឡើងទៅលើគ្រែស្នែង, ព្រោះព្រះបរមរាជបិតាយើង ទ្រង់ចាំទទួលបង នៅក្នុងព្រះបរមរាជវាំង ៗ

លុះបានឃើញហ្វូងនាគជាច្រើន ដែលមកទទួលខ្លួន, ចៅបាយក្តាំងនឹកខ្លាចយ៉ាងក្រៃលែង ៗ តែបើទោះជាយ៉ាងណាក៏ដោយ ចៅបាយក្តាំងលាងខ្លួនទឹងទឹកអប់ ស្លៀកពាក់ដ៏ល្អហើយ ទើបឡើងលើព្រះសារិកា ។ ពួកនាគទាំងអស់ ដង្ហែទៅដល់ព្រះបរមរាជវាំង នៃព្រះបាទភុជង្គ ៗ

ព្រះរាជបុត្រទាំងពីរព្រះអង្គ បាននាំចៅបាយក្តាំងចូលទៅគាល់ព្រះ

បរមរាជបិតា ។ កាលបើទតឃើញអ្នកសប្បុរសនេះហើយ , ព្រះរាជាទ្រង់យាងចុះពីលើរាជបល្ល័ង្ក ទៅចាប់ដៃនាំទៅគង់បន្ទប់ ហើយមានព្រះបន្ទូលថា នែបុរស! ការដែលអ្នកយកអាសាកូនខ្ញុំទាំងពីរនាក់ មានដីខ្សែផែក ឧបមា, ខ្ញុំមិនអាចរករបស់អ្វី ឲ្យស្មើនឹងដីខ្សែនេះបាន ដើម្បីឲ្យជារង្វាន់អ្នកៗ ការសង្គ្រោះរបស់អ្នក ចំពោះកូនខ្ញុំធំណាស់ ហើយបើទុកជាខ្ញុំមានចិត្តចង់យ៉ាងណា ក៏ខ្ញុំមិនអាចសងគុណនោះវិញបានឡើយ ។

បន្ទាប់មក,ព្រះបាទកូដង្គទ្រង់បង្គាប់ ឲ្យរៀបចំអាហារយ៉ាងពោរពាស ដើម្បីជប់លៀងទៅបាយក្លាំង ។ លុះទៅបាយក្លាំងបរិភោគបរិបូណ៌ហើយ ព្រះរាជបុត្រទាំងពីរនាំទៅបាយក្លាំង ទៅដេកលើគ្រែមួយយ៉ាងល្អផើត ។

លុះព្រឹកឡើង, ទៅបាយក្លាំងនិយាយទៅកាន់នាគប្អូនទាំងពីរថា ឱប្អូនសំឡាញ់! បងមកតាមប្អូនបីថ្ងៃហើយ ។ ឥឡូវបងឃើញថា ប្អូនបានសប្បាយនឹងរុងរឿងហើយ, បងសុំលាប្អូនត្រឡប់ទៅស្រុកវិញ ។ បងមកពេលដ៏ដូចយូរណាស់ហើយ ។ គាត់ក្រលំបាកគោកយ៉ាកណាស់ ដែមទាំងនៅផ្ទះតែម្នាក់ឯងផង ។

ព្រះអង្គម្ចាស់ទាំងពីរព្រះអង្គ ឮទៅបាយក្លាំងថ្លែងដូច្នោះហើយ ទ្រង់មិនហ៊ានទទឹងចំណង់ ហើយមានព្រះបន្ទូលថា ឱបង! យើងគ្មានខ្វះអ្វីទាំងអស់ តែយើងនឹងឲ្យប្រាក់ទៅបងច្រើនទៅ ក្រែងបងយកទៅមិនរួច ។

ហេតុដូច្នេះ បានជាយើងឲ្យត្បូងនេះទៅបង ។ ដោយគេនវត្ថុនេះ បើបងចង់បានអ្វីនឹងបានរបស់នោះ ដូចបំណង ។ ហើយបើកាលណាមានបច្ចាមិត្តមកគំរាមកំហែង , បងគ្រាន់តែបង្វិលត្បូងនេះជុំវិញខ្លួន, សត្រូវនោះវិនាសឃ្លាតឆ្ងាយទាំងអស់ ។

លុះថ្ងៃព្រឹកស្អែក ព្រះអង្គម្ចាស់ទាំងពីរនាំចៅបាយក្តាំង ទៅក្រាបបង្គំលាព្រះបាទភូជង្គ ។ បន្ទាប់មក, ព្រះរាជបុត្រទាំងពីរព្រះអង្គទ្រង់បន្ទូលឲ្យចៅបាយក្តាំងតោងក ហើយហោះទៅក្នុងឋានមនុស្សលោក ។

កាលបើបានដាក់ចៅបាយក្តាំងដល់ហើយ, ព្រះរាជបុត្រទាំងពីរមានព្រះបន្ទូលសួរទៅចៅបាយក្តាំងថា នែ បងរកផ្លូវទៅផ្ទះឃើញឬទេ?

ចៅបាយក្តាំងឆ្លើយវិញថា បងរកមិនឃើញទេ ។ ប្អូននាំបងទៅកន្លែង ដែលបងចិញ្ចឹមប្អូន ទើបបងរកផ្លូវឃើញ ។

ព្រះរាជបុត្រទាំងពីរហោះនាំចៅបាយក្តាំង ទៅដាក់ដល់ព្រៃដែលចៅបាយក្តាំងធ្លាប់ចិញ្ចឹម កាលទើបនឹងចេញពីព្រះឧទរនោះ ។ នៅពេលនោះ, ព្រះរាជបុត្រទាំងពីរទ្រង់ព្រះកន្សែង ទ្រង់អាឡោះអាល័យ មុននឹងបែកចេញពីចៅបាយក្តាំង ។ លុះបែកគ្នាហើយ, ព្រះរាជបុត្រទាំងពីរក៏ហោះវិលទៅនគរវិញ, ចំណែកចៅបាយក្តាំង ក៏ដើរតម្រង់ទៅផ្ទះខ្លួន ។

កាលបើឃើញចៅបាយក្តាំងត្រឡប់មកវិញហើយ ជីដូនសប្បាយ

វែកពយយ៉ាន់ក្រៀលង៉ ហើយសួរថា ចៅឯងទៅទីណាទើបនឹងមកវិញ ? ។ ចៅបាយក្តាំងឆ្លើយថា ឱយាយ ខ្ញុំទៅឆ្ងាយណាស់ ។

បន្ទាប់មកបានបីថ្ងៃ, ចៅបាយក្តាំងនិយាយទៅកាន់ជីដូនថា: យាយ ! សូមយាយទៅដណ្តឹងព្រះរាជបុត្រី ដែលនៅក្មេងជាងគេទាំងអស់ ។

ជីដូនព្រួយហើយឆ្លើយថា យីអើហ៎, ចៅសំឡាញ់ពេញចិត្ត, យើងជាអ្នកក្រទុគ៌ត, បើយើងទៅសួរដណ្តឹងព្រះរាជបុត្រី ទុកដូចជាយើងប្រមាថស្តេច ។

ចៅបាយក្តាំងនិយាយទៅទៀតថា យាយទៅ! យាយទៅ! យាយនិយាយតែតាមខ្ញុំចុះ ស្តេចមុខជាព្រមហើយ ។

ចៅបាយក្តាំងទទូចហើយទទូចទៀត លុះគ្រាតែជីដូនទៅក្នុងព្រះបរមរាជវាំង ។ ព្រះរាជាទតឃើញយាយហើយ មានព្រះបន្ទូលសួរថា យាយ អញ្ជើញមកមានការអ្វី? ។

យាយឆ្លើយតបទៅស្តេចវិញថា សូមទ្រង់មេត្តាប្រោសព្រះរាជទានទោស ដ្បិតចៅទូលព្រះបង្គំជាខ្ញុំ បង្ខំឲ្យទូលព្រះបង្គំជាខ្ញុំមកដណ្តឹងព្រះរាជបុត្រី ដែលនៅក្មេងជាងគេ យកទៅធ្វើប្រពន្ធ ។

កាលបើដូច្នោះហើយ, ព្រះរាជាទ្រង់គិត ក្នុងព្រះចិន្តាថា " យាយ

នេះមិនសូវញាប់អញ្ចោះសោះទេតើ ទើបហានចូលមកដណ្ដឹងកូនស្រីអញឲ្យ

ទៅគាត់ ។" ។

បន្ទាប់មក ព្រះរាជាទ្រង់មានព្រះបន្ទូលទៅកាន់យាយនោះថា នែ

យាយ, ខ្ញុំព្រមឲ្យកូនស្រីខ្ញុំទៅនៅជាមួយយាយ តែយាយត្រូវសង់ស្ពានមាស-

ប្រាក់មួយ និងប្រាសាទមាសមួយផង ហើយឲ្យរួចស្រេចក្នុងថ្ងៃស្អែក ។

បើមិនដូច្នោះទេ, ខ្ញុំចាប់យកជីដូនទីងទៅ ទៅស៊ោរក្នុងខ្ទះដែក ។

កាលបើឮព្រះរាជឱង្ការនោះ យាយក៏ក្រាបថ្វាយបង្គំលា ដោយមាន

សេចក្ដីភ័យរន្ធត់យ៉ាងខ្លាំង ។ លុះត្រឡប់មកដល់ផ្ទះ, យាយនោះក៏ចូល

ដេកសន្ធឹកសន្ធៃ អត់បាយអត់ទឹក ។

ចៅបាយក្ដាំងឃើញជីដូនដូច្នោះ ក៏សួរជីដូនថា យាយជាទីស្នេហា !

ហេតុដូចម្ដេច បានជាយាយសម្រាន្តសន្ធឹកសន្ធៃ ដូចអស់កំឡាំងខ្លាំង

ណាស់ អត់បាយ, អត់ទឹកឬ ។ យាយម្ដេចក៏មិនប្រាប់ខ្ញុំ, តើស្ដេច

ទ្រង់យល់ព្រមព្រះរាជទានព្រះរាជបុត្រីខ្ញុំឬទេ ? ។

ជីដូនឆ្លើយថា ចៅសំឡាញ់! យាយមិនព្រមទៅសោះ, ឯងបេះតែ

ទទូចបង្ខំឲ្យយាយទៅ ។ ឥឡូវ ទៅរួចហើយ ។ ព្រះរាជាទ្រង់ព្រមព្រះ

រាជទានព្រះរាជបុត្រីឲ្យចៅឯងហើយ តែទ្រង់បញ្ជាឲ្យឯងសង់ស្ពានមាស-

ប្រាក់មួយ និងប្រាសាទមាសមួយផង ឲ្យរួចស្រេចក្នុងថ្ងៃស្អែក ។ បើចៅធ្វើតាមព្រះរាជឱង្ការនេះទាន់, ចៅនឹងបានព្រះរាជបុត្រី, បើធ្វើមិនទាន់ទេ, ព្រះរាជាទ្រង់យកយើងទៅសម្លាប់ទាំងពីរនាក់ ។ ហេតុនេះហើយបានជាយាយភិតភ័យខ្លាំងណាស់ ។

លុះឮដីដូនរៀបរាប់ដូច្នោះ, ចៅបាយក្តាំងឆ្លើយទៅដីដូនថាៈ យាយជាទីស្នេហា, យាយកុំបារម្ភឲ្យសោះ! យាយក្រោកទៀងពិសារ-បាយទៅ, ព្រោះខ្ញុំចេះធ្វើសព្វគ្រប់ហើយ ។

កាលបើឮចៅធានាអះអាងធ្វើបាន តាមព្រះរាជឱង្ការនៃព្រះរាជាហើយ, យាយក្រោកដួសទឹកស៊ីបាយ ។

នៅពេលយប់, កាលបើអ្នកស្រុកដេកស្ងាត់អស់ហើយ, ចៅបាយក្តាំងគិតថា "នាគប្អូនអញទាំងពីរ បានឲ្យត្បូងមួយមកអញ ហើយ.និយាយថា បើបងចង់បានរបស់អ្វី, បងគ្រាន់តែលើកកែវមណីជោតិនេះ ហើយបន្ទឹលជុំវិញខ្លួន បួងសួងតាមប្រាថ្នា វត្ថុដែលបងចង់បាននឹងកើតឡើងភ្លាម" គិតរួចហើយ, ចៅបាយក្តាំងអុជធូបបីសរសៃ ហើយដើរគេច ចូលវាលស្ងាត់ ហើយបួងសួងថា ឱលោកម្ចាស់! ខ្ញុំចង់បានប្រាសាទមាសមួយ និងចង់បានស្ពានមាស ប្រាក់មួយផង ។

(មានត)

## ឆាងឆាយចង្ក្រាន

លោក ឈាង ហាប់-អាន សាស្ត្រាចារ្យ

គ្រូវិទ្យាល័យព្រះសុរាម្រិត

រៀបរៀង

កាលណោះ មានមហាសេដ្ឋីម្នាក់ពោះម៉ាយ បានរៀបការជាលើកទីពីរ ជាមួយនឹងស្រីម្នាក់ដ៏ល្អឯក ធ្វើជាភរិយា ។ នាងនោះមានកូនស្រីពីរនាក់ មានមុខដូចៗគ្នាបេះបិទ ។ ចំណែកលោកសេដ្ឋីមានកូនស្រីដើមមួយនាក់ ដែលមានលក្ខណៈសុភាពរាបទាប ហើយស្រឡាញ់ម្ដាយចុងដូចជាម្ដាយខ្លួនបង្កើត ។ ប៉ុន្តែ នាងម្ដាយចុងដែលជាអសប្បុរស ក៏តែងប្រណៅធ្វើបាបនាងកូនដើមជាអនេក ។ ហើយបានដាក់កំរិត ឲ្យបំពេញមុខការគ្រប់បំពួកនៅក្នុងផ្ទះ គឺឲ្យជូតក្ដារ លាងចាន បោកអ៊ុតខោអាវ ជូតសំអាតបន្ទប់ខ្លួន នឹងកូនសំណប់ទាំងពីរ ហើយចាត់ឲ្យនាងដេកនៅ តែក្នុងជង្រុកលើបង្អើង ដ៏ស្មៀបមាស់ ។ នាងកញ្ញានេះមានទុក្ខក្រាំក្រា ក្នុងខ្លួនតែឯកឯង នាងពុំហ៊ានដំរាបលោកបិតាឡើយ ដោយមានសេចក្ដីកោតក្រែងដល់ម្ដាយចុង ។ ពេលធ្វើការ នាងកញ្ញាតែងនៅពួនធ្វើតែម្នាក់ឯងប្រផុកក្នុងផ្ទះបាយ ។ ហេតុដូច្នោះហើយ ទើបនាងបុត្រីច្បងបានសន្មត់ហៅ

បំអកថា នាងកញ្ជះបង្ក្រាន ៗ ប៉ុន្តែ នាងបន្ទាប់ហៅថា នាង នាយ-ចង្ក្រាន ៗ ពិតមែនតែនាងមានសម្លៀកបំពាក់ពុំគប្បី គង់នាងនៅល្អឆើត ជាងបងជាបុត្រីម្តាយចុងទាំងពីរ ៗ

សម័យមួយ ព្រះរាជបុត្រព្រះចៅសោយរាជ្យ បានប្រកាសអញ្ជើញអស់ពពួកកញ្ញាទាំងឡាយ ជាបុត្រីមហាសេដ្ឋី និងនាម៉ឺនធំតូចទាំងឡាយ ចូលមកពិកំសាន្ត នៅក្នុងព្រះរាជដំណាក់ ៗ នាងកញ្ញាបុត្រីចុងរបស់មហាសេដ្ឋីក៏ត្រូវគេអញ្ជើញទៅដែរ ព្រោះនាងទាំងពីរនេះ មានឈ្មោះល្បីឯកក្នុងនគរ ៗ នាងទាំងពីរក៏បានប្រុងប្រៀបសម្លៀកបំពាក់ យ៉ាងល្អុក ជាមុនស្រេច ៗ លំដាប់នោះហើយ ដែលនាងនាយចង្ក្រានត្រូវទទួលការអុតសំអាតសំលៀកបំពាក់ឲ្យបង ៗ មាតាបានប្រើឲ្យគេអញ្ជើញជាងមកកាត់ម៉ូរសក់ ឲ្យបុត្រីទាំងពីរនេះតែងខ្លួនតាមសម័យ ៗ ពេលនោះ បងទាំងពីរ ក៏បានប្រាប់សេចក្តីអំពាវនាវ របស់ព្រះអង្គម្ចាស់ដល់នាងនាយចង្ក្រាន ហើយក៏បានអនុញ្ញាតឲ្យនាងកាត់សក់ ខ្ទីងវែងនោះចោលចេញ ជាមួយផង ៗ កំពុងកាត់ នាងបងទាំងពីរក៏និយាយចំអកទៅថា " ហ៊ើមនាយចង្ក្រាន តែងខ្លួនទៅព្រះរាជដំណាក់មហាស្រពដែរ ! ហ៎ះ យ៉ាងណាទៅ បើគេឃើញស្រីកញ្ជះចង្ក្រាន មកប្រឡូកក្នុងហ្វូងអ្នកមានមុខមាត់ធំៗយ៉ាងនេះ! " ៗ នាងនាយចង្ក្រានក៏ខ្មាសសំដីបងណាស់ ប៉ុន្តែ នាងពុំមានគប

ដោយកំហឹងសោះ នាងគ្រាន់តែអង្វរថា "សូមបងកុំចំអកឲ្យខ្ញុំ" តែប៉ុណ្ណោះ ៗ នាងទាំងពីរដោយសេចក្ដីអំនួតដ៏ក្រៃលែង ក៏ក្ដួចក្ដាំងអាហារមួយចំណីអស់ពីរថ្ងៃ ៗ ពេលគេឃើញតែនាងទាំងពីរ អង្គុយធ្ងុះក្អាក់មួយម្នាក់ តាក់តង់ខ្វន់ ។

ដល់កាលបរិច្ឆេទ នាងទាំងពីរក៏ភ្ញាក់បណ្ដើរគ្នាយ៉ាងប្រិមប្រិយ ទៅទីប្រជុំនោះ ៗ ចំណែកនាងនាយបញ្ជ្រាន ដែលមានសេចក្ដីអន្ទះអន្ទែងចង់ទៅជាខ្លាំង ក៏ចាំដើរតាមមើលបងរហូតដល់ផុតកន្ទុយភ្នែក ៗ មានចំណង់ណាស់នាងក៏ទៅជាស្រែកយំ នឹកតូចចិត្តតែខ្លួនឯង ៗ មួយរំពេច ស្រាប់តែមានស្ត្រីម្នាក់រូបឆោមស្អាត ចេញខ្លួនមកបង្ហាញនាង សួរអំពីដំណើរដែលនាងយំនោះ ៗ នាងកញ្ញាពុំបានប្រាប់សោះ ហើយនឹងតែយំស្រណោះស្រណោកជាយ៉ាងខ្លាំង ៗ ដោយអំណាចចិត្តទិព្វ របស់នាងទេពធីតាដែលជាម្ដាយចិញ្ចឹម របស់នាងនាយបញ្ជ្រាន ពីតាយល់ហេតុពិតថា នាងកញ្ញាមានចំណង់ទៅលេងទីប្រជុំនឹងគេ ៗ ទើបនាងនិយាយលួងលោមថា "អើ កូនស្រីម្ដាយ នាងច្បាស់ជាចង់ទៅកំសាន្ត ជាមួយគេហើយ ! ឯងនេះកុំស្មានថា គ្មានសំណាងឲ្យសោះ កុំយំចាំម្ដាយបើកឲ្យទៅ" ៗ តមកនាងទេពធីតាក៏នាំនាងនាយបញ្ជ្រានចូលទៅ ក្នុងបន្ទប់ហើយ ស្រដីប្រើទៅថា "ចូរកូនស្រីចូលទៅក្នុងសួនច្បារបេះផ្លែត្រប់មួយយកមកឲ្យម្ដាយ" ៗ

នាងនាយបង្ក្រានមានអំណរពេក ក៏ចុះទៅរកបេះផ្លែក្រូច បានមួយយ៉ាង ទុំរលោង មកជូននាងទេពធីតាដោយគិតក្នុងចិត្តថា តើផ្លែក្រូច នោះនឹងធ្វើយ៉ាងណាទៅ ឲ្យខ្លួនបានទៅទីប្រជុំជនគេនោះ ។ នាងទេពធីតាទទួលផ្លែក្រូចពីដៃបុត្រីចិញ្ចឹមហើយ ក៏មកយកសាច់ចោលចេញអស់ ទើបទាញបង្កឹះទិព្វវាយបង្អុលសេពអាគម ។ មួយរំពេច សំបកក្រូចក៏ប្រែភេទទៅជាគូរទេះទូរមួយយ៉ាងថ្មីស្រឡាង ។

តមក នាងទេពធីតាក៏ចូលទៅបើកហិបតូចមួយ ឃើញមានកណ្ដុរ ៦ ។ ធីតាប្រាប់ឲ្យបុត្រីបើកគម្របបន្ទើប ឲ្យចេញម្ដងមួយៗ ទើបយកបង្កឹះទិព្វវាយលើខ្នងកណ្ដុរ ឲ្យប្រែភេ ទៅជាសេះយ៉ាងធំធាត់ទាំង ៦ សំរាប់អូសរទេះ ។

បានដូច្នោះហើយ នាងកញ្ញាក៏ស្រដីទៅធីតាជាមាតាចិញ្ចឹមថា "ចាំខ្ញុំទៅរកចាប់កណ្ដុរប្រែងមួយ មកជូនដើម្បីសេព ឲ្យបានជាអ្នកបររទេះ!" ។ នាងទេព្វធីតាមានអំណរណាស់ក៏តបថា "អើប្រពៃណាស់កូនស្រី ឯងទៅរកចាប់យកឲ្យឆាប់មក" ។ នាងនាយបង្ក្រានក៏បានទៅយកទ្រុងអង្គប់កណ្ដុរប្រែងមួយ ដែលមានកណ្ដុរបើនៅក្នុងនោះ មកឲ្យមាតាទេពរើសយកមួយមកសេព ឲ្យទៅជាអ្នកបររទេះម្នាក់យ៉ាងចំណាន ។ ហើយនាងធី-តាបង្គាប់ទៅបុត្រីទៀតថា "ចូរកូនរត់ទៅក្នុងសួនច្បារ ឯងនឹងបានប្រទះឃើញបង្គួយប្រាំមួយនៅដើមរបង ចូរឯងចាប់យកមកឲ្យឆាប់" នាង

កញ្ញាស្ទុះតែទៅរក ឃើញហើយក៏ចាប់យកមកជូនមាតា ដែលបានសេពមួយរំពេច ឲ្យទៅជាអ្នកបំរើទាំង ៦ យ៉ាងរៀបចំ ។

ស្រេចហើយនាងទេពធីតា ប្រាប់ទៅបុត្រីថា “ ឥឡូវបានហើយ ចូរកូនទៅលេងទីងគេចុះ ” ។ នាងបុត្រីស្រដីថា “អ្នកម៉ែឲ្យកូនទៅទាំងក្រខ្វក់យ៉ាងនេះ ” ។ ថាដូច្នោះភ្លាម នាងទេពធីតាក៏យកបន្តិះទិព្វពាល់ទៅលើខ្លួននាង ៗ មួយរំពេច សម្លៀកបំពាក់ចាស់ក៏ប្រែកេទជាថ្មីហើយ អង្គនាងក៏ស្រោចស្រក់ទៅដោយគ្រឿងអលង្ការមានខ្សែកដៃ មាសពេជ្រចិញ្ចៀនក្តិបញ្ចាច ។ ធីតាហុចស្បែកជើងកែវមួយគូ ឲ្យបុត្រីពាក់ ហើយផ្តាំផ្តាច់ថា “ ចូរកូនកុំនៅឲ្យហួសដល់អធ្រាត្រ បើកូនមិនត្រឡប់មកពីមុនឲ្យទាន់ពេលវិញទេ រទេះនោះមុខជាទៅជាសំបកក្រូច សេះទៅជាកណ្តុរ បំរើទៅជាបង្គួយ ហើយសម្លៀកបំពាក់ថ្មី ក៏ទៅជាចាស់ដូចដើមវិញ ” ។ នាងបុត្រីទទួលពាក្យនាងទេពធីតាថា នឹងវិលមកឲ្យទាន់ពេលវេលាដូចបណ្តាំ ។

ដល់ក្នុងព្រះរាជដំណាក់ អ្នកផងបានឲ្យដំណឹងដល់ព្រះអង្គម្ចាស់ថា មានព្រះនាងក្សត្រីម្នាក់ ជិះរទេះទូរបួលមកដល់ហើយ ។ ឮដូច្នោះព្រះអង្គម្ចាស់ក៏យាងចេញមកទទួល ។ ព្រះអង្គម្ចាស់ទ្រង់ហុចដៃទទួលនាងឲ្យចុះមកដី ហើយទ្រង់អញ្ជើញចូលទៅ ក្នុងមន្ទីរកំសាន្ត ៗ មួយ-

រំពេច ស្នូរសម្រែកក្អេងក៏ស្ងាត់ស្ងៀម ។ គេឮតែស្នូរមាត់សរសើរគ្រប់ៗគ្នា ចំពោះសេចក្ដីល្អឆើតរបស់នាងនាយប្រិះដាច់គេឯង ។ កុំថាឡើយដល់ទៅព្រះរាជា ដែលទ្រង់ជរាភាពហើយនោះ ក៏គង់តែទ្រង់គយគន់ទតរំពៃមកលើរូបនាង ហើយទ្រង់សរសើរ ចំពោះក្សត្រីព្រះអគ្គមហេសីថា ទ្រង់តាំងពីឡើងសោយរាជសម្បត្តិមក ពុំដែលបានប្រទះឃើញកញ្ញាស្រស់ល្អឆើតយ៉ាងនេះសោះ ៗ ស្រីៗទាំងអស់ខំផ្ចៀងផ្ចង់គយគន់សម្លៀកបំពាក់ប្លែករបស់នាង ពុំដាក់ភ្នែកសោះ ខំខំចំណាំគំរូ ដើម្បីនឹងជួលជាងដេរឯកឲ្យកាត់តាម នៅពេលដែលត្រឡប់ទៅផ្ទះវិញ ។

ព្រះអង្គម្ចាស់បានអញ្ជើញឲ្យនាងអង្គុយ នៅកន្លែងដ៏ឧត្តម ហើយក៏ទ្រង់អញ្ជើញឲ្យក្រោកឡើងរាំជាមួយព្រះអង្គ ។ ក្ដឹកដៃអង្គនាង ព្រះអង្គម្ចាស់ក្ដុបទាំងសោយចំណីផ្សេងៗ ដែលគេលើកយកមកថ្វាយស្ងោះ ៗ នាងកញ្ញាក៏បានក្រោកដើរទៅជិតបងស្រីទាំងពីរ ដែលគាំងពុំស្គាល់នាងដល់បន្តិចសោះ ហើយក៏នាំទទួលសេចក្ដីកក់ក្ដៅ យ៉ាងស្និទ្ធស្នាល ។ បន្តិចមក នាលិកាបន្លឺម៉ោង ១១ សែសិបប្រាំនាទី នាងកញ្ញាក៏នាំលាភ្ញៀវទាំងអស់ ព្រមទាំងថ្វាយបង្គំលាព្រះរាជា វិលត្រឡប់មកផ្ទះវិញ តាមបណ្ដាំនាងមាតាទេព ។ ដល់ផ្ទះហើយនាងក៏ចូលទៅសំពះអរគុណមាតាទេព ។ នាងបានរ៉ាយរ៉ាប់ប្រាប់អំពីដំណើរ របស់នាងនិងសេចក្ដីឆ្ងល់

របស់អ្នកទាំងអស់ ៗ នាងជំពបមាតាទេពថា ព្រះអង្គម្ចាស់សូមអញ្ជើញនាងទៅកំសាន្ត នៅថ្ងៃស្អែកទៀត ៗ កំពុងតែនិយាយស្រាប់តែឮសូរមាត់បងស្រីមកគោះទ្វារហៅ ៗ នាងនាយបង្ក្រានស្ទុះចេញទៅទទួលបងដោយធ្វើជាស្ងាបហើយយកដៃញីភ្នែក មានសញ្ញាដូចជាទើបនឹងក្រោកពីដេក សើនមម៉ើនដូច្នោះ ៗ មួយរំពេច បងស្រីម្នាក់ស្រដីសួរទៅនាងថា “នាយបង្ក្រានអើយ ! បើឯងទៅមន្ទីរដំណាក់ផង ប្រហែលជាឯងនឹកផ្ទុកអស្ចារ្យ ដូចបងជាពុំខានហើយ រុំអើយ មានព្រះនាងក្សត្រីកញ្ញាម្នាក់រូបល្អឆើតកែស្រីក្រមុំប្រៀបគ្មាន ហើយចេះគួរសមសុភាពរាបទាប ទាំងបានគួរសមចែកផ្លែក្រូចដល់យើងទាំងពីរស៊ីផង យ៉ាងស្និទ្ធស្នាល គ្មានឆ្មើងទេ នាងនាយបង្ក្រាន ក៏ធ្វើជាសួរឈ្មោះព្រះនាងក្សត្រីនោះ ” ៗ ប៉ុន្តែបងទាំងពីរតបមកវិញថា គេពុំដែលឃើញព្រះនាងនោះសោះ ជាអង្វើនមកហើយ ព្រះអង្គម្ចាស់ទ្រង់សព្វព្រះហឫទ័យ ភ្លេចទាំងក្រយាស្ងោយ ទន់ដៃជើងអស់ ៗ នាងនាយបង្ក្រានធ្វើជាសើចតបទៅវិញថា “ ឃើ ល្អណាស់ហ្ន៎! ធ្វើម៉េចទៅឲ្យខ្ញុំបានឃើញផង ន៎! បើដូច្នោះ សូមបងមេត្តាឲ្យខ្ញុំខ្ចីអាវចាស់ពណ៌លឿងមួយមក ” ៗ នាងបងស្រីឆាបប្រជាយទៅថា ហ៎ះ ! អីក៏គ្រាន់បើម្ល៉េះ មីកញ្ជះបង្ក្រាន ឯងស្មានថា អញនឹងឲ្យឯងខ្ចីផ្ដេសផ្ដាសយ៉ាងនេះឬ ” ៗ

ស្អែកឡើងនាងកញ្ញា តាំងពីបានតែងខ្លួនទៅមន្ទីរប្រជុំកំសាន្តទៀត ។ ចំណែកនាងនាយបង្ក្រានក៏បានស្លៀកពាក់យ៉ាងល្អ លើសលុបជាងថ្ងៃមុន ឡើងជិះរទេះសេះដដែលបរចេញទៅ ។ ព្រះអង្គម្ចាស់ពេញទៅដោយសេចក្ដីត្រេកត្រអាល ក៏បានមកអង្គុយជិតប្រកៀក ពិភាក្សានឹងនាងនាយបង្ក្រានក្សត្រី យ៉ាងស្និទ្ធស្នាល សប្បាយហួសប្រមាណ នាងកញ្ញាភ្លេចពាក្យបណ្ដាំមាតាទេព ។ លុះនាឡិកាវាយម៉ោង ១២ គត់ នាងស្មានតែម៉ោង ១១ ប៉ុណ្ណោះ ។ ប៉ុន្តែ មួយរំពេចមក ស្រាប់តែនាងក្រោកឈរឡើង សំពះគំនាប់លាភ្ញៀវ ព្រមទាំងព្រះមហាក្សត្រ នូវព្រះអគ្គមហេសី ស្ទុះរត់ចេញមកក្រៅជាប្រញាប់ ។ ឆ្ងល់ពន់ពេក ព្រះអង្គម្ចាស់ក៏ដេញតាមនាងមកក្រៅ ប៉ុន្តែ ទ្រង់តាមពុំទាន់នាង ។ រហ័សដូចព្រួញ នាងកញ្ញាភ្លាត់ស្បែកជើងមួយចំហៀងធ្លាក់នៅលើជណ្ដើរ ។ ព្រះអង្គម្ចាស់ទ្រង់ស្ទុះទៅរើសយកមកទុកយ៉ាងប្រពៃ ។

នាងនាយបង្ក្រានដើរ ត្រឡប់មកផ្ទះវិញ នៅសល់តែស្បែកជើងមួយចំហៀងជាលំអរ ។ សម្លៀកបំពាក់នាង ប្រែកេរទៅជាចាស់ក្រខ្វក់ដូចដើម ចំណែករទេះសេះនឹងបរិក្ខារក៏ក្លាយទេ ទៅជាសត្វកណ្ដុរបង្គួយរត់បាត់អស់ ។ ព្រះអង្គម្ចាស់បានបញ្ជាក់សួរឆ្មាំយាមទ្វារថា មានឃើញរទេះព្រះនាងក្សត្រីបរចេញទៅតាមទ្វារទេ ។ នាយឆ្មាំទ្វារទូលតបថា បាន

ឃើញតែស្រីកំសត់ ស្លៀកសំពត់អាវចាស់ម្នាក់ រត់ចេញទៅ តែប៉ុណ្ណោះ ដែលមានភាពជាកូនអ្នកស្រែស្មោះ ។

លុះនាងបងទាំងពីរត្រឡប់មកដល់ផ្ទះវិញ នាងនាយព្រានក៏សួរបញ្ជាក់ អំពីសេចក្តីសរសើរដល់ព្រះនាងក្សត្រី ពីថ្ងៃមុននោះ ។ នាងទាំងពីរបានរាយរឿងប្រាប់ថា ព្រះនាងកញ្ញានោះ ប្រដាប់អង្គរឹតតែល្អជាងថ្ងៃមុនទៅទៀត ប៉ុន្តែ ដល់នាលិកាវាយម៉ោង ១២ គត់ ស្រាប់តែព្រះនាង ស្ទុះរត់ចេញគៀសខ្លួនបាត់ទៅ ។ ហើយដោយហួសពេក ព្រះនាងក៏របូតស្បែកជើងម្ខាងធ្លាក់នៅលើអង្គ ។ ព្រះអង្គម្ចាស់ ក៏បានរើសស្បែកជើងកែវនោះទុក ហើយទ្រង់សព្វព្រះហឫទ័យ ទៅដល់ព្រះនាងជាខ្លាំង សឹងផ្ទំពុំលក់ ។

វិលង់ប៉ុន្មានថ្ងៃក្រោយមក ដោយសេចក្តីអន្ទះអន្ទែងទប់ពុំបាន ព្រះអង្គម្ចាស់ ក៏បានអំពាវនាវគ្រប់ជម្ពូ ដល់កញ្ញាទាំងឡាយ ដែលមានទំហំជើងត្រូវនឹងស្បែកជើងនោះ នឹងបានបានខ្លួនជាទីអគ្គមហេសី ។ ក្រុមព្រះញាតិវង្សទាំងអស់ បាននាំបុត្រីមកលជើង នឹងស្បែកជើងនោះ ប៉ុន្តែ ពុំមានត្រូវដល់ម្នាក់សោះ ។ បន្ទាប់មក ដល់វេនពួកបុត្រីឧត្តមមន្ត្រីរហូតដល់មន្ត្រីជាន់ទាប ប៉ុន្តែ ពុំមានល្មមជើងសោះ ។ គេក៏បាននាំបុត្រីលោកម-ហាសេដ្ឋីទាំងបីយកទៅ ឲ្យលទៀត ។ លុះឃើញបងប្រឹងសាកពុំចុះហើយ

នាងនាយបង្ក្រានបន្ទំពា ដោយស្គាល់ជាក់ជាស្បែកជើងរបស់ខ្លួនឡើង ថា "មើលឲ្យខ្ញុំលមើលតើប្រពៃទេ" ។ ឮដូច្នោះ នាងបងទាំងពីរក៏នាំគ្នាសើចចំអកឲ្យនាងប្អូន ។ អ្នកប៉ាវគង់ ក៏សូមអញ្ជើញ ឲ្យនាងនាយបង្ក្រានចូលមកលស្បែកជើងនោះ ។ នាងកញ្ញាក៏បានចូលទៅអង្គុយនៅកន្លែងដ៏សមគួរមួយ ហើយនាយតម្រួត ក៏ទាញស្បែកជើងយកមកឲ្យនាងពាក់ល ។ នាងកញ្ញាទទួលសុពណ៌បាទមកពាក់ត្រូវកុំ គ្មានចន្លោះ ។អ្នកទាំងអស់ព្រមទាំងបងស្រីទាំងពីរ ក៏នាំគ្នាភាំងធ្ងល់សំឡឹងមើលមុខនាងនាយបង្ក្រានក្រុសៗ ។ ដើម្បីសហេតុឲ្យរឹងរឹតតែប្រាកដឡើង នាងក៏ដកទាញយកស្បែកជើងដូចគ្នា មួយចំហៀងទៀតពីហោប៉ៅមកពាក់បង្ហាញអ្នកទាំងអស់ឲ្យឃើញជាក់ថា ជារបស់នាងពិត ។ ហើយគាត់តែស្ងួចរាសនានាទៅទៀត ។

មួយរំពេច នាងទេពធីតាជាមាតាចិញ្ចឹម ក៏បានមកដល់ទីនោះ ។ នាងយកបន្ទះទិព្វពាល់ទៅលើសម្លៀកបំពាក់ប្រាណនាង ។ មិនបានទាំងមួយដំទាស់ដៃផង ស្រាប់តែសំពត់អាវចាស់ ក្រខ្វក់ប្រែកទៅជាហូលខិនចរល្បាប់ដីក្ដិរលើបរណាន ប្រដាប់នូវខ្សែមាសពេជ្រ ស្រោចស្រក់ទាំងកាយនាង ធ្វើឲ្យនាងបងទាំងពីរស្គាល់ជាក់ថា នាងនាយបង្ក្រាននេះហើយដែលត្រូវខ្លួនជាព្រះនាងក្សត្រី កាលដែលខ្លួនបានឃើញគោរគោរព

សរសើរទៅក្នុងព្រះរាជមន្ទីរមហោស្រពនោះ ៗ ទើបនាងទាំងពីរតក់ស្លុតឥតឧបមា នឹកខ្លាចស្លុងពេក ស្ទុះចូលទៅ ក្រាបទូលដើមនិយាយអង្វរ សូមទោសកុំឲ្យនាងប្រកាន់ឲ្យសោះ កាលដែលខ្ញុំបានធ្វើបាបមើលងាយពេបជ្រាយ ទាំងប៉ុន្មានអំពីមុននោះ ៗ នាងនាយចង្រ្កានក៏ចាប់លើកបងទាំងពីរឲ្យក្រោកឈរឡើងហើយនិយាយពាក់ភាក់បញ្ជាក់ថា ខ្ញុំគ្មានគំហឹងគំនុំគុំគួនអ្វីឡើយគឺពិតជានៅស្រឡាញ់បងដូចបងបង្កើតពោះមួយ ៗ ជីវិត ៗ

ក្រោយពីនោះនាងក៏បានរៀបផ្ញើនាងនាយចង្រ្កានជិះលើ ចូលទៅក្នុងព្រះរាជវាំងថ្វាយចំពោះព្រះភក្ត្រព្រះអង្គម្ចាស់ ព្រមទាំងព្រះរាជបិតាមាតាទ្រង់ព្រះញាតិវង្សទាំងនាម៉ឺនសព្វមុខមន្ត្រីធំតូច ដែលនៅចាំទទួលនៅទីនោះ ៗ

លុះដល់ពេលល្អ ព្រះរាជាក៏បានរៀបអភិសេកព្រះរាជបុត្រនឹងនាងកញ្ញានាយចង្រ្កានជាទីអគ្គមហេសីយ៉ាងមហោឡារិក ៗ លំដាប់មកព្រះអង្គក៏ទ្រង់ផ្ទេររាជ្យឲ្យព្រះរាជបុត្រគ្រងស្នង ហើយនាងនាយចង្រ្កានក៏ឡើងបានឧត្តមជាព្រះម្ចាស់ក្សត្រីយ៉ាងប្រាកដ ៗ ព្រះនាងក៏បាននាំបងស្រីទាំងពីរ ចូលទៅនៅក្នុងមហាប្រាសាទជាមួយ ហើយនៅថ្ងៃអភិសេកជាមួយនោះ ព្រះនាងក៏បានរៀបការបងទាំងពីរនាក់ ឲ្យទៅនាម៉ឺនគេម្នាក់ឯកយ៉ាងសុខអន្តភាព ក្នុងព្រះរាជវាំងជាស្រេច ។

ចប់ ។

## និគមបទ

ការមើលងាយគេជាបាបមួយ ឲ្យផលទុក្ខព្រួយយ៉ាងអប្រិយ
ឲ្យអាប់មុខមាត់នារីលោកិយ ទៅបរលោកក្តីសឹងដូចគ្នា ៗ
ដូចនាងបង ៗ ដោមមើលងាយ នាងនាយបង្ក្រានឥតមេត្តា
បានក្តីអាម៉ាស់មុខណាស់ណា កណ្តាលហ្វូងមហាជនប្រជុំ ៗ
តែនាងជាស្រីនាយបង្ក្រាន នាងបានម្តាយដើមជួយឧបត្ថម្ភ
លៃលកឲ្យនាងបានជាធំ ឧត្តមរុងរឿងរួចថោកទាប ៗ
គឺបានឡើងជាអគ្គមហេសី ខ្ពស់លើសបងស្រីតាំងទេភាព
ដោយគុណម្តាយដើមជួយឲ្យលាភ ប្រសើររៀងរាបលើសស្រីផង ៗ
លុះបានជាធំមិនឆ្មើងឆ្មៃ នាងជួយកែខ្សែស្រីជាបង
ឲ្យបានស្វាម៉ីរួមគូគ្រង ល្អៗកន្លងពេកណាស់អើយ !

ស្រី – អ៊ី

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

( តមក )

## លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង

ចូរអ្នកឯងចេញឆាប់ ! អ្នកឯងកុហកៈបោកបញ្ឆោតឲ្យខូចកិត្តិយសខ្ញុំ ៗ ក្នុងពេលនោះ រូបព្រះនាងមានផ្ទុកបន្ទោរក្លិចប្រាក់ត្រឡប់វិញ ទេវតាទាំងប្រាំបីនៃរន្ទះ ក៏រត់ចេញពីព្រះសិរសា, ព្រះសុដន់, ព្រះឧទរ, ព្រះហស្ត និងព្រះបាទព្រះនាងអស់លើងគ្មានសល់ ៗ

ទេវតាអ៊ិជសាណាគី ក៏ថយចេញទៅ, ចិត្តតក់ស្លុតរន្ធត់ភ័តខ្លបមា ៗ ឥឡូវនេះ, ទេវតា ក៏រត់ចេញពីឋាននរកនោះទៅ ៗ

តែដោយសេចក្តីអាម៉ាស់នោះ , ព្រះនាងអ៊ិជសាណាមី , ក៏មានព្រាយរត់ដេញតាមទេវតាអ៊ិជសាណាគី ៗ

ទេវតាអ៊ិជសាណាគីរត់យ៉ាងលឿនចេញពីឋាននរក, លោកបានយកកម្រងបុប្ផា ដែលពាក់ព្រះសិរសា បោះទៅលើពួកព្រាយទាំងនោះ, កម្រងបុប្ផានោះ ប្រែកាយទៅជាផ្លែទំពាំងបាយជូរទាំងចង្កោមៈ ពួកព្រាយនោះក៏បង្អង់ឈប់ចាំអាស្រ័យផ្លែទំពាំងបាយជូរនោះសិន ៗ

រួចពួកព្រាយក៏តាំងដេញតាមទេវតា អ៊ិជសាណាគីម្តងទៀត ៗ ក្នុង

ពេលនោះ, ទេវតាបានឮស្នូរជើងព្រាយរត់តាម, លោកក៏យកគ្រាស់របស់លោក កាច់បំបាក់ហើយបោលទៅក្រោយ, បំពួកព្រាយ, គ្រាស់នោះក៏ប្រែភាពទៅក្រោយបំពួកព្រាយ, គ្រាស់នោះក៏ប្រែភាពទៅជាទំពាំង ។ ពួកព្រាយក៏បន្ថយល្បឿន, ចាំរើសទំពាំងនោះបរិភោគ ។

ឥឡូវនេះ ទៅជាទេវតារន្ទះទាំងប្រាំបីរូប នឹងពួកទាហាននៅស្ថាននរក មានចំនួនជាង មួយពាន់ប្រាំរយនាក់ រត់ដេញតាមទេវតា អ៊ិដសាណាគី ៗ ក៏ហូតព្រះខ័ន, ហើយរត់បណ្ដើរ, គ្រវីពីក្រោយបណ្ដើរ ដើម្បីឲ្យសត្រូវនោះជៀសចេញឆ្ងាយ ។

ទេវតានោះបេះតែរត់, រត់ទៅស្រាប់តែបាត់ដំនឹក ។ នៅឆ្ងាយ, សែនឆ្ងាយ, មានរស្មីភ្លឺចាំងចែង, គឺទីនោះឯងជាស្ថានមនុស្សលោក ។

ទេវតាអ៊ិដសាណាគី នឹកក្នុងចិត្តថា អញជិតផុតពីភយន្តរាយ, តែក្នុងពេលនោះ, សត្រូវរត់ដេញប្រកិតជិតទាន់លោក ។ លោកជិតដួល, ក៏ស្រាប់តែក្រឡេកទៅ ឃើញផ្លែប៉ែសបី, លោកក៏យកផ្លែនោះបោលទៅលើសត្រូវ ហើយសត្រូវក៏ឈប់បន្តិចរើសផ្លែនោះគាស្រ័យ ។

ទេវតាអ៊ិដសាណាគី ក៏ពោលទៅកាន់ផ្លែប៉ែសថា "ដោយសារឯងជួយអញ, អញសុំឲ្យជួយមនុស្សណា ដែលមានអាសន្ន អញឲ្យនាមឯងថា "ផលទេព" ។

តែក្នុងពេលនោះ, ស្រាប់តែសពព្រះនាងអ៊ិជសាណាមីស្ទុះភាយមក ទៀតៈ ព្រះហស្តនៃសពនោះគ្មានសាច់ទេ, ក៏លើកឡើងបម្រុងនឹងស្រវាចាប់ទេវតា អ៊ិជសាណាគីៗ ក៏ស្ទុះលោតទៅដល់ស្ថានមនុស្សលោក ។ អ៊ិជសាណាគី ក៏យកថ្មផាមួយធំសម្បើមអស្ចារ្យ ដែលមនុស្សមួយហ្មឺននាក់មិនអាចលើករួច យកមកសន្ទប់ផ្លូវ ដែលទៅស្ថាននរក ។

ចាប់ពីនោះមក, ស្ថាននរកនឹងស្ថានមនុស្ស លោកក៏ស្ថិតនៅដាច់ដោយឡែកពីគ្នា . . . ។

ទេវតាអ៊ិជសាណាគី ក៏ស្រែកទៅកាន់ព្រះនាងអ៊ិជសាណាមីវិញថា "ខ្ញុំសូមលាហើយ, ខ្ញុំសូមលា, យើងទាំងពីរនាក់ លែងឃើញមុខគ្នាពីត្រឹមនេះតទៅ" ។

ព្រះនាងអ៊ិជសាណាមីទ្រង់តបទៅស្វាមីវិញថា "បើលោកបោះបង់ចោលខ្ញុំៗ នឹងសម្លាប់មនុស្សលោក ក្នុងមួយថ្ងៃជាងមួយពាន់នាក់ ។

ទេវតា អ៊ិជសាណាគីក៏តបទៅវិញថា " ខ្ញុំបង្កើតមនុស្ស ក្នុងមួយថ្ងៃមួយពាន់ប្រាំរយនាក់, ខ្ញុំសូមលាហើយ! ខ្ញុំសូមលា ហើយ! ៕ នាងឯងជាទេវតាខាងស្ថាននរក ។

ទេវតាអ៊ិជសាណាគី ក៏បានទៅស្វែងរកប្រភពទឹកថ្លាមួយហើយក៏ចុះទៅងូតទឹកលុបព្រះកាយ ដែលប្រឡាក់ញើសហូរសស្រាក់ ហើយលាងខ្លួនឲ្យ

បរិសុទ្ធស្អាតផុតមន្ទិលសៅហ្មង ដែលលោកបានទៅកប់ប្រសព្វនឹងមនុស្សជាប់ក្លិន អាសោចមកជាមួយផង ។

ទេវតាអ៊ិជសាណាគីក៏បានរកឃើញស្ទឹងមួយនៅកោះគីយូស៊ូ, ហៅថា "ស្ទឹងក្រុបពោធិ៍សាត់, នៅទីនោះ, លោកបានលុបមុខលាងខ្លួន ឲ្យបរិសុទ្ធស្អាត ។

ស្រាប់តែមានអព្ភូត ហេតុមួយជាថ្មី កើតមានឡើង ។ មានទឹកមួយដំណក់ស្រក់ពីព្រះនាសិកៈ កើតជាទេវតានាមសុសានូគីទេវតាព្យុះសង្ឃរា ។ មានទឹកមួយដំណក់ស្រក់ពីព្រះនេត្រស្ដាំ កើតជាទេវតាត្សុគីណូគាមី, គឺទេវតាព្រះចន្ទ ឬ ចន្ទទេព ។ ទឹកមួយដំណក់ស្រក់ពីព្រះនេត្រឆ្វេង, កើតជាទេវតានាមអមៈតេរ៉ាសុ, ទេវធីតានៃព្រះអាទិត្យ ឬ សុរិយាទេវី ។

លោកអ៊ិជសាណាគីក៏បានបំភាគកម្មួយ ដែលនឹងទៅជានាងទេវធីតាមួយរូបទៀត ។ គឺនាងទេវធីតានេះ នឹងបានស្គាល់នូវសេចក្ដីសប្បាយនឹងសេចក្ដីទុក្ខ ដែលព្រះនាងអ៊ិជសាណាមី បានទទួលពីកាលមុនមក ។

ទេវតាអ៊ិជសាណាគីក៏ពោលថា: "ឥឡូវនេះ ត្រូវមាននាងទេវធីតាឯងហើយ!" ។

( មានត )

## កំណត់ដំណឹងប្រវត្តិការណ៍

# ពិធីអនុសំវច្ឆរៈមហាសន្និបាតលើកទី១៤

## នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៥៨ នៅមន្ទីរព្រះសទ្ធម្ម

ក្នុងវត្តព្រះកែវមរកត

លោក ឯន - ប៊ិង រៀបរៀង

---

*ពិធីអនុសំវច្ឆរៈមហាសន្និបាតលើកទី ១៤ នៃមន្ត្រីសង្ឃសំរាប់ឆ្នាំ ១៩៥៨ ដូចមានសេចក្ដីរៀបរាប់តទៅនេះ ៖*

*កាលពីថ្ងៃទី ៧ មករា ១៩៥៨ វេលាម៉ោង ២ និង ១៤ នាទីរសៀល ក្នុងវិហារវត្តបទុមវតី មានការសន្និបាតនៃមន្ត្រីសង្ឃគណៈធម្មយុត្តមាន សម្ដេចព្រះសុគន្ធាធិបតីសង្ឃនាយក, ព្រះមហាព្រហ្មមុនី ទេព អ៊ូ ព្រះអរិយកស្សប កែវ-អ៊ូច ជាដើម; ចំណែកឯសប្បុរសជនខាងគ្រហស្ថ មាន លោក មាស យ៉ន់ អនុរដ្ឋលេខាធិការក្រសួងធម្មការ, លោក យ៉ែម-ឃុត នាយកការិយាល័យ ក្រសួងធម្មការ, លោកគិម-ហុង នាយខុទ្ទកាល័យ, លោកយៀន ចឹម អគ្គលេខាធិការ នៃពុទ្ធសាសនបណ្ឌិត្យជាដើម ។*

លោកមាស-យ៉េន អនុរដ្ឋលេខាធិការ បានធ្វើគារវកិច្ចចំពោះព្រះសង្ឃ ហើយទូលសួរហេតុផ្សេងៗ តាមផ្លូវពុទ្ធសាសនា ដោយសេចក្តីរីករាយ ។ សម្តេចព្រះសុគន្ធាធិបតី សង្ឃនាយកគណៈធម្មយុត្តិ ក៏មានថេរវាចាសំណេះសំណាលតបវិញ ដោយស្រោះស្រាយ ។

ដល់ម៉ោង ២ និង ៥៥ នាទី រសៀល លោក មាស យ៉េន អនុរដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងសហការីទាំងឡាយ បានចេញពីវត្តបទុមវតីទៅកាន់ទីមហាសន្និបាតមួយដ៏ធំ ឡារក្នុងវត្តឧណ្ណាលោម ដែលមានសម្តេចព្រះមហាសុមេធាធិបតី ជ.ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះពោធិវង្ស ហួត តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, ព្រមទាំងមន្ត្រីសង្ឃ មេគណ អនុគណ គ្រប់ខេត្តក្នុងព្រះរាជាណាចក្រ មាន ព្រះវណ្ណរត្ន អ៊ឹម គួត មេគណខេត្តបាត់ដំបងជាដើម ។ លោក មាស-យ៉េន អនុរដ្ឋលេខាធិការ ក្រសួងធម្មការ បានបន្ទន់កាយធ្វើគារវកិច្ចហើយថ្លែងសេចក្តីប្រស្រ័យ រាក់ទាក់ខាងពុទ្ធសាសនា ចំពោះព្រះសង្ឃទាំងឡាយ ដោយសេចក្តីរីករាយ ។ បន្ទាប់មក សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ បានថ្លែងសន្ទនាមួយយ៉ាងវែងជាកិច្ចដាស់តឿនព្រះសង្ឃទាំងឡាយ ឲ្យខំយកព្រះទ័យទុកដាក់ សិក្សាធម្មវិន័យ ឲ្យបានម៉ត់ចត់ អស់រយៈវេលាចំនួន ២ ម៉ោង ។

ព្រឹកឡើង ថ្ងៃទី ៨ មករា ឆ្នាំ១៩៥៨ វេលាម៉ោង ៧ មានការជួបជុំព្រះសង្ឃជាឧឡារិក នៅមន្ទីរព្រះសទ្ធម្ម ក្នុងវត្តព្រះកែវមរកត, ព្រះសង្ឃទាំងឡាយបានស្វាធ្យាយធម៌ ចំរើនសត្តប្បករណ៍ ឧទ្ទិសថ្វាយព្រះរាជកុសល ចំពោះព្រះបិតរនៅៈបតិយព្រះកែវមរកត ។

ម៉ោង ៨ និង ១៥ នាទី ឯកឧត្តមប្រធានរដ្ឋសភា, ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, គណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការក្រសួងធម្មការ, សមាជិកសភាទាំងពីរ, លោកអ្នកឧកញ៉ាហៅហ្វាយក្រុង ព្រម-ទាំងឥស្សរជន ជាពុទ្ធបរិស័ទជាច្រើនទៀត បាននៅរង់ចាំក្រាបថ្វាយបង្គំគាល់ព្រះមហាក្សត្រទាំងពីរព្រះអង្គ នៅមុខព្រះវិហារ ព្រះកែវមរកត ។

នៅម៉ោង៨និង៣០នាទី ព្រះមហាក្សត្រទាំងពីរព្រះអង្គ ស្ដេចយាងចេញពីព្រះបរមរាជវាំង ដោយមានព្រះរាជបរិពារ ហែហមអមព្រះរាជដំណើរផង ។

នៅពេលដែលព្រះមហាក្សត្រទាំងពីរព្រះអង្គ ស្ដេចយាងចុះពីព្រះទីនាំងរថយន្ត លោក មាស យ៉ង់ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ, ប្រធានសភាទាំងពីរ និងឯកឧត្តមនាយករដ្ឋមន្ត្រី បានក្រាបថ្វាយបង្គំនៅទីនោះ បន្ទាប់មក ក្រុមតូរ្យតន្ត្រីព្រះរាជទ្រព្យ បន្លឺបទនគររាជ ជាទីគោរព ហើយបន្លឺបទលីលា ជូនព្រះរាជដំណើរ ស្ដេចយាងចូលទៅកាន់មន្ទីរព្រះសទ្ធម្មដែលមានមន្ត្រីសង្ឃទាំងឡាយ គង់នៅទីនោះ ។

ក្រោយដែលព្រះមហាក្សត្រទាំងពីរព្រះអង្គ ទ្រង់ថ្វាយបង្គំព្រះសង្ឃរួចហើយ ព្រះនរបតីទ្រង់មានព្រះរាជឧង្ការទទួលព្រះអំណរ ប្រស្រ័យយ៉ាងជិតស្និទ្ធទៅកេមន្ត្រីសង្ឃ ដោយព្រៃភក្ត្រញញឹម ព្រមទាំងមានព្រះរាជហឫទ័យ ទ្រង់រីករាយយ៉ាងក្រៃលែង ហើយទ្រង់មានព្រះបន្ទូលសូរ-សីហនាទទៅកាន់មន្ត្រីសង្ឃ ដូចតទៅនេះ ៖

## ព្រះបន្ទូលសូរសីហនាទ ៖

សូមពិតពុទ្ធដីកាព្រះតេជព្រះគុណគ្រប់ព្រះអង្គ !

ខ្ញុំព្រះករុណាមានសេចក្ដីសោមនស្សយ៉ាងពន្លឹក ដោយបានឃើញព្រះតេជព្រះគុណទាំងអស់ និមន្តមកកាន់មហាសន្និបាតនេះ ដើម្បីជ្រាបនូវកិច្ចការខ្លះ ខាងពុទ្ធចក្រនិងខាងអាណាចក្រ ដែលបានប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលនេះ ។

ខ្ញុំព្រះករុណាមានសេចក្ដីសង្ឃឹមថា ព្រះតេជព្រះគុណរាល់ព្រះអង្គ នឹងអាចជួយគ្រោមជ្រែងព្រះពុទ្ធសាសនា នៅក្នុងប្រទេសកម្ពុជាយើង ឲ្យបានរីងរឹតតែចំរើនតទៅទៀត ហើយនឹងជួយឧបត្ថម្ភ ដល់រាជរដ្ឋាភិបាលក្នុងការបំរើមាតុប្រទេស ឲ្យបានទៅកាន់វឌ្ឍនភាព យ៉ាងឆាប់រហ័ស ។

ខ្ញុំព្រះករុណា សង្ឃឹមលើព្រះតេជព្រះ គុណគ្រប់ព្រះអង្គ ក្នុងការរម្ងាប់

(មានត)

# ដំណើរទស្សនាការសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណព្រះពោធិវ័ង្ស ហួត-តាត ចាងហ្វាង

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រុងភ្នំពេញ

## រៀបរៀងដោយជា ទុំ

សាស្ត្រាចារ្យទទួលភារៈខាងការបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

( តមក )

គ្រប់គ្រឿង, ធ្វើការផ្សេងៗ ក្នុងហាងដ៏ធំៗ ក្នុងកន្លែងឯទៀតៗ ធ្វើប៉ូលិស ធ្វើការនេះធ្វើការនោះប្លែកៗគ្នា គ្មានទំនេរនៅផ្ទះចាំតែពេលដាំបាយទេ ។ អ្នកមានប្រពន្ធប្ដី ច្រើនតែធ្វើការដូចគ្នា ។ នៅក្នុងផ្ទះ ធ្វើការផ្ទះទាំងអស់គ្នា, អាមេរិកាំងថ្នាក់ណា ក៏ត្រូវជួយធ្វើការប្រពន្ធក្នុងផ្ទះ លាងចាន, ជូតចាន រៀបចំទុកដាក់ របស់ទ្រព្យផ្សេងៗ ។ បានឮថា នៅសហរដ្ឋ មិនសូវមានគ្រួសារដែលមានឈ្នួល ឬ ខ្ញុំកំដរបាវព្រាវ បីទេ ព្រោះចុះបច្ច័យ គឺប្រាក់ ឬ លុយណាស់ ឈ្នួលម្នាក់ៗ ស៊ីថ្លៃយ៉ាងតិច ១ ដុល្លា ១ ម៉ោង ហើយតាមច្បាប់ ធ្វើការតែ ៨ ម៉ោងក្នុង ១ ថ្ងៃ តែប្រើហួសពីនេះ ត្រូវទ្វេតថ្លៃ មួយជាពីរ ម្ល៉ោះហើយកិច្ចការគ្រប់យ៉ាង ក្នុងផ្ទះ ប្រពន្ធនឹងប្ដីត្រូវធ្វើទាំងអស់គ្នា ទើបសុខជានឹងគ្នា ។ ឡានក៏គ្មានសុហ្វ័រ

(អ្នកបរ) ដែរ ត្រូវបើកខ្លួនឯង ៗ ប្ដីក៏មានការធ្វើ មានប្រាក់បៀវត្ស គ្រាន់នឹងចាយ, ប្រពន្ធក៏មានការធ្វើ មានប្រាក់ថៃប្រាក់ខែដែរ ជួនកាលមានឡានមួយម្នាក់ផងទៀត. មានអធិបតេយ្យភាពទាំងពីរ តែលៃមិនសូវគ្នា មិនបានជានាំគ្នាយូរទេ មុខជាមានការប្រេះឆារពុំខាន ៗ ដោយហេតុនេះ បានជាថា ប្ដីប្រពន្ធអាមេរិកាំង ច្រើនតែលះលែងគ្នា ដោយការមិនមានតុល្យភាព ក្នុងកិច្ចការ គឺការមិនស្របស្រួលនឹងគ្នា ដោយកាយវាចានិងដោយចិត្ត ៗ

ផ្នែកខាងផ្លូវសាសនា អាមេរិកាំងមានសេរីភាព, សេរីភាពក្នុងសាសនាអ្វីក៏បាន តាមសេចក្ដីពេញចិត្ត, តែសង្កេតឃើញថា ប្រជាជាតិនេះកាន់គ្រិស្តសាសនាទាំងអស់ ប្លែកតែនិកាយផ្សេងគ្នាប៉ុណ្ណោះ ៗ ក៏ប៉ុន្តែសាសនាគ្រិស្ត មិនមែនជាសាសនារបស់រដ្ឋទេ រដ្ឋបើកផ្លូវសាសនាឱ្យទូលាយសំរាប់ប្រជាជន ៗ ប្រជាជនមានជំនឿយ៉ាងណា ឬមានទំនាយយ៉ាងណា ដើម្បីញុំាងសាសនាឱ្យចំរើន ក៏តាមតែសេចក្ដីត្រូវការ របស់ប្រជាជន ៗ នៅក្នុងភូមិ ឃុំ ស្រុក ខេត្តនិងក្រុងធំៗ យើងសង្កេតឃើញមានវិហារគ្រិស្តសាសនាជាច្រើន ដែលគេហៅថា Church (ឆឺច-ឆ៍) ហើយមានឆឺចខ្លះមានសាលាឈ្នួលថែមទៀត ដូចជា សាលាបឋមសិក្សាមធ្យមសិក្សាវិទ្យាល័យ និងមហាវិទ្យាល័យ ៗ Church នីមួយៗ ជាមជ្ឈដ្ឋាន

សំរាប់អប់រំខាងផ្លូវចិត្ត ក្នុងមួយអាទិត្យ ឬ មួយសប្តាហ៍ គេទៅ Church ម្តង ដើម្បីស្តាប់លោកសង្ឃ របស់គេទេសនាប្រៀនប្រដៅធម៌អាថ៌ ។ មាន Church ខ្លះទៀត មានសាលាសំរាប់អប់រំក្មេងប្រុសស្រី ហៅថា Sunday School (ស័នដេស្គូល) ។ នៅក្នុងសាលារៀនទានា តាំងពីថ្នាក់ជាន់ក្រោម ដល់ថ្នាក់ជាន់លើ គេមានថ្នាក់រៀនពិសេសខាងសាសនា ។ ចុះដឹង នឹងថា គេបង្រៀនសាសនាសាកល គឺសាសនាទាំងអស់ ប្រៀបធៀបទៅគ្រិស្តសាសនា (ដូចជានៅសាលាយើង បង្រៀនសាសនាទាំងអស់ ប្រៀបធៀបនឹងព្រះពុទ្ធសាសនា ដូច្នោះដែរ) ។ ក្រៅពីនេះ គេមានសមាគមយុវជនគ្រិស្តសាសនា ហៅថា Young Mem Christion Association Y.M.C.A. និងសមាគមយុវគ្រិស្តសាសនា Y.W.C.A. ដែលជាអគ្គារសំរាប់អប់រំយុវនរៈនិងនារី ផ្នែកខាងផ្លូវសាសនា ។ អគ្គារនេះបាន-ចំរើនឡើងជាលំដាប់ គេមានសង់កន្លែងធំៗ សំរាប់ជួលសំណាក់ផង សំរាប់អប់រំ ខាងផ្លូវសាសនាផង ហៅថា Y.M.C.A. ឬ Y.W.C.A. ។

សហរដ្ឋអាមេរិក មិនមានសាសនាសំរាប់សហរដ្ឋទេ, ប៉ុន្តែសាសនាគ្រិស្ត ជាសាសនាដែលអាមេរិកជនទូទៅ ទទួលគោរពប្រតិបត្តិតាម ជាប់ជាទំនៀមពីបុរាណមក ។ សព្វថ្ងៃនេះ សាសនាគ្រិស្តបែកចេញទៅជាច្រើននិកាយ ប៉ុន្តែនិកាយដែលធំៗ មានមនុស្សទទួលកាន់គេច្រើន

ជាងគេ មានតែបី គឺ និកាយប្រូតិសស្តង់ the Protestant មានប្រជាជនជាសមាជិក ចំនួនប្រមាណពី ៥០ ទៅ៦០ លាននាក់ ជានិកាយធំជាងគេបំផុត; និកាយរ៉ូម៉ាំងកាតូលិក the Romam Catholic មានប្រជាជនជាសមាជិកប្រមាណជា ៣០ ឬ ៤០ លាននាក់; និកាយជ្វីស្ហ the Jewish មានប្រជាជនជាសមាជិក ប្រមាណជា ៥ លាននាក់; រីឯនិកាយតូចតាចរាយរង ដែលបែកចេញពីប្រូតិស-ស្តង់ទៅទៀត មានច្រើនណាស់ ពុំអាចស្គាល់អស់ឡើយ ។

ទីកន្លែងដែលគេគោរពប្រតិបត្តិសាសនា ហៅថាឆឺច-ឆ៍ Church ។ ឆឺច-ឆ៍ និងអគ្គការទំនុកបំរុងខាងសាសនាទាំងឡាយកើតឡើង ដោយសេចក្ដីស្ម័គ្រចិត្ត ឬ ពេញចិត្តនៃប្រជាជន, រដ្ឋការរដ្ឋ ឬ រដ្ឋការសហរដ្ឋ មិនមានជួយទំនុកបំរុងអ្វី សូម្បីបន្តិចបន្តួច ចំពោះកិច្ចការខាងសាសនាឡើយ. ច្បាប់ធានាអះអាង ចំពោះជនទាំងអស់ ចំពោះសេរីភាពខាងប្រតិបត្តិសាសនា តាមចិន្តាជ្រើសរើស ។ រីឯថ្ងៃបុណ្យសម្រាប់សាសនា ដែលប្រជាជនគ្រប់គ្នាទទួលស្គាល់ មានតែមួយប៉ុណ្ណោះ ហៅថា Chrismas ជាថ្ងៃបុណ្យធំដែលគេធ្វើគ្រប់ទីកន្លែង នៅថ្ងៃទី ២៥ ធ្នូ រៀងរាល់ឆ្នាំ រំឭកដល់ថ្ងៃមរណៈនៃព្រះគ្រិស្ត ។

ពួកជនអ្នកកាន់គ្រិស្តសាសនាជាតិអាមេរិកាំង តែងមានសេចក្ដី

ស្រុកឃ្លានចង់ដឹងអំពីសាសនានានា ទាំងអំពីរបៀបកាន់សាសនានៅប្រទេសផ្សេងៗ ណាស់, កាលណាមានអ្នកដំណើរទៅពីបរទេស គេតែងអញ្ជើញឲ្យទៅនិយាយអំពីសាសនា អំពីរបៀបកាន់សាសនា អំពីការសិក្សាជាដើមនៃបរទេសនោះៗ ព្រោះហេតុនោះ ព្រះតេជព្រះគុណព្រះពោធិវង្ស ប្រធានពុទ្ធិកវិទ្យាល័យ, កាលដែលនិមន្តទៅទស្សនាសហរដ្ឋ បានត្រូវអាមេរិកជន និមន្តទៅថ្លែងការអំពីប្រទេសកម្ពុជា ការសិក្សា និងព្រះពុទ្ធសាសនា ព្រមទាំងរបៀបកាន់ព្រះពុទ្ធសាសនា នៃកម្ពុជាជន ជាច្រើនលើក ៗ ក្នុងលើកនិមួយៗមានគេចោទសួរប្រស្នាផ្សេងៗ តាមការចង់ដឹងរបស់គេៗ របៀបនេះជាវិធីសិក្សាមួយយ៉ាងដែរ ព្រោះគេអាចដឹងរបៀបស្រុកទេស និងរបៀបសាសនានៃនានាប្រទេស តាមអ្នកដំណើរបរទេស ។

ក្រៅពីគ្រិស្តសាសនា, សហរដ្ឋអាមេរិក មានប្រជាជនមួយចំណែកតូច ជាអ្នកកាន់ពុទ្ធសាសនា លទ្ធិមហាយាន ។ ពុទ្ធសាសនាលទ្ធិមហាយាន បាននាំចូលទៅដោយជនជាតិជប៉ុននិងចិន មានវិហារពុទ្ធសាសនាជាច្រើនកន្លែងដែរ គេហៅថា Buddhist Church ឬ Buddhist Temple តែឯពុទ្ធសាសនិកជនមហាយានិកទាំងនោះ ឃើញច្រើនតែជាតិជប៉ុន មិនសូវមានជាតិអាមេរិកាំងទេ មានប្រទះអាមេរិកាំង ពុទ្ធិកៈមួយៗ ។ នៅហូណូលូលូ នៃកោះហាវ៉ៃ និងសានហ្វ្រាំងស៊ីស-ស្កូ មានវិហារពុទ្ធសាសនាមហាយានិក ច្រើនជាងកន្លែងឯទៀតក្នុងសហរដ្ឋ ។

នៅនារដ្ឋធានីវ៉ាស៊ីនតុន ឌីស៊ី មានក្រុមជន ១ ក្រុម ជាអ្នកកាន់ពុទ្ធសាសនាលទ្ធិហីនយាន មានសមាជិក ជាតិអាមេរិកាំងខ្លះ ជាតិសៀមខ្លះ ជាតិភូមាខ្លះ ជាតិយួនខ្លះ គេហៅថា សមាគមមិត្តពុទ្ធសាសនិកហីនយានិក នៅវ៉ាស៊ីនតុន The Association of Friends of Buddhism in Washinqton D.C. ។ សមាគមនេះ មិនទាន់មានទីសំណាក់ការប្រាកដប្រជានៅឡើយសព្វថ្ងៃ វេលាប្រជុំគ្នាម្ដងៗ ជួនកាលប្រជុំគ្នានៅស្ថានទូតថៃ ឬ នៅស្ថានទូតភូមា ។ លោកប្រធានសមាគមជាជាតិអាមេរិកាំង, ក្នុងដំណើរទស្សនាសហរដ្ឋ ព្រះតេជព្រះគុណព្រះពោធិវង្ស បានទទួលនិមន្តទៅឆាន់ និងទេសនា នៅស្ថានទូតថៃម្ដង នៅស្ថានទូតភូមាម្ដង, ព្រះតេជព្រះគុណបានបួងសួងចំពោះគុណព្រះរតនត្រ័យ សូមឲ្យសមាគមមិត្តពុទ្ធសាសនិកហីនយានិក នៅវ៉ាស៊ីនតុន បានចំរើនរុងរឿងតទៅអនាគត ។

ដំណើរទស្សនាការសហរដ្ឋអាមេរិក នៃព្រះតេជព្រះគុណចាងហ្វាងពុទ្ធិកវិទ្យាល័យ បានចាប់ផ្ដើម តាំងពីថ្ងៃសៅរ៍ ១ កើត ខែកត្ដិក ឆ្នាំមមែសប្ដស័ក ពុទ្ធសករាជ ២៤៩៩ ត្រូវនឹងថ្ងៃទី ៣ វិច្ឆិកា ស ១៩៥៥ វេលាម៉ោង ២.៣០ រសៀល រហូតដល់ថ្ងៃចន្ទ ១៣ កើតខែបុស្ស ឆ្នាំដដែល គឺថ្ងៃទី ២៣ មករា ១៩៥៦ វេលាម៉ោង ១១ ព្រឹក ទើបព្រះតេជព្រះគុណបាននិមន្តត្រឡប់មកដល់ក្រុងភ្នំពេញវិញដោយសុវត្ថិភាព ។

ចប់ ។

# ពិធីបុណ្យទទួលព្រះត្រៃបិដកជាភាសាទីបេត៍

# នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

---

កាលពីថ្ងៃអង្គារ៍ទី ១៤ តុលា ១៩៥៧ ម៉ោង ៩ ព្រឹក នោះបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានពិធីបុណ្យទទួលព្រះត្រៃបិដក ជាភាសាទីបេត៍ ចំនួន ២០ ក្បាលដែលលោកកេនហ្ស៊ូ ម៉ាត់ សុមុរ៉ សមាជិកសភាតំណាងរាស្ត្រនិងអតីតរដ្ឋមន្ត្រី ប្រទេសជប៉ុនបានជូនជាអំណោយ ចំពោះពុទ្ធសាសនបណ្ឌិត្យ ។

ក្នុងឱកាសនោះ, មានឥស្សរជនទាំងបព្វជិតទាំងគ្រហស្ថ ព្រមទាំងបរទេស បាននិមន្ត និងអញ្ជើញមកកាន់ពិធីនេះ ។

ខាងបព្វជិត, មានសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយ វត្តឧណ្ណាលោម, សម្តេចព្រះសុធម្មាធិបតី កុល-ទេស, សង្ឃនាយក គណៈធម្មយុត្តិកវត្តបទុមវតី, ព្រះពោធិវង្ស ហួត-តាត វជិរប្បញ្ញោ ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, រាជាគណៈ ឋានានុក្រម, ។

ខាងគ្រហស្ថ, មានសហជីវិន មាស-យ៉ង់ អនុរដ្ឋលេខាធិការក្រសួងធម្មការ, លោកៈយឿន-ចឹម អគ្គលេខាធិការ ក្រុមពុទ្ធសាសនបណ្ឌិត្យ,

លោកសម-ញាណ, ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ, លោកទ្រិញ-វ៉ាញ កំណាន់រាស្ត្រ, លោកវ៉ាយ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ, បុគ្គលិកក្រសួងធម្មការ, ពុទ្ធសាសនបណ្ឌិត្យ និងឥស្សរជនឯទៀតជាច្រើន ។

ខាងបរទេស មានឯកឧត្តម យុស៊ីយូកា ឯកអគ្គរាជទូតប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជា និងឥស្សរជនជប៉ុន ៦ នាក់ ។

ម៉ោង ៩ និង ៥ នាទី, ឯកឧត្តម យុស៊ីយូកា ឯកអគ្គរាជទូតបានថ្លែងនូវសន្ទរកថាមួយដូចតទៅនេះ ៖

សម្តេចសង្ឃនាយកទាំងពីរគណៈ !

ឯកឧត្តម !

លោក-អ្នកទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំបាទមានចិត្តសោមនស្សជាយ៉ាងក្រៃពេកដោយបានមករួមរមកក្នុងពិធីបុណ្យ ប្រគល់ព្រះត្រៃបិដក ជាភាសាទីបេត៍ ចំនួន ៦០ក្បាល ជាអំណោយដល់លោករដ្ឋមន្ត្រីក្រសួងធម្មការ, ចំពោះព្រះភក្ត្រសម្តេចសង្ឃនាយក ទាំងពីរគណៈ និងមន្ត្រីសង្ឃទាំងឡាយ ។

ឯកឧត្តមៈកនហ្សូ ម៉ាត់សុម្មុរ៉ាអតិតរដ្ឋមន្ត្រី និងសមាជិក តំណាងរាស្ត្រប្រទេសជប៉ុនដែលបានកំណត់ថា និងអញ្ជើញមកទស្សនានៅប្រទេសកម្ពុជា ពីខែមីនាមុននេះ, ក្នុងឋានន្តរៈជា ប្រេសិតពិសេសនៃនាយករដ្ឋមន្ត្រី

ប្រទេសជប៉ុន លោកតិនហ្ស៊ី អ៊ីស្ហ៊ីបាស្ហ៊ី ហើយគាត់ខាន មិនបានអញ្ជើញមកវិញ ដោយមានវិតក្កបំណាង ចង់ធ្វើឲ្យការគមនាគមន៍ ដោយមេត្រីភាព រវាងប្រទេសជប៉ុន និងប្រទេសកម្ពុជាឲ្យកាន់តែមានសភាពម៉ាំមួនឡើង, បានផាត់ឲ្យខ្ញុំទទួលការកិច្ច ជូនជាអំណោយចំពោះរដ្ឋាភិបាលខ្មែរនូវព្រះត្រៃបិដក ២០ សៀវភៅជាភាសាទីបេត៍ (ក្បួនច្បាប់ពុទ្ធសា-សនាទីបេត៍) ដែលបង្ហាស្ថានៃការសិក្សាព្រះត្រៃបិដកទីបេត៍ មានលោកកេនហ្យូ-ម៉ាត់ស៊ុមុរា ជាអគ្គនាយកបានបោះពុម្ពផ្សាយនៅទីក្រុងប៉េកាំង ។

ព្រះត្រៃបិដកដែលបោះពុម្ពទាំងអស់មានចំនួន ១៧០ សៀវភៅ នៅសល់ ១៣០ សៀវភៅទៀត ដែលនឹងត្រូវបោះពុម្ពនៅលើកក្រោយ ។ ខ្ញុំព្រះករុណា ខ្ញុំបាទបានទទួលសៀវភៅទាំងនេះ ទឹងជូនមករដ្ឋាភិបាលខ្មែរតាមលំដាប់មិនហានខាន ។ ខ្ញុំព្រះករុណាខ្ញុំបាទមានអំណរពន់ពេក, បើសៀវភៅនេះអាចនឹងជួយចំពោះវិទ្យាសាស្ត្រ សាសនា និងគណៈព្រះសង្ឃពុទ្ធសាសនាខ្មែរឲ្យមានវឌ្ឍនភាពតទៅអនាគត ។

លំដាប់តមក លោកមាស-យ៉ង់ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ បានថ្លែងនូវសុន្ទរកថាមួយដូចតទៅនេះ

ឯកឧត្តម អគ្គរាជទូត !

គឺជាកិត្តិយសដ៏ឧត្តម និងសេចក្តីរីករាយចិត្តជាយ៉ាងជ្រាលជ្រៅដោយ

ខ្ញុំបាទបានទទួលនូវព្រះត្រៃបិដក ជាភាសាទីបេតដែលឯកឧត្ដម កេនហ្ស៊ូ-មាត់ស៊ុម៉ុក សមាជិកនៃសភាជំណាន់រាស្ត្រ និងអតីតរដ្ឋមន្ត្រីប្រទេសជប៉ុនបានជូនជាអំណោយចំពោះរាជរដ្ឋាភិបាល ប្រទេសកម្ពុជាក្នុងថ្ងៃនេះ ដោយមហាសប្បុរស។ គឺគម្ពីរនេះឯង ដែលឯកឧត្ដមបានអញ្ជើញមកផ្ទាល់ប្រគល់ ក្នុងនេះយើងសូមថ្លែងនូវអំណរគុណ ដោយចិត្តស្មោះស្ម័គ្រចំពោះឯកឧត្ដម ។

គ្មានពុទ្ធសាសនិកជនណាមួយមិនជ្រាបថា គម្ពីរធំសម្បើមអស្ចារ្យដែលមានអត្ថបទពិសិដ្ឋ គឺព្រះត្រៃបិដកនេះឯង ជាគម្ពីរសំខាន់នៃព្រពុទ្ធ-សាសនា គឺជាអត្ថបទដែលពណ៌នាអំពីធម៌ និងវិន័យព្រះពុទ្ធសាស-នា ។ ព្រះត្រៃបិដកនេះមានសារៈសំខាន់ណាស់, បានជាប្រទេសដែលនិយមកាន់ព្រះពុទ្ធសាសនានីមួយ ៗ មានបំណងចង់បានជាកម្មសិទ្ធិរបស់ខ្លួនហើយយល់ថា គម្ពីរព្រះត្រៃបិដកសម្រាប់ជាតិខ្លួននោះ ជាឃ្លាំងនៃវិជ្ជាសាស្ត្រ ខាងសាសនាដែលប្រទេសនោះទុកជាការចាំបាច់ជាបឋម ។

គម្ពីរព្រះត្រៃបិដកជាភាសាទីបេត ក៏គង់តែមានតម្លៃពេញលេញទៅតាមក្បួនច្បាប់ព្រះពុទ្ធសាសនា ។ គម្ពីរនេះជាផលនៃកិច្ចការពួកវិញ្ញូជន ក្នុងវិជ្ជាស្ថានការសិក្សាព្រះត្រៃបិដកទីបេតដែលមានឯកឧត្ដមកេនហ្ស៊ូ-មាត់ស៊ុម៉ុក ជាអគ្គនាយក ជាស្នាដៃមួយធំសម្បើម ព្រមទាំង

សភាពថ្លៃថ្នូរ របស់ប្រជាជាតិដ៏ឧត្តមមួយនៃទ្វីបអាស៊ី ។

ព្រះត្រៃបិដកនេះ ដែលបោះពុម្ពដោយអក្សរមានលំអឆើតយ៉ាងក្រៃលែង បញ្ជាក់ឲ្យឃើញថា មានសភាពស្រប់ស្រែងដ៏អស្ចារ្យ បើតាមសំនួនសៀវភៅប្រហែលគ្នានឹងព្រះត្រៃបិដកខ្មែរ ដែលកំពុងបោះពុម្ពសព្វថ្ងៃ ជាការផ្សាយមួយកើតឡើងដោយឆន្ទៈ នៃសង្ឃបណ្ឌិតរបស់យើងដែលមានអង្គខ្លះគង់នៅទីនេះ ។ ព្រះត្រៃបិដកដែលឯកឧត្តមបានធ្វើអំណោយមកយើង ព្រមទាំងភាគឯទៀតជាខាងក្រោយ ដរាបដល់ចប់គ្រប់ជា ១៤០ សៀវភៅ យើងថែរក្សាទុកជាវត្ថុយ៉ាងថ្លៃថ្លា ។ គម្ពីរនេះ នឹងអាចជួយឲ្យវិជ្ជាខាងសាសនា មានវឌ្ឍនភាពតទៅអនាគត ហើយជាប្រភពតែមួយដ៏ប្រសើរនៃក្បួនច្បាប់ព្រះពុទ្ធសាសនា ដែលប្រជារាស្ត្រនិយមកាន់ព្រះពុទ្ធសាសនាទាំងឡាយតែងស្រាវជ្រាវ ដើម្បីប្រយោជន៍ចំពោះព្រះសង្ឃ សុភមង្គល ចំពោះមនុស្សជាតិទាំងឡាយ ព្រមទាំងសន្តិភាពលោក ។

ការដែលឯកឧត្តម បានប្រគល់ជាអំណោយនូវព្រះត្រៃបិដកនេះ ចំពោះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ឈ្មោះថា ឯកឧត្តមបានប្រគល់នូវសារវត្ថុដ៏វិសេសវិសាល ក្នុងដែនវប្បធម៌ នឹងសាសនា ។ អំណោយនេះ ដែលបញ្ជាក់ឲ្យឃើញសុទ្ធចិត្ត នឹងបំណងដ៏បរិសុទ្ធនៃប្រជារាស្ត្រជប៉ុន

មកកាន់ប្រជារាស្ត្រខ្មែរ ទុកជាកាយវិការមួយ មិនមែនគ្រាន់តែប្រកបដោយមហាសប្បុរស ដែលមានន័យដ៏ខ្ពង់ខ្ពស់បំផុតនោះទេ ថែមទាំងជានិមិត្តរូបជាក់ច្បាស់ នៃការប្រកបដោយសម្បណ៌ិកភាពមហាប្រទេស ជាកល្យាណមិត្តមួយចំពោះសហការវប្បធម៌ រវាងប្រជារាស្ត្រយើងទាំងពីរ ។

ក្នុងនាមនៃរាជរដ្ឋាភិបាលប្រទេសកម្ពុជា នាមគណៈសង្ឃខ្មែរនិងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងនូវឧបការគុណដ៏ជ្រាលជ្រៅ ចំពោះឯកឧត្តម អំពីសារប្រយោជន៍វិទ្យាសាស្ត្រ និងសាសនាដែលឯកឧត្តមនិងប្រជារាស្ត្រជប៉ុន មានឯកឧត្តម កេនហ្ស៊ូម៉ាត់ស៊ុក ជាអ្នកតំណាងបានធ្វើ ចំពោះប្រជារាស្ត្រខ្មែរ ដោយជាក់ស្តែងគឺអំណោយដ៏ថ្លៃថ្លានៃគម្ពីរនេះ ។ កាយវិការនេះ ខ្ញុំជឿជាក់ចំពោះខ្លួនខ្ញុំហើយ ខ្ញុំសូមបញ្ជាក់ចំពោះឯកឧត្តមថា មុខជាជនជាតិខ្មែរ ក្នុងព្រះរាជអាណាចក្រទាំងមូល នឹងពេញចិត្តជាទីបំផុត ក្នុងនាមនៃជនជាតិខ្មែរទាំងនោះ ខ្ញុំសូមថ្លែងនូវអំណរគុណជាចុងក្រោយម្តងទៀតចំពោះឯកឧត្តម ។

លុះចប់សន្ទកថាហើយ ព្រះសង្ឃក៏សូត្រជមិជយន្តោ ជូនពរជ័យមង្គលសិរីសួស្តីចំពោះឯកឧត្តមអគ្គរាជទូតប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជា ។

រួចទើបមានពិធីជប់លៀងនំទឹកតែ ទឹកក្រូចជាកិត្តិយស ។

ពិធីបុណ្យនេះបានបញ្ចប់នៅម៉ោង ៩និង៣០នាទី ។

# ពិធីទទួលព្រះត្រៃបិដកអក្សរចិន

ស្រី-អ៊ី រៀបរៀង

---

បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានព្រះត្រៃបិដក ៨ ចប់ គឺ ព្រះត្រៃបិដកអក្សរខ្មែរ - សៀម - មន - ភូមា - លង្កា - អឺរុប - ទីបេត៍ ចិនប្រជាមានិត និងចិនជាតិនិយម ១ ទៀត ជាគម្រប់ ៩ ដែលយើងទើបនឹងបានទទួលនៅពេលថ្មីៗនេះ ៖

នៅថ្ងៃ ១៥ កុម្ភៈ ១៩-៨ ពេលព្រឹក ម៉ោង ៩ នៅមន្ទីរពុទ្ធ-សាសនបណ្ឌិត្យ ក្រសួងធម្មការ មានធ្វើពិធីមួយយ៉ាងអធិកធិក ដោយឯកឧត្ដមកុងស៊ុលចិនជាតិនិយម ប្រចាំប្រទេសកម្ពុជា បានធ្វើអំណោយសៀវភៅព្រះត្រៃបិដកអក្សរចិន ៤០ ក្បាល ដែលជាអំណោយរបស់សម្ដេច ទៀវិងពុទ្ធ កាន់ដួរ៉ាំ " ហូទូគេទូ " តាមរយៈវង្គាភិបាលនៃសាធារណរដ្ឋចិន មកជាសម្បត្តិរបស់មន្ទីរពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។

នៅឱកាសនោះ លោកប៉ាយ-ល្អុត រដ្ឋមន្ត្រីក្រសួងធម្មការ សម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រះពោធិវង្ស ហួត-តាត ចាងហ្វាង ព្រះមហាព្រហ្មមុនី ចាងហ្វាងរង ព្រមទាំងសាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះ

សុពម្រឹត ព្រះសង្ឃក្រុមជំនុំព្រះត្រៃបិដកនិងឯកឧត្តម សម-ញាណ អនុប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងមន្ត្រីក្រសួងធម្មការ ក្រុមពុទ្ធសាសនបណ្ឌិត្យ ជាច្រើនរូប បាននិមន្ត អញ្ជើញមកជួបជុំនៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ យ៉ាងកុះករ ។

វេលាព្រឹក ម៉ោង ៩ គត់ ឯកឧត្តមកុងស៊ុលចិន និងសហការីរបស់លោកព្រមទាំងលោកសង្ឃចិន ៥ អង្គ បានអញ្ជើញ បាននិមន្តមកដល់ ។ ក្រោយដែលបានធ្វើគារវកិច្ច ដោយពាក់ទាក់ទៅវិញទៅមក ឯកឧត្តមកុងស៊ុលចិន បានចាប់ផ្តើមថ្លែងសន្ថា ជាភាសាចិន រួចប្រែជាភាសាបារាំង រៀបរាប់អំពីហេតុ ដែលនាំឲ្យមានការធ្វើអំណោយសៀវភៅព្រះត្រៃបិដក ៤០ ក្បាលនេះ ។ ឯសន្ថានោះ បានប្រែមកជាភាសាខ្មែរ មានសេចក្តីដូចតទៅ ៖

## សន្ថា

## របស់លោកកុងស៊ុលប្រទេសចិនថ្លែងក្នុងឱកាសប្រគល់

## សៀវភៅព្រះត្រៃបិដកមកព្រះរាជរដ្ឋាភិបាល

## ប្រទេសកម្ពុជា

ឯកឧត្តមរដ្ឋមន្ត្រី !

ក្នុងថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយពន់ប្រមាណដោយបានទទួលឯកសិទ្ធិ មកជាតំណាងពុទ្ធិកសមាគមនៃប្រទេសខ្ញុំ ដើម្បីប្រគល់សៀវភៅព្រះត្រៃបិដកចំនួន ៤០ ក្បាល មកព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ដែលមានឯកឧត្តមជាតំណាង នៅចំពោះព្រះភក្ត្រសម្តេចព្រះសង្ឃ-នាយកទាំងពីរគណៈ និងមន្ត្រីសង្ឃទាំងឡាយ ។

សៀវភៅទាំងនេះមានកត់ត្រានូវពាក្យប្រៀនប្រដៅទាំងឡាយនៃព្រះសម្មាសម្ពុទ្ធបរមគ្រូ ដែលជាស្នាដៃមួយ ដ៏មានសារៈសំខាន់ក្រៃលែង ដោយអ្នកប្រាជ្ញខាងសាសនានៃប្រទេសខ្ញុំបានបកប្រែមកនេះ ។ គម្ពីរទាំងនេះជារបស់ក្រណាស់ ដែលប្រទេសកាន់ព្រះពុទ្ធសាសនាទាំងឡាយក្នុងសាកលលោកជឿជាក់នូវតំលៃខាងសតិអារម្មណ៍ ។

អាស្រ័យហេតុនេះហើយ បានជាសម្តេច ឡេវឹនពុទ្ធ-កាន់ដួរពាំ "ហ្វូវគេទូ" បានស្នើសុំទៅរដ្ឋាភិបាលសាធារណរដ្ឋខ្ញុំថា សូមតម្រូវឲ្យខ្ញុំទទួលភារៈជាតំណាងប្រទេសចិន ដើម្បីប្រគល់សៀវភៅដ៏ឧត្តុង្គឧត្តមនេះមកព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ។ កិច្ចនេះធ្វើឡើងស្របទៅតាមពាក្យសន្យារបស់សម្តេចឡេវឹនពុទ្ធ កាលសម្តេចនិមន្តមកទស្សនាប្រទេស

កម្ពុជា ក្នុងខែកុម្ភៈមុននោះ ហើយទាំងមានបំណងចង់ពង្រីងបំណង មេត្រីភាព ដែលធ្លាប់មានមកអស់កាលជាច្រើន សតវត្សរ៍មកហើយ រវាងជនជាតិចិននឹងជនជាតិខ្មែរ ។

ឯកឧត្តម ខ្ញុំព្រះករុណាជឿជាក់ថា គឺគេសេចក្ដីរីករាយខ្លាំងណាស់ ខ្ញុំក្នុងថ្ងៃនេះទៅទៀត បើសិនជាសៀវភៅព្រះត្រៃបិដកទាំងនេះ ដែលជាប្រភពពាក្យប្រៀនប្រដៅនៃព្រះពុទ្ធជាម្ចាស់ អាចជាជំនួយជួយបង្កើនសាសនតិចណ្ហិត ដែលពលរដ្ឋក្នុងប្រទេសឯកឧត្តមភាគច្រើន បានប្រព្រឹត្តតាមស្រាប់ហើយ ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ សុទ្ធតែច្បាប់សម្រាប់ញ៉ាំងសេចក្ដីល្អ ដល់សាសនសង្គមពិភពលោក និងសុភមង្គលដល់មនុស្សជាតិទូទៅទាំងអស់ ។

សម្ដេច ! អស់លោកទាំងឡាយ !

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណា, ខ្ញុំ សូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅនិងដិតស្និទ្ធ ចំពោះសម្ដេច ព្រះគជព្រះគុណ និងអស់លោកទាំងឡាយ ដែលបាននិមន្តនិងអញ្ជើញមកក្នុងទីនេះ ដើម្បីញ៉ាំងពិធីនេះ ឲ្យទៅជាមានសភាពដ៏រុងរឿង ។

តពីនោះមក លោកពាយ-លុត រដ្ឋមន្ត្រីក្រសួងធម្មការ បានថ្លែងសន្ថរថាជាភាសាខ្មែរ រួចប្រែជាភាសាបារាំង ឆ្លើយតបទៅវិញ មាន

សេចក្ដីដូចតទៅនេះ ៖

សុន្ទរកថា

របស់លោក ភាយ-ល្អុត រដ្ឋមន្ត្រីក្រសួងធម្មការ

សូមក្រាបថ្វាយបង្គំសម្ដេច

សូមជំរាបឯកឧត្ដម

សូមគោរព ព្រះតេជព្រះគុណទាំងឡាយ

សូមជំរាបអស់លោកទាំងឡាយ

ជាដំបូង ខ្ញុំព្រះករុណា-ខ្ញុំ សូមសំដែងនូវសេចក្ដីគោរពនមស្ការ ថ្វាយបង្គំចំពោះសម្ដេចនៃគណៈមហានិកាយ និងធម្មយុត្ត ទាំងពីរព្រះអង្គ និងសូមសំដែងនូវអំណរគុណ ដ៏បរិសុទ្ធចំពោះឥស្សរជនជាបព្វជិត និងជាគ្រហស្ថ ដែលបាននិមន្ត - អញ្ជើញមកកុះករ នាំឲ្យពិធីនេះមានរស្មីរឹតតែរុងរឿងឡើងក្នុងពេលនេះ ។

ឯកឧត្ដម លោកកុងស៊ុល !

ជាកិត្តិយសមួយធំដល់ខ្លួនខ្ញុំ ហើយដោយសេចក្ដីរីករាយជាទីបំផុតនៅនាថ្ងៃនេះ ខ្ញុំបានធ្វើជាប្រធាននៃពិធីទទួលសៀវភៅព្រះត្រៃបិដកចំនួន ៤០ ក្បាល ជាភាសាចិន ដែលឯកឧត្ដមបានខ្វល់ខ្វាយនាំមកប្រគល់ជូនក្រសួងធម្មការ ព្រះត្រៃបិដកនេះជាអំណោយរបស់សម្ដេច ឡេ-

វិជ្ជពុទ្ធ កាន់ផ្លូវ "ហូចូគេចូ តាមអរិយៈរដ្ឋាភិបាលនៃសាធារណរដ្ឋចិន ។

សៀវភៅមួយឈុតនេះ សំខាន់ជាពន់ពេកណាស់ និទានពីពាក្យប្រៀនប្រដៅ ដែលប្រមូលគ្នាទៅហៅថា អនុត្តរធម៌របស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ ។ ជាការពិតណាស់ សៀវភៅនេះ គឺកើតឡើងមកពីអ្នកប្រាជ្ញដ៏ឧត្តម របស់មហាប្រទេសលោក បានខំប្រឹងប្រែងសង្វាតព្យាយាមដ៏យូរ ដើម្បីប្រមូលផ្តុំឯកសារយ៉ាងទូលំទូលាយ ថ្វីបើមានពើបពះប្រទះនឹងការលំបាកយ៉ាងណាក៏ដោយ ខ្ញុំសូមសំដែងនូវសេចក្តីស្ងើចយ៉ាងក្រៀវក្រារបស់ខ្ញុំ ចំពោះអស់លោកអ្នកប្រាជ្ញជាទីនមស្ការៈទាំងនោះ ទោះបីលោកគង់រស់នៅសព្វថ្ងៃនេះក្តី លោករលាងខន្ធទៅកាន់បរលោកនាយហើយក្តី ។ សូមអស់លោកទាំងនោះទុកចិត្តចុះ ព្រហ្មវិហារធម៌ មានករុណាធម៌របស់លោកជាដើម ចំពោះសត្វលោកឥតសាបសូន្យសោះឡើយ ។

ឯកឧត្តម !

ពុទ្ធមាមកជនណាក៏ដឹងដែរថា ក្នុងសៀវភៅទាំងនេះ មានធម៌ជាទីគោរពនមស្ការ ព្រោះធម៌ទាំងនោះសុទ្ធសឹងតែពីឯកភាព សាមគ្គីភាព ភាតរភាព រវាងមនុស្សលោក ព្រមទាំងសកម្មភាពខាងប្រជាសង្គ្រោះ, ការសិក្សា, វប្បធម៌ និងកិច្ចការដទៃទៀតជាមនុស្សធម៌ ដើម្បី

បង្កើតឲ្យមានសន្តិភាព និងសុខដុមរមនាមនុស្សជាតិ និងសុភមង្គលដល់សត្វលោកទាំងឡាយ ។

ខ្ញុំសូមបន្ថែមសេចក្តីបន្តិចទៀតថា ក្នុងសៀវភៅទាំងនេះ មានពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តាព្រះអរហន្តសម្មាសម្ពុទ្ធរបស់យើងទាំងអស់គ្នា សុទ្ធសឹងជាពាក្យប្រៀនប្រដៅប្រកបដោយវិចារណញ្ញាណ ហើយប្រសើរអស្ចារ្យ ព្រោះជាពាក្យប្រៀនប្រដៅបង្ហាញប្រាប់អ្នកប្រតិបត្តិតាមនូវផ្លូវពិត ផ្លូវត្រង់ទៅកាន់អភិវឌ្ឍនធម៌ ពោលគឺព្រះនិព្វាន ។

ឯកឧត្តម !

អំណោយដ៏ឧត្តមនេះ ជាទីពេញចិត្តយើងខ្ញុំជាពន់ពេកណាស់ អំណោយនេះកើតមានឡើង នៅពេលដែលមហាប្រទេសរបស់ឯកឧត្តមដូចជាប្រទេសរបស់ខ្ញុំដែរ កំពុងត្រូវការជាក់ឧត្តមគតិ ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់បានកំណត់ហើយ ឲ្យពុទ្ធមាមកៈរាល់រូបថែទាំរក្សាគោរពជាអចិន្ត្រៃយ៍ ដើម្បីរួបរួមគ្នាជាកំឡាំងមួយ ខាងសន្តិភាពនិងខាងការស្រុះស្រួលគ្នា ទៅតស៊ូនិងស្ថានភាពតឹងរឹងពិភពលោកសព្វថ្ងៃនេះ នេះ. ១៦ - ១១ ទៀតអំណោយដ៏ឧត្តមនេះ ពង្រឹងសាជាថ្មីម្តងទៀតនូវចំណងមិត្តភាព ដែលមានរាប់ច្រើនរយសតវត្សរ៍មកហើយ រវាងប្រទេសចិននិងព្រះរាជអាណាចក្រកម្ពុជាផងដែរ ។ ជំនូននេះមានន័យខាងផ្លូវលោកផ្លូវ

ធម៌ទូលំទូលាយណាស់ ដំនួននេះត្រូវចូលទៅពង្រីកបណ្ណាល័យនៃក្រសួងធម្មការ ក្រសួងធម្មការសប្បាយរីករាយណាស់ នឹងដាក់ជំនូនដ៏ឧត្តមនេះជូនមហាជនប្រើប្រាស់តាមត្រូវការ ក៏ជាហេតុនាំឲ្យអំណោយនេះជ្រួតជ្រាបជាទីបំផុតដល់ជនានុជនទូទៅ ។

ជាអវសាន ក្នុងនាមនៃរាជរដ្ឋាភិបាល ក្នុងនាមផ្ទាល់នៃខ្ញុំព្រះ-ករុណា - ខ្ញុំ ។ សូមឯកឧត្តម មេត្តាបញ្ជូនចំពោះទៅសម្តេច ទៀវឹនតុង-កានជួរអាំ "ហ្វូទូកេទូ" ព្រមទាំងចំពោះទៅរដ្ឋាភិបាលនៃសាធារណៈរដ្ឋចិននូវមនោសញ្ចេតនាប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រៅក្លា ព្រមទាំងអំណរគុណដ៏បរិសុទ្ធ នៃរាជរដ្ឋាភិបាលខ្មែរឲ្យបានកុំខានផង ។

កាលចប់សេចក្តីថ្លែងសន្ទកថាហើយ លោកសង្ឃប៉ិនតាំង ៤ អង្គ ចាប់ផ្តើមស្វាធ្យាយន៍ធម៌ជាភាសាចិនប្រសិទ្ធពរ ដោយបទសរភញ្ញដ៏ពីរោះ ក្នុងឱកាសនោះ ឯកឧត្តមកុងស៊ុលចិន ក៏ចាប់លើកស្ពុយសៀវភៅព្រះត្រៃបិដកមកជូនផ្ទាល់ដៃលោកពាយ-លុក រដ្ឋមន្ត្រីក្រសួងធម្មការ ចំពោះព្រះភក្ត្រសម្តេចព្រះសង្ឃនាយកទាំងពីរគណៈនិងមន្ត្រីសង្ឃទាំងឡាយ ៗ គមកព្រះសង្ឃខ្មែរ ក៏ស្វាធ្យាយធម៌ជយន្តោប្រសិទ្ធពរជ័យជូនឯកឧត្តមកុង-ស៊ុលចិន និងមន្ត្រីទាំងឡាយ ។

នៅទីបញ្ចប់ ក្នុងបរិយាកាសដ៏ក្សាន្ត មានការប្រគេន ការលៀង ភេសជ្ជៈនិងនំ ចំពោះព្រះសង្ឃនិងភ្ញៀវកិត្តិយសទាំងឡាយ ដោយរីករាយ ។

ពិធីនេះបានបញ្ចប់សព្វគ្រប់ នៅវេលាម៉ោង១០ព្រឹក ។

# ព្រះមហាប៉ាង–ខាត់ រៀបរៀង

អង្កុរ បុំ. ពន្លក, លំពង់ឈើ; សក់, លោហិត, ទឹក; ពហុ. នៅខ្ចី ។ –វន្ត, គុ. ដែលមានលំពង់ ។

អង្កុរក បុំ. សំបុក ។

អង្កុឝ បុំ. កង្វេ ។ គ្រហ, បុំ. អ្នកកាន់កង្វេ, ហ្មដំរី ។ ធរ. បុំ. អ្នកកាន់កង្វេ, ហ្មដំរី ។ អង្កុឝិន ដែលមានកង្វេ ។

អង្កូរ បុំ. មើលអង្កុរ ។

អង្កោឋ, អង្កោដ, អង្កោល, អង្កោល្ល, អង្កោលក, បុំ. ដើមអង្កោដ ឬ អង្កោល ។ អង្កោល-សារ, បុំ. ខ្ទឹមអង្កោល, ថ្នាំពុល ដែលផ្សំពីខ្ទឹមអង្កោល ។

អង្ក្ត មើលពាក្យ អញ្ជ ។

អង្ក្យ គុ. ដែលសំគាល់ដោយស្លាករបួស ។

អង្ខ ធាតុ, កំរើក ។

( មានត )

ផ្នែកខាងព្រះសង្ឃ មានសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះពោធិវង្ស ហួត-តាត ពាន់ហ្មាន់, ព្រះមហាព្រហ្មមុនី ទេព-អ៊ូ ពាន់ហ្មាន់រង់ជាដើម ។

ផ្នែកខាងគ្រហស្ថ មានលោកប៉ែម-យុត នាយកមន្ទីរ លោកយ៉ា-គឹមហុង នាយកាតិៈណា គំណាងរដ្ឋមន្ត្រីក្រសួងធម្មការ ជាដើម លោកសម-ញាណ អនុប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងមន្ត្រីបាកំងខ្មែរឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយពុំបានយកនាមពុំសព្វគ្រប់ ។

ដំបូង ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត បានថ្លែងសុន្ទរកថាជាភាសាខ្មែរ ហើយប្រែជាភាសាបារាំង រៀបរាប់អំពីព្រឹត្តិការណ៍នោះ យ៉ាងពីរោះក្បោះក្បាយ ។ បន្ទាប់មក ព្រះសង្ឃមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកជាប្រមុខ ចាប់ផ្តើមសូត្រព្យាយធម៌ជយន្តោស្រិទ្ធិពរជ័យប្រគេនព្រះគ្រូសង្ឃសត្ថា ឲ្យមានជោគជ័យល្អ ក្នុងដំណើរចេញទៅបត្តិវិជ្ជានោះ ។

ចប់ការសូត្រព្យាយធម៌ហើយ មានការជប់លៀងភេសជ្ជៈ នំនំចំពោះភ្ញៀវកិត្តិយសអស់រយៈវេលាដ៏សមគួរ ។

សន្និបាតនេះ បានបញ្ចប់នៅវេលាម៉ោង ៦ និង ៣០ នាទីល្ងាច ដោយបរិយាកាស ដ៏ប្រកបដោយសេចក្តីរីករាយយ៉ាងក្រៃលែង ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣០ លេខ ៣ ខែមិនា

ព.ស. ២៥០០ គ.ស. ១៩៥៨

— ភ្នំពេញ —

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣០ លេខ ៣ ខែមិនា

ព.ស. ២៥០០ គ.ស. ១៩៥៨

ភ្នំពេញ

# ពិធីទទួលរថយន្តជាព្រះរាជអំណោយសម្តេចព្រះឧបយុវរាជ

កាលពីថ្ងៃព្រហស្បតិ៍ ទី ២៧ កុម្ភៈ ១៩៥៨ ម៉ោង ១៦ និង ៣០ នាទី មានធ្វើពិធីទទួលរថយន្ត កាមីញ៉ុងណែត១ កម្លាំង២សេះ អំពីសម្តេចព្រះឧបយុវរាជ ដែលទ្រង់ព្រះរាជទានដល់សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃពុទ្ធសាសនិក ។

វរសមណៈ និងវរជន ដែលនិមន្ត អញ្ជើញមកជួបជុំនៅទីនោះ ផ្នែកបព្វជិត សម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកគណៈធម្មយុត្ត ព្រះពោធិវង្សចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ព្រះរាជាគណៈហានានុក្រម, ព្រះថេរានុត្ថេរៈ ផ្នែកគ្រហស្ថ សម្តេចចៅហ្វាវាំងវរវៀងជ័យ ប៉ែន-នុត នាយករដ្ឋមន្ត្រី សមាជិករដ្ឋាភិបាល នាម៉ឺនសព្វមុខមន្ត្រី លោកយួន-ណៃ ប្រធានសមាគមគិលានសង្គ្រោះ សមាជិកសមាគមនេះ ក្រុមបុគ្គលិកមន្ទីរពេទ្យព្រះសង្ឃជាដើម ។

ម៉ោង ១៧ សម្តេចព្រះឧបយុវរាជទ្រង់ស្តេចយាងដល់ ព្រមទាំងលោកវរសេនីយឯកមាស-ហ៊ុល រាជឱរស្ស ក្រុមប្រឹក្សាព្រះរាជា ព្រះរាជបរិពារ ។

ក្រោយដែលបានធ្វើគារវកិច្ចចំពោះព្រះសង្ឃ សម្តេចព្រះឧបយុវរាជទ្រង់ថ្លែងព្រះសុន្ទរកថាមួយ រៀបរាប់អំពីហេតុដែលទ្រង់បានរថយន្តនេះពីសមាគមដំឡើងគ្រឿងចក្ររថយន្ត នៅវិថីព្រែនគរ រថយន្តនេះទ្រង់នឹងធ្វើអំណោយ ចំពោះសមាគមគិលានសង្គ្រោះ សម្រាប់ដឹកនាំព្រះសង្ឃ

☛ (តទៅក្រោយខាងចុង)

1958_3

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


ផ្នែកសាសនា — ទំព័រ

- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង . . . . . . ១៩៣
- ធុរៈ ២ យ៉ាងក្នុងព្រះពុទ្ធសាសនា ព្រះទេពសត្ថា គឹម-គូរ រៀបរៀង . . . . . ១៩៩
- សេចក្ដីពិចារណាទៃពុទ្ធសាសនិកជនម្នាក់ (តមក) លោកភ៉ាប-ប៊ុក រៀបរៀង . . ២០៥

ផ្នែកអក្សរសាស្ត្រ

- រឿងអង្គុលិមាលកុមារ លោក លាង-ហាប់-អាន រៀបរៀង . . . . . . . . . . ២០៩
- រឿងទេវន្ធរបស់អម្រឹតញ្ញត្រីម៉ុក (តមក) លោកញ៉ុក-ថែម ពិនិត្យ . . . . . . ២២៥
- រឿងសាមកុក (តមក) . . . . . . ឧកញ៉ាទូ-កន ប្រែ . . . . . . . ២៣៣
- រឿងព្រេងនិងរឿងប្លូកណាទៃប្រទេសជប៉ុន លោក ភ៉យ-ប៊ុក ប្រែរៀបរៀង . . . ២៤១
- រឿងអ្នកគង្វាលចៀមបិត្តស្ទូគក្រង់និងព្រះរាជធីតា (តមក) លោកផេង-គ្រី រៀបរៀង ២៤៩
- រឿងចៅបាយក្ដាំង (តមក) លោកទៀង-តៃ-ឈុន ប្រែរៀបរៀង . . . . . ២៥៥

ផ្នែកកំណត់និងប្រវត្តិការណ៍

- ពិធីអនុសាវរីយ៍: មហាសន្និបាតលើកទី ១៤ ខេមរ្ទសង្ឃ លោក ឯន-ប៉ង់ រៀបរៀង ២៦៧
- មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យ លោក ភ៉យ-ប៊ុក រៀបរៀង . . . . ២៧៩
- ទេសភាពវត្តប្រទេសនេបាល់និងរដ្ឋបិង្គ័ល លោក ភយ-ប៊ុក រៀបរៀង . . . ២៩៥
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហាជាង-ខាត់ រៀបរៀង . . . . . ២៨៨



មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជារ ២៣០៛០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique


## TABLE DES MATIERES


*PARTIE RELIGIEUSE* :

-Histoire du Bouddhisme au Cambodge ( suite ) par Vén. *PANG-KHAT* . . . . . . . . . . . . . . . . . . . 193
-Deux devoirs dans le Bouddhisme par Vén. *KEM-TO* . .. 199
-Réflexion d'un Bouddhiste (suite) par *M. RAY-BUC* . . . 205

*PARTIE LITTERAIRE* :

-Histoire du « PETIT POUCET » traduite par *M. LEANG-HAP-AN* . . . . . . . . . . . . . . . . 209
-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* . . . . . . . . . 225
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . . 233
-Conte et Légende du Japon (suite) traduits par *M.RAY-BUC* . . . . . . . . . . . . . . . . 241
-Le Berger fidèle de la princesse (suite) par *M. PHENG-CHRIV* . . . . . . . . . . . . . . 249
-Légende du « Sieur Croûte de riz » (suite) traduite par *M. TIANG-TAY-CHHUN* . . . . . . . . . . . 255

*NOTES ET CHRONIQUES* :

-Quatorzième réunion annuelle des dignitaires religieux pour l'année 1958 par *M. EN-PANG* . . . . . . 267
-Assemblée Générale de l'Association des Amis du Lycée Bouddhique par *M. RAY-BUC* . . . . . . . 279
-Voyage de Nepal à Bengale par *M. RAY-BUC* . . . . 285
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT* . . . . . . . . . . . . 288



Prix d'abonnement annuel ( comprenant 12 numéros ) : 230 r 00 .

## ផ្នែកសាសនា

# ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

( តមក )

| | អតីតនាម | បច្ចុប្បន្ននាម |
|---|---|---|
| ១. ព្រះមជ្ឈន្តិកត្ថេរ | ទៅ កស្មិរៈ គន្ធារៈ | កស្មិរៈ កន្ធារៈ |
| ២. ព្រះមហាទេវត្ថេរ | ទៅ មហិស មណ្ឌល | ខេត្តមៃសោរ ( Mysore) |
| ៣. ព្រះរក្ខិតត្ថេរ | ទៅ វនវាសីប្រទេស | ខាងឧត្តរទិសនៃខេត្តកន្នរៈ ( Kannara) |
| ៤. ព្រះយោនកធម្មរក្ខិតត្ថេរ | ទៅ អបរន្តប្បទេស | ខេត្តគុជរាត ( Gujrat ) |
| ៥. ព្រះមហាធម្មរក្ខិតត្ថេរ | ទៅ មហារដ្ឋ | ខេត្តមរាថ ( ·Marathe ) |
| ៦. ព្រះមហារក្ខិតត្ថេរ | ទៅ យោនកប្បទេស | អាណាចក្រក្រិក ទិសពាយ័ព្យឥណ្ឌា |
| ៧. ព្រះមជ្ឈិមត្ថេរ | ទៅ ហិមវន្តប្បទេស | តំបន់ហិមាល័យខាងឧត្តរទិស |
| ៨. ព្រះមហាមហិន្ទត្ថេរ | ទៅ តម្ពបណ្ណិ | កោះសិរីលង្កា |
| ៩. ព្រះសោណកត្ថេរឧត្តរត្ថេរ | ទៅ សុវណ្ណភូមិ | សុវណ្ណភូមិ (អាស៊ីអាគ្នេយ៍) |

*ដរទៅពីប្រកតកោះសិរីលង្កា ដែលបានពោលមកនេះ មានសិលាចារឹកព្រះរាជប្រកាសនៃព្រះបាទធម្មាសោកមហារាជ ច្រើនកន្លែងទៀត*

ខ្លះនៅក្នុងប្រទេសឥណ្ឌា ខ្លះទៀតនៅក្រៅប្រទេសឥណ្ឌា ដែលទ្រង់ព្រះរាជបញ្ជាឲ្យដំកល់ទុក ក្នុងទីឋាននានា ដែលព្រះអង្គផ្សាយពុទ្ធសាសនាទៅដល់ ។

ខ្ញុំដកស្រង់ព្រះរាជប្រកាសទាំងនោះ បំពោះតែគោល ៗ ខ្លះ យកមកទុកក្នុងទីនេះ សម្រាប់ប្រាប់ការបេះដឹងរបស់យើង ព្រោះប្រកតទាំងនេះ អ្នកប្រាជ្ញទាំងឡាយ តែងអះអាងថាជាសេចក្ដីពិត គួរជឿបានដូចតទៅនេះ ៖

"ក្រោយរាជាភិសេក ទ្រង់បានធ្វើសង្គ្រាម មានជ័យនៅកលិង្គរដ្ឋ ចាប់ឈ្លើយបាន ១៥០.០០០ នាក់ សម្លាប់ចោលអស់ ១០០ ០០០ នាក់ ស្លាប់ក្នុងសមរភូមិច្រើនអនេកទៅទៀត (ព្រោះតែមានមហន្តរាយនៃសង្គ្រាមនេះហើយ) តមក, ទ្រង់មិនលះបង់ការប្រតិបត្តិធម៌ និងការផ្សាយព្រះធម៌ឡើយ (ព្រះរាជប្រកាសលេខ ១៣) ។ ជ័យព្រះអង្គគឺធម្មវិជ័យ ( ព្រះរាជប្រកាសលេខ ៤ ) ធម្មវិជ័យដែលទ្រង់ឈ្នះក្នុងទីនេះ និងទីឆ្ងាយទៅទៀតដល់ ៦០០ យោជន៍ (ព្រះរាជប្រកាសលេខ ១៣) ។ នៅក្នុងព្រះរាជអាណាចក្រនៃព្រះអង្គ និងប្រទេសជិតខាង ព្រះរាជប្រកាសព្រះអង្គ (ព្រះរាជប្រកាសលេខ ១៣) បានប្រាប់ឈ្មោះទីឋានតទៅនេះគឺ យោនកៈ ឬ យវនៈ, កម្ពោជៈ, បាណ្ឌ្យៈ, ចោលៈ, ចេរៈ, បុលិណ្ឌៈ,

ដែនតាម្ពបណ្ណិ គោះសិរីលង្កា ។ល។ ឆ្ងាយទៅទៀត, ព្រះរាជប្រ-
កាសព្រះអង្គមានប្រាប់នាមព្រះបាទអន្តិយកៈ ឬ អន្តិយោកៈ ព្រះរាជប្រ-
កាសលេខ ២ ដែនព្រះរាជា ៤ អង្គទៀតគឺ តុរមាយៈ ឬ តុរមេយៈ ១,
ព្រះបាទអន្តិកិនិ ឬ អន្តិកិនៈ ១, ព្រះបាទមគៈ ឬ មកៈ ១, ព្រះបាទ
អលិកសុន្ទរៈ ឬ អលិកសុទ្ធរៈ ឬ អលិកសន្ទ្រ ១, (ព្រះរាជប្រកាស
លេខ ១៣) ឈ្មោះទីឋានដែននាមព្រះរាជាទាំងនេះ សរសេរពាក្យប្លែកៗ
គ្នាខ្លះ ៗ អ្នកប្រាជ្ញបុរាណ បានស្រាវជ្រាវគេឃើញថា :

១- ព្រះបាទអន្តិយកៈនោះគឺ ព្រះបាទអន្តិយោកុស (Antiochus Ier Soter) ២៨០-២៦១ មុនគ្រិស្តសករាជ ឬអន្តិយោកុសទី ២ (Antiochus II Theos) ២៦១-២៤៦ មុនគ្រិស្តសករាជ ជាព្រះរាជានៃប្រទេសស៊ីរី (Syrie)

២- ព្រះបាទតុរមេយៈ គឺព្រះបាទបូទ្លេម៉េ (Ptoléme Philadelphe) (២៨៥-៥២៤.៧ មុនគ្រិស្តសករាជ) ជាព្រះរាជានៃប្រទេសអេហ្ស៊ីប

៣- ព្រះបាទអន្តិកិនិ គឺព្រះបាទអន្តិគោន(Autigone)២៧៨-២៣៩ មុនគ្រិស្តសករាជ ជាព្រះរាជានៃប្រទេសក្រិក ម៉ាសេដ្វាន (Macedane)

៤ ព្រះបាទមគៈ គឺព្រះបាទមគ័ស (Magas) (៣០០-២៥៨ មុនគ្រិស្តសករាជ) ជាព្រះរាជានៃប្រទេសស៊ីរេន (Cyréne) ជាប្រទេស

ចំណុះក្រិក ឋិតនៅខាងលិចប្រទេសអេហ្ស៊ីប ទ្វីបអាហ្វ្រិក ។

៥ ព្រះបាទអលិកសុន្ទរៈ គឺព្រះបាទអឡេកសង់ដ្រ៍ (Alexendre) (២៧២-២៥៨ មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសអេពីរ (Epire) ឬអឡេកសង់ដ្រ៍ (២៥២-២៤៤ មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសកោរិន្ថ (Corinthe) ។

កងព្រះរាជប្រកាសព្រះបាទធម្មាសោកមហារាជ មិនឃើញមានកត់ត្រាឈ្មោះសុវណ្ណភូមិ ក្នុងព្រះរាជប្រកាសព្រះអង្គ ដូចប្រកពកោះសិរីលង្កាទេ គ្រាន់តែមានសេចក្តីបញ្ជាក់ថា ទ្រង់បានផ្សាយពុទ្ធសាសនាទៅគ្រប់ទិសានុទិស ។ ដោយស្នាព្រះហស្តព្រះអង្គ និងព្រះរាជាអង្គខ្លះទៀត ដូចព្រះបាទកនិស្កៈជាដើម ព្រះពុទ្ធសាសនាផ្សាយទៅ ខាងបច្ចិមទិសដល់រាជអាណាចក្រក្រិក ដល់ទ្វីបអាហ្វ្រិកភាគឧត្តរ ខាងអាស៊ីភាគកណ្តាល ដល់ប្រទេសចិន, ម៉ុងគោលី, កូរេ, ជប៉ុន, ខាងឧត្តរទិសដល់ប្រទេសទីបេត, ខាងទក្ខិណទិសដល់កោះសិរីលង្កា ហួសឆ្ងាយទៅទៀតដល់សុវណ្ណភូមិ ។

សេចក្តីដូចបានពោលរៀបរាប់មកហើយប៉ុណ្ណោះ យើងជឿជាក់ថាព្រះសោណកត្ថេរនិងព្រះឧត្តរត្ថេរ ជាសមណទូតនាំពុទ្ធសាសនា មកដល់សុវណ្ណភូមិកាលពីពុទ្ធសតវត្សទី ៣ ពិតមែនហើយ ដូចសេចក្តីដែល

មានបែងទុក ក្នុងប្រកពកោះសិរីលង្កាស្រាប់ តែពីបាកនឹងកំណត់ឲ្យទៀង ទាត់ថា ដែនដីឯណាប្រទេសណាទៀត នឹងប្រទេសចិននេះ ទីឋានត្រង់ ណាជាសុវណ្ណភូមិ ដែលព្រះថេរៈទាំងពីរអង្គ មកតាំងមជ្ឈមណ្ឌលផ្សាយ ពុទ្ធសាសនានុះ? នឹងថា នៅប្រទេសភូមា ក៏នៅមានការជជែកគ្នា នឹងថា នៅប្រទេសសៀម ក៏មិនសមហេតុផលគ្រប់គ្រាន់ ឬ នឹងថា នៅ ប្រទេសណា ក៏មិនប្រាកដដែរ ព្រោះជាហេតុការណ៍ ដែលមានមកមុន ប្រវត្តិកាលនៃប្រទេសទាំងឡាយ ដែលមានក្នុងភូមិភាគនេះទាំងអស់ទៅ ទៀត ។ បណ្ដាប្រទេសទាំងឡាយ ដែលកាន់ពុទ្ធសាសនាថេរវាទ នៅ ក្នុងភូមិភាគនេះទាំងអស់ ប្រទេសនីមួយ ៗ ក៏បានទុករឿងព្រះថេរៈទាំង ពីរអង្គ នឹងសុវណ្ណភូមិនេះ ជាប្រវត្តិបុរាណ របស់ប្រទេសរៀងខ្លួន ហើយអះអាងគ្រប់គ្នាថាតាំងនៅក្នុងដែនដីតែរៀងខ្លួនទៀត ដូចសេចក្ដី ដែលលោក ប៉ ឌុយប៉ុង សរសេរថា ៖

"ប្រវត្តិប្រទេសភូមានឹងសិលាចារឹក ពីគ្រិស្តសតវត្សទី ១៥ បានពោលអះអាងថា ព្រះបាទធម្មាសោកមហារាជ បានបញ្ជូនសមណ ទូតមកកាន់ប្រទេសភូមា ៣ លើក ពីពុទ្ធសតវត្សទី ៣ តែចំនួននឹងនាម សមណទូតមានតែពីរអង្គ ដូចប្រកពកោះសិរីលង្កាដែរ ។ ឯប្រវត្តិដែល និយាយពីព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរ និមន្តមកកាន់សុវណ្ណភូមិនេះ

ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ នៅអាស៊ីភាគអាគ្នេយ៍ បានដឹងទាំងអស់គ្នាជាអាទិ៍ ដូចប្រទេសសៀម ហ៊ានទាំងពោលថា ប្រវត្តិសោណកត្ថេរនិងឧត្តរត្ថេរនេះជាប្រវត្តិប្រទេសរបស់ខ្លួន ហើយតាំងនៅក្នុងប្រទេសខ្លួនថែមទៀតផង: រឿងរ៉ាវព្រះសោណកត្ថេរនិងព្រះឧត្តរត្ថេរ ទាំងពីរអង្គនេះ មានកាលបរិច្ឆេទទំនងជាមិនពិតត្រឹមត្រូវទេ តែគេរក្សាទុកថាជាប្រពៃណីសមណទូតនៃពុទ្ធសាសនា ដែលមានមកដល់ឥណ្ឌូចិនបច្ចិមទិសាភាគ តាំងពីបុរាណកាល ” ។

រឿងរ៉ាវសុវណ្ណភូមិ ជារឿងដែលយើងគួរតែចង់ចេះដឹងណាស់ហើយ យើងគប្បីតែស្រាវជ្រាវរកឲ្យឃើញ សម្រាប់ប្រជាប់ការចេះដឹង ព្រោះជារឿងដែលទាក់ទងនឹងប្រទេសយើងដោយចំពោះ ។

តទៅ, ខ្ញុំសូមឱកាសរៀបរាប់ ពីដំណើរដើមទងសុវណ្ណភូមិបន្តិចសិន សម្រាប់ប្រជាប់នៃការចេះដឹងរបស់យើង សឹមនិយាយពីព្រះពុទ្ធសាសនា ដែលចូលមកកាន់ប្រទេសខ្មែរយើងជាលំដាប់ ព្រោះថាការចេះដឹងរឿងសុវណ្ណភូមិសព្វគ្រប់ ជាហេតុនាំឲ្យយើង យល់ប្រស្នាព្រះពុទ្ធសាសនា ដែលមកប្រតិស្ឋាននៅប្រទេសយើងដោយបរិបូណ៌ ។

ដើមទងដែលនាំឲ្យជនជាតិឥណ្ឌៀ មកកាន់សុវណ្ណភូមិ ក្នុងកាលនោះ

( មានត )

# ធុរៈក្នុងព្រះពុទ្ធសាសនា ២ យ៉ាង

ព្រះទេពសត្ថា កឹម-គូរ រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៗ

នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសេចក្តីគោរព ។

វេលានេះ អាត្មាភាពសូមសំដែងអំពីធុរៈព្រះពុទ្ធសាសនា ២ យ៉ាង តាមសេចក្តីនិមន្តរបស់លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។ មុននឹងសំដែងធម៌នេះ អាត្មាភាពសូមពណ៌នាអំពីជំនឿរបស់មនុស្សទូទៅ ដែលមានសេចក្តីប្រកាន់ខ្ជាប់ទៅលើសាសនាមួយៗ និងកំណើតព្រះពុទ្ធសាសនាដូចមានសេចក្តីបរិយាយ ដោយសង្ខេបតទៅនេះ :

ធម្មតាមនុស្សក្នុងលោក តាមតែសញ្ញាណកំណត់ដោយ សុទ្ធសឹងតែមានជំនឿទៅក្នុងអ្វីមួយ បើមិនច្រើនក៏តិចដែរ ដែលខ្លួនយល់ឃើញថាជាវត្ថុស័ក្តិសិទ្ធិគួរពឹងពាក់ពំនាក់អាស្រ័យ គួរគោរពរាប់អាន ពុំសូវមាននៅតែឯកឯងឥតទីពឹងឡើយ ។ ឯវត្ថុស័ក្តិសិទ្ធិទាំងនោះគេច្រើននិយមយកលទ្ធិដែលជាបវេណីរបស់បុព្វបុរសសម្រាប់ជាតិនីមួយ ៗ ដែលធ្លាប់ប្រព្រឹត្តប្រតិបត្តិកាន់ជាប់តៗគ្នាមកកំណត់ហៅថា សាសនា ។

សាសនានោះសោតទៀត មានរបៀបរបបផ្សេងៗពីគ្នា តាមមតិរបស់សាស្តាចារ្យនីមួយៗប្រឌិតបង្កើតឲ្យមានឡើង ដើម្បីនឹងឲ្យបរិស័ទចុះចូលជឿស្តាប់គោរពកាន់ដូចយើងបានឃើញ បានឮមកហើយដែលមាននៅក្នុងលោកនេះ ។

បណ្តាសាសនាទាំងអស់ក្នុងលោក មានតែព្រះពុទ្ធសាសនាមួយទេ ដែលជាសាសនាមានសារៈសំខាន់បំផុតជាងសាសនាឯទៀតៗ ទាំងអស់ ព្រោះជាសាសនាអាចធ្វើមនុស្សគ្រប់ឋានៈជាអ្នកប្រតិបត្តិតាម ឲ្យមានសន្តិភាព មេត្រីភាពនិងសេរីភាព ទូទៅក្នុងលោក រហូតដល់ព្រះនិព្វានជាទីបំផុត ។ កំណើតនៃព្រះពុទ្ធសាសនានេះគឺ មហាបុរសយ៉ាងឆ្នើមមួយរូប ជាអ្នកមានវិចារណញ្ញាណយ៉ាងជ្រាលជ្រៅបានរកឃើញសេចក្តីប្រតិបត្តិដែលមានខ្លឹមសារវិសេស អាចធ្វើមនុស្សគ្រប់ឋានៈដែលជឿហើយប្រតិបត្តិតាម ឲ្យដល់នូវទីបំផុតទុក្ខបាន បានទាំងប្រកាសផ្សាយទុកមានជាបមកដល់សព្វថ្ងៃនេះ ឯមហាបុរសនោះគឺ ព្រះសម្មាសម្ពុទ្ធរបស់យើងហ្នឹងឯង ។ ដំណើរដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ស្វែងរកសេចក្តីប្រតិបត្តិដែលមានខ្លឹមសារនោះ ពុំមែនទើបនឹងស្វែងរកក្នុងជាតិមួយជាទីបំផុតនេះទេ គឺទ្រង់ស្វែងរកអស់កាលជាច្រើនជាតិណាស់ ដូចមានប្រវត្តិដែលអ្នកប្រាជ្ញទាំងឡាយ បានចារទុកក្នុងគម្ពីរជាច្រើន មាន

គម្ពីរបឋមសម្ពោធជាដើម ដែលមានសេចក្តីដំណាលថា កាលដែលព្រះសម្ពុទ្ធបរមគ្រូរបស់យើង នៅគង់ឋានៈជាពោធិសត្វនៅឡើយនោះ មានឈ្មោះថា សុមេធបណ្ឌិត បានបំពេញបារមីធម៌ទាំងឡាយមានទានបារមីជាដើម អំណើះកាលអំពីនោះមក សូម្បីព្រះអង្គកើតជាជាតិអ្វីក៏ដោយ ទោះជាតិជាមនុស្សក្តី ជាតិជាអមនុស្ស មានទេវតាជាដើមក្តី ជាតិជាតិរច្ឆានក្តី សុទ្ធតែបានបំពេញបារមីធម៌គ្រប់ ៗ ជាតិ ដើម្បីស្វែងរកមោក្ខធម៌ តម្រាំងរហូតដល់បច្ឆិមជាតិ ( ជាតិជាទាងចុងបំផុត ) ដែលមាននាមថា សិទ្ធត្ថកុមារ អស់រយៈកាលគំរប់ ៤ អសង្ខេយ្យ ១សែនកប្ប នៅតែមិនទាន់ជួបប្រទះនឹងខ្លឹមរបស់សេចក្តីប្រតិបត្តិគឺមោក្ខធម៌នៅឡើយ ។

លុះព្រះបរមពោធិសត្វលះរាជសម្បត្តិ ហើយចេញទ្រង់ព្រះផ្នួសស្វែងរកមោក្ខធម៌ មិនយូរប៉ុន្មានក៏បានឃើញជាក់ច្បាស់នូវមោក្ខធម៌គឺ សព្វញ្ញុតញ្ញាណ ដែលមានខ្លឹមសារដោយប្រាជ្ញាញាណរបស់ព្រះអង្គឥតមានទើសទាក់ ឬគំបាំងនឹងអ្វីឡើយ ហាក់ដូចជាគេរំពាលពន្លឺភ្លើងទៅក្នុងទីងងឹត ដែលយើងហៅថា ព្រះអង្គត្រាស់ដឹង ទ្រង់គង់លើរតនបល្ល័ង្ក ក្រោមពោធិព្រឹក្សមាននាមថា ព្រះពុទ្ធ ។

ចាប់ដើមពីត្រឹមនោះមក ព្រះពុទ្ធជាម្ចាស់ ទ្រង់ទេសនាប្រកាស

ផ្សាយឧវាទានុសាសនធម៌ គឺពាក្យប្រៀនប្រដៅដ៏មានខ្លឹមសារ ដែលព្រះអង្គបានត្រាស់ដឹងនោះឯង ដល់សត្វនិករទូទៅក្នុងត្រៃលោក ។

ឧវាទានុសាសនធម៌ដែលព្រះអង្គទ្រង់សំដែងប្រោសសព្វសត្វអស់រយៈកាល ៤៥ ឆ្នាំ ពីត្រឹមឆ្នាំដែលបានត្រាស់ទៅដល់ឆ្នាំដែលបរិនិព្វាននោះ គឺទ្រង់សំដែងតែក្នុងឧវាទ ៣ យ៉ាងគឺ ១ - សព្វបាបស្ស អករណំ ការមិនធ្វើអំពើអាក្រក់ទាំងពួងដោយកាយ វាចា ចិត្ត ឧវាទនេះចាត់ទៅជាវិន័យ ហៅថា វិនយបិដក, ២ - កុសលស្សូបសម្បទា ការបំពេញកុសលផ្សេងៗ ដោយកាយ វាចា ចិត្ត ឧវាទនេះចាត់ទៅជាព្រះសូត្រ ហៅថា សុត្តន្តបិដក, ៣ - សចិត្តបរិយោទបនំ ការធ្វើចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ចាកកិលេសមានរាគៈ ទោសៈ ជាដើម ឧវាទនេះចាត់ទៅជាអភិធម្ម ហៅថា អភិធម្មបិដក; ឧវាទទាំង ៣ យ៉ាងនេះឯង ជាគោលនៃព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនា បើចាត់ទៅជាធុរៈ ដែលពុទ្ធសាសនិកត្រូវបំពេញ មាន ២ យ៉ាងគឺ គន្ថធុរៈ ១ វិបស្សនាធុរៈ ១ ។ ការតាំងព្យាយាមដ៏មុតមាំខំសិក្សានូវពុទ្ធវចនៈ គឺព្រះត្រៃបិដកតាមកម្លាំងសតិបញ្ញា និងសមត្ថភាពរបស់ខ្លួន បានចេះចាំស្ទាត់គ្រប់បិដកទាំង ៣ ក្តី ត្រឹមតែបិដកមួយក្តី ឬត្រឹមតែនិកាយមួយក្តី ឬក៏ដោយហោចទៅត្រឹមតែពុទ្ធវចនៈបទណាមួយ

ក្តី ហើយអាចបង្អាក់បង្អៀនគេកើត អាចសំដែងណែនាំពន្យល់គេកើត ហើយមានសេចក្តីប្រតិបត្តិត្រឹមត្រូវតាមពុទ្ធវចនៈនោះៗ មិនឲ្យឃ្លៀងឃ្លាតផង ហៅថា គន្ថធុរៈ ។

ការសិក្សារៀនសូត្របានចេះចាំពុទ្ធវចនៈបទណាមួយ ឲ្យស្ទាត់ប្រាកដហើយបានធ្វើខ្លួនឲ្យស្រាលគឺបើខាងគ្រហស្ថ លះបង់សកិច្ច (ការរវល់គ្រប់គ្រងផ្ទះ) ចេញ, បើខាងបព្វជិត លះពលិពោធ (ការកង្វល់ផ្សេងៗ) មានការរវល់ក្នុងអាវាស ឬការគ្រប់គងពួកក្រុមជាដើមចេញតាមពេលដែលគួរលះបាន ហើយកេទីសេនាសនៈដ៏ស្ងប់ស្ងាត់លើកអាវុធគឺបញ្ញាឡើង ពិចារណាឃើញច្បាស់នូវទោសរបស់សង្ខារធម៌ទាំងខាងក្នុងទាំងខាងក្រៅ ដែលជាសភាវៈនាំឲ្យកើតឡើង ទាំងនាំឲ្យវិនាសសាបសូន្យទៅវិញ ចំពោះអត្តភាពរបស់ខ្លួន ឬចំពោះអត្តភាពមនុស្សសត្វដទៃឲ្យឃើញថា សុទ្ធតែលុះនៅក្នុងអំណាចត្រៃលក្ខណ៍ដូចគ្នាទាំងអស់ ការនឹករំពឹងពិចារណារឿយៗ ដកបទាល់តែចិត្តនឿយណាយធុញទ្រាន់ចំពោះសត្វនឹងសង្ខារទាំងអស់ បើទបនិស្ស័យមានមកពីបុព្វជាតិចាស់ក្លាជាជំនួយខ្លះផង ក៏បានលុះនូវគុណធម៌ជាន់ខ្ពស់មានសោតាបត្តិផលជាដើម បើពុំដូច្នោះទេ គង់នឹងបានជាទបនិស្ស័យក្នុងបច្ចុប្បន្ននឹងអនាគតទៀតពុំខាន សេចក្តីពណ៌នាមកដោយសង្ខេបប៉ុណ្ណេះហៅថា វិបស្សនាធុរៈ ។

ធុរៈទាំងពីរយ៉ាងដូចបានពណ៌នាមកហើយនេះ ជាសេចក្ដីសង្ខេបខ្លីពេក បើអស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ ចង់ជ្រាបសេចក្ដីច្បាស់លាស់ជាងនេះ សូមមើលព្រះត្រៃបិដក ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពចេញខ្លះហើយនោះ ទើបឃើញសេចក្ដីពិស្ដារទូលំទូលាយល្អណាស់ ដែលយើងហៅថា ព្រះត្រៃបិដកៗជាឈ្មោះគោលដើមរបស់គម្ពីរទាំងឡាយ ។ ព្រះត្រៃបិដកចែកចេញជា ៣ គឺ វិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។

ពុទ្ធឱវាទដែលមានសេចក្ដីបញ្ញត្តិ និងអនុញ្ញាតមិនឲ្យបុគ្គលប្រព្រឹត្តឈានពានតាមអំពើចិត្ត ហៅថា វិន័យ បើបែកខាងបព្វជិត ហៅថា អនាគារិយវិន័យ បើខាងគ្រហស្ថហៅថា អាគារិយវិន័យ មា ឈ្មោះ ៥ គម្ពីរគឺ មហាវិភង្គ ឬ ភិក្ខុវិភង្គ ១ ភិក្ខុនីវិភង្គ ១ មហាវគ្គ ១ ចុល្លវគ្គ ១ បរិវារៈ ១ បើរាប់ទៅជាពួកក្រុមឬជាកងដែលកំណត់ដោយធម្មក្ខន្ធនោះមាន ២ ហ្មឺន ១ ពាន់ធម្មក្ខន្ធ ហៅថា វិនយបិដកៗនេះ មានចំនួន ១៣ សៀវភៅ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពចប់ផ្សាយចេញតាំងពីពុទ្ធ-សករាជ ២៤៧៩ គ. ស. ១៩៣៦ តាំងពីឆ្នាំនោះហូតមកដល់ឥឡូវនេះ បានសើរើបោះពុម្ពបន្ថែមតាំងពីភាគ ១ ភាគ ២ ជាលំដាប់មកទៀត ដើម្បីបំពេញសេចក្ដីត្រូវការរបស់លោក អ្នកពុទ្ធបរិស័ទកុំឲ្យខ្វះខាត ។

(មានត)

# សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់

លោក រ៉ាយ-ប៊ុក រៀបរៀង

(តមក)

ដោយហេតុនេះបានជាតាំងពីព.ស.៤.២០០ឆ្នាំមកហើយ ពួកលទ្ធិពុទ្ធសាសនាខាងថេរវាទគឺផ្នែកខាងត្បូង, មិនដែលមានការទទួលបំបួសភិក្ខុនីសោះឡើយ ។ បើតាមគម្ពីរ "ទីបវំស" ប្រវត្តិការណ៍ប្រទេសសីឡង់, គេមានឃើញភិក្ខុនីដែលបាននិមន្ត ទៅរួបរួមក្នុងពិធីបុណ្យដែលព្រះបាទអសោកបានធ្វើក្នុងព្រះពុទ្ធសាសនា តែខាងក្រោយមក, គេមិនដែលឮពោលអំពីភិក្ខុនីសង្ឃនេះសោះ; ព្រះភិក្ខុនីសង្ឃក៏លែងមានតាំងពីឆ្នាំនោះមក ។

បើដូច្នេះ, តើនឹងមានភិក្ខុនីសង្ឃពីណាមក? បើគ្មានភិក្ខុនីសង្ឃតើបានភិក្ខុនីណាធ្វើជាឧបជ្ឈាយ៍ កម្មវាចា គ្រូសូត្របាន ។ នេះហើយហេតុរឿងរ៉ាវផ្សេងៗ ដែលនាំឲ្យបាត់ភិក្ខុនីសង្ឃ ។

សួរ តើភិក្ខុនីដែលបួសក្នុងពេលដែលព្រះអង្គ គង់ធរមាននៅតើនាងណាខ្លះ? ឆ្លើយស្ដ្រីដែលបួសជាបឋមគឺ ព្រះនាងប្រជាបតិគោតមីជាម្ដាយមីង (ព្រះបិតុច្ឆា) របស់ព្រះអង្គ, ព្រះនាងយសោធរាជាមាតារាហុលកុមារ,

ជាព្រះអគ្គមហេសីរបស់ព្រះអង្គ, ស្ត្រីជាញាតិសាលោហិតរបស់ព្រះអង្គ ៗ

បើតាមគម្ពីរ "ថេរីគាថា" មានភិក្ខុនីមួយរូបឈ្មោះនាងខេមាជា អតីតអគ្គមហេសីព្រះបាទពិម្ពិសារនេះបានបួស ជាលំដាប់តមកជាមួយនឹង នាងវិមលា ដែលជាស្ត្រីផ្កាមាស, ឥឡូវ នាងកោរសក់, គ្រងចីពរស្បង់ លឿង, និមន្តទៅទ្រង់ បិណ្ឌបាត ៗ ក្រៅពីនេះនៅមានស្ត្រីនៃពួកសេដ្ឋី, គហបតី កដុម្ពិក បានលះបង់គ្រួសារ ទៅបួសជាច្រើនដែរ ៗ តែតាំង ពីព្រះបរមគ្រូទ្រង់ចូលកាន់បរិនិព្វាន ចំនួនព្រះភិក្ខុនីកាន់តែថយចុះតាម លំដាប់,រហូតដល់ព្រះពុទ្ធសាសនាយូរកាលបាន ១០០០ ឆ្នាំ ស្រាប់តែគ្មាន ស្ត្រីបួសសោះ ៗ កាលព្រះអង្គចូលបរិនិព្វានគេបានបន្ទោសព្រះអានន្ទត្រូវ ម្តេចក៏អនុញ្ញាតឲ្យស្ត្រី មកទួញសោកលើព្រះបរមសពព្រះអង្គដែលនាំឲ្យ មានមន្ទិលសៅហ្មង ៗ

សួរ· ដែលព្រះអង្គទ្រង់បញ្ញត្តតឹងរ៉ឹងចំពោះព្រះភិក្ខុនីដូច្នេះ តើព្រះ អង្គទ្រង់ស្អប់ពួកស្ត្រី ឬព្រះអង្គទ្រង់មានព្រះរាជបំណងចង់លើកតម្កើងភេទបុរស ឲ្យខ្ពស់ជាងភេទស្ត្រីឬព្រះអង្គទ្រង់ប្រមាថមើលងាយភេទស្ត្រី?

ឆ្លើយ· មិនមែនដូច្នោះទេ ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្រេចសម្មា-សម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន, ទ្រង់គ្មានកិលេស, តណ្ហា, អវិជ្ជា, ទ្រង់មិនអាចប្រព្រឹត្តបាបអកុសលទៅបាន ទ្រង់គ្មានបុណ្យ,

គ្មានបាប, ទ្រង់បរិសុទ្ធស្អាតទៅហើយ ៗ ម្យ៉ាងវិញទៀត, ព្រះអង្គទ្រង់បាន ធ្វើព្រះរាជសមាគមនឹងព្រះនាងយសោធរា ឬព្រះនាងពិម្ពា, ជាមាតារាហុលកុមារផងថែមទៀត ៗ ទ្រង់បានទទួលនិមន្តទៅឆាន់ នៅគេហដ្ឋាននាងអម្ពបាលីជាស្ត្រីផ្កាមាស, ស្ត្រីបុំជានាងនាដការបេះប្រៀងពីរោះថែមទៀត; អម្ពបាលីបានស្តាប់ព្រះអង្គទេសនាក៏បានកើតធម្មចក្ខុ សុំចូលជាឧបាសិកាក្នុងព្រះពុទ្ធសាសនា; លំដាប់តមក, នាងបានបួសជាភិក្ខុនី ហើយបានចម្រើនមេត្តាភាវនា ក៏បានសម្រេច អរហត្តផល ជាអរិយបុគ្គល ៗ ម្យ៉ាងទៀត, ដូចនាងធម្មទិន្នា ជាភរិយាវិសាខឧបាសក បានលះបង់គ្រួសារទៅបួសជាភិក្ខុនី ក៏បានសម្រេច អរហត្តផល ចំណែកឯនាងវិសាខាជាមហាឧបាសិកាក៏និមន្តព្រះអង្គព្រមទាំងព្រះភិក្ខុសង្ឃ ឆាន់មិនដែលដាច់ ៗ ឧទាហរណ៍ ខាងលើនេះសឲ្យឃើញថាព្រះអង្គទ្រង់មិនមែនប្រមាថមើលងាយភេទស្ត្រីសោះឡើយ ៗ

ក្រៅពីនេះនៅមានស្ត្រីជាច្រើនដែលបានបួសជាភិក្ខុនីចូលមកកាន់ព្រះពុទ្ធសាសនាឬចូលមកជាឧបាសិកាឬបួសជាសិក្ខមានាជាសីលវតី, ជាយាយជី ៗ

សួរៈ ស្ត្រីដែលកសាងក្រៅពីភិក្ខុនី តើមានប្រភេទប៉ុន្មានយ៉ាង ?

ឆ្លើយ ស្ត្រីដែលកសាងក្រៅពីកិច្ចនឹងស្ត្រីអាចនឹងមានចិត្តប្រាថ្នា:

១-ជាកន្សៀសារពេជ្ញ ;

២-ជាពុទ្ធមាតា ;

៣-ជាមហាឧបាសិកា ;

៤-ជាស្រីកែវស្តេចចក្រពត្រាធិរាជ ;

៥-ជាស្រីទេពអប្សរបរិកញ្ញា ;

៦ ជាអគ្គមហេសីព្រះមហាក្សត្រិយ៍,

៧-ជាភជជននី ;

៨-ជាព្រះអគ្គម្ចាស់ក្សត្រី

៩-ជានារីរត្ន ;

សួរ. តើព្រះសិទ្ធត្ថកុមារមានអគ្គមហេសីប៉ុន្មានរូប ? ។

ឆ្លើយ. ព្រះសិទ្ធត្ថកុមារមានអគ្គមហេសី ៣ រូបគឺ: ១ ព្រះនាងម្រគជា, ២ ព្រះនាងគោបិកា. ៣- ព្រះនាងយសោធរា ។ ព្រះនាងយសោធរាទ្រង់ជាអគ្គមហេសី, ឯព្រះនាងម្រគជា និង ព្រះនាងគោបិកាជាមហេសី ។

បើតាមគម្ពីរព្រះពុទ្ធសាសនាប្រទេសចិននាម "ប៉ូសេងចេ" ព្រះវិន័យនៃគណៈមូលាសិជាស្តិវាទិន, មាននិទានរៀងដូចខាងក្រោម :

(មានត)

# ផ្នែកអក្សរសាស្ត្រ

## រឿងអង្គុដ្ឋកុមារ

លោក លាង ហាប់-អាង សាស្ត្រាចារ្យ

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត រៀបរៀង

---

កាលណោះ មានអ្នកកាប់អុសប្តីប្រពន្ធ មានកូន ៧ នាក់ ។ កូនច្បងមានអាយុ ១០ ឆ្នាំ ។ ឯកូនពៅទើបនឹងបានអាយុ ៧ ឆ្នាំ ។

មាតាបិតា មានសេចក្តីក្រលំបាកជាអនេក, ហើយកូនទាំង ៧ នាក់ ដែលនៅក្នុងវ័យ កំពុងស្រេកឃ្លាន តែងទារចំណីជាប្រក្រតី ។ មាតាបិតា មានមនោសញ្ចេតនាសន្តោសកូនពៅជាងគេ ដោយកូនពៅនោះមានគំនិតស្លូតបូតហើយចេះអត់ធន់ ពុំមានយំស្រែកដល់បន្តិចបន្តួចឡើយ ។ កុមារនេះមានកាយតូចពេកណាស់ ។ កាលដែលទើបនឹងកើតភ្លាមមកនោះ មានទំហំប្រមាណប៉ុនមេដៃប៉ុណ្ណោះ ទើបគេសន្មតឲ្យឈ្មោះថា

អង្គុដ្ឋកុមារ ។

អន្ធកុមារដើរកំប៉ុងបរៈក្នុងផ្ទះជាងគេ ប៉ុន្តែពុំសូវគាប់ចិត្តដល់អ្នកទាំងអស់ឡើយ ។ កុមារនេះមានប្រាជ្ញាវៃឆ្លាតជាងបងៗទាំងអស់ ហើយមានសមត្ថភាពជាអ្នកពុំសូវមាត់ក ហើយជាអ្នកស្តាប់ការណ៍យ៉ាងមធ្យ័តៗ

ឆ្នាំមួយជាឆ្នាំអត់ឃ្លានដ៏ក្រៃលែង ប្តីប្រពន្ធបានពិគ្រោះគ្នាថា នឹងយកកូនទៅប្រោសចោល ។ នៅពេលល្ងាចមួយនោះ កូនទាំងអស់កំដេកលក់ស្កប់ស្កល់ ។ ប្តីប្រពន្ធនាំគ្នាទៅអង្គុយ នៅជិតគប់ភ្លើង ពិភាក្សាយ៉ាងអាណោចអធម៌ ។ ប្តីនិយាយថា “ ខណៈនេះយើងពុំអាចនឹងរកស៊ីចិញ្ចឹមកូនទាំងអស់ឲ្យរស់ជីវិតបានឡើយ យើងមុខជានឹងដាច់ពោះស្លាប់ជាពុំខាន គួរណាស់តែយើងនាំកូនទាំងអស់ យកទៅប្រោសចោលក្នុងព្រៃ នៅវេលាស្អែកនេះ ដោយយើងនាំវាឲ្យទៅជាមួយ ហើយក្នុងពេលដែលទុកវាឲ្យនៅបង់ទស យើងនឹងនាំគ្នារត់ចោលមកវិញ ” ។ ញ័ររន្ធត់នាងតវ៉ាតបថា “ ឱ អ្នកអើយ! អ្នកអាចកាត់សេចក្តីមេត្តាបានដែរឬ? ” ។ ប្តីបាននិយាយអង្វរករយ៉ាងច្រើនដង ។ ពិតមែនតែនាងឃើញថាទាល់ក្រលំបាកហើយ ប៉ុន្តែ ឋានៈនាងជាម្តាយ ពុំអាចដាច់ចិត្តយកកូនទៅប្រោសចោលឡើយ ។

តមក នាងបានរិះគិតអំពីសេចក្តីអត់ឃ្លាន ដែលបានសង្កត់សង្កិនជាមុន នាងឃើញពិតថា នឹងរកចិញ្ចឹមកូនពុំបានឡើយ ទើបនាងដាច់ចិត្ត

ធ្វើតាមប្តី នាងក៏ទៅដេកបារម្ភទ្រហោយំអាសូរកូនទៅតូចៗរញ៉ន់ ។

ចៅអង្គុដ្ឋកុមារ បានឮពាក្យចរចារបស់បិតាមាតាទាំងអស់ ដោយកុមារលបចុះពីលើគ្រែខ្លួន ទៅពួនស្តាប់នៅកៀនស្បែកជើងឪពុក ដោយពុំបានធ្វើឲ្យអ្នកណាឃើញសោះ ៗ កុមារត្រឡប់មកកន្លែងវិញ ដោយរិះគិតរកឧបាយអស់មួយរាត្រីជុំ ៗ កុមារក្រោកពីងងឹតហើយលបរត់ទៅមាត់ស្ទឹងរើសដុំក្រួសតូចៗ ដាក់ពេញតែថង់ដម្រង់មកផ្ទះវិញ ។

ព្រឹកព្រានព្រះសុរិយា ឪពុកម្តាយនាំកូនចេញទៅប្រោសចោល ។ អង្គុដ្ឋកុមារ ដឹងកិច្ចទាំងអស់ ប៉ុន្តែ ពុំមានប្រាប់ឲ្យបងៗដឹងឡើយ ។ អ្នកទាំងអស់គ្នាចូលទៅក្នុងព្រៃញឹកមួយយ៉ាងធំ ។ បុរសឪពុកតាំងធ្វើជាកាប់ឧសយ៉ាងញាប់ដៃ ហើយចាត់ឲ្យកូនតូចៗ ប្រមូលឧសចងជាបាច់ៗ ។ មាតាបិតាឃើញកូនកំពុងងោកងក់ ក្តៅស្មារតីនឹងចងឧស ក៏លបរត់ចេញយ៉ាងរហ័ស បត់តាមផ្លូវវៀងរត់បាត់ទៅ ។

លុះកុមារទាំងអស់ឃើញបាត់ឪពុកម្តាយ ក៏នាំគ្នាស្រែកយំយ៉ាងទ្រហឹងអឺងកងពេញព្រៃ ។ កុមារអង្គុយនៅស្ងៀម ដោយខ្លួនស្គាល់ផ្លូវច្បាស់នឹងត្រឡប់ទៅវិញ ពីព្រោះកាលដែលមកនោះ កុមារបានលួចទំលាក់ក្រួសបំ-ណាំចប់រហូតមក ។ កុមារឆ្លើយទៅបងៗថា " សូមបងទាំងអស់កុំភ័យ ឪពុកអ្នកម៉ែទុកយើងទៅទីនេះ ប៉ុន្តែ មកតាមខ្ញុំៗ នឹងនាំឲ្យដល់ផ្ទះវិញ" ។

កុមារនាំបង ៗ ដើរតាមផ្លូវដើមរហូតទាល់តែដល់មកផ្ទះវិញ ៗ ដល់ហើយ កុមារទាំងអស់ពុំហ៊ានចូលទៅក្នុងផ្ទះឡើយ ហើយនាំគ្នាឈរតំរៀបនៅមាត់ទ្វារ ដើម្បីចាំស្តាប់ការពិភាក្សារបស់ម្តាយឪពុក ៗ

ក្នុងពេលបុរសប្តីប្រពន្ធត្រឡប់មកដល់ផ្ទះវិញនោះ លោកសេដ្ឋីបានបើកប្រាក់ខែឲ្យ ១០ រៀល ព្រោះលោកទើបនឹងនឹកឃើញ ៗ បុរសប្តីអរណាស់ដោយបានសោហ៊ុយ នឹងទិញអាហារចំអែតពោះ ៗ ប្តីក៏ប្រើភរិយាឲ្យទៅកន្លែងសម្លាប់សត្វ ៗ ដោយពុំដែលបានស្គាល់ជាតិស៊ីសាច់ម្តងសោះជាអង្វែងមក នាងភរិយាក៏ទិញសាច់មួយដុំធំល្មមខ្លួនទាំងពីរអាស្រ័យបានបីដង ៗ ក្នុងពេលដែលអ្នកទាំងពីរ ប្រជុំគ្នាបរិភោគ នាងភរិយានឹករំពៃព្រួយទៅកូន ហើយនិយាយថា " ឱ អនិច្ចា កូនយើងឃ្លាតទៅណាអស់ហើយ បានជាពេលនេះនៅតែយើងពីរនាក់យ៉ាងនេះ ! អ្នកប្រុសថ្លៃអើយ អ្នកនេះហើយដែលកាត់អាល័យ យកកូនទៅបំបរបង់នោះ! ឱកូនមាសម្តាយទាំងអស់អើយ តើអ្នកខ្លាចផ្សាក្នុងព្រៃយ៉ាងណាទៅ ឱព្រះម្ចាស់ថ្លៃអើយ ឬមួយចចកខ្លាប្រហារជីវិត ជាចំណីអស់ទៅហើយ អ្នកប្រុសអើយ អ្នកគ្មានមេត្តាសោះ ៗ

បុរសប្តី លុះឮពាក្យសម្រែងរបស់ភរិយា ក៏នឹកខ្លាចចិត្តមួយរំពេចមុខជោគទៅដោយទឹកភ្នែក ៗ ប៉ុន្តែ ដោយភរិយានិយាយបន្ទោសច្រំ

ដែលញយ ៗ បុរសប្តីអត់ទឹងពុំបាន ក៏គំហកឲ្យឈប់មាត់ ។

នាងភរិយារឹងរឹតតែខ្លោចផ្សា និយាយទាំងយំសស្រាក់ឡើងទៀតថា " ឱព្រះម្ចាស់ថ្លៃអើយ តើកូនខ្ញុំទៅណាអស់ទៅ! ឱកូនបណ្តូលជីវិតម្តាយអើយ កូនទៅទីណាម្តេចក៏ពុំឮមាត់ ។ កុមារទាំងអស់ដែលនៅឈរតំរៀបគ្នាមាត់ទ្វារ លុះឮពាក្យម្តាយសំបូងសង្រ្រេងហៅដូច្នោះ ក៏នាំគ្នាស្រែកយំឆ្លើយស្របឡើងថា " អ្នកម៉ែអើយ យើងខ្ញុំនៅទីនេះ កូននៅឯណេះ ! " ។ នាង មាតាអរណាស់ ស្ទុះចេញទៅបើកទ្វារទទួលកូនហើយលោតទៅបីត្រកងកូនថើបគ្រប់ ៗ គ្នា និយាយថា " ឱគុណព្រះម្ចាស់ថ្លៃខ្ញុំអើយ វាសនាខ្ញុំខ្ពស់ណាស់បានឃើញមុខកូនវិញយ៉ាងនេះ! ឱកូនស្ងួនពន្លកម្តាយ ឯងឃ្លានណាស់ហើយឬ ! នែ ជេដ្ឋាមាសម្តាយ ! ម្តាយខ្លោចផ្សានឹងឯងណាស់ " ។ ជេដ្ឋានេះជាឈ្មោះបុត្រច្បងដែលនាងស្រឡាញ់ស្មើជីវិត ជាងបុត្រទាំងអស់ ។

គ្រួទាំងមូលប្រជុំគ្នាបរិភោគអាហារនៅជុំវិញតុ ។ បុត្រម្នាក់ ៗ ក៏តាំងរ៉ាយរៀងប្រាប់ឪពុកម្តាយ អំពីដំណើរ នៃសេចក្តីរន្ធត់ ដែលបន្ទាបឡើងនៅក្នុងព្រៃ ។ ឪពុកម្តាយមានសេចក្តីកក្រយពន់ប្រមាណនឹងបុត្រសឹងលេបបាយពុំចូល ។

មិនយូរប៉ុន្មាន សោហ៊ុយនោះក៏អស់សូន្យទៅ ។ បុរសប្តីប្រពន្ធ

ក៏ផ្លាក់ខ្លួនទៅក្នុងសេចក្តីអត់ឃ្លានជាថ្មី ៗ យ៉ាងនេះហើយបុរសក្តីក៏គិតសន្មត់ថា យកបុត្រប្រុសទៅចោលម្តងទៀត ឲ្យឆ្ងាយជាងមុន ពីព្រោះជៀសវាងកុំឲ្យការស្រេកឃ្លានមកគ្របសង្កត់ផ្តួលដល់ខ្លួនទាន់ ៗ

អ្នកទាំងពីរពុំអាចពិគ្រោះគ្នាឲ្យជិតស្ងាត់ ពីគ្រោះបៀកទៅអង្គុដ្ឋកុមារបាន ៗ កុមារបានដឹងហើយក៏ប្រុងប្រៀបថា នឹងប្រើឧបាយដូចមុនទៀត ៗ លុះដល់ព្រលឹមឡើង កុមារបំរុងនឹងលបចេញទៅរើសក្រួសទៀត ប៉ុន្តែទ្វារផ្ទះចាក់សោដល់ទៅពីរជាន់យ៉ាងជាប់ ៗ កុមារទាល់គំនិត ៗ ក៏ច្បាស់កាលណា មាតាបានយកនំបុ័ងមកលៃកាត់ជា៧ ចំណែកចែកកូនគ្រប់គ្នា ៗ អង្គុដ្ឋកុមារ បានឱកាសនឹកឃើញថា នឹងយកនំបុ័ងចំណែកតាមផ្លូវចំណាំ ជំនួសដុំក្រួសជាការប្រសើរដែរ ៗ គិតដូច្នោះភ្លាម កុមារទទួលចំណែកនំបុ័ងពីម្តាយ ដាក់នៅក្នុងហោប៉ៅភ្លាម ៗ

ដល់ពេលកាលណា បុរសក្តីនឹងប្រពន្ធក៏នាំកូនចេញទៅ ។ ម្តងនេះ បុរសក្តីនាំចូលទៅក្នុងព្រៃជ្រៅក្រាស់ឃ្មឹក ហើយងងឹតសូន្យ ៗ ប្រុសនាំកូនយកទៅចោលឆ្ងាយ ល្មមតែនឹងវិលមកវិញពុំរួច ហើយក៏បន្ទន់រត់ចោលមកផ្ទះវិញ ៗ អង្គុដ្ឋកុមារគ្មានរន្ធត់សោះ ដោយគិតថា នឹងនាំបង ៗ ត្រឡប់តាមផ្លូវដែលខ្លួនធ្វើចំណាំមកវិញបានដូចប្រាថ្នា ៗ ប៉ុន្តែដល់ពេលមកក្រោយ កុមារក៏គាំងគាំងស្មារតី ដោយពុំបានប្រទះនឹងកំទេចនំ

ប៉ុនឹងដល់មួយចំណិតទេហើយ ពីព្រោះសត្វរើសស៊ីអស់ទៅ ៗ ម្តងនេះ មុខដាវផ្លែនពិតប្រាកដ ៗ កុមារខំនាំប្អូនកាត់ព្រៃចូលរាលរកផ្លូវចេញ ៗ ប្រឹងគ្រាំណាស់ ចំងាយផ្លូវកាន់តែស្រឡូមឆ្ងាយដាច់សង្វែងទៅ ៗ ៗ កុមារទាំងអស់វង្វេងនាំបងប្អូន ដើរផ្តុំគ្នាទៅតាមព្រៃ ៗ

ព្រះសុរិយាទន់ទាបហៀបនឹងលិចបាត់ទៅដើមព្រៃ ៗ រស្មីទន់ខ្សោយបន្តិចម្តង ៗ ៗ កុមារខ្លាចផ្សាស្រែកយំរកម៉ែយ៉ាងខ្លាំង ៗ ព្រៃទាំងមូល ក៏លេតពន្លឺសូន្យឈឹងមួយរំពេច ៗ កុមារទាំងអស់ធ្លាក់ខ្លួនទៅក្នុងសេចក្តីបារម្ភឥតឧបមា ៗ ក៏យំទៀត ៗ កុមារឮស័ព្ទសម្រែកបបកក្នុងព្រៃលួយ៉ាងខ្លាំងអឺងកាប់ នៅជុំវិញខ្លួន ៗ កុមារតាំងផ្តុំប្រជុំគ្នា ពុំហ៊ានមាត់កទឹងផាកកញ្ជលផង ៗ តមក សន្ធឹកស្លឹកបណ្តើរឈើទ្រឹសម្ងំរឹប ១ យ៉ាងញ័រកុមារងឹងខ្លាចមហិមា ៗ ផ្គរខ្ទរខ្ទះឡើងផ្ទងផាំងនៅឯនាយ ៗ ផ្លេកបន្ទោរក្លែត ១ តែប្រផេះនៅលើមេឃ ធ្វើឲ្យកុមារលែងបើកភ្នែក ៗ មួយរំពេចគ្រាប់ភ្លៀងធ្លាក់បង្អោរយ៉ាងគ្រាក់មួយមេធំ ៗ កុមាររងារញ័រប្រទុបគ្នាយ៉ាងស្អិត ៗ ទ្រាំពុំបានកុមារនាំគ្នាកើលរកកន្លែងជ្រក ៗ មិនបានប៉ុន្មានម៉ែត្រផង កុមារទាំងអស់ធ្លាក់ទៅក្នុងកក់យ៉ាងស្អិត ហើយខំប្រវាឡើងវិញខ្លួនប្រឡាក់ស្រម៉ក ៗ

សេចក្តីគាបានបំភក្នុងកាយអន្ធកុមារ ជាអ្នកមានស្មារតី តាំងប្រវា

ឡើងដើមឈើមួយខ្ពស់ស្រឡឹម ៗ នៅលើចុង កុមារក៏ពៃមើលគ្រប់ទិស ។ មួយរំពេច កុមារឃើញពន្លឺភ្លើងប្រទីបលឹម ៗ នៅឯនាយព្រៃ ។ កុមារសំរូតចុះមកវិញ ។ ដល់មកដី កុមារចាក់ភ្នែកពុំយល់ឡើយ ។ ប៉ុន្តែម្ដងនេះ កុមារលែងខ្លាចហើយ ។ កុមារពីរ ត្រាះទៅបង ៗ ត្រូវពាក្យ ក៏កាន់ដៃគ្នាទាំង ៧ យ៉ាងជាប់ ដើរតម្រង់សំរៀមទៅទិស ដែលខ្លួនឃើញពន្លឺប្រទីបនោះ ។ បន្តិចមក កុមារទាំងអស់ក៏ចេញផុតពីក្នុងព្រៃ ។

តមកទៀត កុមារទាំងអស់បានទៅដល់ផ្ទះ ដែលមានផុតប្រទីបនោះ ។ កុមារគោះទៅមាត់ទ្វារកំផែង ។ ស្ត្រីចំណាស់សម្បុរសម្នាក់ ចេញមកបើកទ្វារទទួលកុមារក្មេង ៗ ស្ត្រីនោះបានសាកសួរកុមារទាំងអស់ថា មានការអ្វី ។ អន្គុដ្ឋឆ្លើយតបថា ពួកខ្លួនជាកូនកំព្រារង្វេងម្ដាយឪពុក នៅក្នុងព្រៃ ហើយដែលមកនេះ ដើម្បីសូមផ្ទះសំណាក់មួយរាត្រី ។ ឃើញកុមារទាំងនេះ មានរូបឆោមល្អ នាងស្ត្រីនិយាយទាំងយំសស្រាក់ថា ឱ កូនតូច ៗ ទាំងអស់អើយ អ្នកមកពីណា អ្នកពុំដឹងកន្លែងនេះ ជាអាស្រមយក្ស ដែលតែងបរិភោគកូនក្មេងទេឬ ? ។ ក័យញ័រដាងបងទាំងអស់ អន្គុដ្ឋកុមារឆ្លើយតបថា " ឱ អ្នកមីងជំមានធម៌សប្បុរសអើយ បើយ៉ាងហ្នឹងឲ្យខ្ញុំត្រឡប់ទៅណាវិញ ? ព្រៃនេះមានសុទ្ធសឹងតែសត្វសាហាវ វានឹងមិនបង្អង់នឹងផ្ដាច់សិរសាយើងខ្ញុំបរិភោគឡើយ ! ហេតុនេះខ្ញុំជឿជាក់ថា លោកយក្ស

គង់នឹងមានមេត្តា ដល់យើងខ្ញុំកំសត់នេះជាពុំខាន សូមអ្នកម៉ីងជួយអង្វរលោកជំនួសយើងខ្ញុំ ដោយករុណាផង ។

នាងករិយាយក្សមានចិត្តទន់ខ្លោចផ្សា ក៏ទទួលជួយយកអាសាកុមារ ដោយនាងគិតស្មានថា នឹងលាក់បានពីគណ្តាប់ដៃប្តី រហូតដល់ក្តី ។ នាងក៏នាំកុមារទាំង ៧ នាក់ចូលទៅក្នុងផ្ទះ ហើយយកទៅឲ្យអាំងភ្លើងនៅជើងក្រាន ដែលមានមេចៀមមួយយ៉ាងសស្គុះ ផ្អើរនៅលើចង្អើរទុកសំរាប់ជាអាហារយក្ស ។

កំពុងតែអាំងភ្លើង កុមារទាំងអស់ឮសន្ធឹកខ្ទរញ័រប្រែបពីនឹងសំរែកយ៉ាងខ្លាំងនៅក្រៅកំផែង កុមារដឹងជាក់ជាយក្សត្រឡប់មកដល់ហើយ ។ មួយរំពេច នាងស្រីឲ្យកុមារទាំងអស់លូនចូលទៅក្រោមគ្រែ ហើយនាងដើរចេញទៅបើកទ្វារឲ្យស្វាមី ។

ចូលមកដល់, យក្សក៏ប្រើករិយាឲ្យរៀបអាហារនឹងស្រាឲ្យបរិភោគ ។ ចៀមផ្អើរនៅនៅស្រស់នៅឡើយ ប៉ុន្តែ ជាការប្រសើរចំពោះអាហារយក្ស ។ យក្សក៏ណាចប្រឹងស្រូបក្លិនផាកជុំវិញខ្លួន ដោយបានធុំក្លិនសាច់ស្រស់ ។ ករិយាដឹងកិច្ច ក៏និយាយទៅថា "ក្រែងឯងធុំក្លិនគោដែលខ្ញុំទើបនឹងពន្លះស្បែកអម្បាញ់មិញទេឬ? ។ យក្សក៏ហ៊ោកសំឡក់ទៅករិយាថា "អញធុំក្លិនសាច់ស្រស់ជាចម្លែក ក្នុងទីនេះប្រហែលជាមានសត្វអ្វីថ្មីទៀតហើយ" ។ គ្រាន់តែថាប៉ុណ្ណោះភ្លាម យក្សក្រោក

ចេញពីគុក ហើយដើរតម្រង់ទៅកន្លែងគ្រែ ដែលដាក់កុមារ ។ យក្សឱន មើលទៅក្រោមគ្រែភ្ញាក់ស្រែកឡើងថា "យ៉ោម៉ែចោរកំភរនេះ បញ្ឆោតអញ ឃើះ ចាប់ឲ្យអញទំពាក្បាលវាឥឡូវ ឃើញទោសតូចមួយគំនរ អញនឹង អញ្ជើញសម្លាញ់អញបានពីរបីនាក់ មកជប់លៀងក្នុងពេលខាងមុខនេះ ។

យក្សតាំងចាប់ទាញកុមារម្ដងមួយម្ដង ៗ ចេញពីក្រោមគ្រែ ។ កុមារភ័យឥតឧបមា ក៏នាំគ្នាលុតជង្គង់សំពះយក្ស ។ យក្សក៏ណាបមិនមានមេត្តា បែរជាបើកភ្នែកសាហាវធំ ៗ ស្រែកសន្ធាប់ថា "ប្រពៃណាស់ អញនឹងប្រហារវាសួរឲ្យហូរឈាមឥឡូវនេះ !" ៗ ថាហើយយក្សតាំងចូលទៅទាញយកកាំបិតធំមួយ ហើយសំដៅទៅដកកុមារទាំងអស់ ៗ យក្សតាំងសំលៀងកាំបិតនឹងថ្មមួយដុំគាន់នៅដៃឆ្វេង ៗ ហើយក៏ចាប់កុមារម្នាក់ក្ដាប់ជាប់ក្នុងដៃ ៗ ប៉ុន្តែភរិយាស្រែកឃាត់ទៅថា "នែអ្នក ឯងប្រញាប់ប្រហារអី ចាំថ្ងៃស្អែកមិនបានឬ ? យក្សសន្ធាប់ឡើងថា "កុំចេះ អញត្រូវតែប្រហារឥឡូវនេះ ។ នាងភរិយាអង្វរថា "បុះសាច់ឯណេះខ្វះអីទៅ គរគោក នៅគោមួយ ចៀមពីរ នឹងជ្រូកមួយចំហៀងធំ " ៗ យក្សសើចឆ្លើយតាមសម្រួលថា "អេ៎ឯងនិយាយត្រូវ បើដូច្នោះជាកម្មឲ្យវាស៊ីផឹកទៅដើម្បីកុំឲ្យភក់សាច់ រួចហើយនាំវាយកទៅឲ្យដេកឲ្យស្រួលបួល !" ៗ នាងភរិយាមានអំណរដ៏ក្រៃលែង ហើយក៏តាំងរៀបអាហារឲ្យកុមារបរិភោគ

យ៉ាងច្រើន ៗ ប៉ុន្តែ កុមារទាំងអស់បែរជាបរិភោគពុំចូល ដោយគិតភ័យផ្អក ៗ ក្នុងពោះពុំមានស្រាន្ត ៗ ចំណែកយក្សកំណាចចំប្រើនផឹកស្រាដោយមានអំណរនឹងសត្វបម្លែកនោះ ៗ មិនគិតតួបយក្សផឹកជាប់ម្តៃករច្រើនជាងធម្មតា ៗ ស្រវឹងទន់ដៃជើងយក្សក៏ដើរក្រេតក្រោតទៅដេក ៗ

យក្សកំណាចនេះមានបុត្រី ៧ នាក់ នៅវ័យកុមារទាំងអស់ ៗ កុមារីទាំងនេះមានសម្បុរល្អឆើតឆាយ ដោយអាស្រ័យតែសាច់ស្រស់ដូចឪពុក ៗ ប៉ុន្តែនាងមានភ្នែកតូច ហើយមានពណ៌ខៀវមូលក្រ ប្រមុះកោងក្រញ៉ុក មាត់ធំបែងង មានធ្មេញធំ ៗ វែងស្រួចរលាំ ដោយដុះឃ្លាតពីគ្នាយ៉ាងរង្វើល ៗ កុមារីទាំងនេះ នៅពុំទាន់សាហាវនៅឡើយទេ ។ ប៉ុន្តែ ធ្លាប់ចាប់កូនក្មេងទាំងផ្សាក់ហុតឈាមខ្លះមកហើយ ៗ មាតាតែងនាំបុត្រីទាំងនេះយកទៅផ្តេកពីព្រលប់នៅលើគ្រែមួយ ដំរៀបគ្នាទាំង ៧ នាក់ ហើយមានទាំងបំពាក់មួដនៅលើក្បាលមួយ ៗ ម្នាក់ជាចំណាំ ៗ

នៅក្នុងបន្ទប់កូនស្រីយក្ស មានគ្រែមួយទៀតដាក់ទន្ទឹមគ្នា ៗ គឺក្នុងគ្រែនេះហើយដែលនាងករិយាយក្ស យកកុមារកំសត់ទាំងប្រាំពីរឲ្យទៅដេក បន្ទាប់មក នាងករិយាក៏ចូលទៅដេកក្នុងដំណេកនឹងយក្សប្តីទៅ ៗ

អង្គុដកុមារ ដឹងជាក់ជាបុត្រីយក្សមានមួដមួយ ៗ ម្នាក់ ពាក់នៅលើក្បាលជាចំណាំ ៗ កុមារតាំងក្រោកឡើងលបដើរតិច ៗ ទៅដោះមួក

ពីក្បាលបង ៗ ទាំងអស់ព្រមទាំងមួកខ្លួន ហើយទៅលបដកម្កុដពីបុត្រីយក្ស បំពាក់មួកឲ្យទៅវិញ ៗ កុមារយកម្កុដមកបំពាក់បង ៗ ព្រមទាំងខ្លួន ហើយក៏ដេកទៅ ៗ ធ្វើយ៉ាងនេះកុមារលៃបំភាន់យក្ស បារម្ភក្រែងវាមកវាចាប់ទាំងយប់ នឹងបានប្រទូំនាំយកកូនវាទៅប្រហារ ហើយក្រែងខ្លួននឹងបានរួបទុក្ខជាពុំខាន ។ កិច្ចនោះបានសម្រេចដូចប្រាថ្នា ៗ

ប្រមាណជាពាក់កណ្ដាលអធ្រាត្រ យក្សស្មានស្រាបន្តិចក៏ក្រោកឡើង ៗ សេចក្ដីសាហាវអន្ទះអន្ទែងរបស់យក្សផ្ទុះឆេះពីដួងចិត្តាភាម ៗ យក្សមិនបង់ចាំព្រឹក នឹងប្រហារកុមារទាំងនោះសោះ ៗ ទើបយក្សស្ទុះក្រោកចេញពីគ្រែទៅចាប់យកកាំបិតមួយយ៉ាងធំ ហើយនិយាយថា “អើ អញទៅលែងអាកូនសត្វទាំងនេះ ឲ្យវាដឹងដៃម្ដង!” ៗ យក្សចាំគ្រែជាក់ក៏ចូលទៅបន្ទប់កូនស្រី ដើម្បីចាប់កុមារយកមកប្រហារទាំងយប់ ៗ យក្សតម្រង់ទៅគ្រែនោះហើយលូកដៃស្ទាបៗក្បាលគ្រប់ៗ គ្នាឃើញមានម្កុដទាំងអស់ៗ យក្សក្ដាត់មាត់ថា “យីអញផឹកច្រើននាំវង្វេងអស់ !” ៗ ថាដូច្នោះហើយ យក្សដើរទៅគ្រែកូនស្រីវិញ ៗ យក្សលូកដៃស្ទាប ៗ ក្បាល ៗ មួយរំពេច យក្សនិយាយថា “នែ អាកូនសត្វនៅឯណេះសោះ!” ៗ និយាយបណ្ដើរ យក្សកាំងស្ទាបក្បាលកាត់កកូនស្រីឯងបណ្ដើរទាល់តែអស់ យក្សសប្បាយពន់ពេកញាក់មុខញាក់មាត់ចំលាក់កាំបិត ដើរទៅដេកទីងប្រពន្ធទៀត ៗ

បន្តិចមក អគ្គីដ្ឋកុមារដែលពុំមានភ្លេចបន្តិចសោះ ក៏បានឮមាត់យក្សស្រមុកឃូៗ ៗ កុមារតាំងដាស់បង ៗ ឲ្យក្រោកស្ងាត់ស្ងៀមភ្លាម ហើយខ្សឹប ៗ ឲ្យលបចេញតាមខ្លួនមក ៗ កុមារទាំងអស់ព្រមព្រៀងលួចចុះតិច ៗ កាត់តាមសួនច្បារ ហើយនាំគ្នាឡើងតាមកំផែងលោតផ្លោះទៅក្រៅទាំងអស់គ្នាបានដូចប្រាថ្នា ៗ កុមារតាំងនាំគ្នារត់ត្របាញ់ជើង ក្នុងពេលពាក់កណ្ដាលអធ្រាត្រ ដោយនឹកខ្លាចពុំដឹងជាទៅទិសណាជាទិសណា ៗ

ទៀតក្ដី យក្សក្រោកឡើងនិយាយកាន់ទៅភរិយាថា " ចូរឯងក្រោកឡើងយកសម្លៀកបំពាក់ទៅពាក់ឲ្យអាកូនសត្វទៅ " ៗ នាងភរិយាបានឮពាក្យបង្គាប់របស់ស្វាមីយ៉ាងនេះ ក៏សែនធ្ងល់ជាអនេកដោយស្មានថាយក្សមានមេត្តាមកវិញ ៗ នាងក៏ដើរចូលទៅក្នុងបន្ទប់ទុកកុមារនោះ ៗ គ្រាន់តែដល់ភ្លាម នាងភ្ញាក់ខ្លួនព្រើតបាត់ស្មារតី ដោយបានឃើញបុត្រីទាំង ៧ នាក់ ដាច់កដេកនៅក្នុងឈាមជាំក្រាស់ឃ្មឹក ៗ

បាត់យូរពេក យក្សស្មានថា ភរិយាពុំធ្វើតាមបង្គាប់ ក៏ចូលទៅតាមបំរុងនឹងជួយធ្វើភរិយា ៗ គ្រាន់តែដល់ភ្លាម យក្សបាត់ស្មារតីនឹងហេតុដ៏សាហាវនោះ ក៏ស្រែកទ្រហោថា " យើ អស្ចារ្យណាស់ហ្ន៎! អាកូនសត្វនេះវាសងសឹកអញពេញទី " ៗ

យក្សក្រោធសឹងធ្លាក់ឈាមពីមាត់ ទើបស្រែកឲ្យភរិយាយកស្បែក

ដើនទី ៣៧ យោជន៍មកឲ្យខ្លួន ដើម្បីពាក់ទៅតាមចាប់កុមារ យកមក ប្រហារវិញ ៗ ពាក់ស្រេច យក្សតាំងហោះទៅតាម ៗ មួយសន្ទុះយក្សក៏ ដល់ទៅផ្លូវដែលកុមារនាំគ្នារត់ ៗ

រីឯកុមារ ក្នុងមួយយប់នោះ ដោយវាសនាល្អក៏បានទៅដល់ ជិត ខ្ទមមាតាបិតានៅតែមួយរយម៉ែត្រប៉ុណ្ណោះ ៗ កុមារងាកមកក្រោយឃើញ យក្សនៅ ស្រឡូមខ្ពស់ស្ពង់ហោះលយល្បឿនផុតធ្នង់ភ្នំមួយទៅភ្នំមួយ ធ្នង់ ស៊ីនធំទូលាយ ដូចជាធ្នង់កូនថ្មកគួបឥតទេបមា ៗ កុមារនាំគ្នាបេះតែរត់ ៗ អគ្គិដ្ឋកុមារមានស្មារតី ងាកទៅដើនថ្មល់ឃើញមានផែនថ្មមួយផ្ទាំងធំមាន ប្រហោងយ៉ាងស្រួលទីងពួនលាក់កាត្មាតាំងអស់បាន ៗ មួយរំពេច កុមារ ឲ្យបងៗត្បូលចូលទៅពួននៅក្នុងប្រហោងថ្មនោះ ៗ យក្សក៏កាន់តែមក ជិតដល់ ដោយពុំបានឃើញហ្វូងកុមារសោះ ៗ

មិនបានតាំងមួយនាទីផង យក្សមកដល់ទីនោះ ៗ អស់កំលាំងជា អនេកព្រាមតាំងនៅស្រវាំងបង្គួចៗផង យក្សក៏សន្ទុតឈប់សំកនៅលើផែន ថ្មនោះ ៗ យក្សតាំងសំងំឲ្យមានកំឡាំងនឹងហោះតាមទៅទៀត ៗ

ដោយខ្យល់ត្រជាក់ៗយក្សក៏ដេកលក់ស្រមុកគ្រូកៗ ខ្ទរអស់ផែនដី ៗ កុមារដែលនៅក្នុងរូងថ្មក៏យញ្ញើរអស់សពាក្យ ៗ អគ្គិដ្ឋកុមារគ្មានញញាប់ ញញើរអ៊ីសោះ ហើយបង្គាប់ទៅបងៗឲ្យចេញរត់សំដៅទៅផ្ទះ ដែលខ្លួន ចំណាំច្បាស់នៅត្រើយនោះ ៗ បងក៏ធ្វើតាមបង្គាប់ប្អូន ៗ

លុះឃើញបងៗដល់ផ្ទះអស់ហើយ អគ្គុដ្ឋកុមារក៏តាំងលបទៅជិតយក្ស ដែលកំពុងដេកលក់មិនដឹងខ្លួន លួចទាញដោះស្បែកជើងយក្សតិច ៗ ។ ស្បែកជើងនោះធំហើយវែងរលាំឥតគណនា ។ ប៉ុន្តែដោយជារបស់ទិព្វ កុមារស៊កជើងពាក់ទៅត្រូវល្មមគ្មានខ្ចោះ ។

សំរេចដូចបំណង កុមារតាំងបោះសំដៅទៅលំនៅយក្សវិញ ។ ដល់ហើយកុមារឃើញភរិយាកំពុងបោកខ្លួន យំដូចអកកឹកទោបកូនស្រី ។ កុមារស្រដីទៅថា "ហៃអ្នកម៉ែង ប្ដីអ្នកម៉ែងមានគ្រោះថ្នាក់ធំណាស់ ឥឡូវនេះ ត្រូវពួកចោរប្លន់ព្រួតគ្នាចាប់បានហើយ វាបានសន្យាថានឹងប្រហារជីវិតបង់ បើប្ដីអ្នកម៉ែងគ្មានមាសនឹងប្រាក់ពេជ្រយកទៅលោះវា ក្នុងពេលដែលវាហៀបនឹងកាត់កនឹងដាវដ៏សុស្លាប ស្រាប់តែពួកយក្ស ក្រឡេកមកឃើញខ្ញុំ ហើយក៏ហៅខ្ញុំឲ្យចូលមកជិតនិយាយអង្វរថា ឲ្យខ្ញុំពាក់ស្បែកជើងនេះរត់មកផ្ទះប្រាប់អ្នកម៉ែង ឲ្យយកមាសពេជ្រដ៏មានថ្លៃទាំងអស់ហើយឲ្យប្រគល់ដល់ខ្ញុំយកទៅឲ្យចោរនោះឆាប់ៗទាន់វេលា !" ។ ភរិយាយក្សស្លុតស្មារតី ក៏ម្នីម្នាទៅប្រមូលមាសប្រាក់ពេជ្រដ៏មានថ្លៃ យកមក ប្រគល់ឲ្យចៅអគ្គុដ្ឋ-កុមារនាំយកទៅលោះស្វាមី ។ បានទទួលរបស់របរដ៏មានថ្លៃទាំងអស់ស្រេច កុមារដ៏មានឫទ្ធិតាំងប្រឹកទៅក្នុងស្បែកជើងណែនហើយបោះពួយរឹងសំដៅមកលំនៅឪពុកម្ដាយដើម ។ មិនយូរប៉ុន្មាន កុមារក៏មកដល់ផ្ទះជួបជុំបងប្អូនម្ដាយឪពុកយ៉ាងសប្បាយ ។

បំណែកឯយក្សលុះភ្ញាក់ឡើងបាត់ស្បែកជើងក៏ខឹងទោមេញ ឯណា ខឹងអាល័យបុត្រ ឯណាខឹងខ្លួសករិយាវិញ ៗ ទើបហួសប្រមាណយក្ស ទាំងមាត់បែកក្បាលស្លាប់ខ្លួនទីងប្រកន្ទខណៈនោះទៅ ៗ

ក្រោយមក បានឮដំណឹងសុះសាយទៅពេញទាំងនគរ ៗ ថ្ងៃមួយ អគ្គិផ្លកុមារក៏ពាក់ស្បែកជើងទិព្វចូលទៅគាល់ព្រះរាជា ដើម្បីស្នើការ សូមខ្លួនទៅពិនិត្យការណ៍ចម្បាំងកងទ័ព ដែលកំពុងបយុទ្ធចម្ងាយពីរ យោជន៍ពីនគរ ៗ ព្រះរាជាព្រមអនុញ្ញាតឲ្យកុមារទៅតាមមើលការណ៍ ដើម្បីវិលមកទូលព្រះអង្គវិញ ឲ្យទាន់ព្រះរាជហឫទ័យ ៗ កុមារដ៏មានឫទ្ធិ ក៏បានហោះទៅសមរភូមិ ។ កុមារត្រឡប់នាំការណ៍ពិតមកថ្វាយព្រះ-ជាក្នុងពេលល្ងាចថ្ងៃនោះវិញថា កងទ័ពខាងព្រះរាជាមានជ័យជំនះលើ បច្ចាមិត្ត ៗ ព្រះមហាក្សត្រទ្រង់មានព្រះរាជអំណរ ហើយក៏ទ្រង់ថ្វាយ រង្វាន់ ដ៏មានដម្លៃច្រើនដល់កុមារ ៗ

ជាលំដាប់មកទៀត កុមារ តែងធ្វើជាអ្នកជំនួយខាងរត់សំបុត្ររបស់អ្នក នគរទាំងមូល ៗ ស្រីៗតែងពឹងពំនាក់កុមារឲ្យនាំយកសំបុត្រនេះទៅសួរ សុខទុក្ខប្តីនិងញាតិសាលោហិត ដែលនៅឆ្ងាយដាច់ស្រែង ៗ កុមារ ទទួលផលដ៏ឧត្តមបំពេញគ្រួសារញាតិមាតាបិតានូវបងទាំងអស់ គ្មានឲ្យ លំបាកមួយវេលាណាឡើយ ៗ

- ចប់ -

# រឿងទេវន្ទ (ពាក្យកាព្យ)

លោក អមាត្យត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក-ថែម ពិនិត្យ ( តមក )

---

ឥសីផ្តាំថា បើបានយាត្រា កុំព្រះភូធរ ហៀរហោះរមួល តែម្តង
បោះបរ ប្ញក្សត្រូវរ ចាំពាក្យដីកា ៗ ទៅតែហួសគុំ ទទឹងធាធំ ទៅមុខ
នោះណា មានស្រះមួយធំ ស្តេចកុំយាត្រា ចូរឈប់និទ្រា នៅឆ្នេរស្រះ
ស្រី ៗ ទំនើងស្តេចចង់ សេពសោយស្រប់ស្រង់ បុប្ផាបុប្ផ នូវរុក្ខផលា
អាហារបំណើ បំណង់អ្វី ៗ តាមចិត្តប្រាថ្នា ៗ ព្រឹកព្រានស្រាងស្រេច
ស្រួលបួលសឹមស្តេច បោះបោយាត្រា បើដល់ដែនយក្ខ អបល័ក្ខណ៍មោហា
ហាក់ហៅព្រោះប្រា ការគល់អ្វី ១ ៗ កុំផ្ញេក(១) មើលវា កុំស្តាប់វាចា
កុំជឿសំដី បើព្រះចមទៅ ឈប់នៅនោះនៃ នឹងបង់សេចក្តី បំណង់ប្រាថ្នា ៗ

តោធិបតិ ទូលថាអញ្ចុំ ទទួលព្រះដីកា ដោយដាក់ដំកល់ មណ្ឌល

---

១ គឺកំព្រឡេក ។

សំរេសា កុំព្រះដីកា ព្រួយនឹងអញខ្ញុំ ៗ ស្រេចព្រះភូមិន្ទ ស្ដេចប្រទក្សិណ ឥសីបីដុំ អាស្រមស្រេចស្រាប់ សម្ដេចព្រះបរម ពោធិឧត្តម ក្រញូក្រាប លុតលា ៗ កែក្រាយបោបរ រូបដេកសរ ឯកអង្គថៃថ្វា លុះក្រៅអាស្រម ពិតពុំវេរា ឡើងគង់អាជា-នេយ្យនាំហោះទៅ ៗ ស្ដេចហោះហួស ក្នុំ យល់ស្រះមួយធំ ព្រះបាទចមទៅ ស្រង់សោយផលា អាហារឥត សៅ ស្អែងស្ដេចផុំនៅ អស់ឯករាត្រី ៗ ស្អែងស្ដេចស្រប់ស្រង់ ជម្រះ ព្រះអង្គ ទៀងទើបនរបតី គង់សេះហោះដល់ មណ្ឌលយក្ខិនី យក្ខយល់ បក្រី អរឯងគិតថា ៗ

អះអញនឹងរំ៖ បញ្ចោតអ្នកនេះ ជាកក្ខកោក្ដា ក្រងយក្ខគនទំតិត និម្មិត-សាលា មួយមានអស់អា- ហារហើយហៅហៅ ៗ ពន្សព្រុទ្ធនរ ពុំបើកបន្ទូល ប្រឹងបរសេះទៅ យក្ខយល់ហ្ទោះសោត គ្រវក្រោធក្ដាត់ក្ដៅ ហៀវហោះវាងទៅ អំពីព្រះកក្រ្ត ៗ និម្មិតសាលា មានគ្រឿងសេយ្យា ដូចទីមហាបក្រ និម្មិតអាត្មា ឯងជាស្រីម្នាក់ កាយគបៈលក្ខណ៍ ដូច ស្រីសួគ៌នាយ ៗ ហើយហៅហៅថា នែអ្នកទៅណា អញ្ជើញមកអាយ ស៊ីស្លាឈប់ខាន សម្រាន្តអង្គកាយ ព្រឹកព្រានសួរសាយ សង្រ្វមអ្នកទៅ ៗ

ពន្សព្រុទ្ធបក្រ ពុំឈ្មៀងព្រះកក្រ្ត ពុំស្ដាប់ពាក្យហៅ គិតក្រែងអំពល់ យក្ខយល់បមទៅ ប្រឹងបរសេះទៅ ពុំមើលអាត្មា ៗ វាងហិបហោះ

ទៅ ពីកក្រុបមហៅ និម្មិតសាលា មានត្បូងត្រ្ទី មានស្រីផងជា អ្នក
លេងសួស្តីសា សួរសព្វលេងល្បើយ ។ រើករូបពង ល្អសល្មុនយាស-
យាង ហាក់ហុចហៅហើយ តែក្រោយឈ្នងឈ្នៀង ជួបជ្រៀងព្រ-
ងើយ ក្នុងក្លាក់ផ្លាស់ផ្ទើយ សព្វសោតសមសួរ ។ ហាក់ដូចត្រ្ទី អំពី
សួគ៌ស្រី សម្តេចព្រះពុ- ធរេន្ទសេដ្ឋ លោកៈវិទូ ពុំស្តាប់សព្វសួរ ពុំ
ផ្អកនេត្រទៅ ។

យក្ខយល់រើរ៉ះ ថាអះអ្នកនេះ ហៅហួសលំនៅ អង្គអញនេះនឹង
ធ្លងស្លឹងហួសទៅ អង្គអញអាសៅ អសារខានស៊ី ។ គួរអញទៅតាម ចាំ
ស៊ីហុតឈាម ឲ្យក្សយជីវី គិតស្រេចតែបក្លាយ ក្នុងកាយឥន្ទ្រិយ ជា
យក្ខគ្រវី តំបងតាមទៅ ។ ឈើឈរញ៉ោរញ៉ោក ទោរទន់ដោយតេជ យក្ខ
យង់ឃោរឃៅ ខេរខឹងផ្ទុះផ្ទក គ្រះឡេកគ្រះឡោ សព្វសូរឮទៅ បីដូច-
រន្ទះ ។ សេះសោតយង់យល់ យក្ខះទៀបដេញដល់ ទើងទើបទូលព្រះ
ពង្សពុទ្ធឧត្តម អញរំសូមពះ ដោយតេជតបះ នឹងយក្ខមោហា ។ បូរ
ស្តេចចុះទៅ គង់នឹងនិត្យនៅ ចាំទតបេស្លា ខ្ញុំយុទ្ធនឹងយក្ខ ឲ្យដាក់ដៀង
ប្រា- កដកើតកាលគ្រា នេះទឹងឲ្យស្តែង ។ តោធីប្រសើរ ចរចុះពីលើ
សេះសោតឥតក្រេង បរបួលឈរឈប់ ក្រោមម្លប់ឥតល្វែង ចិត្តចង់សំ
ដែង បុណ្យប្បារមីមាន ។

យក្ខបង់ចាប់ស្ដេច ត្រវែងពេជ្រ យក្ខយន់ពុំហាន គិតថាអញចាប់ សម្លាប់អស្សយាន ស៊ីសិនគង់បាន អ្នកនេះទាំងឆាយ ៗ គិតស្រេចក្រឡាប់ ក្រឡេះបូលចាប់ សេះសោតប្រះប្រាយ ស្រែកសព្ទពន្លឺសីហ៍ បន្លឺឮឆ្ងាយ លោតឡើងកកាយ កាន់អាកាសា ៗ មាត់មុខខាំស៊ី ជើងមុខទាំងពីរ ជាន់ត្រូវទ្រា ជើងក្រោយជាន់ជាក់ ត្មៀយក្ខមោហា ដាច់សាច់មំសា លោហិតខ្ចរខ្ចាយ ៗ ហោះឡើងលើភ្នំ ប្រមៀលអស់ជុំ សិលាទាំងឡាយ ផតឈើរើថ្ម ចោលមកព្រោងព្រាយ មមាមិញមាំយ សម្លាប់ក្សត្រថ្លៃ ៗ ទេព្ដាដាយដាត់ ការកាយមហាក្សត្រ សេះសោតក្រោធក្រៃ អញ្ជើញព្រះមហា ក្សត្រាថ្លៃ គង់ហោះឯង អាកាសវេហា ៗ បរបូលគតាំង ទល់ទព្វពាំង ទីងយក្ខមោហា ទ្រង់ខាន់វាយពត់ កាប់កាត់យក្សា យក្ខសោតមរណា ដាច់ខ្លួនខ្ទាត់ខ្ចាយ ៗ

សេះនាំហោះដល់ ត្រីមត្រើយមណ្ឌល ស្ទឹងធំទូលាយ ស្រេចសោយស្ដេចស្រង់ ព្រះគង្គាកាយ ស្ងួតគង់សប្បាយ ក្រោមដើមព្រះជ្រៃ ៗ ស្ដេចសូត្រចិន្ដា- មណីមន្ដជា ព្រះមន្ដទិព្វថ្លៃ ត្រីផង់នៅក្នុង កម្ពង់ជលស័យ ពុំអាចអាស្រ័យ និត្យនៅនឹងបាន ៗ សោតសឹងឡើងមក ពាសពេញកុះកក បន្ដំក្សត្រក្សាន្ដ ទាំងមហាលោមា ជាតិជាប្រធាន រឹងត្អឹងពុំបាន សឹងមកវន្ទា ៗ សួរសព្វហេតុផង ស្ដែងស្ដេចនឹងជូន អញ្ជើញក្សត្រា

គង់ទៀនលើខ្នង បម្វងគង្គា ត្រីផងពោមជា បរក់រៃហលហៃ ៗ សេះហ៊ប ពោះទៅ ឈប់ឈរចាំនៅ មើលក្សត្រក្សាន្តឯ មាត់ត្រើយស្ទឹងម្ខាង ស្ដេច យាងទៅតែ នឹងត្រីហៃលហៃ ព្រះបាទបង្សចប្វាស់ ៗ ដល់ហើយបម ទៅ គង់សេះពោះទៅ ដល់ផ្ទះដូនចាស់ ក្នុងទីទឡាន ក្សេមក្សាន្តពេក ណាស់ បើកបង្គួលត្រាស់ នឹងដូនចាស់ថា ៗ តាដូននិត្យទៅ ឯកឥត កូនចៅ កំព្រាកំព្រា អាស្ងួរឲ្យចៅ និត្យនៅផងក៏ ចៅនឹងរក្យ បញ្ចឹមតា យាយ ៗ ដ្បិតចៅឯកឯង ដើរព្រៃវង្វេង មកពីស្រុកឆ្ងាយ ចាស់ពីរក្រោក អរ ស្មោះសរីកកាយ កេះកាជនថ្វាយ ស្ដេចសេពសោយស្រេច ៗ ស្ងួរសព្ទ នាមករ ទីទេសនគរ បុរីរដ្ឋស្ដេច ស្រេចទើបព្រះអង្គ ពូជពង្សសារពេជ្រ លុតលើលាគេប មកកាន់អស្សយាន ៗ

ចូរបង់ទៅនៅ រះកេស៊ីស្មោ ព្រៃព្រះពោមពាន្ត បើប្អូនមានទុក្ខ ពុំ សុខក្នុងប្រាណ -នឹកដល់កុំខាន ចូរធាប់វិលមក ៗ សេះសោគលាទៅ ដើរកេស៊ីស្មោ ដោយព្រៃឈ្លូងធក ព្រះម្កុដត្រែកព ត្រឡប់វិលមក និត្យ នៅរះក បញ្ចឹមជូនចាស់ ៗ

យាយតែងបេះផ្កា គ្រប់ក្រងបងជា ក្តីផ្កាឆ្កូកឆ្ងាស់ ថ្វាត់ថ្វាយជីតា ជាតិជាអម្ចាស់ រៀងមកយាយចាស់ នោះតែងក្រងថ្វាយ ៗ ក្សណ ក្សត្រប្បាស់ប្ងន បេះបុប្ផាផង រះរៀបរៀងកាយ ចាប់បេសចាក់បង ក្រាល

ក្រងលើគលាយ ពណ៌ពិតលែបខាយ ដោយប្រាជ្ញាញាណ ។ អធិដ្ឋាន ថា បើនាងនោះណា ជាគូបុព្វណា ជាស្រីគ្នាថ្ងៃ កន្សែងពោធិញ្ញាណ កាយ កបបុណ្យបាន បាទបរិចារិកា ។ ឃើញផ្កាអង្គអញ នេះត្រេកស្រឡាញ់ ហាក់ដូចយល់គ្នា ផ្សងស្រេចប្រែប្រាយ ប្រាប់យាយតាស់ថា យាយ អើយយកផ្កា ទៅថ្វាយក្សត្រី ។ ពីថ្ងៃនេះទៅ ទុកការឲ្យទៅ ក្រងជួស ប្រក្រតី យាយបានទៅហើយ យាយអើយក្រឡី ចិត្តទៅប្រណី ដៀតយាយ តាស់ហើយ ។ យាយស្តាប់ព្រះមហា- បុរសហើយថា ឱអ្នកថ្លៃអើយ បានអ្នកបេះក្រង ស្តាប់ស្នងយាយហើយ ទ្រូងយាយបានស្បើយ បាន បាត់ឈឺខ្លួន ។

ថាហើយយកផ្កា ទៅថ្វាយធីតា នាងយល់កម្រង បុប្ផាផលប្លែក ចំឡែកសព្វផង ព្រះហឫទ័យចង គួបកើតស្នេហា ។

ទើបសួរយាយតាស់ ផ្កានេះប្លែកណាស់ បានពីនរណា ឯអ្នកបេះចង បេះក្រងទងផ្កា នេះប្លែកបូរថា ដោយពាក្យពិតត្រង់ ។

យាយតាស់ទូលថា បពិត្រធីតា ប្រសើរវរវង្ស ខ្ញុំតែងក្រងថ្វាត់ ថ្វាយក្សត្រីទ្រង់ មិនដែលឲ្យអង្គ អ្នកណាក្រាលក្រង ។

នាងស្តាប់យាយតាស់ ពិតពុំជឿគ្រាស់ សួរពីរបីដង យាយឆ្លើយ ប្រាប់ប្រែ ថាតែខ្ញុំក្រង ពុំថ្នងដោយដង ដោយដំណើរត្រង់ ។ ទើប

នាងបណ្តេញ អស់ស្រីផងចេញ ហៅយាយចូលក្នុង សង្កេតសួរស្រួល
យាយទូលតាមត្រង់ បពិត្រសូមទ្រង់ ប្រោសប្រាណមេត្តា ។

ដ្បិតអង្គអញខ្ញុំ មែនមានចៅកំ ឡោះមួយលីលា ពីប្រទេសឆ្ងាយ
តែកាយឯកា មកសូមនៅជា មួយនឹងអម្ចាស់ ។ នាមឈ្មោះទេវន្ទ
ប្រសើរសោភ័ណ ឥតមានទោសទាស់ វិសេសវិសាល ត្រីកាលល្អណាស់
ប្រុសប្រាជ្ញច្បាស់ លែងលោកដទៃ ។

នាងឮព្រឺព្រួច ព្រះហឫទ័យកាន់គួច កើតក្តីអាល័យ ហាក់យល់កត្រា
ព្រះមហាក្សត្រថ្លៃ សោតសំណាងនៃ នាងនោះប្រាថ្នា ។ នឹងព្រះពង្ស
ពោធិសត្វឧត្តមោ ច្រើនជាតិជាក់ជា កន្សែសម្តេច សារពេជ្រសាស្តា
ញាណញែយ្យសម្មា-សម្ពោធិញ្ញាណ ។ ត្រាស់ថាដូច្នោះ យាយទៅ
មុនចុះ ទៅរៀបទីឋាន ឯអង្គអញឯង បង់លែងឲ្យបាន ឲ្យសុខឲ្យសាន្ត
ឲ្យក្សេមសប្បាយ ។ ក្រោយយាយទៅលង់ តិចទើបនាងទ្រង់
សំអាងព្រះកាយ នាំអស់ស្និទ្ធស្នំ ចាស់ទុំទាំងឡាយ ចរចូលថ្វាត់ថ្វាយ
បង្គំបិតា ។ ទូលថាអញខ្ញុំ លុតលាអង្គអ- ម្ចាស់បរយាត្រា ទៅលេង
ឲ្យបាន កំសាន្តចិន្តា សូមព្រះករុណា ប្រោសប្រទានទៅ ។

ស្តេចស្តាប់បុត្រនេ្ត ពិតពុំទាំងយាក់ បើកបន្ទូលហៅ អាមាត្យមួយ
ថ្វាត់ ហើយក្សត្រចមចៅ ត្រាស់ឲ្យរៀបទូរ សេនាពជយាន ។ អាមាត្យ

លុតលា ចេញរៀបសេនា សេនីទាហាន តូរ្យតន្ត្រីត្រែ គ្រប់ត្រែស្គរគាទ សេនាសិនមាន គ្រឿងគ្រប់ដោយដៃ ។

នាងលាក្សត្របាន រំលងរាជដ្ឋាន ប្រាសាទទិព្វថ្ម ស្រីស្រស់ទ្រង់គ្រឿង រុងរឿងប្រពៃ ដូចជាទេវី នីរអ្នកផ្ទឹមបាន ។ យានយាសកាយករ លីលាចេរចរ ចេញចាករាជដ្ឋាន គង់លើគ្រែមាស ទុកាសផ្ចើនស្ថាន សេនាទាហាន ហែៗចេរចរ ។ អស់ស្នំបរិវារ ចាស់ទុំស្រីក្ខារ តូច ៗ ល្អ ៗ រាងរៅរៀវរៀវ ស្រស់ស្រៀវស្រគរ គ្នីគ្នាប្រើសប្រៈ ដាប់ដង្ហែទៅ ។ តន្ត្រីសន្ធឹងត្រែ ប្រគំដង្ហែ ក្សត្រីចមទៅ វិសេសវិសាល ត្រកាលឥតសៅ លន់លុះដល់ទៅ ទន្លេនតុំលង់ ។ សម្តេចក្សត្រី កបកល្យាណី ផ្លាក់ផ្លាស់គ្រឿងទ្រង់ នាំអស់បរិវារ ស្រីក្ខារគ្រប់អង្គ លីលាចុះស្រង់ ស្រះស្រីរងថ្វា ។ ផ្សាយផ្សះគេសី វររាជក្សត្រី គ្រេកព្រះទ័យា នូវស្នំហែលហាច ហែលគេចដេញគ្នា សើចសើះហោហា កញ្ឆ្រោកទះទឹក ។

ខ្លះហែលបេះផ្កា បទុមាមាន សុគន្ធាធិក លំបង់គេកាយ កបកាយ - ស្លោមស្លឹក លូតលាស់លើទឹក រុះពោយគេសរ ។ បេះចង្កូលណី កម្រទបុប្ផ៍ ទត្បលគន្ធ សើមសៀតចង់ជួត បង្គួតបង្អ បេះបានថ្វាយវ៉ា រក្សាជ - ក្សត្រី ។ នាងសាន្តសុខសល់ ក្នុងព្រះគមល ដូចទេពសួគ៌ស្រី

(មានត)

# រឿងសាមកុក

## កណ្ឌទី ៣០

ឧកញ៉ាវិបុលរាជសេនា ញ៉ូ-កាន ប្រែរៀបរៀង

( តមក )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

សន្តានបងប្អូនអួនសៀវ នឹងបណ្តាស្ត្រីអ្នកស្រុក ឲ្យបានសេចក្តីក្តៅក្រហាយឡើយ ដែលលោកជាកូនទើបចូលទៅនោះ ឃើញថាជាការល្មើស នឹងពាក្យមហាឧបរាជ ។

ចោភីបានស្តាប់ពុំដូច្នោះ ក៏ស្រែកគំហក ហើយដើរចូលទៅដល់ល្វែងក្នុង ឃើញស្រី ២ នាក់ ឱបគ្នាយំទួញ ចោភីក៏ខឹងឈ្លួលឆេះហូតក្រប៊ីចេញនឹងកាប់ស្រីទាំង ២ នាក់នោះចេញ ហើយបែរត្រឡប់គិតទាន់ទើបសួរថា ចៅទាំងពីរនេះឈ្មោះអ្វី ? ហេតុម្តេច បានជាមកអង្គុយយំដូច្នេះ ? នាងឡៅដីឆ្លើយតបវិញថា ខ្ញុំឈ្មោះនាងឡៅដី ជាភរិយាអួនសៀវ នាង

នេះឈ្មោះអៀនស៊ី ជាភរិយាអ្នកហ៊ុចៅហ្វាយស្រុកគុជីវ ដែលជាបុត្រអ្នកសៀវ ចោគីក៏ថាឲ្យនាងអៀនស៊ីងើបមុខទ្រៀងនឹងមើល ក៏ឃើញមុខមាត់និងរូបរាងល្អស្រស់ប្រិមប្រិយ ក៏កើតសេចក្ដីស្នេហាស្រឡាញ់ ទើបប្រាប់ថា យើងឈ្មោះចោគីជាបុត្រមហាឧបរាជ យើងនឹងរក្សាថែទាំមិនឲ្យមានសេចក្ដីអន្តរាយបានឡើយ ។

ឯបូឆ្លក៏ជិះសេះនាំខៅហ៊ុវនឹងសេនាទាហាន ចូលទៅដល់ទ្វារស្រុកគីជីវ ខៅហ៊ុវក៏មានចិត្តភ្ញើនថា បូឆ្លនឹងខ្លួនជាកៀនសំឡាញ់គ្នា មកពីដើម ក៏បរសេះស្ទុះតមកទន្ទឹមនឹងសេះបូឆ្ល ហើយយកសែសេះបង្អុលត្រង់ទ្វារស្រុកថា បើយើងមិនត្រិះរិះឲ្យធ្វើចម្បាំង ក៏ទឹងមិនបានមកឃើញទ្វារស្រុកគីជីវនេះឡើយ ។ បូឆ្លបានឮហើយក៏ធ្វើជាអស់សំណើច ហើយមិនតបថាអ្វីសោះ តែបណ្ដាទាហានទាំងពួងនោះ ក៏មានចិត្តខឹងក្ដៅនឹងខៅហ៊ុវពន់ប្រមាណ ។ បូឆ្លក៏ចូលទៅដល់ទ្វារផ្ទះអ្នកសៀវ ហើយសួរអ្នកចាំទ្វារថា នរណាប៉ុលមកធ្វើអន្តរាយភរិយាបុត្រនឹងបងប្អូនអ្នកសៀវខ្លះ ? នាយទ្វារជំរាបថា ឥឡូវចោគីបុត្រលោកចូលទៅនៅខាងក្នុង ។ បូឆ្លក៏ឲ្យគេហៅខ្លួនចោគីចេញមក ហើយនិយាយរលឹកប្រដៅ មិនឲ្យធ្វើកំរិតទៅ ។

ខណៈនាងឡេវជីចេញមកគំនាប់បូឆ្លហើយថា ដែលចោគីចូលមកនេះ បានការពាររក្សាបក្ខពួកខ្ញុំម្ចាស់ ស្រួលបួលណាស់ ប៉ុន្តែបានចោគី

មកការពារ ទាហានទាំងពួងនឹងប្រមាថមើលងាយ ធ្វើអន្តរាយផ្សេង ៗ មិនខាន ឥឡូវ ខ្ញុំម្ចាស់នឹងលើកនាងកៀវស៊ុំជាកូនប្រសា ឲ្យជាភរិយាតោក៏ចុះ ៗ បុធ្ធក៏ឲ្យហៅខ្លួនចេញមក ឃើញនាងកៀវស៊ុំមានរូបរាងល្អស្អាតគួរជាភរិយាតោពិត ក៏រៀបចំឲ្យនៅរួមសុខ - ទុក្ខនឹងគ្នា បុធ្ធក៏ឲ្យរៀបតែងតុ ដោតធូបទៀនមានផ្កាភ្ញី សែនគំនាប់សពអ្នកសៀវ ហើយក៏យំសោកសាល័យជាច្រើន ៗ រ៉ៅព្រើក្សានឹងសេនាទាហានទាំងពួង ឃើញដូច្នោះក៏មានសេចក្ដីសង្ស័យ ទើបដំណើរសួរបុធ្ធថា លោកនឹងអ្នកសៀវធ្វើសឹកសង្គ្រាមជាប់ដៃនឹងគ្នាមក ឥឡូវលោកហ៊ុយយកបានទាំងស្រុកគីដាវផង ហើយហេតុម្ដេច ក៏មកតែងគ្រឿងសែនគំនាប់ ជាសេចក្ដីរាប់អាន ហើយថែមទាំងយំយែករលឹកអាល័យអ្នកសៀវទៅវិញ ៗ

បុធ្ធក៏ក្លែង៖បាយ ប្រាប្ទាងនឹងឲ្យទាហានទាំងពួង សរសើរចិត្តថ្លើមបុធ្ធថា ជាអ្នកមានសត្យានុស័ត្យពិតត្រង់ ហើយក៏ពណ៌នាសេចក្ដីថា កាលគ្រាតង់គុ តាំងខ្លួនជាមហាចបរាជនោះ យើងនឹងអ្នកសៀវ ហើយនឹងពងខេត្រ លើកកងទ័ព ទៅតាំងនៅ ក្រៅគយទីស៊ុយគួន ដើម្បីនឹងកំចាត់តង់គុចេញ អ្នកសៀវក៏លបសួរយើងថា បើធ្វើសឹកសង្គ្រាមចាញ់តង់គុហើយ តើយើងនឹងទៅតាំងប្រមូលសេនាទាហានទៅទំដំបន់ណា ដើម្បីនឹងបានគិតការតទៅទៀត? យើងបានសួរអ្នកសៀវថា ខ្លួនអ្នកនឹងទៅនៅទំដំបន់ណា? អ្នក

សៀវប្រាប់យើងថា នឹងមកនៅខាងអាណាខែត្រទិសឧត្តរនេះ ព្រោះជាទីធំទូលាយ ទាំងស្បៀងអាហារក៏មានបរិបូណ៌ សេនាទាហានក៏ចំណានក្នុងការសឹកសង្គ្រាម នឹងបានគិតការធំទៅ យើងក៏បានថាខ្លួនយើងនេះមិនរើសទឹកដីខ្លួនទេ ទោះទៅនៅទីដំបន់ណាមានមនុស្សរាប់អានរួមចិត្តគំនិតគិតការជាមួយនឹងយើង ៗ ក៏នៅគិតការត្រង់ទីនោះ ទោះបីអ្នកសៀវនឹងយើងជាគូវិវាទ ធ្វើសឹកសង្គ្រាមនឹងគ្នាក្តី ក៏នៅជាកៀននឹងគ្នា មកពីដើមបានជាយើងនឹករឿងកំសត់អត់ស្រក់ទឹកភ្នែកមិនបាន ដោយមាននិស្ស័យដូច្នេះ ៗ

ទាហានទាំងពួង បានស្តាប់បួឆថាដូច្នោះ ក៏នាំគ្នាសរសើរថា ចិត្តមហាឧបរាជមានសត្យានុស័ត្យពិតត្រង់ល្អមែន ៗ បួឆក៏ចាត់ចែងមាសប្រាក់គ្រឿងសម្លៀកបំពាក់ ឲ្យនាំទៅឡាយជាកិរិយាអ្នកសៀវជាច្រើនហើយបង្គាប់ថាបណ្តាអាណាខែត្រខាងទិសឧត្តរនេះ អាណាប្រជារាស្ត្រមានសេចក្តីក្តៅក្រហាយ ព្រោះមានការសឹកសង្គ្រាមមកច្រើនឆ្នាំហើយ ក្នុងឆ្នាំនេះកុំឲ្យទារយកពន្ធសួយសារអាករឡើយ ៗ

លុះព្រឹកឡើង ទៅធ្ងរជិះសេះ ចូលទៅដល់ទ្វារស្រុក ទទួលជួបប្រទះនឹងទៅហ៊ុំ ៗ ក៏និយាយថា ទាហានទាំងអម្បាលនេះ បានមកនៅក្នុងស្រុកគីដេរ ក៏ព្រោះគំនិតរបស់យើងផ្តើមគិតឡើង ទើបបានស្រុកនេះ ៗ

ទៅជូតបថា ខ្លួនអញក៏ជាទាហានមានប្ដីដែរ បានទាំងតតាំងច្បាំង ដោយកាយ ទំលាយចូលទៅវាំងក្រុង ទើបបានស្រុក ហេតុម្ដេច ក៏ឯងមកអួតអាងថា ស្រុកនេះបានដោយសារគំនិតរបស់ខ្លួនវិញ ។ ទៅ-ហ៊ីវតបថា ខ្លួនឯងមានប្ដីដែក៏ពិតមែន តែអញផ្ដើមគំនិតឲ្យ ទើបឯងធ្វើតាម ។ បមាដូចអញជានាយទៅហ្វាយបានប្រើឯង ។ ទៅជូឮដូច្នោះ ក៏ខឹងណាស់ ទើបហូតគ្រឹបចេញហើយក៏កាប់ផាប់ក្បាលទៅហ៊ីវស្លាប់នៅទីនោះ ហើយយួរយកក្បាល ចូលទៅដំរាបប៊ូឆូថា ទៅហ៊ីវនិយាយមើលងាយខ្ញុំបាទជាពាក្យទ្រគោះយ៉ាងធ្ងន់ ឥឡូវ ខ្ញុំបាទធន់មិនបានៗ សម្លាប់ស្លាប់ហើយ គាត់យកតែក្បាលមកជូនលោក ។ ប៊ូឆូតបថា " ទៅហ៊ីវនោះ ជាកឿនសំឡាញ់របស់យើងមកពីដើម ដែលរ៉ាហ៊ាននិយាយដូច្នេះ ព្រោះជាថ្វីអួតអាងលើកកំពស់ ហេតុម្ដេច បានជាខ្លួនមិនពិគ្រោះឲ្យល្អិតល្អសិន ហ៊ានកាប់សម្លាប់ទៅហ៊ីវចេញ ដោយអំពើចិត្តឯងនោះមិនគួរទេ " ហើយប៊ូឆូក៏ឲ្យគាត់ទោសទៅជូដាក់គុក ទើបឲ្យតែងការសពទៅហ៊ីវ ហើយក៏ឲ្យនាំទៅបញ្ចុះតាមទំនៀមប្រពៃណី ។

ខណៈនោះ ប៊ូឆូក៏ឲ្យទៅបញ្ចុះបញ្ចូលអ្នកមានផ្សេះប្រាជ្ញា ដែលនៅក្នុងអាណាខែត្រទិសទក្ខ ត្រូវទៅស្ដាប់បង្គាប់ស្រុកគីជីវ បានស៊ុយតាំទីប្រឹក្សាអួនសេុវ ដែលបាននិយាយឃាត់ហាមអួនសៀវមកពីដើម អួន

សៀវមិនព្រមជឿស្ដាប់ ស៊ុយតាំ ក៏ធ្វើជាឈឺចេញទៅនៅផ្ទះវិញ ។ ប៊ូធូបានស៊ុយតាំចូលមកក៏មានចិត្តសោមនស្សណាស់ តាំងស៊ុយតាំជាទីប្រឹក្សា ហើយប៊ូធូបានយកបញ្ជីមនុស្សបំណុះស្រុកគីជីវ៉ដែលមានគ្រួសារដល់ទៅ ៣០ ម៉ឺនប្រាយ ប៊ូធូនិយាយថា ស្រុកគីជីវ៉នេះជាខេត្តឯក មានមនុស្សក៏ច្រើន ។ ស៊ុយតាំជំរាបថា ដែលមានបញ្ជីបំណុះស្រុកនោះក៏មែនហើយ តែដែលលោកនឹងទុកចិត្តថា មានមនុស្សគ្រប់តាមបញ្ជីនោះមិនបានទេ ព្រោះមានសឹកសង្គ្រាមមកច្រើនឆ្នាំហើយ មនុស្សស្លាប់អស់ច្រើនណាស់ ឥឡូវអួនថាំនឹងអួនស៊ុនក៏ពុងតែច្បាំងគ្នា មនុស្សនានាក៏បែកបាក់ខ្ចាត់ខ្ចាយទៅគ្រប់ដំបន់ សូមឲ្យលោកប្រាបប្រាមឲ្យរាបទាបជាប្រក្រតី ហើយបញ្ចុះបញ្ចូលឲ្យភូមិស្រុកនៅជាសុខក្សេមក្សាន្ត ឯទាហាន ដែលបែកបាក់ទៅតាំងប៉ុន្មាន ក៏នឹងវិលត្រឡប់ចូលមកទីពឹងលោកវិញ ។ ប៊ូធូយល់ឃើញត្រូវ ក៏គិតធ្វើតាមពាក្យស៊ុយតាំនិយាយ ហើយក៏ឲ្យមនុស្សសួងទៅស្ដាប់ដំណឹងអួនថាំនឹងអួនស៊ុន ។

ឯអួនថាំ, អួនស៊ុន កាលប៊ូធូច្បាំងយកស្រុកគីជីវ៉បាននោះ អួនថាំក៏លើកទ័ព ទៅវាយបានស្រុកកាំឡៀង, ស្រុកហាំងបេង, ស្រុកពុតហៃ, ស្រុកហោគ័ន ហើយកៀរប្រមូលទាហានយកឈ្លើយបានជាច្រើន លុះឮដំណឹងថា អួនស៊ុនរត់ពីប៊ូធូទៅលាក់ខ្លួនពួនអាត្មា: ឯក្នុងព្រៃក៏លើកទ័ព

ជាប់តាមទៅ ឯអ្នកសុងក៏នាំទាហានទៅនៅនឹងអ្នកហ៊ុជាបង ទៅស្រុកគុ-ដីរ អ្នកថាំក៏មិនបានលើកទ័ពតាមអ្នកសុងទៅ ត្រឡប់លើកទ័ពវិលមកស្រុកពេងឆ្នួនគួនវិញ ហើយក៏គិតថា ឥឡូវ ចូឆូវាយបានស្រុកគីជីវហើយបើនឹងស្មៀមព្រះនើយទៅឃើញថា សាប់សាលោហ៊ាតញាតិសន្តាននឹងអាណាប្រជារាស្ត្រ នឹងបានសេចក្ដីក្ដៅក្រហាយ ចាំនឹងលើកកងទ័ពទៅបង្ក្រាបចំលាយចូឆូ ដណ្ដើមយកស្រុកគីជីវឲ្យបានមកវិញ ។

ខណៈនោះ មានបំរើសេះម្នាក់ចូលមកប្រាប់អ្នកថាំថា មហាទបរេជឲ្យហៅខ្លួនលោកទៅនិយាយការរេជការ ។ អ្នកថាំក៏និយាយនឹងអ្នកបំរើថាខ្លួនចូលទៅប្រាប់ចូឆូវិញចុះថា យើងទៅជាក្រោយ ។ ចូឆូឮដូច្នោះក៏ធ្វើសំបុត្រឲ្យបំរើសេះកាន់ទៅឲ្យទៀតជាសេចក្ដីថា "ខ្លួនយើងជាធំឲ្យហៅខ្លួនអ្នកថាំមកនិយាយការរេជការផង អ្នកថាំហេតុម្ដេច បានជាខ្លួនរឹងទទឹងមិនចូលទៅ ឯបុត្រីយើងដែលថានឹងលើកឲ្យជាភរិយាខ្លួនអ្នកថាំនោះឥឡូវយើងឈប់លែងឲ្យវិញហើយ" ចូឆូក៏ចាត់ចែងទាហានជាច្រើនលើកទៅវាយស្រុកពេងឆ្នួនគួន ប្រាថ្នាដើម្បីនឹងបង្ក្រាបកំចាត់អ្នកថាំចេញ ។

ចំណែកអ្នកថាំដឹងដំណឹងក្នុងសំបុត្រនោះហើយ ក៏ដឹងថាចូឆូលើកកងទ័ពមកវាយទៀត អ្នកថាំក៏ធ្វើសំបុត្រឲ្យទៅដល់ឡៅប៉ៀវទៅហ្វាយស្រុកកេងជីវ សេចក្ដីថា ចូឆូលើកកងទ័ពទៅវាយ យកស្រុកគីជីវបានហើយ

ឥឡូវនឹងលើកទៅវាយយកស្រុកពេនដួនគួនទៀត ឬអ្នកក្រឡេកឃើញ ដល់ផ្លូវមេត្រីនៃយើង សូមឲ្យលើកកងទ័ពទៅជួយ ។

ឡៅបឿវឃើញសេចក្ដីសំបុត្រនោះហើយ ក៏ប្រឹក្សានឹងឡៅពីរតប ថា ឥឡូវបុច្ចលើកទ័ពទៅវាយយកអាណាខេត្រទិសឧត្តរ បានអស់ហើយ ក៏មានចិត្តកំរើកធំទ្រើងទៀតពន្ទឹកណាស់ បណ្ដាបុត្រញាតិសាលោហិតបងប្អូនរបស់អ្នកសៀវទាំងប៉ុន្មាន បានរិះគិតតាំងច្បាំងសងសឹកនឹងបុច្ចនោះ ឃើញថាមិនបានទេ គឺសែអ្នកទាំងប៉ុន្មាននោះឃើញថា បុច្ចនោះសាគនឹងសង្កត់សង្កិនចាប់យកខ្លួនកំទេចអស់ហើយ ឯចិត្តបុច្ចនោះសាគក៏មុខជានឹងលើកទ័ពមកញីញក់ធ្វើអន្តរាយដល់ស្រុកយើងថែមទៀត ដែលលោកនឹងលើកទៅជួយអ្នកថាំនោះឃើញថា មិនស្រួលទេ សូមឲ្យលោកបម្រុងទាហានទុកឲ្យមានកំឡាំងសិន បើបុច្ចលើកទ័ពមកក៏នឹងបានការពាររក្សាស្រុកឲ្យគង់ ។

ឡៅបឿវយល់ឃើញត្រូវ, ក៏និយាយថា ដែលយើងមិនលើកទ័ពទៅជួយអ្នកថាំនោះ គេនឹងឲ្យមានសំបុត្រឆ្លើយតបទៅវិញថា ម្ដេចទើបបានស្រួល ? ឡៅពីថា ខ្លួនលោកជាធំត្រូវធ្វើសំបុត្រទៅជាទីរលឹកប្រដៅអ្នកថាំថា ការសង្គ្រាមមកដល់ហើយ ត្រូវតែបងចិត្តគិតស្ម័គ្រសមាគមបងប្អូន

(មានត)

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

( តមក )

## លោក រ៉ាយ-ប៊ុក ប្រែរៀបរៀង

## ៣- មហាទោសៈនៃព្រះនាងអាមាតេរាស៊ូ

( អាទិទេវី នៃព្រះសូរ្យា )

ព្រះនាងអាមាតេរាស៊ូ ( អាទិទេវីនៃព្រះសូរ្យា ) ទ្រង់បានទទួលនូវមហាមេឃជាមតិក ពីព្រះបរមរាជបិតាអ៊ិតសាណាគី, ព្រះអាទិទេពត្សុគីយ៉ូមី (អាទិទេពនៃព្រះចន្ទ) បានទទួលព្រះរាជអាណាចក្រ "និសា" ព្រះអាទិទេពស៊ុសាណូ ( អាទិទេពនៃពាយោ ) បានទទួលមហាសាគរ ដែលមានរលកប្រាំបីសែន ។

ព្រះនាងអាមាតេរាស៊ូជាព្រះអាទិទេវីនៃសូរ្យា ជានារីមានទ្រង់ទ្រាយប្រកបដោយសាច់ណែនពេញ មានកេសាវែង, មានព្រះនេត្រភ្លឺចាំង, មានព្រះរូបប្រកបដោយរស្មីផ្ទុះភ្លឺប្រាលផ្លេ ។

ក្នុងពេលនោះ ទទួលមានបេសកៈនៃព្រះអាទិទេព មកដល់ក្រាបចំពោះព្រះភក្ត្រនាង ហើយក្រាបបង្គំទូលព្រះនាងថា :

បពិត្រព្រះនាងដ៏ចំរើនអើយ, ទូលបង្គំខំតែមកក្រាបបង្គំទូលថា ព្រះ

រាមដែលជាអាទិទេពនៃរាយោ    បានហោះមកកាន់ព្រះរាជអាណាចក្រ ព្រះអង្គ៖ ព្រះរាមទ្រង់បន្ទូលព្រះស្មរស៊ីហនាទជំនូរឡារ ហើយគ្រវីព្រះខ័នគួរឲ្យខ្លាចពន់ពេក ។ នៅតាមផ្លូវនៃព្រះរាជដំណើរព្រះរាម , អ្នកខ្លាចតក់ស្លុត, អ្នកណាក៏រន្ធត់ញាប់ញ័រពន់ពេក... មានគេសួរគ្នាថា ម្ដេចក៏ព្រះអាទិទេពស្លុះទៅកាន់មហាមេឃ ចេញពីមហាសាគរដូច្នេះ ។

ព្រះនាងមាមាតេកាស៊ីទ្រង់កម្រើកប្រមោយានញាប់សម្បើមអស្ចារ្យ ។ ព្រះរាមព្រះអង្គតែងធ្វើឲ្យទ្រង់លំបាកជាច្រើនលើក៖ ឥឡូវនេះ ព្រះរាមនេះទ្រង់កាន់តែធ្វើព្រះនាង ឲ្យតក់ស្លុតរន្ធត់ខ្លាំង៖ តើព្រះរាមនេះធ្វើព្រះរាជដំណើរមកកាន់ទីនេះដើម្បីអ្វី ? ។

ព្រះនាងទ្រង់មានព្រះបន្ទូលដោយព្រះអង្គឯងថា៖    ហេតុដែលព្រះរាមទ្រង់យានមកកាន់ទីនេះ មិនមែនស្រួលទេ គឺប្រាកដជាមានរឿងអ្វីមួយមិនខាន, ប្រហែលជាព្រះរាមចង់ដេញអញចេញពីព្រះរាជអាណាចក្រ, តែអញប្រុងប្រៀបស្រេចនឹងតស៊ូ    ។

ព្រះនាងទ្រង់យាងទៅកាន់ទីដែលស្ថិតជិតមហាមេឃ ហើយប្រថាប់នៅមាត់ទីនោះ ។ ព្រះនាងទ្រង់ទ្រង់ស្ពាយប្រអប់តឹរ ដែលដាក់សរជាច្រើន៖ ទ្រង់យកស្រោមដៃមកស្រោបព្រះហស្តព្រះអង្គ, ទ្រង់បានកាន់ធ្នូធំសម្បើមអស្ចារ្យ យកទៅដាក់ពីមុខព្រះភក្ត្រព្រះនាង រួចទ្រង់ញែក

ព្រះធរណី ដូចគេញែកព្រីលទឹកកកដូច្នោះ ទ្រង់ក៏ចុះទៅស្ងួតនៅត្រើម ព្រះឩរុ ( ភ្លៅ ) ។

ព្រះនាងប្រុងប្រៀបរួចជាស្រេច ដើម្បីតយុទ្ធ នឹងពួកបច្ចាមិត្តដោយ សេចក្ដីក្លៀវក្លា ។

ឥឡូវនេះ ព្រះកាមនៃព្រះនាងទ្រង់យាងមកដល់, មានសភាពគួរឲ្យខ្លាច តក់ស្លុតរន្ធត់អស់អង្គ, គ្រវីសក់វែងអន្លាយ ហើយបន្លឺព្រះសូរសីហនាទ ខ្ទរខ្ទារខ្ទាំង, ព្រោះហេតុដូច្នោះ បានជាគេសន្មតនាមព្រះកាមថា "ព្រះបុរសឃោរឃៅ" ។ ព្រះកាមឈរប្រថាប់ជាត្រើយនទីម្នាង នៃមហាមេឃ ។ ព្រះនាងអាម៉ាតេរាស៊ូទ្រង់ស្រែកថា៖

ស៊ុសាណូ, ម្ដេចបងឯងមិនស្ងួតនៅដែនបងឯង ? ហេតុម្ដេចក៏បងឯងយាងមកកាន់ទីនេះ ដោយគ្មានអ្នកណាហៅគេសោះឡើយ ? ។

" ឱព្រះកនិដ្ឋា, បងមកនេះ ដើម្បីមកលេងកំសាន្ត " ហើយព្រះអា-ទិទេពក៏ទ្រង់ព្រះសម្រួល ។

ព្រះនាងទ្រង់នៅតែមិនទុកចិត្ត ។ ត្រូវតែស៊ុសាណូថ្លែងម្ដងទៀត បញ្ជាក់សេចក្ដីថា៖

បងចង់ឃើញប្អូន, បងមកលេងនឹងប្អូន, នេះជាហេតុដែលបងមក កាន់ទីនេះ ។ ម្ដេចក៏មានការប្រុងប្រៀបគ្រឿងប្រដាប់សង្គ្រាមដូច្នេះ

ម្តេចក៏មានគ្រឿងសស្ត្រាវុធយ៉ាងនេះ ? ចូរអូនបំផ្លាញគ្រឿងសស្ត្រាវុធនេះចេញ ។ សន្តិភាពប្រសើរជាងការសង្គ្រាម ? ចូរយើងព្រមព្រៀងគ្នាទាំងពីរនាក់ ប្រកាសសន្តិភាព ហើយចូរយើងស្រឡាញ់គ្នា ដោយភាតរភាព ។

ស៊ុសាណូហុចព្រះខ័នថ្វាររបស់ខ្លួន ទៅព្រះនាងអាម៉ាតេរ៉ាស៊ូ ទ្រង់ក៏យកព្រះខ័នថ្វានោះមកកាច់បំបាក់ជាបីកំណាត់ ។ ព្រះនាងទ្រង់បោះគ្រឿងសស្ត្រាវុធរបស់ខ្លួន ទៅថ្វាយព្រះរាម ៗ ក៏ផ្លុំទៅលើ គ្រឿងសស្ត្រាវុធទាំងនោះ រលាយអស់គ្មានសល់ ។

ស៊ូសាណូនឹងត្រូវព្រះនាងទទួលទៅទីនោះជាភ្ញៀវកិត្តិយស ។ តែភ្ញៀវនេះ មានបរិយាយមិនរម្យទម, ហោរហៅ, មិនមានសណ្តាប់ធ្នាប់សោះឡើយ ។

ព្រះអាទិទេពហោយាទ្រង់យាងទៅកាន់ទីណា, ទីនោះមិនអាចទប់ទល់នឹងវិទ្ធនភាពបាន, វត្ថុទាំងឡាយតែងធ្លាក់ចុះរួយអស់, របងដែលខាំងស្រែ រលំធ្លាក់បែកខ្ទេចខ្ទី, ដីធ្លាក់ពេញព្រែកដែលសម្រាប់ធ្វើជាកសាស្ត្រកសិកម្ម, សូម្បីតែប្រាសាទព្រះនាងក៏កម្រើកញាប់ញ័រទាំងអស់ ។

ព្រះនាងអាម៉ាតេរ៉ាស៊ូទ្រង់ព្រះក្រោធខ្លាំង តែទ្រង់លាក់សេចក្តីក្រោធនោះក្នុងព្រះរាជហឫទ័យ មិនឲ្យស៊ុសាណូជ្រាប ។

មានព្រឹត្តិការណ៍មួយថ្មី ធំសម្បើមអស្ចារ្យ ដែលនឹងបញ្ចេញសេចក្តីក្រោធព្រះនាងឲ្យផ្សាយមកក្រៅ ។

មានមួយថ្ងៃ, ព្រះនាងទ្រង់កំពុងគង់នៅបន្ទប់ដេរប៉ាក់អាវទេវតា. ទ្រង់មានព្រះនេត្រទំពៃត្រួតត្រានាងទេវធីតា កំពុងដេរប៉ាក់អាវសម្រាប់ពពួកទេវបុត្រ ទេវតានោះ, នាងខ្លះវៃអំបោះទិព្វ, នាងខ្លះត្បាញសំពត់ទិព្វ. នាងខ្លះប្រៀនសប្បាយ កំស្រាប់តែឮសូរសព្ទគឹកកងរំពងជាខ្លាំង ដែលជាហេតុឲ្យនាងទាំងនោះឈប់ធ្វើការទាំងអស់គ្នាគឺ ពីលើតំបូលត្រង់បន្ទប់ដេរប៉ាក់នោះ មានកូនពាជីមួយដែលគេបកស្បែកអស់ ធ្លាក់មកក្រោម ។

ក្នុងពេលនោះ នាងទេវធីតាក្រោកឈរឡើង រត់ប៉ាត់ប៉ាយ នាងខ្លះម្ជុលចាក់ដៃរបួស, ចេញឈាម, នាងខ្លះទទួលអនិច្ចកម្ម ក្នុងពេលនោះ ។

នេះជាអាកប្បកិរិយាកំប្លែងលេងសើច មិនសមគួរនៃអាទិទេពស៊ុសាណូ ។

ព្រះនាងអាមាតេរ៉ាស៊ូទ្រង់ទប់ទល់នូវព្រះក្រោធ លែងបានសោះឡើយ ហើយទ្រង់ក្តាប់ព្រះហស្ត សំដែងនូវព្រះកិរិយាជាយ៉ាងមហិមា ។ ព្រះនេត្រចេញផ្កាភ្លើង, ព្រះឃានញ័រជាខ្លាំង ។ ព្រះនាងទ្រង់បន្លឺនូវព្រះសូរសីហនាទសម្រេចថា នឹងលាក់បំពួនខ្លួនព្រះអង្គ បើអាទិទេពឯទៀតនៅតែអនុញ្ញាតឲ្យអាទិទេពស៊ុសាណូ ឋិតនៅលើព្រះរាជអាណាចក្រព្រះអង្គ ។

ព្រះនាងទ្រង់យាងថយទៅប្រថាប់លើថ្មក្ដិមួយ ដែលបិតជិតព្រះបរមរាជវាំង; ទ្រង់បានលៃលកធ្វើឲ្យទ្វារគុហានោះជាប់មុតមាំ ។

ព្រះសូរ្យោអស្ដង្គត ។ នៅមហាមេឃនឹងព្រះធរណីគ្មានរស្មីអ្វីសោះឡើយ គឺជាយប់ងងឹតសូន្យសុង ។

ពួកអាទិទេពសម្រេចថា នឹងប្រជុំគ្នានៅជើងក្លាយលើនភាល័យ ។ បន្តិច មានអាទិទេពមួយរូបយាងមកដល់ បន្តិចទៀតពីរ, រួចបី, បួន, ប្រាំ, ឥឡូវនេះ មានអាទិទេពចំនួនដប់រូប, មួយរយ, មួយពាន់, មួយម៉ឺន, មួយលាន ប្រាំបីលានរូប ។

អាទិទេពប្រាំបីលានរូប ទ្រង់យាងមកជួបជុំ នៅជើងក្លាយព្រះសូរសព្ទ ដូចសូររុយហើរពេលវស្សានរដូវជ្ជោះ ។

ពួកអាទិទេពទាំងនេះ បានសន្ទនាគ្នានឹងគ្នាថា ត្រូវរកមធ្យោបាយយ៉ាងណា ដើម្បីឲ្យព្រះនាងអាមាតេរ៉ាស៊ូទ្រង់យាងចេញមកវិញបាន ។

ពួកអាទិទេព ក៏ទូលស្នើទៅអាទិទេព ដែលប្រមូលចិន្តា ទ្រង់ព្រះនាម តក មី-មុស៊ីប៊ី ជាអាទិទេពឧបាយកល ។

អាទិទេព តក មី-មុស៊ីប៊ី ទ្រង់មានបន្ទូលតបមកថា: "ប្រហែលជាបាន ព្រោះថា ព្រះនាងអាមាតេរ៉ាស៊ូចំណាំតែចេញពីប្រាសាទកាលណា ព្រះនាងទ្រង់ពុំមានរង្គៀ " ។

កូនមួយរំពេច គេក៏យកបង្អោងឈើមកដាក់ហើយគេយកមាន់ដែលមានស្លាបរលើបរលោងហើយមាត់កមាំ មកឲ្យទំលើបង្អោងនោះ ។

មាន់នោះក៏រងាវ តែគេមិនបានឃើញរស្មីព្រះសូរិយាដែលធ្លាប់តែចាំងពេលបច្ចូសសម័យនោះឡើយ ។ ព្រះនាងទ្រង់ក៏មិនបានចេញមកសោះ ។

អាទិទេពទាល់ឧបាយកល ទ្រង់ក៏គិតធ្វើផែនការមួយផ្សេងទៀត ។ ទ្រង់ព្រះតម្រិះថា ព្រះនាងអាមាតេរ៉ាស៊ូកេទស្រី . . . បើប្រសិនជាធ្វើកិច្ចការអ្វីមួយ ដោយយកលំអជាបុព្វហេតុ នាំឲ្យទ្រង់មានព្រះរាជហឫទ័យប្រណែននឹងស្ត្រីណាមួយ ដែលមានរូបកាយល្អសមសួនជាងព្រះនាង ប្រហែលជាព្រះនាងចេញមកមិនខាន ។

ពួកអាទិទេពក៏ទ្រង់ចាត់ឲ្យហៅព្រះវិស្សកម្មទេវបុត្រ ដែលមានព្រះនេត្រតែមួយ, ហើយត្រាស់បង្គាប់ឲ្យធ្វើកញ្ចក់មួយ ដែលគេយកទៅបញ្ឈរបំពីមុខគុហាជិតគ្រោងទ្វារចូលប្រាសាទព្រះនាង ។ នៅពីលើកញ្ចក់នោះគេយកខ្សែរតនឹងផ្កាយឯទៀតព្រមទាំងព្រះពស្រួស, ទៀនមកដាក់ ។

នៅជិតគុហានោះ, គេបានយកក្តារមកក្រាលលើដើមម៉ាវីង, ហើយគេចាត់ឲ្យនាងទេវធីតាអ៊ុហ្សមេរាំនៅលើនោះ ។

តើគេនឹងឃើញរស្មីព្រះសូរិយាចាំងពីក្នុងគុហាមកឬ ? ឬក៏ព្រះនេត្រ

នៃពួកអាទិទេពមិនធ្លាប់ឃើញនៅក្នុងទីនឹងត ? ។

តែពួកអាទិទេពទាំងអស់ទ្រង់ទតទៅឃើញ ព្រះនាងអាមាតេរ៉ាស៊ូដែរ, ហើយទ្រង់មានព្រះរាជហឫទ័យសោមនស្សជាមុន បើប្រសិនជាទ្រង់ទតទៅឃើញព្រះភ័ក្ត្រព្រះនាងមូល, ភ្លឺសប្បាយ, ថ្ពាល់ធំ មានសកៈពពង រៀវបន្តិច ។

នៅលើដើមម៉ៃវ៉ែង នាងទេវធីតាអ៊ីហ្សូមេកុំ ។ នាងរាំមានលំនាំគួរឲ្យសើច សប្បាយរីករាយពន់ពេក ។ ពួកអាទិទេពទ្រង់លេងកំសាន្តសប្បាយ ។ គេបានឮសូរស័ព្ទព្រមទាំងសំណើច នៃពួកអាទិទេពដែលធ្វើឲ្យដើងក្លាយកក្រើកអំពើកជាខ្លាំង ។

ព្រះនាងអាមាតេរ៉ាស៊ូទ្រង់ព្រះសណ្ដាប់នូវសំណួរតឹកកង់រំពងដូច្នោះ មានព្រះរាជហឫទ័យឆ្ងល់ពន់ពេក, ទ្រង់ចង់ជ្រាបណាស់អំពីរឿងរ៉ាវ ដែលមានក្នុងពេលនោះ ។ ទ្រង់ក៏បើកទ្វារគុហានោះឡើង, មិនទាន់បានទតមកក្រៅផង ទ្រង់ក៏មានព្រះសូរសីហនាទថា :

“ ខ្ញុំគិតថា ការដែលខ្ញុំធ្វើដំណើរទៅនេះ នាំឲ្យលោកអ្នកព្រួយបារម្ភខ្លាំង, តែមិនដូច្នោះ, ទៅជាលោកអ្នកសប្បាយចិត្តទៅវិញ ។ ឱពួកអាទិទេពទាំងប្រាំបីលានរូប, លោកទាំងអស់គ្នា ម្ដេចក៏ទៅជាសើចក្អាកក្អាយសប្បាយទៅវិញ ” ។

( មានត )

# រឿងអ្នកគង្វាលចៀមចិត្តស្លូតត្រង់និងព្រះរាជធីតា

លោក ផើង-ជ្រីវ នៅក្រសួងឃោសនាការជាតិ

ប្រែចាកសៀវភៅ កុនត៍អេឡេសង់ដ៍ ដឺរ៉ូម៉ានី

( តមក )

( Contes et Légen des deRoumanie. )

---

ចំណែកអ្នកគង្វាលយើងក៏ឡើងទៅទៀត ៗ លុះទៅដល់ត្រង់កន្លែងកំពូលចុងទៀប មាណពស្រាប់តែជួបជាស្ថិតនៅក្នុងប្រាសាទកែវមួយ ហើយនឹកក្នុងចិត្តថា: ហ្នឹងហើយ ប្រាកដជាលំនៅរបស់ព្រះយមរាជ ៗ អើផ្លែមាសអើនុ៎ះ ! និយាយក្នាម បេះក្នាម ៗ លុះយកផ្លែទៀបដាក់ក្នុងហោប៉ៅហើយ ក៏សំរូតចុះមកវិញ ៗ

ប៉ុន្តែ ខណៈនោះ ការរញ្ជួយកម្រើកតាំងពីចុងរហូតដល់គល់ទៀប ផែនដីញាប់ញ័ររបណ្ដាយ ហើយសូរសព្ទយ៉ាំងខ្លាំងនោះ ក៏ឮដល់ព្រះសោតនៃព្រះយមរាជ ៗ ស្ទុះហោះមកវិញ ដេញតាមកិតពីក្រោយខ្នង ៗ គេភ័យញាក់ដូចគ្រុន តែមិនព្រមលះបង់ចោលផ្លែទៀប ហើយសូមអង្វរថា: បពិត្រព្រះអង្គជាអម្ចាស់ . សូមព្រះគុណមេត្តាអត់ទោស ដល់ខ្ញុំម្ចាស់

សូមព្រះគុណប្រទានផ្លែទៀបទាំងនេះឲ្យខ្ញុំម្ចាស់ . . . . ៗ ព្រះរាជា-ធិរាជនឹងព្រះរាជធីតា មិនដឹងជាទ្រង់អត់សង្កត់ព្រះរាជហឫទ័យ ដើម្បីចាំមើលផ្លូវ ខ្ញុំម្ចាស់យ៉ាងណាទេ !

– ណ្ហើយអ្នកកំឡោះប្ដូរយកចុះ ដ្បិតឯងចេះនិយាយតទ្វរអញដោយត្រឹមត្រូវល្អ ! អញឲ្យផ្លែនេះដល់ឯង ហើយប្ដូរផ្លែទៀបជួយឲ្យឯងបានសេចក្ដីសុខសួស្ដី ៗ

អ្នកពល់គ្នាឃើញថ្មូទេ សូម្បីព្រះយមរាជដែលជាទេវតាមិនដែលអត់ទោសឲ្យដល់អ្នកណាម្នាក់ គង់មិនអាចទប់នឹងសេចក្ដីអង្វររបស់អ្នកគង្វាលចិត្តស្លូតត្រង់ ហើយអ្នកកំឡោះក៏ចុះមកទៀត ចំណែកព្រះយមរាជត្រឡប់ទៅឯទៅកាន់ប្រាសាទកែវវិញ ឈប់សម្រាកមួយស្របក់ មុននឹងត្រាច់ទៅរកកត់បញ្ជីកូនដីដទៃទៀត ៗ

អ្នកគង្វាលចិត្តស្លូតត្រង់ ចូលទៅកាន់សំណាក់លោកតាព្រះកេតុនិយាយអរគុណចំពោះលោក រួចសូមលាលោកចុះមកទៀត តាំងពីកក្អែកហោម ៗ តមក គេបានដល់សំណាក់យាយព្រះសៅរ៍ យកសេះទាំងពីរ ហើយនាំទាំងនាងក្រមុំយកមកផង ៗ លុះដល់សំណាក់យាយព្រះសុក្រ គេចូលលាគាត់ហើយចុះមកទៀត រហូតដល់ព្រះបរមរាជវាំងនៃព្រះចៅ ៗ

វេលាដែលមុននឹងចុះដល់ដី គេឲ្យកូនស្រីរបស់យាយព្រះសៅរ៍ នឹងសេះ លោកហាក់ទៅឈប់ចាំឯក្នុងព្រៃមួយឆ្ងាយបន្តិច ចំណែកខ្លួនចុះជាមួយនឹងសេះមួយរហូតមក ។

បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គស្តេចទតចុះ ទឹកក្នុងកែវតមានទេវតាអ៊ីបន្តិច ហើយនេះផ្លែទៀបមាស សូមព្រះអង្គទត ដោយព្រះហឫទ័យរីករាយ ។

ព្រះចៅរាជាធិរាជ ស្តេចទតផ្លែទៀបមាស ដោយព្រះទ័យស្នេហា ព្រមទាំងអ្នកគង្វាលចៀម ដែលទ្រង់ឈប់សំគាល់ទុកជាអ្នកគង្វាលសាមញ្ញ គឺទ្រង់ទុកជាមនុស្សដែលផុតវិស័យនឹងគិត ហើយទ្រង់មានព្រះបន្ទូលថា : ចំដាអស្ចារ្យមែន ! នេះគឺជាអភូតបុព្វហេតុ ! ។

ព្រះចៅរាជាធិរាជ ព្រះរាជបិតា ព្រះរាជអគ្គមហេសី និងព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី ដែលនឹកស្មានថា អ្នកគង្វាលប្រហែលជាស្លាប់បាត់ជាយូរណាស់ទៅហើយ ស្រាប់តែនាំគ្នាកោតសរសើរ នូវកិច្ចការដែលគេបានបំពេញដោយម៉ឺតចត់នេះ ។ ប៉ុន្តែអ្នកដែលសប្បាយជាងគេ តើគឺអ្នកណា ? យើងអាចទាយត្រូវឥតពីបាកទើយ ។ អ្នកគង្វាលក្រាបបង្គំទូលថា :

បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឥឡូវនេះ សូមព្រះអង្គទ្រង់នូវពាក្យសត្យ ហើយសូមព្រះទាននូវព្រះរាជដីកាដល់ទូលព្រះបង្គំ ។

គេក៏ឲ្យព្រះអង្គម្ចាស់ក្សត្រីដល់អ្នកគង្វាល តើគេនឹងទៅវាំអ្វីទៀត ។

មិនយូរប៉ុន្មាន អ្នកគង្វាលលើកព្រះរាជដីកាដាក់លើខ្នងមនោម័យ ហើយហោះទៅកាន់ព្រៃ ដែលកូនយាយព្រះសៅរនៅរង់ចាំក្នុងទីនោះ ។ រូបអ្នកទាំងអស់គ្រាប់ទៅជាមួយគ្នា ទៅកាន់សំណាក់អ្នកគង្វាលជាបង ដែលតាំងពីបីឆ្នាំមកហើយ តែងធ្វើបុណ្យនិងសូត្រធម៌ឧទ្ទិសផលជូនដល់វិញ្ញាណក្ខន្ធរបស់ប្អូន ដែលគាត់ស្មានថាជាធ្វើមរណកាលរូបទៅហើយឯក្នុងព្រះបរមរាជវាំង ។

លុះឃើញប្អូនទៅដល់ មុនដំបូងបងយកដៃជូតភ្នែក ដោយស្មានថា ខ្លួនដេកយល់សប្តិ ។ រូបគាត់តាំងតែស្រែកហៅ ស្ទុះទៅឱបប្អូនដោយសេចក្តីត្រេកអររកអ្វីប្រៀបគ្មាន ។ គាត់ស្មានថាជាក្បាលរបស់ប្អូនគាត់ទៀងតែគេដោតនៅឯចុងបង្គោលរបងទៅហើយ ។ បងសួរថា: ចុះពីមុនឯងនៅឯណា ? ក្នុងរាំងពេលនោះតើឯងធ្វើអ្វី ? រឿងនេះត្រូវតែនិយាយប្រាប់គាត់ឲ្យសព្វគ្រប់ ប៉ុន្តែប្អូនបានសម្រេចថា: បពិត្រអ្នកបង ណ្ហើយឈប់ពីយរាប់រឿងហ្នឹងសិនចុះ ។ តើអ្នក

បងបានជួយថែរក្សាចៀមរបស់ខ្ញុំបានផងឬទេ ? ចំណែកខ្លួនខ្ញុំៗ បាននាំប្រពន្ធមួយមកជូនអ្នកបង រូបគេបង្ហាញកូនស្រីយាយព្រះសៅរ៍ ហើយនាងក៏មិនមានសេចក្ដី យល់ទាស់ឡើយ ។

គ្រានោះអ្នកទាំងអស់ពេញដោយសេចក្ដីរីករាយតែសព្វខ្លួន ក៏នាំគ្នាវិលទៅកាន់ព្រះបរមរាជវាំងវិញ ។ ហើយមង្គលការអាពាហ៍ពិពាហ៍របស់បងប្អូនទាំងពីរ ក៏កើតឡើងក្នុងព្រះបរមរាជវាំង ដែលអ្នកទាំងពួងតែងនាំគ្នានិយាយតៗមក ។

ចប់ ។

ខ្មាសគ្រូគ្មានវិជ្ជា ខ្មាសភរិយាពុំមានកូន
ខ្មាសការងារសោះសូន្យ ខ្មាសបងប្អូនគ្មានភៀវទៀង
ខ្មាសទាសខានប្រើការ ខ្មាសអាហារពោះក្រៀមក្រើង
ខ្មាសយសស័ក្តិពុំថ្កើង ខ្មាសអ្នកយើងខានធ្វើបុណ្យ
ខ្មាសបារីគ្មានអាជ្ញា ខ្មាសមុសាលក់ខាតទុន
ខ្មាសសិស្សខានដើរមុន ខ្មាសព្រះគុណខានធ្វើកាប
ខ្មាសកូនខានប្រដៅ ខ្មាសញាតិផៅសៅអំណាប
ខ្មាសខ្លៅទើបគេខ្លាប ខ្មាសអ្នកប្រាជ្ញហៅព្រើលធំ ៗ

*ពាក្យព្រេនតែងប្រតិស្ឋ ប្រដៅសិស្សដោយន័យម*
*និយាយតាមបរម បុរាណថាទុកជូនចុះ* ៗ
*ឯពាក្យគ្រូអាចារ្យ បំណងការឲ្យសិស្សចេះ*
*បង់ឲ្យមានចំណេះ បង់ឲ្យចេះតែគ្រប់គ្នា* ៗ

# រឿងចៅបាយក្តាំង

## លោក ទៀង តែ-ឈុន

ប្រែរៀបរៀង ( តមក )

---

ប្រាក់មួយផង លុះបន់ស្រន់រួចស្រេច, ចៅបាយក្តាំងយកកែវមណីជោគ គ្រវីមួយជុំហើយពោលថា សូមឲ្យលោកម្ចាស់ជួយបំផុសវត្ថុខាងលើនេះ តាមបំណងខ្ញុំ! ។

កាលណោះ ចៅបាយក្តាំងគ្រវីត្បូងទិព្វបានបីជុំ, ស្រាប់តែកើតស្ពានមាស-ប្រាក់មួយនិងប្រាសាទមាសមួយយ៉ាងត្រចះត្រចង់អស្ចារ្យ ។

ចៅបាយក្តាំងសប្បាយរីករាយឥតឧបមា ដោយយល់ឃើញថា ខ្លួនបង់បានរបស់អ្វី, របស់នោះផុះឡើងដូចសេចក្តីប្រាថ្នា ហើយដើម្បីពិសោធន៍មើល, ចៅបាយក្តាំងនិយាយថា ឱ លោកម្ចាស់, ខ្ញុំបង់ឲ្យរបស់ទាំងនេះរលាយបាត់ទៅវិញ ។

បន្ទាប់មក, ប្រាសាទមាស និងស្ពានមាស ប្រាក់ក៏បាត់អស់ទៅវិញ ដូចបំណងមែន ។

លុះយប់ស្ងាត់ពិតប្រាកដហើយ ចៅបាយក្តាំងដើរដម្រង់ទៅរកព្រះបរមរាជវាំង ទិសខាងជើង ។ នៅទីនោះ ចៅបាយក្តាំងបួងសួងសុំឲ្យកើតប្រាសាទមាសមួយ និងស្ពានមាស-ប្រាក់មួយផង ដោយគ្រវីកែវមណីជាតិបីជុំដូចលើកមុន ។ ពេលនោះស្ពាន និងប្រាសាទកើតឡើង មានរស្មីភ្លឺព្រោងព្រាតពាសពេញផ្ទៃមេឃ ។

វត្ថុអស្ចារ្យទាំងនេះកើតមានស្រេចអស់ហើយ, ចៅបាយក្តាំងត្រឡប់មកផ្ទះដេកវិញ ។

លុះថ្ងៃព្រឹកស្អែក, ព្រះរាជាទ្រង់បើកបង្អួច ហើយទតទៅទិសខាងជើងព្រះបរមរាជវាំង ឃើញប្រាសាទមាស និងស្ពានមាសប្រាក់ ពេលរស្មីត្រចះត្រចង់ពាសពេញផ្ទៃមេឃដូច្នោះ, ព្រះអង្គទ្រង់ចាត់ព្រះរាជបំរើម្នាក់ទៅស៊ើបសួរពីវត្ថុអស្ចារ្យនេះ ។

ព្រះរាជបំរើត្រឡប់មកទូលព្រះរាជាថា សូមទ្រង់មេត្តាប្រោស, គ្មានអ្នកណាដឹងរឿងដែលប្រាសាទមាស និងស្ពានមាសប្រាក់ ដែលផុះមកនេះទេ ។

តមកទៀត, ព្រះមហាក្សត្រិយ ទ្រង់ត្រាស់បង្គាប់ឲ្យហៅដូនចាស់មកហើយ ទ្រង់មានព្រះបន្ទូលថា នែយាយ, កាលណោះខ្ញុំបានដាក់កំហិតឲ្យចៅយាយធ្វើតាមបំណងខ្ញុំដែលខ្ញុំស្មានថា មិនអាចនឹងធ្វើឲ្យសម្រេច

បាន ៗ ឥឡូវនេះ ហេតុនិមិត្តកើតបានត្រូវទាំងនេះដោយសារហេតុ មន្តអាគម ៗ បើដូច្នេះ យាយទៅហៅចៅយាយមក, ខ្ញុំផ្សំផ្គុំនឹងកូនស្រីខ្ញុំ ៗ កាលបើព្រះរាជទានការហើយ, ជូនចាស់គេទៅប្រាប់ចៅបាយក្តាំង នៅពេលនោះ ព្រះរាជាទ្រង់ត្រាស់បង្គាប់ ទៅរដ្ឋមន្ត្រី ឲ្យរៀបចំសង់រោងធ្វើអាពាហ៍ ពិពាហ៍ ៗ

លុះដល់ថ្ងៃកំណត់ចូលរោង, ព្រះមហាក្សត្រទ្រង់ត្រាស់បញ្ជាព្រាហ្មណ៍នឹងបុរោហិត ឲ្យទៅប្រសិទ្ធពរដល់ចៅបាយក្តាំង នឹងព្រះអង្គម្ចាស់ក្សត្រី ជាទីបង្ហើយកិច្ចនៃអាពាហ៍ពិពាហ៍ ៗ

បន្ទាប់មក, ចៅបាយក្តាំងចាត់បំរើទៅនាំយាយ, ឆ្កែ, នឹងឆ្មាមកនៅប្រាសាទអស្ចារ្យនេះជាមួយគ្នា ដោយសុវត្ថិភាព ៗ

មានកាលថ្ងៃមួយ, មានស្តេចមួយព្រះអង្គ មានព្រះចិន្តាប្រណាននឹងប្រទេសខ្មែរ, ព្រោះប្រទេសនេះមានប្រាសាទនឹង ស្ពានល្អអស្ចារ្យណាស់ៗ កំពែងព្រះបរមរាជវាំងធ្វើសុទ្ធតែអំពីមាសនឹងប្រាក់ ហើយដាំពេជ្រទាំងអស់ ៗ ស្ពានក៏ល្អដូច្នោះដែរ ៗ. ជាហេតុឲ្យព្រះរាជអាណាចក្រកម្ពុជារុងរឿងនឹងសប្បាយសម្បូណ៌ ដោយភោគសម្បត្តិ ប្រកបដោយកិត្តិសព្ទយ៉ាងក្រៃលែង ៗ ប្រជារាស្ត្រស្គាល់តែសេចក្តីសុខសាន្តនឹងសិរីសួស្តី ៗ

ស្តេចប្រណេននេះ, ទ្រង់ត្រាស់បញ្ជារដ្ឋមន្ត្រីឲ្យផ្គុំកនូវគ្រឿងសាវុធគ្រប់មុខ មានកាំភ្លើងធំជាដើមពេញកប៉ាល់សមុទ្រ ហើយលើកកងទ័ពមកវាយប្រទេសខ្មែរ ដែលកំពុងស្គាល់តែស្តេចក្តីសប្បាយសម្បូណ៌ ដោយភោគសម្បត្តិយ៉ាងអស្ចារ្យ ដើម្បីបង្ក្រាបព្រះរាជអាណាចក្រនេះយកធ្វើជាស្រុកចំណុះប្រទេសព្រះអង្គ ។

លុះកប៉ាល់ចម្បាំងបានបោះយុថ្កានៅក្នុងប្រទេសខ្មែរហើយ ស្តេចប្រណេនទ្រង់ចាត់ដោយរួសរាន់នូវទូតម្នាក់ ឲ្យទៅបន្ទំព្រះរាជាខ្មែរ ដើម្បីឲ្យទទួលស្គាល់ព្រះអង្គជាអធិរាជ ។ ព្រះអង្គទ្រង់យកសារលិខិតចុះចូល ដែលសរសេរលើបន្ទះមាស ទៅថ្វាយស្តេចបច្ចាមិត្រចំពោះព្រះភក្ត្រ ។ បើព្រះរាជានេះទ្រង់មិនព្រមទេ, ស្តេចប្រណេននឹងរៀបចំធ្វើចម្បាំង ។

កាលណោះ, ស្តេចខ្មែរទ្រង់មានព្រះចិន្តាទុក្ខព្រួយយ៉ាងខ្លាំង, ព្រះអង្គទ្រង់ត្រាស់បញ្ជាឲ្យរដ្ឋមន្ត្រី និងនាយទាហានទាំងអស់ ឲ្យមកគាល់ព្រះអង្គ ហើយទ្រង់មានព្រះបន្ទូលថា លោកទាំងឡាយ! ឥឡូវនេះប្រជារាស្ត្ររបស់ស្តេចប្រណេននឹងប្រទេសយើង ដែលមានទ្រព្យសម្បត្តិច្រើន បានកាន់អាវុធគ្រប់គ្នាមកបង្ក្រាបយើង ឲ្យចុះចូលតែម្តង ។ បើយើងមិនសុខចិត្តចុះចូលទេ, ត្រូវតែយើងធ្វើចម្បាំង ។ ដូច្នេះ, ក្នុងចំណោមពួកយើងទាំងអស់គ្នា, មានលោកណាម្នាក់ មានសមត្ថភាពអាចហ៊ានលើកទ័ពទៅច្បាំង នឹង

បច្ចាមិត្រ ឬទេ? ។ ពេលនោះ, គ្មានទាហានណាមួយ ហ៊ានឆាន់អាសាទទួលធ្វើការនេះឡើយ ។

បន្ទាប់មក, ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យទៅនាំចៅបាយក្តាំងមក ហើយមានព្រះបន្ទូលថា: កូនជាទីស្នេហា, ឥឡូវនេះ មានស្តេចបច្ចាមិត្រមួយព្រះអង្គ បានលើកទ័ពមកវាយដណ្តើមយកនគរយើង, ឯងមានសមត្ថភាពនឹងធ្វើចម្បាំងនោះបានឬទេ? ។ ចៅបាយក្តាំងក្រាបទូលទៅព្រះបរមរាជបិតាក្មេកថា: សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំច្បាំងដោយពិត ។

- កូនឯងត្រូវការទាហានប៉ុន្មាននាក់? ។

- ទូលព្រះបង្គំជាខ្ញុំមិនត្រូវការទ័ពទេ ។ ទូលព្រះបង្គំជាខ្ញុំច្បាំងតែម្នាក់ឯង ។

- យីអើ! កូនសំឡាញ់! ឯងគិតតយុទ្ធនឹងទ័ពគេច្រើនយ៉ាងនេះ តែម្នាក់ឯង ហើយឲ្យមានជ័យជំនះថែមទៀត? ។

- សូមទ្រង់ព្រះមេត្តាប្រោស ព្រះអង្គកុំព្រួយព្រះទ័យពីទ័ពគេច្រើននោះឲ្យសោះ ។

បន្ទាប់មក, ចៅបាយក្តាំង លំអុតកាយថ្វាយបង្គំលាព្រះបរមរាជ

បិតាក្មេក ហើយត្រឡប់ទៅប្រាសាទទិព្វវិញ ដើម្បីរៀបចំទៅច្បាំង ។ មុននឹងចេញទៅ, ចៅបាយក្តាំងសំប៉ុងសង្រួនបង្វិលកែវមណីជោតិ ស្រាប់តែកើតមានទ័ពយ៉ាងច្រើនក្រាម មានកាំភ្លើងធំតូចគ្រប់បែបគ្រប់យ៉ាង ។

ចៅបាយក្តាំងនាំទ័ពទិព្វទាំងនេះទៅច្បាំង នឹងទ័ពរបស់ស្តេច-ប្រៃណានៗ

ទ័ពបច្ចាមិត្របរាជ័យ ក៏ថយអស់ទៅ ។ ចៅបាយក្តាំងទៅព្រះបរមរាជវាំង ក្រាបបង្គំទូលព្រះបរមរាជបិតាក្មេកថា ខ្ញុំច្បាំងមានជ័យជំនះហើយ ។ ឯទ័ពសត្រូវក៏បាក់បែកខ្ចាត់ខ្ចាយ ថយទៅបាត់អស់ឥតមានសេសសល់ឡើយ ។ លុះបានដំណឹងថា កងទ័ពសត្រូវចាលចាញ់គេជដៃរត់បាត់អស់ទៅហើយ, ព្រះរាជាទ្រង់មានព្រះរាជហទ័យត្រេកអរយ៉ាងក្រៃលែង ។ ចៅបាយក្តាំងក្រាបបង្គំលាព្រះបរមរាជបិតាក្មេកត្រឡប់ទៅប្រាសាទទិព្វវិញ ។

កាលណោះ, ស្តេចសត្រូវទ្រង់គិតក្នុងព្រះចិន្តាថា “ ខ្មែរដែលមានអនុភាពយ៉ាងដូច្នេះ ដោយសារមានកែវមណីជោតិពិតប្រាកដ” ។

ស្តេចប្រៃណាន កាលបើព្រះអង្គទ្រង់ត្រិះរិះយ៉ាងនេះហើយ ទ្រង់ត្រាស់ចាត់ព្រះរាជបំរើម្នាក់ដោយរួសរាន់ ឲ្យទៅសូមធ្វើជាអ្នកបំរើចៅបាយ .

ក្តាំង ដើម្បីនឹងលួចយកត្បូងទិព្វ ។

លុះចូលបំរើបានបន្តិចទៅ, ចៅបាយក្តាំងមានសេចក្តីទុកចិត្តលើព្រះរាជបំរើនោះយ៉ាងពេញលេញ ហើយក៏ប្រគល់កែវមណីជោតិឲ្យថែរក្សា ។

ព្រះរាជបំរើនេះគិតថា “ព្រះអង្គដែលជាចៅហ្វាយអញ ទ្រង់ផ្តាំថា ឲ្យយកកែវមណីជោតិ ទៅថ្វាយព្រះអង្គឲ្យបាន, ឥឡូវ គេឲ្យអញថែរក្សារតនវត្ថុនេះ, បើដូច្នេះអញលួចកែវនេះ យកទៅថ្វាយព្រះអង្គបានដោយងាយ” ។ ដំណើរនេះហើយបានជា ព្រះរាជបំរើរបស់ស្តេចសត្រូវនឹងស្តេចខ្មែរ លួចបានយកកែវមណីជោតិ ពីចៅបាយក្តាំងទៅថ្វាយព្រះមហាក្សត្រ ដែលជាចៅហ្វាយខ្លួន ។ កាលបើបាន ត្បូងពេជ្រនេះ ស្តេចបច្ចាមិត្ត ទ្រង់មានព្រះរាជហឫទ័យសប្បាយរីករាយយ៉ាងក្រៃលែង ហើយទ្រង់លើកទ័ពទៅវាយដណ្តើមព្រះរាជអាណាចក្រ របស់ចៅបាយក្តាំងម្តងទៀត ។ ចៅបាយក្តាំងបរាជ័យ, ស្តេចសត្រូវទ្រង់ចាប់ស្តេចខ្មែរនឹងអគ្គមហេសី ព្រមទាំងប្រជាជនជាច្រើន យកទៅធ្វើជាឈ្លើយសង្គ្រាម ។ ប៉ុន្តែ កាលណោះ ចៅបាយក្តាំងរត់រួច ។ ចៅបាយក្តាំង ហៅក្អែកនឹងឆ្មាមកជិត ហើយនិយាយថា នែក្អែកប្អូន! ឆ្មាប្អូន កាលៈទេសៈនេះ ឯង

ចាំងពីរនាក់ត្រូវជួយអញ ៗ បើកាលណាអញបានធ្វើស្តេច, អញតាំងម្នាក់ ឲ្យធ្វើរដ្ឋមន្ត្រីទំពាដើងទឹក, ម្នាក់ទៀត អញឲ្យធ្វើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៗ អញទុកចិត្តលើឯងទាំងពីរ ដើម្បីទៅយកកែវមណីជោតិ ដែលស្តេចបច្ចា-មិត្តបានលួចយកទៅ ដោយសារតែត្បូងទិព្វនេះហើយ ទើបស្តេចនេះ បង្កាំងឈ្មោះយើងដូច្នេះ ៗ

ក្អែកនិងឆ្មាឆ្លើយថា: កុំព្រួយឲ្យសោះ យើងខ្ញុំទៅយកកែវនោះឲ្យបាន តាមបង្គាប់ ៗ

បន្ទាប់មក, ក្អែកនិងឆ្មានាំគ្នាទៅទាំងពីរនាក់ ៗ លុះទៅដល់មាត់ស-មុទ្រ, ក៏ឃើញក្រពើកំពុងហែលទឹក ៗ ក្អែកនិងឆ្មាបង្កួតហៅក្រពើ ហើយ និយាយថា: អើបងក្រពើ, អាណិតប្អូនយើងទៅត្រើយម្ខាងផង ៗ ក្រពើព្រម ៗ នៅពេលកំពុងឆ្លង, ក្អែកដែលអង្គុយលើក្បាលក្រពើកិតកយខ្លាំងពេក ក៏លេចអាចម៍លើកញ្ចឹងកដំនេះវា ៗ លុះបានដល់ទៅមាត់ច្រាំងសមុទ្រម្ខាងហើយ, ក្អែកនិងឆ្មាលោតទៅលើដី ហើយអង្វរក្រពើឲ្យ នៅរង់ចាំគេមកទៀត, ក្អែក និង ឆ្មា នាំគ្នាដើរតម្រង់ទៅរកព្រះបរមរាជវាំង នៃស្តេច ដែលលួចកែវមណីជោតិ ៗ នៅតាមផ្លូវ ឆ្មាគិតតែម្នាក់ឯងថា " ក្អែកវាបេះតែរកអាហារក្រោមខ្ទមប៉ុណ្ណោះទេ " ៗ

លុះពេលយប់ឆ្មាដើរក្រឡេងជុំវិញមហាប្រាសាទ ស្រាប់តែប្រទះឃើញស្តេចកណ្តុរសប្រែងមួយ កំពុងស្ទុះស្ទើររកអាហារ ៗ ឆ្មាស្ទុះដោយលាក់លៀម ទៅចាប់កណ្តុរនោះបាន ៗ ស្តេចកណ្តុរនោះអង្វរឆ្មាថា: ឱបងឆ្មា, បើបងស៊ីខ្ញុំ តើនឹងបានឆ្អែតប៉ុន្មានថ្ងៃ? ទុកអាយុជីវិតខ្ញុំផង កាលណាបងមានទុក្ខធុរៈអ្វី ៗ ខ្ញុំធានាអះអាងនឹងជួយដោះស្រាយទុក្ខធុរៈនោះ ៗ ឆ្មាឆ្លើយថា: ណ្ហើយចុះម្ចាស់កណ្តុរស, បើឯងជួយយកកែវមណីជាតិរបស់ចៅហ្វាយអញ ដែលស្តេចទីក្រុងនេះលួចមកនោះ អញនឹងលែងឯងឲ្យរស់ជីវិត ៗ អញដឹងដំណឹងថា ត្បូងទិព្វនេះ ស្តេចទ្រង់ទុកដាក់ក្នុងទូដែកហើយចាក់សោជិត កណ្តុរឆ្លើយថា ខ្ញុំសន្យាយកកែវនោះមកឲ្យបង ៗ កាលបើបានឮពាក្យសន្យាយ៉ាងនេះហើយ ឆ្មាក៏លែងស្តេចកណ្តុរសនោះឲ្យរួចខ្លួន ៗ លុះបានរួចពីគ្រោះថ្នាក់, ស្តេចកណ្តុរសថយខ្លួនប្រញាប់ដើម្បីទៅប្រមូលកណ្តុរទាំងឡាយ ដែលនៅក្រោមអំណាចខ្លួន ៗ តាមបង្គាប់របស់ស្តេចខ្លួន, កណ្តុរទាំងនោះ នាំគ្នាទៅកកេរទូដែកទាល់តែធ្លុះពីម្ខាងទៅម្ខាង ៗ កណ្តុរខ្លះបាក់ធ្មេញអស់ នៅសល់តែធ្មេញមុខពីរ ៗ ទោះបីយ៉ាងដូចម្តេច កណ្តុរទាំងនោះយកបានត្បូងទិព្វ ទៅ

ប្រគល់ឲ្យឆ្មាជាស្រេច ៗ លុះបានកែវមណីជោតិនេះ ឆ្មាសំដែងសេចក្ដីអរគុណដល់កណ្ដុរទាំងនោះ ហើយនាំឆ្កែត្រឡប់ទៅនគរវិញ ៗ ក្រពើក៏បានចម្លងឆ្មានឹងឆ្កែ ទៅដល់ត្រើយម្ខាងវិញ ៗ

បន្ទាប់មក ឆ្មានឹងឆ្កែ ដើរដល់ស្ទឹងមួយ ៗ ឆ្កែ និយាយទៅកាន់ឆ្មាថា ប្អូន ! ឲ្យកែវមណីជោតិមកអញ ១ បន្តិច ៗ ឆ្មាឆ្លើយថា: អញមិនឲ្យទៅឯងទេ ៗ ឯងជាសត្វនិយាយច្រើន ៗ អញខ្លាចក្រែងឯងឃើញវត្ថុអ្វី ១ ឯងព្រុះហើយធ្លាក់ត្បូងទៅក្នុងទឹក ៗ កាលបើឯងធ្វើឲ្យបាត់ មុខជាលំបាកវេទនាយើងទាំងពីរនាក់ទៀតហើយ ៗ ប៉ុន្តែ ឆ្កែមិនស្ដាប់ក៏ដណ្ដើមកែវមណីជោតិពីឆ្មា យកមកខាំហើយលោតទៅក្នុងទឹកឆ្លងស្ទឹង ៗ លុះកំពុងតែហែលកាត់ស្ទឹង, ឆ្កែឃើញត្រីពោរហែលចំហរមាត់នៅលើផ្ទៃទឹក ក៏ព្រុះដោយភ្លាត់ភ្លាំងស្មារតី ៗ ត្បូងទិព្វធ្លាក់ពីមាត់ហើយត្រីពោរលេបបាត់ទៅ ៗ កាលបើហែលដល់ច្រាំងម្ខាងហើយ ឆ្មាបានស្ដីបន្ទោសឆ្កែថា: ហេតុម្ដេច បានជាឯងមិនជឿអញ, អញបាននិយាយហើយនិយាយទៀតថា ឯងជាសត្វនិយាយច្រើន ៗ ឥឡូវនេះ បាត់កែវ

ទៅហើយ ៗ រកមកឲ្យអញ អញមិនដឹងធ្វើដូចម្ដេចទេ ៗ ក្អែកនៅស្ងៀម ស្ដាប់ឆ្មាបន្ទោសឥតឆ្លើយសោះ ៗ ប៉ុន្តែ ឆ្មាជាសត្វប្រាជ្ញ ( ប្រសប់ដោះកុន ) ៗ ក៏ដើរលួចចាប់បាន អគ្គមហេសីនៃស្ដេចកេមួយ ៗ ដោយឮអគ្គមហេសីកេនេះអង្វរគេ, ឆ្មាឆ្លើយថា នែអគ្គមហេសីកេ បើឯងសន្យាយកកែវមណីជោតិ ដែលត្រីពោរលេបបាន អញនឹងលែងឯងឲ្យរួចជីវិត ៗ

-. ឲ្យតែខ្ញុំរួចខ្លួនចុះ ខ្ញុំហ៊ានធានាអះអាងយកត្បូងទិព្វឲ្យបងឆ្មាបាន ៗ លុះបានស្ដាប់សេចក្ដីសន្យាខាងលើនេះហើយ ឆ្មាក៏លែងអគ្គមហេសីកេឲ្យទៅប្រមូលសត្វកេទាំងឡាយ ដើម្បីមុជទឹកចាប់ ៗ តែកាលណោះសត្វកេហែកពោះត្រី ទៅមិនឃើញត្បូងទិព្វទេ ៗ នៅសល់តែត្រីពោរមួយ ដែលពុំទាន់ចាប់បាន ៗ បន្តិចមក សត្វកេក៏ចាប់បានត្រីខាងក្រោយនេះ យកមកហែកពោះ ទើបឃើញកែវមណីជោតិ ៗ សត្វកេយកកែវនោះទៅប្រគល់ឲ្យឆ្មា ៗ នៅវេលានោះ, ឆ្មាបានទទួលយកកែវមណីជោតិជាស្រេច ហើយហៅក្អែកនាំគ្នាធ្វើដំណើរទៅមុខទៀត ៗ ដល់ពាក់កណ្ដាលផ្លូវ, ក្អែករៀងដណ្ដើមត្បូងពីឆ្មាទៀត ៗ ឆ្មាមិន

ព្រមឲ្យកែវនោះមកក្អែ  តែក្អែបន្ទំឆ្នាដោយអំណាច យកត្បូងមកពាំម្តង-ទៀត ៗ លុះពាំត្បូងបានបន្តិចទៅ, ក្អែឃើញត្មាតកំពុងតែចុះមកហែកខ្មោចក្របីស៊ី, រាក់ព្រោះត្មាតនោះឥតសំចៃ. ត្បូងធ្លាក់ពីមាត់ទៅដី ៗ ឃើញដូច្នោះត្មាតលោតមកចិកយកកែវមណីជាតិ  ហើយគ្រលៀវលេបបាត់ទៅ ៗ ត្មាខឹងយ៉ាងខ្លាំង ហើយនិយាយទៅកាន់ក្អែថា ហេតុដូចម្ដេច បានជាឯងមិនជឿពាក្យអញ! ឥឡូវនេះ តាមតែឯងធ្វើម្ដេចបានធ្វើទៅចុះ ៗ ចំណែកអញ អញមិនដឹងទេ ! អញទៅផ្ទះសិនហើយ ៗ ក្អែមានទុក្ខព្រួយយ៉ាងក្រៃលែង គ្មាននិយាយមួយម៉ាត់សោះ ៗ ដោយនឹកខ្លាចក្រែងចៅហ្វាយក្ដាំងសម្លាប់ វាអង្គុយញ័រជើងចំប្រប់ ធ្វើមុខស្ញូតឲ្យអាណិតហើយញាក់មុខទឹងប្រាប់ក្អែកផង ៗ រួចពីបន្ទោសក្អែមក ត្មាដើរតម្រង់ទៅផ្ទះ នៅតាមផ្លូវវាប្រទះឃើញពស់វែកមួយ ក៏ខាំពស់នោះត្រង់កជាប់បំរះមិនរួច ៗ នៅពេលពស់នោះអង្វរថា៖ ឱបងត្មា! អាណិតខ្ញុំផង, លែងខ្ញុំឲ្យរស់ជីវិតពេលនេះទៅ, ដល់ពេលក្រោយ ខ្ញុំនឹងជួយដោះទុក្ខបងជាមិនខាន ៗ

(មានត)

## កំណត់ហេតុប្រវត្តិការណ៍

# ពិធីអនុសិរីប្បរៈមហាសន្និបាតលើកទី ១៤ នៃមន្ត្រីសង្ឃ សម្រាប់ឆ្នាំ ១៩៥៨ នៅមន្ទីរព្រះសទ្ធម្ម ក្នុងវត្តព្រះកែវមរកត

( តមក )

លោក ឯន - ប៊ិង រៀបរៀង

នូវអធិករណ៍ផ្សេងៗ ដែលមានកើតឡើងក្នុងអាពមខ្លះ ឲ្យបាត់បង់ទៅវិញ ដោយព្យាយាមពន្យល់ដល់ពុទ្ធបរិស័ទទាំងអស់ថា ការឈ្លោះប្រកែកគ្នានេះ នាំឲ្យបាត់បង់សាមគ្គីជាតិ ហើយជាបច្ច័យនាំឲ្យសង្គមយើងទាំងមូលថយកំឡាំងទៅវិញផង ។

នៅទីបំផុតខ្ញុំព្រះករុណា សូមប្រកាសបើកមហាសន្និបាតមន្ត្រីសង្ឃលើកទី ១៤ ព្រមទាំងប្រគេនសក្ការសាធុការពរ ចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមឲ្យបានប្រកបដោយនូវសេចក្ដីសុខសេចក្ដីចំរើនរហូតដល់ព្រះនិព្វាន ។

តមក លោក មាស - យ៉ន់ អនុរដ្ឋលេខាធិការក្រសួងធម្មការ ថ្លែងសុន្ទរកថា មានសេចក្ដីដូចតទៅនេះ ៖

# សុន្ទរកថារដ្ឋមន្ត្រីក្រសួងធម្មការ

សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

សម្តេចព្រះមហាក្សត្រិយានី

សម្តេចព្រះឧបយុវរាជ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្វាយនូវអំណរព្រះករុណាធិគុណដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះឧបយុវរាជ ដែលទ្រង់ព្រះមេត្តាប្រោស ស្តេចបានយាងមកជាព្រះរាជាធិបតី នឹងព្រះរាជាធិបតាក្នុងពិធីបុណ្យ អនុសំវច្ឆរសន្និបាតមន្ត្រីសង្ឃ ទី ១៤ សម្រាប់ឆ្នាំរកា នព្វស័ក ព.ស. ២៥០០, គ.ស. ១៩៥៨ នេះ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ដើម្បីប្រស្រ័យជាមួយនឹងព្រះថេរានុត្ថេរៈទាំងឡាយ ដោយមានបំណងចង់ឲ្យព្រះសង្ឃបានជ្រាបនូវដំណើរកិច្ចការខ្លះខាងពុទ្ធចក្រនឹងអាណាចក្រ ដែលបានប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលនេះ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

សូមក្រាបថ្វាយបង្គំសម្តេច នឹងព្រះថេរានុត្ថេរ គ្រប់ព្រះអង្គ ខ្ញុំព្រះករុណាមានសេចក្តីរីករាយជាទីបំផុត ចំពោះសម្តេចនឹងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ដែលបាននិមន្តមកកាន់មហាសន្និបាតនេះ ៕

សម្តេច !

ព្រះករុណាគ្រប់អង្គ !

ឱកាសនេះ ជានក្ខត្តសម័យដែលខ្ញុំព្រះករុណាបានមកជួបព្រះភក្រ្តសម្តេច នឹងព្រះករុណាគ្រប់ព្រះអង្គ គួរចាត់ទុកជាទស្សនានុត្តរិយៈមួយដ៏ប្រសើរ ៕ ខ្ញុំព្រះករុណាបានចូលមកកាន់ការនៅក្រសួងធម្មការ ចំនួនជិត ៦ ខែហើយ ក្នុងរយៈវេលា ដែលខ្ញុំព្រះករុណាបានប្រតិបត្តិការមកនេះ ទោះបីមានសេចក្តីធ្លាំធ្លងខ្លះ ពុំសមគួរទៅតាមព្រះទ័យក៏សូមសម្តេច ព្រះករុណាគ្រប់ព្រះអង្គ មេត្តាអភ័យទោស ព្រោះការទាស់ធ្លងនេះប្រសិនបើមាន ក៏ពុំមែនប្រកបទៅដោយចេតនាឡើយ ៕

ខ្ញុំព្រះករុណា សូមផ្ញើសេចក្តីសង្ឃឹមលើព្រះករុណាគ្រប់ព្រះអង្គជាមេគណអនុគណថា នឹងជួយរិះរកមធ្យោបាយយ៉ាងណា សម្រួលកិច្ចការទាំងពួង ដែលខាងពុទ្ធចក្រមានដំណើរទៅស្រួល គួយ៉ាងដូចជាអធិករណ៍សង្ឃជាដើម សូមកុំឲ្យកើតមានឡើង ក្នុងស្រុកខែត្រច្រើនពេក គឺថាអធិករណ៍ណាដែលកើតឡើងហើយ ក្នុងស្រុកខែត្រ សុំព្រះករុណាជាមេ

គណអនុគណ រឺរកមធ្យោបាយស្ទាបស្ទង់មើលយ៉ាងហ្មត់ចត់ បើអាចរម្ងាប់បាន គួរតែសម្របសម្រួល ឲ្យបានសះជាក្នុងទីនោះ ដោយស្រួលផង សុំកុំឲ្យពន្យារពេលទុកឲ្យអធិករណ៍នោះ រីកពលធំឡើងនាំឲ្យអំពល់ដល់ព្រះរាជរដ្ឋាភិបាលចាត់ចែង ការឯទៀតដែលមានសារប្រយោជន៍បូជាមាតុប្រទេស ព្រោះខ្ញុំព្រះករុណាបានសង្កេតឃើញអធិករណ៍ខ្លះ ដែលកើតឡើងមុនដំបូង ជាការបន្តិចបន្តួចសោះ ពុំមែនជាអធិករណ៍រឹងត្អឹងទេ មានសភាពល្មម គួរតែព្រះតេជព្រះគុណមេគណអនុគណ សម្របសម្រួលបាន ដោយគ្រប់គ្រាន់ តែអធិករណ៍នោះត្រឡប់ទៅជារីកពលធំឡើងពុំអាចរម្ងាប់បាន ដោយងាយទៅវិញ ។ ឧទាហរណ៍ដូចជាភ្លើងសម្រាមជម្មតា ភ្លើងសម្រាមមុនដំបូងពុំសូវមានអណ្តាតភ្លើងសន្ធោសន្ធៅប៉ុន្មានទេ តែបើបណ្តោយឲ្យភ្លើងនោះឆេះតាមចិត្តទៅ ភ្លើងនោះក៏រមែងឆេះរាលដាល ក្លាយទៅជាឆេះផ្ទះសម្បែង មានអណ្តាតសន្ធោសន្ធៅពុំអាចពន្លត់បានដោយងាយឡើយ ។

ត្រង់ខនេះ ជានិមិត្តរូបឲ្យឃើញថា អធិករណ៍ដែលកើតឡើងទាំងប៉ុន្មាន បណ្តាលមកតែពីការបន្តិចបន្តួចប៉ុណ្ណោះ បីដូចជាភ្លើងសំរាម បើប្រសិនជារម្ងាប់ភ្លាមៗទៅ ភ្លើងនោះក៏ពុំអាចឆេះរាលដាលទៅបានឡើយ។ ចំពោះរឿងអធិករណ៍នេះ បើមានកើតឡើងក្នុងវត្តារាមណា ខ្ញុំព្រះករុណា

សូមព្រះតេជព្រះគុណមេគណ អនុគណ មេត្តាប្រជុំជាមួយរាជការស្រុកខេត្ត រិះរកមធ្យោបាយម្ងាប់ហេតុ ក្នុងភាពមនោះក្លាម ៗ ឲ្យបានសម្រេចតែម្តងទៅ ទើបបានលទ្ធផលល្អ ដើម្បីការពារកុំឲ្យអធិករណ៍នោះរីករាលធំទូលាយតទៅទៀតបានឡើយ ។

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ ! យើងមានភ័ព្វល្អណាស់ ដែលមានព្រះពុទ្ធសាសនាប្រតិស្ឋាន នៅក្នុងប្រទេសយើងនេះ ព្រមទាំងបានកើតទាន់ពាក់កណ្តាលព្រះពុទ្ធសាសនា ហើយបានទាំងធ្វើពិធីបុណ្យរំលឹកពុទ្ធសករាជ ២៥០០ ព្រះវស្សា ចំនួន ៧ ទិវារាត្រីយ៉ាងឧឡារិក ត្រង់ទីប្រតិស្ឋាននៃព្រះសក្យមុនីចេតិយ ឆាមុខស្ថានយារាជអយស្ឋយាន ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំង ២ ព្រះអង្គ និងគ្រប់អាណាខេត្ត ក្នុងព្រះរាជអាណាចក្រទាំងមូលផង ។ ព្រះពុទ្ធសាសនាជាលទ្ធិដឹកនាំសត្វឲ្យដើរទៅរកសេចក្តីស្ងប់ គឺសន្តិភាពមិនឲ្យមនុស្សរំលោភលើមនុស្សផងគ្នា ប្រដៅសត្វឲ្យជឿកម្មនិងផលនៃកម្ម ដូចព្រះតេជព្រះគុណជ្រាបស្រាប់ហើយ ។ ទ្រង់ព្រះករុណាសង្ឃឹមថា ព្រះសង្ឃជាសិស្សផ្ទាល់នៃព្រះពុទ្ធបរមគ្រូ នឹងប្រកាន់យកផ្លូវស្ងប់តាមគម្រោយនៃព្រះពុទ្ធអង្គដោយពិត ។

យើងមានភ័ព្វម៉្យាងទៀត ដោយបានព្រះមហាក្សត្ររបស់យើង

ទ្រង់កាន់ព្រះពុទ្ធសាសនាយ៉ាងដិតស្និទ្ធ ហើយព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភ គឺព្រះអង្គជាក្សត្រទ្រង់ទំនុកបម្រុងព្រះពុទ្ធសាសនា ដោយព្រះរាជហឫទ័យជ្រះថ្លាដ៏បរិសុទ្ធ ដូចជាក្នុងពិធីបុណ្យអនុស្សាវរីយ៍មហាសន្និបាតមន្ត្រីសង្ឃរៀងរាល់ឆ្នាំមក ព្រះអង្គទ្រង់តែងបរិច្ចាគដោយព្រះបសាទសទ្ធានូវថវិកាសម្រាប់ព្រះរាជទ្រព្យ ១ ម៉ឺនរៀល ដើម្បីចាត់ធ្វើកត្តប្រគេនព្រះករុណាគ្រប់ព្រះអង្គ ដែលនិមន្តមកកាន់ទីមហាសន្និបាតនេះ ។

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ!

ព្រះពុទ្ធសាសនានៅប្រទេសយើង ពិតមែនតែប្រទេសតូចមានពលរដ្ឋតិច ប៉ុន្តែ ប្រទេសទាំងឡាយដែលជាពុទ្ធសាសនិកបានទទួលស្គាល់ថាជាប្រទេសកាន់ពុទ្ធសាសនា យ៉ាងហ្មត់ចត់ត្រឹមត្រូវតាមពុទ្ធោវាទមានពុទ្ធសាសនិក ៩៩ ភាគរយ ។ កិត្តិគុណប្រទេសយើងដែលកើតឡើងនេះគឺកើតដោយសារស្នាព្រះហស្ថនៃសម្តេចព្រះឧបយុវរាជ ជាបិតាឯករាជ្យព្រះអង្គបានបំពេញព្រះរាជបេសកកម្ម ប្រស្រ័យទាក់ទងនឹងប្រទេសឯទៀតជាច្រើន ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ឲ្យគេទទួលស្គាល់នូវគុណសម្បត្តិរបស់ប្រទេសយើងថាជាប្រទេសកាន់ព្រះពុទ្ធសាសនា ហើយប្រជាពលរដ្ឋ ក៏សុទ្ធតែអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់គ្នា ។

អាស្រ័យហេតុនេះ គួរព្រះតេជព្រះគុណ មេគណ អនុគណគ្រប់ព្រះ

អង្គប្រជុំលោកគ្រូចៅអធិការគ្រប់វត្តក្នុង១ ឆ្នាំ ២ ដង ឬ ៣ ដងពន្យល់ណែនាំអស់លោកគ្រូចៅអធិការគ្រប់វត្តគ្រប់អង្គ ឲ្យលោកបានយល់អំពីច្បាប់របស់ព្រះពុទ្ធសាសនា និងសេចក្តីប្រតិបត្តិ ដែលព្រះសង្ឃត្រូវប្រតិបត្តិឲ្យមានសេចក្តីរៀបរយ កុំឲ្យមានការយើករយាក ដូចដែលធ្លាប់ប្រទះមកហើយ ដើម្បីលើកកិត្តិសព្ទពុទ្ធសាសនា នៅប្រទេសយើងឲ្យល្បីខ្ចរខ្ចាយទូទៅ សមតាមព្រាជបំណងនៃសម្តេចព្រះឧបយុវរាជ ដែលព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភដ៏វិសេស ព្រោះប្រទេសយើងបានចក្រ ២ គឺពុទ្ធចក្រនិងអាណាចក្រ លុះត្រាតែចក្រទាំង ២ វិលទៅមានល្បឿនស្មើគ្នា ទើបនាំបានដល់ត្រើយនៃវឌ្ឍនភាព ។

បពិត្រព្រះករុណាគ្រប់ព្រះអង្គ ! ការសិក្សាបែកខាងព្រះពុទ្ធសាសនានៅប្រទេសយើង ក្នុងបច្ចុប្បន្ននេះ ឃើញថាមានដំណើរជឿនទៅមុខគួរសមហើយ តែសេចក្តីប្រតិបត្តិរបស់បព្វជិត ក្នុងព្រះរាជអាណាចក្រ បើពិនិត្យឲ្យល្អិតឃើញថា នៅខ្សោយជាងការសិក្សាទៅវិញ ព្រោះមានអធិករណ៍សង្ឃ ជាឧបសគ្គមួយយ៉ាងធំ ដែលជាមន្ទិលក្នុងព្រះពុទ្ធសាសនា ។

សូមព្រះតេជព្រះគុណគ្រប់ព្រះអង្គ ជ្រាបច្បាស់ចលនានៃព្រះពុទ្ធសាសនានៅប្រទេសយើង ដែលមានល្បឿនលឿន មកប៉ុណ្ណោះដោយសារ

សេចក្ដីខ្វះខ្វែងនៃព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានសម្ដេចព្រះឧបយុវរាជជាប្រធាន ព្រះអង្គទ្រង់ពុំមែនឈ្លៀងចតតែខាងកិច្ចការអាណាចក្រទេ គឺទ្រង់ខំជួសខាត់បក្រទាំង ២ ឲ្យវិលទៅមានល្បឿនស្មើគ្នា ដើម្បីញ៉ាំងសេចក្ដីបរិវេឲ្យកើតមានឡើងដល់ប្រទេសជាតិ ។

ហេតុនេះ ខ្ញុំព្រះករុណាសុំផ្ញើសេចក្ដីទុកចិត្ត លើព្រះករុណាគ្រប់ព្រះអង្គជាមន្ត្រីសង្ឃ មានព្រះតេជព្រះគុណមេគណ អនុគណជាដើម គ្រប់ខេត្តគ្រប់ស្រុកថា នឹងយកព្រះទ័យទុកដាក់ដាស់តឿនក្រើនរំលឹកលោកគ្រូចៅអធិការគ្រប់វត្តនូវអស់ភិក្ខុសាមណេរគ្រប់រូប ព្រមទាំងពុទ្ធបរិស័ទចំណុះវត្ត ឲ្យខំបំពេញករណីយកិច្ចឲ្យបានសមតាមពុទ្ធដីកា នៃអង្គសម្ដេចព្រះសព្វញ្ញុតញ្ញាណរបស់យើង ដែលព្រះអង្គទ្រង់និយមយកសន្តិភាពជាគោលសេចក្ដីប្រតិបត្តិ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ទីបំផុតនៃសុន្ទរកថានេះ ទូលព្រះបង្គំជាខ្ញុំសូមបង្អោនព្រះរាជកុសលថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំង ២ ព្រះអង្គ ព្រមទាំងសម្ដេចព្រះឧបយុវរាជ សូមព្រះអង្គគង់នៅជាសុខ ក្នុងព្រះរាជសិរីសម្បត្តិព្រមទាំងបានប្រកបដោយសិរីសួស្ដីជយមង្គលគ្រប់ប្រការ កំចាត់បង់នូវឧបសគ្គទាំងពួង កុំឲ្យកើតមានឡើងដល់ព្រះអង្គ ដើម្បីបានទ្រង់ដឹកនាំ

ប្រទេសជាតិ និងព្រះពុទ្ធសាសនា ឲ្យដើរឆ្ពោះទៅរកសន្តិភាពនិងវឌ្ឍន-ភាពជានិច្ចនិរន្តរ៍តរៀងទៅ ។

ចប់សុន្ទរកថា ។

នៅពេលដែលចប់សុន្ទរកថានៃ លោក មាស-យ៉ង់ អនុរដ្ឋលេខាធិការក្រសួងធម្មការហើយ ព្រះតេជព្រះគុណព្រះបាឡាតបទុមវង្សាតេត វត្ត-ទេពធីតាកម ខេត្រកំពង់ធំ ថ្វាយសុន្ទរកថាតបវិញ មានសេចក្តីដូចតទៅនេះ

## សុន្ទរកថា

សូមថ្វាយព្រះពរព្រះករុណាជាម្ចាស់ជីវិតទាំង ២ ព្រះអង្គ និងសម្តេចព្រះឧភយាឯកអគ្គ សូមទ្រង់ជ្រាប ។

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក បានតម្រូវលើរូបអាត្មាភាព ឲ្យជាតំណាងសង្ឃដែលបាននិមន្តមកជួបជុំ ក្នុងទីចំពោះព្រះភ័ក្ត្រ នាមហាសន្និបាតនេះ ឲ្យអាត្មាភាពថ្វាយសេចក្តីតបសុន្ទរកថានៃអ្នកឧកញ៉ារដ្ឋមន្ត្រីក្រសួងធម្មការ ។

អាត្មាភាពសូមព្រះពរទានព្រះបរមរាជានុញ្ញាត សូមថ្វាយសេចក្តីដោយសង្ខេប ចំពោះតែត្រង់ខ្លះ ដែលមានសារប្រយោជន៍ ស្របគ្នានឹងសុន្ទរកថានៃលោករដ្ឋមន្ត្រីក្រសួងធម្មការ ។

សូមថ្វាយព្រះពរ,

មន្ត្រីសង្ឃគ្រប់ថ្នាក់ គ្រប់ដំណែងសុទ្ធសឹងតែធុញទ្រាន់ ស្អប់ខ្ពើមអធិករណ៍ ដែលកើតមានក្នុងវត្តអារាម, ស្រឡាញ់តែសេចក្តីសុខស្ងប់ជានិច្ច, គំនិតប្រឹងរកមធ្យោបាយកុំឲ្យមានអធិករណ៍ ដែលបានជាជួលកើតមានខ្លះហើយ គំនិតរលត់រលាយណាស់ដែរ, ជួនកាលក៏បានស្ងប់រម្ងាប់ ជួនកាលក៏ក្លាយទៅជារីកពលធំឡើង ពុំអាចធ្វើឲ្យរលត់បានទៅវិញ ដែលបែរទៅជាផ្ទុយដូច្នេះ ដោយមកពីហេតុដូចខាងក្រោមនេះ ៖

អធិករណ៍ដែលកើតឡើងក្នុងវត្តអារាមណាមួយ, ព្រះវិន័យប្រាប់ថាត្រូវរម្ងាប់ដោយសារសមថៈ ៧ យ៉ាង តោះសមថៈណាក៏ដោយ តាមយថាហេតុ ដូចជាភ្លើងឆេះសំរាមជាដើម ត្រូវរលត់ដោយគ្រឿងរលត់មានទឹកជាដើម ដូច្នោះដែរ ។ ក្នុងសម័យសព្វថ្ងៃនេះ នឹងយកសមថៈទាំងនោះមករម្ងាប់អធិករណ៍ឲ្យសព្វគ្រប់ តាមក្បួនព្រះវិន័យពុំកើត ព្រោះមកពីគូវិវាទ ច្រើនតែពុំទទួលគោរពព្រះវិន័យ ទាំងព្រះរាជក្រម ព្រះរាជក្រឹត្យ និងប្រកាសផ្សេងៗ ដែលជាជំនួយព្រះវិន័យនោះ គូវិវាទច្រើនតែពុំសូវគោរពដែរ ដោយមកពីបេះដូងខ្លួនឥតមានកំហុសគុំគួន ទោះហើយអធិករណ៍ សូម្បីតូចមួយសោះទេ ក៏អាចរីកពលទៅជាអធិករណ៍ធំបាន ក៏សឹងតែមានខ្លះ ៗ

ត្រង់ខនេះ សូមព្រះរាជរដ្ឋាភិបាលជួយលៃលក ឲ្យគណៈសង្ឃ មានសិទ្ធិប្រតិបត្តិការឲ្យបានបរិបូណ៌ តាមលំអានព្រះវិន័យ និងព្រះរាជក្រម ព្រះរាជក្រឹត្យ ព្រមទាំងប្រកាសទាំងពួងនោះឡើង ទើបនឹងបានងាយប្រតិបត្តិការ, អធិករណ៍ក៏នឹងពុំសូវកើតមានឡើងប៉ុន្មាន បើទុកជាកើតមានឡើងបន្តិចបន្តួច សង្ឃក៏អាចនឹងរម្ងាប់បានដោយងាយៗ ។

អាត្មាភាពសូមថ្លែងសេចក្ដីសន្ទើបតែត្រឹមប៉ុណ្ណោះ ដ្បិត ក្រសួងធម្មការដែលបានប្រតិបត្តិការរាល់ថ្ងៃមក ក៏បានជ្រាបដំណើរអធិករណ៍ទាំងពុទ្ធចក្រដោយជាក់លាក់ណាស់ហើយ ។

នៅទីបញ្ចប់នេះ អាត្មាភាពជាជំណាងមន្ត្រីសង្ឃ សូមលើកយកកុសលបុញ្ញរាសី ដែលសង្ឃគ្រប់វត្ត បានប្រព្រឹត្តប្រតិបត្តិក្នុងរយៈកាល ១ ឆ្នាំមកហើយនេះ ជាព្រះរាជកុសល ថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិតទាំង ២ ព្រះអង្គ និងសម្ដេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ សូមទ្រង់ទទួលអនុមោទនា ហើយសូមទ្រង់ប្រកបដោយសិរីសុខគ្រប់ប្រការ ព្រមទាំងសូមព្រះអង្គ មានព្រះជន្មាទីឃាយុយឺនយូរអស់កាលអង្វែងវែងឆ្ងាយ !

សូមថ្វាយព្រះពរ ។

មួយទៀត សូមជូនសាធុការពរ ចំពោះអស់លោកគណៈរដ្ឋមន្ត្រី

នឹងអស់លោកមន្ត្រីធំតូច គ្រប់ថ្នាក់ គ្រប់ក្រុម សូមបានប្រកបដោយសុភមង្គលគ្រប់យ៉ាង សព្វកាលវេលាទិវារាត្រី !

សូមកម្ពុជរដ្ឋ ឯករាជ្យ អព្យាក្រឹត ឋិតនៅជាស្ថាពរដោយការចំរុងចំរើនជានិច្ចនិរន្តរ៍ !

សូមចំរើនពរ ។

ក្រោយដែលចប់សុន្ទរកថា នៃព្រះតេជព្រះគុណព្រះបាទឡាក់បទុមវង្សាគេត វត្តទេពធីតារាម ខេត្តកំពង់ឆ្នាំងហើយ ព្រះសង្ឃទាំងអស់គ្នាព្រមព្យាយធម៌ជយន្តោប្រសិទ្ធិពរ ថ្វាយព្រះមហាក្សត្រទាំងពីរព្រះអង្គនឹងឥស្សរជនទាំងឡាយ ។

ម៉ោង ៩ និង ៣០ នាទី ព្រះមហាក្សត្រទាំងពីរព្រះអង្គថ្វាយបង្គំលាព្រះសង្ឃ ស្តេចយាងចូលព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារ ហែហមអម ព្រះអង្គ ។ ចំណែកឥស្សរជនទាំងអស់គ្នាអញ្ជើញទៅកាន់ដំណែងរៀងខ្លួនវិញ ។

ម៉ោង ១០ និង ៣០ នាទី មានការប្រគេនភត្ត គង់ព្រះបរមនាមព្រះករុណាជាម្ចាស់ជីវិតលើត្បូងដល់ព្រះសង្ឃ នៅមហាកុដិវត្តឧណ្ណាលោម ចំពោះមុខលោកម្ចាស់-យ៉ង់អនុរដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងមន្ត្រីក្រសួងធម្មការ-ឧបាសក ឧបាសិកា ។

ចប់ ។

# មហាសន្និបាតសមាគមមិត្តពុទ្ធិកវិទ្យាល័យ

លោកក៉យ - ប៊ុករៀបរៀង

កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៥៨ វេលាម៉ោង ១៩ និង៣០នាទី នៅសាលាបាលីវត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ គេឃើញមានការជួបជុំនៃពុទ្ធបរិស័ទ ទាំងភេទបព្វជិត និងគ្រហស្ថចំនួនច្រើន ក្រោមបរិយាកាសយ៉ាងស្និទ្ធស្នាលក្រៃលែងដែលជាមិត្តភាព ។

ចំណែកភ្ញៀវខាងព្រះសង្ឃ មានព្រះតេជគុណ ព្រះញាណកោសល ញាណ-ឈឺន ព្រះពុទ្ធវង្ស គៅ-ស៊ុម និងព្រះមហា ប៉ាង-ខាត់ ជាដើម ព្រមទាំងភិក្ខុសាមណេរ អង្គឯទៀតជាច្រើន ដែលយើងសុំអភ័យទោសពុំអាចនឹងកត់នាមប្រគេនឱ្យអស់បាន ។

ប៉ែកខាងភ្ញៀវគ្រហស្ថមាន លោក សម-ញាណ លោកក៉យ លុត និងលោក ក៉យ ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យជាដើម និងអស់លោកៗឧបាសកៗឧបាសិកា ជាច្រើនទៀត ដែលយើងសុំអភ័យទោសដោយពុំបានកត់ឈ្មោះជូនឱ្យបានសព្វគ្រប់ ។

លុះដល់ម៉ោង ១៦ និង៣០នាទី មហាសន្និបាតក៏បានបើកសម័យឡើងៗ ដើមដំបូងលោក ក៉យ ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ បានថ្លែងសុន្ទរកថាមួយ ដ៏ពិរោះក្បោះក្បាយ រៀបរាប់អំពីស្ថានការណ៍សមាគម

ក្នុងឆ្នាំ ១៩៥៧ ដែលកន្លងហួសមកនេះ ដោយសង្ខេប ហើយនឹងបាន បញ្ជាក់ដល់មហាសន្និបាត នូវកិច្ចការជាអត្ថប្រយោជន៍សំខាន់ ដែលសមាគមបានបំពេញរួចខ្លះមកហើយ នឹងដំហាននមិត្តភាព ខាងពុទ្ធសាសនាកម្ពុជរដ្ឋ រវាងពុទ្ធសាសនាបរទេសផង ដែលគេបានទទួលស្គាល់សមាគមយើងដោយពេញលក្ខណៈ ។

នៅទីបំផុតលោក ពយ ប៊ុក អំពាវនាវដល់មហាសន្និបាតថា សូមឲ្យអស់លោកជាពុទ្ធបរិស័ទមេត្តាជួយទំនុកបំរុង សមាគមនេះឲ្យបានរីងដំហរឋិតថេរចិរកាល ដោយរុងរឿងតទៅអនាគត ។

បន្ទាប់ពីនោះទៅទៀត លោកម៉ៅ-ម៉ី ក្នុងឋានៈជាអគ្គហេរញ្ញិកបាន ថ្លែងរៀបរាប់ពីស្ថានភាពហិរញ្ញវត្ថុ របស់សមាគមក្នុងឆ្នាំ ១៩៥៧ ដែលកន្លងផុតមកនេះ ។

ប្រាក់ចំណូល ចំណាយ ដូចមានតទៅនេះ ៖

១- ប្រាក់ចំណូល មានចំនួន ១៦១ ១៤៥ រ០០

២- ប្រាក់ចំណាយ មានចំនួន ១១៤ ៤៥៧ រ០០

៣- ប្រាក់នៅសល់មានចំនួន ៤៦ ៦៨៨ រ ០០ ក្នុងហិបសមាគមសព្វថ្ងៃ ។

ចប់សេចក្តីថ្លែងការហើយ លោក ម៉ៅ ម៉ី ថ្លែងអំណរគុណចំពោះ

មហាសន្និបាតដែលមានសភាពគុះគរ សឲ្យឃើញថា អ្នកកាន់ព្រះពុទ្ធ-សាសនានៅប្រទេសយើង កាន់តែមានដំណើររលឿនទៅមុខជាដរាប ។

សូមបញ្ជាក់ថា: នៅពេលចប់សុន្ទរកថានីងសេចក្តីថ្លែងការម្តងៗ សូរស័ព្ទទះដៃពុត្តិគគគ៌រពងទ្បើង ជាសញ្ញាទទួលសេចក្តីគ្រេកអរចំពោះសមាគម ។

លំដាប់តទៅទៀត មហាសន្និបាត បានរៀបចំពិធីបោះឆ្នោត រើសគណៈកម្មាធិការនាយកថ្មីសម្រាប់ឆ្នាំ ១៩៩៨ ជាជំនួសគណៈកម្មាធិការនាយកចាស់ ដែលស៊ុំលាលែងឈប់ពីតំណែង ។ មហាសន្និបាតបានតាំងគណៈកម្មការបណ្តោះអាសន្នមួយ តម្រូវលើលោក សម ញាណ ជា-ប្រធាន លោក សូរ ស៊ីផន នឹង លោក តាន់-គីមតិក ជាលេខាធិការ ។

ពិធីបោះឆ្នោតក៏ចាប់ផ្តើមឡើង ដែលមានបេក្ខជន ២៦ រូប ឈរឈ្មោះសម្រាប់ឲ្យគេបោះឆ្នោត ជ្រើសរើសយក ១៦ រូប ធ្វើជាគណៈកម្មាធិការ-នាយកសម្រាប់ឆ្នាំថ្មី ។

លទ្ធផលនៃការបោះឆ្នោត បានសម្រេចដូចតទៅនេះ

| | | | | |
|---|---|---|---|---|
| ១- | លោក | ពៃយ ប៊ុក | បានឆ្នោត | ៦០ |
| ២- | លោក | ផេង-ជ្រៅ | -ដ- | ៥៧ |
| ៣- | លោក | មៅ ម៉ុ | -ដ- | ៥៤ |

| | | | |
|---|---|---|---|
| ៤- លោក | សាម-ឡាមុត | -ដ- | ៤៣ |
| ៥- លោកស្រី | សម-ញាណ | -ដ- | ៤៨ |
| ៦- លោក | យក់-សាមេត | -ដ- | ៤៧ |
| ៧- លោក - | អ៊ុក-ផន់ | -ដ- | ៤៤ |
| ៨- លោក | សូរ-ស៊ីផន | -ដ- | ៤២ |
| ៩- លោកស្រី | សម-ណៃ | -ដ- | ៤១ |
| ១០- លោកស្រី | តុប-ស្អាត | -ដ- | ៣៩ |
| ១១- លោកស្រី | ប៉ាយ-លុត | -ដ- | ៣៩ |
| ១២- លោកស្រី | ប៉ាយ-ប៊ុក | -ដ- | ៣៦ |
| ១៣- លោក | ម៉ុង ជុនលីន | -ដ | ៣៥ |
| ១៤- លោក | អ៊ីង-ទួន | -ដ- | ៣៤ |
| ១៥- លោក | មាឃ-គុម | -ដ- | ៣២ |
| ១៦- លោក | ញ៉ូង-សៀង | ដ- | ៣២ |

រួចហើយ លោកប្រធានក៏បានប្រកាស ដល់មហាសន្និបាតឲ្យបានដឹងថា:បេក្ខជនទាំង ១៦ រូបខាងលើនេះ ដែលបានឆ្នោតច្រើនជាងគេ ត្រូវបានតែងតាំងជាគណ:កម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៥៨ ។

មហាសន្និបាតបានលើកពេលប្រជុំ នៅវេលាម៉ោង ១៨ ក្រោយពី

បានទទួលជយន្តមង្គលពីក្រុមព្រះសង្ឃ ដែលបាននិមន្តចូលមករួមមហាសន្និបាត នឹងក្រោមបរិយាកាសយ៉ាងរីករាយបំផុត ។

លុះដល់ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៥៨ សមាគមបានអញ្ជើញក្រុមអភិបាល ដែលបានជាប់ឆ្នោតទាំង ១៦ រូប ដើម្បីបែកមុខការធ្វើការសម្រាប់ឆ្នាំ ១៩៥៨ ។ បានសម្រេចដូចតទៅនេះ ៖

| | | | |
|---|---|---|---|
| ១- | លោក | ពាយ-ប៊ុក | ប្រធាន |
| ២- | លោកស្រី | ពាយ-លុត | អនុប្រធាន |
| ៣- | លោក | អ៊ុង-ទួន | អនុប្រធាន |
| ៤- | លោក | ផេង-ជ្រីវ | លេខាធិការ |
| ៥- | លោក | យក់-សាមេត | អនុលេខាធិការ |
| ៦- | លោក | សូរ-ស៊ុផន | អនុលេខាធិការ |
| ៧- | លោក | ម៉ៅ-ម៉ី | អគ្គហេរញ្ញិក |
| ៨- | លោក | សាម-ឡាមុត | អនុហេរញ្ញិក |
| ៩- | លោក | ម៉ុង-ឈុនលីន | អនុហេរញ្ញិក |
| ១០- | លោក | អ៊ុក-ផន់ | បណ្ណារក្ស |
| ១១- | លោក | មាឃ-គុម | បណ្ណារក្ស |
| ១២- | លោកស្រី | សម-ញាណ | ស្នងការ |

១៣- លោកស្រី ក៉យ-ប៊ុក ស្នងការ

១៤- លោកស្រី តូប-ស្អាត ស្នងការ

១៥- លោកស្រី គង់-សរ ស្នងការ

១៦- លោក ញូង-សឿង ស្នងការ

ធ្វើនៅភ្នំពេញ នៅថ្ងៃទី ២០ កុម្ភៈ ១៩៥៨

ប្រធាន

# ទេសភាពរវាងប្រទេសនេប៉ាលនិងរដ្ឋបិហ្គ័ល (ប្រទេសឥណ្ឌា) ពីព្រៃលុម្ពិនីទៅទីក្រុងកុសិនារា ។

លោក ភ័យ-ប៊ុក រៀបរៀង

ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ទ្រង់ប្រសូតនៅព្រៃលុម្ពិនី (ប្រទេសនេប៉ាល់) ទ្រង់បានត្រាស់សម្មាសម្ពោធិញ្ញាណ នៅក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរនៅពុទ្ធគយា (ប្រទេសឥណ្ឌា) ទ្រង់បានសំដែងព្រះធម្មចក្រ នៅព្រៃឥសិបតនៈមិគទាយវ័ន ជិតទីក្រុងពារាណសី (ប្រទេសឥណ្ឌា) ទ្រង់ចូលបរិនិព្វាន នៅចន្លោះដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា (ប្រទេសឥណ្ឌា) ដូចបានទុកពុទ្ធដំណែលមកដល់សព្វថ្ងៃ ។

ពុទ្ធដំណែលទាំងបួនកន្លែងនេះ ជាបូជនីយដ្ឋានដែលពួកទេសចរគ្រប់ប្រទេសអញ្ជើញមកទស្សនា ជាច្រើនម៉ឺននាក់សព្វៗ ឆ្នាំ ។ ព្រោះហេតុដូច្នេះ យើងនឹងពណ៌នាអំពីទិដ្ឋភាពសម័យបច្ចុប្បន្ន ដែលយើងបានទៅទស្សនាដូចតទៅនេះ ៖

## ១ លុម្ពិនីស្ថានដែលព្រះអង្គទ្រង់ប្រសូត

ឧទ្យានលុម្ពិនី ដែលយើងបានទៅទស្សនានោះ គឺស្ថិតនៅប្រទេសនេប៉ាល់ មានរបងដែកព័ទ្ធជុំវិញ សសរដែលព្រះបាទអសោក បានសាងពីមុន

មក សសរនេះឯងជាទីកន្លែងដែលព្រះនាងមហាមាយាទេវី ពុទ្ធមាតា, ទ្រង់មានព្រះគភ៌ស្វាយរំជួលព្រះរាជហឫទ័យ យកព្រះហស្ថ តាប់មែកសាលព្រឹក្ស ហើយប្រសូតព្រះរាជបុត្រ គឺព្រះសម្ពុទ្ធ ។ ឆ្ងាយបន្តិច មានស្រះបោក្ខរណី ដែលព្រះគិលៀនបានយកព្រះរាជបុត្រទៅស្រង់ទឹក នៅកន្លែងស្រះបោក្ខរណីនេះ គេបានសាងនូវមុជដ្ឋានធ្វើពីឥដ្ឋមានលំអអស្ចារ្យ ។ នៅជិតនោះ មានព្រះវិហារមួយចាស់ ដែលមានរូបគំនូរជាក្បាច់ចញ្ចាំងនៃព្រះសម្ពុទ្ធទ្រង់ប្រសូត ។ នៅជិតព្រះវិហារមានអក្សរចារឹកថា: "នៅទីនេះជាទីដែលព្រះសក្យមុនីទ្រង់ប្រសូត" ។

យើងបានទៅពិនិត្យសសរដែលព្រះបាទអសោកបានចាត់ឲ្យសាងពីឆ្នាំ ២៥០ មុន គ.ស. (ព.ស ២៩៣), នោះបានឃើញថា: សសរនេះធ្វើពីថ្មមានកំពស់១០ម៉ែត្រ ។

មានភោជនាគារមួយ ដែលរដ្ឋាភិបាលប្រទេសនេប៉ាល់បានសាងទុកសម្រាប់ឲ្យពួកបូជនីយសក៍ ស្នាក់អាស្រ័យបានដោយងាយ ។

លុម្ពិនីនេះ, សព្វថ្ងៃ គេហៅថា "រុម្មិណ្ឌេ" គេតែងទៅតាមរថយន្តពីស្ថានីយ៍ អយស្ម័យយាន ណោតានវ៉ា ទៅរដ្ឋបង្គាល (ប្រទេសឥណ្ឌា) ចម្ងាយ ១៖ ម៉ឺ ។ សព្វថ្ងៃ រដ្ឋាភិបាលប្រទេសនេប៉ាល់កំពុងរៀបចំធ្វើផ្លូវថ្នល់ ដើម្បីសម្រួលដំណើរពួកពុទ្ធសាសនិកជន ដែលមាន

បំណងចង់ទៅទស្សនាលុម្ពិនី ។ ផ្លូវនេះ គេអាចទៅបានតាមអាកាស-យានពីទីក្រុងកល់កត្តា ទៅទីក្រុងកត្ថមណ្ឌូ (ប្រទេសនេប៉ាល់) ។

## ២- ពុទ្ធគយា ស្ថានដែលព្រះអង្គត្រាស់ដឹងនូវអនុត្តរ-សម្មាសម្ពោធិញ្ញាណ

យើងបានទស្សនាឃើញព្រះពោធិព្រឹក្សមួយដើម នៅតូចដែលដុះចេញពីពោធិព្រឹក្សចាស់ ដែលជាព្រះរាជបុត្រីព្រះបាទអសោកបានកាប់ចោល។

នៅជិតមហាពោធិព្រឹក្សនោះ មានក្ដុំតូចមួយនាមថា "មោរមហារះគឺ នៅលើកំពូលក្ដុំតូចនេះឯង ដែលព្រះសម្ពុទ្ធទ្រង់ស្ដេចយាងទៅពិចារណានូវធម៌ទាំងឡាយដោយសេចក្ដីស្ងប់ស្ងាត់ ។

នៅទីនេះ គេបានសាងមហាពោធិវិហារ តាំងពីសតវត្សរ៍ ទី១១មានសើនមួយខ្ពស់ប្រកបដោយទ្រង់ទ្រាយជាត្រីកោណ មានជ្រុងត្រង់ហើយមានស្តូបពីលើផង ។ នៅខាងក្នុង គេបានឃើញព្រះពុទ្ធរូបអង្គធំលាបទឹកមាស យកព្រះហស្តបង្អុលព្រះធរណីជាសាក្សីថា ព្រះអង្គទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។ មហាពោធិវិហារនេះ គឺគេធ្វើតាមគំរូក្បាច់សិល្ប ព្រះមហាពោធិវិហារនៃប្រទេសភូមា ។

☛ (មានត)

( តមក )

# ព្រះមហា ប៉ាង-ខាត់ រៀបរៀង

*អគ្គ* ធាតុ ទៅ ។

*អគ្គ* និបាតប្រាប់សេចក្ដីសួរ ឬ បញ្ជាក់ ដូចជា ពិត, បាទជាដើម ។ *កិមគ្គ* តាំងបាច់និយាយថ្មី ។

*អគ្គ* នបុំ. អង្គ, អវយវៈតូចធំ, រាងកាយ, ចំណែក, អង្គនៃវេទៈ; ផ្នែកវិទ្យាដូចជាវេទាង្គៈទាំង៦; ឈ្មោះគម្ពីរធំនៃលទ្ធិជិនៈ, អង្គមន្ត្រៈមាន៥ ប្រការគឺៈ ១- *កម៌ាណាំ អារម្ភាបាយ* ឧបាយប្រារព្ធដើម្បីធ្វើការងារ, ២- *បុរុសទ្រវ្យ សម្បទ*, សម្បទគឺបុរសនឹងទ្រព្យ, ៣-*ទិគ កាល-វិភាគ*, ការចែកនូវទិសនឹងកាល,៤-*វិបត្តិ-ប្រតីការ* ការធ្វើប្រឆាំងតនឹងសេចក្ដីវិបត្តិ, ៥-*កាយ៌-សិទ្ធិ* ការសម្រេចនូវកិច្ចការ ទាំង ៥ ប្រការនេះ ហៅថា បញ្ចាង្គៈ ។ *អគ្គតា* ស្ត្រី. ភាវនៃកិរិយាពឹងពាក់ ។ អង្គី - ក្ឫ សូម, កំណត់, បង្កើត ប្រព្រឹត្តទៅតាម, យល់ព្រមតាម ។ - *កតិន* នបុំ. កិរិយាកាត់នូវអង្គ ។ - *កមិន* នបុំ., ឬ -*ក្រិយា* ស្រី. កិរិយាប្រុសព្រំនូវរាងកាយ (ដោយគ្រឿងក្រអូប)។-*គ្រហ* បុំ. "កិរិយាចាប់នូវអង្គ" ការកន្ត្រាក់ ។ -*គ្លានិ* ស្រី. កិរិយាស្វាកនៃអង្គ ឬ រាងកាយ ។

(មានត)

អាពាធ និងបុគ្គលិកមន្ទីរពេទ្យព្រះសង្ឃ ទ្រង់នឹងជួយឧបត្ថម្ភមន្ទីរពេទ្យនេះឲ្យមានវឌ្ឍនភាពតទៅអនាគតជាដើម ។

លំដាប់មកលោក ឃួន-ណៃ ប្រធានសមាគមគិលានសង្គ្រោះ បានថ្លែងសុន្ទរកថា រៀបរាប់អំពីព្រះរាជអំណោយដ៏ថ្លៃថ្លានៃសម្តេចព្រះបិតាឯករាជ្យជាតិ អំពីរាជរដ្ឋាភិបាលដែលបានជួយឧបត្ថម្ភឲ្យមន្ទីរពេទ្យព្រះសង្ឃ អំពីការខ្វះខាតទឹកក្កើនឱសថ អំពីឧបសគ្គផ្សេងៗជាដើម ។

កាលចប់សុន្ទរកថារបស់លោកឃួន-ណៃ សម្តេចព្រះបិតាឯករាជ្យជាតិ ទ្រង់មានព្រះបន្ទូលទៅកាន់រាជរដ្ឋាភិបាលឲ្យជួយឧបត្ថម្ភការខ្វះខាតនិងសម្រួលកិច្ចការ ឲ្យសមាគមនេះមានវឌ្ឍនភាពតទៅ ។

រួចហើយសហជីវិន ប៉យ-ល្មុត រដ្ឋមន្ត្រីក្រសួងធម្មការ បានថ្លែងសុន្ទរកថាទទួលអំណរព្រះគុណាធិគុណនៃសម្តេចជាម្ចាស់ ដែលទ្រង់ធ្វើព្រះរាជអំណោយរថយន្ត ចំពោះសមាគមគិលានសង្គ្រោះនេះនិងទ្រង់ផ្តល់បច្ច័យចំនួន ១០០០៛ ក្នុង ១ ខែ ដល់សមាគមនេះផង សម្រាប់ចាយក្នុងការប្រើប្រាស់រថយន្តនេះតទៅ ថា ទាននេះត្រូវទុកជាព្រហ្មទានមួយដ៏ប្រសើរ ចំពោះព្រះពុទ្ធសាសនា ។

ក្រោយពីសហជីវិនប៉យ-ល្មុត ថ្លែងសុន្ទរកថា, សម្តេចព្រះបិតាឯករាជ្យទ្រង់ស្តេចយាងទតមន្ទីរពេទ្យព្រះសង្ឃ ទ្រង់មានព្រះបន្ទូលថា ទ្រង់នឹងព្យាយាមជួយទំនុកបម្រុងមន្ទីរពេទ្យនេះ តាមព្រះពលកាយ ។

ម៉ោង ១៨ សម្តេចព្រះឧបយុវរាជទ្រង់ស្តេចត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ។

ពិធីនេះចប់នៅម៉ោង ១៨និង៣០ នាទី ដោយបរិយាកាសដ៏រីករាយ ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣០ លេខ ៤ ខែមេសា

ព.ស. ២៥០០ គ.ស. ១៩៥៨

- ភ្នំពេញ -

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## TABLE DES MATIERES

### *PARTIE RELIGIEUSE* :


-Histoire du Bouddhisme au Cambodge ( suite ) par
Vén. *PANG-KHAT* . . . . . . . . . . . . . . . . . . 289
-Deux devoirs dans le Bouddhisme par Vén. *KEM-TO* .. 299
-Réflexion d'un Bouddhiste (suite) par *M. RAY-BUC* . . . 309


### *PARTIE LITTERAIRE* :


-Histoire de Devanda de *M. MOK* (suite) revue
et corrigée par *M. NHOK-THEM* . . . . . . . . . 321
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . . 337
-Conte et Légende du Japon (suite) traduits
par *M.RAY-BUC* . . . . . . . . . . . . . . . . . 353
-Histoire de Sieur « Croûte de riz » (suite) traduite
par *M. TIANG-TAY-CHHUN* . . . . . . . . . . . 355
-Cérémonie traditionnelle « Trot Sang Kran »
par *M. CHAP-PIN* . . . . . . . . . . . . . . . . . . 359
-Quelques proverbes expliqués en vers par *M. CHAP-PIN* ...367
-Histoire d'un prince traduite par *M. LEANG-HAP-AN* ....373


### *NOTES ET CHRONIQUES* :


-Voyage de Nepal à Bengale par *M. RAY-BUC* . . . 377
-Dictionnaire Sanskrit-Khmèr (suite) par
Vén. *PANG-KHAT* . . . . . . . . . . . 382



Prix d'abonnement annuel ( comprenant 12 numéros ) : 230 r 00

# សព្ទសាធុការពរឆ្នាំថ្មី

ព ស ២៥០១

ឆ្នាំប្រសិទ្ធិស័កល្អពិសី ព.ស. គឺពីរពាន់ប្រាំ-
រយមួយត្រឹមត្រូវតាមចំណាំ សង្ក្រាន្តចូលឆ្នាំបរិបូណ៌បាន ៗ
ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រសិទ្ធិពរថ្វាយ-ជូនសព្វឋាន
ឆ្ពោះជាតិសាសនាមហាក្សត្រក្សាន្ត ឲ្យបានថ្កុំថ្កើងវឌ្ឍខេមរា :
សូមព្រះនរបតីបវរក្សត្រ សោយរាជសម្បត្តិខាត់ទុក្ខា
សូមក្រុមព្រះរាជញាតិវង្សា មានរិទ្ធិចេស្តាលាភជ័យជោគ!
សូមពួកព្រះសង្ឃសីលបរិសុទ្ធ បានរួចចេញផុតភ័យក្នុងលោក
មានគតិសាមគ្គីកុំបីស្មោក ប្រយោគព្យាយាមលះភពបី !
សូមព្រះរាជរដ្ឋាភិបាល បានស្រាលបាកកលកិច្ចអប្រិយ
បំពេញកិច្ចការគតផែនដី បានស្រីសួស្តីសុខសាន្តត្រាណ!
សូមពួកនាហ្មឺនគ្រប់ក្រសួង ធំតូចទាំងពួងអម្បាលមាន
បានសុខចម្រើនគ្រប់ៗប្រាណ ស្មោះស្មានបំរើកម្ពុជា !
សូមអស់បណ្តាជនរួមជាតិ បានឃ្លាតចាកទុក្ខភ័យនានា
សំបូរសប្បាយពេញកាល ក្រោមម្លប់រាជាវង្សមហាក្សត្រ !

ពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

# ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

( តមក )

មិនមែនហេតុអ្វីដទៃទេ គឺហេតុតែត្រូវការរកមាសជាធំ បានជាគេគិតពាក្យថា “សុវណ្ណភូមិ„ ឡើង ។ មែនពិត, ជនជាតិឥណ្ឌៀក៏ដូចជនជាតិឱរ៉ុបដែរ ដែលចេញទៅរកមាស នៅទ្វីបអាហ្វ្រិកខាងត្បូងក្តី ឬទៅទ្វីបអាមេរិការដ្ឋកាលីហ្វ័រនីក្តី មិនមែនដោយផ្លូវនយោបាយជាហេតុតែប៉ុណ្ណោះទេ គឺដោយមានបំណងរកមាសជាហេតុផង ។ ភូមិប្រទេសណាមានមាស ក៏តែងមានមនុស្សធ្វើដំណើរ ទៅកាន់ភូមិប្រទេសនោះ ហើយឲ្យឈ្មោះទីឋាននោះ បើជាភាគផែនដីធំថា សុវណ្ណភូមិ បើជាកោះថា សុវណ្ណទ្វីប ហេតុនេះហើយបានជាភូមិប្រទេសយើងនេះ មានសមញ្ញាថា សុវណ្ណភូមិ ឬ សុវណ្ណទ្វីប ឬ អែលដូរាដូ ( Eldorado, chersones d'or ) តាំងពីកាលនោះមក, មិនមែនតែមាសទេ សូម្បីតែគ្រឿងទេសទាំងឡាយដូចក្រវាញ កប្បិរ ខ្លឹមច័ន្ទន៍ក្រស្នា ជាដើម ក៏ជនជាតិឥណ្ឌៀត្រូវការដែរ បានជាមានកើតឈ្មោះថា តក្កោលៈ “ផ្កាលេក់ក្រ-

វាញ" ឈ្មោះថា កប្បុរទ្វីប "កោះកប្បូរ" ឈ្មោះនារិកេលទ្វីប ឬ នាឡិកេរទ្វីប "កោះដូង" ជាដើមឡើង ដូចលោកសឺដែសសរសេរទុកថា:-

"ការពាក់ទងជនជាតិម៉េឌីតែរ៉ាណេ នឹងជនជាតិបូព៌ា ដោយសង្គ្រាមព្រះបាទអាឡិចសង់ដ្រ៍មហារាជក្តី ការកើតអាណាចក្រព្រះបាទធម្មាសោកមហារាជ តមក ព្រះបាទកនិស្កនៅប្រទេសឥណ្ឌាក្តី ការកើតអាណាចក្រពង្សសេឡឺស៊ីដ (Seleucide) នឹងអាណាចក្ររ៉ូម៉ាំង ( Romain ) នៅទ្វីបអឺរ៉ុបក្តី ទាំងអស់នេះកើតឡើងក៏ព្រោះតែ "ភោគទ្រព្យធើត" ដែលជនជាតិឡាតាំង នឹកចង់បានហើយស្តាយតាំងពីគ្រិស្តសតវត្សទី ១ ម្ល៉េះ ៗ ពិតហើយ, គ្រឿងទេស, ខ្ទឹមចន្ទន៍ក្រស្នា, ក្រវាញ, កប្បូរ សុទ្ធតែជាផលិតផល ដោយចំពោះនៃប្រទេស ឬកោះដែលនៅក្រៅដែនដីទន្លេគង្គា ដូចមានឈ្មោះកំពង់ពីអតីតកាលថា តក្កោលៈ (Takkola) "ផ្សារលក់ក្រវាញ", ឈ្មោះកប្បុរទ្វីប "កោះកប្បូរ", ឈ្មោះនារិកេល ឬ កេរទ្វីប "កោះដូង" ព្រមទាំងមានកំពង់ដទៃទៀតច្រើនដែលមានភូមិនាមប្រហែលៗគ្នា ទាំងនេះសំដែងឲ្យឃើញថា អត្ថប្រយោជន៍នេះហើយដែលទាញជនជាតិឥណ្ឌាឲ្យទៅកាន់ទីនោះៗ" ។

នៅក្នុងពិភពលោក ត្រង់ភូមិភាគយើងនេះ មានភូមិនាមជាសំស្ក្រឹតថា ម៉ាសដូចគ្នាច្រើនណាស់ ដូចលោកស៊ុល្វាំងឡេវីសរសេរថា "ពាក្យ

គនគបុរីដែលប្រែថា បុរីមាស,, ក្នុងទីបាន្តរៈ សំដែងឲ្យឃើញថា មាសនេះនាំជនជាតិឥណ្ឌៀមកកាន់សុវណ្ណភូមិនិងឥណ្ឌូណេស៊ី មិនមែនមានតែឈ្មោះសុវណ្ណភូមិ សុវណ្ណទីប ជាពស្តុតាងប៉ុណ្ណោះទេ សូម្បីតែឈ្មោះទន្លេក៏មាននាមថា "មាស" ដែរ ដូចបញ្ជាក់នូវផែនទីប្តូឡេម៉េស្រាប់ គឺប្រាកដជាមាសនេះឯងហើយ ដែលនាំជនជាតិឥណ្ឌៀឲ្យទៅអែលដូរដូ (Eldorado) នៅបូព៌ា" ។

មិនមែនតែជនជាតិឥណ្ឌៀទេ ដែលស្គាល់សុវណ្ណភូមិ ប្តូឡេម៉េអ្នកភូមិសាស្ត្រក្រិក គ្រិស្តសតវត្សទី ២ អ្នកនិពន្ធចិនច្រើននាក់មានកាំងថៃ (k'ang t'ai) គ្រិស្តសតវត្សទី ៣ ជាដើម ក៏បានស្គាល់សុវណ្ណភូមិនេះពិតណាស់ បានជាមានពាក្យហៅថា គេរសោណែសឌ័រ (Chersonèse d'or ) ប្រែថា " ដែនដីមាស " ហៅថា លិន គិន (lin kin) ប្រែថា " ព្រំដែនមាស ឬ កំពែងមាស " ។

ជនជាតិឥណ្ឌៀអ្នកស្វះស្វែងមាស ធ្វើដំណើរដោយសំពៅសមុទ្រ ចេញពីកំពង់ធំៗ នៅឆ្នេរខាងទក្ខិណទិសាភាគប្រទេសឥណ្ឌៀ ដូចកំពង់កមរៈនៅមាត់ទន្លេកវេរិ ១ កំពង់ប៉ូឌូកេ ១ កំពង់សោបត្មៈ ១ ឬតាមកំពង់ធំមួយទៀត នៅមាត់ទន្លេគង្គាឈ្មោះតាម្រលិប្តិ សព្វថ្ងៃហៅ តាមលុក (ជាកំពង់ដែលលោកចិន ហ្វា ហៀនគ្រិស្តសតវត្សទី ៥ ទីនលោក

ចិន យី-គីង៍គ្រិស្តសតវត្សទី ៧ ធ្វើដំណើរត្រឡប់ទៅប្រទេសចិនវិញ) ធ្លោះទៅកាន់កំពង់តូចធំ នៅឯសុវណ្ណភូមិឬគ្រីសេ (chrysé) របស់ប្តូឡេម៉េ ឬកំលិន គិនរបស់ចិន ។

កំពង់ទាំងឡាយពីបុរាណកាលនៅកោះក្តី នៅភូមិភាគផែនដីធំក្តី នៃអាស៊ីភាគអាគ្នេយ៍ ដែលគេបានចូលមកដល់ ហើយគេបានស្គាល់តាមគម្ពីរនិទ្ទេស ឬ តាមបញ្ជីក្នុងផែនទីប្តូឡេម៉េ ឬ តាមឯកសារចិននោះ មាន ដូចខាងក្រោមនេះ :

១- នៅប៉េគូប្រទេសភូមាមានកំពង់ ៣ គឺតក្កោលៈ ១ តេនស្ស្រិម១, វេសុន្ទ១,

២- នៅជ្រោយម៉ាឡាយូមានកំពង់ ១ ឈ្មោះតាំព្រលិង្គៈ

៣- នៅកោះសូមាត្រា មានកំពង់ ១ ឈ្មោះបក្កា

៤- នៅដែនដីមាសជាគ្រីសេរបស់ក្រិក (chrysé des Grecs) ឬ នៅកំពែងមាសជាលិន-គិនរបស់ចិន ។

៥- កំពង់អុកកែវ ជាកំពង់ធំនៅមាត់សមុទ្រនៃប្រទេសកម្ពុជាពីបុរាណ ។

កំពង់ឈ្មោះតេនស្ស្រិមនិងតក្កោលៈ ជាកំពង់បុរាណនៅនាទីឆ្នេរនៃ សមុទ្រឥណ្ឌា ខាងក្រោមប៉េគូប្រទេសមន (ភូមាសព្វថ្ងៃ) មានពាណិជ

តែងចេញចូលធ្វើជំនួញត្រាំញ ៗ លោកសឺដែសសរសេរថាៈ

"កំពង់តក្កោលៈនេះ មានបែនក្នុងគម្ពីរមិលិន្ទបញ្ហាហើយថា តាំង នៅត្រង់ទីក្រុងតាកួបា (takuapa) ជាខាងលិចជ្រោយក្រា (kra) ចិន ហៅថា តៀវ-គីវ-លី (T'eou-kiu-li) គឺកំពង់នេះហើយដែលពួកជំនួញ ប្រទេសនគរភ្នំ (អតីតកម្ពុជា) បានចុះសំពៅទៅកាន់ប្រទេសឥណ្ឌៀពី គ្រិស្តសតវត្សទី៣ៈ

"កំពង់តាំព្រលិង្គនេះ ចិនហៅថា តាន់ ម៉ី លៀវ (tan-mei-lieou) តាំងនៅក្នុងតម្បន់លីគោរ (Ligor) មានសិលាចារឹកសំស្ក្រឹតពីគ្រិស្ត សតវត្សទី ៦ ៗ តាមគម្ពីរនិទ្ទេសបាលីលោកហៅកំពង់នេះថា តាម្រលិង្គ ជាក្រុងចាស់ កើតក្នុងរវាងគ្រិស្តសតវត្សទី ២";

កំពង់បង្កាជាកំពង់បុរាណមួយ លោកសឺដែសសរសេរថាៈ

"កោះសុមាត្រា ដូចជាកោះជាប្ដូរបៃឡេប (Célebes) មានព្រះពុទ្ធ រូបបូរាណរចនាបែបអមរាវតីមួយ នៅខាងលិចស្រុកប៉ាឡេមបាំងលើទួល សេគុនតាំង ៗ ឯកំពង់បង្កានៅនឹងកោះមួយ ខាងកើតកោះស៊ូមាត្រា ទំនង ជាកំពង់នេះហើយ ដែលមានសំពៅឥណ្ឌៀមកមុនគេ ហេតុដូច្នេះ ហើយបានជាមានឈ្មោះនិយាយក្នុងគម្ពីរនិទ្ទេសថា កំពង់វង្គៈ (Vaṅga) ៗ លោកសឺដែលសរសេរបន្ថែមទៀតថាៈ

'ពិតមែនហើយ មានសិលាចារឹកជាភាសាម៉ាឡេស៊ីបុរាណ ៣ កន្លែងនៅកោះស៊ូម៉ាត្រា ពីរនៅស្រុកប៉ាឡេមបាំង (Palembang) មួយទៀតនៅស្រុកការ៉ាំង ព្រាហ៊ី (karang-Brahi) ជាខាងលើស្ទឹងប៉ា-តាំង-ហារី (Patanghari) មានសិលាចារឹកមួយទៀតនៅស្រុកកូតា-កពួរ (kota-kapur) នៅលើកោះបង្កា (Banka) ។ សិលាចារឹកទាំង ៤ នេះបញ្ជាក់ថា ក្នុង គ.ស. ៦៨៣ ៦៨៦ ស្រុកប៉ាឡេមប៉ាំងជារាជអាណាចក្រកាន់ពុទ្ធសាសនា រាជធានីឈ្មោះស្រីវិជ័យ លោកចិនយី-ត្សីង (Yi-Tsing) ហៅថា ចេ-លី-ហ្វូ-ចេ (che-li-fo-che)" ។

នៅមានកំពង់មួយទៀតឈ្មោះក្នុងបច្ចុប្បន្នថា អុក-កែវ ជាកំពង់ពីអតីត នៅមាត់សមុទ្រប្រទេសខ្មែរបុរាណ ។ ខ្ញុំស្តាយណាស់ព្រោះមិនបានស្គាល់អតីតនាមនៃកំពង់នេះ តែពិតជាកំពង់ធំមួយនៃប្រទេសនគរភ្នំ ។ កំពង់នេះនៅចន្លោះប្រទេសចិននិងឥណ្ឌា សម្រាប់ការទាក់ទងជំនួញផ្លូវសមុទ្រទៅកាន់ប្រទេសឆ្ងាយ ៗ ដូចសេចក្ដីដែលលោកម៉ាល្លេរេត៍សរសេរថា:

"គេបានដឹងថាកំពង់ អុក កែវ ជាក្រុងបុរាណនៅមាត់សមុទ្រនៃប្រទេសនគរភ្នំ (Founan) ខាងលិចសមុទ្រសៀម ជាកំពង់សម្រាប់ធ្វើការទាក់ទងនៃជំនួញតាមផ្លូវសមុទ្រ ខាងអាស៊ីភាគអាគ្នេយ៍ ព្រមទាំង

ទៅប្រទេសឆ្ងាយ ៗ ទៅដល់កំពង់ឆ្នេរទក្ខិណទិស នៃប្រទេសឥណ្ឌា, កំពង់នៅមាត់ទន្លេគង្គា ឬ ក៏អាចទាក់ទងរហូតទៅដល់ប្រទេសអ៊ីរ៉ង់នឹងសមុទ្រមេឌីទែរ៉ាណេទៀតផង " ។

នៅកំពង់នេះ គេបានរកឃើញបុរាណវត្ថុ ដែលមានអាយុតាំងពីគ្រិស្តសតវត្សទី១ម្ល៉េះ មានរូបអ្នកស្រុក ទេវរូប ព្រះរូប និងរូបបិយវត្ថុជាតិរ៉ូម៉ាំង ជាតិឥណ្ឌា អក្សរព្រាហ្មី គួរនឹងរាប់ថាជាកំពង់បុរាណ ដែលបានទទួលយកវប្បធម៌ឥណ្ឌា សាសនាព្រាហ្មណ៍ ពុទ្ធសាសនា តាំងពីកាលនោះមក ។

យើងបានទៅរកកំពង់បុរាណ ដែលអ្នកឥណ្ឌាមករកមាស នៅភូមិភាគនេះឃើញហើយ សមគួរល្មមនឹងចុះមតិសម្រេចថា ទីឋានទាំងនេះហើយជាសុវណ្ណភូមិ ព្រោះការសន្មត់នេះ មិនឃ្លាតពីសេចក្ដីពិតណាស់ណាទេ តែមិនត្រូវអស់ចិត្ត ដូចជាថាមិនត្រូវអស់សង្ស័យភ្លាម ៗ គួរតែទុករកតទៅទៀត ដើម្បីឱ្យការចេះដឹងប្រវត្តិនៃសុវណ្ណភូមិបានពិចិត្រពិស្ដារ ទើបខ្ញុំយល់ថា រឿងនេះត្រូវតែរកមើល តាមទស្សនៈអ្នកប្រាជ្ញថែមទៀត ឱ្យបានសព្វមុខសព្វអន្លើ សម្រាប់ប្រើជាប់ការចេះដឹងរបស់យើង ឱ្យបានពេញបរិបូណ៌ ។

ពួកអ្នកប្រាជ្ញទាំងឡាយ ដែលខំរិះរកទីឋានសុវណ្ណភូមិ តាមប្រភព

នានា ទោះជាគម្ពីរមហានិទ្ទេសក្តី ទោះជាបញ្ញើផែនទីប្តូលេមីក្តី ទោះជា សេចក្តីរាយការណ៍អ្នកនិពន្ធចិនក្តី មិនហ៊ានបញ្ជាក់ឲ្យច្បាស់លាស់ជាក់លាក់ទេ គ្រាន់តែដៅ ឬ សន្និដ្ឋានថា ប្រហែលជា ឬទំនងជាត្រង់នេះត្រង់នោះហើយ ។ អ្នកប្រាជ្ញតណ្ឌៀក្នុងបច្ចុប្បន្ន សាស្ត្រាចារ្យ ប. បាប៉ុតសរសេរថា "ព្រះបាទធម្មាសោកមហារាជ បានបញ្ជូនសមណទូតទៅឆ្ងាយហួសកោះសិរីលង្កាទៅទៀត ទៅរហូតដល់សុវណ្ណភូមិ ដែនដីមាស (ប្រហែលមាឡាយូនិងកោះសុមាត្រា) (Suvarnabhumi) the Land of Gold (Malay and Sumatra)" ហើយបន្ថែមសេចក្តីទៅទៀតថា "ប្រកតកោះសិរីលង្កាថា ព្រះមោគ្គលិបុត្តតិស្សត្ថេរបានបញ្ជូនសមណទូតទៅសុវណ្ណភូមិ ហើយថាសុវណ្ណភូមិនៅឯប្រទេសភូមា ។ លោកថា ការពោលនេះ ពុំទាន់យកជាការគួរជឿជាក់បាននៅឡើយទេ បើនឹងថាសុវណ្ណភូមិនៅប្រទេសភូមា មិនបាច់ដេកគ្នាក៏បានដែរ តែបើកាលណាមានអ្នកខ្លះសន្មតថា សុវណ្ណភូមិនៅឯប្រទេសភូមាហើយ គង់មានអ្នកខ្លះទៀតនិយាយផ្សេងទៅវិញ អាចនឹងថា សុវណ្ណភូមិនៅឯប្រទេសសៀម ឬនៅនៃផែនដីអាស៊ី ភាគអាគ្នេយ៍ទាំងមូល ក៏សឹងបានទៀតដែរ ព្រោះថា បើលើកលែង កុំនិយាយរឿងព្រះសោណកត្ថេរនិងព្រះឧត្តរត្ថេរ តាមប្រកតកោះសិរីលង្កានេះចេញហើយ មិនមានភស្តុតាងអ្វីជាក់លាក់លម

នឹងពោលអះអាងថា ព្រះពុទ្ធសាសនារុងរឿង ក្នុងប្រទេសភូមាមុនគ្រិស្ត សតវត្សទី ៤ បានទេ ថ្វីត្បិតតែ ប្រទេសភូមានឹងឥណ្ឌានៅជិតខាងគ្នា នឹងថាទៅមករកគ្នាពុំទាន់បានមុនគ្រិស្តសករាជ ក៏សឹងថាបានដែរ ព្រះពុទ្ធសាសនាប្រហែលជា មិនអាចចូលមកប្រទេសភូមា មុនគ្រិស្តសតវត្សទី៥ បានឡើយ តពីកាលនោះមក ទើបពុទ្ធសាសនាថេរវាទ ចំរើនរុងរឿងក្នុងអាណាចក្រព្យូស (Pyus) ដែលគេបានស្គាល់ថាជាអាណាខេត្តស្រីក្សេត្រៈ ទីក្រុងនៅជិត (Prome) នឹងមានបុរាណដ្ឋាននៅម៉ាហ្សា (Maza) សព្វថ្ងៃនេះ" ។

ពាក្យដែលសាស្ត្រាចារ្យប៉ាប៉ុតថា សុវណ្ណភូមិ នៅជ្រោយម៉ាឡាយូ (នឹងសុមាត្រា) ក្នុងវង់ក្រចកយ៉ាងនេះ សមនឹងពាក្យលោកសីដែសដែរ ។ ក្នុងខយលក្ខណៈសៀវភៅលោក មានសេចក្តីថា "កិត្តិគនាគ. ជាសិស្សព្រះមហាថេរអសង្គៈ បានសិក្សានៅមហាវិទ្យាល័យនាលន្ទា អស់រយៈវេលា ៣០ ឆ្នាំ ហើយបានទៅសុវណ្ណទ្វីប (កោះសុមាត្រា ឬ ម៉ាឡេស៊ី) ក្នុងវង់ក្រចក ហើយលោកបន្ថែមទៀតថា "បើលើកលែងកុំនិយាយពីរឿងព្រះសោណត្ថេរនឹងឧត្តរត្ថេរ ជាសមណទូតដែលព្រះបាទធម្មាសោកមហារាជបានបញ្ជូនទៅសុវណ្ណភូមិ ក្នុងពុទ្ធសតវត្សទី៣ហើយ មកសន្មតថា សុវណ្ណភូមិនៅឯប្រទេសមុនបុរាណនោះ មិនដឹងជាថានេះ

ខុស ឬ ត្រូវទេ ដោយបំពោះថាទៅ ថាតុង (Tha tong) ជាទីក្រុងសុធម្មវតី ឬសុធម្មបុរៈពីបុរាណកាល ខ្ញុំមិនឃើញមានបុរាណដ្ឋានអ្វីមួយជាសក្ខីភាព ល្មមឲ្យស្គាល់បានថា មានវប្បធម៌ឥណ្ឌាបានចូលមកទីនេះ ពីអតីតកាលមុនសន្លឹកមាសចារឹកជាបាលីថា "យេ ធម្មា ហេតុបភវា ហើយដែលគេបានរកឃើញនៅម៉ាហ្សា Maza នឹងនៅម៉ោងគាន (Moung-gan) ជាទីឋានបុរាណនៅប្រោម (Prome) កាលគ្រិស្តសតវត្សទី ៤ នោះបានឡើយ" ។

សេចក្តីយល់អ្នកប្រាជ្ញទាំងពីរខាងលើនេះ ក៏មិនខុសនឹងពាក្យលោកស៊ីល្វាំងឡេវីដែរ លោកថា "ប្រភពចិនមាននិយាយថា ព្រះបាទហ្វាន់ចេ-មុន (ស្រីមារៈ?) ជាព្រះរាជានគរភ្នំ ទ្រង់ទិវង្គតក្នុងឱកាសដែលទ្រង់លើកសែនឡានុភាពទៅច្បាំងប្រទេស គិន លិន (kin-lin) "ព្រំដែនមាស" ត្រូវនឹងពាក្យថាសុវណ្ណភូមិ ដូចប្រភពបាលី ឬ សុវណ្ណកុដ្យៈ ដូចប្រភពសំស្ក្រឹតដែលសន្មតថា នៅ (ភាគក្រោមប្រទេសភូមា ឬ ជ្រោយម៉ាឡេស៊ី) ដែរ" ។

សមន្តប្បាសាទិកា ជាប្រភពបាលីកោះសិរីលង្កាក៏ថា សុវណ្ណភូមិជាកោះដែរ ដូចមាននិទានដំណាលថា "កាលព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរ

☛ (មានត)

# ធុរៈក្នុងព្រះពុទ្ធសាសនា ២ យ៉ាង

ព្រះទេពសត្ថា ពិម-គួរ រៀបរៀង

( តមក )

ពុទ្ធឱវាទដែលមានសេចក្តីសំដែងអំពីការធ្វើការបំពេញកុសលផ្សេងៗ មានទាន សីល ភាវនាជាដើម ហៅថា ព្រះសូត្រ មានឈ្មោះ ៥ គម្ពីរគឺ ទីឃនិកាយ១ មជ្ឈិមនិកាយ១ សំយុត្តនិកាយ១ អង្គុត្តរនិកាយ ១ ខុទ្ទក-និកាយ១ បើចាត់ទៅជាពួកក្រុម ឬជាគន្ធដែលកំណត់ដោយធម្មក្ខន្ធនោះ មាន ២ ហ្មឺន១ពាន់ធម្មក្ខន្ធ ហៅថា សុត្តន្តបិដកៗ នេះមានចំនួន ៦៣សៀវភៅ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពចេញរួចហើយចំនួន ៣៨ សៀវភៅ នៅសល់ចំនួន២៥ សៀវភៅទៀត កំពុងតែចាត់ការបោះពុម្ពទៅឲ្យត្រាតែចប់សុត្តន្តបិដក ដើម្បីបំពេញអធ្យាស្រ័យរបស់អស់លោក-អ្នកពុទ្ធបរិស័ទដែលត្រូវការ ។ ពុទ្ធឱវាទដែលមានសេចក្តីសំដែងយ៉ាងល្អិតល្អន់អំពីចិត្ត ចេតសិក រូប និព្វាន ហៅថា អភិធម្ម មានឈ្មោះ ៧ គម្ពីរគឺ ធម្មសង្គណី១ វិភង្គ ១ ធាតុកថា ១ បុគ្គលប្បញ្ញត្តិ ១ កថាវត្ថុ ១ យមកៈ ១ បដ្ឋាន១ បើចាត់ទៅជាពួកក្រុម ឬជាគន្ធ ដែលកំណត់ដោយធម្មក្ខន្ធនោះមាន ៤ ហ្មឺន ២ ពាន់ធម្មក្ខន្ធហៅថា អភិធម្មបិដក ។ នេះមានចំនួន ៣៤ សៀវភៅ ពុទ្ធសាសនបណ្ឌិត្យ ពុំទាន់បោះពុម្ពនៅឡើយទេ តែបំរុងនឹង

បោះពុម្ពគ្នានវេលាដែលចប់សុត្តន្តបិដកនោះតទៅ ។ ហេតុនោះ សៀវភៅព្រះត្រៃបិដកដែលអស់លោក - អ្នកពុទ្ធបរិស័ទបានដាវយកទៅខ្លះហើយនោះ មិនទាន់ចប់ត្រឹមប៉ុណ្ណោះទេ នៅចំនួន ៥៩ សៀវភៅទៀតទាំងព្រះសូត្រទាំងព្រះអភិធម្ម ។ សៀវភៅព្រះត្រៃបិដកដែលបានបោះពុម្ពចេញស្រេចហើយនោះចំនួន ៥១ សៀវភៅ គឺវិនយបិដក ១៣ ក្បាល សុត្តន្តបិដក ៣៨ ក្បាលនៅសល់ជាងពាក់កណ្ដាលទៀត ។

ពុទ្ធសាសនបណ្ឌិត្យយល់ឃើញថា វត្តនីមួយៗដែលមានលោកគ្រូចៅអធិការ ឬអាចារ្យវត្តជាអ្នកដឹកនាំឲ្យដាវព្រះត្រៃបិដកដំកល់ទុកក្នុងវត្តសម្រាប់ភិក្ខុ-សាមណេរសិក្សាជាការប្រសើរល្អណាស់ ប៉ុន្តែវត្តខ្លះទើបមិនមានព្រះវិនយបិដក ១៣ ក្បាល វត្តខ្លះបាន ៦១ ក្បាល វត្តខ្លះបាន ២៥ ក្បាល ឬ ៣០ ក្បាល ប៉ុណ្ណោះក៏ឈប់បាត់ទៅ ឬមួយក្រុបទេក៏ពុំដឹង ? ដកបមកដល់ឥឡូវនេះ ក៏ពុំទាន់ឃើញមកទទួលយកតទៅទៀត បើប្រសិនជាឈប់មែន គួរឲ្យស្ដាយយ៉ាងក្រៃលែង ព្រោះសៀវភៅព្រះត្រៃបិដកភាគមកខាងចុងៗសម្បូរដោយគន្ថធម៌ និងសេចក្ដីអធិប្បាយនៃគន្ថធម៌នីមួយៗយ៉ាងពីរោះហើយប្លែកៗ ផងទៀត ដែលយើងពុំធ្លាប់ដឹងពុំធ្លាប់ឮ ។

ព្រះត្រៃបិដកនេះ មិនមែនមានតែក្នុងប្រទេសយើងទេ ប្រទេសឯទៀតដូចជាប្រទេសថៃ ភូមា ឥណ្ឌា លង្កា និងទុរប ជាដើមក៏មាន

ដែរ ប៉ុន្តែគេបោះពុម្ពជាភាសាបាលីសុទ្ធ មិនមានប្រែជាសម្រាយឲ្យចប់សព្វគ្រប់ ដូចប្រទេសយើងដែលកំពុងធ្វើសព្វថ្ងៃនេះទេ ។ ប្រទេសយើងដែលបានព្រះត្រៃបិដកបោះពុម្ពបាលីម្ខាង សម្រាយម្ខាងនៅទន្ទឹមគ្នានេះ ប្រៀបដូចជាបានប្រទីបប្រគោមធំពីរដួរ តាំងនៅអមផ្លូវទាំងសងខាងជាគ្រឿងបំភ្លឺឲ្យអ្នកដើរទៅកាន់ទីដ៏ក្សេមក្សាន្ត ។ ព្រះត្រៃបិដកដែលយើងពលគ្នាបានតែមួយចប់ក៏ពិតមែន តែទុកដូចជាបានពីរចប់ដែរ ព្រោះបានបោះពុម្ពបាលីម្ខាង សម្រាយម្ខាង ចង់មើលតែខាងបាលីក៏បាន មើលតែខាងសម្រាយក៏បាន ឈ្មោះថាជាប្រយោជន៍ដ៏សំខាន់ក្នុងការពិនិត្យផ្ទៀងសេចក្តីឲ្យដឹងខុសត្រូវ ។

អ្នកកាន់ព្រះពុទ្ធសាសនា ទោះបព្វជិតក្តី គ្រហស្ថក្តី គួរធ្វើចិត្តឲ្យមានសេចក្តីស្រឡាញ់ជ្រះថ្លា ចំពោះព្រះត្រៃបិដក ដែលមានសេចក្តីប្រែជាសម្រាយភ្ជាប់នៅទំព័រម្ខាងនោះឲ្យច្រើន ព្រោះសង្គីតិកាចារ្យ គឺក្រុមជំនុំព្រះត្រៃបិដក ដែលបានពិនិត្យផ្ទៀងផ្ទាត់បាលីឲ្យត្រឹមត្រូវហើយប្រែចេញមកជាសម្រាយបោះពុម្ពនោះ ឃើញថាជាកិច្ចមានប្រយោជន៍ច្រើនប្រការណាស់ គឺ ១-សេចក្តីប្រែជាសម្រាយនាំឲ្យងាយមើល ងាយស្តាប់ជាងបាលី ព្រោះលោកអ្នកប្រែបានរិះគិតរកទំនងសេចក្តីឲ្យស្រួលមើល ស្រួលស្តាប់រួចជាស្រេចហើយ ។ ២- ធ្វើដំណើរព្រះពុទ្ធសាសនា តាំងពីខាងដើម

ហេតុដល់ខាងចុង គឺតាំងពីព្រះសម្មាសម្ពុទ្ធមិនទាន់ចូលនិព្វាន ហេតុមកដល់ឥឡូវនេះឲ្យច្បាស់លាស់ឡើង មិនឲ្យគប់កបាំងបាត់ ។ ៣- បើពុទ្ធបរិស័ទមានបំណងនឹងរៀនសូត្រ នឹងប្រតិបត្តិតាមសីល សមាធិ បញ្ញា ក៏មានបរិបូណ៌ ក្នុងព្រះត្រៃបិដកនោះដោយសព្វគ្រប់ ។ ល ។

ព្រះត្រៃបិដកទុកដូចជាកញ្ចក់សម្រាប់ឆ្លុះមើលឲ្យឃើញការល្អអាក្រក់ ឬទុកជាច្បាប់យ៉ាងពិសេស សម្រាប់តម្រឹមតម្រង់បង្អុរបង្ហាញផ្លូវដល់អ្នកកាន់ព្រះពុទ្ធសាសនាគឺឲ្យដឹងថា នេះខុស នេះត្រូវ នេះទោស នេះគុណ ឬឲ្យដឹងថាអំពើនេះនាំឲ្យចំរើន នេះនាំឲ្យវិនាស ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក អ្នកកាន់ព្រះពុទ្ធសាសនា គ្មានអ្វីជាគ្រឿងកាន់ក្រៅអំពីព្រះត្រៃបិដកឡើយ ។

ព្រះត្រៃបិដកជាគោល ជាអាយុជីវិតនៃអ្នកកាន់ព្រះពុទ្ធសាសនា បើអ្នកកាន់ព្រះពុទ្ធសាសនា មិនមានព្រះត្រៃបិដកទុកនៅប្រចាំវត្តទេ ឬមិនសូវអើពើនឹងព្រះត្រៃបិដក ឬក៏មិនយកចិត្តទុកដាក់ស្រាហ៍មើលព្រះត្រៃបិដកទេ ជាហេតុឲ្យអ្នកកាន់ព្រះពុទ្ធសាសនានោះ មានសេចក្តីយល់ខុស ប្រព្រឹត្តខុសឃ្លៀងឃ្លាតចាកសេចក្តីពិតទៅក៏មាន ។

កាលបើអ្នកកាន់ព្រះពុទ្ធសាសនា មានសេចក្តីយល់ខុសប្រតិបត្តិខុស ហើយបានឈ្មោះថា ធ្វើពុទ្ធសាសនា គឺធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធឲ្យ

ស្រអាប់បាត់ពន្លឺរស្មីវិនាសថយខ្សោយចុះទៅជាលំដាប់ ក៏ជាហេតុនាំដឹក នាំមនុស្សទាំងពួងអ្នកជឿស្តាប់ពាក្យខ្លួន ឲ្យវង្វេងកាន់គំនិតសំគាល់ខុសថា ជាត្រូវ សំគាល់ត្រូវថាជាខុសទៅវិញដោយច្រើន ដូចគ្នានឹងព្រះអាទិត្យ ព្រះចន្ទរះឡើងកំពុងមានរស្មីពន្លឺត្រចះល្អ បើមានសភាវៈដទៃ មានរាហូ អសុរិន្ទឬពពកជាដើម ចូលមកបៀតបៀនជ្រៀតជ្រែក បិទបាំងព្រះ អាទិត្យនិងព្រះចន្ទកាលណាហើយ ពន្លឺរស្មីដែលកំពុងរុងរឿងល្អនោះ ក៏ ប្រែទៅជាស្រអាប់បាត់ពន្លឺវិនាសសូន្យទៅមួយរំពេច ក្នុងកាលនោះឯង ឯធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធក៏ដូច្នោះដែរ ។

រួមសេចក្តីដែលបានពណ៌នាមកថា ធម៌វិន័យដែលមានមកក្នុងព្រះ ត្រៃបិដក បានចំរើនរុងរឿង ឬវិនាសសាបសូន្យទៅ ក៏ដោយសារតែ ពួកពុទ្ធបរិស័ទទាំងបព្វជិត ទាំងគ្រហស្ថហ្នឹងឯង ។

ក្នុងគម្ពីរមនោរថបូរណី មានសេចក្តីសំដែងយ៉ាងច្បាស់លាស់ ចោទ ជាបញ្ហាសួរថា ព្រះពុទ្ធសាសនាគឺធម៌និងវិន័យ ដែលអាចរុងរឿងតាំង នៅអស់កាលជាយូរអង្វែងទៅបាន អាស្រ័យដោយសារបរិយត្តិគឺការរៀន ព្រះត្រៃបិដកជាឬសគល់ ឬក៏អាស្រ័យដោយសារបដិបត្តិ ការប្រតិបត្តិ ជាឬសគល់ ? បញ្ហានេះ សូមទាញយករឿងដែលមានក្នុងគម្ពីរដដែលនេះ មកឆ្លើយបញ្ជាក់ថា មានភិក្ខុពីរពួកគឺ ភិក្ខុខាងបរិយត្តិរៀនព្រះត្រៃបិដក

មួយពួក ភិក្ខុខាងប្រតិបត្តិកាន់ធុតង្គវត្តមូលមួយពួក ។ ពួកខាងភិក្ខុអ្នកប្រព្រឹត្តការធុតង្គវត្តមូលឆ្លើយឡើងថា បដិបត្តិជាឫសគល់នៃព្រះពុទ្ធសាសនា ។ ឯពួកភិក្ខុខាងបរិយត្តិឆ្លើយឡើងថា បរិយត្តិការរៀនព្រះត្រៃបិដក ជាឫសគល់ព្រះពុទ្ធសាសនា ។ ខណៈនោះព្រះថេរៈដែលតាំងនៅជាកណ្តាលប្រកាសឡើងថា យើងពុំទាន់យល់ស្របព្រមតាមពាក្យរបស់លោកទាំងសងខាងទេ សូមលោកទាំងឡាយ លើកយកសូត្រជាភាសិតនៃព្រះជិនស្រីសម្មាសម្ពុទ្ធមកពោលតាំងផងទើបបាន ។ លំដាប់នោះពួកភិក្ខុខាងកាន់ធុតង្គវត្តមូលលើកយកសូត្រពីរអន្លើមកពោលអាងថា ឥមេ ច សុភទ្ទ ភិក្ខូ សម្មា បដិបត្តឹ វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្ស សេចក្តីថា "ម្នាលសុភទ្ទ! ប្រសិនបើភិក្ខុទាំងឡាយនេះ មានការប្រតិបត្តិដោយប្រពៃជាប្រក្រតីលោក(នេះ) មិនគប្បីសូន្យចាកព្រះអរហន្តទាំងឡាយឡើយ " ។

បដិបត្តិមូលកំ មហារាជ សត្ថុ សាសនំ បដិបត្តិយំ ធរន្តេ តិដ្ឋតិ " បពិត្រមហារាជ! សាសនារបស់ព្រះសាស្តាមានសេចក្តីប្រតិបត្តិជាឫសគល់ ឋិតនៅលើអ្នកទ្រទ្រង់សេចក្តីប្រតិបត្តិ " ។

ឯពួកភិក្ខុខាងបរិយត្តិរៀនព្រះត្រៃបិដក ក៏នាំយកសូត្រមួយនេះមកពោលអាងថា :

យាវ តិដ្ឋន្តិ សុត្តន្តា   វិនយោ យាវ ទិប្បតិ
តាវ ទក្ខន្តិ អាលោកំ   សុរិយេ អព្ភុដ្ឋិតេ យថា ។
សុត្តន្តេសុ អសន្តេសុ   បមុដ្ឋេ វិនយម្ហិ ច
តមោ ភវិស្សតិ លោកស្ស   សុរិយេ អដ្ឋង្គតេ យថា ។
សុត្តន្តេ រក្ខិតេ សន្តេ   បដិបត្តិ ហោតិ រក្ខិតា
បដិបត្តិយំ ឋិតោ ធីរោ   យោគក្ខេមា ន ធំសតិ ។

សេចក្តីថា ព្រះសូត្រទាំងឡាយឋិតនៅដរាបណា ព្រះវិន័យនៅរុងរឿងដរាបណា សត្វលោកក៏អាចនៅឃើញពន្លឺបានដរាបនោះ ដូចជាព្រះអាទិត្យដែលរះខ្ពស់ត្រដែតឡើងដូច្នោះឯង ។ កាលបើព្រះសូត្រទាំងឡាយមិនមានទេ ទាំងព្រះវិន័យក៏ភិក្ខុភ្លេចភ្លាំងអស់ទៅហើយដែរ ងងឹតអំពអន្ធការក៏នឹងកើតមានដល់សត្វលោក ដូចជាព្រះអាទិត្យដែលអស្តង្គតបាត់ពន្លឺដូច្នោះឯង ។ កាលបើភិក្ខុទាំងឡាយ នៅរក្សាព្រះសូត្រ(និងព្រះវិន័យ) បាននៅឡើយ សេចក្តីប្រតិបត្តិក៏ឈ្មោះថាជាគុណជាតិដែលភិក្ខុនៅរក្សាបានដែរ ធីរជន អ្នកឋិតនៅក្នុងសេចក្តីប្រតិបត្តិ រមែងមិនខានកាត់ឃ្លាតចាកធម៌ជាដែនក្សេមចាកយោគៈឡើយ ។

កាលពួកភិក្ខុខាងបរិយត្តិរៀនព្រះត្រៃបិដក នាំយកព្រះសូត្រមកសំដែងការដូច្នេះហើយ ពួកភិក្ខុខាងប្រតិបត្តិកាន់ធុតង្គក្រមួល ក៏យល់

ស្របជាមួយគ្នា ហើយនៅស្ងៀមទៅ ។

សេចក្ដីនេះ លោកបានអធិប្បាយបន្ថែមដោយសេចក្ដីប្រៀបធៀបបំភ្លឺថា ហ្វូងគោដែលមានសុទ្ធតែគោបាទាំងរយទាំងពាន់ កាលបើមិនមានមេគោជាសត្វរក្សាតំណបវេណីនៅក្នុងហ្វូងគោបានោះផងទេ វង្សប្រវេណី ឬពូជគោនោះឯង ក៏មុខជានឹងដាច់សូន្យទៅយ៉ាងណាមិញ បរិយត្តិធម៌ក៏ដូច្នោះដែរ ទោះបីមានភិក្ខុច្រើនរូបដល់ទៅរយពាន់ក៏ដោយ បើសុទ្ធតែជាអ្នកកាន់ធុតង្គក្រុមមួលប្រារព្ធវិបស្សនាកម្មដ្ឋាននៅអាស្រ័យក្នុងព្រៃ តែបើមិនមានភិក្ខុអ្នករៀនបរិយត្តិគឺព្រះត្រៃបិដកជាពូជទេ ឬបរិយត្តិអន្តរធានទៅដោយហេតុណាមួយហើយ ការធ្វើសេចក្ដីប្រតិបត្តិផ្សេងៗ ដើម្បីឲ្យបានឈានសមាបត្តិមគ្គផល ក៏ពុំមានដែរ ព្រោះមិនមានបរិយត្តិព្រះត្រៃបិដកជាច្បាប់សម្រាប់ចង្អុលបង្ហាញបំភ្លឺផ្លូវប្រតិបត្តិឲ្យត្រឹមត្រូវទៅបាន ។ លោកប្រៀបថាដូចជាអក្សរដែលគេឆ្លាក់ភ្ជាប់នៅនឹងផ្ទាំងថ្ម ដើម្បីជាគ្រឿងសំគាល់ឲ្យដឹងនូវទីដែលមានផ្ទាំងកំណប់ទ្រព្យដែលគេកប់ទុក ដរាបណាអក្សរនោះនៅមិនទាន់រលុបលាយបាត់ទៅទេ ដរាបនោះ ផ្ទាំងកំណប់ទ្រព្យនោះឈ្មោះថាមិនវិនាសបាត់ទៅនៅឡើយ យ៉ាងណាមិញ; ឯពុទ្ធសាសនានេះ ក៏យ៉ាងនោះឯង បើបរិយត្តិគឺព្រះត្រៃបិដក នៅមានភិក្ខុទ្រទ្រង់សិក្សារៀនសូត្រនៅឡើយ ឬមិនទាន់អន្តរធានទៅដោយហេតុណា

មួយទៀត សាសនា របស់ព្រះសម្មាសម្ពុទ្ធ ក៏មិនទាន់អន្តរធានសាបសូន្យទៅដែរ ព្រោះអាស្រ័យបរិយត្តិជាប្រមាណ គឺបរិយត្តិការរៀនព្រះត្រៃបិដក ជាឫសគល់របស់ព្រះពុទ្ធសាសនា ដូចសេចក្តីដែលពណ៌នាមកនេះ ។

នៅទីអវសានៃធម្មទេសនានេះ អាត្មាភាពសូមថ្វាយព្រះរាជកុសល ចំពោះព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ ព្រមទាំងសម្តេចព្រះវររាជបុត្រ ... 

ចំពោះព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ ព្រមទាំងសម្តេចព្រះយុវរាជ សូមឲ្យព្រះអង្គទ្រង់បរិបូណ៌ដោយព្រះសុខភាព និងវឌ្ឍនភាព ក្នុងព្រះសិរីរាជសម្បត្តិ អស់កាលជាយូរអង្វែងដើម្បីជាម្លប់នៃប្រជាពលរដ្ឋទៅ ។ មួយទៀត សូមជូនកុសលនេះចំពោះលោកអ្នករាជការ គ្រប់ឋានៈមានព្រះរាជវង្សានុវង្ស ... 

មានព្រះរាជវង្គាភិបាលជាដើម ព្រមទាំងប្រជាជនពលរដ្ឋ ពុទ្ធសាសនិក សូមឲ្យអស់លោក អ្នកបានឋិតនៅក្នុងសុខភាព និងវឌ្ឍនភាពគ្រប់ប្រការ កុំបីឲ្យអាក់ខានឡើយ ។

ការសំដែងអំពីធុរៈព្រះពុទ្ធសាសនា ២ យ៉ាង ក៏សូមកំណត់ចាប់ដោយសេចក្តីសង្ខេបត្រឹមប៉ុណ្ណេះ តាមសមគួរដល់កាលវេលា ។

ភ្នែកមកតោងមើលអាការបេញ

ពោលពាក្យម្ដេចមិញគង់ឃើញពិត

ពាក្យស្នេងវែងសួតបួនជាមិត្រ

ពាក្យពិតបួនពាលមមាលវិញ

ពាក្យលេងបួនឡកលប្រាជ្ញា

ពាក្យព្រាងមុសាការគេដេញ

អួតៗនតោងឃ្លាតពីខ្លៅបេញ

ស្រឡាញ់តោងថ្នមលោមមើលចិត្ត

គេលើកកុំឡើងទៅតាមយស

ឡើងខ្ពស់មើលទាបរក្សាមិត្រ

ដើរមុខៗទុកក្រោយកុំឲ្យជិត

លោកប្រែតោងប្រព្រឹត្តចិត្តកុំប្រែ ។

# សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់

## លោក រ៉ាយ-ប៊ុក រៀបរៀង

(តមក)

---

កាលណាព្រះសិទ្ធត្ថបានចម្រើនវ័យវឌ្ឍនាការ ពេញបរិបូណ៌ឡើង ព្រះបរមរាជបិតាទ្រង់ចង់រកព្រះអគ្គមហេសី ថ្វាយព្រះរាជឱរស ។ ទ្រង់បានចាត់អាមាត្យឲ្យប្រមូលនារីទាំងឡាយចូលមក ក្នុងព្រះបរមរាជវាំង ។

ក្នុងពេលនោះ គេបានចាត់ឲ្យនាងកញ្ញាទាំងនោះ ត្រាច់ដើរចំព្រះភក្ត្រព្រះអង្គៗ ទ្រង់ពេញព្រះរាជហឫទ័យនឹងព្រះនាងយសោធរា ជាព្រះរាជបុត្រីព្រះបាទទណ្ឌបាណិសាក្យៈ (ខាងព្រះពុទ្ធសាសនាថេរវាទថា ព្រះបាទសុប្បពុទ្ធ) ។ ព្រះនាងយសោធរាទ្រង់យាងមកគង់នៅមហាប្រាសាទមានទាសី ២០.០០០ នាក់ ហែហមផង ។

ចំពោះព្រះនាងគោបិកា គឺមានរឿងរ៉ាវដូច្នេះ "កាលដែលព្រះសិទ្ធត្ថកុមារវិលត្រឡប់មកកាន់នគរកបិលពស្ដុ, ក្រោយដែលទ្រង់បានកាត់ក្បាលពស់នាគរាជមួយ ដែលធ្វើវិនាសកម្ម ចំពោះអ្នកស្រុកជាច្រើនកន្លែង ទ្រង់បានទតទៅឃើញនាងកញ្ញាមួយរូប នៅលើប្រាសាទនាមនាងគោបិកាជាធីតាក្នុងរាជវង្សសាក្យៈ ។ ទ្រង់គង់លើព្រះរាជរថ, ទ្រង់ក៏បានបញ្ឈប់ពាជីដោយយកព្រះបាទទប់គង់ព្រះរាជរថ ។ ក្នុងពេលនោះ ព្រះនេត្រនៃព្រះ

ដូច្នេះ ទ្រង់ក៏សព្វព្រះរាជហឫទ័យនឹងព្រះនាង, ទ្រង់ក៏បោះខ្សែកទៅឲ្យព្រះនាង, ខ្សែ កនោះក៏ធ្លាក់ទៅលើស្មាព្រះនាង ។ ព្រះបាទសុទ្ធោទនៈទ្រង់បានជ្រាបដូច្នោះ ក៏ទ្រង់ឲ្យហៅព្រះនាងស្រគជាមកគង់ក្នុងប្រាសាទឯព្រះបរមរាជវាំង ហើយទ្រង់ព្រះរាជទានទាសី២០.០០០នាក់ ជាបរិវារ ។

បើតាមគម្ពីរ " លលិតវិស្តរៈ " នៃព្រះពុទ្ធសាសនាអាចារិយវាទខាងជើងថា : ព្រះអគ្គមហេសី នៃព្រះសិទ្ធត្ថទ្រង់ព្រះនាម " គោបា " ជាព្រះរាជបុត្រីសាក្យៈទណ្ឌបាណិ ( អ្នកកាន់ដំបង ) ។

តាមគម្ពីរ " ជីវភាពវិថីនៃព្រះពុទ្ធ " បានពោលថា : ព្រះពុទ្ធទីបង្ករៈទ្រង់បានប្រកាសចំពោះសុមេធតាបសថា " មួយយេ កំឡុងមកទៀត , លោកនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គទ្រង់ព្រះនាមព្រះសក្យមុនី , ព្រះវរបិតាទ្រង់ព្រះនាមព្រះបាទសុទ្ធោទនៈ ព្រះវរមាតា ព្រះនាងមហាមាយាទេវី , ព្រះអគ្គមហេសី ព្រះនាមនាងគោបា , ព្រះរាជបុត្រា ព្រះនាមរាហុលកុមារ " ។

តាមគម្ពីរ "អភិនិស្ក្រមណសូត្រ" ពោលថា : " កាលព្រះអង្គម្ចាស់ទ្រង់មានព្រះជន្មាយុ ១៩ ឆ្នាំ , ព្រះវរបិតាទ្រង់

បានជ្រើសរើសព្រះនាងយសោធរា ជាបុត្រីនៃសក្យៈ រដ្ឋមន្ត្រីមហានាម ជាព្រះអគ្គមហេសី ” ។

បើតាមខ្ញុំសង្កេតមើល តាមរឿងរ៉ាវក្នុងព្រះពុទ្ធសាសនា ដែលមានចារិកក្នុងព្រះត្រៃបិដក , ព្រះសិទ្ធត្ថមានព្រះអគ្គមហេសីតែមួយព្រះអង្គ គឺព្រះនាងយសោធរា ( ព្រះនាងពិម្ពា ) ។

តែបើតាមគម្ពីរ លលិតវិស្តរៈ អត្ថបទសំស្ក្រឹតនិងទីបេត៍ ១, គម្ពីរ ជីវភាពទីពីរនៃព្រះបរមសម្ពុទ្ធភាគពីរ ១, គម្ពីរ ព្រះវិន័យពួកធម៌គុប្តៈ ១ ជាតក ១ បានពោលថា “ ព្រះសិទ្ធត្ថមានព្រះអគ្គមហេសីតែមួយព្រះអង្គ ទ្រង់ព្រះនាម “ គោបា ” ជាព្រះរាជបុត្រីទណ្ឌបាណិ ” ។

បើតាមគម្ពីរ លលិតវិស្តរៈ អត្ថបទដែលចិនប្រែ១ , គម្ពីរជីវភាពទីពីរនៃព្រះបរមសម្ពុទ្ធ ភាគបួន ១ គម្ពីរ ព្រះវិន័យពួកមហាសង្ឃិកៈ ១ គម្ពីរចិនផ្សេងៗ ១ , គម្ពីរសទ្ធម្មបុណ្ឌរិកសូត្រ ១, គម្ពីរ និព្វាណសូត្រ ១ , បានថ្លែងថា : “ ព្រះសិទ្ធត្ថទ្រង់មានព្រះអគ្គមហេសីតែមួយព្រះអង្គ ទ្រង់ព្រះនាម “ យសោធរា ” ។ គម្ពីរ លលិតវិស្តរៈ និងគម្ពីរ ព្រះវិន័យពួកមហាសង្ឃិកៈ បានបញ្ជាក់ថា ព្រះនាងយសោធរា ជាបុត្រីទណ្ឌបាណិ ។ ចំណែកឯគម្ពីរ ជីវភាពទីពីរនៃព្រះបរមសម្ពុទ្ធថា ព្រះនាង

យសោធរា ជាបុត្រីមហានាម ។

បើតាមគម្ពីរ ពហុលមាលាជាតក បានពោលថា ៖ ព្រះសិទ្ធត្ថ មានព្រះអគ្គមហេសីពីរព្រះអង្គ គឺ ព្រះនាងយសោធរា ១ អង្គ និងព្រះនាងគោបា ១ អង្គ ។

បើតាមគម្ពីរ វិន័យមូល សិក្ខាវិភង្គ ១, ទុលវៈ១, ដំណាលនៃព្រះបរមសម្ពុទ្ធកាល១, គម្ពីរចិនជាច្រើន បានថ្លែងថា ព្រះសិទ្ធត្ថមានព្រះអគ្គមហេសី ៣ព្រះអង្គគឺ

១- ព្រះនាងយសោធរា ជាបុត្រីទណ្ឌបាណិ,

២- ព្រះនាងគោបីកា ជាបុត្រីកិណកនិស្សរ,

៣- ព្រះនាងម្រគជា ជាបុត្រីកាលាក្រម ។

មានគម្ពីរខ្លះថា ព្រះនាងគោបីកា, គម្ពីរខ្លះថា ព្រះនាងគោបា, ខ្លះទៀតថា ព្រះនាងគោបី, ចំណែកឯព្រះនាងយសោធរា, មានគម្ពីរខ្លះថា ព្រះនាងយសោធរា ជាបុត្រីទណ្ឌបាណិ គម្ពីរខ្លះថា ជាបុត្រីមហានាម, គម្ពីរខ្លះថា ជាបុត្រីសុប្បពុទ្ធ ។

តែបើទុកជាយ៉ាងណាក៏ដោយ យើងមិនអាចដោះស្រាយនូវបញ្ហាថា "ព្រះសិទ្ធត្ថទ្រង់មានព្រះអគ្គមហេសី ៣ ព្រះអង្គ ឬ ២ ព្រះអង្គ ឬ ១ ព្រះអង្គ" ទេ ឡើយ ។

ពិតមែនបើថា ព្រះអគ្គមហេសី ទី ១ គឺព្រះនាងគោបា , ទី ២ គឺព្រះនាងយសោធរា, ទី ៣ គឺព្រះនាងម្រគជា, តែមាតាព្រះរាហុលកុមារគឺព្រះនាងយសោធរា ( ព្រះនាងពិម្ពា ) ។

បើតាមពិនិត្យឲ្យជ្រៅឆ្ងាយទូលាយទៅ, យើងនឹងអាចយល់បានថា: " គម្ពីរព្រះពុទ្ធសាសនា មុនសតវត្សទី ៤ ពោលថា ព្រះអគ្គមហេសីព្រះសិទ្ធត្ថទ្រង់ព្រះនាមគោបី, ក្នុងដើមសតវត្សទី ៤, មានគម្ពីរខ្លះថាព្រះអគ្គមហេសីព្រះសិទ្ធត្ថ ទ្រង់ព្រះនាម គោបី, គម្ពីរខ្លះថា យសោធរា, ហើយក្រោយ គ.ស. ២៥០ ទើបព្រះនាមព្រះនាងយសោធរាតែមួយព្រះអង្គមានបារកក្នុងគម្ពីរជាច្រើន " ។

បើពិនិត្យតាមគម្ពីរ ព្រះពុទ្ធសាសនាខាងជើង ច្រើនពោលថា ព្រះនាងយសោធរា, តែមានគម្ពីរជាតកបាលីពោលថា ព្រះនាងពិម្ពា ឬ ភទ្ទកច្ចានា ក្នុងគម្ពីរ ពុទ្ធវង្ស; លោករីសដាវិដ្សបានពោលពីព្រះនាងភទ្ទកច្ចានា, គម្ពីរ ជិនត្ថបកាសិនី បានពោលថា: " ព្រះអង្គម្ចាស់ទ្រង់បានជ្រើសរើសព្រះអគ្គមហេសីទ្រង់ព្រះនាម " ពុទ្ធកច្ចានា " ហើយទ្រង់បានថ្វាយព្រះនាមថា ព្រះនាង " យសោធរាពិម្ពាទេវី "; លោកហ៊ឺណ្ណក៍បានពោលថា : " បើតាមអក្សរសាស្ត្រពុទ្ធសាសនានៃប្រទេសលាវ, មានជាតកខ្លះបារកថា : ព្រះនាងពិម្ពាថេរី , " ។

ហេតុដូច្នេះ យើងអាចពោលបានថា: "ព្រះសិទ្ធត្ថកុមារមានព្រះអគ្គ-មហេសី ប៉ព្រះអង្គគឺ

១ ព្រះនាងគោបី បុត្រីទណ្ឌបាណិ (ប្រហែលជាមានសម្មតិនាមថា កិណកិទិស្សរៈ) ព្រះសិទ្ធត្ថទ្រង់ធ្វើព្រះរាជសមសេនឹងព្រះនាងគោបី តាំងពីទ្រង់មានព្រះជន្មាយុ១៧ឆ្នាំ ; ព្រះនាងទ្រង់គ្មានបុត្រទេ ។

២ ព្រះនាងយសោធរា (ព្រះនាងពិម្ពា) ជាបុត្រីមហានាម បើតាមពុទ្ធសាសនាប្រទេសកម្ពុជាថា បិតាព្រះនាងយសោធរា គឺសុប្បពុទ្ធ បើតាមគម្ពីរព្រះពុទ្ធសាសនាដោយភាគច្រើនបានពោលថា ទណ្ឌបាណិ ជាបិតាព្រះនាងគោបី, មហានាមជាបិតាព្រះនាងយសោធរា, សុប្បពុទ្ធជាបិតាព្រះនាងមហាមាយាទេវី និងព្រះនាងបជាបតីគោតមី ព្រះនាងយសោធរាមាតាព្រះរាហុលកុមារ ។

៣- ព្រះនាងម្រគជា ជាបុត្រីកាភិកៈ (គម្ពីរខ្លះថា កាលាក្រមៈ, ខ្លះថា សាក្យៈប្រយហបតិ) ។

បើតាមពិនិត្យឲ្យច្បាស់លាស់ទៅ, ព្រះនាងគោបី ដោយគ្មានបុត្របានជាព្រះបាទសុទ្ធោទនៈទ្រង់ជ្រើសរើសព្រះនាងយសោធរា (ពិម្ពា) ជាព្រះអគ្គមហេសី ។ ចំណែកឯព្រះនាងម្រគជា ដែលព្រះសិទ្ធត្ថបានយកធ្វើជា

ព្រះរាជទេវី , ក្រោយដែលទ្រង់ទតឃើញនិមិត្តទាំងបួន ប្រហែលជាទ្រង់មិនបានស្ថិតនៅរួមសុខទុក្ខ ជាមួយនឹងព្រះសិទ្ធត្ថអស់យូរកាលទេ ព្រោះព្រះសិទ្ធត្ថទ្រង់ត្រូវយាងទៅសាងព្រះផ្នួស , រត់ចោលព្រះនាងយសោធរា, តែបើទុកជាយ៉ាងណាក៏ដោយ ស្រេចនៅបណ្ឌិតខាងព្រះពុទ្ធសាសនាអនាគតវិនិច្ឆ័យតទៅទៀតចុះ ។

## ៤ អំពីរឿងបុណ្យនិងបាប

សួរ -- អ្វីដែលហៅថា បុណ្យ ? ។

ឆ្លើយ · បុណ្យជាអរូបធម៌ ជាធម្មជាតជំរះសន្តានចិត្តរបស់សត្វឲ្យស្អាតប្រៀបបីដូចជាតម្រងទឹកធ្វើទឹកឲ្យថ្លាៈ ទុកជាបុណ្យ· បុណ្យដែលជំរះសន្តានចិត្តឲ្យថ្លាស្អាត ជាសេចក្តីល្អដែលចិត្តបានធ្វើបានប្រព្រឹត្ត ។

សួរ ·- មែនពិត, បុណ្យជានាមធម៌ បានត្រង់កម្មដែលមនុស្សប្រព្រឹត្តសុចរិត, ល្អ ត្រង់ មានកាយសុចរិត, វចីសុចរិត, មនោសុចរិត, មានទាន, សីល, សមាធិ, បញ្ញា ជាដើម ។

សួរ · តើអ្វីជាហេតុឲ្យកើតបុណ្យ ?

ឆ្លើយ .- ហេតុដែលឲ្យកើតបុណ្យមាន ៣ យ៉ាងគឺ បសាទោ សេចក្តីជ្រះថ្លា, សំវេគោ សេចក្តីសង្វេគ, តេសុចរិតា បំពេញសុចរិត ៣ ។

សួរ.- បុគ្គលអ្នកឲ្យទានត្រូវប្រកបដោយចេតនាប៉ុន្មាន ? ។.

ឆ្លើយ.- ត្រូវប្រកបដោយចេតនា ៣ គឺ បុព្វចេតនា ១, មុញ្ចនចេតនា១, អបរាបរចេតនា១,។ បុព្វចេតនា គឺមុននឹងឲ្យវត្ថុជាដំបូងត្រូវមានចិត្តសទ្ធាជ្រះថ្លា, មុញ្ចនចេតនា គឺពេលដែលកំពុងឲ្យត្រូវមានចិត្តសទ្ធាជ្រះថ្លាទៀត, អបរាបរចេតនា គឺឲ្យវត្ថុនោះហើយត្រូវនឹករលឹកដល់បុណ្យដែលធ្វើនោះញយៗទៀត, នឹកពេលណា បុណ្យកើតពេលនោះ ។

សួរ.- ពាក្យថា សីលតើសីលអ្វីខ្លះ? ។

ឆ្លើយ.- សីល គឺ សីល ៥, សីល ៨, សីល ១០, សីល ៤ ដែលមានសិក្ខាបទ ២២៧ ។

សីលដែលបុគ្គលប្រព្រឹត្ត, ប្រតិបត្តិទៅហើយបានបុណ្យនោះ លុះត្រាតែប្រព្រឹត្តទទួលសីលនោះហើយ ត្រូវយកសីលនោះមករក្សាឲ្យមាំចក់កុំឲ្យធ្លុះធ្លាយ កុំឲ្យពព្រុសពពាល, ត្រូវពិនិត្យតាមសិក្ខាបទដែលបានកាន់ឲ្យបានល្អ, ព្យាយាមដុសខាត់សីលនោះឲ្យស្អាត, បរិសុទ្ធ កុំឲ្យសៅហ្មង ។

សួរ.- ដូចម្តេចហៅថា ភាវនា ? ។

ឆ្លើយ.- ភាវនាដែលកុលបុត្របានរក្សាសីលបរិសុទ្ធ, ផូរផង់ហើយទើបចំរើនភាវនាបាន ។ ភាវនាមាន ៣ យ៉ាង គឺ បរិកម្មភាវនា ១

ទុបដាភាវនា ១, អប្បនាភាវនា ១ ។ ភាវនានេះជាកុសលខ្ពស់ជាងគេ ។

សួរ - កុសលចិត្តមានប៉ុន្មានយ៉ាង? ។

ឆ្លើយ- កុសលចិត្តមាន ៤ យ៉ាងគឺ កាមាវចរកុសល ១, រូបាវចរកុសល ១, អរូបាវចរកុសល ១, លោកុត្តរកុសល ១ ។

កាមាវចរកុសលមាន៨ គឺ សោមនស្សកុសល , ឧបេក្ខាកុសល ៤។

រូបាវចរកុសលមាន ៥ យ៉ាង គឺៈ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ បញ្ចមជ្ឈាន ១ ។

អរូបាវចរកុសលមាន ៤ យ៉ាង គឺៈ អាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ១ អាកិញ្ចញ្ញាយតនៈ១ នេវសញ្ញានាសញ្ញាយតនៈ១។

លោកុត្តរកុសលមាន ២០ យ៉ាងឬ ៤ យ៉ាង លោកុត្តរកុសល ២០ យ៉ាង គឺ លោកុត្តរបឋមជ្ឈាន ៤ លោកុត្តរទុតិយជ្ឈាន ៤ លោកុត្តរតតិយជ្ឈានន ៤, លោកុត្តរចតុត្ថជ្ឈាន ៤, លោកុត្តរបញ្ចមជ្ឈាន ៤ ។

លោកុត្តរកុសល ៤ គឺ សោតាបត្តិមគ្គ ១, សកទាគាមិមគ្គ ១, អនាគាមិមគ្គ ១, អរហត្តមគ្គ ១ ។

កុសល, បើគ្រាន់តែកាមាវចរកុសលមានដោយពិស្តារ ១.៦៨០ គឺ

មហាកុសល ៨ គុណ × បុញ្ញកិរិយាវត្ថុ ១០ = ៨០

៨០ × អារម្មណ៍ ៦ = ៤៨០

$$\frac{៤៨០}{២} = \begin{matrix} ញាណសម្បយុត្ត ២៤០ \\ ញាណវិប្បយុត្ត ២៤០ \end{matrix}$$

ញាណសម្បយុត្ត ២៤០ × អធិបតី ៤ = ៩៦០

ញាណវិប្បយុត្ត ២៤០ × អធិបតី ៣ = ៧២០

បូករួម ១៦៨០ ฯ

សួរ ៈ បុះអកុសលចិត្តមានប៉ុន្មានយ៉ាង? ฯ

ឆ្លើយ ៈ អកុសលចិត្តមាន ១២ យ៉ាងគឺ លោភមូល ៨, ទោសមូល ២, មោហមូល ២ ฯ

សួរ ៈ អកុសលឲ្យផលយ៉ាងណាខ្លះ? ฯ

ឆ្លើយ ៈ អកុសលឲ្យផលគឺទៅកើតអបាយភូមិ ៤ គឺ នរក ១, ប្រេត ១, អសុរកាយ ១ តិរច្ឆាន ១, បើមកកើតជាមនុស្ស ជាមនុស្សវិកល, វិការៈ, គ្រលំបាក, ខ្វាក់, ខ្វិន គ, ថ្លង់, មានជម្ងឺច្រើនជាដើម ฯ មនុស្សកើតមកមានភ្នែកខ្វាក់ មកពីបុគ្គលនោះសោយផលបាបអកុសល, ក្នុងបដិសន្ធិកាល ៣៩ ថ្ងៃ គ្មានបុណ្យបាបឲ្យផលទេ, បុណ្យបាបឲ្យផលក្នុងបវត្តិកាល គឺក្រោយ ៣៩ ថ្ងៃ ដែលសត្វបដិសន្ធិ គឺ

បាប, អកុសលក៏មកឲ្យផលពេលនោះ ចក្ខុម្ខាង ក៏បែកធ្លាយ, បានជាបុគ្គលនោះខ្វាក់ភ្នែកម្ខាង ។

សួរ–· បុណ្យនឹងបាប, តើអ្នកណាឲ្យ ? ។

ឆ្លើយ–· បុណ្យនឹងបាប គឺខ្លួនឲ្យខ្លួនឯង គឺខ្លួនធ្វើ. ប្រព្រឹត្តបុណ្យឬបាបហើយ· ត្រូវខ្លួននោះឯងទទួលផលល្អឬអាក្រក់ សមដូចពុទ្ធភាសិត. ធម្មបទខុទ្ទកនិកាយថា:

សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ប្រែថា សេចក្តីបរិសុទ្ធិ នឹងមិនបរិសុទ្ធិជារបស់ចំពោះខ្លួន អ្នកដទៃនឹងញុំាងអ្នកដទៃឲ្យបរិសុទ្ធមិនបានឡើយ ។

សួរ –· ចុះមានសាសនាខ្លះប្រដៅថា គេត្រូវមុជទឹកលាងបាប តើបាបនោះជ្រះឬទេ ? ។

ឆ្លើយ –· បាបមិនមែនលាងដោយទឹកស្ទឹងនោះទេ , បាបត្រូវលាងដោយការព្យាយាមលែងប្រព្រឹត្ត, លែងធ្វើតទៅទៀត តែអ្នកដែលទៅមុជទឹកលាងបាបនោះ គឺសំដៅយកចិត្តជ្រះថ្លាចំពោះទឹកស្ទឹងដែលគេទុកជាទឹកសោមៈ, ទឹកអម្រឹត, បើតាមពិត គឺចិត្តដែលលះបាបអកុសលនោះឯង ។

(មានត)

# ផ្នែកអក្សរសាស្ត្រ

## រឿងៈឥរវង្ស (ពាក្យកាព្យ)

លោក អម្មាត្យត្រីម៉ុក រៀបរៀង ក្នុងរជ្ជព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក-ថែម ពិនិត្យ ( តមក )

---

ហើបហែលទៅមក ក្នុងបោក្ខរណី គិតព្រះ ឥតបី ត្រូវពីបិទ្ធា ។ ហើយនាង ទុបាយ កល់គិតនិយាយ ថាយើងកល់គ្នា លេងនេះទៀយខ្លួន លេងពួន វិញផា បិទមុខពល់គ្នា តេលេងប្រពោយ ៗ អស់ទាំងស្ងំស្ងួត សោតសឹង ដូចចិត្ត ពុំគិតទុបាយ សឹងទៅដើមកផ្កាប់ ពពស្រូតទាំងឡាយ ហៅគ្នា ប្រញាយ មកជុំត្រង់ទី ៗ សឹងបានទៅពួន ដោយខ្លួនដោយខន នូវស្តំ នារី មួយបិទមុខមាំ ឈរចាំនៅទី រាជទេវី សុវណ្ណកេសរ ។ ទៅពួន លាក់កាយ នៅទាំងផ្ទះយាយ ទាំងគុម្ពផ្កាប្រ យោងនិយល់ព្រះបាទ នរ នាថភូធរ ឯកអង្គបវរ នីរក្សកណាយល់ ៗ

កាលណោះព្រះពោ-ធិសត្វសេដ្ឋា វរញាណវេសពាល ពុស្ត៏ បុតា នាងនាដនិមិល យាងយាត្រាដល់ ទាំងផ្ទះយាយអា ៗ ព្រឹព្រួបក្លា ក្លាក់ ប្រាស់ប្រែព្រះភ័ក្ត្រ បែរបើកកៅតា ឯអង្គទៅតាមទៅ ទតទៅគុម្ពផ្កា យល់វរធីតា គង់នៅឯកអង្គ ៗ មនោអ្នកនឹក ក្តីគាំងត្រូវតឹក ហេតុដោយ

កិស្សវង់ ក្លួបកើតបេតី មេត្រីត្រេកត្រង់ ពេញព្រះទ័យទ្រង់ រំពឹងថាៗ នាងនេះវិសាល វិសេសត្រកាល ត្រកូលជាតិជា កន្លង់លែងស្រី ទាំងត្រីលោកា នឹងរកស្រីណា ប្រៀបផ្ទឹមពុំបាន ។ ម្ដោះប្ដូមាសមិត្រ មានតែបរិត កកបកល្យាណ បញ្ញាសតិ នត្ថិមិនមាន ប្រុះប្រាជ្ញាញាណ ម្ដមានប្រាជ្ញា ។ គិតគួរអញនឹង ប្រស្នាបង់ដឹង ស្រេចមហាក្សត្រា យកផ្កាបទុម ក្រពុំមួយផ្កា រីកមួយមហា ក្សត្រថ្វៃបោះទៅ ។

ក្សត្រីយង់យល់ ក្សត្រានិមិល ឯកអង្គឥតសៅ គង់នាបង្ខំ លបលួចទតទៅ នាងនាដចមចៅ ក្លួបកើតស្នេហា ។ អៀនអន់ផាក់ក្រក្រ គង់គិតថាអ្នក នេះរូបថ្វៃថ្លា កន្លង់លែងប្រុស ជាបុរសអាជា នេយ្យនិរអ្នកណាទៅប្រៀបផ្ទឹមបាន ។ ប្រកបលក្ខណា ទុក្ខិសាការ ប្រុះប្រាជ្ញាញាណ បណ្ឌិលបណ្ដាច់ សារពេជ្របួយាន ប្រសើរថ្កើងថ្កាន ជាម្ចុដកតវត្រ ។ នាងគិតកាលណោះ យល់ស្ដែងស្ដេចបោះ ផ្កាផ្ដោះកក្រថ្វៃ ហេតុព្រះអំណាចប្រុះប្រាជ្ញញាណញេយ្យ ជ្រាបឥតសង្ស័យ នឹងប្រាជ្ញាថា ។ ឯផ្កាក្សត្រក្សាន្ត សួរថាបើមាន គួរគូស្នេហា ឲ្យយករីកពិត បើឥតកស្ដា ឲ្យចាប់យកផ្កា ដែលនៅក្រពុំ ។ អង្គអញនឹងលង ប្រាជ្ញាកល់ល្បង ក្សត្រក្សាន្តឧត្ដម គិតស្រេចធីតា ចាប់ផ្កាក្រពុំ ហត្ថាបង្គំ ផ្ទេចព្រះនេត្រា ។ រួសរត់ទៅទី ជុំស្នំនារី បន្ទូលទៅថា ឥឡូវសុរិយេន៍ ពាបទន់សន្យា យើង

ល្មមយាត្រា ទៅកាន់ទីឋាន ៗ ត្រាស់ស្រេចកែក្រោយ គន់គ្រែសិវិកាយ
ស្នំនូវពាហន ហែហាយាត្រា ដោយមាគ៌ាឋាន នាងនាដបកបាន គ្រប់ក
បទុមា ៗ ទំលាក់ខ្លុះពោយ ដកបរៀនដោយ ដានដងមាគា ដំរុះកេសរ បរ
បុប្ផា លុះដល់ប្រាង្គប្រា-សាទសុខសួស្តី ៗ លុះពេលល្មមសោយ ស្នំ
លើកព្រះស្ងោយ ថ្វាត់ថ្វាយក្សត្រី នាងគិតខ្មាយ ទុកថ្វាយបក្រី ទើប
មានសវនីយ៍ នឹងអស់ស្នំថា ៗ អញញ៉ាំវេជ្ជិយ អញពុំទាន់ធី បូរហាងនាំគ្នា
លើកមកទុកខាង ទែនទីសោយស្រា អញចង់កោត្កា សិមអញបរិភោគ ៗ
អស់ស្នំចាំងឲ្យាយ ពុំដឹងខ្មាយ នាងនាដពន្ទុក បង្កិនាំគ្នា ម្ចមាលើក
យក ព្រះភាជន៍មាសមក ទុកខាងបន្ទំ ៗ ស្រេចនាំគ្នាទៅ នាងនាដនិត្យ
នៅ ឯកឯងរំពៃ ពឹងពីពង់ត្រុទ្ធ ខ្ញុំក្សត្រខ្មត្តម រកប្រស្នាខ្ញុំ យល់ថ្កាំ
យល់ ៗ ខ្ញុំអ្នកប្រល្ហ ល្ហល្ហះកក្រ ក្រអ្នកខ្ទុំមដល់ ជាធ្វើមលោកា ថ្ងៃថ្ងា
ថ្កើងថ្កល់ ញាំងមានយោបល់ ប្ដូមួយពុំមាន ៗ បំណាចប្រាសថ្ងៃ ជាធ្វើម
ភពត្រៃ មានប្រាជ្ញាញាណ ធៀវឈ្លាសផ្ទាស់ផ្ទុះ លែងប្រុសសព្វបាន
មកផ្ទឹមពុំបាន មិនអ្នកឡើយណា ៗ នាងគិតមហាក្សត្រ សម្ងំស្ងៀមស្ងាត់
ពុំចេញចរចា សញ្ជប់សញ្ជឹង ទ្រូងផ្ទាំមហា ឬរសថ្ងៃថ្ងា អ្នកនឹងយាងទៅ ៗ

ថ្ងៃឯងពះពោ-ធិសត្វពេ ធិកាដបមពៅ បញ្ញាតិក្ខុន ដរទប្រាបពៅ
កាលព្រះប្អូនពៅ ប្រស្នាថ្វាយមក ៗ ទ្រង់ជ្រួតជ្រាបថា នាងនាដចាប់ផ្តា

ក្រពុំនោះយក ប្រាយប្រាប់មកថា នាងនាដពន្ធុក នឹងអ្នកណាមក ជាតិ
ជាស្វាមី ៗ ខ្លួននៅក្រមុំ ដូចផ្កាក្រពុំ ពុំទាន់មានប្ដី ឆ្មបក្អកបន្តិ ព្រះ
បរមចក្រី នៅវិតក្សត្រី ក្រាបទូលស្ដេចថា ៗ ហើយបង្អឹត ដូចនាងឆ្មប
បិទ នៃព្រះនេត្រា ក្សត្រីឧត្តម បន្តិនោះថា ឲ្យអញ្ជើញមហា-បុរស
ស្ដេចទៅ ៗ សម្ដេចក្សត្រា ស្ដេចជាបប្រស្នា នៃព្រះប្អូនពៅ ទ្រង់ត្រេក
ហាក់បាន រួមហ៊ានថៃបនៅ ទន្ទឹងយប់ជ្រៅ នឹងចរយាត្រា ៗ

បឋមយាមេ អតិក្កន្តេ បឋមយាមា យាមដំបូងរំលង កន្លងចូលជា
មជ្ឈិមយាមា យាយតាដេកលក់ ៗ ស្ដេចរៀបព្រះអង្គ ព្រះករស្ដេចទ្រង់
ព្រះខ័នទីរទុក្ខ ស្រេចហើយក្សត្រា បើលាជាសុខ មកបិតនៅមុខ របង
យាយតា ៗ នឹកដល់សេះស្រេច មកដល់រំពេច ដូចព្រះចិន្តា ស្ដេចប្រាប់
អស្សយាន កាលបានប្រស្នា នឹងវរធីតា សព្វគ្រប់ហេតុផង ៗ សេះ
ស្ដាប់គួរ ព្រឺព្រមត្រេកអរ អញ្ជើញច្បាស់ប្បង ឡើងគង់ខ្នាប់ស្រេច
នាំស្ដេចចរផ្គង ដោយត្របកឈូកផង ដែលនាងរុះរោយ ៗ លង់លុះដល់
ទ្វារ បន្ទាយទេព្ដា បើកស្រោប់ទុកឲ្យ សេះនាំក្សត្រា លីលាតាមដោយ
នារីរុះរោយ កេសរបទុមា ៗ ព្រះបាទភូមី ស្ដេចសូត្រមណី-ចិន្ដាមន្ដជា
សណ្ដំអស់មនុស្ស ស្រីប្រុសនានា ស្រាតសឹងនិទ្រា ដូចក្ស័យជីវិត ៗ
លុះទៀបប្រាសាទ រស្មីព្រោងព្រាត ធ្លាស់ធ្លុះពេកពិត មណីមាសពាស-

ពេជ្រ ស្តែងស្តេចទេវេត លុះចូលទៅជិត ប្រាសាទពេជហ៊ាន ៗ យានចុះ
ចាកសេះ ហើយទ្រង់សំណោះ នឹងអគ្គអស្សយាន ហៃបងអស្សតរ ចូរ
ឈរឈប់ខាន ប្រយ័ត្នប្រុងប្រាណ កុំប្រហែសកាយ ៗ រវៀសរវាំង គន់
មើលអស់ទាំង មនុស្សម្នាទាំងឡាយ កុំបងបែរបោល ចរពោលប្អូនឆ្ងាយ
ក្រែងក្រក្រែងឆ្ងាយ ឲ្យបានជួបគ្នា ៗ ស្តេចផ្តាំសេះសព្វ ព្រះម្កុដក្រែកព
ប្រុងព្រះកាយា ចូលក្នុងទីឋាន ពិមានសុវណ្ណា ប្រទីបផ្កាលា ក្លីពោត
ក្រោងក្រោយ ៗ អស់ទាំងតាស់ទុំ ដេកស្វាត់ជ្រងំ ពុំក្លាក្លាក់កាយ ខ្វះដេក
ស្រមុក ក្រុកៗព្ទាយ សំពត់រសាយ ពោលដោះនៅក្រៅ ៗ ស្តេចហួសពី
ស្នំ ចូលដល់បន្ទំ នៃព្រះប្អូនពៅ នាងជ្រាបដាក់ជា ក្សត្រាចូលទៅ សម្ងំ
ផ្ទំនៅ ដូចស្លាប់កាយា ៗ ចង់ដឹងក្សត្រក្សាន្ត ស្តេចនឹងអាចហ៊ាន ពះពាន
ពាធា ឬមួយដាស់ហៅ ដោយនូវវាចា មុទុប្ដា ប្រការដូចម្តេច ៗ មហា-
ក្សត្រឧត្តម យន់យល់នាងផ្ទំ ស្មានស្លាប់ហើយស្តេច គយគន់លក្ខណា
ឥរិយាសព្វសេច គ្រេចគ្រប់លក្ខណ៍លេច លើសលែងស្រីផង ៗ ពេញ
ព្រះទ័យសល់ ពុំអាចទប់ទល់ បៀតបៀនត្រកង ថែរថើបដាក់នៅ ទ្រូគ្ន-
រង ព្រះស្ងួរសាសង លួងលោមពរពា ៗ ព្រលឹងបងអើយ បងមកដល់
ហើយ កុំកែវនិទ្រា បំណាច់ប្អូនស្ងួន ខ្ញុំមខ្លួនពុំង៉ា ផ្តាំឲ្យយាត្រា មក
រកប្អូនស្រី ៗ

នាងនាដស្ដាប់ជាក់ ធ្វើជាភ្ញាក់ បង់ល្បែងនរបតី បម្រះចុះទៅ ពីគ្រៀបគ្រែ ប្រែព្រះភក្ត្រខ្ចី បង្គំទូលថា ៗ មហាក្សត្រពន្លក ព្រះអង្គស្ដេច មក អំពីឋានណា ពោធិ៍ស្ដាប់ហើយ ឆ្លាស់ឆ្លើយទៅថា ហៃស្ងួនពុំឆ្ងារ បងអ្នកពុំដឹង ៗ

នាងសួរវឹងថា ព្រះអង្គយាត្រា មកហើយតើនឹង ស្ដេចទៅឋានណា ក្សត្រាឆ្លើយវឹង បងអ្នកពុំដឹង ជាទៅឋានណា ៗ នាងនាដទូលស្នើ បើដូច្នោះតើ សម្ដេចក្សត្រា បានទ្រង់ជ្រាបខ្លះ ឬព្រះរាជា ពុំដឹងដូចគ្នា សូមប្រោសប្រណី ៗ

ស្ដេចឆ្លើយវិលវឹង ប្អូនអើយបងដឹង ខ្លះដែរប្អូនស្រី នាងថាបពិត្រ មហាក្សត្រធិបតី កាលដើមបក្រី ត្រាស់ថាពុំដឹង ៗ សូមក្សត្រប្រសើរ ប្រាយប្រាប់ដំណើរ ឲ្យខាន់ខ្ញុំនឹង បានដឹងអស់អាថ៌ ក្សត្រាឆ្លើយវឹង ហៃប្អូនព្រលឹង ពន្លកស្នេហា ៗ បងអ្នកមកកើត យោះយកកំណើត ជាតិជាមនុស្សា ពុំដឹងពីស្រុក នរកទេព្ដា បានជាបងថា បងអ្នកពុំដឹង ៗ

នាងនារីរត្ន ក្រញាំក្រាបប្រណិបត្ត ទូលតបវិលវឹង នាមមហាក្សត្រា ត្រាស់ថាស្ដេចដឹង ខ្លះតើដំណឹង ដំណើរដូចម្ដេច ៗ

ស្ដេចឆ្លើយវឹងថា ប្អូនអើយមនុស្សា ទោះរាស្ដ្រទោះស្ដេច សព្វសត្វទេព្ដា សង្ខារតែងផ្ដាច់ ផ្ដល់ឲ្យសម្រេច រូបកាយមរណា ៗ ពុំដែលនឹងនៅ

ហេតុនេះប្អូនពៅ បានជាបងថា បងបានដឹងខ្លះ ព្រោះព្រះទេសនា ថា សង្ខារ ពុំទៀងនឹងនៅ ។

នាងទូលវិញថា បពិត្រក្សត្រា នាព្រះចមទៅ ត្រាស់ថាពុំដឹង ដំ-ណឹងទឹងទៅ ទីឋានលំនៅ ទៀតតើដូចម្ដេច ។ ស្ដេចឆ្លើយវិញថា ហៃប្អូនស្នេហា សួគសង្សារសាច់ អនិច្ចសញ្ញា សង្ខារផ្ដិលផ្ដាច់ រូបឲ្យសម្រេច ពុំដឹងជានឹង ។ ទៅកើតនរក ឬឋានសួគ៌សុខ បងអ្នកពុំដឹង នាងស្ដាប់ក្សត្រា ចិន្ដារំពឹង ថាអ្នកនេះដឹង គេអ្នកផ្ដឹមគ្នា ។ អង្គអតិរេក ចម្លើយចំឡែក លែងមនុស្សស្រព្យឋាន គិតស្រេចបង្គំ បរមក្សត្រក្សាន្ដ សួរស្នោះដោយដាន ដោយដំណើរថា ។ ព្រះអង្គបេរបេរ ពិតពីនគរ គោត្រនាមា មាតាបិតុរង្គ ព្រះអង្គឯកា ឬមានព្រះមហា ព្រះមហេសីហើយ ។

ពង្សព្រុទ្ធក្ខូរ បែរបើកបន្ទូល មធុរឆ្លាស់ឆ្លើយ ហៃមាសមិត្រស្ងួន ខ្ញុំមខ្លួនបងអើយ បិតាត្រាណត្រើយ ទ្រង់នាមព្រហ្មទត្ត ។ សម្ដេចមាតា ទ្រង់នាមវិមលា រីបូរីរដ្ឋ ឈ្មោះពារាណសី ព្រះបិតាក្សត្រ ព្រះអង្គសន្ធត នាមបងទេវទ្ទ ។ បងអ្នកទំនេរ អង្គឯកឥតមហេ សីទេណាគង់ នាងស្ដាប់អភិប្រាយ ក្រាបថ្វាយអភិវ-ន្ទាទើបទូលដ-ណ្ដឹងដោយដំណើរ ។

ហេតុម្ដេចចក្រី ចរពាលបូរី មានព្រះដំណើរ ទឹងទៅឋានណា ក្សត្រាប្រសើរ មកដល់អាយតើ ប្រាថ្នាកស្តុអ្វី ។

ស្ដេចឆ្លើយវិញថា ហៃប្អូនជាតិជា ឆ្មួតឆ្មើមបវរ បងស្ទុះស្វែងមក
បងយកប្អូនស្រី ជាតិជាមហេសី គួរគូផងគ្នា ។

នាងទូលវិញថា បពិត្រមហាក្សត្រ បវរក្សត្រា គ្មានស្រីដល់ម្នាក់
កបលក្ខណា ប្រសើរគួរជា មហេសីប្អី ។

ស្ដេចឆ្លើយវិញថា ប្អូនអើយហោរា ព្រាហ្មណ៍ពិទូរសេទី ឲ្យសារ-បណ្ដាំ ទៅនាំបុត្រី ក្សត្របុះបុរី រយឯកអង្គា ។ មកឲ្យបងជ្រើស បានស្រាលរកើស យកជាពនិតា មិនមានគ្រប់លក្ខណ៍ ដល់ម្នាក់គួរជា អគ្គអគ្គមហា មហេសីថ្លៃ ។ បានជាបងចរ ចេញចាកនគរ ហោះទីង មនោម័យ មកបានប្រទះ ព្រះឥសីសេយ្យ នាមអសេន្ធយ្យ ប្រោសប្រាប់បងថា ។ នៅក្នុងលោកិយ មានតែប្អូនស្រី ប្រសើរថ្លៃថ្លា ទោះទេពអប្សរ កិន្នរគ្រុឌា មនុស្សទ្វេរយក្សា សឹងផ្ទឹមពុំបាន ។ ជាឆ្មើមកញ្ញា អាចអគ្គអ៊ី ។ កម្រប៉ុន្មាន ដោះស្រាយពុំយូរ ជាគួបុរាណ ប មជាតិក្សាន សានទីង អញបង ។ លោកឃាត់បងឈប់ ដេកបានបីយប់ ក្រាបសព្វ ងាយផង ជ្រោះប្រេកជ្រោយស្ទឹង ប្តូបងព្រៃផង ប្តូយក្ខយង់ឃ្លង អាស្រ័យទិត្យទៅៗ ស្រេចហើយបងលា ឥសីសីលា មករកប្អូនពៅ ប្រទះយក្ខស្រី អប្រិយ ឃោរឃៅ តតាំងចាំងទៅ កណ្ដាលមគ្គា ។ បងសម្លាប់យក្ខ ដួរជាតិ អប្បលក្ខណ៍ ក្សិណក្ស័យជន្មា លុះដល់មកស្ទឹង សុទ្ធសិងមច្ឆា ស្រេប

ស្រុះនាំគ្នា បម្ងបង់អ្នក ។

នាងនាដស្តេងស្តាប់ ព្រះសូរសារសព្ទ ក្សត្រថ្ងៃវរល័ក្ខណ៍ ព្រំព្រម បេតី មេត្រី ស្មោះស្ម័គ្រ គឺមោះស្មើរស្មាក់ ផ្កាជានារី ។ ទើបទូលវិងថ្កាន បពិត្រខ្ញុំមាន ជនកជននី បើព្រះប្រាថ្នា ជាតិជាទេពី សូមព្រះភូមី ប្រោសប្រាណមេត្តា ។ ចូរក្សត្រពន្លក ព្រះអង្គរះរក អ្នកផ្ញើចៅមហា ឲ្យទៅបន្ទួច ពាក្យពេចន៍មុទិតា ដល់ព្រះអង្គជា ជនកជននី ។ បើព្រមប្រោសផ្សំ ខ្ទង់ខ្ញុំជាខ្ញុំ ស្រាប់ហើយភូមី នឹងបានម្តេចល្មើស ប្រលើសពិតពី ព្រះទ័យជននី ជនកប្រធាន ។ បើក្សត្រនឹងខ្ញុំ រួមសេកមៀ្យ មូលមួយស្មោះស្មាន ហាក់ជាក់ជាំងង មិនក្រែងក្សត្រក្សាន្ត មួយសោតនឹងមាន ជំនៀល អប្រិយ ។

ស្តេចឆ្លើយវីងថា ប្អូនអើយបងយា - គ្រាចាកប្ញី មកតែក្បាលមួយ ទៅដោយស្រុកស្រី តើនឹងស្រដី រកអ្នកឯណា ។ ជាមហាឲ្យទៅ ដណ្តឹងប្អូនពៅ បើពៅមេត្តា ចូរជួយរិះគិត ព្រោះផ្សិតប្អូនក្ដី មានញាតិកា នៅអាយច្រើនក្រៃ ។

នាងទូលទៅថា បពិត្រព្រះមហា ក្សត្រាដេស្ដជ័យ ធរណីគប្ប័កល្ប រហ្មារក្សត្រថ្ងៃ បុរាណប្រពៃ ណាំពុំដែលមាន ។

ពោធិសត្វឆ្លើយ ពិតពេកប្អូនអើយ គឺមោះបងគ្មាន អ្នកជាញាតិ -

កាសាចសន្តាន ជាតិជាមហាហាន នឹងទៅដណ្តឹង ។ បើបងរួមរក រួមរសនឹងអ្នក មាសមិត្រព្រលឹង មែនមិនស្អតស្អាត់ មិនបាត់ដំណឹង ដំណើរគង់ជឹង ដល់មហាក្សត្រក្សត្រ ។ ក្រាស់ស្រេចត្រកង ព្រះប្អូនស្នេហ៍ស្នង ថៃថើបកល្យាណ ព្រើសព្រមសោមនស្ស រួមរសកិស្សមាណ មេត្រីកប់កាន ស្មោះសរមកទៅ ។

អញ្ជើញស្តេចសោយ អស់ក្រយាស្ងោយ នានាដស្រីពៅ ក្រញក្រាបគង់គាល់ ផ្ទឹមផ្ទាល់ថែបនៅ បំរើបមទៅ សេពសោយភោជនា ។ ស្រេចហើយនាងសោយ សំណល់សល់ក្រោយ ព្រះមហាក្សត្រា ឥតអៀនឥតអន់ ស្មោះស្ម័គ្របរបា ទៅមកកាន់គ្នា ស្មោះសរពេះពាយ ។

ស្រេចហើយព្រះពោ-ធិសត្វត្តមោ លើសលោកសម្លាយ ស្តែងស្តេចថ្នាក់ថ្នម លួងលោមនិយាយ ដំណើរប្រាប់ប្រាយ ប្រាប់ព្រះប្អូនគ្នា ។ ដើមទងអំពី ក្រុងយក្សាស៊ី សម្តេចបិតា សេះដឹងហេតុច្បាស់ នាំព្រះក-ជា ខ្ញុំព្រះប្អូនគ្នា រួតរត់ចេញទៅ ។ ដល់ស្រុកហេមន្ត បានប្អូនកុម្ភណ ស្តេចស្មាខ្ញាខ្ញុំ អកយកុមារ ក្សត្រាបមទៅ លើកទពវិលទៅ សម្លាប់យក្សា ស្តែងស្តេចថៃងសព្វ ដំណើរសព្វគ្រប់ ប្រាប់ព្រះប្អូនគ្នា ហើយព្រះបមទៅ លោមទៅទៀតថា ហៃប្អូនសង្ការ កែវកល្យាណី ។ បងនឹងនាំពៅ ត្រឡប់វិលទៅ នាគ្នុងរាត្រី បើនៅយូរនឹង ដំណឹងសេចក្តី

ដល់ក្សត្រសម្បី នឹងរវល់រវ ។

នាងទូលតបថា បពិត្រក្សត្រា ក្សត្រក្សន្តកូបរ វិពីរក្សត្រថ្ងៃ ព្រះទ័យស្តេចល្អ មួយសោតស្តេចស្រឡាញ់ខ្ញុំនេះណាស់ ៗ ក្រែងពីរក្សត្រថ្ងៃ សោយសោកក្សិណក្ស័យ ខ្ញុំទូលហាក់ទាស់ ហាក់ទើសប្រលើស លន់លើសជម្រាស់ តែសូមអម្ចាស់ រិះរង់ឈប់សិន ៗ ចាំខ្ញុំលុតលា ព្រះវរមាតា បិតាធិបតិន្ទ្រ ឲ្យជ្រាបសេចក្តី ព្រះទ័យនរិន្ទ្រ តែងព្រោសប្រោណ មិន ដូចក្សត្រជទៃ ។

ពោធីទ្រង់រិទ្ធ ត្រាស់ថាហៃមិត្រ ហៃមេថ្លើមថ្លៃ មេត្តាតែប្អូន ជាកូនវិស័យ បងអ្នកជទៃ ក្រែងពុំមេត្តា ៗ ប្អូនអើយបងគិត ទោះបច្ចាមិត្រ ចាំងទសទិសា បងពុំករុញ ព្រឺព្រួញព្រមា ដូចព្រះបិតា នៃព្រះប្អូនគន់ៗ បើបាញ់ព្រះអង្គ សមក្សត្រាទ្រង់ បំបាត់ជីពជន្ម បើឈ្មោះព្រះអង្គ សមទ្រង់អាក់អន់ ហេតុនេះប្អូនគន់ បងខ្លាចមហិមា ៗ ព្រះលឺងមាសមិត្រ បងអ្នកគន់គិត មិនឲ្យក្សត្រា យល់យើងពីរពង្ស សមទ្រង់ជ្រាបជា ឯក្រោយយើងយា ត្រា ដាច់ហួសទៅ ។

រីពជអស្សពាហ៍ ក្រវែលចាំមហា ក្ស តានៅក្រៅ ទៀបព្រានសុរិយា អសុរ្រពាហ៍ទៀនទៅ បពិត្រចមទៅ ចូរឆាប់ម្ចា ៗ

ក្សិណនាងទូលទៅ បពិត្រចមទៅ បើយើងយាត្រា ធ្វើម្តេចនឹងជឹង

ដំណើរដល់មហា-ក្សត្រជាមាតា បិតាប្រធាន ៗ សោះស្តេចសោយសោក

សែនសល់អាយ៉ោក នឹងយើងពីរប្រាណ ពោធិស្តាប់ហើយ ត្រាស់ឆ្លើយ

រីងប្ដាន ថាមេមាសមាន រូបរត្នប្រិមប្រិយ ៗ យើងសរសេរជា កំណត់

ទុកថា ព្រះរាជបុត្រ មានជាសំបុត្រ កំណត់សេចក្តី ថ្លាត់ថ្លាយព្រះបិ-តា

នូវមាតា ៗ

សូមទ្រង់ប្រាណប្រោស ប្រណីអត់ទោស កូនសូមក្រាបលា ទៅនឹង

ស្វាមី មកពីនគរ សន្ធនាមា ឈ្មោះពាលណសី ៗ ព្រះនាមសោត័ណ

ហៅព្រះទេវនូ ទ្រើសទ្រង់បារមី វិសេសថ្កើងថ្កាន មិនមានដើរដី នាំនាំ

កូនស្រី ហោះជាយវេហាស៍ ៗ កូនសូមសន្ធត់ ប្រាំពីរឆ្នាំគត់ យើងនឹង

នាំគ្នា វិលមកអភិវាទ ព្រះបាទបិតា នូវព្រះមាតា សូមប្រោសប្រណី ៗ

នាងនាដស្តែងស្តាប់ ព្រះសូរសារសព្ទ ព្រមតាមស្វាមី ស្តេចយល់

នាងព្រម ថ្នាក់ថ្នមប្អូនស្រី ហើយព្រះចក្រី សរសេរសារ ៗ

មច្ចិមយាមោ អតិក្កន្តោ មជ្ឈិមយាមា យាមយូរម្ទង់ កន្លងចូល

ជា បច្ចិមយាមា អរុណសែគស ៗ សេះទៀនទូលថា អញ្ចាញក្សត្រា

ឆាប់ ៗ បរ ៗ ព្រះអង្គគិតម្តេច បន្តិចវឹកវរ អរុណសោគស ត្រែង

មនុស្សផងក្បាក ៗ

ពោធិសត្វឆ្លើយ ឈប់សិនបងអើយ ត្រាស់ហើយចមចក្រ ប្រើង

សរសេរសារ សូត្រស្ទាន់ជាក់ មនុស្សសោកក្តាក្តាក់ សេះទៀនទៀតថា ៗ ធាប់ឡើងម្ចាស់អើយ ក្តីណាស់ទៅហើយ កុំរង់រេក ស្តេចសរសេរស្រេច សម្តេចក្សត្រា បត់ដាក់អត្ថក ក្រោមរង់ព្រះសិរ ៗ ស្រេចព្រះសោកណា ពព្រះប្អូនគន់ ចចុះចេញពី សីហបញ្ជរ សុន្ទរពាជី ទនឲ្យក្សត្រពីរ លីលាឡើងគង់ ៗ គង់បរិបូណ៌ស្រេច ទៀនទើបសម្តេច មុនីទ្វារ ស្តេចមានព្រះស្ងួរ មធុរនឹងអគ្គ សិទ្ធពអស្រពង្ស លួងលោមទៅថា ៗ កាលយើងចេចេរ មកពីនគរ យូរបីមាសា ឥឡូវនាំប្អូន ខ្ញុំមខ្ញុំនពុំផា ចូរបន់យាត្រា ទៅតែមួយថ្ងៃ ៗ ឲ្យដល់ផ្ទះមេ្យ ជំរុតនាង់ពិតពុំ ដែលដេកដោយព្រៃ សេះស្តាប់ឆ្លើយថា កុំព្រួយព្រះទ័យ ខ្ញុំទៅតែថ្ងៃ នេះ ឲ្យបានដល់ ៗ សេះទូលតែម៉្មោះ ស្ទាញស្ទុះហៀរហោះ លឿនលើស លែងខ្យល់ ដោយឫទ្ធិកម្លាំង ពលំសេះសល់ ចេញពាកមណ្ឌល មណី រចនា ៗ ពីរពង្សនៃបទិត្យ ដូចព្រះចន្ទ្រឋិត នៃបទ្ធរស្សូត្រា ពុំនោះត្រចះ ដូចព្រះឥន្ទ្រា នៃបទឹងសុជតា គង់សេះហោះទៅ ៗ

ក្រោយព្រះពង្សពោធិសត្វរេក នាំព្រះប្អូនពៅ ហោះហោះផ្ទះ ផ្ទាក ចេញពាកលំនៅ សូរ្យសែងផ្គនផ្តៅ ស្ទុស្ទុទ្ធក្តាក្តាក់ ៗ ចូល កាន់បន្ទំ ប្រសើរសុខសម នៃនាងវរលក្ខណ៌ ពុំយល់ស្រីគ្គ ស្ទុស្ទុទ្ធ គមគាក់ កិតភ័យផ្អើលក្តាក់ រត់រេកពល់គ្នា ៗ រេកសព្វគៀនគោះ អស់

ឥតបន្ទោះ ពុំយល់ធីតា ខ្វះវត់បរបួល ទៅទូលរាជា ពីរក្សត្រជ្រាបជា រាជបុត្របាត់ ៗ សោយសោកសន្ធប់ ញាប់ញ័រសោយសព្វ ថើម ថ្ងៃប្រមាត់ បន្តិចស្តេចក្សារ ប្រុងស្វារតីក្សត្រ ចាកប្រាសាទរត្ន ព្រះរាជបុត្រី ៗ

នាងបទុមា ប្រាសប្រាណទួញថា ឱកូនពិសី ពិសេសពិសុទ្ធ ជាម្កុដស្រស់ស្រី ជាឆ្នើមកពង្រែ កបបុណ្យលក្ខណា ៗ មានតែមាសមួយ មាសមិត្រជាត្រួយ បណ្តូលហទយា បីដូចប្រស្រី កែវនៃនេត្រា មាតាបិតា តែងថ្នាក់ថ្នមអ្នក ៗ មាសមិនដែលឃ្លាត ចាកចោលប្រាសាទ ប្រសើរសោភ័ត្រ សោភ័ណល្អសល់ច ក្បូរក្បាច់ចម្លាក់ ចំឡែកល្អហាក់ ប្រាសាទឥន្ទ្រា ៗ ថ្ងៃនេះមិត្រមាស មាសមេ-ប្រែប្រាស់ៗ ព្រាត់ឃ្លៀងឃ្លាៗ ឃ្លាតចេញពីមន្ទីរបទា ចោលស្នំស្នេ-ហា ចោលចិលទៅ ៗ ឱមាសប្រសើរ ប្រសិនណាបើ មាសអ្នកពិតពុំដឹងដោយដែនដាន ពិតមានដានដំ ណើរអ្នកសោតសំ ម្ភាយអាក្រុកក្សែយ។ នាងសោកមមៀល ព្រះអង្គនទៀល លើបន្ទំថ្ងៃ ស្រយ៉ន់ស្រយ៉ុត រន្ធត់ហឫទ័យ ហេតុក្តីអាល័យ ព្រះរាជធីតា ៗ ប្រែប្រួលរាសព្រះ ហស្ត-ហាក់ដូចទះ រងព្រះសិរសា រមៀលឃ្លាឃ្លាត នាងនាងថ្ងៃថ្ងា ចៀងព្រះនេត្រា យល់សព្វអក្សរ ៗ នាងយកមកលាត លាថ្វាយព្រះបាទ

ក៏ក្រេកក្រានកូងរ ទតសព្វសេចក្តី ក៏ក្រៃថ្ងៃក្រែកអរ លួងលោមអន្ទរ ព្រះអគ្គមហេសី ។

ប្អូនអើយកូនពៅ យើងយាត្រាទៅ នឹងអគ្គស្វាមី មកពីកជដ្ឋាន ពារាណសី ទ្រើសទ្រង់បារមី ឈ្មោះហៅទេវន្ទ ។ នាំកូនមិត្រមាស ហោះដោយអាកាស សន្ធូតលាក់ខាន់ តែឆ្នាំប្រាំពីរ នឹងវិលអភិវន្ទ សូមលាទោសទណ្ឌ ទោសទាស់គ្គាំគ្គង ។ បានជានាំគ្នា រត់ទៅពុំលា ព្រោះខ្លាចអញបង នឹងប្អូនព្រលឹង ខេរខឹងខ្ទំនផង ដៀតដឹងខ្លួនផ្គង នឹងយើងទ្វេហា ។ មួយក្រែងបងប-ម្រាស់បំពត់ពុំ ឲ្យប្អូនប្អូបជា គូគួរស្នេហ៍ស្និទ្ធ មូលមិត្រប្រោសបា-រម្ភរិះឱអា-សូរសោមក៏យកិត ។ ឱកូនមានបុណ្យ កូនរត្នស្ងួនគន់ ស្ងួនតែងមានក្រិត្យ មានក្រំកិរិយា មាតាស្នេហ៍ស្និទ្ធ បិតាត្រូវចិត្តរក្សាស្ងួនគ្រង ។ អ្នកតែងធ្វើវត្ត អ្នកតែងប្រណិបត្ត សព្វថ្ងៃសព្វជង មិនដែលឲ្យអាក់ ប្ជាំងប្ជាក់មានហ្មង មាសជាកន្ទោង កន្ទុងលែងស្រី ។ ទោះស្រីនៅក្នុង ប្រលោះប្រទ្បង់ ដម្កូវបក្តី ទោះស្រីនៅនា ទ្វីបាទាំងបី ទាំងស្រីស្ងួតក្តី សឹងផ្តុំមពុំបាន ។ អាពុកតែងពឹង ប្រាជ្ញាព្រលឹង ទោះបីបើមាន ទុញទាល់ក្រីក្រ កម្រប៉ុន្មាន មានតែវិញ្ញាណ អ្នកមាសថ្មើមថ្ងៃ ។ តែងនឹងពិគ្រោះ ស្រាយស្រដីដោះ មិនឲ្យសង្ស័យ ឥឡូវអ្នកទៅ លំនៅទីទៃ ទីទូរឆ្ងាយក្រៃ ឆ្ងាយក្រយោត្រា ។ បើអាពុកព្រួយ ទាល់ក្រនិមួយ

ទឹងមានអ្នកណា ឯងអាចប្រាជ្ញប្រុះ ឈ្មោះស្ទុះលោកា ដូចអ្នកជាតិជា ពន្លកថ្មើមថ្មើ ៗ ទុះហេតុសម្ភារ បុណ្យបារមីគត់ សូមទេពព្រឹក្សព្រៃ ទាំងឆកាមា វចរលើសក្រៃ សូមឲ្យជួយជ័យ ទាំងពីរអង្គ ៗ ឲ្យឈ្នះសត្រូវ រៀនរាបដោយផ្លូវ ទៅដល់នគរ ទោះដកទោះដាក់ ដំណាក់ព្រឹក្សា នៅទីឯណា សូមទេពទីនោះ ៗ សូមអ្នកករុណា រក្សាការពារ ឲ្យស្ងួនឲ្យស្ងោះ កុំឲ្យមានភ័យ ទោះបីមានមោះ សោកសូមអនុគ្រោះ រៀនមគ្គាទៅ ៗ ទោះទៅដល់ស្រុក ឲ្យគ្រូមក្សាន្តទុក្ខ រោគាហ្មងសៅ វង្សាមន្ត្រី ស្វាមីកូនចៅ ឲ្យប្រកបនូវ សេចក្តីករុណា ៗ កុំបីឲ្យមាន ចិត្តពោរឈ្មានពាន បៀតបៀនបំណ្ហា ឲ្យមានតែចិត្ត ស្ពាលសិទ្ធស្នេហា បីដូចជាតិជា កូនបង្កើតពិត ៗ

ពីរពង់ក្សត្រក្សាន្ត ទ្រង់គ្រូមមិនមាន មោះមែតនគិត បងជាសត្រូវ ទៀងទៅដល់ផិត ដល់ព្រះបពិត្រ ជាព្រះសុណិសា ៗ ហេតុព្រះកូមី នូវនាងទេវី ត្រកូលឯកអារ សាងសូមផាតដាក់ សាវ័កសាវិកា គបដោយសម្មា ទិដ្ឋិធម៌ទ្រង់ ៗ ឃាសឃោនវិលទៅ ប្រាសាទលំនៅ ប្រសើរស្តេចគង់ ស្តេចគិតរាជបុត្រ ត្រីវត្តវរវង្ស សព្វពេលព្រះអង្គ ពុំដលភ្លាំងភ្លេចៗ

(ចប់ខ្សែ ៤ តែប៉ុណ្ណេះ) ៗ

(មានក)

# រឿងសាមកុក

## កណ្ឌទី ៣០

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

( តមក )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ទាំងអស់ឲ្យព្រួតដៃជួយគ្នាទៅវិញទៅមកជាប្រក្រតី ទើបនឹងបានជួយប្រាំងគ្នាការពារកេរ្តិ៍ដំណែលរបស់បិតា មិនឲ្យអន្តរាយនឹងចូចូបាន ។ ឡៅប៉ៀវយល់ឃើញត្រូវ ក៏ឲ្យធ្វើសំបុត្រតបទៅដល់អួនថាំតាមពាក្យឡៅពីនិយាយ ។

អួនថាំដឹងសេចក្តីក្នុងសំបុត្រឡៅប៉ៀវដូច្នោះ ក៏ពិគ្រោះឃើញថាដែលឡៅប៉ៀវតបមកដូច្នេះ ឃើញថាមុខជាមិនឲ្យកងទ័ពមកជួយទេ ទើបគិតថា បើនឹងនៅក្នុងស្រុកនេះ ក៏នឹងទប់ទល់នឹងទ័ពចូចូមិនបាន គិតហើយក៏ចាត់ចែងទាហានទាំងពួង លើកទៅតាំងនៅស្រុកលាំកី ។

ចំណែកប្អូនដឹងដូច្នោះ ក៏លើកកងទ័ពទៅដល់ដែនស្រុកលាក់ក្នុងទួល ជាទេសកាលរដូវរងា ទឹកក្នុងទន្លេនោះក៏រឹងជាដុំកកទាំងអស់ ទូកដែលនឹងដើរចេញចូលនាំស្បៀងនោះក៏មិនបាន ប្អូនក៏ឲ្យប្រកាសឃោសនាបណ្ដាអ្នកស្រុកមកដឹកទំលាយទឹកកកឲ្យទូកស្បៀងចេញចូលបាន ៗ រាស្ត្រទាំងពួងឮដូច្នោះ ក៏នាំគ្នាកើតទុក្ខក្រហល់ក្រហាយនិយាយថា គ្រានេះយើងបានសេចក្ដីលំបាកជាទម្ងន់ហើយ ទើបនាំគ្នារត់ចោលផ្ទះសម្បែងទៅជ្រកពួនទៅក្នុងព្រៃ ៗ ប្អូនដឹងដូច្នោះក៏ខឹងណាស់ ទើបបង្គាប់ទាហានតាមទៅចាប់ខ្លួនពួកនោះមកសម្លាប់ចេញ បណ្ដាអ្នកស្រុកទាំងអម្បាលនោះមិញ បានដឹង ក៏គិតភ័យខ្លាចសេចក្ដីស្លាប់ នាំគ្នាត្រឡប់មកចុះចូលទៅនឹងប្អូន ហើយសូមទោសកំហុស ព្រមចូលធ្វើការរាជការនឹងប្អូន ៗ ក៏នឹកតែក្នុងចិត្តថា "ដែលបណ្ដារាស្ត្រអ្នកស្រុកត្រឡប់មកសូមទោសដូច្នេះ បើនឹងលើកទោសចោល ការដែលបានបង្គាប់ទៅហើយក្រែងថ្ងៃក្រោយនឹងមិនសម្រេច បើនឹងធ្វើទោសទៅអ្នកស្រុកទាំងពួងនឹងនិន្ទា បើដូច្នេះ ចាំនឹងគិតការឲ្យបានទាំងសងខាង" គិតហើយក៏និយាយនឹងអ្នកស្រុកទាំងពួងថា បើយើងសម្លាប់អ្នករាល់គ្នាចេញក៏មានសេចក្ដីអាណិត បើដូច្នេះ ចូរនាំគ្នារត់ពួនជ្រកឲ្យរួចពីទាហានយើងទៅចុះ អ្នកស្រុកទាំងអស់ឮដូច្នោះ ក៏ភ័យស្លុតចិត្ត ស្រែកយំអាណិតគ្នាអឺងកង ហើយក៏រត់ទៅជ្រកក្នុងទីផ្សេង ៗ

ពួកទាហានប្អូនបានជួបប្រទះគេកាប់សម្លាប់ចោលជាច្រើន ។

ឯអ្នកចាំជីងជាប្អូនលើកទ័ពមកដូច្នោះ ក៏ចាត់ចែងទាហានហើយ លើកចេញមកច្បាំងនឹងប្អូន ។ ឃើញអ្នកចាំលើកចេញមក ក៏បរសេះចេញ ទៅឈរពីមុខទាហានហើយនិយាយនឹងអ្នកចាំថា ពីដើមខ្ញុំនឹងបងអ្នកស៊ុង ជាប្អូន បានជារត់មកចុះចូលនៅនឹងយើង ។ ក៏មានសេចក្ដីអាណិតអាសូរ ប្រងនឹងលើកបុត្រីឲ្យជាភរិយា ឥឡូវយើងបានស្រុកគីជីវហើយ យើងឲ្យ ហៅខ្លួន ។ ក៏មិនទៅ ដែលខ្លួនត្រឡប់មកគិតប្រទុស្តរាយយើងវិញដូច្នេះ ពេញជាមនុស្សអកតញ្ញូរយោសពេកណាស់ ។ អ្នកចាំតបថា ហេតុទាំង នេះព្រោះខ្លួនលើកកងទ័ពមកច្បាំងនឹងយើងទាំងបងនឹងប្អូនបានជាទាស់គ្នា លុះបានស្រុកហើយខ្លួនក៏ធ្វើទុកបុកម្នេញបងប្អូនយើងផ្សេង ៗ បានជាយើង មានចិត្តខឹងក្ដៅក្រហាយណាស់ ហេតុម្ដេចបានជាមកថាយើងមិនដឹងគុណ វិញ ។ ប្អូនឮហើយក៏ខឹងណាស់ ទើបប្រើស៊ីហ៊ុងឲ្យចេញទៅច្បាំង នឹងអ្នកចាំ ។ ក៏ប្រើផែអាន់ ឲ្យចេញមកច្បាំងនឹងស៊ីហ៊ុងបាន ៤ ភ្លើង ស៊ីហ៊ុងយកដាវកាប់ផែអាន់ធ្លាក់ពីលើសេះស្លាប់ ។ អ្នកចាំឃើញដូច្នោះ ក៏ញញើត បរសេះនាំទាហានថយរត់ចូលទៅក្នុងស្រុកលាំគី ។ ប្អូនក៏ លើកកងទ័ពតាមចូលទៅឡោមព័ទ្ធស្រុកនោះទុក ។ អ្នកចាំយល់ឃើញ ថា ទ្រាំនឹងកំឡាំងប្អូនមិនបាន ក៏ប្រើស៊ុនបេងឲ្យចេញទៅអង្វរលន់តួ

ទោសសូមចុះចូលប្អូនទៀត ប្អូនឃើញដូច្នោះក៏និយាយថា អ្នកចាំបរោទុកនឹងយើងពីមុននោះ ក៏ត្រឡប់ពាក្យសំដីវិលមកធ្វើប្រទូស្តរាយនឹងយើងវិញ ឥឡូវអស់ជម្រេះហើយឬ បានជាឲ្យមកអង្វរលន់តួទោសដូច្នេះ? យើងមិនព្រមទេ ហើយថាស៊ុនគីប្អូនអ្នកឯងនោះបានមកនៅធ្វើការរាជការជាមួយនឹងយើង ហើយខ្លួនអ្នកត្រឡប់ចូលទៅរកអ្នកចាំនោះ ក៏នឹងបណ្ដោយទៅតាមគ្នាជាប្រាកដ អ្នកចូលមកនៅនឹងយើងចុះ យើងចិញ្ចឹមឲ្យដល់ខ្នាតឲ្យដូចប្អូនប្រុសរបស់អ្នក ។ ស៊ុនបេងតបថា ដែលមហាទេពរាជចរោដូច្នេះមិនគួរសោះ ព្រោះពាក្យបុរាណបានពោលទុកថា ធម្មតាជាខ្ញុំគេហើយ ត្រូវតែឲ្យតាំងចិត្តស្វាមីភក្ដិនឹងចៅហ្វាយនាយ បើចៅហ្វាយនាយបានសេចក្ដីសុខ ខ្លួនក៏បានសុខផង បើចៅហ្វាយនាយបានសេចក្ដីទុក្ខ ក៏គប្បីឲ្យទេរមានកាយឲ្យលំបាកផងទើបគួរ ឯខ្លួនខ្ញុំបាទនៅនឹងអ្នកសៀវក៏យូរណាស់មកហើយ ឥឡូវអ្នកសៀវដែលមានគុណូបការក៏ដល់នូវសេចក្ដីមរណភាពទៅ ខ្ញុំបាទនឹងសូមនៅតបគុណសៃអ្នកទៅទាំងតែអស់ជីវិត ដែលស៊ុនគីប្អូនខ្ញុំបាទបានមកនៅនឹងលោកនោះ ក៏តាមតែវាសនារបស់គេចុះ ។ ប្អូនបានស្ដាប់ដូច្នោះ ក៏គិតថា ស៊ុនបេងនេះមានចិត្តសុចរិតស័ត្យទៀងត្រង់ណាស់ មុខជានិយាយបញ្ចុះបញ្ចូលទុកមិនបាន ទើបថាបើខ្លួនអ្នកមិនព្រមនៅនឹងយើងហើយ ចូរស្រូតត្រឡប់ទៅប្រាប់

អួនថាំតាមពាក្យយើងនិយាយចុះ ។

ស៊ុនបេងក៏លាប្អូនត្រឡប់ទៅប្រាប់អួនថាំគ្រប់ប្រការ អួនថាំបានឮដូច្នោះក៏ខឹងនឹងស៊ុនបេង ហើយនិយាយថាប្អូនរបស់ខ្លួនទៅនៅនឹងប្អូនប្រាប់កិច្ចការអាថ៌កំបាំងអស់ ឥឡូវយើងឲ្យខ្លួនទៅនិយាយនឹងប្អូនៗ ក៏មិនព្រម ឯសេចក្តីយ៉ាងនេះគឺប្អូនប្រើខ្លួនឲ្យត្រឡប់មកធ្វើប្រទូស្តកាយដល់យើងវិញឬ? ស៊ុនបេងបានស្តាប់ដូច្នោះ ក៏មានសេចក្តីខឹងក្តៅក្រហាយជាច្រើនណាស់ ទោមនស្សទាល់តែខ្យល់ចាប់ដួលចុះសន្លប់នៅទីនោះ អួនថាំក៏ឲ្យទាហាននាំខ្លួនស៊ុនបេងចេញទៅខាងក្រៅ នៅបានតែ ១ ស្របក់ក៏ដាច់ខ្យល់ស្លាប់ទៅ ។

កួគៅនិយាយនឹងអួនថាំថា ដែលយើងឲ្យទៅអង្វរលន់តួទោសប្អូន ៗ មិនព្រម ឥឡូវខ្លួនយើងក៏នៅក្នុងទីចង្អៀតទញទាល់បីដូចជាមនុស្សមានជម្ងឺឈឺធ្ងន់ជាបពេក កប់តែថ្ងៃវេលានឹងស្លាប់ហើយត្រូវតែរិះគិតយកថ្នាំមកផ្សំបញ្ចូលគ្នាឲ្យផឹកលេបម្តងទៀតមើល ប្រសិនបើល្មមនឹងតែពេតនោះបាន ក៏គង់នឹងរួចពីសេចក្តីស្លាប់បាន សូមឲ្យលោកកេណ្ឌយកស្ត្រីអ្នកស្រុកឲ្យអស់រលីងលើកទៅជាកងទ័ពមុខ លោកត្រូវលើកពលទាហានឯទៀតទៅជាកងទ័ពប្រចាំជូនច្បាំងនឹងប្អូនទៀត ។ អួនថាំយល់ឃើញត្រូវ ក្នុងពេលកណ្តាលយប់នោះ ក៏ប្រមូលទាហាននឹងបណ្តាអ្នកស្រុកទាំង

ពួនជាទ័ពមុខ ៤ កង ត្រៀមប្រុងទុកស្រេច ហើយចាត់ចែងបណ្ដាទា-
ហានជាកងទ័ពជំនួយបានគ្រប់ទាំង ៤ កង លុះវេលាព្រឹកឡើងក៏ឲ្យបើក
ទ្វារទាំង ៤ ទិស ហើយលើកកងទ័ពចេញទៅប្រឡុកវាយបន្ទាយបូឆូទាំង
៤ ផ្លូវ ៗ បូឆូឃើញដូច្នោះ ក៏ឲ្យបំរើសេះស្រួតទៅប្រាប់ត ៗ គ្នាគ្រប់បន្ទាយ
ហើយដេញទាហានឲ្យចេញតតាំងច្បាំងជាពន្ទឹក តាំងពីព្រឹកដល់ថ្ងៃត្រង់ទា
ហានទាំងសងខាងក៏ចាក់កាប់សម្លាប់គ្នាស្លាប់ជាច្រើន មិនទាន់ឈ្នះចាញ់
បូឆូឃើញដូច្នោះ ក៏គិតខ្លាចក្រែងទាហានទាំងពួននឹងហាត់នឿយណាស់
ទើបឡើងទៅលើភ្នំហើយក៏វាយស្គរចម្បាំង ប្រាថ្នានឹងដេញទាហានទាំង
ពួនឲ្យចូលច្បាំងពុះពារយកជ័យជំនះឲ្យបាន ពួកទាហានបូឆូបានឮសំ
ឡេងស្គរក៏ស្ទុះស្រូចូលទៅប្រកាប់ប្រចាក់ពាក់ពូនលើគ្នា បណ្ដាទាហាន
អ្នកចាំនឹងអ្នកស្រុកក៏ស្លាប់ដេរដាសប្រុសាសរត់ចេញទៅ ចោហងក៏បង្ខំដេញ
ពលទាហានចូលចាក់កាប់ពាក់ពូនលើគ្នាជាប្រឡបល់ ចោហងបានចំណាប់
ក៏យកដាវដេញកាប់អ្នកចាំត្រូវរបួសជាច្រើនអន្ទើ អ្នកចាំក៏គ្រាំគ្រាពាលតែ
ធ្លាក់ពីលើសេះស្លាប់ ក្លៅកីបរសេះនឹងត្រឡប់ចូលស្រុកវិញ ងកជនក្រ
ឡេកឃើញក៏ញាក់សេះដេញតាម ហើយយិតធ្នូបាញ់ត្រូវក្លៅធ្លាក់ពីលើ
សេះចុះទៅក្នុងស្នាមគ្បូស្លាប់ ៗ បូឆូក៏ឲ្យទាហានកាត់យកក្បាលអ្នកចាំទៅ
ប្រកាសប្រាប់ដល់បណ្ដារាស្ត្រអ្នកស្រុកថា កុំឲ្យនរណាយំសោកអាល័យអ្នក

ចាំឡើយ បើនរណាមកយំសោកក៏ឲ្យចាប់ខ្លួនសម្លាប់ចេញ លុះប្រកាសហើយឲ្យយកក្បាលអួនចាំងោតទុកនៅទ្វារស្រុកខាងទិសឯជើង ចូឆូក៏លើកទាហានចូលទៅក្នុងស្រុកលាំកី ហើយប្រាប់ប្រាមអ្នកស្រុកឲ្យនៅជាប្រក្រតី ទទួលមានបំរើសេះម្នាក់មកប្រាប់ចូឆូថា មាននាយទាហាន ២ នាក់នាំទាហានជាច្រើនលើកមកជិតស្រុកលាំកីហើយ ចូឆូបានឮក៏ឲ្យរៀបពលទាហានលើកចេញទៅក្រៅស្រុកបំណងនឹងតតាំងច្បាំងគ្នា ។

ឯទៀវហៀននឹងទៀវឡាំ ឃើញចូឆូលើកទ័ពចេញមក ក៏ចុះពីលើសេះបោះអាវុធចេញហើយដោះគ្រោះអស់ពីខ្លួន ចូលទៅគំនាប់ចូឆូ ៗ សួរថា អ្នកទាំង ២ នេះឈ្មោះអ្វី ? មកពីទីណា ? នាយទាហានទាំង ២ នាក់ក៏ជំរាបថា ខ្ញុំបាទឈ្មោះទៀវហៀន , ទៀវឡាំជានាយទាហាន អួនហ៊ុជាបុត្រអួនសៀវ ខ្ញុំបាទឮដំណឹងថាមហាឧបរាជមានចិត្តមេត្តារាប់អានទាហានខ្ញុំរាជការដោយសុចរិត ទើបគិតគ្នានាំទាហានទាំងនេះមកប្រាថ្នានឹងចូលទៅធ្វើការរាជការជាមួយនឹងលោក ។ ចូឆូបានស្តាប់ក៏ទទួលអំណរណាស់ តាំងឲ្យទៀវហៀន ទៀវឡាំជានាយទាហានឆ្វេងស្តាំ ។

ឯទៀវអៀនជាមេចោរនៅក្នុងអេងស៊ុទដឹងដំណឹងថា ចូឆូវាយយក

បានស្រុកគីជីវនឹងស្រុកលាំភី ក៏លើកពួកទាហានទោរប្រហែល ១០ ម៉ឺន មកសូមចូលទៅធ្វើពជការជាមួយនឹងបូឆ ។ តាំងឲ្យទៀវអៀនជាទីប៉ាក់ប៊ុងកុន គឺស្ដេចប្រាបប្រាមអាណាខែត្រទិសឧត្ដរ ។

ឯអង់ស៊ីវ កាលឮដំណឹងថាអួនថាំស្លាប់ហើយ ក៏មានសេចក្ដីសោកស្ដាយអាឡោះអាល័យ ក៏ចូលទៅអង្គុយយំសោកអាណិតអួនថាំដែលគេជាក់ក្បាលនោះ ទាហានល្បាតឃើញដូច្នោះក៏ចាប់យកខ្លួនទៅឲ្យបូឆ ។ សួរថា អ្នកយំនោះឈ្មោះអ្វី? ហេតុម្ដេចបានជាយំអាណិតអួនថាំ? អង់ស៊ីវឆ្លើយថា ខ្ញុំបាទឈ្មោះអង់ស៊ីវ ជាទីប្រឹក្សាអួនថាំ ខ្ញុំបាទបានហាមឃាត់អួនថាំឲ្យគិតគូរស្រុះស្រួលមាគមនឹងបណ្ដាញាតិ បងប្អូនជាមេត្រីនឹងគ្នា ដើម្បីនឹងជួយការពាររក្សាស្រុកគីជីវទុកឲ្យគង់ អួនថាំមិនព្រមស្ដាប់ពាក្យខ្ញុំបាទសោះ បានជាខូចស្រុកថែមទាំងខ្លួនក៏មានទុក្ខទាល់តែស្លាប់ទៅទៀត ខ្ញុំបាទឃើញរូបក៏តឹងចង្អៀតចិត្តអាណិត ព្រោះហេតុនេះបានជាយំ បូឆសួរថា កាលយើងឲ្យយកក្បាលទៅស្រែកប្រកាសដល់បណ្ដាអ្នកស្រុកទាំងពួងថា បើនរណាមកយំអាឡោះអាល័យអួនថាំ យើងសម្លាប់នោះ ខ្លួនដឹងឮឬទេ? អង់ស៊ីវឆ្លើយថា ដែលលោកហាមប្រាមនោះខ្ញុំបាទក៏បានដឹងដែរ បូឆថា បើខ្លួនបានដឹងឮហើយ ហេតុម្ដេចក៏ហ៊ានមកយំសោក ខ្លួនមិនខ្លាចស្លាប់ទេឬ? អង់ស៊ីវឆ្លើយថា ពីដើមរៀងមកនោះ ខ្ញុំបាទក៏

បានសេចក្ដីសុខច្រើនណាស់ ព្រោះអ្នកថាំជួយទំនុកបម្រុង ឥឡូវអ្នកថាំស្លាប់ទៅហើយ បើនឹងនៅព្រងើយកន្តើយ ក៏ហាក់បីដូចជាមនុស្សអកតញ្ញូនឹងចៅហ្វាយនាយ ព្រោះបើនឹងរស់នៅជាមនុស្សក៏គ្មាននរណាគេសរសើររាប់អាន ហេតុនេះបានជាខ្ញុំបាទមកយំអាណិត ព្រោះគិតដល់គុណអ្នកថាំ ព្រោះបើលោកនឹងសម្លាប់ខ្ញុំបាទចេញ ដោយទោសល្មើសដូច្នេះក៏ស្រេចនៅលោកចុះ តែសូមឲ្យខ្ញុំបាទតែងសពអ្នកថាំសិន រួចសឹមបិទមុខស្លាប់តាមនាយចៅហ្វាយទៅទៀត ។

ចូច្ចូបានស្ដាប់ក៏យល់ឃើញពិត ទើបនិយាយថា បណ្ដាអាណាខេត្រខាងវិសុទ្ធត្រនេះ មានទាហានដែលមានថ្វីដៃខ្លាំងពូកែ នឹងមានដម្រេះប្រាជ្ញាប្រកបទាំងចិត្តសត្យានុស័ត្យពិតទៀងត្រង់ នឹងនាយចៅហ្វាយជា-ច្រើនណាស់ ប្រសិនបើអ្នកសៀវនឹងបុត្រមានចិត្តអាណិតប្រណីមេត្រីរាប់អានបានចិញ្ចឹមរក្សាមនុស្សល្អឲ្យដល់ខ្នាតហើយ កាលណាឡើយយើងនឹងមកវាយយកស្រុកតីដីវបាន ហើយចូច្ចូក៏ឲ្យទាហានតែងការសពអ្នក-ថាំតាមប្រវេណី ឯអង់ស៊ីវនោះចូច្ចូក៏តាំងឲ្យធ្វើជានាយឃ្លាំង ហើយសួរអង់ស៊ីវថា ឥឡូវអ្នកសុងរតេទៅនៅនឹងអ្នកហ៊ុងស្រុកអាវដីវ អ្នកនឹងរិះគិតប្រការម្ដេចទើបនឹងចាប់ខ្លួនអ្នកសុងបាន ? អង់ស៊ីវតបថា មហាឧបរាជក៏មានឧបការគុណនឹងខ្ញុំបាទបើជាការដទៃមានមកនោះ ខ្ញុំបាទនឹងរិះគិត

គប់ស្នងសងគុណលោកទៅតាមសក្តិកំឡាំង ត្រាតែអស់ជម្រះប្រាជ្ញាមិនថាអ្វីសោះ វេលានេះ លោកនឹងឲ្យខ្ញុំបាទទៅគិតចាប់ខ្លួនអ្នកសុង ដែលជាបងប្អូននាយចៅហ្វាយរបស់ខ្ញុំបាទនោះខ្ញុំបាទក៏ទាល់ហើយ តាមតែលោកនឹងមេត្តាអត់ទោសប្រោសប្រណីទៅចុះ ប្បឆ្បបានឮដូច្នោះក៏សរសើរថា អង់ស៊ីវនេះជាមនុស្សមានចិត្តសុចរិតទៀងត្រង់នឹងអ្នកមានគុណណាស់ ហើយទើបប្រឹក្សានឹងទាហានទាំងពួងថា យើងនឹងគិតប្រការម្តេចទើបនឹងចាប់ខ្លួនអ្នកសុងមកបាន គុយកៃឆ្លើយថា សូមឲ្យលោកប្រើទាហានអ្នកសៀវ ដែលមកនៅនឹងលោកនោះ ឲ្យលើកកងទ័ពទៅរិះគិតធ្វើការចម្បាំងចាប់ខ្លួនអ្នកសុងឲ្យបាន ប្បឆ្បយល់ឃើញត្រូវក៏ប្រើទៀវហៀននឹងទៀវឡាំលើកទាហាន ១ កង ឲ្យលីកងលីសៀងលើកទាហាន ១ កង ឲ្យម៉ាអៀន នឹងទៀវគីលើកទាហាន ១ កង ទៅវាយស្រុកអ៊ីវជីវចាប់ខ្លួនអ្នកហ៊ុនឹងអ្នកសុងឲ្យបាន នាយទាហានទាំង ៣ កង ក៏លើកកងទ័ពចេញទៅ ហើយប្បឆ្បប្រើទៀវអៀននាយចោរនឹងលីទៀន , ង៉កជិន ឲ្យលើកទាហានទៅចាប់ខ្លួនគោកនឯស្រុកបេងជីវ ។

ខណៈនោះ អ្នកហ៊ុនឹងអ្នកសុងដឹងដំណឹងថា ប្បឆ្បឲ្យលើកកងទ័ពទៅដូច្នោះ ក៏គិតគ្នាថាយើងនឹងនៅតទល់ឃើញជាមិនបាន ទើបនាំទាហានរត់ចេញពីស្រុក ប្រាថ្នានឹងទៅពឹងនៅផោយុសារហោហ្គួន ចៅហ្វាយស្រុក

សៀវសៃ ដែលឡើងចំណុះស្រុកអីដែរ ៗ

ឯហោហ្លួនកាលបួធវាយបានស្រុកគីដីវនោះ ហោហ្លួនក៏បបួលពួកកៀនដែលជាទាហានអ្នកសៀវទៅសួរថាស្បានដឹងគ្នាថានឹងរួបរួមចិត្តគិតនិតស្រឡាញ់គ្នា តែចិត្តហោហ្លួននោះគិតនឹងចូលទៅនៅនឹងបួធ លុះអំណឹះតមក ហោហ្លួនចាត់បំរើឲ្យទៅអញ្ជើញពួកកៀនមកផឹកស្រាព្រមគ្នា ហោហ្លួន ក៏លើកក្រូបផាក់លើតុហើយថា បួធនោះខាំងពូកែណាស់ ទាំងទាហានធំ តូច ក៏មានច្រើន ឥឡូវវាយបានស្រុកគីដីវហើយ បើយើងនឹងស្ងៀមនៅដូច្នេះ ក៏នឹងមិនរួចពីដៃបួធ យើងត្រូវតែប្រមូលគ្នាទៅចូលនៅនឹងបួធ បើនណាមួយមិនព្រម យើងនឹងយកក្រូបនេះកាត់ក្បាលចេញ ៗ

ហ៊ានហាំងពួកដូច្នោះក៏ខឹងណាស់ កន្ត្រាក់ក្រូបនោះបោះចោលចេញហើយស្រែកថា អ្នកសៀវចិញ្ចឹមយើងរៀងមកបានសេចក្តីសុខ តែយើងនៅមិនទាន់បានតបគុណស្រែអ៊ីនៅឡើយ ឥឡូវគួរចៅ ចៅហ្វាយយើងបានសេចក្តីក្តៅក្រហាយដោយអន្តរាយស្រុកទេស គួរតែយើងតាំងចិត្តយកអាសាត្រាតែអស់ជីវិត ហោតុអ៊ីអ្នកឯងមកគិតទុរយសទៅចូលនឹងបួធនោះវិញ យើងមិនយល់ព្រមផងទេ ៗ នាយទាហានទាំងពួងឃើញហោហ្លួននឹងហ៊ានហាំងជជែកទាស់គ្នាដូច្នោះ ក៏មិនបានគិតថាជាប្រការម្តេចៗហោហ្លួនក៏

និយាយនឹងហ័នហានថា " ការទាំងនេះយើងរិះគិតគ្នានឹងអ្នកទាំងពួង អ្នកទាំងពួងក៏យល់ព្រមអស់ហើយ តែខ្លួនអ្នក ១ នៅមិនព្រមចូលនឹងយើង ហេតុនេះខ្លួនចូលមកនៅនឹងពួកយើងនោះមិនគួរ " ទើបឲ្យមនុស្សបណ្ដេញហ័នហានចេញផុតពីទីនេះទៅ ។

ឯទាហានចូចូទាំង ៣ កងនោះ លុះលើកទ័ពទៅជិតដល់ស្រុកអ៊ែវជីវហើយ ទទួលដឹងដំណឹងថា អួន ហ៊ុ, អួនស៊ុងរត់ទៅតាមផ្លូវស្រុកលៀវសៃ ក៏លើកកងទ័ពតាមទៅដល់ស្រុកលៀវសៃទៀត ។ ខណៈនោះ ហោហួនដឹងក៏ចេញមកទទួលទាហានចូចូ នាយទាហានទាំង ៣ កងក៏សួរថា អួនហ៊ុ, អួនស៊ុងមកសំណាក់អាស្រ័យនឹងអ្នកឬ ? ហោហួនឆ្លើយថា មិនដឹងទេ ហើយប្រាប់ថា ខ្ញុំបាទនេះស្ម័គ្រចង់ទៅនៅធ្វើរាជការនឹងមហាឧបរាជ ។ នាយទាហានទាំងនោះក៏នាំខ្លួនហោហួនទៅឲ្យចូចូ ហើយសាសព្ទដំណើររឿងរ៉ាវ ដែលមានមកពីដើមឲ្យចូចូស្ដាប់ ចូចូក៏មានសេចក្ដីត្រេកអរសាទរណាស់ ទើបតាំងហោហួនជាចៅហ្វាយស្រុកលៀវសៃដូចដើម តែយកខ្លួនទុកធ្វើការរាជការជាមួយ ។

ខណៈនោះ មានបំរើសេះមកប្រាប់ចូចូថា ទៀវអៀន, ង៉ក់ជិន, លីទៀនដែលទៅវាយស្រុកបេងជីវនោះ ខាងកោក័នចៅហ្វាយស្រុកក៏លើកទាហានចេញមកតាំងបន្ទាយតគ្នានៅជំបន់គយហោគួន បានច្បាំងតគ្នា

ជាច្រើនលើកច្រើនគ្រា  នាយទាហានទាំង ៣ នាក់នឹងកាប់យកស្រុកនោះ ក៏មិនបាន ។ បុច្ចុឮដូច្នោះ ក៏ចាត់ចែងទាហានលើកជាកងទ័ពប្រដាប់សម្រាប់ បញ្ជូនទៅទៀតលុះទៅដល់គយហោគន  នាយទាហានទាំង៣នាក់ក៏ចូល ទៅជំរាបបុច្ចុតាមដែលបានតតាំងច្បាំងគ្នានឹងគោកគននោះគ្រប់ប្រការ ។

បុច្ចុដឹងហើយក៏ប្រឹក្សានឹងនាយទាហានទាំងពួងថា  យើងនឹងគិត ប្រការម្តេច ទើបនឹងចាប់ខ្លួនគោកគនបានដោយងាយ ?  ស៊ុនហ៊ុតបថា ទាហានអួនសៀវ ដែលមកនៅក្នុងកងទ័ពយើងជាច្រើន ត្រូវចាត់រកនរណា ដែលមានតម្រេះប្រាជ្ញាឲ្យធ្វើជារត់ទៅរកគោកគន  ហើយនឹងគិតជាកលសឹក ទើបនឹងចាប់គោកគនបានដោយងាយ ។  បុច្ចុយល់ឃើញត្រូវ  ទើបឲ្យប្រាប់លីកងលីសៀងឲ្យទំរិះគិតទៅធ្វើការចាប់ខ្លួនគោកគនឲ្យបាន ។

លុះវេលាយប់ លីកង , លីសៀង ក៏នាំទាហានដែលស្និទ្ធប្រហែល ៥០ នាក់ទៅដល់ទ្វារគយ  ហើយក៏ប្រាប់ទាហានដែលចាំទ្វារថា  យើង សូមចូលទៅជួបនឹងគោកគន  នាយទ្វារទើបយកសេចក្តីនោះទៅប្រាប់ គោកគនរួជឹងដូច្នោះហើយ ក៏អើតមើលទៅតាមបន្ទោះសើន ឃើញលីកងលី សៀងហើយសួរថា ខ្លួនមករកយើងនេះដោយប្រការអ្វី ? លីកងលីសៀង តបថា  ខ្ញុំជាទាហានអួនថាំ  ដែលខ្ញុំបាទបានចូលទៅនៅនឹងបុច្ចុនោះ ដោយអួនថាំប្រើទៅក៏ចាំចិត្តនៅ  ឥឡូវបុច្ចុធ្វើការខុសចិត្តអាក្រក់ផ្សេង ៗ

ដល់ខ្ញុំបានសេចក្ដីឈឺចិត្ត  បានជាខ្ញុំលបរត់មកប្រាថ្នានឹងចូលមកនៅនឹង លោកឯណោះ ដើម្បីនឹងបានជួយធ្វើការរិះគិតកំចាត់ប្អូនជាផ្សែងសឹកវិញៗ

គោកនស្ដាប់ហើយក៏នៅមានចិត្តសង្ស័យ  សួរទៅលីកងលីសៀង វិញថា  បើខ្លួនគិតដូច្នេះ ត្រូវឲ្យទាហានដែលមកជាមួយនៅខាងក្រៅ  ខ្លួន ទាំង ២ ចូលមកនិយាយនឹងយើងសិន   លីកងលីសៀងឃើញថាគោកន មិនជឿចិត្តដូច្នោះ ក៏ក្លែងធ្វើជាបោះអាវុធចេញពីដៃ ដោះគ្រោះចេញប្រាថ្នា នឹងឲ្យគោកនអស់សង្ស័យ   គំនាប់គោកនហើយប្រាប់ថា  ប្អូនទើបនឹង លើកកងទ័ពមកដល់កំពង់នៀយហាត់នៅឡើយ  ហើយតាំងបន្ទាយនៅទី នោះ មិនទាន់មាំមួន ពេលកណ្ដាលអធ្រាត្រយប់នេះ បើលោកលើកកង- ទ័ពទៅប្លន់  ក៏នឹងបានបន្ទាយប្អូនដោយងាយណាស់  ៗ

គោកនបានស្ដាប់ហើយក៏យល់ឃើញត្រូវផង   ទើបអស់សេចក្ដី សង្ស័យ  តាំងកេណ្ឌទាហានដែលមានថ្វីដៃត្រៀមទុកប្រហែល ១ ម៉ឺន  ឯ ប្អូនក៏ចាត់ចែងទាហានឲ្យចេញទៅតាំងនៅក្រៅបន្ទាយ ៤ កង  បើឃើញ គោកនចេញមកប្លន់បន្ទាយ  ឲ្យវាយស្ទាក់ទុកកុំឲ្យគោកនថយវិលត្រឡប់ ចូលទៅក្នុងឥយវិញបាន  ទាហានទាំង២ ក៏ចេញទៅធ្វើតាមបង្គាប់ប្អូន ៗ

ឯគោកននោះ លុះដល់ពេលប្រហែលយាម ២ ប៉ុយ  ក៏ប្រើលីកង

លីសៀនឲ្យលើកទៅជាកងទ័ពមុខ ខ្ងនកោក័នជាកងទ័ពជំនួយ លើកទាហានបើកទ្វារបន្ទាយស្រែកហ៊ោចេញទៅប្លន់បន្ទាយបូច្ចូ ឯទាហានបូច្ចូដែលបង្កប់នៅទាំង ៤ ទិស ឃើញៈកោក័នលើកទ័ពចេញមកប្លន់បន្ទាយ ក៏អុជផាវជាសញ្ញាឡើង ហើយបរពលវាយខ្ទប់ប្រសព្វគ្នាមកទាំង ៤ ទិស កាប់សម្លាប់ទាហានកោក័នស្លាប់អស់ជាច្រើន កោក័នឃើញដូច្នោះ ក៏គិតថា យើងចាញ់កល់ៗបាយបូច្ចូហើយ ទើបនាំទាហានដែលសល់នោះថយត្រឡប់ទៅ នឹងចូលក្នុងទ្វារគេយវិញទទួលលីទៀន, ង៉កដិនលើកទាហានវាយខ្ទប់ស្កាត់ពីមុខ ឯទាហានទាំង ៤ កង ក៏លើកតាមពីក្រោយនឹងសងខាងថែមទៀត កោក័នក៏នាំទាហានបរសេះពុះពារទ័ពបូច្ចូចេញទៅបានហើយរត់ទៅ ក្នុងខណៈនោះ បូច្ចូក៏លើកពលយោធាដេញតាមកោក័នទៅ ។

ឯកោក័នក៏រត់ចេញផុតដែនស្រុកគីជីវ ទៅដល់ស្រុកកាន់អ៊ូ ទើបចូលទៅគេហអៀនអង ចៅហ្វាយស្រុក ហើយពណ៌នារឿងរ៉ាវថា វេលានេះបូច្ចូមានកំឡាំងខ្លាំងពូកែណាស់ ទាំងសេនាទាហានក៏មានច្រើន បានលើកទ័ពមកធ្វើអន្តរាយអាណាខេត្រខាងទិសៗគ្នា ឲ្យបានសេចក្តីក្តៅក្រហាយណាស់ ខ្ញុំបាទឃើញថា បូច្ចូមានចិត្តកំរើក ប្រាថ្នាទឹងធ្ងន់មកដល់ដែនស្រុកនេះទៀត សូមឲ្យលោកលើកកងទ័ពទៅទប់ទល់ ហើយ

រាយយកអាណាខេត្រ ដែលប្អូនរាយបាននោះ មកជាចំណុះស្រុកលោកតាំងអស់វិញ ទើបលោកមិនមានអន្តរាយ ។

ពោធិសៀនអង់បានស្តាប់អក្រោយដូច្នោះ ក៏និយាយថា ប្អូននឹងយើងមិនដែលមានសេចក្តីអ្វី ឲ្យជាទីទាស់អធ្យាស្រ័យនឹងគ្នាសោះ ដែលអ្នកឯងថានឹងលើកធ្វើមករាយយកស្រុកយើងនោះ យើងមិនយល់ឃើញព្រមផងទេ ហាក់តែខ្លួនមានចិត្តព្យាបាទប្អូន ទើបមកក្លែងញុះញង់ចង់ទឹងឲ្យយើងមានសត្រូវតែទៅ និយាយហើយក៏បង្គាប់ទាហានឲ្យបណ្តេញគោកនបេញទៅពីក្នុងស្រុក គោកនមករំពឹងគិតតែក្នុងចិត្តថា យើងនឹងទៅទីពឹងអាស្រ័យនៅនឹងឡាវបៀវចៅហ្វាយស្រុកកេងដីវិញចុះ ឃើញថាស្រួលជាង គិតហើយក៏នាំទាហាន ធ្វើចូលដែនខេត្រខាងទិសឧត្តរ ខំស្រូតគាត់តម្រង់ទៅដល់កណ្តាលផ្លូវ ដូនជាពេលយប់ក៏ឈប់សំណាក់នៅទីនោះមួយអន្ទើសិន អង់តាំងជាទាហានគោកនក៏លបកាប់សម្លាប់គោកនស្លាប់ ហើយគាត់យកក្បាលទៅឲ្យប្អូនឯទីគយហោគួន ប្អូនក៏ទទួលអំណរណាស់ ទើបតាត់តាំងអង់តាំងជានាយទាហាន ហើយប្អូនក៏លើកទ័ពចូលទៅរាយយកស្រុកបេងដីវបាន ។

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

( តមក )

## លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង

នាងទេវធីតាអ៊ីហ្សូមេ មុននឹងតបទៅព្រះនាងអាមាតេរ៉ាស៊ូ មិនបាន

គិតវែងឆ្ងាយឡើយ ។ នាងក៏ឆ្លើយតបតមកវិញភ្លាមថា :

" ហេតុម្តេចក៏ព្រះនាងទ្រង់យល់ថា យើងសប្បាយ ? ហេតុម្តេចថា

យើងរីករាយត្រេកត្រអាល ? ព្រោះថា ក្នុងចំណោមព្រះអាទិទេពទាំង

ឡាយមានព្រះនាងទេពធីតាថ្មី មានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ

ល្អលើសព្រះរូបព្រះនាងទៅទៀត " ។

ព្រះនាងទ្រង់មានព្រះហឫទ័យចង់ឃើញកាន់តែខ្លាំងឡើង , ថែម

ទាំងថប់ព្រួយបារម្ភទៀត ។ ចិត្តប្រណាំងក៏ចូលមកស្ទិតនៅជាប់ស្អិតក្នុង

ព្រះហឫទ័យវិត្កហើយធ្វើឲ្យទ្រង់ខាំបបូរមាត់ដោយទ្រង់ព្រះក្រោធខ្លាំង ។

ព្រះនាងទេវធីតាថ្មីហើយមានរូបល្អជាងអញ ? ហេតុម្តេចក៏នាងនេះ

ហ៊ានពោលដូច្នេះ ? ព្រះសូរិយាទេវីទ្រង់មានបំណងចង់ឃើញនាងដែល

អ្នកខ្លួនថា ល្អជាងគេ ។ ទ្រង់ក៏បើកទ្វារគុហាកាន់តែធំៗឡើង ។

តើទ្រង់ឃើញយ៉ាងណាទៅ ? នៅក្នុងកញ្ចក់ដែលតាំងចំមុខព្រះ

កគ្រូព្រះនាង ៗ ទ្រង់ទតទៅឃើញនាងទេវធីតាមួយអង្គ មានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ, មានរស្មីផ្សាយចេញពីព្រះកាយព្រះនាងព្រាលឆ្អៅ .... ។ តើនាងទេវធីតាដែលប្រកបដោយសោភណភាពមានរូបកាយស្អាតល្អពន់ពេកនោះ គឺព្រះនាងនេះឯង ? ។

ព្រះនាងទ្រង់ទតមើលព្រះកាយព្រះនាងក្នុងកញ្ចក់ឃើញរូប ព្រះនាងប្រកបដោយសម្រស់ល្អអស្ចារ្យ, ទ្រង់ក៏ចូលទៅជិតកញ្ចក់ ... ។ មានអាទិទេពមួយអង្គ ទ្រង់ស្ទុះទៅចាប់ព្រះហស្តព្រះនាង; មានអាទិទេពមួយអង្គទៀត ទ្រង់ចោលខ្សែធ្វើពីចំបើងមួយពីក្រោយព្រះនាង ដើម្បីកុំឲ្យព្រះនាងទ្រង់វិលទៅក្រោយបាន ។ រស្មីក៏ផ្សាយចេញពាសពេញពិភពលោក ។

ព្រះនាងអាមាតេរាស៊ូទ្រង់ក៏មានព្រះហឫទ័យសោមនស្ស ចង់ស្និតនៅជាមួយពពួកអាទិទេពទាំងឡាយ, តែទ្រង់សូមឲ្យពួកអាទិទេពធ្វើកណ្ដកម្មចំពោះព្រះវៀមស៊ុសាណូ ។ ហើយពួកអាទិទេពក៏ចាប់អាទិទេពស៊ុសាណូ យកមកកាត់ពុកចង្កា, ដកក្រចកដៃក្រចកជើងអស់ ហើយបំបរបង់ចេញពីមហាមេឃ ទម្លាក់មកឲ្យនៅលើផែនដី ជាអវសាន ។

## អាទិទេពស៊ុសាណូនិងនាគក្បាលប្រាំបី

ទ តាចាស យាយចាស់មានចិត្តញៀររន្ធត់ តែមិនដឹងជាដោយហេតុអ្វី

(មានត)

# រឿងចៅឆាយក្តាំង

## លោក ទៀង-តែ-ឈុង

ប្រែរៀបរៀង ( តចប់ )

ឆ្មាឆ្លើយថា នែពស់វែក , អញលែងឯងបាន , ប៉ុន្តែឲ្យឯងទៅចឹកក្របីមួយឲ្យស្លាប់ ។ ឲ្យតែលែងខ្ញុំចុះ, ខ្ញុំសន្យានឹងទៅសម្លាប់ក្របីនោះឲ្យបាន ។

វេលានោះ , ឆ្មាលែងពស់វែកឲ្យរួចខ្លួន , ពស់នេះលូនទៅចឹកក្របីស្លាប់ ហើយចូលរូងបាត់ទៅ ។

កាលណោះ ត្មាតឃើញខ្មោចក្របីក៏ចុះមកហែកស៊ី ។ ឆ្មាស្ទុះទៅដិតកន្លែងនោះ ដោយលាក់ខ្លួនហើយចាប់បានត្មាតខាំត្រង់កជាប់ ។ ឆ្មាសួរទៅត្មាតថា នែស្តេចត្មាត , ឯងទុកកែវមណីជោតិដែលឯងលួចទៅទុកឯណា ? ឲ្យមកអញវិញ អញនឹងលែងឲ្យឯងរស់ជីវិត ។

ត្មាតដោយខ្លាចស្លាប់ ក៏ក្អួតត្បូងចេញមក ។ ឆ្មាពាំកែវទិព្វដែលរកឃើញមកវិញ ហើយដើរទៅផ្ទះចៅហ្វាយវា ។

កាលបើឆ្កែឃើញឆ្មាពាំកែវមណីជោតិ , ក៏ខំបោលទៅតាមឆ្មាពីក្រោយ ។ លុះទាន់ឆ្មាហើយ, ទើបនិយាយថា នែប្អូនឲ្យត្បូងមកអញពាំម្តងទៀត ។ "អញមិនឲ្យទៅឯងទេម្តងនេះ , ព្រោះឯងធ្វើឲ្យអញព្រួយចិត្តច្រើនលើកច្រើនគ្រាមកហើយ" ឆ្មាឆ្លើយទៅឆ្កែវិញ ។

ក្អែស្ទុះទៅដណ្តើមកែវមណីជោតិពីឆ្មា, តែឆ្មាមិនព្រមឲ្យសោះ ។ ក្អែខឹងយ៉ាងខ្លាំងហើយខាំឆ្មា ។ ឆ្មាឈឺពេកក៏ឲ្យត្បូងនោះទៅក្អែ ហើយរត់ទៅផ្ទះមុនក្អែ ។ នៅតាមផ្លូវ, ក្អែឃើញកុកក្រក់ ហើយគាំងព្រួសកុកនោះទាល់តែក្អួចខ្ជួន ។ កែវមណីជោតិក៏ធ្លាក់ពីមាត់ទៅដី ។ ក្អែមិនគិតរកត្បូងនោះទេ បេះតែបោលត្រង់ទៅផ្ទះតែម្តង ។

ចំណែកឆ្មា, ទៅដល់ផ្ទះមុនជាស្រេចៗ កាលបើឃើញឆ្មាមកដល់ហើយ, ចៅហ្វាយក្តាំងសួរទៅឆ្មាថា ប្អូនឯងយកកែវមណីជោតិបានមកឲ្យអញឬទេ? ។ "បាទ, ប៉ុន្តែក្អែពាំមកតាមក្រោយខ្ញុំ ឆ្មាឆ្លើយ" ។

បន្ទាប់មក ឆ្មាអធិប្បាយរឿងរ៉ាវអំពីការតក់ស្លុតដែលក្អែបានប្រព្រឹត្តតាមផ្លូវ ឲ្យចៅហ្វាយក្តាំងស្តាប់ ដូចបាននិយាយពីខាងលើមកស្រាប់ ។

ក្នុងពេលនោះ, ក្អែមកដល់ ។ ចៅហ្វាយក្តាំងពោលពាក្យមិនពីរោះទៅកាន់ក្អែថា នែក្អែ, ឲ្យកែវមណីជោតិមកអញយ៉ាងប្រញាប់ ។

ក្អែឆ្លើយវិញដោយទឹកមុខស្លូតថា ខ្ញុំមិនដឹងជាត្បូងនោះធ្លាក់នៅកន្លែងណាទេ ។ ឆ្មាស្រែកកាត់ឡើងថា ខ្ញុំដឹងច្បាស់ថា ត្បូងនោះធ្លាក់នៅត្រង់កុកក្រកណេះ ។

ចៅហ្វាយក្តាំងជេរក្អែថា អាឯង ជាក្អែប៉ុនខាងឆបោក, មានគល ល្បិចមិនស្មើនឹងកូនក្អែប្រដេញផង ។ ទៅរកត្បូងនោះឲ្យឃើញ! បើអាឯង

រកមិនឃើញយកមកឲ្យអញប្រញាប់ទេ , អញនឹងសម្លាប់អាឯងភ្លាមឥឡូវនេះ ៗ ពួកជូហ្នោះហើយ , តែគិតភ័យយ៉ាងខ្លាំង ៗ ក៏ហៅគ្នាឲ្យទៅជួយរកកែវមណីជោតិ ៗ លុះរកឃើញត្បូងទិព្វនេះ , តែនឹងគ្នានាំគ្នាយកទៅឲ្យចៅបាយក្ដាំងដោយស្រួល ៗ កាលបើបានកែវមណីជោតិមកវិញហើយ , ចៅបាយក្ដាំងសំដែងសេចក្ដីក្លាហាន នឹងធ្វើចម្បាំងជាមួយនឹងស្ដេចប្រណែនម្ដងទៀត ៗ ដូច្នេះ ចៅបាយក្ដាំងបួងសួងថា ដោយអានុភាពនៃកែវមណីជោតិនេះ, ខ្ញុំឲ្យលោកម្ចាស់ជួយឲ្យកើតកងទ័ពមួយ ដែលមានទាហានច្រើនអនេក ព្រមទាំងឲ្យមានគ្រឿងអាវុធ គ្រប់យ៉ាងគ្រប់បែបផង ៗ

បួងសួងរួចហើយ, ចៅបាយក្ដាំងលើកត្បូងទិព្វបង្អិល , ស្រាប់តែទ័ពផុសឡើងដូចប្រាថ្នា ៗ ចៅបាយក្ដាំងនាំកងទ័ពខាងលើនេះ ទៅវាយប្រទេសដែលប្រកួតគ្នា ដោយគ្មានឲ្យដំណឹងជាមុនដល់គូសត្រូវ ៗ ក្រោយដែលបានចូលទៅលុកនគរនេះ , ទ័ពចៅបាយក្ដាំងវាយទីក្រុងនេះ បាក់បែកខ្ទេចខ្ទីអស់គ្មានសេសសល់ ព្រមទាំងសម្លាប់ទាហានបច្ចាមិត្តច្រើនជាអនេកពុំអាចនឹងរាប់បាន ៗ

បន្ទាប់មក , ចៅបាយក្ដាំងបង្គាប់ឲ្យរកគ្រួសារខ្លួនដោយស្រួល គឺស្ដេចដែលជាព្រះបរមពង្សបិតាក្មេក , ព្រះមាតានឹងព្រះនាងពៅជាភរិយា ៗ តមកទៀត , ចៅបាយក្ដាំងរកឃើញជីដូនជាខាងក្រោយបន្ទស់ ៗ នៅទីបុ

ផុត , ចៅបាយក្តាំងនាំនិរទេសកជនទៅក្នុងព្រះរាជអាណាចក្រទេពបុរីវិញទាំងអស់ ។ ក្រោយពីជ័យជំនះនេះមក, ព្រះបរមរាជបិតានិងព្រះមាតាក្មេកទ្រង់មានព្រះចិន្តាគិតថា : " ចៅបាយក្តាំងកូនប្រសាយើងមានគុណូបការយ៉ាងឧត្តម ។ យើងទាំងពីរនាក់ចាស់ហើយ, ហេតុដូច្នេះ យើងសម្រេចធ្វើពិធីប្រសិទ្ធិចៅបាយក្តាំងនឹងនាងពៅកូនស្រីយើង ជាក់ឲ្យសោយរាជ-សម្បត្តិជំនួសយើង ដើម្បីឧបត្ថម្ភប្រជារាស្ត្រតរៀងទៅ " ។ ព្រះអគ្គទ្រង់មានព្រះចិន្តាគិតស្រេចហើយ , ទ្រង់ត្រាស់បង្គាប់ឲ្យហោរាគន់គូររើសរកថ្ងៃដែលមានជោគជ័យល្អ ធ្វើពិធីអភិសេកចៅបាយក្តាំងនឹងនាងពៅឲ្យសោយរាជ្យ ។ ការធ្វើអភិសេកនេះ អាចបញ្ជាក់ឲ្យឃើញច្បាស់ថា ចៅបាយក្តាំងនឹងនាងពៅមានអានុភាពពេញជាព្រះមហាក្សត្រគ្រប់គ្រងប្រទេស ។

ចៅបាយក្តាំងតាំងគ្នាជាក្រឡាហោម ។ ប្រជារាស្ត្រទាំងអស់ហៅឯកឧត្តមក្រឡាហោមម៉ា ។ ថ្កៃបានទទួលឋានៈជាឧកញ៉ាយោមរាជ ។ ប្រជារាស្ត្រទាំងអស់ហៅឯកឧត្តមយោមរាជថ្កៃ ។

ចៅបាយក្តាំឡើងជាព្រះករុណាចៅបាយក្តាំង ។

នាងពៅបានឋានៈជាអគ្គមហេសីទី ១ ។ អ្នកទាំងពីរនេះសោយរាជ្យដោយជាប់ខាតនៅក្នុងព្រះរាជអាណាចក្រទេពបុរី ហើយគ្រប់គ្រងប្រជា–រាស្ត្រដោយសុវត្ថិភាពនិងសន្តិសុខ ។

ចប់រឿងចៅបាយក្តាំងតែប៉ុណ្ណេះ ។

# ព្រះរាជពិធីត្រស្តិសង្ក្រាន្ត

## លោក ប៉ាប-ពិន រៀបរៀង

ប្រទេសខ្មែរយើង មានពិធីចូលឆ្នាំជា ២ រយៈ ៖

១ សម័យបុរាណ តាមអាយន្តសង្ក្រាន្ត (ចន្ទគតិ) កំណត់ការចូលឆ្នាំមិនទៀង ចួនកាលថ្ងៃនេះ ចួនកាលថ្ងៃនោះ ចួនកាលខាងខ្នើត ចួនកាលខាងរនោច គ្រាន់តែមានកំណត់ទុកថា សង្ក្រាន្តមានក្នុងរវាង១ខែ គឺមិនមុនថ្ងៃ ៤ កើត ខែចេត្រ និងមិនហួសថ្ងៃ ៤ កើត ខែពិសាខ ។

២ សម័យបច្ចុប្បន្ន តាមសាមញ្ញសង្ក្រាន្ត (សុរិយគតិ) កំណត់ការចូលឆ្នាំទៀងទាត់ នៅពេលដែលព្រះអាទិត្យចូលកាន់មេសរាសី គឺព្រះអាទិត្យដើរត្រង់ពីលើក្បាល, ថ្ងៃចូលឆ្នាំរមែងត្រូវលើថ្ងៃទី ១៣ ខែមេសាជាដរាបរៀងរាល់ឆ្នាំ ។

ដោយហេតុការកំណត់ចូលឆ្នាំថ្មីរបស់ខ្មែរយើងមាន ២ រយៈ ដូច្នេះបានជាទំនៀមខ្មែរយើងតាំងពីថ្ងៃ ១ កើត ខែចេត្រទៅ លោកហៅថាឆ្នាំថ្មី ហើយព្រោះផ្លាស់ឈ្មោះឆ្នាំតាមនក្ខត្តឫក្ស១២ គឺជូត ឆ្លូវ ។ល។ កុរ ១ជាន់ តែមិនទាន់ផ្លាស់ស័ក ឬសកពជនៅឡើយ ។ លុះតែព្រះអាទិត្យគោចរចូលកាន់មេសរាសីកាលណាទើបផ្លាស់សកពជថ្មីក្នុងថ្ងៃនោះ គឺក្នុងថ្ងៃដែល

យើងធ្លាប់ហៅថាថ្ងៃឡើងស័ក ។ ក្នុងពេលចូលខែចេត្រហើយតែនៅមិនទាន់ឡើងសករាជ ត្រូវប្រើប្រាប់ជាឆ្នាំថ្មីហើយ តែសករាជត្រូវនៅជាឆ្នាំចាស់នៅឡើយ ។

ក្នុងព្រះបរមរាជវាំងនៃប្រទេសកម្ពុជាយើង តែងធ្វើព្រះរាជពិធី ១ នៅពេលដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ។ ព្រះរាជពិធីនេះធ្វើអស់រយៈវេលា ៤ ថ្ងៃ ៤ យប់ គឺនៅថ្ងៃ១២-១៣ ១៤.១៥កើត ខែផល្គុន ហៅថា "ព្រះរាជពិធីត្រស្តិសង្ក្រាន្ត ប្រែថា ព្រះរាជពិធីផ្តាច់ឆ្នាំចាស់ ផ្លាស់សង្ក្រាន្តជាឆ្នាំថ្មី" ។ សម័យបុរាណលោកហៅថា " ព្រះរាជពិធីសម្ពច្ឆរច្ឆិន្ទ " ដូច្នេះក៏មានប្រែថា ព្រះរាជពិធីផ្តាច់ឆ្នាំ ដូចគ្នា គឺជាព្រះរាជពិធីជូនដំណើរឆ្នាំចាស់ដែលត្រូវចេញទៅ ទទួលឆ្នាំថ្មីដែលត្រូវចូលមកទៀត ហើយនឹងជាព្រះរាជពិធីកាត់ឧបទ្រពចង្រៃឆ្នាំចាស់ បណ្តេញខ្មោចបិសាចចាស់ អញ្ជើញទេវតាថ្មី ចំរើនសិរីសួស្តីជ័យមង្គលមហាប្រសើរក្នុងឆ្នាំថ្មីតទៅទៀត ។

ព្រះរាជពិធីត្រស្តិសង្ក្រាន្ត មានរបៀបដូចរៀបរាប់ដោយសង្ខេបតទៅនេះ:

-ខាងក្រៅកំពែងព្រះបរមរាជវាំង មានមណ្ឌលពិធី ៥ កន្លែង គឺខាងមុខព្រះបរមរាជវាំង ២ ខាងត្បូង ១ ខាងជើង ១ ខាងលិច ១ ។ ក្នុងរោងនីមួយៗ សម្រាប់ព្រះសង្ឃគង់ ៨ អង្គ ។ មានរានទេវតាគ្រប់ ៨ទិស ។

រដ្ឋកាលបច្ចុប្បន្ន (គ-ស-១៩៥៨) ពេនមណ្ឌលទាំង ៥ ធ្វើក្នុង ព្រះបរមរាជវាំង ។

-មានខ្សែក្រមួនស្បូវក្រាំងចងព័ទ្ធកំពែងព្រះបរមរាជវាំងជុំវិញហើយ ចងអំបោះសីមាតភ្ជាប់ពីចុងខ្សែស្បូវក្រាំងនោះចូលទៅក្នុងព្រះបរមរាជវាំង , ព័ទ្ធសីមាគ្រប់ព្រះតំណាក់ទាំងឡាយមានមហាប្រាសាទជាដើម ហើយ ចូលទៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ប្រជុំចុងអំបោះសីមាទាំងនោះនៅគ្រែ ព្រះរាជពិធីនឹងស៊ុំទៀនជ័យ ។ គ្រែព្រះរាជពិធីមាន ២ គឺតាំងនៅត្រង់ ល្វែងខាងជើង ១ ខាងត្បូង ១ នៃព្រះទីនាំងទេវាវិនិច្ឆ័យ សម្រាប់លោក គង់សូត្រមន្តនឹងសូត្រគាណយក្ស ។ ស៊ុំទៀនជ័យតាំងនៅត្រង់ល្វែងខាង កើតនៃព្រះទីនាំងទេវាវិនិច្ឆ័យ សម្រាប់អុជទៀន ១ ដើមធំ ហៅទៀនជ័យ តាំងពីថ្ងៃចូលព្រះរាជពិធីរហូតដល់ថ្ងៃបង្ហើយ ។ ល្វែងកណ្ដាលជាព្រះ រាជាសនៈ នឹងអាសនៈព្រះរាជវង្សានុវង្ស ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រី ។

-មានដំបងពេជ្រ ជាដំបងបណ្ដេញខ្មោច ធ្វើដោយស្ពឹកកំពូល ក្តោតបង្កួបខាងចុងមានសណ្ឋានដូចបំពុះក្អែក សរសេរអក្សរទាំងពីរខាង ម្ខាងថា សត្តេ យក្ខា បិសាចាវ អាឡវកាទយោបិច ១ក្តំ តាលបត្តំ ទិស្វា សត្តេ យក្ខា បលាយន្តិ ម្ខាងទៀតថា ឯកបត្តា ទេ្វកបត្តា សត្តេ យក្ខា បលាយឹសុ,

សម្រាប់ព្រះរាជា ព្រះរាជវង្សានុវង្សទ្រង់ នាម៉ឺនសព្វមុខមន្ត្រីកាន់ នៅពេលព្រះសង្ឃសូត្រភាណយក្សរួច ។

-មានអំបោះអភិសមរ ជាខ្សែចំណងបង្ការខ្មោច ធ្វើដោយអំបោះ ៨សរសៃ ទីងស៊ីកកំពូលក្តោតប៉ុនកូនដៃ សរសេរអក្សរថាវិសមរ បត់ជា ៤ជ្រុងចងជា ៩ អន្ទើ សម្រាប់ទ្រង់ឈៀង ពាក់ឈៀង នៅពេលជាមួយនឹងដំបងពេជ្រ ។

-មានអំបោះក្តុក ជាអំបោះមង្គល ធ្វើដោយអំបោះច្រើនសរសៃធ្លាយរង្វេល សម្រាប់ទ្រង់នៅព្រះសិរ ពាក់នៅសីសៈដំណាលនឹងដំបងពេជ្រ។

ព្រះរាជពិធីត្រស្តិសង្រ្កាន្ត ជាព្រះរាជពិធីធំមួយក្នុងបណ្តាព្រះរាជពិធីទ្វាទសមាស ហើយជាព្រះរាជពិធីទាក់ទងដោយព្រះពុទ្ធសាសនានឹងព្រាហ្មណសាសនា មានលំនាំប្រហែលនឹងពិធីសូត្រមន្ត ធមន្តលោកជាន់នៅវេលាដាច់ឆ្នាំ ជាព្រះរាជពិធីបណ្តេញខ្មោចបិសាច រំដោះគ្រោះម្ចាប់ចង្រៃក្នុងឆ្នាំចាស់ចំរើនសិរីសុខសួស្តីមហាវិជ័យមង្គលគ្រប់ប្រការក្នុងឆ្នាំថ្មី ចំពោះព្រះរាជា ព្រះរាជវង្សានុវង្ស និងដល់ប្រជារាស្ត្រទូទាំងព្រះរាជអាណាចក្រ។

កម្មវិធីរាល់ឆ្នាំនៃព្រះរាជពិធីត្រស្តិសង្រ្កាន្ត :

ថ្ងៃ១២រោច ខែផល្គុន :

ម៉ោង ៦ ល្ងាច ព្រះរាជាស្តេចយាងចេញទ្រង់ប្រារព្ធទៀនជ័យជា

មួយសម្តេចព្រះសង្ឃនាយក ដោយព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រីក្រាបបង្គំគាល់ ។

-ព្រះសង្ឃ ១០ អង្គចម្រើនព្រះបរិត្តក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ, ៤០ អង្គនៅមណ្ឌលទាំង ៥ មណ្ឌលនីមួយ ៗ ៨ អង្គ ។

ថ្ងៃ ១៣រោច ខែផល្គុន៖

-ម៉ោង ១១ ព្រឹកព្រះរាជាស្តេចយាងចេញប្រថាប់ក្នុងព្រះទីនាំងទេវា-វិនិច្ឆ័យប្រគេនចង្ហាន់ព្រះសង្ឃដែលចម្រើនព្រះបរិត្តពីល្ងាច ដោយមន្ត្រីក្នុងព្រះបរមរាជវាំងក្រាបបង្គំគាល់ ។

-ម៉ោង ៦ ល្ងាច ព្រះរាជាស្តេចយាងចេញប្រថាប់ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យទ្រង់ព្រះសណ្តាប់ព្រះបរិត្ត ដោយមន្ត្រីក្នុងព្រះបរមរាជវាំងក្រាបបង្គំគាល់ ។

-ព្រះសង្ឃ ១០ អង្គចម្រើនព្រះបរិត្តក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ៤០ អង្គនៅមណ្ឌលទាំង៥ ដូចល្ងាចទី១ ។

ថ្ងៃ ១៤ រោច ខែផល្គុន៖

ម៉ោង១០ ព្រឹក ព្រះរាជាស្តេចយាងចេញប្រថាប់ក្នុងព្រះទីនាំងទេវា-វិនិច្ឆ័យ ដោយមន្ត្រីក្នុងព្រះបរមរាជវាំងក្រាបបង្គំគាល់ ។

-ព្រះថេរៈ ១ អង្គសូត្រប្រកាសទេវតា ។

-ប្រគេនចង្ហាន់ព្រះសង្ឃដែលចម្រើនព្រះបរិត្តពីល្ងាច ។

-ម៉ោង ៥ ល្ងាច ព្រះសង្ឃចម្រើនព្រះបរិត្តដូចល្ងាចទី ១ តែព្រះរាជាពុំស្តេចយាងចេញទេ, មានតែមន្ត្រីក្នុងព្រះបរមរាជវាំងប្រតិបត្តិការ ។

-ម៉ោង ៩ យប់ ព្រះរាជាស្តេចយាងចេញប្រថាប់ក្នុងព្រះទីនាំងទេវា-វិនិច្ឆ័យ ដោយព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រីក្រាបបង្គំគាល់ ។

-ព្រះថេរៈ ១ អង្គឈរលើអាសនៈខ្ពស់កណ្តាលព្រះទីនាំងទេវាវិនិច្ឆ័យ ប្រកាសទេវតា ដោយមានបុគ្គលិក៤នាក់ពាក់លំផកការដាយសអង្គុយខាងកើតជិតអាសនៈនោះដំណាងស្តេចចតុលោកបាលទាំង ៤ចាំស្តាប់ព្រះធម៌ ។

-ព្រះសង្ឃ ៤ អង្គសូត្រព្រះធម្មចក្រនៅអាសនៈខាងត្បូង,៤អង្គសូត្រមហាសម័យលើគ្រែព្រះរាជពិធីខាងត្បូង, ៥ អង្គ សូត្រភាណយក្សនៅគ្រែព្រះរាជពិធីខាងជើង,៨១អង្គសូត្រភាណយក្សនៅរោងមណ្ឌលពិធីទាំង៥ ។

ការសូត្រភាណយក្សតែងសូត្រទាល់ភ្លឺនៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យនិងក្នុងមណ្ឌលទាំង៥ ។

ក្រោយពីសូត្រភាណយក្សលើកដំបូង ក្រុមមុខក្រសួងថ្វាយនិងជូនដំបងពេជ្រ-អំបោះអភិសមរ អំបោះក្អកចំពោះព្រះរាជា, ដល់ព្រះរាជវង្សា-នុវង្ស និងដល់នាម៉ឺនសព្វមុខមន្ត្រី ។

ថ្ងៃ១៥រោច ខែផល្គុន :

-ម៉ោង ៨ ព្រឹកព្រះករុណាទ្រង់ព្រះពស្ត្រព្រះសុកាក់សស្រង់ព្រះសុគន្ធវារីព្រះពុទ្ធមន្តក្នុងព្រះបរមរាជវាំង ដោយសម្តេចព្រះសង្ឃនាយកថ្វាយព្រះសុគន្ធវារី មានតែមន្ត្រីគ្រប់តំណែងក្នុងព្រះបរមរាជវាំងក្រាបបង្គំគាល់ ។

-ម៉ោង ១០ ព្រឹក ព្រះករុណាស្តេចយាងចេញប្រថាប់ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ប្រគេនបង្ហាន់ព្រះសង្ឃ២៦ អង្គ ដោយមន្ត្រីក្នុងព្រះបរមរាជវាំងក្រាបបង្គំគាល់ ។

-ព្រះសង្ឃឆាន់រួច ព្រះករុណាស្តេចយាងចេញលត់ទៀនជ័យជាមួយសម្តេចព្រះសង្ឃនាយក ។

-ម៉ោង ៥ ល្ងាច ព្រះថេរៈ ២ អង្គនិមន្តបាចសាចទឹកព្រះពុទ្ធមន្តក្នុងព្រះបរមរាជវាំង (គ្មានគាល់) ។

ចប់ព្រះរាជពិធីត្រឹមប៉ុណ្ណេះ ។

សេចក្តីបញ្ជាក់ :

ព្រះរាជពិធីត្រស្តិសង្ក្រាន្ត ក្នុងរជ្ជកាលមុនៗមានធ្វើព្រះរាជពិធីបញ្ចាន់ជាទបកិច្ចបណ្តេញខ្មោចបិសាច គឺធ្វើរូបយក្សយ៉ាងធំមាំឲ្យកាន់ដំបងឈរនៅក្បែរកេនមណ្ឌលពិធីខាងមុខព្រះបរមរាជវាំង,ឲ្យមេមត់ម្នាក់កាន់គោកចអង្រួយលើកទ ១ ក្បែររូបយក្សនោះ ។ ពេលព្រះសង្ឃកំពុងតែស្រែក

សន្ទាប់កាណយក្ស កាំភ្លើងកំពុងតែបាញ់ពួកដំរីពង គេក៏លែងដំរីសារឲ្យទៅព្រៃជ្ញរូបយក្សនឹងមេមត់នោះ ។ ពេលដំរីទៅជិតដល់ ឲ្យជនម្នាក់ឈរក្បែរទីនោះបញ្ឆោតដំរីឲ្យដេញព្រៃជ្ញខ្លួន ។ ជននោះរត់ទៅរកមេមត់ៗរត់ចោលកនទៅ នៅតែរូបយក្សនឹងកនទទេ ដំរីក៏ចាប់បោចពេចជាន់ព្រៃជ្ញរូបយក្សនឹងកនទនោះខូចខ្ទីអស់ ។ ហេតុនេះបានជាលោកហៅថាព្រះរាជពិធីបញ្ចាន់ត្រស្ដិ៍ គឺបញ្ចាន់បណ្ដេញខ្មោចផ្ដាច់ឆ្នាំ ជានិមិត្តរូបនៃការបណ្ដេញបំបរខ្មោចបិសាចឲ្យបវៀសបៀសឆ្ងាយទៅ ។

រដ្ឋកាលមុនៗ កាលព្រះសង្ឃសូត្រកាណយក្សចប់លើកដំបូង មុនពេលបញ្ចាន់ ព្រះរាជាទ្រង់ព្រះទម្រង់អគ្គី (កាំភ្លើង) តូចៗកាំភ្លើងទៅតាមព្រះសីហបញ្ជរនៃព្រះទីនាំងទេវាវិនិច្ឆ័យ ។ បន្ទាប់ពីនោះពួកទាហាន ១២ នាក់ ឈរនៅកើយព្រះទីនាំងទេវាវិនិច្ឆ័យបាញ់កាំភ្លើងតូចៗទៅលើអាកាស ហើយភ្នាក់ងារកាំភ្លើងធំនៅមុខព្រះបរមរាជវាំងបាញ់កាំភ្លើងធំតទៅទៀត ជានិមិត្តរូបនៃការសំដែងព្រះរាជានុភាពបណ្ដេញយក្សមារសត្រូវគ្រប់យ៉ាង ។

កាលបាញ់កាំភ្លើងលើកទី ១ ហើយ ព្រះសង្ឃក៏សូត្រកាណយក្សលើកទី ២ តទៅទៀត ចប់ហើយភ្នាក់ងារកាំភ្លើងធំនៅមណ្ឌលពិធីមុខព្រះបរមរាជវាំងផ្ដើមបាញ់កាំភ្លើងឡើង ហើយមណ្ឌលឯទៀតក៏បាញ់ព្រមគ្នាតទៅៗ

ធ្វើរបៀបនេះដរាបដល់ភ្លឺ ។

# អធិប្បាយសុភាសិតខ្លះ

ពាក្យកាព្យ

## លោក ឋាប-ពិន រៀបរៀង

ទីជំទំអត់, ឲ្យត់ទំរគា

បទពាក្យ ៦

សុភាសិតនេះ ជាពាក្យសោភា
អស់យើងគ្រប់គ្នា គួរគិតគួរគន់ ៗ
កើតមកជាមនុស្ស គួរមានចិត្តធ្ងន់
គួរអត់គួរធន់ កុំខឹងផ្ដេសផ្ដាស ៗ
ខឹងខុសខូចខាត ប្រមាថទុច្ចាសន៍
បង់កេរ្តិ៍បង់ខ្មាស បង់យសព្រោះខឹង ៗ
បើខ្វះសម្បត្តិ លោកឲ្យខំប្រឹង
រៀនឲ្យចេះដឹង ខំរកទើបបាន ៗ
ធម្មតាសត្វម្រឹគ នៅព្រៃស្មសាន
ពុំដែលហៅហាន រត់ចូលមាត់ខ្លា ៗ
ទ្រព្យឬចំណេះ ពុំដែលយាត្រា
រត់រកមនុស្សណា ដែលខ្ជិលនោះទើយ ៗ

## ប្រហែសធាត់, ប្រយ័ត្នគង់

**បទមណ្ឌកគតិ**

ពាក្យនេះល្អណាស់ អ្នកប្រាជ្ញជាន់ចាស់សំដែង
ប្រដៅយើងឯង ឱ្យខំខ្នះខ្នែងសង្វាត ។
ថាត្រូវប្រយ័ត្ន នូវទ្រព្យសម្បត្តិ, វិជ្ជា,
រំលឹក, រក្សា ឱ្យល្អណាស់ណាទើបគង់ ។
បើមិនប្រយ័ត្ន, វិជ្ជា, សម្បត្តិ នឹងបង់
នឹងបាត់ពុំគង់ ពុំបានយូរលង់ដូចចិត្ត ។
ប្រាជ្ញលោកពន្យល់ បញ្ជាក់ហេតុផលតាមពិត
ឱ្យឃើញស័ក្តិសិទ្ធិ គួរយើងប្រព្រឹត្តតាមហោង ។

## កុំខ្ពុំមុនស្រគាល

**បទពាក្យ ៧**

សុភាសិតនេះប្រាជ្ញបុរាណ

ប្រដៅមហាជនគ្រប់អង្គប្រាណ ឱ្យបានប្រិតប្រៀនរៀនសិក្សា ។
រៀនអ្វីត្រូវខំ កុំអៀនប្រៀន គឺរៀនឱ្យចេះស្ទាត់ណាស់ណា
បើចេះស្ទើរៗកុំអាលថា "ខ្ញុំបានសិក្សាចេះស្ទាត់ណាស់" ។

រៀនការណាមួយត្រូវកំណត់ ឲ្យចាំហ្មត់ចត់ក្រុកជាច្បាស់
បើមិនទាន់បេះ កុំគាលផ្លាស់ ក្រឡាស់ពេលមុនយកក្រោយផ្ទួន ៗ
ដូចរៀនអក្សរជាដើមអាទិ ត្រូវចំសង្កាត់ឲ្យមាំមួន
ដកបបេះចប់គ្រប់ចំនួន សឹមសំគាល់ខ្លួនថាជ្រៅជ្រាល ៗ
បុរាណប្រដៅសិស្សតូចធំ ថា " កុំឲ្យទុំមុនស្រគាល "
គឺបើចំណេះនៅព្រាំព្រាល កុំគាលលះពេលកណ្ដាលការ ៗ

## ចង់ឆ្ងាញ់ត្រូវការអង្កាំ

## ចង់ស្រណុកត្រូវរៀននឿយ

បទពាក្យ ៨

ពាក្យនេះប្រាជ្ញបុរាណបានប្រឌិត

ប្រដៅយើងទាំងនេះឲ្យបេះគិត តាមគោលដែលល្អពិតគន់និតប៉ង ៗ
អ្នកណាប្រាថ្នាសុខស្រណុកខ្លួន ត្រូវប្រឹងឲ្យមាំមួនខ្ជាំងកន្ទង
រៀនវិជ្ជាព្យាយាមរកទ្រព្យផង ទើបបានផ្ទួងពាកទុក្ខស្រណុកប្រាណ ៗ
ដូចអ្នកដែលប្រាថ្នាពិសាឆ្ងាញ់ ឲ្យមានចម្ងាញ់យ៉ាងក្សេមក្សាន្ត
ត្រូវរកអង្កាំល្អដកល្បាណ ទើបនឹងបានឆ្ងាញ់មាត់ប្រាកដស្ដែង ៗ
ដូច្នេះយើងគួរតែគិតឲ្យរឿយៗ ធ្វើការឲ្យហត់នឿយជាមុនឯង
ទើបក្រោយបានស្រណុកសុខក្រៃលែង ដូចជាប្រាជ្ញសំដែងថ្លែងប្រាប់មក

## តក់ៗដូចទឹកត្នោត ព្រឹកឡើងសោតពេញបំពង់

បទពាក្យ ៩

ពាក្យនេះឯងប្រាជ្ញសំដែងប្រដៅគ្នា
ឲ្យខិតខំសន្សំទ្រព្យ សព្វវិជ្ជា ប្រៀបគួរនាដូចជាធារទឹកត្នោតស្រក់ ៗ
គឺខំរកលៃលករៀនរបៀនផង គ្រប់ពួកគន់វិជ្ជា ទ្រព្យ កុំដំអក់
កុំខ្ជាបនឿយឲ្យរឿយៗដូចដំណក់ ទឹកត្នោតស្រក់ជាច្រើនតក់ពេញបំពង់ៗ
ទ្រព្យ វិជ្ជា ក៏គួរនាដូច្នោះឯង បើប្រឹងប្រែងខ្នះខ្នែងរកពុំរារង់
នឹងមានបានតាមលំអានមិនយូរលង់ បានខ្ពស់ខ្ពង់យ៉ាងរុងរឿងពុំខានឡើយ

## ទឹកត្រជាក់ត្រីកុំ

បទពាក្យ ១០

សុភាសិតនេះលោកអ្នកប្រាជ្ញពីបុរាណ
ពោលជាទុកឲខេមរជាតិទាំងប៉ុន្មាន
ត្រូវមានសន្តានក្សាន្តសន្តោសប្រោសមេត្តា ៗ
ដល់អស់បងប្អូនញាតិសន្តានព្រៀងលានផង
កុំឲ្យមួម៉ងឆ្គាំឆ្គងខឹងនឹងអ្នកណា
ទើបគេស្រឡាញ់អស់អញ្ចិត្តជាមិត្តភាព
គ្រាន់បានគឺគ្នាជាគូកនបនមិត្តភក្តិ ៗ

ដូចកល់គគ្គាផាលំនៅនៃមច្ឆា
មានទឹករេថ្លាជាទីល្អដ៏ត្រជាក់
អស់ពួកមច្ឆាត្រៀបត្រាមករកពឹងពាក់
ខឹងទឹកត្រជាក់សំណាក់នៅសុខក្សេមក្សាន្ត ។

## ឈើពុកកុំដាក់ត្ទូឋលើ (១)

បទពាក្យ ១១

សុភាសិតនេះឯងលោកសំដែងប្រដៅគ្នា
ឲ្យបានខ្ពស់ប្រសើរដំណើរល្អដ៏សោភា
គឺកុំគប់ពាលយកជាគ្នារួមជាមិត្រ ។
មនុស្សពាលគំនិតខូចលោកប្រដូចនឹងឈើពុក
អ្នកណាស៊ុកគ្រលុករួមសុខទុក្ខរួមប្រព្រឹត្ត
ពាលឯងតែងនាំអ្នកដែលប្រឡាក់រួមគំនិត
ឲ្យកើនខូចទឹកចិត្តលុះប្រព្រឹត្តពាលទាំងឡាយ ។
កាលបើប្រព្រឹត្តពាលតែងបណ្ដាលឲ្យពាធា
បៀតបៀនមនុស្សនានានឹងសម្បត្តិសត្វទាំងឡាយ
ឲ្យប្រាសចាកនិកាសវិនាសបាត់រូបខាតខ្ចាយ
រមែងកើតអន្តរាយដល់អ្នកសេពពិតណាស់ណា ។

---

១ សុភាសិតនេះ នឹងអធិប្បាយថា « ជនពាលហ៊ានៈទាបតូច ទុកដូចឈើពុក អ្នកផងកុំដាក់គួចលើ គឺកុំជិះជាន់ប្រមាថមើលងាយ » ដូច្នេះក៏បាន ។

ហេតុនេះទើបលោកហាមឃាត់ទ្រាប់ប្រាមឲ្យគិតក្រែង
ឲ្យមានចិត្តស្ញប់ស្ញែងរអែងខ្លាចមនុស្សពាលា
កុំចូលទៅសេពគប់គប់ប្រសព្វនឹងពួកវា
កុំយកជាមិត្តក្ដា ត្រូវលីលាចៀសចេញឆ្ងាយ ។

### មាត់មានគ្រប ដបមានឆ្នុក

បទពាក្យ ១២

ពាក្យនេះឯងប្រាជ្ញសំដែងថ្លែងរំឭកកេរ្តិ៍យា
ថាជនប្រុសស្រីគប់ក្លិតបិទបាំងកាយវាចា
ឲ្យជិតជិតល្អណាស់ណាទើបសុខាប្រាសក្តីទុក្ខ ។
គឺខាងកាយត្រូវផ្គង់ផ្គត់ពត់តម្រង់ឲ្យត្រង់ផ្លូវ
ខាងវាចាគួរបិទទុកឲ្យសុខុមកុំបបូរ ។
មានសេចក្តីអ្វីបុកៗកុំបំបែកឲ្យបែកទៅ
ឬរបស់ល្អៈក្តីមត្រូវយ៉ាងត្រកាលគួរការពារ ។
ខាងឯមាត់ត្រូវមានគ្រប ខាងឯដបត្រូវមានឆ្នុក
បើខាងមាត់ពុំបិទទុក ដបពុំចុកនឹងខូចការ ។
គំពប់ខ្ចាយរលាយអស់ទ្រព្យរបស់អស់ខ្លឹមសារ
ឯពាក្យបរិហារកេ៍ឧបមាដោយប្រការដូច្នោះឯង ។

# រឿងឯកអគ្គក្សត្រ

## លោក លាង-ហាប់-អាន ប្រែរៀបរៀង

ក្នុងសម័យពីព្រេងនាយ មានមហាក្សត្រមួយព្រះអង្គសោយរាជ្យក្នុងនគរមួយ ទ្រង់មានព្រះអគ្គមហេសីប្រកបដោយលក្ខណសម្បត្តិ ទ្រង់សោយរាជ្យជាសុខសាន្តក្នុងព្រះនគរ ។ ក្នុងថ្ងៃមួយ ទ្រង់មានបរិវិតក្ក ដោយពុំមានព្រះរាជបុត្រគ្រាន់នឹងស្នងព្រះអង្គសោះ ។

ទ្រង់បានបន់ស្រន់អស់ក្ដេទេវតាព្រះឥន្ទ្រព្រះព្រហ្មសូមឲ្យលោកប្រទាននូវបុត្រ ឬធីតាគ្រាន់ជាទីស្នងព្រះអង្គ ។

កន្លងមក ព្រះអគ្គមហេសីក៏ទ្រង់គភ៌ដូចព្រះបំណន់មែន ។ លុះគ្រប់ខែថ្ងៃក៏ទ្រង់ប្រសូតបានបុត្រីមួយព្រះអង្គល្អឆើតឆាយ ។ ព្រះមហាក្សត្រទ្រង់មានព្រះអំណរឥតឧបមា ទ្រង់បានចាត់ព្រាហ្មណ៍បុរោហិតឲ្យរើសនាមថ្វាយព្រះរាជបុត្រី ។

លុះដល់ថ្ងៃជាមហោឡារិកព្រះរាជា ក៏ទ្រង់រៀបពិធីចំរើនព្រះកេសាថ្វាយព្រះរាជបុត្រី ។ ព្រះអង្គទ្រង់រើសនាងទេពធីតា ៧ អង្គដែលនៅក្មេងស្រស់ប្រិមប្រិយដែលជាទីគោរព ចូលថ្វាយពរជ័យដល់បុត្រី ។ ព្រះរាជាបានរៀបភាជន៍មាស ៣ ប្រកបដោយពានកែវចង្កឹមមាស ស្លាបព្រា

សមមាស កាំបិតមាសចង្កឹះពេជ្រ ភ្ជិចញ្ញាចពោរពាសមានម្ហូបឈ្ងុយឈ្ងប់ ដប់លៀងទេពធីតាទាំង ៧ អង្គ ។

នៅពេលដែលនាងទេពធីតាទាំងអស់ កំពុងរៀបសោយ គ្រប់ៗអង្គ ស្រាប់តែមានយាយទេពញ៉េរញ៉ាក់មួយអង្គ សក់សសំពោងដើរទទ្រេតចូល មក ។ ព្រះរាជាពុំបានអញ្ជើញសោះ ក៏ទ្រង់ស្ទុះទៅរៀបតុដ៏សមគួរ មួយទៀត ទទួលយាយទេពនោះ ។ ប៉ុន្តែការជន៍នេះពុំមានរៀបរបស់មាន តម្លៃដូចការជន៍ទាំង ៧ នោះឡើយ ។ លុះឃើញដូច្នោះយាយទេពកើត មានសេចក្តីប្រណាំងចង់ឈ្នានីសដល់ព្រះរាជបុត្រី ។ នាងទេពធីតាមួយ អង្គក្មេង ដែលអង្គុយជិតនោះបានឈ្វេងយល់ ដោយចន្ទាទិព្វឃើញសេចក្តី ផ្តន្ទានោះក្លាម ទើបរិះគិតដោយគម្រិះប្រាជ្ញាថា នឹងជួយសង្គ្រោះដល់រាជ- បុត្រីឲ្យបានដូចបំណង ។ នាងទេពធីតានេះក៏គេចខ្លួនចេញទៅឈរ រង់ចាំនៅក្រោយវាំងនន ដោយពុំបានឲ្យអ្នកផងដឹងកិច្ចសោះ ។

ពិធីដប់លៀងក៏ចប់ ទើបព្រះរាជាទ្រង់អញ្ជើញទេពធីតាទាំងនោះ ឲ្យចូលមកប្រសិទ្ធិពរថ្វាយព្រះរាជបុត្រី ។ នាងទេពធីតាទី ១ ទ្រង់ថ្វាយ ពរឲ្យព្រះរាជបុត្រីមានព្រះនាមល្បីល្បាញខ្ចរខ្ចាយនឹងល្អលើសលុបស្រីផង ទាំងពួងក្នុងមហាទ្វីប , ទេពធីតាទី ២ ថ្វាយពរឲ្យមានប្រាជ្ញាឆេតលើស លុបរាជបណ្ឌិតទាំងឡាយ , ទេពធីតាទី ៣ ថ្វាយពរឲ្យចេះភ្លេងពិណ

ពាទ្យឯកលើសលុបអ្នកភ្លេងទាំងឡាយ, ទេពធីតាទី ៤ ឲ្យមានហឫទ័យទិព្វ, ទេពធីតាទី៥ ឲ្យមានចម្រៀងឯកលើសអ្នកចម្រៀងទាំងអស់, ទេពធីតាទី ៦ ឲ្យចេះល្បាំះធើតក្នុងលោក ។ តមក ដល់វេណយាយទេពដោយគំនុំនឹងព្យាបាទ យាយទេពនេះក៏ថ្វាយពរឲ្យព្រះរាជកុមាររងគ្រោះមុតដៃនឹងរហាត់ហើយឲ្យទិវង្គត ក្នុងពេលនោះ ។

គ្រាន់តែឮប៉ុណ្ណោះ ព្រះរាជវង្សានុវង្សដែលនៅជួបជុំទាំងអស់ ក៏ទ្រង់ខ្សឹកខ្សួលអស់សង្ឃឹម ។ មួយរំពេច នាងទេពធីតាទី ៧ ក៏ស្ទុះក្រោកចេញពីក្រោយរាំងននមក ហើយក៏បន្លឺវាចាទូលព្រះរាជានិងព្រះរាជវង្សាថា “ សូមមហារាជកុំបារម្ភ ខ្ញុំម្ចាស់នេះដែលត្រូវបង្ហើយពរ ចំពោះព្រះរាជបុត្រី ប៉ុន្តែ ពរចង្រៃដែលយាយទេពថ្វាយនោះនឹងមានប្រាកដ តែខ្ញុំម្ចាស់សូមថ្វាយពរឲ្យព្រះរាជបុត្រីមិនអស់ជន្មាយុ ក្នុងគ្រោះថ្នាក់នោះឡើយ គ្រាន់តែផ្ទុំខ្ទនលក់នៅក្នុងដំណេកដ៏យឺនយូររាប់មួយសតវត្សប៉ុណ្ណោះ ទើបមានព្រះរាជបុត្រព្រះចៅឯនគរនាយនោះ មកដាស់ព្រះនាងឲ្យក្រោកឡើងជាគូវាសនា ” ។ ព្រះរាជាទ្រង់ស្រាន្តទុក្ខមួយអន្លើទៅ ។

លំដាប់នោះ ព្រះមហាក្សត្រត្រាស់បញ្ជាស្រីស្នំក្រមការអ្នកម្នាងនិងមនុស្ស ក្នុងដំណាក់ទាំងអស់ឲ្យលែងប្រើរហាត់ ។ បើអ្នកណាល្មើសនឹងត្រូវទទួលទោសដល់ជីវិត ។

ព្រះរាជបុត្រីក៏ទ្រង់បានជន្មាយុ ១៦ ឆ្នាំគត់ ។ ថ្ងៃមួយ ព្រះរាជាព្រមទាំងអគ្គមហេសីយាងទៅប្រថាប់នៅដំណាក់មួយ ។ ព្រះរាជបុត្រីក៏បានលបចេញទៅកំសាន្តក្នុងដំណាក់ឯទៀតៗ ។ ព្រះនាងឡើងចុះពីបន្ទប់មួយទៅបន្ទប់មួយ ដល់ដំណាក់មួយនោះ ព្រះនាងក៏យាងចូលទៅក្នុងបន្ទប់មួយតូច ស្រាប់តែព្រះនាងបានជួបនឹងយាយចាស់ម្នាក់ កំពុងអង្គុយរវៃអម្បោះនឹងរហាត់ៗ យាយនេះពុំបានដឹងឮនូវព្រះរាជតម្រាស់នោះឡើយ ។ ព្រះនាងសួរទៅយាយចាស់ថា ធ្វើអ្វីយាយ? ។ - ចា៎ះខ្ញុំម្ចាស់រវៃអម្បោះ ។ -អើ៎ ហ្ន៎ ល្អមើលណាស់! យាយ ឲ្យខ្ញុំសុំរវៃលេងបន្តិចផងបានឬទេ? ។ ដោយពុំបានដឹងអ្វីសោះ យាយចាស់ក៏ទទួលព្រមឲ្យព្រះនាងចូលមករវៃលេង ។ មួយរំពេច ស្រាប់តែព្រះនាងភ្លាត់ព្រះហស្តមុតនឹងដែកស្រួចដួលបាត់ស្មារតី ។ យាយចាស់ភ័យណាស់ស្រែកហៅគេឯងនោះឡោមក ។ ព្រះរាជដំណាក់ទាំងមូលញាប់ញ័រយ៉ាងក្រៃលែង ក្នុងខណៈនោះ ។ គេក៏បាននាំគ្នាយកទឹកប្រស់ព្រំលាងព្រះភក្ត្រថ្វាយព្រះនាង ។ ប៉ុន្តែ ឥតអំពើសោះ ទំនាយទៅទុកមកស្រេចថា ព្រះនាងនឹងត្រូវផ្ទុំមួយសតវត្ស ។ ដោយទ្រង់ទឹកឃើញនូវពរចង្រៃរបស់យាយទេពនិងពរពិសេសរបស់នាងទេពធីតាសប្បុរស ។

☛ ( មានត )

## កំណាត់នៃប្រវត្តិការណ៍

# ទេសភាពរវាងប្រទេសនេប៉ាល់នឹងរដ្ឋបិង្គល (ប្រទេសឥណ្ឌា) ពីព្រៃលុម្ពិនីទៅទីក្រុងកុសិនារា ។

( តចប់ )

លោក ភ៉យ-ប៊ុក រៀបរៀង

តាមសេចក្ដីឲ្យការពួកប្រជាពុទ្ធម្នាក់នៅទីនោះថា "ព្រះមហាពោធិវិហារនេះ គឺព្រាហ្មណ៍ម្នាក់ នាម អមរៈ បានសាងពី គ.ស. ៩៤៧.- ព.ស.១៥០០ ។ ក្រោយមក, ពួកពុទ្ធសាសនិកជន ភូមា បានមកជួសជុល ព្រះវិហារនេះប្រហែលជា ព.ស. ១២០៦ ឬ ១៣០៩ ត្រូវជា គ.ស. ៦៦៣ ឬ ៧៦៦, លំដាប់តមក, រដ្ឋាភិបាលឥណ្ឌា បានមកជួសជុលជាថ្មីឡើងទៀត ពី គ.ស. ១៨៨៤, ព.ស. ២៤២៧, អស់ប្រាក់- ២០០.០០០ រូពី ។

ថា : "ព្រះបាទអសោកទ្រង់បានសាងព្រះមហាពោធិវិហារនេះពីថ្មព្រមទាំងបាយអ, មានកំពស់ ៥០ ម៉ែត្រ តែព្រះវិហារនោះបាក់បែកខ្ទេចខ្ទីអស់ ដូចនៅក្រោម កម្រាលឥដ្ឋគេបានពិនិត្យទៅឃើញនូវក្ដែ

ណែលចាស់នៃព្រះមហាពោធិវិហារនេះ ។

នៅខាងជើងមហាពោធិវិហារគេបានឃើញ យ៉មួយធ្វើពីឥដ្ឋខ្ពស់ពីដីមួយម៉ែត្រ, បណ្តោយចំនួន ១៩ ម៉ែត្រ ដែលគេហៅថា រតនៈចង្រ្កមត្រង់កន្លែងស្នាមព្រះបាទ មានក្បាច់សិល្បៈធ្វើពីថ្មឆ្លាក់មានរូបបុប្ផាកល្ប-ព្រឹក្ស រីកក្រោមព្រះបាទ ។ នៅទីនេះ គេតម្កល់ព្រះស្វេតច្ឆត្រដាំពេជ្រក្តិថា ព្រមទាំងសាងកម្រាលថ្មបាយក្រៀមក្រហម ដែលគេសន្មតហៅថា " កណ្តាលលោកសន្និវាស" ។

នៅជុំវិញព្រះវិហារមានស្តូបជាច្រើនដែលឆ្លាក់ដោយក្បាច់របនាដ៏ប្រសើរមានរបាំងថ្មព័ទ្ធជុំវិញ មានក្បាច់ចម្លាក់គួរឲ្យស្ញប់ស្ញែង ។

## ៣)- សារនាថ, កន្លែងដែលព្រះអង្គសំដែងធម្មចក្កប្ប-វត្តនសូត្រ

ទីក្រុងសារណាតជាទីដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងធម្មចក្កប្ប-វត្តនសូត្រប្រោសបញ្ចវគ្គិយភិក្ខុ ។

យើងបានឃើញព្រះស្តូបមួយនាមថា "ចៅកណ្ឌី" ស្ថិតនៅតាមផ្លូវពីទីក្រុងពារាណសីទៅទីក្រុងសារណាត, ជាទីដែលព្រះអនាវរណញាណទ្រង់បានជួបនឹងបញ្ចវគ្គិយភិក្ខុជាលើកដំបូង ។

ក្រៅពីនេះ មានព្រះស្តូបនាម " ធម្មមេឃ " ដែលមានព្រះស្តូប

តូបមួយឋិតនៅក្នុងវៀង ខាងត្បូងមានរបាំងធ្វើពីថ្មឆ្លាក់ក្បាច់សិល្បៈមានលំអស្អាតគួរឲ្យទស្សនាពន់ពេក ៗ ខាងលិចព្រះស្តូបធម្មមេឃ , យើងបានឃើញសសរមួយធ្វើពីថ្មបាយក្រៀមមានសភាពបាក់បែកនៅសល់តែមួយកំណាត់ ៗ គឺនៅត្រង់សសរនេះឯង ជាកន្លែងដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រប្រោសបញ្ចវគ្គិយភិក្ខុ, ក្បាលសសរមានរូបសិង្ហ គេបានយកទៅតម្កល់ទុកនៅពិពិធភណ្ឌស្ថាននៃទីក្រុងសារណាត ៗ ព្រះស្តូបមធ្មមេឃ នឹងសសរនេះគឺព្រះបាទអសោកសាងទុកជាកេរ្តិ៍តំណែល ៗ

ក្រៅពីនេះ មានវិមានឯទៀតមានសភាពបាក់បែកខ្ទេចខ្ទីអស់.គេឃើញតែថាកែនាមទុកគឺ ព្រះស្តូបធម្មរាជិកៈ ១ ធម្មចក្រជិនវិហារ ១ ហិម-ចក្រជិនៈវិហារ ១ , វិមានមាំងស្រិន ១ ព្រះវិហារជេន ១ ៗ

មានកន្លែងមួយទៀតគឺមូលគន្ធកុដីមហាវិហារទើបនឹងសាងថ្មី ប្រកបដោយអច្ឆរិយភាពមានកម្រាលថ្មកែវនីងសេនមួយឋិតនៅជិតក្លោងទ្វារចូល មានក្បាច់សិល្បៈរបៀបតណ្ឌៀសម័យ, នៅលើជញ្ជាំងមហាវិហារនេះមានគំនូរវិចិត្រណាបពណ៌ដែលចិត្រករ ជប៉ុនម្នាក់បានគូរអំពីរឿងពុទ្ធប្រវត្តិមានលំអគួរឲ្យទស្សនាពន់ពេក ៗ នៅកណ្តាលមហាវិហារមានទីតម្កល់ព្រះបរមសារីរិកធាតុព្រះដ៏មានព្រះភាគ ដែលយើងបានចូលទៅគោរពនម-ស្ការ ៗ មហាវិហារនេះមានបណ្ណាល័យមួយដែលពួកទេសចរនឹងពលរដ្ឋ

ចូលទៅកាន់សៀវភៅ ទស្សនាវដ្ដី សារពត៌មានបានដោយសេរី ។

មូលគន្ធកុដីមហាវិហារនេះគឺ មហាពោធិសមាគមបានសាង ។ ឯមូលគន្ធកុដីមហាវិហារដែលសាងពីកាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ធរមាន ៗ

## ៤ ក្រុងកុសិនារា ឬ កសិនគរ

ទីក្រុងនេះ ជាទីដែលព្រះសម្ពុទ្ធបរមគ្រូទ្រង់ចូលកាន់បរិនិព្វានឋិតនៅចម្ងាយ ៩ គីឡូម៉ែត្រពីទីក្រុងគោរក្ខបុរៈ ក្នុងរដ្ឋឧត្តរប្រទេស ។ នៅទីនោះឯងដែលព្រះអនាវរណញាណ, ទ្រង់មានព្រះជន្មាយុ ៨០ ព្រះវស្សា បានលះបង់អាយុសង្ខារក្នុងចន្លោះដើមសាលាព្រឹក្សទាំងគូ ។ នៅទីនេះមានវិមាននិងព្រះស្តូបដូចព្រះស្តូប មហាបរិនិព្វាននិងព្រះវិហារដែលមានព្រះពុទ្ធរូបធំមួយព្រះអង្គទ្រង់និទ្រាបរិនិព្វាន មានព្រះលោហិតហូរចេញពីព្រះឧស្ណ ។ នៅជិតនោះមានទីកន្លែងមួយទៀតដែលគេហៅថា អង្គចេតិយ (ពួកអ្នកស្រុកហៅថា "រាមាភា") ជាទីដែលគេបូជាព្រះបរមសារីរិកធាតុព្រះសម្ពុទ្ធបរមគ្រូ ។ លុះបូជារួចហើយ, ព្រះបរមសារីរិកធាតុព្រះអង្គបានបែងចែកចំពោះព្រះមហាក្សត្រនៃរដ្ឋទាំងឡាយ ។

បូជនីយដ្ឋានទាំងបួនកន្លែងជាទីដែលពួកពុទ្ធសាសនិកជនគួរអញ្ជើញទៅទស្សនា ព្រោះជាស្ថានបញ្ជាក់នូវពុទ្ធប្រវត្តិឲ្យឃើញជាក់ច្បាស់ ដោយ

ដោយមិនសង្ស័យ ហើយនាំឲ្យចិត្តជ្រះថ្លាជាអនេកប្បការចំពោះព្រះបរមសម្ពុទ្ធ; ម្យ៉ាងទៀត ការធ្វើដំណើរទៅកាន់ទីនោះអាចមានសតិសម្បជញ្ញៈនឹករលឹកដល់អង្គព្រះសព្វញ្ញុតញ្ញាណដែលជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ, ទ្រង់ស្ថាបនានូវសាសនាមួយដែលធ្វើឲ្យប្រជាជនរាប់លាននាក់ជឿជាក់ហើយប្រតិបត្តិតាមដើម្បីសេចក្ដីសុខ ចំពោះកាមភព, រូបភព អរូបភពនិងសេចក្ដីប្រាសចាកអាសវៈ កិលេស, ផុតពីកណ្ដាប់ដៃជាតិ, ជរា, ព្យាធិ, មរណៈ គឺ ព្រះនិព្វាននោះឯង ។ មិនតែប៉ុណ្ណោះស្ថានទាំងនេះអាចញ៉ាំងចិត្តឲ្យកើតធម្មសង្វេគ ចំពោះសត្វនិងសង្ខារ ដែលវិលវល់ក្នុងក្នុងវាលវដ្ដសង្សារជាអនេកប្បការធ្វើកុសលឲ្យកើតមានក្នុងសន្ដានចិត្តឡើងមានបីតិបាមោជ្ជជាដើម ធ្វើចិត្តឲ្យឡើងកាន់វិបស្សនាញាណ ឆ្ពោះទៅកាន់អមតបុរី មគ្គផលជាអវសាន, បានជាទីស្ថានទាំង ៤ កន្លែងនេះ ឲ្យឈ្មោះជាសំវេជនិយដ្ឋាន ។

# ព្រះមហា ប៉ាង-ខាត់ រៀបរៀង

-*ជ* គុ. ដែលកើតពីរាងកាយ ឬ លើរាងកាយ; បុំ, បុត, ស្វាប ( រោម , រោម , សក់); កាមទេព; *អង្គជា* ស្រ្តី. ធីតា; អង្គជម៌ នបុំ. ឈាម។-*ជនុស* បុំ.បុត។-*ជាត* បុំ. "ដែលកើតពីអង្គ ,, កូន , ពហុ . ក្មេង ។ - *ទ* នបុំ , កង (ដែលពាក់នៅដើមដៃ) បុំ . បុត្រនៃព្រះលក្ខណ៍; ឈ្មោះស្វា ជាកូនទៃពាលីន៍; *អង្គទិន* គុ. ដែលពាក់កង ; *អង្គទីយ* គុ . ( ដែលប្រកបដោយអង្គទៈ ដែលជារបស់អង្គទៈ។ *ទ្វីប* បុំ, អង្គទ្វីប គឺ ទ្វីបមួយក្នុងទ្វីបតូចទាំងប្រាំមួយ ។ -*ន្យាស* បុំ. ពិធីការរៀបចំចំណែកនៃរាងកាយ ។-*បាលិ* ស្រី. កិរិយាឱប(ដប់)។-*ពន្ធន* នបុំ.កិរិយាចងនូវរាងកាយ (ការទាក់សត្វហើយដាក់ទ្រុង) ។-*ភង្គ* គុ. ដែលបំបាក់នូវអង្គ ។ -*ភូ* បុំ. កូន ។-*ភេទ* បុំ. កិរិយាបំបែកនូវអង្គ (ការកុហកខ្លួនឯង)។-*មទ៌*, -*មទ៌ក*, -*មទ៌ន* បុំ. អ្នកនិសក្អែលនៃរាងកាយ ។ -*មថ៌*, បុំ, សេចក្តីទុក្ខក្នុងអង្គកាយ ។ -*យ*ష్ట* បុំ. បង្គោលគឺរាងកាយ (កាយដូចជាបង្គោល) , កាយរាងវៀវ ។-*រក្ត* បុំ . ដើមគណ្ឋារោចន៍ ។ -*រក្សក* បុំ, អ្នករក្សាអង្គ ។-*រក្សា* ស្រី. កិរិយារក្សានូវអង្គ ។ -*រក្សណី* ឬ *រក្សិណី* ស្រី . "-គ្រឿងការពារអង្គ" អាវក្រោះ ។-*រាគ* បុំ. ថ្នាំលាបស្រឡាបខ្លួន, គ្រឿងទេសលាបលនខ្លួនឲ្យមានក្លិន ។ -*រុហ* គុ . ដែលដុះឡើងអង្គ ; នបុំ សក់, រោម , ស្បែក (នៃសត្វណា) ។-*លតិកា* ស្រី . កាយរាងរៀវដូចវល្លិ ។- *លេបា* ស្រី . ឈ្មោះក្រុង ។- *លោឌ្យ* បុំ . នីប្ល ។

( មានត )

ឲ្យឈរជាបេក្ខសមណៈ ឲ្យបោះឆ្នោតតាមសេចក្ដីណែនាំដ៏វៀងវៃ នៃសម្ដេចព្រះសង្ឃនាយក លោកកជាគណៈទាំងពីរព្រះអង្គ ក៏ព្រមឈរឈ្មោះតាមសេចក្ដីសុំរបស់ជំនុំសង្ឃ ។

ការបោះឆ្នោតក៏បានធ្វើឡើងចំពោះមុខគណៈកម្មការត្រួតត្រា តាមលក្ខណៈព្រះសង្ឃប្រកាស ដោយសេចក្ដីរៀបរយថ្លៃថ្នូរបានលទ្ធផលដូចតទៅ ៖

ព្រះសង្ឃដែលចូលបោះឆ្នោត ១៤១ អង្គ ឆ្នោតដែលបានទៅព្រះញាណកោសលញាណ ឈឹន ២៩ សន្លឹក ឆ្នោតដែលបានទៅព្រះពុទ្ធវង្ស កៅ ស៊ឹម ១១២ សន្លឹក ។

សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ដែលជាអធិបតីការបោះឆ្នោត ក៏បានប្រកាសលទ្ធផលខាងលើនេះចំពោះជំនុំសង្ឃ ។

ព្រះពុទ្ធវង្សកៅ ស៊ឹម ដែលបានឆ្នោតច្រើនជាងគេ ត្រូវទទួលតែងតាំងជាចៅអធិការ ។

ក្រោយដែលបានឲ្យដំបូន្មានដ៏ឧឡារិកចំពោះរូបចៅអធិការថ្មី និងព្រះសង្ឃក្នុងវត្តទាំងអស់ សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកក៏បានបិទពេលប្រជុំ នាវេលាម៉ោង ១៧ កន្លះ ។

យើងមានសេចក្ដីសោមនស្ស គួរសរសើរដ៏ក្រៃលែង ចំពោះចរិយាសម្បត្តិនៃព្រះសង្ឃវត្តលង្កាទាំងមូល ដែលបានបំពេញករណីយកិច្ចរើសរូបលោកចៅអធិការដោយសេចក្ដីថ្លៃថ្នូររៀបរយ សមទៅតាមព្រះពុទ្ធឱវាទ គួរទុកជាគំរូដល់គណៈសង្ឃក្នុងព្រះរាជអាណាចក្រទៅអនាគត ។